# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ពាហិរនិទាន វេរញ្ជកណ្ឌ

## ភាគ ១

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ពាហិរនិទាន វេរញ្ជកណ្ឌ

## ភាគ ១

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## វេរញ្ជកណ្ឌ

## បឋមភាគ ចប់

ឈ្មោះសៀវភៅ **សមន្តបាសាទិកា ពាហិរនិទាន-វេរញ្ជកណ្ឌ**

**ភាគ ១**

ប្រែដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ **ភិក្ខុ-សាមណេរ វត្តនិគ្រោធវ័ន "គល់ទទឹង"**

| | |
|---|---|
| ភិក្ខុ គូ សុភាព | ភិក្ខុ តុន ប៊ុនសាយ |
| ភិក្ខុ ភួង សុវណ្ណ | សាមណេរ សឿន សាន |
| ភិក្ខុ ឈឹម ហ៊ាន | សាមណេរ នៅ ហៃឡុន |

កាលបរិច្ឆេទ ព.ស. ២៥៤៩ ដល់ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306006



ភិក្ខុ អគ្គធីរោ គង់_សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៥ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។ ញោមប្រុសឈ្មោះ គង់-តិក(ស្លាប់) ញោមស្រីឈ្មោះ ហុក-តាង កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំថោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡូយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំពង់ចាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹ ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ)" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហា

មោគ្គល្លានទូលសូមសម្ដែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារស ដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

១ ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះ

សាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

ព្រះសារីបុត្តទូលសូមឱ្យព្រះអង្គបញ្ញត្តសិក្ខាបទ គ

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពាររាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្ដីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុង

សាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររាំងនូវធម៌ទាំងឡាយ

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ(ឥឡូវ)ភិក្ខុសង្ឃនៅមិនទាន់មានពុត(ហ៊ានលបលួចធ្វើអាក្រក់)នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង ស្អុទ្ធសឹងតែផូរផង់ផ្លង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្តែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឲ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឲ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះ

ចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ប ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកប្ញាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ គ្របសង្កត់ពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះ មានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញ៉ាំញុីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (សាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្ដាប់នូវសំឡេងព្រាហ្មណ៍សាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រូបទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាននឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នក

ណាហ្ន៎ស្រែកជាសំឡេងដូចលា” ។ ឃោសៈព្រាហ្មណ៍នោះសួរថា “នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?” ព្រះថេរៈតបថា “យើង



ដឹង” ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បានលំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួនឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវនេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុងការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា “នែព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹងសាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?” ព្រាហ្មណ៍តបថា “ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ” ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមក:[១]នេះថា “យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ, :

ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

---
១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។



ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?" ព្រះថេរៈតប ថា "ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?" ព្រះថេរៈ តបថា "ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែ អ្នកបួសជាបព្វជិតដូចយើង" ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយ ជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍ បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹង អត្ថធម៌របស់ព្រះត្រៃបិដកថា "នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរ ជាផលទ្ធិចាស់របស់ខ្លួន)" (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្តរបស់ព្រះអរហន្ត ខណៈចិត្តរបស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។



ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្តើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុក និង

ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរ ត្រួតមើលកថាមគ្គ (សម្ដែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ



បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង” ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្ដាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

## តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្ដាប់(ជ្រាបសេចក្ដី) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយ

ជឿទុកចិត្តថា "នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត" ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា "សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា" ។ ដើម្បីសាកល្បង សមត្ថភាពរបស់



លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្តែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្តាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្តាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈ

និមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស ( ប្រទេសលង្កា ) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ ( ឱ្យសង្ឃស្តាប់ ) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្វះថា ព្រះសង្ឃ ។



បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសភ្លាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា “នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ”[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំ រហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

---

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។



ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈ ទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា ( គឺភាសាដើម ) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ (អាចារ្យធំ) ជាដើម កាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តប្បាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ



ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធៈ ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ធឃោសៈ ធ្វើអដ្ឋកថាសីហឡៈទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធៈ ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួង

យ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរៈ ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយៈកាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ធឃោសៈ ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។



ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេងៗហើយ ស្ដេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្ដីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

**យំ សិទ្ធំ ឥមិនា បុញ្ញ យំ ចញ្ញំ បសុតំ មយា**

ឯតេន បុញ្ញកម្មេន    ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ    សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ    បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ    មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ    សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស    សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ    សោភេយ្យំ ជិនសាសនន្តិ ។

## ត    *ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ*

*បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នក*

ប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ ( អរហត្តផល ) ញុំាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្តីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្តីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្តី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្លាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ផ្ទើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| វិន. បារា. | វិន័យបិដក | ខុទ្ទកនិកាយ | បារាជិក | ភាគ ១ |
| វិន. សង្ឃា. | វិន័យបិដក | ខុទ្ទកនិកាយ | សង្ឃាទិសេស | ភាគ ២ |
| វិន. និស្ស. | វិន័យបិដក | ខុទ្ទកនិកាយ | និស្សគ្គិយ | ភាគ ៣ |
| វិន. បាចិ. | វិន័យបិដក | ខុទ្ទកនិកាយ | បាចិត្តិយ | ភាគ ៤ |
| វិន. ភិក្ខុនី. | វិន័យបិដក | ខុទ្ទកនិកាយ | ភិក្ខុនីវិភង្គ | ភាគ ៥ |
| វិន. មហា. | វិន័យបិដក | ខុទ្ទកនិកាយ | មហាវគ្គ | ភាគ ៦-៨ |
| វិន. ចុល្ល. | វិន័យបិដក | ខុទ្ទកនិកាយ | ចុល្លវគ្គ | ភាគ ៩-១១ |
| វិន. បរិ. | វិន័យបិដក | ខុទ្ទកនិកាយ | បរិវារៈ | ភាគ ១២-១៣ |
| ទីឃ. សីល. | សុត្តន្តបិដក | ទីឃនិកាយ | សីលក្ខន្ធវគ្គ | ភាគ ១៤-១៥ |
| ទីឃ. មហា. | សុត្តន្តបិដក | ទីឃនិកាយ | មហាវគ្គ | ភាគ ១៦-១៧ |
| ទីឃ. បាដិ. | សុត្តន្តបិដក | ទីឃនិកាយ | បាដិកវគ្គ | ភាគ ១៨-១៩ |
| មជ្ឈិ. មូល. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មូលបណ្ណាសក | ភាគ ២០-២២ |
| មជ្ឈិ. មជ្ឈិ. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក | ភាគ ២៣-២៥ |
| មជ្ឈិ. ឧប. | សុត្តន្តបិដក | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក | ភាគ ២៦-២៨ |
| សំយុ. សគា. | សុត្តន្តបិដក | សំយុត្តនិកាយ | សគាថវគ្គ | ភាគ ២៩-៣០ |
| សំយុ. និទា. | សុត្តន្តបិដក | សំយុត្តនិកាយ | និទានវគ្គ | ភាគ ៣១-៣២ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុកនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អប្បទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា |
|---|---|
| សមន្ត. ពាហិ. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ ពាហិរនិទាន |
| សមន្ត. វេរ. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ វេរញ្ជកណ្ឌ |
| សមន្ត. បារា. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ បារាជិកកណ្ឌ |
| សមន្ត. សង្ឃា. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ សង្ឃាទិសេស |
| សមន្ត. និស្ស. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ និស្សគ្គិយ |
| សមន្ត. បាចិ. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ បាចិត្តិយ |
| សមន្ត. មហា. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ មហាវគ្គ |
| សមន្ត. ចុល្ល. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ ចុល្លវគ្គ |
| សមន្ត. បរិ. | សមន្តប្បាសាទិកា អដ្ឋកថានៃវិនយ បរិវារៈ |
| សុមង្គ. សីល. | សុមង្គលវិលាសិនី អដ្ឋកថានៃទីឃនិកាយ សីលក្ខន្ធវគ្គ |
| សុមង្គ. មហា. | សុមង្គលវិលាសិនី អដ្ឋកថានៃទីឃនិកាយ មហាវគ្គ |
| សុមង្គ. បាដិ. | សុមង្គលវិលាសិនី អដ្ឋកថានៃទីឃនិកាយ បាដិកវគ្គ |
| បបញ្ច. មូល. | បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិមនិកាយ មូលបណ្ណាសក |
| បបញ្ច. មជ្ឈិ. | បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក |
| បបញ្ច. ឧប. | បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិមនិកាយ ឧបរិបណ្ណាសក |
| សារត្ថ. សគា. | សារត្ថប្បកាសិនី អដ្ឋកថានៃសំយុត្តនិកាយ សគាថវគ្គ |
| សារត្ថ. និទា. | សារត្ថប្បកាសិនី អដ្ឋកថានៃសំយុត្តនិកាយ និទានវគ្គ |
| សារត្ថ. ខន្ធ. | សារត្ថប្បកាសិនី អដ្ឋកថានៃសំយុត្តនិកាយ ខន្ធវារវគ្គ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| *សារត្ថ. សឡា.* | *សារត្ថប្បកាសិនី* | *អដ្ឋកថានៃសំយុត្តនិកាយ* | *សឡាយតនវគ្គ* |
| *សារត្ថ. មហា.* | *សារត្ថប្បកាសិនី* | *អដ្ឋកថានៃសំយុត្តនិកាយ* | *មហាវារវគ្គ* |
| *មនោរ. ឯក.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ឯកនិបាត* |
| *មនោរ. ទុក.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ទុកនិបាត* |
| *មនោរ. តិក.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *តិកនិបាត* |
| *មនោរ. ចតុ.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ចតុកនិបាត* |
| *មនោរ. បញ្ច.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *បញ្ចកនិបាត* |
| *មនោរ. ឆក្ក.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ឆក្កនិបាត* |
| *មនោរ. សត្ត.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *សត្តកនិបាត* |
| *មនោរ. អដ្ឋ.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *អដ្ឋកនិបាត* |
| *មនោរ. នវ.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *នវកនិបាត* |
| *មនោរ. ទស.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ទសកនិបាត* |
| *មនោរ. ឯកា.* | *មនោរថបូរណី* | *អដ្ឋកថានៃអង្គុត្តរនិកាយ* | *ឯកាទសកនិបាត* |
| *បរត្ថ. បាឋ.* | *បរមត្ថជោតិកាយ* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *ខុទ្ទកបាឋ* |
| *អដ្ឋ. ធម្ម.* | *ធម្មបទដ្ឋកថា* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *ធម្មបទគាថា* |
| *បរត្ថ. ឧទា.* | *បរមត្ថទីបនី* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *ឧទាន* |
| *បរត្ថ. ឥតិ.* | *បរមត្ថទីបនី* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *ឥតិវុត្តក* |
| *បរត្ថ. សុត្ត.* | *បរមត្ថជោតិកា* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *សុត្តនិបាត* |
| *បរត្ថ. វិមា.* | *បរមត្ថទីបនី* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *វិមានវត្ថុ* |
| *បរត្ថ. បេត.* | *បរមត្ថទីបនី* | *អដ្ឋកថានៃខុទ្ទកនិកាយ* | *បេតវត្ថុ* |

| **អក្សរសង្ខេប** | **អក្សរពេញនៃអដ្ឋកថា** | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ចប. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្ដាលជាលេខឃ្លាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្លាបទី ៤៧៦ ទំព័រទី ៤៧៨ ។

# បញ្ជីមាតិកា


| មាតិកា | ទំព័រ |
|---|---|
| ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ … … … … … … | ក |
| ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ … … … … … … … … | ង |
| ឧប្បត្តិកថា … … … … … … … … … … … … … | ថ |
| អក្សរសង្ខេប និងអក្សរពេញ … … … … … … … … | ជ |
| បញ្ជីមាតិកា … … … … … … … … … … … … … | ម |
| អារម្ភកថា … … … … … … … … … … … … … … … | ១ |

## មាតិកាពាហិរនិទាន

| | |
|---|---|
| ប្រារព្ធមូលហេតុធ្វើបឋមសង្គាយនា … … … … … … … … | ៨ |
| ព្រះមហាកស្សបដឹកនាំធ្វើសង្គាយនា … … … … … … | ១១ |
| ព្រះមហាកស្សបជ្រើសរើសភិក្ខុ ៤៩៩ រូប … … … … | ១២ |
| ការធ្វើសង្គាយនានិងវៀរព្រះអានន្ទមិនបាន … … … … | ១២ |
| ភិក្ខុទាំងឡាយសូមឱ្យជ្រើសរើសព្រះអានន្ទ … … … … | ១៤ |
| ក្រុងរាជគ្រឹះជាកន្លែងធ្វើបឋមសង្គាយនា … … … … … | ១៥ |
| ព្រះមហាថេរៈចែកគ្នានិមន្តទៅកាន់ក្រុងរាជគ្រឹះ … … … | ១៦ |
| សំឡេងស្រែកយំក្នុងទីដែលព្រះអានន្ទទៅដល់ … … … | ១៦. |
| ព្រះអានន្ទសំអាតសេនាសនៈដែលធ្លាប់គង់ … … … … | ១៧ |
| ព្រះអានន្ទឆាន់ថ្នាំបញ្ចុះ … … … … … … … … … | ១៧ |

**មាតិកា** **ទំព័រ**

ព្រះថេរៈទាំងឡាយគិតជុសជុលវិហារ ១៨ កន្លែង ... ... ១៨
ព្រះថេរៈទៅសូមហត្ថកម្មពីព្រះបាទអជាតសត្តុ ... ... ... ២០
ព្រះរាជាទ្រង់ឧបត្ថម្ភកិច្ចសង្ឃគ្រប់យ៉ាង ... ... ... ... ... ២០
ព្រះរាជាបង្គាប់ឱ្យប្រដាប់លម្អដូចវិមានព្រហ្ម ... ... ... ... ២១
ពួកភិក្ខុដាស់តឿនព្រះអានន្ទមិនឱ្យប្រមាទ ... ... ... ... ... ២២
ព្រះអានន្ទធ្វើដំណើរទៅចូលកាន់ជំនុំសង្ឃ ... ... ... ... ២៤
ព្រះថេរៈចាប់ផ្តើមប្រឹក្សា ... ... ... ... ... ... ... ... ... ២៥
ព្រះថេរៈសន្មតខ្លួនជាអ្នកបុច្ឆាវិសជ្ជនាព្រះវិន័យ ... ... ... ២៦
បុច្ឆានិងវិសជ្ជនាព្រះវិន័យ ... ... ... ... ... ... ... ... ២៧
រៀបរៀងព្រះវិន័យរបស់ភិក្ខុទុកជាពួក ៗ ... ... ... ... ... ២៩
រៀបរៀងវិន័យរបស់ភិក្ខុនីទុកជាពួក ៗ ... ... ... ... ... ... ២៩
ចាប់ផ្តើមសង្គាយនាព្រះសូត្រ ... ... ... ... ... ... ... ៣០
ពាក្យសូត្រសន្មតបុច្ឆាវិសជ្ជនាព្រះសូត្រ ... ... ... ... ... ៣០.
បុច្ឆានិងវិសជ្ជនាព្រះសូត្រ ... ... ... ... ... ... ... ... ៣១.
និកាយ ៥ ... ... ... ... ... ... ... ... ... ... ... ... ៣២
ព្រះពុទ្ធវចនៈមានចំនួនផ្សេង ៗ គ្នា ... ... ... ... ... ... ៣៣
ព្រះពុទ្ធវចនៈមានតែម្យ៉ាង ... ... ... ... ... ... ... ... ៣៣.
ព្រះពុទ្ធវចនៈមាន ២ យ៉ាង ... ... ... ... ... ... ... ... ៣៤

**មាតិកា** **ទំព័រ**

ព្រះពុទ្ធវចនៈមាន ៣ យ៉ាង ... ... ... ... ... ... ... ... ៣៤
បិដក ៣ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៧
អត្ថាធិប្បាយពាក្យថា វិន័យ ... ... ... ... ... ... ... ... ៣៨.
អត្ថាធិប្បាយពាក្យថា សូត្រ ... ... ... ... ... ... ... ... ៣៩.
អត្ថាធិប្បាយពាក្យថា អភិធម្ម ... ... ... ... ... ... ... ៤១
បិដកប្រៀបដូចកញ្ជើឬល្អី ... ... ... ... ... ... ... ... ៤៥
អធិប្បាយគម្ពីរភាព ៤ យ៉ាង ... ... ... ... ... ... ... ៤៩
អធិប្បាយគម្ពីរភាពន័យមួយទៀត ... ... ... ... ... ... ៥០
បរិយត្តិ ៣ យ៉ាង ... ... ... ... ... ... ... ... ... ... ៥២
ភិក្ខុដែលបដិបត្តិល្អក្នុងត្រៃបិដកបានផលល្អផ្សេងគ្នា ... ... ៥៥
អ្នកបដិបត្តិខុសក្នុងត្រៃបិដកបានផលអាក្រក់ផ្សេងគ្នា ... ... ៥៦
ព្រះពុទ្ធវចនៈមាន ៥ និកាយ ... ... ... ... ... ... ... ៥៨
ទីឃនិកាយ ៣៤ សូត្រ ... ... ... ... ... ... ... ... ... ៥៩
មជ្ឈិមនិកាយមាន ១៥២ សូត្រ ... ... ... ... ... ... ... ៦០
សំយុត្តនិកាយមាន ៧'៧៦២ សូត្រ ... ... ... ... ... ... ៦០
អង្គុត្តរនិកាយមាន ៩'៥៥៧ សូត្រ ... ... ... ... ... ... ៦០
ខុទ្ទកនិកាយមាន ១៥ ប្រភេទ ... ... ... ... ... ... ... ៦១
ព្រះពុទ្ធវចនៈមាន ៩ យ៉ាង ... ... ... ... ... ... ... ... ៦១

មាតិកា ទំព័រ


អធិប្បាយព្រះពុទ្ធវចនៈមានអង្គ ៩ ... ... ... ... ៦២
ព្រះពុទ្ធវចនៈមាន ៨៤,០០០ ព្រះធម្មក្ខន្ធ ... ... ... ... ៦៤
វិធីគណនារាប់ព្រះធម្មក្ខន្ធចំពោះខន្ធមួយ ៗ ... ... ... ... ៦៤
បឋមសង្គាយនាចាត់ព្រះពុទ្ធវចនៈទុកជាពួក ៗ ... ... ... ៦៥
ព្រះពុទ្ធសាសនាអាចតាំងនៅបាន ៥,០០០ ឆ្នាំ ... ... ... ៦៦
អធិប្បាយសេចក្ដីចាប់ផ្ដើមនៃនិទានវិន័យ ... ... ... ... ... ៦៧
ព្រះមហាថេរៈទាំងឡាយ នាំព្រះវិន័យបិដកបន្តមក ... ... ៦៩
ព្រះឧបាលីថេរៈរៀនព្រះវិន័យបិដកអំពីពុទ្ធ ... ... ... ... ៧០
ព្រះទាសកត្ថេរជាសទ្ធិវិហារិករបស់ព្រះឧបាលីថេរៈ ... ... ៧០
ព្រះសោណកត្ថេរជាសទ្ធិវិហារិករបស់ព្រះទាសកត្ថេរ ... ... ៧១
ព្រះសិគ្គវត្ថេរជាសទ្ធិវិហារិករបស់ព្រះសោណកត្ថេរ ... ... ៧១

ផ្ដើមធ្វើទុតិយសង្គាយនា

ភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ... ... ... ... ... ... ៧៣
ព្រះយសត្ថេរដឹងភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ... ... ៧៤
ជ្រើសរើសព្រះថេរៈ ៧០០ រូប ធ្វើទុតិយសង្គាយនា ... ៧៦

រឿងរ៉ាវមុនតតិយសង្គាយនា

តិស្សមហាព្រហ្មនឹងដោះស្រាយវិបត្តិនៃព្រះសាសនា ... ... ៧៨
ពួកព្រះថេរៈទៅអញ្ជើញតិស្សមហាព្រហ្ម ... ... ... ... ... ៧៩

## មាតិកា ទំព័រ


តិស្សមហាព្រហ្មទទួលប្ដេជ្ញាមកកើតឋានមនុស្ស ... ... ៨០

ពួកព្រះថេរៈដាក់ទណ្ឌកម្មដល់ព្រះសិគ្គវៈនិងព្រះចណ្ឌវជ្ជី ... ៨១

ចាប់ផ្ដើមរឿងតតិយសង្គាយនា

តិស្សមហាព្រហ្មកើតក្នុងមនុស្សលោក ... ... ... ... ... ៨២

ព្រាហ្មណ៍បិតារបស់តិស្សមហាព្រហ្មជួបព្រះសិគ្គវត្ថេរ ... ៨៣

មោគ្គលីព្រាហ្មណ៍ចាំចាប់មុសារបស់ព្រះថេរៈ ... ... ... ... ៨៣

មោគ្គលីព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះថេរៈ ... ... ... ... ... ... ៨៤.

ព្រះសិគ្គវត្ថេរចាប់ផ្ដើមប្រាស្រ័យនឹងតិស្សមាណព ... ... ៨៥

តិស្សមាណពសួរបញ្ហានឹងព្រះថេរៈ ... ... ... ... ... ... ៨៦

ព្រះសិគ្គវត្ថេរសួរបញ្ហានឹងមាណព ... ... ... ... ... ... ៨៧

តិស្សមាណពសូមអនុញ្ញាតមាតាបិតាបួស ... ... ... ... ៨៨

ព្រះថេរៈឱ្យសាមណេរទៅកាន់សំណាក់ព្រះចណ្ឌវជ្ជី ... ... ៨៩

សាមណេរតិស្សៈទៅដល់សំណាក់ព្រះចណ្ឌវជ្ជីថេរៈ ... ... ៩០

សាមណេរតិស្សៈបដិបត្តិកិច្ចវត្តតាមរបៀបព្រះវិន័យ ... ... ៩១

ព្រះចណ្ឌវជ្ជីថេរៈឱ្យសាមណេរតិស្សៈរៀនព្រះពុទ្ធវចនៈ ... ៩១

សាមណេរតិស្សៈរៀនព្រះពុទ្ធវចនៈព្រមទាំងអដ្ឋកថា ... ... ៩២

ព្រះរាជប្រវត្តិរបស់ព្រះបាទអសោកមហារាជ ... ... ... ... ៩២.

ព្រះរាជឫទ្ធិផ្សាយទៅខាងលើខាងក្រោម ១ យោជន៍ ... ... ៩៣

**មាតិកា** **ទំព័រ**

ស្តេចកាឡនាគនិម្មិតព្រះពុទ្ធរូបទ្រង់ឱ្យមើល ... ... ... ... ៩៥
ព្រះបាទអសោកទ្រង់មិនជ្រះថ្លាអ្នកបួសក្រៅសាសនា ... ... ៩៦
ប្រវត្តិនិគ្រោធសាមណេរ ... ... ... ... ... ... ... ... ... ៩៨
និគ្រោធកុមារបួសបានជាព្រះអរហន្តព្រះជន្ម ៧ ឆ្នាំ ... ... ១០០
ព្រះបាទអសោកទ្រង់ជ្រះថ្លានិគ្រោធសាមណេរ ... ... ... ១០១
ព្រះបាទអសោកបង្គាប់ឱ្យនិមន្តសាមណេរចូលមក ... ... ១០២
ព្រះបាទអសោកមហារាជត្រាស់សួរធម៌ ... ... ... ... ... ១០៣
ព្រះបាទអសោកថ្វាយនិច្ចភត្តសាមណេរជាទ្វេគុណ ... ... ១០៤
ព្រះបាទអសោកថ្វាយនិច្ចភត្តដល់ភិក្ខុ ៦ សែនរូប ... ... ១០៦
ព្រះបាទអសោកសាងវត្តនិងចេតិយ ៨៤,០០០កន្លែង ... ... ១០៦
ព្រះបាទអសោកទ្រង់ធ្វើការឆ្លងព្រះវិហារ ... ... ... ... ... ១០៨
ព្រះបាទអសោកទតឃើញជម្ពូទ្វីបទាំងអស់ ... ... ... ... ១០៩
ព្រះបាទអសោកមិនទាន់ជាទាយាទនៃព្រះសាសនា ... ... ១១០
អ្នកដែលឱ្យបុត្របួសបានជាទាយាទនៃព្រះសាសនា ... ... ១១១
ព្រះមហិន្ទត្ថេរវេលាឧបសម្បទាសម្រេចព្រះអរហត្ត ... ... ១១៤
ព្រះបាទអសោកតាំងមូលនិធិថ្វាយសង្ឃ ៥ សែន ... ... ១១៥
ពួកតិរ្ថិយបន្លំបួសក្នុងព្រះពុទ្ធសាសនា ... ... ... ... ... ១១៦
ពួកតិរ្ថិយសម្តែងលទ្ធិក្រៅពុទ្ធសាសនា ... ... ... ... ... ១១៧

មាតិកា ទំព័រ

ព្រះបាទអសោកទ្រង់ប្រើអាមាត្យឱ្យរម្ងាប់អធិករណ៍ ... ... ១១៧
ប្រវត្តិរបស់ព្រះតិស្សត្ថេរនឹងចេញបួស ... ... ... ... ... ១១៩
ព្រះតិស្សត្ថេរអង្គុយឃាំងមិនឱ្យអាមាត្យកាត់សីសៈភិក្ខុ ... ១២២
ពួកភិក្ខុថ្វាយយោបល់ចំពោះព្រះរាជាជា ២ ន័យ ... ... ១២៣
ព្រះមោគ្គលីបុត្តតិស្សត្ថេរមិនមកព្រោះអាពាធនាខុស ... ... ១២៤
ព្រះបាទអសោកទ្រង់ព្រះសុបិនឃើញដំរីសសុទ្ធ ... ... ... ១២៦
រាជបុរសប្រុងកាត់សីសៈព្រះមោគ្គលីបុត្តតិស្សត្ថេរ ... ... ១២៧
ព្រះបាទអសោកទ្រង់សង្ស័យព្រះមោគ្គលីបុត្តតិស្សត្ថេរ ... ១២៨
ព្រះមោគ្គលីបុត្តតិស្សត្ថេរអធិដ្ឋានឱ្យផែនដីញ័រ ... ... ... ១៣០
ព្រះបាទអសោកសួរនូវសេចក្ដីសង្ស័យក្នុងរឿងបាប ... ... ១៣១
ព្រះថេរៈអាងព្រះពុទ្ធវចនៈពោលអតីតនិទាន ... ... ... ... ១៣៣
ព្រះរាជាទ្រង់ជម្រះអធិករណ៍នៃព្រះពុទ្ធសាសនា ... ... ... ១៣៣
ព្រះរាជាទ្រង់ត្រាស់ឱ្យផ្សឹកពួកបន្លំជាភិក្ខុ ៦ ម៉ឺនរូប ... ... ១៣៥
ព្រះថេរៈរើសភិក្ខុមួយពាន់រូបធ្វើតតិយសង្គាយនា ... ... ១៣៧
រឿងនាំព្រះវិន័យបិដកបន្តគ្នាមក ... ... ... ... ... ... ... ... ... ១៣៨
រាយនាមព្រះថេរៈអ្នកនាំព្រះវិន័យបិដកបន្តដល់សព្វថ្ងៃ ... ១៣៨
រឿងបញ្ជូនព្រះថេរៈទៅប្រទេសផ្សេងៗ ... ... ... ... ... ១៤១

**មាតិកា** **ទំព័រ**

ព្រះមជ្ឈន្តិកត្ថេរទៅកស្មីរគន្ធាររដ្ឋ ... ... ... ... ... ១៤៣
ស្តេចនាគអារវាឡប្រែងឫទ្ធិដេញព្រះថេរៈ ... ... ... ១៤៣.
ព្រះថេរៈទូន្មានពួកនាគឱ្យបាត់ចបេសរឹងត្អឹងហើយ ... ១៤៤
ព្រះថេរៈឱ្យឱវាទពួកយក្ខនិងអារក្សទឹកជាដើម ... ... ១៤៦
ព្រះមហាទេវៈទៅមហិសក្រមណ្ឌល ... ... ... ... ១៤៧
ព្រះរក្ខិតត្ថេរទៅដែនវនវាសី ... ... ... ... ... ... ១៤៨
ព្រះយោនកធម្មរក្ខិតត្ថេរទៅអបរន្តកជនបទ.
ព្រះមហាធម្មរក្ខិតត្ថេរទៅមហារដ្ឋ ... ... ... ... ... ... ... ១៤៩
ព្រះមហាធម្មរក្ខិតត្ថេរទៅរដ្ឋយោនក ... ... ... ... ១៥០
ព្រះមជ្ឈិមត្ថេរទៅហិមវន្តប្រទេស ... ... ... ... ... ១៥០
ព្រះសោណកៈនិងព្រះឧត្តរៈទៅសុវណ្ណភូមិ ... ... ... ១៥១
ព្រះថេរៈបណ្តេញពួកអារក្សទឹកហើយការពារកោះ ... ១៥២
ព្រះមហិន្ទត្ថេរទៅកោះលង្កា ... ... ... ... ... ... ... ... ១៥៤
ព្រះមហិន្ទត្ថេរត្រាច់សួរសុខទុក្ខញាតិ ... ... ... ... ១៥៥
ប្រវត្តិសង្ខេបរបស់ព្រះមហិន្ទត្ថេរ ... ... ... ... ... ... ... ១៥៦
ព្រះឥន្ទ្រពោលរឿងពុទ្ធព្យាករណ៍ថ្វាយព្រះមហិន្ទ ... ... ... ១៥៨
ព្រះមហិន្ទត្ថេរព្រមទាំងគណៈទៅកោះលង្កា ... ... ... ... ១៥៩
រឿងចតុត្ថសង្គាយនា លំដាប់រាជវង្សក្នុងកោះលង្កានិងជម្ពូទីប ... ... ១៦០

**មាតិកា** **ទំព័រ**


ព្រះបាទទេវានម្បិយតិស្សទ្រង់ជួបព្រះមហិន្ទត្ថេរ ... ... ... ១៦៣

ឫស្សី ៣ ដើមកើតដល់ព្រះបាទទេវានម្បិយតិស្ស ... ... ១៦៤

រតនៈ ៨ ប្រភេទ កើតដល់ព្រះបាទទេវានម្បិយតិស្ស ... ១៦៦

ព្រះបាទអសោកបញ្ជូនបញ្ចរាជកកុធភ័ណ្ឌទៅថ្វាយ ... ... ១៦៦

ព្រះថេរៈសម្តែងឱ្យព្រះរាជាទតឃើញជន ៦ រូបទៀត ... ១៧០

ព្រះថេរៈសួរបញ្ហាដើម្បីដឹងព្រះបញ្ញារបស់ព្រះរាជា ... ... ១៧១

ព្រះរាជានិងរាជបរិវារតាំងនៅក្នុងត្រៃសរណគមន៍ ... ... ១៧៣

សុមនសាមណេរប្រកាសវេលាស្តាប់ធម៌ពេញកោះលង្កា ... ១៧៥

សំឡេងប្រកាសឮសុះសាយទៅដល់ព្រហ្មលោក ... ... ... ១៧៦

ព្រះបឋមចេតិយក្រុងអនុរាធបុរី ... ... ... ... ... ... ... ១៧៦

ព្រះរាជាទ្រង់ត្រាស់ឱ្យត្រៀមការទទួលព្រះថេរៈ ... ... ... ១៧៧

ព្រះថេរៈសម្តែងធម៌ប្រោសព្រះរាជានិងអ្នកកោះ ... ... ... ១៧៩

ព្រះរាជាថ្វាយឧទ្យានសាងវត្ត ... ... ... ... ... ... ... ... ១៨១

ព្រះថេរៈសម្តែងធម៌ប្រោសអ្នកកោះជាប់តគ្នាទៅ ... ... ... ១៨៣

ព្រះរាជាទ្រង់រថធ្វើដំណើរទៅតាមព្រះថេរៈ ... ... ... ... ១៨៤

អរិដ្ឋអាមាត្យសូមព្រះបរមរាជានុញ្ញាតបួស ... ... ... ... ១៨៥

ព្រះថេរៈណែនាំឱ្យរកវត្ថុដែលគួរក្រាបថ្វាយបង្គំបូជា ... ... ១៨៦

សុមនសាមណេរទទួលរាប់រងរកព្រះធាតុ ... ... ... ... ... ១៨៧

មាតិកា ទំព័រ


ព្រះថេរៈឱ្យសុមនសាមណេរទៅអារាធនាព្រះធាតុ … … ១៨៨
សុមនសាមណេរទៅនាំព្រះធាតុមកកោះលង្កា … … … ១៨៩
ព្រះថេរៈនិងព្រះរាជាព្រមទាំងអ្នកកោះទទួលព្រះធាតុ … … ១៩០
ដំរីនាំព្រះធាតុទៅកាន់ទីនិងសាងព្រះចេតិយ … … … … ១៩២
ប្រវត្តិកោះលង្កាជាប់ទាក់ទងនឹងព្រះពុទ្ធ … … … … … ១៩២
ដំរីមិនព្រមឱ្យលើកព្រះធាតុចុះអំពីពោង … … … … … ១៩៦
ព្រះធាតុសម្ដែងបាដិហារ្យដល់មហាជន … … … … … ១៩៧
ព្រះពុទ្ធធ្លាប់ស្ដេចយាងទៅកោះលង្កា … … … … … … ១៩៨
កុលបុត្រអ្នកកោះចេញបួសក្នុងព្រះសាសនា … … … … ២០០
ព្រះនាងអនុឡាទេវីទ្រង់មានព្រះបំណងនឹងបួស … … … ២០០
ព្រះរាជាបញ្ជូនទូតទៅកាន់ជម្ពូទ្វីប … … … … … … … ២០១
ទូតថ្វាយព្រះរាជសាសន៍និងថេរសាសន៍ … … … … … ២០២
ព្រះបាទអសោកបញ្ជូនដើមមហាពោធិព្រឹក្សទៅកោះលង្កាមុន.. ២០៤
មហាអធិដ្ឋាន ៥ ប្រការ របស់ព្រះមានព្រះភាគ … … … ២០៥
វិស្សុកម្មទេវបុត្របន្និខ្លួនជាជាងនិម្មិតផើងមាស … … … ២០៦.
ស្ដេចយាងទៅកាន់ដើមមហាពោធិព្រឹក្ស … … … … … ២០៧
ព្រះរាជាទ្រង់ធ្វើសច្ចាធិដ្ឋាន … … … … … … … … ២០៨
មែកមហាពោធិព្រឹក្សអណ្ដែតឡើងទៅនៅលើផ្ទៃមេឃ … ២១០

**មាតិកា** **ទំព័រ**

ដើមមហាពោធិព្រឹក្សបែកពន្លកចេញថ្មី ... ... ... ... ... ២១២
ព្រះបាទអសោកតាំងត្រកូលផ្សេង ៗ ឱ្យរក្សាមហាពោធិព្រឹក្ស ២១៣
ព្រះបាទអសោកទ្រង់បញ្ជូនមហាពោធិព្រឹក្សទៅកោះលង្កា ... ២១៤
ព្រះបាទទេវានម្បិយតិស្ស ត្រៀមទទួលមហាពោធិព្រឹក្ស ... ២១៦
ព្រះរាជាតម្កល់មហាពោធិព្រឹក្សក្នុងបូជនីយស្ថាន ៤ កន្លែង.. ២១៧.
ដើមមហាពោធិព្រឹក្សសម្តែងឥទ្ធិបាដិហារ្យ ... ... ... ... ២១៩
ពូជមហាពោធិព្រឹក្សបែកសាខា ៨-៣២ ដើម ... ... ... ២២០
នាងអនុឡាទេវីនិងអរិដ្ឋអាមាត្យបួសហើយសម្រេចព្រះអរហត្ត ២២២
សាសនាតាំងមាំព្រោះកុលបុត្រក្នុងកោះលង្កាបួសរៀន ... ២២២
ព្រះរាជាសាងមណ្ឌបដើម្បីធ្វើចតុត្ថសង្គាយនា ... ... ... ២២៦
ផ្តើមរឿងចតុត្ថសង្គាយនា ... ... ... ... ... ... ... ... ... ... ... ២២៧
ពន្យល់បទមាតិកាថា ព្រះវិន័យបិដកតាំងនៅហើយក្នុងបុគ្គលណា ២៣០
អានិសង្សនៃការរៀនព្រះវិន័យ ៥ ប្រការ ... ... ... ... ២៣១
បដិបត្តិវិន័យ នាំឱ្យបានរួចផុតពីកិលេសជាទីបំផុត ... ... ២៣២
គាថាសរុបរឿង ... ... ... ... ... ... ... ... ... ... ... ២៣៤

**មាតិកា** **ទំព័រ**

## ទេរញ្ជកណ្ឌវណ្ណនា

អធិប្បាយបទថា **តេន** ជាដើម ... ... ... ... ... ... ... ២៣៥
អធិប្បាយបទថា **សមយេន** ជាដើម ... ... ... ... ... ២៣៧.
អត្ថាធិប្បាយពាក្យថា **វេរញ្ជាយំ វិហរតិ** ... ... ... ២៤៣.
អត្ថាធិប្បាយពាក្យថា នឡេរុបុចិមន្ទមូលេ ជាដើម ... ... ២៤៤
អធិប្បាយពាក្យថា **វេរញ្ជាយំ** និង **នឡេរុបុចិមន្ទមូលេ** ... ២៤៦
អធិប្បាយពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ ... ... ... ២៤៩
អធិប្បាយពាក្យថា អស្សោសិ ខោ ជាដើម ... ... ... ... ២៥១.
អធិប្បាយរឿងដែលព្រាហ្មណ៍បានស្តាប់ ... ... ... ... ... ២៥២
អធិប្បាយពុទ្ធគុណ ... ... ... ... ... ... ... ... ... ... ... ... ... ២៥៥
ព្រះនាមថា **អរហំ** ... ... ... ... ... ... ... ... ... ... ២៥៦
សង្សារវដ្ត គឺបដិច្ចសមុប្បាទជាបច្ច័យតគ្នា ... ... ២៥៧
ធម្មដ្ឋិតិញ្ញាណ ... ... ... ... ... ... ... ... ... ... ២៦០.
សង្ខេប និង អទ្ធាក្នុងបដិច្ចសមុប្បាទ ... ... ... ... ២៦១
វដ្ដៈ និងសន្ធិ ៣ ក្នុងបដិច្ចសមុប្បាទ ... ... ... ... ២៦១
ព្រះនាមថា **សម្មាសម្ពុទ្ធោ** ... ... ... ... ... ... ... ... ២៦៤
ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ... ... ... ... ... ... ២៦៧
ទ្រង់ព្រះនាមថា **សុគតោ** ... ... ... ... ... ... ... ... ២៦៩

ទ្រង់ព្រះនាមថា លោកវិទូ ... ... ... ... ... ... ... ... ២៧២



| មាតិកា | ទំព័រ |
|---|---|

អធិប្បាយលោក ៣ ... ... ... ... ... ... ... ... ២៧៤
ព្រះមានព្រះភាគទ្រង់ដឹងច្បាស់លោកទាំង ៣ ... ... ២៧៥
ទំហំព្រះចន្ទជាដើម ... ... ... ... ... ... ... ... ២៧៩
ទ្រង់ព្រះនាមថា អនុត្តរោ ... ... ... ... ... ... ... ... ២៨០.
ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ... ... ... ... ... ... ... ២៨១.
ទ្រង់ព្រះនាមថា សត្ថា ... ... ... ... ... ... ... ... ... ២៨៣
ទ្រង់ព្រះនាមថា ទេវមនុស្សានំ ... ... ... ... ... ... ... ២៨៤
រឿងកង្កែបស្តាប់ធម៌របស់ព្រះពុទ្ធបានជាទេវបុត្រ ... ២៨៤
ទ្រង់ព្រះនាមថា ពុទ្ធោ ... ... ... ... ... ... ... ... ... ២៨៦
ទ្រង់ព្រះនាមថា ភគវា ... ... ... ... ... ... ... ... ... ២៨៧
នាមមាន ៤ យ៉ាង ... ... ... ... ... ... ... ... ២៨៧.
ព្រះមានព្រះភាគទ្រង់បំបាក់បង់កិលេសបាន
ទាំងសែនយ៉ាង ... ... ... ... ... ... ... ... ... ២៩១
អធិប្បាយ សទេវកំ សព្ទជាដើម ... ... ... ... ... ... ២៩៥
អធិប្បាយ សយំ សព្ទជាដើម ... ... ... ... ... ... ... ២៩៩
ព្រះធម៌ល្អខាងដើមកណ្តាលនិងទីបំផុត ... ... ... ... ... ៣០០
អធិប្បាយសព្ទថា សាត្ថំ សព្យញ្ជនំ ... ... ... ... ... ... ៣០៣
អត្ថាធិប្បាយវិសេសនសព្ទនាមថា យេន តេន ... ... ... ៣០៧.

អធិប្បាយសព្ទថា សម្មោទនីយំ និង សារាណីយំ ... ... ៣០៩

ឱ បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**


អត្ថាធិប្បាយពីរសព្ទថា ឯកមន្តំ និសីទិ ... ... ... ... ... ៣១០.
ការអន្តួយវៀរទោស ៦ យ៉ាង ... ... ... ... ... ៣១១.
អធិប្បាយសព្ទផ្សេង ៗ មាន ឯតំ សព្ទជាដើម ... ... ... ៣១២
ព្រះមានព្រះភាគទ្រង់ជំទាស់ ... ... ... ... ... ... ... ... ... ៣១៦.
វេរញ្ជព្រាហ្មណ៍ពោលបន្ទាប់ព្រះពុទ្ធ
ព្រាហ្មណ៍ពោលថា ជាមនុស្សសោះកក្រោះ ឥតរសជាតិ.. ៣១៩
បរិយាយសព្ទចុះក្នុងអត្ថ ៣ យ៉ាង ... ... ... ... ៣២០
ព្រះសម្ពុទ្ធទ្រង់លះរសក្នុងរូបជាដើមបានដាច់ហើយ ៣២២
អធិប្បាយសព្ទ អនភាវំ កតា. អនភាវំ គតា ... ... ៣២៤
វេរញ្ជព្រាហ្មណ៍ពោលថា គ្មានគ្រឿងបរិភោគ: ... ... ... ៣២៦
ព្រាហ្មណ៍ពោលថា ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ ៣២៧
វេរញ្ជព្រាហ្មណ៍ពោលថា ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល ៣២៨
វេរញ្ជព្រាហ្មណ៍ពោលថា ជាអ្នកខ្ពើមរអើមណាស់ ... ... ៣២៩
វេរញ្ជព្រាហ្មណ៍ពោលថា ជាអ្នកបំផ្លាញ ... ... ... ... ... ៣៣០.
វេរញ្ជព្រាហ្មណ៍ពោលថា ជាអ្នកដុតកំដៅ ... ... ... ... ៣៣១
វេរញ្ជព្រាហ្មណ៍ពោលថា ជាមនុស្សឥតកំណើត ... ... ... ៣៣៣.
ព្រះតថាគតជាច្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ... ... ... ៣៣៦.
កូនមាន់ញាស់ចេញមុនហៅថា កូនច្បង ... ... ... ... ... ៣៣៩

ពោធិសត្តសំដៅសេចក្តីដល់ ៤ ន័យ ... ... ... ... ... ៣៤៣.



## មាតិកាវេរញ្ជកណ្ឌ

| មាតិកា | ទំព័រ |
|---|---|
| ប្រៀបធៀបការបំពេញអនុបស្សនាដូចការភ្ញាស់ពង ... ... | ៣៤៥ |
| ព្រះមានព្រះភាគទ្រង់ប្រសើរព្រោះបំពេញព្យាយាម ... ... | ៣៤៨ |
| បឋមជ្ឈានកថា ... ... ... ... ... ... ... ... ... ... ... | ៣៥១ |
| អធិប្បាយ ៦រ អក្សរ ... ... ... ... ... ... ... ... | ៣៥៣ |
| អត្ថាធិប្បាយអង្គ ៥ នៃបឋមជ្ឈាន ... ... ... ... | ៣៦១ |
| អត្ថាធិប្បាយអង្គឈាន គឺ បីតិ និងសុខ ... ... ... | ៣៦៤ |
| ឈាន រមែងកម្ចាត់ធម៌ដែលជាសត្រូវ ... ... ... ... | ៣៦៧ |
| ឈានមាន ២ ន័យ ... ... ... ... ... ... ... ... | ៣៦៨ |
| អត្ថន័យនៃឧបសម្បជ្ជស័ត្ត ... ... ... ... ... ... | ៣៧១ |
| ទុតិយជ្ឈានកថា ... ... ... ... ... ... ... ... ... ... ... | ៣៧៣ |
| អត្ថាធិប្បាយអជ្ឈត្តស័ព្ទ ... ... ... ... ... ... ... | ៣៧៣ |
| អត្ថាធិប្បាយ សម្បសាទនស័ព្ទ ... ... ... ... ... | ៣៧៤ |
| អត្ថាធិប្បាយ ឯកោទិភាវស័ព្ទ ... ... ... ... ... ... | ៣៧៥. |
| អត្ថាធិប្បាយទុតិយជ្ឈានមិនមានវិតក្កៈនិងវិចារៈ ... | ៣៧៨. |
| បឋមជ្ឈានមានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៣ ... | ៣៨១. |
| តតិយជ្ឈានកថា ... ... ... ... ... ... ... ... ... ... ... | ៣៨២ |
| ឧបេក្ខា ១០ យ៉ាង ... ... ... ... ... ... ... ... | ៣៨៤. |
| អត្ថាធិប្បាយលក្ខណៈនៃឧបេក្ខា ... ... ... ... ... | ៣៨៥ |

អធិប្បាយលក្ខណៈនៃសតិនិងសម្បជញ្ញៈ ... ... ... ៣៨៧



មាតិកា ទំព័រ

ទុតិយជ្ឈានមានអង្គ ៤ តតិយជ្ឈានមានអង្គ៥ ... ... ៣៩២
ចតុត្ថជ្ឈានកថា ... ... ... ... ... ... ... ... ... ... ... ៣៩៣
អត្ថាធិប្បាយឧបេក្ខាក្នុងចតុត្ថជ្ឈាន ... ... ... ... ... ៣៩៩
តតិយជ្ឈានមានអង្គ ៥ ចតុត្ថជ្ឈានមានអង្គ ៣ ... ៤០៣
អត្ថាធិប្បាយឈាន ៤ របស់បុគ្គល ៥ ប្រភេទ ... ៤០៤
បុព្វេនិវាសញ្ញាណកថា ... ... ... ... ... ... ... ... ... ៤០៦
ចិត្តមិនញាប់ញ័រដោយធម៌ ៦ យ៉ាង ... ... ... ... ៤០៨
អត្ថាធិប្បាយវិគ្រោះ បុព្វេនិវាសស័ព្ទ ... ... ... ... ៤១១
អត្ថាធិប្បាយ អំពីកប្ប ... ... ... ... ... ... ... ៤១៤
ពុទ្ធខេត្ត ៣ ព្រមទាំងអត្ថាធិប្បាយ ... ... ... ... ៤១៦
ពួកតិរ្ថិយរលឹកជាតិបាន ៤០ កប្ប ... ... ... ... ៤២២
ព្រះអសីតិមហាសាវករលឹកជាតិបាន១សែនកប្ប ... ៤២២
ទិព្វចក្ខុកថា ... ... ... ... ... ... ... ... ... ... ... ... ៤២៧
អត្ថាធិប្បាយពាក្យថា ទិព្វចក្ខុជាដើម ... ... ... ... ៤២៨
ទិព្វចក្ខុរបស់ព្រះពុទ្ធប្រាសចាកឧបក្កិលេស ... ... ៤៣០
លំដាប់ការកើតឡើងនៃយថាកម្មូបគញ្ញាណ ... ... ៤៣៥
ការជេរព្រះអរិយៈហាមសួគ៌និងហាមមគ្គ ... ... ... ៤៣៧.
រឿងភិក្ខុកម្លោះតិះដៀលព្រះអរិយៈជាន់ខ្ពស់ ... ... ៤៣៨

វិធីសូមខមាដើម្បីឱ្យអត់ទោសឱ្យក្នុងការតិះដៀល ... ៤៣៩

មាតិកាវេរញ្ជកណ្ឌវណ្ណនា ឱ

## មាតិកា ទំព័រ


ការតិះដៀលព្រះអរិយៈមានទោសដូចនឹងអនន្តរិយកម្ម.. ៤៤១

អត្ថាធិប្បាយ នរក ឈ្មោះថា អបាយជាដើម ... ... ៤៤៣.

អាសវក្ខយញ្ញាណកថា ... ... ... ... ... ... ... ... ... ... ៤៤៦

ព្រះមានព្រះភាគទ្រង់កើតមុនអ្នកណាទាំងអស់ ... ... ... ... ៤៥២

វេរញ្ជព្រាហ្មណបានរលឹកដឹងខ្លួន ... ... ... ... ... ... ... ... ... ៤៥៤

អធិប្បាយអភិក្កន្តស័ព្ទចុះក្នុងអត្ថ ៤ និង ៩ យ៉ាង ... ... ៤៥៥

បាវចនៈមានសេចក្ដីល្អ ១៨ យ៉ាង ... ... ... ... ... ... ៤៥៨

ព្រាហ្មណ៍សរសើរធម៌ទេសនាដោយឧបមា ៤ យ៉ាង ... ... ៤៥៩

វេរញ្ជព្រាហ្មណ៍សម្ដែងខ្លួនដល់ព្រះរតនត្រ័យជាទីពឹង ... ... ៤៦១

អត្ថាធិប្បាយពាក្យថា ព្រះធម៌ ... ... ... ... ... ... ... ... ៤៦២

អត្ថាធិប្បាយពាក្យថា ព្រះសង្ឃ ... ... ... ... ... ... ... ៤៦៤

អធិប្បាយអគ្គៈស័ព្ទដែលចុះក្នុងអត្ថ ៤ យ៉ាង ... ... ... ... ៤៦៦

វេរញ្ជព្រាហ្មណ៍សូមដល់ព្រះត្រៃរតនអស់មួយជីវិត ... ... ៤៦៨

ព្រាហ្មណ៍ទូលសូមឱ្យព្រះពុទ្ធចាំវស្សាក្នុងស្រុកវេរញ្ជា ... ... ៤៦៩

ព្រះពុទ្ធទ្រង់ទទួលនិមន្តនៅចាំវស្សាស្រុកវេរញ្ជា ... ... ... ៤៦៩

ស្រុកវេរញ្ជាកើតទុព្ភិក្ខភ័យ ... ... ... ... ... ... ... ... ... ៤៧១

ស្រុកវេរញ្ជាមានស្លាកចែកទិញអាហារចិញ្ចឹមជីវិត ... ... ... ៤៧៤

ឈ្មួញសេះថ្វាយបាយមួយនាឡិដល់ភិក្ខុមួយរូប ... ... ... ៤៧៦

អត្ថាធិប្បាយ បុព្វណ្ហសម័យស័តុ ... ... ... ... ... ... ... ៤៨០



**មាតិកា** **ទំព័រ**

ពួកភិក្ខុបានបាយក្រៀមមួយនាឡិ ៗ នាំទៅកិនឆាន់ ... ... ៤៨១
ឈ្មួញសេះថ្វាយបាយក្រៀមចំពោះព្រះមានព្រះភាគ ... ... ៤៨២
ព្រះពុទ្ធត្រាស់ដឹង ២០ ឆ្នាំ មិនមានឧបដ្ឋាកប្រចាំ ... ... ... ៤៨៣
ព្រាហ្មណ៍និងអ្នកស្រុកមិនបានថ្វាយភត្តចំពោះព្រះពុទ្ធ ... ... ៤៨៤
មារមិនអាចធ្វើអន្តរាយដល់បច្ច័យ ៤ បាន ... ... ... ... ៤៨៦
ព្រះមានព្រះភាគត្រាស់សួរវត្ថុដែលជាប្រយោជន៍ ... ... ... ៤៨៨
ពួកភិក្ខុចាំវស្សាស្រុកវេរញ្ជាឈ្នះសេចក្តីអត់ឃ្លានបាន ... ... ៤៩១
ព្រះមហាមោគ្គល្លានទូលសូមអនុញ្ញាតត្រឡប់ផែនដី ... ... ... ... ៤៩៥
ខាងក្រោមមានស្រទាប់នៃផែនដីដែលមានរសឱជា ... ... ... ៤៩៦
ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាតឱ្យត្រឡប់ផែនដី ... ... ... ៥០០
រឿងបញ្ហាព្រះសារីបុត្រ ... ... ... ... ... ... ... ... ... ... ... ... ៥០៤
ព្រះពុទ្ធទ្រង់សម្តែងធម៌ដល់បរិស័ទច្រើនឬតិចក៏ដោយ ... ... ៥០៧.
ព្រះវិបស្សីជាដើមទ្រង់មិនបានបញ្ញត្តិសិក្ខាបទជាដើមទេ ... ៥០៩.
ពួកទេវតាប្រាប់ថ្ងៃធ្វើឧបោសថដល់ពួកភិក្ខុ ... ... ... ... ... ៥១០
ឱវាទបា្បតិមោក្ខគាថា ... ... ... ... ... ... ... ... ... ... ៥១១
ហេតុដែលព្រះពុទ្ធទ្រង់មិនធ្វើឧបោសថនិងបាតិមោក្ខ ... ... ៥១៣
ហេតុឱ្យព្រះសាសនាតាំងនៅមិនយូរនិងយូរ ... ... ... ... ៥១៤
ព្រះពុទ្ធវិបស្សីជាដើមមានអាយុកាលផ្សេងគ្នា ... ... ... ... ៥២៤.

**មាតិកា** **ទំព័រ**

មានអាយុតិច ... ... ... ... ... ... ... ... ... ... ៥២៦.
ព្រះសារីបុត្រទូលសូមឱ្យទ្រង់បញ្ញត្តិសិក្ខាបទ ... ... ... ... ៥២៧
ព្រះមានព្រះភាគត្រាស់ហាមព្រះសារីបុត្រ ... ... ... ... ... ៥២៧
ការតិះដៀលក្នុងការបញ្ញត្តិសិក្ខាបទ ... ... ... ... ... ... ៥៣០
ប្រៀបដូចជាពេទ្យអ្នកមិនឆ្លាតធ្វើការវះកាត់ ... ... ... ... ៥៣១
អធិប្បាយហេតុដែលឱ្យទ្រង់បញ្ញត្តិសិក្ខាបទ ... ... ... ... ៥៣៤
អត្ថាធិប្បាយ ពាក្យថា និរព្វុទោ ជាដើម ... ... ... ... ... ៥៣៩
អាចិណ្ណៈ ទំនៀម មាន ២ យ៉ាង ... ... ... ... ... ... ... ៥៤៣
ព្រះពុទ្ធស្តេចត្រាច់ចារិកទៅក្នុង៣ មណ្ឌល ... ... ... ... ... ៥៤៤
សាវកាចិណ្ណៈ ការធ្លាប់ប្រព្រឹត្តមករបស់ព្រះសាវក ... ... ... ៥៤៧
វេរញ្ជព្រាហ្មណ៍ទូលរឿងមិនបានថ្វាយទាន ៣ ខែ ... ... ... ៥៤៩
វេរញ្ជព្រាហ្មណ៍អារាធនាព្រះពុទ្ធដើម្បីសោយភត្តាហារ ... ... ៥៥២
ព្រះមានព្រះភាគទ្រង់ទទួលអារាធនារបស់ព្រាហ្មណ៍ ... ... ៥៥២
វេរញ្ជព្រាហ្មណ៍ត្រៀមភត្តាហារថ្វាយស្អែក ... ... ... ... ... ៥៥៤
ទ្រង់យាងទៅកាន់លំនៅរបស់វេរញ្ជព្រាហ្មណ៍ ... ... ... ... ៥៥៥
ព្រាហ្មណ៍ថ្វាយត្រៃចីវរ ... ... ... ... ... ... ... ... ... ៥៥៦
ព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងវេសាលី ... ... ... ... ៥៥៩

ចប់ បញ្ជីមាតិកា

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ពាហិរនិទាន

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អារម្ភកថា

យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ ខេទំ
គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ។

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ សត្វនរុករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។
អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ

នមោ អវិជ្ជាទិក្កិលេសជាលំ   វិទ្ធំសិនោ ធម្មវរស្ស តស្ស

សត្វតែងកើតស្លាប់បង់   ព្រោះចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល   ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌   ជាម្ចាស់ល្អស្អាតស្អុខម
គឺព្រះពុទ្ធសេពសម   ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត   វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា   គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បភុតីហិ យុត្តោ
ខេត្តញ្ជនានំ កុសលត្ថិកានំ   តមរិយសង្ឃំ សិរសា នមាមិ

ព្រះសង្ឃអគ្គសាវក   មានសំវរៈដ៏ផូរផង់
កបដោយគុណសីលត្រង់   និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ   កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា   ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី   ដល់ព្រះអរិយបុគ្គល
ជាបុត្តព្រះទសពល   ជាមង្គលដល់សព្វសត្វ ។

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ   នមស្សមានោ រតនត្តយំ យំ

បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ    តស្សានុភាវេន ហតន្តរាយោ ។

ខ្ញុំសូមនមស្ការ    លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី    ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល    ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា    ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់    អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ    ក្តីអន្តរាយកុំបីមាន ។
ដោយកំលាំងអានុភាព    បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន    សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ    ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ    ដាក់ដល់ឋាននិព្វានហោង ។

ខ្ញុំព្រះករុណា នឹងអាស្រ័យអានុភាពរបស់ព្រះបុព្វាចារ្យ ពណ៌នាព្រះវិន័យឱ្យមិនលាយគ្នា ដែលកាលទ្រទ្រង់ហើយ សាសនារបស់ព្រះពុទ្ធ ដែលទ្រង់មិនបានតាំងមាំ ( ក្នុងចំណែកបំផុតគឺទិដ្ឋិទាំងពីរ ) តែទ្រង់តាំងនៅដោយប្រពៃ ( ក្នុងមជ្ឈិមាបដិបទា ) ដែលប្រតិស្ឋាននៅបាន ។ មែនពិត ព្រះវិន័យនេះ

សូម្បីបុព្វាចារ្យអ្នកអង់អាច ដែលកម្ចាត់មន្ទិល និងអាសវៈចេញអស់ហើយដោយទឹក គឺញាណ មានវិជ្ជានិងបដិសម្ភិទាបរិសុទ្ធិ ឆ្លាតក្នុងការពណ៌នាព្រះសទ្ធម្ម មិនងាយរកអ្នកប្រៀបផ្ទឹមក្នុងភាពជាអ្នកដុសខាត់បាន ប្រៀបដូចទង់ជ័យរបស់វត្តមហាវិហារ បានពណ៌នាទុកដោយន័យដ៏វិចិត្រ ស្របតាមព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រោះដូច្នោះ សំវណ្ណនានេះ មិនបានផ្តល់ប្រយោជន៍ណា ៗ ដល់ភិក្ខុក្នុងកោះដទៃ ព្រោះលោករៀបរៀងទុកដោយភាសាអ្នកកោះសីហឡៈ ដូច្នោះ ខ្ញុំព្រះករុណាអ្នករំលឹកដោយល្អ ដោយប្រពៃដល់ពាក្យអារាធនារបស់ព្រះថេរៈនាមថា ពុទ្ធសិរិ ទើបចាប់ផ្តើមដោយល្អ នូវការពណ៌នានេះ ដែលគួរដល់ន័យព្រះបាលីក្នុងកាលឥឡូវនេះ ។ ឯកាលនឹងចាប់ផ្តើមដោយល្អ នូវការពណ៌នានោះ នឹងយកមហាអដ្ឋកថា ជាគោលរបស់វណ្ណនានោះ មិនលះបង់នូវសេចក្តីដែលគួរ សូម្បីចាកសេចក្តីវិនិច្ឆ័យ ដែលលោកពោលទុកក្នុងអដ្ឋកថាមហាបច្ចរី និងអដ្ឋកថាដែលប្រាកដដោយល្អ ដោយឈ្មោះថា កុរុន្ទីជាដើម ធ្វើថេរវាទទុកក្នុងខាងក្នុងហើយ ទើបនិងចាប់ផ្តើមដោយល្អ ដោយប្រពៃនូវសំវណ្ណនា

សូមភិក្ខុទាំងឡាយ ជាថេរៈជាអ្នកបួសថ្មី និងកណ្ដាល អ្នកមានចិត្តជ្រះថ្លា គោរពរាប់អានព្រះធម៌របស់ព្រះតថាគត អ្នកមានដួងប្រទីប គឺ ព្រះធម៌ ចូរតាំងចិត្តស្ដាប់សំវណ្ណនានោះរបស់ខ្ញុំព្រះករុណា ដោយគោរពចុះ ។

ព្រះអដ្ឋកថាចារ្យអ្នកកោះសីហឡ: មិនបានលះមតិ (អធិប្បាយ) របស់ពុទ្ធបុត្រទាំងឡាយ អ្នកដឹងធម្មវិន័យ ដូចដែលព្រះពុទ្ធត្រាស់ទុក បានតែងអដ្ឋកថាក្នុងកាលមុន ។ ព្រោះហេតុនោះឯង ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាទាំងអស់ វៀរលែងតែពាក្យដែលសរសេរដោយភ្លាំងភ្លាត់ចេញ រមែងជាប្រមាណនៃបណ្ឌិតទាំងឡាយ អ្នកមានសេចក្ដីគោរពក្នុងសិក្ខាក្នុងព្រះសាសនានេះ ។ ក៏សូម្បីវណ្ណនានេះ នឹងសម្ដែងសេចក្ដីនៃពាក្យទាំងឡាយ ដែលមកក្នុងព្រះសុត្តន្ត:ឱ្យសមគួរដល់ព្រះសូត្រ លះចោលនូវភាសាដទៃចេញពីអដ្ឋកថានោះឯង និងកាត់បន្ថយសេចក្ដីពិស្ដារ (ពាក្យប្រព័ន្ធដែលពិស្ដារ) ឱ្យរួមផ្ដុំចូល ក៏នឹងមិនឱ្យនៅសល់ទុកនូវសេចក្ដីវិនិច្ឆ័យទាំងពួង មិនរំលងលំដាប់ព្រះបាលីដែលជាបែបផែនយ៉ាងណាមួយ ព្រោះ

ដូច្នោះ បណ្ឌិតគួរតាមសិក្សាវណ្ណនានេះដោយអើពើចុះ ។

ព្រោះខ្ញុំព្រះករុណា បានពោលទុកក្នុងគាថាទាំងនោះថា "នឹងពណ៌នាព្រះវិន័យ" ដូច្នេះ អ្នកសិក្សាគួរកំណត់ព្រះវិន័យជាមុនថា វិន័យនោះ គឺ អ្វី ? ព្រោះដូច្នោះ ទើបខ្ញុំព្រះករុណាពោលពាក្យនេះថា **តំ វណ្ណយិស្សំ វិនយំ** ដែលឈ្មោះថា វិន័យក្នុងទីនេះប្រាថ្នាយកវិន័យបិដកទាំងអស់ ។ ក៏ដើម្បីនឹងសំវណ្ណនាព្រះវិន័យនោះ ខ្ញុំព្រះករុណានឹងពោលមាតិកា ដូចតទៅនេះថា ៖

"ព្រះវិន័យបិដកនេះ អ្នកណាពោលទុក, ពោលក្នុងកាលណា ពោលទុកព្រោះហេតុអ្វី, អ្នកណាទ្រទ្រង់ទុក, អ្នកណានាំបន្តមក, និងតាំងនៅហើយ ក្នុងបុគ្គលណា, ខ្ញុំព្រះករុណាពោលវិធីនេះហើយខាងក្រោយ នឹងសម្តែងសេចក្តីនៃបាលីថា 'តេន' ជាដើមដោយប្រការផ្សេង ៗ ធ្វើការពណ៌នាអត្ថនៃព្រះវិន័យ" ។

បណ្តាមាតិកាទាំងនោះ ពាក្យថា **អ្នកណាពោលទុក, ពោលក្នុងកាលណា ពោលទុកព្រោះហេតុអ្វី,** នេះ លោកអាចារ្យពោលសំដៅយកពាក្យជាដើមយ៉ាងនេះមុនថា សម័យនោះ ព្រះមានព្រះភាគគង់នៅ (ក្រោម

ដើមស្តៅជាលំនៅរបស់នទ្បេរុយក្ស ) ជិតស្រុកវេរញ្ជា[១] ។ ព្រោះពាក្យនេះ មិនមែនជាពាក្យដែលពោលឱ្យប្រចក្សនឹងព្រះអង្គឯងនៃព្រះមានព្រះភាគ[២] ។ ព្រោះដូច្នោះ បណ្ឌិតទើបគួរពោលតាំងបញ្ហានោះ ដូច្នេះថា "ពាក្យនេះ អ្នកណាពោលទុក ពោលទុកក្នុងកាលណា និងព្រោះហេតុអ្វី ទើបពោលទុក ។ ( ឆ្លើយថា ) ពាក្យនេះ ព្រះឧបាលីថេរៈពោលទុក ក៏ឯពាក្យនោះ ព្រះឧបាលីថេរៈពោលទុក ក្នុងគ្រាធ្វើបឋមមហាសង្គីតិ ។ ដែលឈ្មោះថា បឋមមហាសង្គីតិនេះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានពោលហើយ ក្នុងបញ្ចសតិកសង្គីតិខន្ធកៈ[៣] ក៏ពិតមែនហើយ, តែថា ដើម្បីភាពជាអ្នកឆ្លាតក្នុងនិទាន បណ្ឌិតគួរជ្រាបតាមន័យនេះ សូម្បីក្នុងអដ្ឋកថានេះ ។

---

១. សារត្ថទីបនីថា ព្រោះសូម្បីវណ្ណនានេះ ដែលនឹងសម្តែងសេចក្តីនៃពាក្យ ដែលមកក្នុងព្រះសុត្តន្តៈឱ្យសមនឹងព្រះសូត្រ ខ្ញុំព្រះករុណាក៏នឹងលះភាសាដទៃក្រៅពីអដ្ឋកថានោះចេញ ហើយនឹងបង្រួញសេចក្តីដែលពិស្តារឱ្យខ្លី មិនលះបោលសេចក្តីវិនិច្ឆ័យទាំងពួងឱ្យសល់ទុក មិនរំលងលំដាប់ព្រះបាលីដែលជាបែបផែនអ្វី ៗ ហើយនឹងរចនា, ព្រោះដូច្នោះ អ្នកសិក្សាគួរតាំងចិត្តកំណត់វណ្ណនានេះឯង ។ ២. នយ. សារត្ថទីបនីថា គឺមិនមែនជាព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុក ឬជាការដែលលោកពោលទុកក្នុងវេលាដែលព្រះពុទ្ធ ទ្រង់នៅមានព្រះជន្ម ។ ៣. វិន. ចុល្ល. ១១. ២៧៨/៣៥៦ ។

# ពាហិរនិទាន

## ប្រារព្ធមូលហេតុធ្វើបឋមសង្គាយនា

សេចក្ដីពិស្ដារថា កាលព្រះមានព្រះភាគ ដែលជាទីពឹងនៃសត្វលោក ទ្រង់បំពេញពុទ្ធកិច្ច តាំងពីទ្រង់ញ៉ាំងព្រះធម្មចក្រ ឱ្យប្រព្រឹត្តទៅជាដើម ដរាបដល់ប្រោសសុភទ្ទបរិព្វាជកហើយ ស្ដេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាជិតភ្លឺ ក្នុងថ្ងៃវិសាខបុណ្ណមី ត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូក្នុងសាលវ័ន ដែលជាទីប្រពាតរបស់ស្ដេចមល្លៈទាំងឡាយ ជិតក្រុងកុសិនារា ព្រះមហាកស្សបដែលជាព្រះសង្ឃត្ថេរនៃភិក្ខុប្រមាណ ៧ សែនរូប ដែលប្រជុំគ្នាក្នុងស្ថានទីបរិនិព្វាននៃព្រះមានព្រះភាគ រលឹកដល់ពាក្យដែលសុភទ្ទវុឌ្ឍបព្វជិតពោល កាលព្រះមានព្រះភាគទ្រង់បរិនិព្វាន ហើយបាន ៧ ថ្ងៃថា "ម្នាលអាវុសោទាំងឡាយ ណ្ហើយ អ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះតែងបៀត បៀនថា 'អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នក' ក៏ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើអំពើនោះ មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន"[១] ដូច្នេះ លោកពិចារណាឃើញ

---

១ ទីឃ. មហា. មហាបរិនិព្វានសុត្ត. ១៦. ១៥៥/៣៣៩ ។

ថា "ការប្រជុំសង្ឃច្រើនដូច្នេះ គង់ទៅនឹងរកបានលំបាក" ទើបត្រិះរិះថា "ការដែលពួកបាបភិក្ខុ នឹងគប្បីជាអ្នកសម្គាល់ថា 'បាវចនៈមានព្រះសាស្ដាកន្លងទៅហើយ' ដូច្នេះ បានបក្ខពួកហើយ គប្បីញុំាងព្រះសទ្ធម្មឱ្យអន្តរធានបានមិនយូរឡើយ ក៏ដំណើរនេះ ជាឋានៈ(ហេតុ)ដែលនឹងមានជាប្រាកដ ។ សេចក្ដីពិត ព្រះវិន័យតាំងនៅដរាបណា បាវចនៈនៅមានព្រះសាស្ដាមិនកន្លងទៅដរាបនោះ សេចក្ដីនេះ សមដោយព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា 'ម្នាលអានន្ទ ធម៌ណាក្ដី វិន័យណាក្ដី ដែលតថាគតសម្ដែងហើយ បញ្ញត្តិហើយ ដល់អ្នកទាំងឡាយ លុះអំណាះឥតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ'[១] ដូច្នេះ បើដូច្នោះ យើងគប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ ដែលជាវិធីសម្រាប់ព្រះសាសនានេះ គប្បីតាំងនៅមាំអស់កាលយូរ ។ មួយទៀតដោយហេតុដែលយើងជាអ្នកដែលព្រះមានព្រះភាគត្រាស់ថា 'កស្សបៈអ្នកនឹងទ្រទ្រង់សំពត់បង្សុកូល ដែលធ្វើដោយធ្មៃរបស់តថាគត ដែលតថាគតប្រើស្លៀកដណ្ដប់ហើយឬ' ដូច្នេះ ហើយទ្រង់អនុគ្រោះដោយសាធារណបរិភោគក្នុងចីវរ និងដោយការទ្រង់លើកតម្កើងទុក ប្រៀបធៀបព្រះអង្គក្នុងឧត្តរិមនុស្សធម្ម មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជា

---

១. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ១៤១/៣២១ ។

ប្រភេទ ដោយន័យជាដើម យ៉ាងនេះថា 'ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងាត់នោះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបប្រាថ្នា ដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពី សេចក្ដីស្ងាត់នោះ ដរាបនោះដែរ'[១] ដូច្នេះ ភាពជាអ្នកមិនមានបំណុលយ៉ាងដទៃអ្វី នឹងមាន ដល់យើងនោះបាន, ព្រះមានព្រះភាគទ្រង់ជ្រាបយើងថា 'កស្សបនេះ នឹងជាអ្នកបន្តវង្ស ព្រះសទ្ធម្មរបស់តថាគត' ដូច្នេះហើយ ទើបទ្រង់អនុគ្រោះដោយអសាធារណានុគ្រោះនេះ ដូចព្រះរាជាទ្រង់ជ្រាបព្រះរាជឱរសដែលនឹងបន្តវង្សត្រកូលរបស់ព្រះអង្គហើយ ទ្រង់អនុគ្រោះដោយទ្រង់ប្រគល់គ្រឿងក្រោះ និងឥស្សរិយយសរបស់ព្រះអង្គដូច្នោះ មិនមែនឬ" ដូច្នេះ ទើបញុំាងសេចក្ដីឧស្សាហ៍ឱ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីប្រារព្ធសង្គាយនាព្រះធម៌ វិន័យ ដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា "លំដាប់នោះ ព្រះមហាកស្សបៈមានអាយុ ហៅភិក្ខុទាំងឡាយមកថា

---

១. សំយុ. និទា. កស្សបសំយុត្ត. ៣២. ១៦៥/១៤៩ ។

"ម្នាលអាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបារាំនេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមមកឆ្ងាយ ជាមួយនឹងភិក្ខុសង្ឃជាច្រើនចំនួន ៥០០ រូប"[១] ដូច្នេះជាដើម ។

សុភទ្ទកណ្ឌទាំងពួង អ្នកសិក្សាគប្បីជ្រាបដោយពិស្ដារ ។

## ព្រះមហាកស្សបដឹកនាំធ្វើសង្គាយនា

ខាងមុខអំពីនោះ ព្រះមហាកស្សបបានពោលថា "ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនាធម៌ និងវិន័យ តំណទៅមុខ អកុសលធម៌មុខជានឹងរុងរឿង កុសលធម៌ មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យមុខជានឹងរុងរឿង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលដែលជា អធម្មវាទីនឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកម្លាំងចុះ ពួកបុគ្គលដែលជាអវិនយវាទីនឹងមានកម្លាំងឡើង ពួកបុគ្គលដែលជាវិនយវាទីនឹងថយកម្លាំង ចុះ"[២] ដូច្នេះ ។ ភិក្ខុទាំងឡាយបានទូលព្រះថេរៈថា "បពិត្រព្រះថេរៈដ៏ចម្រើន បើដូច្នោះសូមព្រះថេរៈ ជ្រើសរើសនូវភិក្ខុទាំងឡាយចុះ"[៣] ។

---

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៨/៣៥៦ ។ ២. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៨/៣៥៨ ។ ៣. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៩/៣៥៩ ។

## ព្រះមហាកស្សបជ្រើសរើសភិក្ខុ ៤៩៩ រូប

ព្រះថេរៈវៀរភិក្ខុដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សក អ្នកទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសន៍ទាំងអស់ចេញចំនួនច្រើនរយ និងច្រើនពាន់ ជ្រើសរើសយកតែភិក្ខុជាព្រះខីណាស្រពចំនួន ៤៩៩ រូប អ្នកទ្រង់ទុកនូវប្រភេទនៃសព្វបរិយត្តិ គឺ ព្រះត្រៃបិដក បានសម្រេចបដិសម្ភិទាមានអានុភាពច្រើន បែកធ្លាយក្នុងត្រៃវិជ្ជាជាដើម ដែលព្រះមានព្រះភាគទ្រង់លើកឡើង កាន់ឯតទគ្គៈដោយច្រើនប៉ុណ្ណោះ អ្នកដែលព្រះធម្មសង្គាហកាចារ្យសំដៅដល់ ទើបពោលពាក្យនេះថា "ទើបព្រះមហាកស្សបៈមានអាយុជ្រើស រើសនូវព្រះអរហន្ត បានចំនួន ៤៩៩ រូប"[១] ដូច្នេះជាដើម ។

## ការធ្វើសង្គាយនានឹងវៀរព្រះអានន្ទមិនបាន

សួរថា ក៏ព្រះកស្សបត្ថេរធ្វើឱ្យខ្វះ ១ រូប ដើម្បីអ្នកណា ? ឆ្លើយថា ដើម្បីឱ្យឱកាសដល់ព្រះអានន្ទត្ថេរ ។ ពិតមែន ការសង្គាយនាធម៌មិនអាចធ្វើ ទាំងរួម ទាំងបែកចាកព្រះអានន្ទនោះបានទេ ព្រោះព្រះអានន្ទនោះនៅជាព្រះសេក្ខៈមានកិច្ចចាំបាច់ត្រូវធ្វើនៅឡើយ, ដូច្នោះហើយ

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៩/៣៥៩ ។

ទើបមិនអាចធ្វើរួមនឹងលោកបាន, តែព្រោះនវង្គសត្ថុសាសន៍ មានសុត្តៈ គេយ្យៈជាដើម អ្វីណាដែលព្រះទសពលសម្ដែងហើយ ឈ្មោះថា លោកមិនបានទទួលចំពោះព្រះភ័ក្ត្ររបស់ព្រះមានព្រះភាគនោះ មិនមាន, ព្រោះដូច្នោះ ទើបមិនអាចនិងវៀរលោកបាន ។ សួរថា កាលបើមិនអាចធ្វើយ៉ាងនោះបាន សូម្បីព្រះថេរៈនៅជាព្រះសេក្ខៈនៅឡើយ ព្រះថេរៈក៏គួរជ្រើសរើស ព្រោះជាអ្នកមានឧបការៈច្រើនដល់ការសង្គាយនាព្រះធម៌ កាលមានសេចក្ដីចាំបាច់ត្រូវជ្រើសរើសយ៉ាងនោះ ព្រោះហេតុអ្វី ទើបព្រះថេរៈមិនជ្រើសរើសលោក ។ ឆ្លើយថា ព្រោះនឹងវៀរពាក្យតិះដៀលរបស់អ្នកដទៃ ។ សេចក្ដីពិត ព្រះថេរៈជាអ្នកជិតដិតក្នុងព្រះអានន្ទយ៉ាងក្រៃលែងបំផុត ។ ពិតមែន សូម្បីកាលសក់ស្កូវហើយ ព្រះមហាកស្សបៈ ក៏នៅតែហៅព្រះអានន្ទនោះ ដោយប្រើកុមារកវាទៈថា "អានន្ទនេះ នៅក្មេងមិនដឹងប្រមាណឡើយ"[១] ដូច្នេះ ។ មួយទៀត ព្រះអានន្ទនេះ ប្រសូតក្នុងសក្យត្រកូល ជាព្រះភាតារបស់ព្រះតថាគត ជាឱរសរបស់ស្ដេចមា ពិតមែន ភិក្ខុទាំងឡាយ នឹងសម្គាល់ក្នុងព្រះមហាកស្សបត្ថេរនោះដូចជាដល់នូវឆន្ទាគតិ នឹងគប្បីពោលតិះដៀលថា "ព្រះថេរៈវៀរភិក្ខុទាំងឡាយ ដែលបានសម្រេច បដិសម្ភិទាជាអសេក្ខៈចេញជាច្រើន

១. សំយុ. និទា. កស្សបសំយុត្ត. ៣២. ១៨៩/១៦៦ ។

បែរជាជ្រើសរើសយកព្រះអានន្ទ អ្នកសម្រេច បដិសម្ភិទាជាសេក្ខៈវិញ" ។ ព្រះថេរៈកាលនឹងវៀរពាក្យតិះដៀលរបស់អ្នកដទៃនោះចេញហើយ, ទើបគិតថា "ការសង្គាយនា មិនអាចធ្វើបានឡើយ ដោយវៀរព្រះអានន្ទចេញ យើងនឹងទទួលយកព្រះអានន្ទចូលផង តាមអនុមតិរបស់ភិក្ខុទាំងឡាយប៉ុណ្ណោះ" ទើបមិនបានជ្រើសរើសព្រះអានន្ទនោះចូលផង ។

## ភិក្ខុទាំងឡាយសូមឱ្យជ្រើសរើសព្រះអានន្ទ

គ្រានោះ ទើបភិក្ខុទាំងឡាយនាំគ្នាអង្វរព្រះថេរៈ ដើម្បីត្រូវការឱ្យជ្រើសរើសព្រះអានន្ទដោយខ្លួនឯងតែម្តង ដូចដែលព្រះបូរាណាចារ្យពោលទុកថា "ពួកភិក្ខុបានពោលពាក្យនេះចំពោះព្រះមហាកស្សបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទដ៏មានអាយុនេះ នៅជាសេក្ខៈ ពិតមែន តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្តី វិន័យក្តី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុងសំណាក់ព្រះមានព្រះភាគជាច្រើន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈធ្វើការជ្រើសរើសយកព្រះអានន្ទមានអាយុផង" ។ ទើបព្រះមហាកស្សបមានអាយុ ជ្រើសរើសយកព្រះអានន្ទដ៏មានអាយុបញ្ចូលផង"[១] ។ រួមជា

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៩/៣៥៩ ។

មួយភិក្ខុទាំងឡាយនោះ ដែលព្រះមហាកស្សបជ្រើសរើសតាមអនុមតិរបស់ភិក្ខុទាំងឡាយ ទើបជាព្រះថេរៈ ៥០០ រូប ដោយប្រការដូច្នេះ ។

## ក្រុងរាជគ្រឹះជាកន្លែងធ្វើបឋមសង្គាយនា

គ្រានោះឯង ភិក្ខុថេរៈទាំងឡាយបានមានសេចក្តីបរិវិតក្កៈ យ៉ាងនេះថា "យើងទាំងឡាយ គប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យក្នុងទីណាហ្ន៎ ។ គ្រានោះ ឯង ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្តីរិះគិតឃើញដូច្នេះថា នគររាជគ្រឹះជាស្រុកមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន, បើដូច្នោះ គួរតែយើង រាល់គ្នាទៅនៅចាំវស្សាក្នុងនគររាជគ្រឹះ ទើបអាចនឹងសង្គាយនានូវធម៌ និងវិន័យបាន, ចំណែកភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅ នៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ"[១] ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះថេរៈទាំងនោះ ទើបប្រឹក្សាព្រមព្រៀងគ្នាដូច្នោះ ? ។ ឆ្លើយថា ព្រោះនឹងមានវិសភាគបុគ្គលខ្លះ ចូលទៅកាន់កណ្តាលជំនុំសង្ឃ ហើយគប្បីជំទាស់ថាវរកម្មរបស់លោកបាន ។ គ្រានោះ ព្រះមហាកស្សបទើបសូធ្យប្រកាសដោយញត្តិទុតិយកម្មវាចា ។ ញត្តិទុតិយកម្ម[២]នោះ អ្នកសិក្សាគប្បីជ្រាបតាមន័យ ដែលលោកពោលទុកក្នុងសង្គីតិខន្ធកៈនោះឯង ។

---

១-២. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៧៩/៣៥៩ ។

## ព្រះមហាថេរៈចែកគ្នានិមន្តទៅកាន់ក្រុងរាជគ្រឹះ

គ្រានោះ ព្រះមហាកស្សបត្ថេរជ្រាបថា រាប់តាំងពីថ្ងៃ ដែលព្រះតថាគតបរិនិព្វានមក កាលថ្ងៃសាធុកីឡានិងថ្ងៃបូជាព្រះធាតុកន្លងទៅបាន ៧ ថ្ងៃម្ដង ៗ ជាការកន្លងទៅហើយកន្លះខែ, ឥឡូវនេះ រដូវគិម្ហន្តនៅសល់កន្លះខែ តិថីដែលនឹងចូលចាំវស្សា ក៏ជិតចូលមកហើយ ទើបពោលថា "អ្នកមានអាយុទាំងឡាយ ពួកយើងទៅកាន់ក្រុងរាជគ្រឹះចុះ" ហើយបាននាំយកភិក្ខុសង្ឃពាក់កណ្ដាល ដើរទៅមកមួយ ។ ព្រះអនុរុទ្ធត្ថេរ ក៏នាំយកភិក្ខុសង្ឃពាក់កណ្ដាល ដើរទៅមកមួយ ទៀត ។ ព្រះអានន្ទត្ថេរកាន់យកបាត្រ និងចីវររបស់ព្រះមានព្រះភាគ ដែលមានភិក្ខុសង្ឃហែហមមានសេចក្ដីប្រាថ្នានឹងធ្វើដំណើរចូលមកកាន់ក្រុងសាវត្ថី ទៅកាន់ក្រុងរាជគ្រឹះ ក៏ជៀសចារិកទៅមកក្រុងសាវត្ថី ។

## សំឡេងស្រែកយំក្នុងទីដែលព្រះអានន្ទទៅដល់

ក៏ក្នុងស្ថានទីដែលព្រះអានន្ទទៅហើយ ៗ បានមានការស្រែកយំរៀបរាប់យ៉ាងច្រើនថា "ព្រះអានន្ទដ៏ចម្រើន លោកម្ចាស់យាត់ព្រះសាស្ដាទុកទីណា ទើបមកហើយ ក៏កាលព្រះថេរៈទៅដល់ក្រុងសាវត្ថីដោយលំដាប់ បានមានការស្រែកយំរៀបរាប់យ៉ាងច្រើន ដូចក្នុងថ្ងៃដែលព្រះមានព្រះភាគស្ដេចបរិនិព្វានដូច្នោះឯង ។

## ព្រះអានន្ទសំអាតសេនាសនៈដែលធ្លាប់គង់

បានឮថា ក្នុងក្រុងសាវត្ថីនោះ ព្រះអានន្ទបានលួងលោម ពន្យល់មហាជននោះឱ្យស្រោលចិត្ត ដោយធម្មីកថាដែលប្រកបដោយត្រៃលក្ខណ៍ មានសេចក្តីមិនទៀងជាដើម ហើយចូលទៅកាន់វត្តជេតវន បើកទ្វារព្រះគន្ធកុដិដែលព្រះទសពលធ្លាប់គង់ ហើយនាំគ្រែ និងតាំងចេញមក គោះវាយ បោសសំអាតព្រះគន្ធកុដិ ប្រមូលសម្រាមផ្កាឈើដែលស្ងួត ៗទៅចោល ហើយនាំយកគ្រែ និងតាំងត្រឡប់ចូលទៅតាំងទុកក្នុងទីដូចដើមវិញ បានធ្វើវត្តគ្រប់យ៉ាងដែលគួរធ្វើដូចក្នុងកាលដែលព្រះមានព្រះភាគនៅមានព្រះជន្ម ដូច្នោះ ។

## ព្រះអានន្ទឆាន់ថ្នាំបញ្ចុះ

ក្នុងកាលនោះ ព្រះថេរៈ ព្រោះជាអ្នកច្រើនទៅដោយការ ឈរ និងការអង្គុយចាប់តាំងពីកាលដែលព្រះមានព្រះភាគបរិនិព្វានមក ដើម្បីជម្រះកាយដែលមានធាតុក្រាស់ ឱ្យសប្បាយ, ក្នុងថ្ងៃទីពីរ ទើបអង្គុយឆាន់ថ្នាំបញ្ចុះដែលលាយដោយទឹកដោះនៅក្នុងវិហារនុ៎ះឯង ដែលលោកសំដៅដល់ ទើបបានពោល ពាក្យនេះចំពោះមាណពដែលសុភមាណពបញ្ជូនទៅថា "ម្នាលមាណព កាលនេះមិនគួរ ( ទៅទេ ) ដ្បិតថ្ងៃនេះ

យើងបានឆាន់ថ្នាំខ្លះទៅហើយ, បើដូច្នោះ ចាំយើងពិចារណានូវកាលនិងសម័យសិនហើយ សឹមទៅក្នុងថ្ងៃស្អែក”[១] ដូច្នេះ ។ ក្នុងថ្ងៃស្អែកព្រះថេរៈ មានព្រះចេតកត្ថេរជាបច្ឆាសមណៈ បានទៅ (កាន់លំនៅរបស់សុភមាណព) ត្រូវសុភមាណពសួរ ទើបបានសម្ដែងព្រះសូត្រទី ១០ ឈ្មោះសុភសូត្រក្នុងទីឃនិកាយ ។ ក្នុងកាលនោះ ព្រះថេរៈបង្គាប់ឱ្យជាងធ្វើការជួសជុលស្ថានទីទ្រុឌទ្រោម ក្នុងព្រះជេតវនវិហារហើយ កាលថ្ងៃវស្សូបនាយិកា ជិតចូលមកដល់បាន ទៅកាន់ក្រុងរាជគ្រឹះ ។ សូម្បីព្រះមហាកស្សបត្ថេរ និងព្រះអនុរុទ្ធថេរៈ ក៏បាននាំយកភិក្ខុសង្ឃទាំងអស់ទៅកាន់ក្រុងរាជគ្រឹះដូចគ្នា ។

## ព្រះថេរៈទាំងឡាយតិតជុសជុលវិហារ ១៨ កន្លែង

សម័យនោះឯង ក្នុងក្រុងរាជគ្រឹះមានមហាវិហារ ១៨ មហាវិហារទាំងអស់នោះ ក៏ស្រេកេកស្រេកាកទៅដោយរបស់ដែលត្រូវចោល និងធ្លាក់ពាសពេញ ។ ពិតមែន ពួកភិក្ខុទាំងអស់ បាននាំគ្នាកាន់យកបាត្រ និងចីវររបស់ខ្លួន ៗ លះបង់ចោលវិហារ និងបរិវេណទៅក្នុងស្ថានទីដែលព្រះមានព្រះភាគបរិនិព្វាន ។ ព្រះថេរៈទាំងឡាយនៅក្នុងវិហារទាំង

១. ទីឃ. សីល. សុភសូត្រ. ១៥. ១១៨/១៦១ ។

នោះ ដើម្បីនឹងបូជាព្រះតម្រាស់របស់ព្រះមានព្រះភាគ និងដើម្បីដោះវាទ:របស់ពួកតិរ្ថិយចេញ ទើបគិតគ្នាថា "រហូតដល់អស់ខែដំបូង ពួកយើងនឹងធ្វើការជួសជុលវិហារដែលទ្រុឌទ្រោម" ។ ក៏ពួកតិរ្ថិយទាំងឡាយគប្បីពោលថា "ពួកសាវករបស់ព្រះសមណគោតម កាលព្រះសាស្តា ទ្រង់នៅមានព្រះជន្មប៉ុណ្ណោះ ទើបបដិបត្តិវិហារ, កាលព្រះសាស្តាបរិនិព្វានហើយ ក៏នាំគ្នាលះបង់ចោលអស់" ។ លោកពោលអធិប្បាយទុកថា "ក៏ដើម្បីនឹងដោះវាទ:របស់ពួកតិរ្ថិយទាំងនោះ" ទើបព្រះថេរ:ទាំងឡាយបានគិតគ្នាយ៉ាងនោះ ។ សេចក្តីនេះសមដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា "គ្រានោះ ភិក្ខុទាំងឡាយជាថេរ: មានសេចក្តីរិះគិត ដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈ ដែលដាច់ដាចធ្លុះធ្លាយ ព្រះមានព្រះភាគទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នា ជួសជុលសេនាសនៈ ដែលដាច់ដាចធ្លុះធ្លាយអស់ខែមួយដំបូងសិន ដល់មកខែកណ្តាល យើងនឹងប្រជុំគ្នាធ្វើសង្គាយនានូវធម៌និងវិន័យ"[១] ដូច្នេះ ។

---

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធក:. ១១. ២៨០/៣៦១ ។

## ព្រះថេរៈទៅសូមហត្ថកម្មពីព្រះបាទអជាតសត្តុ

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងនោះបានទៅឈរត្រង់ទ្វារព្រះរាជវាំង ។ ព្រះបាទអជាតសត្តុស្តេចមកថ្វាយបង្គំហើយ បន្ទាប់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ នាំគ្នាមក ដោយហេតុដូចម្តេច" ដូច្នេះ ហើយទើបទ្រង់ត្រាស់សាកសួរដល់កិច្ចដែលខ្លួនព្រះអង្គគួរធ្វើ ។ ព្រះថេរៈទាំងឡាយ បានទូលប្រាប់ហត្ថកម្ម ដើម្បីប្រយោជន៍ដល់ការជួសជុលមហាវិហារទាំង ១៨ កន្លែង ។

## ព្រះរាជាទ្រង់ឧបត្ថម្ភកិច្ចសង្ឃគ្រប់យ៉ាង

ព្រះរាជាទ្រង់ទទួលថា ល្អណាស់ លោកម្ចាស់ ហើយបានព្រះរាជទានពួកមនុស្សអ្នកធ្វើហត្ថកម្ម ។ ព្រះថេរៈទាំងឡាយ បន្ទាប់ឱ្យធ្វើជួសជុលវិហារទាំងអស់សម្រេចក្នុងមួយខែដំបូង ហើយបានទូលឱ្យព្រះរាជាទ្រង់ជ្រាបថា "សូមថ្វាយព្រះពរ មហាបពិត្រ ការជួសជុលវិហារសម្រេចអស់ហើយ ឥឡូវនេះ អាត្មាភាពទាំងឡាយ នឹងធ្វើការសង្គាយនាព្រះធម៌និងព្រះវិន័យ" ។

ព្រះរាជា. ល្អណាស់ លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយចូរអស់សេចក្តីងឿងឆ្ងល់សង្ស័យធ្វើចុះ អាណាចក្រចូរទុកជាភារៈរបស់ខ្ញុំ

ព្រះករុណា ធម្មចក្រចូរជាភារៈរបស់លោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់មេត្តាប្រើខ្ញុំព្រះករុណាចុះ លោកម្ចាស់ នឹងឱ្យខ្ញុំព្រះករុណាធ្វើអ្វី ។

ព្រះថេរៈ. សូមថ្វាយព្រះពរមហាបពិត្រ សូមព្រះអង្គ មេត្តាឱ្យសាងស្ថានទីអង្គុយប្រជុំសម្រាប់ភិក្ខុទាំងឡាយ ដែលធ្វើសង្គាយនា ។

ព្រះរាជា. នឹងឱ្យខ្ញុំព្រះករុណាសាងក្នុងទីណា លោកម្ចាស់ ?

ព្រះថេរៈ. សូមថ្វាយព្រះពរ គួរសាងត្រង់ទ្វារល្អាងសត្តបណ្ណិនាភ្នំវេភារៈ ។

## ព្រះរាជាបង្គាប់ឱ្យប្រដាប់ល្អាងដូចវិមានព្រហ្ម

ព្រះបាទអជាតសត្តុទ្រង់ត្រាស់ថា "បានលោកម្ចាស់" ដូច្នេះ ហើយបង្គាប់ឱ្យសាងមណ្ឌប មានគ្រឿងប្រដាប់ដែលជាសារៈ ដែលគួរទស្សនា ដូចនឹងស្ថានទីដែលវិស្សុកម្មទេវបុត្រនិម្មិតទុក មានជញ្ជាំងសរសរ និងជណ្ដើរដែលជាងចែកទុកល្អ វិចិត្រដោយមាលាកម្មនិងលតាកម្មមានប្រភេទផ្សេង ៗ ហាក់ដូចជាគ្របសង្កត់នូវសម្បត្តិនៃរាជមណ្ឌបរបស់ព្រះមហាក្សត្រិយ៍បាត់អស់ ដូចជាអួតសរសើរសិរីនៃទេវវិមាន ដូចជាស្ថានជាទីអាស្រ័យនៅនៃសិរី ដូចកំពង់ជាទីប្រជុំជាទន់ឯករបស់ពួក វិហគគឺភ្នែកនៃទេវតានិងមនុស្ស និងប្រដូចស្ថានទីរីករាយក្នុងលោក ដែលគេ

ប្រមូលចាត់ចែងសព្វគ្រប់ គាត់តែងមណ្ឌបនោះឱ្យដូចជាវិមានព្រហ្ម មានពិតានស្រស់ល្អរុងរឿង ដូចជារលាស់នូវកម្រងផ្កាកុសុមដែលរយើងរយោងមានប្រភេទផ្សេង ៗ វិចិត្រដោយគ្រឿងបូជាផ្កាឈើផ្សេង ៗ មានការងារដែលគួរធ្វើត្រង់ផ្ទៃឋាន ធ្វើសម្រេចរៀបរយល្អហើយ ដូចជាមានផ្ទៃឋានដាក់ពេញដោយកែវមណី ដ៏វិចិត្រដោយរតនៈដូច្នោះ ខាងក្នុងមហាមណ្ឌបនោះ ទ្រង់ត្រាស់ឱ្យក្រាលកម្រាលដែលជាកប្បិយ ៥០០ ដែលគណនាតម្លៃ មិនបានសម្រាប់ភិក្ខុ ៥០០ រូប ហើយឱ្យក្រាលថេរាសនៈ ផ្អែកខាងខាងទិសទក្សិណ បែរមុខទៅខាងទិសឧត្តរ ត្រង់កណ្តាលមណ្ឌបឱ្យតាំងធម្មាសនៈ ដែលគួរជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ បែរមុខទៅខាងទិសបូព៌ា និងទ្រង់បក់ផ្លិតវីជនីដ៏ វិចិត្រដោយភ្លុកទុកលើធម្មាសនៈនោះ ហើយបង្គាប់ឱ្យប្រកាស ដល់ភិក្ខុសង្ឃថា លោកម្ចាស់ដ៏ចម្រើន កិច្ចរបស់ខ្ញុំព្រះករុណាសម្រេចហើយ ដូច្នេះ ។

## ពួកភិក្ខុដាស់តឿនព្រះអានន្ទមិនឱ្យប្រមាទ

ពួកភិក្ខុបានពោលនឹងព្រះអានន្ទថា "អាវុសោ ការប្រជុំនឹងមានក្នុងថ្ងៃស្អែក តែលោកនៅជាសេក្ខៈបុគ្គលនៅឡើយ ព្រោះហេតុនោះ លោកមិនគួរទៅកាន់ទីប្រជុំ លោកចូរជាអ្នកមិនប្រមាទចុះ" ដូច្នេះ ។

គ្រានោះឯង ព្រះអានន្ទត្រិះរិះថា “ការប្រជុំនឹងមានក្នុងថ្ងៃស្អែក ក៏ការដែលយើងនៅជាសេក្ខៈនេះ នឹងគប្បីទៅកាន់ទីប្រជុំនោះ មិនសមគួរដល់យើងឡើយ” ហើយបានសម្រាកនៅដោយកាយគតាសតិ រហូតដល់អស់រាត្រីជាច្រើនតែម្តង ក្នុងវេលារាត្រី ជិតភ្លឺក៏ចុះចាកទីចង្ក្រមហើយចូលទៅកាន់វិហារ( កុដិ ) គិតថា “នឹងសិង” ក៏បានទម្រេតកាយចុះ ។ ជើងទាំងពីរផុតពីផែនដី តែសីសៈ មិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏ផុតពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ សេចក្តីពិត ព្រះអានន្ទនេះសម្រាក នៅហើយក្នុងខាងក្រៅដោយការចង្ក្រម កាលមិនអាចនឹងញ៉ាំងគុណវិសេសឱ្យកើតឡើងបាន ទើបគិតថា “ព្រះមានព្រះភាគបាន ត្រាស់ពាក្យនេះដល់យើងមិនមែនឬថា ‘ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមរឿយ ៗចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់’[១] ជាធម្មតា ទោសនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ មិនមាន យើងប្រារព្ធសេចក្តីព្យាយាមច្រើនពេកណាស់ ព្រោះហេតុនោះ ទើបចិត្តរបស់យើងប្រព្រឹត្តទៅដើម្បីសេចក្តីរវើរវាយ ណ្ហើយចុះ យើងនឹងប្រកបសេចក្តីព្យាយាមឱ្យស្មើ” ដូច្នេះ ទើបចុះចាកទីចង្ក្រម ឈរលាងជើងក្នុងទីលាងជើង ហើយចូលទៅកាន់វិហារ

១. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ១៣៥/៣០២ ។

(កុដិ)គន់លើគ្រែ ត្រិះរិះថា "នឹងសម្រាកមួយភ្លេត" ក៏បានទម្រេតកាយចុះលើគ្រែ ។ ជើងទាំងពីរផុតពីផែនដី សីសៈមិន ទាន់ដល់ខ្នើយ, ក្នុងចន្លោះនេះ ចិត្តក៏ផុតពីអាសវៈទាំងឡាយមិនប្រកាន់មាំដោយ ឧបាទាន ។ ភាពជាព្រះអរហន្តរបស់ព្រះថេរៈវៀរចាកឥរិយាបថ ៤ ។ ព្រោះដូច្នោះ កាលមានអ្នកសួរថា ក្នុងព្រះសាសនានេះ ភិក្ខុរូបណា មិនដេក មិនអង្គុយ មិនឈរ មិនចង្រ្កម បានសម្រេចព្រះអរហត្ត នឹងឆ្លើយថា ព្រះអានន្ទត្ថេរ ក៏គួរ ។

## ព្រះអានន្ទធ្វើដំណើរទៅចូលកាន់ទីជំនុំសង្ឃ

គ្រានោះ ក្នុងថ្ងៃទី ២ ភិក្ខុថេរៈទាំងឡាយធ្វើភត្តកិច្ចស្រេច រក្សាបាត្រនិងចីវរហើយ ទៅប្រជុំគ្នាក្នុងធម្មសភា ។ ចំណែកព្រះអានន្ទត្ថេរ មានសេចក្តីប្រាថ្នានឹងឱ្យអ្នកដទៃដឹងការសម្រេចភាព ជាព្រះអរហន្តរបស់ខ្លួន មិនបានទៅព្រមនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុទាំងឡាយកាលនឹងគន់លើអាសនៈរបស់ខ្លួន ៗ តាមលំដាប់វស្សា បានអង្គុយវៀរអាសនៈទុកសម្រាប់ព្រះអានន្ទត្ថេរ ។ កាលភិក្ខុពួកខ្លះក្នុងធម្មសភានោះសួរថា "នោះអាសនៈរបស់ភិក្ខុណា ?" ភិក្ខុទាំងឡាយឆ្លើយថា "របស់ព្រះអានន្ទ", ភិក្ខុទាំងឡាយសួរថា "ក៏ព្រះអានន្ទទៅណាហ្ន៎ ?" ក្នុងសម័យនោះ ព្រះថេរៈគិតថា "ឥឡូវនេះ ជាវេលាដែលយើងនឹងទៅ" កាលនឹងសម្តែង

អានុភាពរបស់ខ្លួនក្នុងលំដាប់នោះ ទើបមុជចុះក្នុងផែនដីហើយសម្តែងខ្លួនលើអាសនៈរបស់ខ្លួននោះឯង ។ អាចារ្យពួកមួយពោលថា មកមកអាកាសហើយអង្គុយ ក៏មាន ។

## ព្រះថេរៈចាប់ផ្តើមប្រឹក្សា

កាលព្រះអានន្ទនោះ គង់ហើយយ៉ាងនោះ ទើបព្រះមហាកស្សបត្ថេរប្រឹក្សានឹងភិក្ខុទាំងឡាយថា អ្នកមានអាយុទាំងឡាយ ពួកយើងនឹងសង្គាយនាអ្វីមុន ព្រះធម៌ឬព្រះវិន័យ ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា បពិត្រព្រះមហាកស្សប ធម្មតា ព្រះវិន័យជាអាយុរបស់ព្រះពុទ្ធសាសនា កាលព្រះវិន័យតាំងនៅ ព្រះពុទ្ធសាសនាចាត់ថា តាំងនៅ ព្រោះដូច្នោះ ពួកយើងនឹងសង្គាយនាព្រះវិន័យមុន ។

ព្រះមហាកស្សប. នឹងឱ្យជាធុរៈរបស់អ្នកណា ?

ភិក្ខុទាំងឡាយ. ឱ្យព្រះឧបាលី ។

សួរថា ព្រះអានន្ទមិនអាចឬ ?

ឆ្លើយថា មិនមែនមិនអាចទេ ។ ក៏ម្យ៉ាងទៀត កាលព្រះសម្មាសម្ពុទ្ធនៅមានព្រះជន្មនុ៎ះឯង ទ្រង់អាស្រ័យវិន័យបរិយត្តិ ទើបតាំងព្រះឧបាលី ទុកក្នុងតំណែងឯតទគ្គៈថា "ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ

អ្នកទ្រទ្រង់វិន័យ ដែលជាសាវករបស់តថាគត ស្រេចនឹងឧបាលិ”[១] ដូច្នេះ ; ព្រោះដូច្នោះ ភិក្ខុទាំងឡាយ ទើបប្រឹក្សាគ្នាថា “ពួកយើងនឹងសួរព្រះឧបាលីថេរៈសង្គាយនាព្រះវិន័យ” ដូច្នេះ ។

## ព្រះថេរៈសន្មតខ្លួនជាអ្នកបុច្ឆាវិសជ្ជនាព្រះវិន័យ

លំដាប់នោះព្រះថេរៈក៏បានសន្មតខ្លួនឯង ដើម្បីត្រូវការសួរព្រះវិន័យ ។ ចំណែកព្រះឧបាលីថេរៈក៏បានសន្មតខ្លួន ដើម្បីប្រយោជន៍ដល់ការវិសជ្ជនា ។

ក្នុងការសន្មតនោះ មានព្រះបាលីដូចតទៅនេះ ៖

“គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឱ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃគិតកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលី”[២] ។ ចំណែកព្រះឧបាលីក៏ប្រកាសឱ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃគិតកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុត្រូវសួរព្រះវិន័យ ចំពោះខ្ញុំ ខ្ញុំក៏ត្រូវដោះស្រាយក្នុងកាលឥឡូវនេះ”[៣] ។

---

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។ ២-៣. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៨២/៣៦២ ។

## បុច្ឆានិងវិសជ្ជនាព្រះវិន័យ

ព្រះឧបាលី គ្រាសន្មតខ្លួនយ៉ាងនោះហើយ ក៏ក្រោកឡើងចាកអាសនៈដណ្ដប់ចីវរឆៀងស្មា ថ្វាយបង្គំភិក្ខុថេរៈទាំងឡាយហើយ គង់លើធម្មាសនៈចាប់ផ្លិតវីជនីដ៏វិចិត្រដោយភ្លុក ។ គ្រានោះ ព្រះមហាកស្សបគង់លើថេរាសនៈ ហើយសួរព្រះវិន័យនឹងព្រះឧបាលីដ៏មានអាយុថា "ម្នាលឧបាលីមានអាយុ បឋមបារាជិកសិក្ខាបទ ព្រះមានព្រះភាគទ្រង់បញ្ញត្តិក្នុងទីណា ?

ព្រះឧបាលីឆ្លើយថា ក្នុងនគរវេសាលី លោកម្ចាស់ ។

ព្រះមហាកស្សប. ទ្រង់ប្រារព្ធនឹងបុគ្គលណា ?

ព្រះឧបាលី. ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុជាកូននៃកលន្ទកសេដ្ឋី ។

ព្រះមហាកស្សប. ព្រោះវត្ថុអ្វី ?

ព្រះឧបាលី. ព្រោះសេពមេថុនធម្ម ។

លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទ ចំពោះព្រះឧបាលីមានអាយុ ។ ឧបមានេះថា ព្រះមហាកស្សប សួរវត្ថុផង ។ល។ សួរអនា

បត្តិផង នៃបឋមបារាជិកសិក្ខាបទ យ៉ាងណា ព្រះមហាកស្សប ក៏សួរវត្ថុផង ។ល។ សួរអនាបត្តិផង នៃទុតិយបារាជិក ក៏យ៉ាងនោះ សួរវត្ថុផង ។ល។ សួរអនាបត្តិផង នៃតតិយបារាជិកសិក្ខាបទ ក៏យ៉ាងនោះ សួរវត្ថុផង ។ល។ សួរអនាបត្តិផង នៃចតុត្ថបារាជិកសិក្ខាបទ ក៏យ៉ាងនោះដែរ ។ ព្រះឧបាលីមានអាយុ កាលបើព្រះមហាកស្សបសួរសព្វគ្រប់ហើយ ក៏បានដោះស្រាយសព្វគ្រប់ ។”[១]

## រួបរួមព្រះវិន័យរបស់ភិក្ខុទុកជាពួកៗ

លំដាប់នោះ ព្រះថេរៈទាំងឡាយ បានលើកបារាជិកទាំង ៤ នេះឡើងកាន់សង្គហៈ (ការសង្គាយនា)ថា នេះឈ្មោះបារាជិកកណ្ឌ, ហើយបានតាំងសង្ឃាទិសេស ១៣ ទុកថា តេរសកណ្ឌ, តាំង ២ សិក្ខាបទទុកថា អនិយតៈ, តាំង ៣០ សិក្ខាបទទុកថា និស្សគ្គិយបាចិត្តិយ, តាំង ៩២ សិក្ខាបទទុកថា បាចិត្តិយ, តាំង ៤ សិក្ខាបទទុកថា បាដិទេសនីយៈ, តាំង ៧៥ សិក្ខាបទទុកថា សេក្ខិយៈ, (និង) តាំងធម៌ ៧ ប្រការទុកថា អធិករណសមថៈ, ដូច្នេះ ។

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៨២/៣៦២-៤ ។

# រួបរួមវិន័យរបស់ភិក្ខុនីទុកជាពួកៗ

លុះព្រះថេរៈទាំងឡាយ លើកមហាវិភង្គឡើងកាន់សង្គហៈយ៉ាងនេះហើយ ទើបតាំង ៨ សិក្ខាបទក្នុងភិក្ខុនីវិភង្គទុកថា នេះឈ្មោះបារាជិកកណ្ឌ, តាំង ១៧ សិក្ខាបទទុកថា សត្តរសកណ្ឌ, តាំង ៣០ សិក្ខាបទទុកថា និស្សគ្គិយបាចិត្តិយ, តាំង ១៦៦ សិក្ខាបទទុកថា បាចិត្តិយ, តាំង ៨ សិក្ខាបទទុកថា បាដិទេសនីយៈ, តាំង ៧៥ សិក្ខាបទទុកថា សេក្ខិយៈ, (និង) តាំងធម៌ ៧ ប្រការទុកថា អធិករណសមថៈ, ដូច្នេះ ។

ព្រះថេរៈទាំងឡាយ គ្រាលើកភិក្ខុនីវិភង្គឡើងកាន់សង្គហៈ យ៉ាងនេះហើយ ទើបបានលើកសូម្បីខន្ធកៈនិងបរិវារឡើង(កាន់សង្គាយនា) ដោយឧបាយនោះឯង ។ ព្រះវិន័យបិដកព្រមទាំងឧភតោវិភង្គខន្ធកៈ និងបរិវារនេះ ព្រះថេរៈទាំងឡាយ លើកឡើងកាន់សង្គហៈហើយ ដោយប្រការដូច្នេះ ។

ព្រះមហាកស្សបត្ថេរ បានសួរវិន័យបិដកទាំងអស់ ។ ព្រះឧបាលីថេរៈក៏បានវិសជ្ជនាហើយ ។ ក្នុងទីបំផុតនៃការបុច្ឆា និងវិសជ្ជនា ព្រះអរហន្តចំនួន ៥០០ អង្គ បានធ្វើការស្វាធ្យាយជាគណៈ ដោយន័យដែលលើកឡើងកាន់សង្គហៈនោះឯង ។ ក្នុងអវសាននៃការសង្គាយនាព្រះវិន័យ ព្រះឧបាលីថេរៈដាក់ផ្ចិតវីជនី ដែលវិចិត្រដោយភ្លុកហើយ ចុះចាកពីធម្មាសនៈថ្វាយបង្គំពួកភិក្ខុចាស់ ហើយគង់លើអាសនៈរបស់ខ្លួន ។

## ចាប់ផ្តើមសង្គាយនាព្រះសូត្រ

ព្រះមហាកស្សបៈ គ្រាសង្គាយនាព្រះវិន័យហើយ ប្រាថ្នានឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា កាលពួកយើងនឹងសង្គាយនាព្រះធម៌ គួរនឹងធ្វើឱ្យជាធុរៈរបស់អ្នកណា ? ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា ឱ្យព្រះអានន្ទត្ថេរ ។

## ពាក្យសូត្រសន្មតបុច្ឆាវិសជ្ជនាព្រះសូត្រ

"ពដ៏កាលនោះ ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឱ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះព្រះអានន្ទ"[១] ។ "ព្រះអានន្ទមានអាយុ បានប្រកាសសង្ឃឱ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុនឹងសួរធម៌ចំពោះខ្ញុំ ខ្ញុំគប្បីដោះស្រាយក្នុងកាលឥឡូវនេះ"[២] ។

---

១.២. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៨៣/៣៦៤-៥ ។

## បុច្ឆានិងវិសជ្ជនាព្រះសូត្រ

"លំដាប់នោះឯង ព្រះអានន្ទក្រោកឡើងចាកពីអាសនៈ ដណ្ដប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំភិក្ខុជាថេរៈទាំងឡាយ ហើយគង់លើធម្មាសនៈចាប់ផ្លិតវីជនីដែលវិចិត្រដោយភ្លុក ។ ព្រះមហាកស្សបត្ថេរ បានសួរព្រះធម៌ចំពោះព្រះអានន្ទត្ថេរដូច្នេះថា ម្នាលអានន្ទមានអាយុ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគទ្រង់សម្ដែងក្នុងទីណា ?

ព្រះអានន្ទឆ្លើយថា បពិត្រព្រះថេរៈដ៏ចម្រើន ព្រះមានព្រះភាគទ្រង់សម្ដែង ក្នុងព្រះដំណាក់នៃព្រះរាជា នៅនាអម្ពលដ្ឋិកាវែន ជាចន្លោះនៃក្រុងរាជគ្រឹះផង ជាចន្លោះនៃនាលន្ទាគ្រាមផង ។

ព្រះមហាកស្សប. ទ្រង់ប្រារព្ធនឹងបុគ្គលណា ?

ព្រះអានន្ទ. ទ្រង់ប្រារព្ធនឹងសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។

គ្រានោះ ព្រះមហាកស្សបមានអាយុ សួរនិទានផង សួរបុគ្គលផងនៃព្រហ្មជាលសូត្រ ចំពោះព្រះអានន្ទមានអាយុ ។

ហើយព្រះមហាកស្សបសួរតទៅទៀតថា ម្នាលអាវុសោអានន្ទ សាមញ្ញផលសូត្រ ព្រះមានព្រះភាគទ្រង់សម្ដែងក្នុងទីណា ?

ព្រះអានន្ទ. បពិត្រលោកម្ចាស់ដ៏ចម្រើន ទ្រង់សម្ដែងក្នុងជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ លោកម្ចាស់ ។

ព្រះមហាកស្សប. ទ្រង់សម្ដែងជាមួយនឹងបុគ្គលណា ?

ព្រះអានន្ទ. ទ្រង់សម្ដែងជាមួយនឹងព្រះបាទអជាតសត្តុរាជ វេទេហិបុត្ត ។

គ្រានោះ ព្រះមហាកស្សបមានអាយុ សួរនិទានផង សួរ បុគ្គលផង នៃសាមញ្ញផលសូត្រ ចំពោះព្រះអានន្ទមានអាយុ ។ ហើយសួរនូវនិកាយទាំង ៥ ដោយឧបាយនេះឯង”[១] ដូច្នេះ ។

## និកាយ ៥

ដែលឈ្មោះថា និកាយ ៥ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ខុទ្ទកនិកាយ ។ បណ្ដានិកាយទាំងនោះ ព្រះពុទ្ធវចនៈដ៏សេស វៀរលែងតែ ៤ និកាយចេញ ឈ្មោះថា ខុទ្ទកនិកាយ ។ ក្នុងខុទ្ទកនិកាយនោះ ព្រះវិន័យ ឧបាលីថេរៈ បានវិសជ្ជនាហើយ ។ ខុទ្ទកនិកាយដ៏សេស ៤ និកាយទៀត ព្រះអានន្ទត្ថេរ វិសជ្ជនា ។

១. វិន. ចុល្ល. បញ្ចសតិកក្ខន្ធកៈ. ១១. ២៨៣/៣៦៤ ។

## ព្រះពុទ្ធវចនៈមានចំនួនផ្សេងៗ គ្នា

ព្រះពុទ្ធវចនៈទាំងអស់នេះ គប្បីជ្រាបថា មានតែមួយយ៉ាង ដោយអំណាចរស, មាន ២ យ៉ាង ដោយអំណាចធម៌និងវិន័យ, មាន ៣ យ៉ាង ដោយអំណាចបឋមៈ មជ្ឈិមៈ បច្ឆិមៈ, មួយទៀត មាន ៣ យ៉ាង ដោយអំណាចបិដក, មាន ៥ យ៉ាង ដោយអំណាចនិកាយ, មាន ៩ យ៉ាង ដោយអំណាចអង្គ, មាន ៨៤,០០០ យ៉ាង ដោយអំណាចព្រះធម្មក្ខន្ធ ។

## ព្រះពុទ្ធវចនៈមានតែមួយយ៉ាង

ព្រះពុទ្ធវចនៈ ឈ្មោះថា មានតែមួយយ៉ាង ដោយអំណាចរស យ៉ាងណា ? គឺ ដោយសភាពពិត ព្រះមានព្រះភាគបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ដរាបដល់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងរវាងនេះទ្រង់ទូន្មានទេវតា មនុស្ស នាគ និងយក្ខ ឬទ្រង់ពិចារណា រហូតដល់អស់វេលា ៤៥ ឆ្នាំ បានត្រាស់ព្រះពុទ្ធវចនៈណាទុក ព្រះពុទ្ធវចនៈនោះទាំងអស់មានរសតែមួយយ៉ាង គឺ មានវិមុត្តិជារសប៉ុណ្ណោះ ។ ព្រះពុទ្ធវចនៈ ឈ្មោះថា មានតែមួយយ៉ាង ដោយអំណាចរស ដោយប្រការដូច្នេះ ។

## ព្រះពុទ្ធវចនៈមាន ២ យ៉ាង

ព្រះពុទ្ធវចនៈឈ្មោះថា មាន ២ យ៉ាង ដោយអំណាចធម៌ និង វិន័យយ៉ាងណា ? គឺ ដោយព្រះពុទ្ធវចនៈទាំងអស់នេះឯង រមែងដល់ការរាប់ថា ព្រះធម៌និងវិន័យ ។ បណ្ដាធម៌និងវិន័យនោះ វិន័យបិដក ឈ្មោះថា វិន័យ ។ ព្រះពុទ្ធវចនៈដែលសល់ ឈ្មោះថា ធម៌ ។ ព្រោះហេតុនោះ ទើបព្រះមហាកស្សបបានពោលទុកហើយថា "អ្នកមានអាយុ បើដូច្នោះ ពួកយើងគប្បីសង្គាយនាធម៌និងវិន័យ និងថា យើងសួរ ព្រះវិន័យទីងឧបាលីដ៏មានអាយុ គប្បីសួរព្រះធម៌នឹងព្រះអានន្ទ ដ៏មានអាយុ" ដូច្នេះ ។ ព្រះពុទ្ធវចនៈ ឈ្មោះថា មាន ២ យ៉ាង ដោយអំណាចធម៌ និង វិន័យ ដោយប្រការដូច្នេះ ។

## ព្រះពុទ្ធវចនៈមាន ៣ យ៉ាង

ព្រះពុទ្ធវចនៈមាន ៣ យ៉ាង ដោយអំណាចបឋមៈ មជ្ឈិមៈ និង បច្ឆិមៈ យ៉ាងណា ? គឺ ការពិត ព្រះពុទ្ធវចនៈនេះទាំងអស់ទុំះឯង បែងចែកជា ៣ ប្រភេទ គឺ បឋមពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ (និង) បច្ឆិមពុទ្ធវចនៈ ។

បណ្ដាព្រះពុទ្ធវចនៈ ៣ យ៉ាងនោះ ព្រះពុទ្ធ វចនៈថា

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

"កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិញ្ញាណរលំតែ) ស្វះស្វែងរកជាងផ្ទះ គឺ តណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្ដីកើត ជាទុក្ខរឿយ ៗ ។ នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកឯងនឹងធ្វើផ្ទះ(របស់តថាគត)ទៀតមិនបានឡើយ ឆ្អឹងជំនី គឺ កិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ កំពូលផ្ទះ គឺ អវិជ្ជា តថាគត កម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ[១] ដូច្នេះ ។ នេះឈ្មោះថា បឋមពុទ្ធវចនៈ ។

---

១. ខុទ្ទ. ធម្ម. ជរាវគ្គ. ៥២. ២១/៥៤ ។

អាចារ្យពួកខ្លះពោលដល់ឧទានគាថាក្នុងខន្ធកៈថា "ធម៌ទាំងឡាយរមែងប្រាកដ ... ... ក្នុងកាលណា"[១] ដូច្នេះជាដើម ឈ្មោះថា **បឋមពុទ្ធវចនៈ** ។

ក៏គាថានោះ កើតដល់ព្រះមានព្រះភាគដែលទ្រង់សម្រេច ជាព្រះសព្វញ្ញូ ទ្រង់ពិចារណាបច្ចយាការ ក្នុងព្រះញាណដែលសម្រេចដោយសោមនស្ស ក្នុងថ្ងៃបាដិបទ បណ្ឌិតគប្បីជ្រាបថា ឧទានគាថា ។ មួយទៀត ព្រះពុទ្ធបានត្រាស់ព្រះតម្រាស់ណា ក្នុងគ្រាបរិនិព្វានថា "ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ : ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹងសង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេច ដោយការមិនប្រមាទចុះ"[២] នេះ ឈ្មោះថា **បច្ឆិមពុទ្ធវចនៈ** ។

ព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងចន្លោះនៃកាលទាំង ២នោះ ឈ្មោះថា **មជ្ឈិមពុទ្ធវចនៈ** ។ ព្រះពុទ្ធវចនៈ ឈ្មោះថា មាន ៣ យ៉ាង ដោយអំណាចជាបឋមៈ មជ្ឈិមៈ និងបច្ឆិមៈ ដោយប្រការដូច្នេះ ។

---

១. វិន. មហា. មហាខន្ធក. ៦. ១/៣ ។ ២. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ១៤៣/៣២៤ ។

## បិដក ៣

ព្រះពុទ្ធវចនៈទាំងពួងចែកជា ៣ យ៉ាង ដោយអំណាចនៃបិដក យ៉ាងណា ?

ក៏ព្រះពុទ្ធវចនៈសព្វទាំងពួង មាន ៣ ប្រការប៉ុណ្ណោះ គឺ ព្រះវិន័យបិដក ព្រះសុត្តន្តបិដក ព្រះអភិធម្មបិដក ។ ក្នុង៣ បិដកនោះ ព្រះពុទ្ធវចនៈនេះ គឺ ប្រមូលរួមព្រះពុទ្ធវចនៈទាំងអស់ ទាំងដែលចងក្រងក្នុងបឋមសង្គាយនា ទាំងដែលចងក្រងក្នុងកាលខាងក្រោយ ជាបាតិមោក្ខ ២ ផ្នែក, វិភង្គ ២, ខន្ធកៈ ២២, បរិវារ ១៦, ឈ្មោះវិន័យបិដក ។ ព្រះពុទ្ធវចនៈនេះគឺ ទីឃនិកាយ ដែលរួបរួមព្រះសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម, មជ្ឈិមនិកាយ ដែលរួបរួមព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម, សំយុត្តនិកាយ ដែលរួបរួមព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម, អង្គុត្តរនិកាយ ដែលរួបរួមព្រះសូត្រ ៩,៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម, ខុទ្ទកនិកាយ ១៥ ប្រភេទ ដោយអំណាចនៃខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទា អបទាន ពុទ្ធវង្ស ចរិយាបិដក ឈ្មោះសុត្តន្តបិដក ។ ព្រះពុទ្ធវចនៈនេះ គឺ ធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិ កថាវត្ថុ យមក បដ្ឋាន ឈ្មោះអភិធម្មបិដក ។

## អត្ថាធិប្បាយពាក្យថា វិន័យ

បណ្ដាព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្មនោះ ព្រះវិន័យ ដែលបណ្ឌិតអ្នកដឹងអត្ថនៃព្រះវិន័យទាំងឡាយពោលថា វិន័យ ព្រោះមានន័យផ្សេង ៗ ព្រោះមានន័យដ៏ពិសេស និងព្រោះទូន្មាននូវកាយនិងវាចា ។

ពិតមែន ក្នុងព្រះវិន័យនេះ មានន័យផ្សេង ៗ គឺមានបាតិមោក្ខុទ្ទេស៥ កងអាបត្តិ៧ មានបារាជិកជាដើម មាតិកានិងន័យមានវិភង្គជាដើមជាប្រភេទ និងន័យ គឺអនុប្បញ្ញត្តិ ជាពិសេស គឺមានន័យដែលធ្វើឱ្យមាំនិងធ្វើឱ្យធូរជាប្រយោជន៍ ។ មួយទៀត ព្រះវិន័យនេះ រមែងទូន្មានកាយនិងវាចា ព្រោះហាមនូវអជ្ឈាចារមកកាយ និងមកវាចា ។ ព្រោះដូច្នោះ ព្រះវិន័យនេះ ទើបលោកពោលថា វិន័យ ព្រោះមានន័យផ្សេង ៗ ព្រោះមានន័យពិសេស និងព្រោះទូន្មានកាយនិងវាចា ។ ដោយហេតុនោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងអត្ថាធិប្បាយពាក្យនៃវិន័យនេះ ទើបខ្ញុំព្រះករុណាពោលគាថាប្រព័ន្ធនេះទុកថា ៖

> វិវិធវិសេសនយត្តា វិនយនតោ ចេវ កាយវាចានំ
> វិនយត្ថវិទូហិ អយំ វិនយោ វិនយោតិ អក្ខាតោ ។
>
> ព្រះវិន័យនេះ ដែលបណ្ឌិតដឹងអត្ថនៃព្រះវិន័យទាំងឡាយ
> ពោលថា វិន័យ ព្រោះមានន័យផ្សេង ៗ ព្រោះមានន័យ
> ពិសេស និងព្រោះទូន្មានកាយ និង វាចា ដូច្នេះ ។

## អត្ថាធិប្បាយពាក្យថា សូត្រ

ចំណែកព្រះសូត្រក្រៅនេះ លោកពោលថា សូត្រ ព្រោះផ្តល់ប្រយោជន៍ ព្រោះមានអត្ថដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រោះបញ្ចេញប្រយោជន៍ ព្រោះបង្ហូរប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយសរសៃអំបោះ ។

ពិតមែន ព្រះសូត្រនោះ រមែងផ្តល់នូវប្រយោជន៍ផ្សេង ដោយប្រយោជន៍ មានប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃជាដើម ។ មួយទៀត ប្រយោជន៍ទាំងឡាយដែលព្រះមានព្រះភាគ ត្រាស់ល្អហើយក្នុងព្រះសូត្រនេះ ព្រោះត្រាស់ដោយអនុលោមដល់អធ្យាស្រ័យនៃវេនេយ្យ ។ មួយទៀត ព្រះសូត្រនេះ រមែងផលិតប្រយោជន៍ លោកអធិប្បាយថា រមែងផលិតចេញនូវផល ដូចស្រូវ ដូច្នោះ ។

មួយទៀត ព្រះសូត្រនេះ រមែងបង្ហូរប្រយោជន៍ទាំងនោះ លោកអធិប្បាយថា រមែងហូរដូចមេគោបង្ហូរទឹកដោះ ដូច្នោះ ។ មួយទៀត ព្រះសូត្រនេះ រមែងការពារ លោកអធិប្បាយថា រមែងរក្សាដោយល្អនូវប្រយោជន៍ទាំងនោះ ។ មួយទៀត ព្រះសូត្រនេះមានចំណែកស្មើដោយសរសៃអំបោះ ។

ដូចយ៉ាងថា សរសៃខ្សែបន្ទាត់ រមែងជាប្រមាណរបស់ ជាងឈើយ៉ាងណា សូម្បីព្រះសូត្រនេះ ក៏រមែងជាប្រមាណនៃវិញ្ញូជនយ៉ាងនោះ ។ មួយទៀត ដូចផ្កាឈើដែលគេក្រងទុក ដោយសរសៃអំបោះដែលខ្យល់ឱ្យរាត់រាយខ្ចាត់ខ្ចាយមិនបានយ៉ាងណា ប្រយោជន៍ទាំងឡាយ ដែលទ្រង់ប្រមូលទុកដោយព្រះសូត្រ នេះ រមែងមិនរាត់រាយ មិនខ្ចាត់ខ្ចាយយ៉ាងនោះ ។ ដោយហេតុនោះ ដើម្បីភាពជាអ្នកឆ្លាតក្នុងអត្ថាធិប្បាយពាក្យនៃព្រះសូត្រនេះ ទើបខ្ញុំព្រះករុណាពោលគាថា ប្រព័ន្ធនេះទុកថា

អត្ថានំ សូចនតោ សុវុត្តតោ សវនតោថ សូទនតោ
សុត្តាណា សុត្តសភាគតោ ច សុត្តន្តិ អក្ខាតំ ។

ព្រះសូត្រលោកពោលថា សូត្រ ព្រោះផ្តល់ប្រយោជន៍ ព្រោះមានអត្ថ ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រោះបញ្ចេញប្រយោជន៍ ព្រោះបង្ហូរប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយអំបោះ ដូច្នេះ ។

## អត្ថាធិប្បាយពាក្យថា អភិធម្ម

ចំណែកព្រះអភិធម្មក្រៅនេះ

ដោយហេតុដែលធម៌ទាំងឡាយ ដែលមានសេចក្ដីចម្រើន ដែលមានសេចក្ដីកំណត់ដឹង ដែលបុគ្គលគោរពបូជា ដែល បណ្ឌិតកំណត់ហើយ និងដែលក្រៃលែង ដែលព្រះមាន ព្រះភាគត្រាស់ទុកហើយក្នុងព្រះអភិធម្មនេះ ដូច្នោះ ទើប លោកពោលថា អភិធម្ម ។

ក៏អភិសព្ទនេះ រមែងប្រាកដក្នុងអត្ថថា ចម្រើន, ប្រាកដក្នុងអត្ថថា មានសេចក្ដីកំណត់ចំណាំ, ប្រាកដក្នុងអត្ថថា ដែលបុគ្គលបូជាហើយ, ប្រាកដក្នុងអត្ថថា ដែលបណ្ឌិតកំណត់កាត់ហើយ និងប្រាកដក្នុងអត្ថថា ក្រៃលែង ។ ពិតមែន អភិ សព្ទនេះ មកក្នុងអត្ថថា ចម្រើន ក្នុងពាក្យជាដើមថា "**ពាឡ្ហា មេ អាវុសោ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ :** ទុក្ខវេទនា របស់ខ្ញុំព្រះអង្គជូន់ណាស់ តែងចម្រើនឡើង"[១] ដូច្នេះ ។ មក ក្នុងអត្ថថា មានការកំណត់ដឹងក្នុងពាក្យជាដើមថា "**យា តា រត្តិយោ អភិញ្ញាតា អភិលក្ខិតា :** រាត្រីទាំងឡាយណា ដែលគេដឹងច្បាស់

---

១. សំយុ. សឡា. គិលានវគ្គ. ៣៥. ៨៨/១០១ ។

ដែលគេកំណត់ដឹង"[១] ដូច្នេះ ។ មកក្នុងអត្ថថា ដែលបុគ្គលគោរពបូជា ក្នុងពាក្យថា "រាជាភិរាជា មនុជិន្ទោ : បពិត្រព្រះគោតម ព្រះអង្គជាស្តេចដែលពួកស្តេចគោរពបូជា ជាធំជាងពួកមនុស្ស"[២] ជាដើម ។ មកក្នុងអត្ថថា ដែលបណ្ឌិតកំណត់ហើយ ក្នុងពាក្យជាដើមថា "បដិពលោ វិនេតុំ អភិធម្មេ អភិវិនយេ : ភិក្ខុអាចដើម្បីទូន្មានអន្តេវាសិក ឬសទ្ធិវិហារិក ក្នុងអភិធម្ម ក្នុងអភិវិន័យ"[៣] លោកអធិប្បាយថា ជាអ្នកអាចនឹងណែនាំក្នុងធម៌និងវិន័យដែលវៀរចាកការលាយឡំគ្នា ។ មកក្នុងអត្ថថា ក្រៃលែង ក្នុងពាក្យជាដើមថា "អភិក្កន្តេន វណ្ណេន : មានសម្បុរល្អក្រៃលែង[៤] ដូច្នេះ ។

ក៏ព្រះមានព្រះភាគត្រាស់ធម៌ទាំងឡាយក្នុងព្រះអភិធម្មនេះ មានសេចក្តីចម្រើនខ្លះ ដោយន័យជាដើមថា "រូបូបបត្តិយា មគ្គំ : បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព[៥] មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ : ភិក្ខុមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិស១[៦] ។

---

១. មជ្ឈិ. មូល. ភយភេរវសូត្រ. ២០. ៤៥/៦៦ ។ ២. ខុទ្ទ. សុត្ត. សេលសូត្រ. ៥៤. ៦៣/១៩៦ ។ ៣. វិន. មហា. មហាខន្ធក. ៦. ៩៨/២១៩; ៩៩/២២៩ ។ ៤. ខុទ្ទ. វិមា. បទីបវិមាន. ៥៥. ៩/១៥; ១០/១៧; ១៣/២២ ... ។ ៥. អភិ. សង្គ. រូបាវចរកុសល. ៧៨. ១៣៩/៨០ ។ ៦. អភិ. វិភ. អប្បមញ្ញាវិភង្គ. ៨១. ៤៩០/៣១២ ។

ឈ្មោះថា មានសេចក្តីកំណត់ចំណាំខ្លះ ព្រោះជាធម៌គួរកំណត់បានដោយកម្មទ្វារ និងបដិបទា ដែលសម្បយុត្តដោយអារម្មណ៍ជាដើម ដោយន័យជាដើមថា "រូបារម្មណំ វា សទ្ទារម្មណំ វា : ចិត្ត ... មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី[១] ។ ដែលបុគ្គលបូជាហើយខ្លះអធិប្បាយថា គួរបូជា ដោយន័យជាដើមថា "សេក្ខា ធម្មា អសេក្ខា ធម្មា : ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល"[២]; "លោកុត្តរា ធម្មា : ពួកធម៌ជាលោកុត្តរៈ"[៣] ។ ឈ្មោះថា ដែលបណ្ឌិតកំណត់កាត់ខ្លះ ព្រោះជាធម៌ដែលលោកកំណត់តាមសភាព ដោយន័យជាដើមថា "តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ : ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនាកើតមាន"[៤] ។ សូម្បីធម៌ទាំងឡាយដ៏ក្រៃលែង ទ្រង់ត្រាស់ទុកដោយន័យជាដើមថា "មហគ្គតា ធម្មា អប្បមាណា ធម្មា : ពួកធម៌ដល់ភាពជាធំ ពួកធម៌ប្រមាណមិនបាន"[៥] "អនុត្តរា ធម្មា : ពួកធម៌មិនមានឧត្តរៈ"[៦] ។ ដោយហេតុនោះ ដើម្បី

---

១. អភិ. វិភ. បច្ចយាការវិភង្គ. ៨១. ៣៧/១៩ ។ ២. អភិ. សង្គ. អភិធម្មមាតិកា. ៧៨. ១/២ ។ ៣. អភិ. សង្គ. អភិធម្មមាតិកា. ៧៨. ៣/៤ ។ ៤. អភិ. សង្គ. កាមាវចរកុសល. ៧៨. ១៦/១៦ ។ ៥. អភិ. សង្គ. អភិធម្មមាតិកា. ៧៨. ១/៣ ។ ៦. អភិ. សង្គ. អភិធម្មមាតិកា. ៧៨. ១៤/១៣ ។

ភាពជាអ្នកឆ្លាតក្នុងអត្ថាធិប្បាយពាក្យនៃព្រះអភិធម្មនេះ ទើបខ្ញុំព្រះករុណាពោលគាថាប្រព័ន្ធនេះទុកថា ៖

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។

ដោយហេតុដែលធម៌ទាំងឡាយ មានសេចក្តីចម្រើន មានសេចក្តីកំណត់ចំណាំ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌ដែលបណ្ឌិតកាត់ជាចំណែក ៗ និងជាធម៌ដ៏ក្រៃលែងដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយក្នុងព្រះអភិធម្មនេះ ដូច្នោះ ទើបលោកពោលថា **អភិធម្ម** ។

ចំណែកបិដកស័ព្ទណា ជាស័ព្ទដែលមិនពិសេសក្នុងព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្មនេះ បិដកស័ព្ទនោះ

បិដកំ បិដកត្ថវិទូ បរិយត្តិព្ភាជនត្ថតោ អាហុ
តេន សមោធានេត្វា តយោបិ វិនយាទយោ ញេយ្យា ។

ដែលបណ្ឌិតទាំងឡាយ អ្នកដឹងអត្ថនៃបិដក ពោលថា បិដក ដោយអត្ថថា បរិយត្តិនិងភាជនៈ ស័ព្ទទាំង៣មានវិន័យជាដើម បណ្ឌិតគប្បីឱ្យប្រជុំចុះដោយបិដកស័ព្ទនោះហើយ ទើបជ្រាប ។

## បិដកប្រៀបដូចកញ្ជើ

ពិតមែន សូម្បីបរិយត្តិ លោកក៏ហៅថា បិដក ក្នុងពាក្យទាំងឡាយជាដើមថា "មា បិដកសម្បទានេន : កុំជឿប្រកាន់ដោយការអាងក្បួនតម្រា"[១] ។

សូម្បីភាជនៈយ៉ាងណាមួយ លោកក៏ហៅថា បិដក ក្នុងពាក្យជាដើមថា "អថ បុរិសោ អាគច្ឆេយ្យ កុទាលបិដកំ អាទាយ : កាលនោះ បុរសម្នាក់កាន់ចប និងកញ្ជើដើរមក"[២] ។ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ អ្នកដឹងអត្ថនៃ បិដកពោលថា បិដក ដោយអត្ថថា បរិយត្តិនិងភាជនៈ ។

ឥឡូវនេះ គប្បីជ្រាបអត្ថនៃបាទគាថាថា តេន សមោធានេត្វា តយោបិ វិនយាទយោ ញេយ្យា ដោយន័យយ៉ាងនេះ សព្ទសូម្បីទាំង ៣ មានវិន័យជាដើមទាំងនោះ ដែលបណ្ឌិតគប្បីសង្ខេប ចូលជាសមាសជាមួយនឹងបិដកសព្ទដែលមានអត្ថ ២ យ៉ាង នោះហើយ គប្បីជ្រាបយ៉ាងនេះថា វិន័យនោះផង ឈ្មោះថា បិដកផង ព្រោះជាបរិយត្តិ និង

---

១. អង្គុ. តិក. ៤១. ៦៧/២១៨; ចតុក្ក. មហាវគ្គ. ៤៣. ៤៣/១២២ ។

២. សំយុ. និទាន. ទុក្ខវគ្គ. ៣១. ២០៩/១៩៣; ២១១/១៩៥ ។

ព្រោះជាភាជនៈនៃសេចក្តីនោះ ៗ ហេតុនោះ ទើបឈ្មោះថា វិន័យបិដក, សុត្រនោះផង ឈ្មោះថា បិដកផង ដោយន័យតាមដែលពោលហើយនោះឯង ហេតុនោះ ទើបឈ្មោះថា សុត្តន្តបិដក, អភិធម្មនោះផង ឈ្មោះថា បិដកផង ដោយន័យតាមដែលពោលហើយនោះឯង ហេតុនោះ ទើបឈ្មោះថា អភិធម្មបិដក ។ ក៏គ្រាជ្រាបយ៉ាងនេះហើយ ដើម្បីភាពជា អ្នកឆ្លាតដោយប្រការផ្សេង ៗ ក្នុងបិដកទាំងនោះឯងសូម្បីទៀត

បណ្ឌិតគប្បីសម្តែងសេចក្តីផ្សេងគ្នានៃទេសនា សាសនា
កថា និង សិក្ខា បហានៈ គម្ភីរភាពក្នុងបិដកទាំងនោះ
តាមសមគួរ ។ ភិក្ខុ រមែងដល់នូវសេចក្តីផ្សេងគ្នានៃ
បរិយត្តិក្តី សម្បត្តិ និងវិបត្តិក្តី យ៉ាងណា ក្នុងបិដកណា
មានវិន័យបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បី
ប្រកាសសេចក្តីផ្សេងគ្នានៃបរិយត្តិជាដើម សូម្បីទាំងអស់
នោះ ដោយប្រការនោះ ។

វាចាគ្រឿងសម្តែងនិងវាចាគ្រឿងប្រកាស ក្នុងបិដកទាំង ៣ នោះ ដូចតទៅនេះ ៖

ពិតមែន បិដកទាំង ៣ នេះ លោកហៅថា អាណាទេសនា វោហារទេសនាបរមត្ថទេសនា និងយថាបរាធសាសន៍ យថានុលោម

សាសន៍ យថាធម្មសាសន៍ និងថា សំវាសំវរកថា ទិដ្ឋិវិនិវេឋនកថា និងនាមរូបបរិច្ឆេទកថា តាមលំដាប់ ។ សេចក្ដីពិត បណ្ដាបិដកទាំង ៣ នេះ វិន័យបិដកលោកឱ្យ ឈ្មោះថា អាណាទេសនា ព្រោះព្រះមានព្រះភាគអ្នកគួរដល់អាជ្ញា ទ្រង់សម្ដែងទុកដោយជាបិដកមកច្រើនដោយច្បាប់, សុត្តន្តបិដក លោកឱ្យឈ្មោះថា វោហារទេសនា ព្រោះព្រះមានព្រះភាគទ្រង់ឆ្លាតក្នុងវោហារ ទ្រង់សម្ដែងទុកជាបិដកច្រើនដោយវោហារ, អភិធម្មបិដក លោកឱ្យឈ្មោះថា បរមត្ថទេសនា ព្រោះព្រះមានព្រះភាគ ទ្រង់ឆ្លាតក្នុងបរមត្ថ ទ្រង់សម្ដែងទុកដោយជាបិដកច្រើន ដោយបរមត្ថ ។ មួយទៀត បិដកដំបូងលោកឱ្យឈ្មោះថា យថាបរាធសាសន៍ ព្រោះសត្វទាំងឡាយដែលជាអ្នកមានសេចក្ដីខុសច្រើននោះ ព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅតាមសេចក្ដីខុសក្នុងបិដកនេះ ។ បិដកទីពីរលោកឱ្យឈ្មោះថា យថានុលោមសាសន៍ ព្រោះសត្វទាំងឡាយ អ្នកមានអជ្ឈាស្រ័យអនុស័យ ចរិយា និងអធិមុត្តិ មិនមែនដូចគ្នា ព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅតាមសមគួរក្នុងបិដកនេះ, បិដកទីបី លោកឱ្យឈ្មោះថា យថាធម្មសាសនៈ ព្រោះសត្វទាំងឡាយ ដែលមានការសម្គាល់ក្នុងវត្ថុត្រឹមតែជាកងធម៌ថា "យើង" ថា "របស់យើង" ព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅតាមធម៌ក្នុងបិដកនេះ ។ មួយទៀត បិដកដំបូង លោកឱ្យ

ឈ្មោះថា សំវរាសំវរកថា ព្រោះការសង្រួមតូចនិងធំ ដែលជាបដិបក្ខចំពោះការល្មើស ព្រះមានព្រះភាគត្រាស់ ទុកក្នុងបិដកនេះ, បិដកទីពីរលោកឱ្យឈ្មោះថា ទិដ្ឋិវិនិវេឋនកថា ព្រោះការកម្ចាត់ទិដ្ឋិដែលជាបដិបក្ខចំពោះទិដ្ឋិ ៦២ ព្រះមានព្រះភាគ ត្រាស់ទុកក្នុងបិដកនេះ, បិដកទីបីលោកឱ្យឈ្មោះថា នាមរូបបរិច្ឆេទកថា ព្រោះការកំណត់នាមរូប ដែលជាបដិបក្ខចំពោះកិលេស មានរាគៈជាដើម ព្រះមានព្រះភាគត្រាស់ទុកក្នុងបិដកនេះ ។ ក៏ឯក្នុងបិដកទាំងបីនេះ បណ្ឌិតគប្បីជ្រាបសិក្ខា ៣ បហានៈ ៣ គម្ភីរភាព ៤ ប្រការ ។ ពិតមែន អធិសីលសិក្ខាលោកពោលទុកដោយពិសេស ក្នុងព្រះវិន័យបិដក, អធិចិត្តសិក្ខា លោកពោលទុកដោយពិសេស ក្នុងព្រះសុត្តន្តបិដក, អធិបញ្ញាសិក្ខា លោកពោលទុកដោយពិសេសក្នុងព្រះអភិធម្មបិដក ។ មួយទៀត ការលះវីតិក្កមកិលេសលោកពោលទុកក្នុងវិន័យបិដក ព្រោះសីលជាសត្រូវចំពោះសេចក្តីល្មើសនៃកិលេសទាំងឡាយ, ការលះបរិយុដ្ឋានកិលេស លោកពោលទុកក្នុងព្រះសុត្តន្តបិដក ព្រោះសមាធិជាសត្រូវចំពោះបរិយុដ្ឋានកិលេស, ការលះអនុស័យកិលេស លោកពោលទុកក្នុងអភិធម្មបិដក ព្រោះបញ្ញាជាសត្រូវចំពោះអនុស័យកិលេស ។ មួយទៀត ការលះកិលេសទាំងឡាយដោយអង្គនោះ ៗ លោកពោលទុកក្នុងបិដកទីមួយ, ការលះដោយការគ្របសង្កត់ និងកាត់ដាច់ លោកពោលទុកក្នុងបិដក ២ ក្រៅនេះ ។

មួយទៀត ការលះសន្ដិលេស គឺ ទុច្ចរិត លោកពោលទុកក្នុងបិដកទីមួយ, ការលះកិលេស គឺ តណ្ហា និងទិដ្ឋិ លោកពោលទុកក្នុងបិដក ២ ក្រៅនេះ ។ ក៏បណ្ឌិតគប្បីជ្រាបសេចក្ដីដែលព្រះពុទ្ធវចនៈ ជាគុណជ្រាលជ្រៅដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធទាំង ៤ យ៉ាង ក្នុងបិដកទាំង ៣ នេះ តែមួយយ៉ាង ៗ ។

## អធិប្បាយគម្ភីរភាព ៤ យ៉ាង

បណ្ដាគម្ភីរភាពទាំង ៤ នោះ ព្រះបាលី ឈ្មោះថា ធម៌ ។ សេចក្ដីនៃព្រះបាលីនោះឯង ឈ្មោះថា អត្ថ ។ ការសម្ដែងព្រះបាលីនោះ ដែលកំណត់ទុកដោយចិត្តនោះ ឈ្មោះថា ទេសនា ។ ការយល់ដឹងព្រះបាលី និងអត្ថនៃព្រះបាលីតាមសេចក្ដីពិត ឈ្មោះថា បដិវេធៈ ។ ក៏ព្រោះក្នុងបិដកទាំង ៣ នេះ ធម្មៈ អត្ថៈ ទេសនា និងបដិវេធៈទាំងនេះ ដែលបុគ្គលអ្នកមានបញ្ញាខ្សោយទាំងឡាយ ឈានចុះបានលំបាក និងមានទីតាំងអាស្រ័យដែលពួកគេមិនគប្បីបាន ដូចមហាសមុទ្រដែលសត្វទាំងឡាយ មានទន្សាយជាដើម ឈានចុះបានលំបាកដូច្នោះ, ព្រោះដូច្នោះទើបចាត់ថា ជាគុណជ្រាលជ្រៅ ។ ក៏ឯបណ្ឌិតគប្បីជ្រាបគម្ភីរភាពទាំង ៤ ក្នុងបិដក ទាំង ៣ នេះ ពីបិដកនីមួយ ៗ ដោយប្រការដូច្នេះ ។

# អធិប្បាយតម្រិភាពន័យមួយទៀត

ម្យ៉ាងទៀត ហេតុ ឈ្មោះថា ធម៌, សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "សេចក្ដីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា"[១] ។ ផលនៃហេតុឈ្មោះថា អត្ថ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "សេចក្ដីដឹងក្នុងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា"[២] ។ បញ្ញត្តិ អធិប្បាយថា ការសន្ទនាធម៌តាមធម៌ ឈ្មោះថា ទេសនា ។ ការត្រាស់ដឹងឈ្មោះថា បដិវេធ ។ ក៏បដិវេធនោះជាលោកិយៈផង លោកុត្តរៈផង គឺ សេចក្ដីដឹងរួមចុះក្នុងធម៌តាមសមគួរដល់អត្ថ ក្នុងអត្ថតាមសមគួរដល់ធម៌ ក្នុងបញ្ញត្តិតាមសមគួរដល់មកនៃបញ្ញត្តិ ដោយវិស័យ និងដោយការមិនវង្វេង[៣] ។

---

១.២. អភិ. វិភង្គ. បដិសម្ភិទាវិភង្គ. ៨២. ១៣/២១ ។ ៣. សារត្ថទីបនី. អធិប្បាយថា ក្នុងការត្រាស់ដឹង ជាលោកិយៈ និងលោកុត្តរៈនោះ ការយល់ដឹងជាលោកិយៈ មានធម៌មានអវិជ្ជាជាដើមជាអារម្មណ៍ មានសង្ខារ មានអត្ថជាដើមជាអារម្មណ៍ មានការឱ្យយល់ធម៌ និងអត្ថទាំងពីរនោះជាអារម្មណ៍ ឈ្មោះថា សេចក្ដីដឹងរួមចុះក្នុងធម៌ជាដើម តាមសមគួរដល់អត្ថជាដើមដោយវិស័យ. ចំណែកសេចក្ដី ត្រាស់ដឹងជាលោកុត្តរៈនោះ មាននិព្វានជាអារម្មណ៍ សម្បយុត្តដោយមគ្គ មានការកម្ចាត់សេចក្ដីល្វង់ក្នុងធម៌ អត្ថនិងបញ្ញត្តិតាមដែលពោលហើយ ឈ្មោះថា សេចក្ដីដឹងរួមចុះក្នុងធម៌ជាដើមតាមសមគួរដល់អត្ថជាដើម ដោយការមិនភាន់ច្រឡំ ។

ឥឡូវនេះ គួរជ្រាបគម្ពីរភាពទាំង ៤ ប្រការ ក្នុងបិដកនីមួយ ៗ នៃបិដកទាំង ៣ នេះ ព្រោះហេតុដែលធម្មជាតិ ឬអត្ថជាតិណា ៗ ក្តី អត្ថដែលព្រះមានព្រះភាគ គប្បីឱ្យជ្រាប រមែងជាអត្ថមានមុខឆ្ពោះចំពោះញាណរបស់អ្នកសិក្សាទាំងឡាយ ដោយប្រការណា ៗ ទេសនាដែលបំភ្លឺអត្ថនោះ ឱ្យភ្លឺច្បាស់ដោយប្រការនោះ ៗ នេះក្តី បដិវេធគឺសេចក្តីយល់ដឹងមិនវិបរិតក្នុងធម៌ អត្ថនិងទេសនា នេះក្តី ក្នុងបិដកទាំងនេះ ធម៌ អត្ថ ទេសនា និងបដិវេធទាំងអស់នេះ ដែលបុគ្គលអ្នកមានបញ្ញាខ្សោយទាំងឡាយ មិនមែនអ្នកមានកុសលសម្ភារបានកសាងទុក គប្បីស្ទាបស្ទង់ដល់បានលំបាក និងមានទីពឹងទីអាស្រ័យមិនបាន ដូចមហាសមុទ្រដែលសត្វទាំងឡាយមានទន្សាយជាដើម ឈានដល់បានលំបាក ដូច្នោះ ។ ក៏ព្រះគាថានេះថា ៖

ធេសនាសាសនកថា ភេទំ តេសុ យថារហំ
សិក្ខាប្បហានគម្ភីរ ភាវញ្ច បរិទីបយេ ។

បណ្ឌិតគប្បីសម្តែងសេចក្តីផ្សេងគ្នានៃទេសនា សាសនា កថា និងសិក្ខា បហានៈ គម្ភីរភាពក្នុងបិដកទាំងនោះ តាមសមគួរ ដូច្នេះ ។

ជាការដែលខ្ញុំព្រះករុណាពង្រីកសេចក្តីហើយ ដោយពាក្យត្រឹមតែ

ប៉ុណ្ណោះ ។

ចំណែកក្នុងព្រះគាថានេះថា ៖

បរិយត្តិភេទំ សម្បត្តឹ វិបត្តិញ្ចាបិ យំ យហឹ
បាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។

ភិក្ខុរមែងដល់នូវសេចក្ដីផ្សេងគ្នានៃបរិយត្តិក្ដី សម្បត្តិ និងវិបត្តិក្ដី យ៉ាងណា ក្នុងបិដកណា មានវិន័យបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បីប្រកាស សេចក្ដីផ្សេងគ្នានៃបរិយត្តិជាដើម សូម្បីនោះទាំងអស់ ដោយប្រការនោះ ដូច្នេះ ។

បណ្ឌិតគប្បីឃើញសេចក្ដីផ្សេងគ្នានៃបរិយត្តិ ៣ យ៉ាង ក្នុង៣បិដកដូច្នេះ ៖

## បរិយត្តិ ៣ យ៉ាង

ពិតមែន បរិយត្តិ ៣ គឺ អលគទ្ទូបមាបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិយបរិយត្តិ[១] ១ ក្នុងបរិយត្តិ ៣ យ៉ាងនោះ បរិយត្តិណា ដែលបុគ្គលរៀនមិនល្អ គឺ រៀនព្រោះហេតុមានការប្រកែក

[១]. វិនយដ្ឋកថា ជាភណ្ឌាគារិកបរិយត្តិ ។

តវាជាដើម, បរិយត្តិនេះ ឈ្មោះថា បរិយត្តិ ប្រៀបធៀបដោយពស់ពិស ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស អ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ក៏ត្រាច់ទៅស្វែងរកពស់ ពិស បុរសបានឃើញពស់វែក ១ យ៉ាងធំ ហើយក៏ចាប់ពស់វែកនោះ ត្រង់ខ្លួនឬកន្ទុយ ពស់វែកនោះក៏ងាកមកចឹកបុរសនោះត្រង់ដៃ ឬដើមដៃ ឬត្រង់អវយវៈតូចធំណាមួយ បុរសនោះ ក៏ដល់សេចក្តីស្លាប់ ឬដល់នូវ សេចក្តីទុក្ខជិតតែនឹងស្លាប់ ដោយមានពស់វែកនោះ ជាហេតុ ដំណើរ នោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពស់វែកបុរសនោះ ចាប់មិនស្រួល ម្នាលភិក្ខុទាំងឡាយ មានមោឃបុរសពួកខ្លះ ក្នុងសាសនា នេះ រៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ លុះមោឃបុរសទាំងនោះ រៀនធម៌នោះហើយ មិនបានពិចារណានូវសេចក្តីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងឡាយនោះ មិនបានពិចារណានូវសេចក្តីដោយប្រាជ្ញា ហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយ មានបំណងតែខាងលើកទោសគេផង ដោយមាន បំណងតែខាងដោះ ស្រាយនូវវាទៈ ដូច្នេះ ដូច្នោះផង កុលបុត្រទាំងឡាយរៀនធម៌ដើម្បី ប្រយោជន៍ណា មោឃបុរសទាំងនោះ ក៏មិនបាននូវប្រយោជន៍នោះ

របស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះរៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាធម៌ទាំងឡាយដែលមោឃបុរសរៀនមិនល្អហើយយ៉ាងនេះឯង"[១] ។

មួយទៀត បរិយត្តិដែលបុគ្គលរៀនល្អហើយ គឺ ចំណង់ប្រាថ្នានូវសេចក្ដីបរិបូណ៌នៃគុណ មានសីលក្ខន្ធជាដើមនុ៎ះឯង រៀនហើយ មិនរៀនព្រោះហេតុមានការប្រកែកតវ៉ាជាដើម, បរិយត្តិនេះ ឈ្មោះថាបរិយត្តិមានប្រយោជន៍ ដែលទឹងចេញ ចាកវគ្គៈដែលព្រះមានព្រះភាគទ្រង់សំដៅត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះរៀនធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ កុលបុត្រទាំងនោះលុះរៀនធម៌នោះហើយ ក៏ពិចារណានូវសេចក្ដីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងនោះលុះកុលបុត្រពិចារណានូវសេចក្ដីដោយប្រាជ្ញាហើយ ក៏បានប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះ មិនមែនរៀនធម៌ដោយមាន បំណងតែខាងលើកទោសគេផង មិនមែនរៀនធម៌ដោយមានបំណងតែខាងដោះស្រាយនូវវាទៈដូច្នេះផង ដូច្នោះផង កុលបុត្រ ឯទៀតរៀនធម៌ដើម្បីប្រយោជន៍ណា

---

១. មជ្ឈិ. មូល. អលគទ្ទូបមសូត្រ. ២១. ១៦/៤១ ។

កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះ របស់ធម៌នោះ ធម៌ទាំងឡាយនោះដែលកុលបុត្រ ពួកនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំងឡាយដែលកុលបុត្រទាំងនោះ បានរៀនដោយល្អ”[១] ដូច្នេះ ។

ចំណែកព្រះខីណាស្រពអ្នកមានខន្ធដែលកំណត់ដឹងហើយ មានកិលេសដែលលះហើយ មានមគ្គដែលអប់រំហើយ មានធម៌ ដែលមិនកម្រើកចាក់ធ្លុះហើយ មាននិរោធដែលធ្វើឱ្យច្បាស់ហើយ រមែងរៀននូវបរិយត្តិណា ដើម្បីត្រូវការដល់ដែលតម្រង់នូវប្រពៃណី ដើម្បីត្រូវការដល់ការតាមរក្សានូវវង្ស បរិយត្តិនេះ ឈ្មោះថា បរិយត្តិរបស់លោកអ្នកប្រដូចនាយឃ្លាំង ។

## ភិក្ខុដែលបដិបត្តិល្អក្នុងត្រៃបិដកបានផលល្អផ្សេងគ្នា

មួយទៀត ភិក្ខុដែលបដិបត្តិល្អក្នុងព្រះវិន័យ អាស្រ័យសីលសម្បត្តិ រមែងបានសម្រេចវិជ្ជា ៣ ក៏ព្រោះត្រាស់ចែកប្រភេទវិជ្ជា ៣ ទាំងនោះឯងទុកក្នុងព្រះវិន័យនោះ ។ អ្នកបដិបត្តិល្អក្នុងព្រះសូត្រ អាស្រ័យ

---

១. មជ្ឈិ. មូល. អលគទ្ទូបមសូត្រ. ២១. ១៦/៤១ ។

សមាធិសម្បត្តិ រមែងបានសម្រេចអភិញ្ញា ៦ ក៏ព្រោះត្រាស់ចែកប្រភេទ អភិញ្ញា ៦ ទាំងនោះទុកក្នុងព្រះសូត្រនោះ ។ អ្នកបដិបត្តិល្អក្នុងព្រះអភិធម្មអាស្រ័យបញ្ញាសម្បត្តិ រមែងបានសម្រេចបដិសម្ភិទា ៤ ក៏ព្រោះត្រាស់ចែកប្រភេទបដិសម្ភិទា ៤ នោះ ទុកក្នុងព្រះអភិធម្មនោះឯង ។ អ្នកបដិបត្តិល្អក្នុងបិដកទាំងនេះ រមែងសម្រេចសម្បត្តិផ្សេងគ្នា គឺ វិជ្ជា ៣ អភិញ្ញា ៦ និងបដិសម្ភិទា ៤ នេះតាមលំដាប់ដោយប្រការដូច្នេះ ។

## អ្នកបដិបត្តិខុសក្នុងត្រៃបិដកបានផលអាក្រក់ផ្សេងគ្នា

ក៏ភិក្ខុដែលបដិបត្តិមិនល្អក្នុងព្រះវិន័យ រមែងមានសេចក្ដីសម្គាល់ថា មិនមានទោស ក្នុងផស្សៈទាំងឡាយ មានប៉ះខ្លួនរូបជាឧបាទិន្នកៈជាដើម ដែលព្រះមានព្រះភាគត្រាស់ហាមហើយ ដោយភាពជាអាការស្មើដោយសម្ផស្សនៃវត្ថុ មានកម្រាលនិងសំពត់ដណ្ដប់ជាដើម ដែលមានសម្ផស្សជាសុខ ដែលព្រះមាន ព្រះភាគទ្រង់អនុញ្ញាតហើយ ។

សូម្បីសេចក្ដីនេះ ត្រូវដោយពាក្យដែលអរិដ្ឋភិក្ខុពោលថា "ធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគសម្ដែងថា តែងធ្វើនូវអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្ដីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្ដែងហើយ ដោយប្រការ

ដូច្នោះ”[១] ដូច្នេះ ។ ភិក្ខុនោះ រមែងដល់ភាពជាអ្នកទ្រុស្តសីល ព្រោះសេចក្តីបដិបត្តិមិនល្អនោះ ។

ភិក្ខុដែលបដិបត្តិមិនល្អក្នុងព្រះសូត្រ មិនដឹងនូវអធិប្បាយ ក្នុងព្រះបាលីជាដើមថា “ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាន”[២] ដូច្នេះ រមែងកាន់យកខុស ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅថា “ឈ្មោះថា ពោលបង្អាច់តថាគតផង ឈ្មោះថា គាស់រំលើងនូវខ្លួនឯងផង ឈ្មោះថា ទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់”[៣] ដូច្នេះ ភិក្ខុនោះ រមែងដល់ ភាពជាអ្នកមានទិដ្ឋិខុស ព្រោះការប្រកាន់នោះ ។

ភិក្ខុដែលបដិបត្តិមិនល្អក្នុងព្រះអភិធម្ម ពិចារណាធម៌ជ្រុលហួសពេក រមែងគិតនូវរឿងដែលមិនគួរគិត រមែងដល់សេចក្តីរវើរវាយនៃចិត្ត ព្រោះគិតនូវរឿងដែលមិនគួរគិតនោះ ។ សេចក្តីនេះត្រូវពិត តាមព្រះពុទ្ធវចនៈដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ(ហេតុដែលមិនគួរគិត) មាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះ គប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាក”[៤] ដូច្នេះ ។

---

១. វិន. បាចិ. សប្បាណកវគ្គ. ៤. ២៨០/២៧៦ ។ ២. អង្គ. ចតុ. ភណ្ឌគ្គាមវគ្គ. ៤២. ៥/១១ ។ ៣. មជ្ឈិ. មូល. អលគទ្ទូបមសូត្រ. ២១. ១៤/៣៥ ។ ៤. អង្គ. ចតុ. អបណ្ណកវគ្គ. ៤២. ៧៨/១៩៧ ។

ភិក្ខុដែលបដិបត្តិមិនល្អ ក្នុងបិដក ៣ ទាំងនេះ រមែងដល់សេចក្តីវិបត្តិផ្សេងដោយភាពជាអ្នកទ្រុស្តសីល ភាពជាអ្នកមានទិដ្ឋិខុស និងសេចក្តីរវើរវាយនៃចិត្តនេះតាមលំដាប់ ដោយប្រការដូច្នេះ ។

សូម្បីព្រះគាថានេះថា

**បរិយត្តិភេទំ សម្បត្តឹ វិបត្តឹ ចាបិ យំ យហឹ**
**បាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។**

ភិក្ខុ រមែងដល់នូវសេចក្តីផ្សេងគ្នានៃបរិយត្តិក្តី សម្បត្តិនិងវិបត្តិក្តី យ៉ាងណា ក្នុងបិដកណា មានវិន័យបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បីប្រកាស សេចក្តីផ្សេងគ្នានៃបរិយត្តិជាដើម សូម្បីនោះទាំងអស់ដោយប្រការនោះ ដូច្នេះ ។

សេចក្តីដែលខ្ញុំពន្យល់ហើយ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ៗ បណ្ឌិតកាលជ្រាបបិដកដោយប្រការផ្សេង ៗ យ៉ាងនោះហើយ ក៏គួរជ្រាបព្រះពុទ្ធវចនៈនោះថា មាន ៣ យ៉ាង ដោយអំណាចនៃបិដកទាំងនោះ ។

## ព្រះពុទ្ធវចនៈមាន ៥ និកាយ

ព្រះពុទ្ធវចនៈមាន ៥ ដោយអំណាចនៃនិកាយ យ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នុ៎ះឯង រមែងមាន ៥ ប្រភេទ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ ( និង ) ខុទ្ទកនិកាយ ។

## ទីឃនិកាយ ៣៤ សូត្រ

បណ្តានិកាយទាំង ៥ នោះ ទីឃនិកាយដូចម្តេច ? ព្រះសូត្រ ៣៤ សូត្រមានព្រហ្មជាលសូត្រជាដើម សង្គ្រោះ ( រួបរួម ) ជា ៣ វគ្គ ឈ្មោះថា ទីឃនិកាយ ។

និកាយណាមានព្រះសូត្រ ៣៤ សូត្រគត់សង្គ្រោះជា ៣
វគ្គ, និកាយដំបូងនេះ អនុលោមតាមសេចក្តី ឈ្មោះថា
ទីឃនិកាយ ។

ក៏ព្រោះហេតុអ្វី និកាយនេះ ទើបលោកហៅថា ទីឃនិកាយ ? ព្រោះជាទីប្រជុំ និងជាទីរួមនៃព្រះសូត្រទាំងឡាយដែលមានខ្នាតវែង ។ ពិតមែន ទីប្រជុំនិងទីរួមលោកហៅថា និកាយ ក៏ក្នុងនិកាយសព្ទ ដែលជាសព្ទប្រាប់សេចក្តីប្រជុំ និងសេចក្តីរួមនេះ មានឧទាហរណ៍ដែលគួរជាសាធក ទាំងមកសាសនាទាំងមកលោក ជាដើមយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆាននេះដ៏វិចិត្រ យ៉ាងណា ចិត្តដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយ ដទៃអំពីចិត្តនោះឡើយ"[១] គឺ ពួកកណ្តៀរ ពួកសត្វតូច ៗ ។ បណ្ឌិតគប្បីជ្រាបវចនត្ថ ( អត្ថន័យរបស់ពាក្យ ) ក្នុងសេចក្តីដែលនិកាយទាំង ៤ សូម្បីដែលសល់ ឈ្មោះថា និកាយ ដោយប្រការដូច្នេះ ។

---

១. សំយុ. ខន្ធ. បុប្ផវគ្គ. ៣៣. ២៥៩/៣៤៤ ។

## មជ្ឈិមនិកាយមាន ១៥២ សូត្រ

មជ្ឈិមនិកាយដូចម្ដេច ? ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម សង្គ្រោះជា ១៥ វគ្គ ដែលមានខ្នាតកណ្ដាល ឈ្មោះថា មជ្ឈិមនិកាយ ។

និកាយដែលមានព្រះសូត្រ ១៥២ សូត្រ ចាត់ជា
១៥ វគ្គ ឈ្មោះថា មជ្ឈិមនិកាយ ។

## សំយុត្តនិកាយមាន ៧,៧៦២ សូត្រ

សំយុត្តនិកាយដូចម្ដេច ? ព្រះសូត្រ ៧.៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ដែលតាំងនៅដោយអំណាចនៃសំយុត្ត មានទេវតាសំយុត្តជាដើម ឈ្មោះថា សំយុត្តនិកាយ ។

និកាយ ដែលមានព្រះសូត្រ ៧.៧៦២ សូត្រដែលរួប
រួម ពួកសំយុត្ត នេះឈ្មោះថា សំយុត្តនិកាយ ។

## អង្គុត្តរនិកាយមាន ៩,៥៥៧ សូត្រ

អង្គុត្តរនិកាយដូចម្ដេច ? ព្រះសូត្រ ៩.៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ទីតាំងនៅដោយអំណាចនៃអង្គមួយ ៗ និងលើសមួយ ឈ្មោះថា អង្គុត្តរនិកាយ ។

ក្នុងអង្គុត្តរនិកាយ រាប់ចំនួនព្រះសូត្របានដូច្នេះគឺ ៩.៥៥៧ សូត្រ ។

## ខុទ្ទកនិកាយមាន ១៥ ប្រភេទ

ខុទ្ទកនិកាយដូចម្ដេច ? វៀរ ៤ និកាយចេញ ព្រះពុទ្ធវចនៈដែលសល់ គឺ ព្រះវិន័យបិដក ព្រះអភិធម្មបិដកទាំងអស់ និង ព្រះបាលី ១៥ ប្រភេទ ដែលសម្ដែងទុកហើយក្នុងខាងដើម មានខុទ្ទកបាលីជាដើម ឈ្មោះថា ខុទ្ទកនិកាយ ដោយប្រការដូច្នេះ ។

វៀរនិកាយសូម្បីទាំង ៤ មានទីឃនិកាយជាដើមនោះចេញ
ព្រះពុទ្ធវចនៈដទៃអំពីនោះ បណ្ឌិតហៅថា ខុទ្ទកនិកាយ
ដូច្នេះឯង ។

ព្រះពុទ្ធវចនៈមាន ៥ យ៉ាង ដោយអំណាចនៃនិកាយ ដូចពណ៌នាមក ដូច្នេះ ។

## ព្រះពុទ្ធវចនៈមាន ៩ យ៉ាង

ព្រះពុទ្ធវចនៈមាន ៩ យ៉ាង ដោយអំណាចនៃអង្គយ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈទាំងអស់នោះឯង មាន ៩ ប្រភេទ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។

# អធិប្បាយព្រះពុទ្ធវចនៈមានអង្គ ៩

បណ្ដាព្រះពុទ្ធវចនៈដែលមានអង្គ ៩ នោះ ឧភតោវិភង្គ និទ្ទេសខន្ធកៈ បរិវារ និងព្រះសូត្រ មានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និងតុវដកសូត្រជាដើម ក្នុងសុត្តនិបាត និងព្រះតថាគតវចនៈ (ព្រះតម្រាស់របស់ព្រះតថាគត) ដែលមានឈ្មោះថា សូត្រសូម្បីដទៃ គប្បីជ្រាបថា ព្រះសូត្រ ។

ព្រះសូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា គេយ្យៈ ។

សគាថកវគ្គ (វគ្គដែលមានគាថា) ទាំងអស់ ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា គេយ្យៈ ដោយពិសេស ។

ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថាលាយ និងព្រះពុទ្ធវចនៈដទៃ ដែលមិនបានសង្គ្រោះចូលដោយអង្គ ៨ គប្បីជ្រាបថា វេយ្យាករណៈ ។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះថា សូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា គាថា ។

ព្រះសូត្រ ៨២ សូត្រ ដែលបដិសំយុត្តដោយគាថា ដែលសម្រេចដោយសោមនស្សញ្ញាណ គប្បីជ្រាបថា ឧទាន ។

ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា "វុត្តំ ហេតំភគវតា : ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ"[១] គប្បីជ្រាបថា ឥតិវុត្តកៈ ។

ជាតក ៥៥០ មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតកៈ ។

ព្រះសូត្រ ដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ អច្ឆរិយអព្ភូតធម៌ (ធម៌ជាអស្ចារ្យ ចំឡែក)ទាំងឡាយ ៤ យ៉ាងនេះ មាននៅក្នុងព្រះអានន្ទ"[២] គប្បីជ្រាបថា អព្ភូតធម្មៈ ។

ព្រះសូត្រដែលមនុស្សជាដើមសួរហើយ បានសេចក្តីដឹង និងសេចក្តីត្រេកអរទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថា វេទល្លៈ ។

ព្រះពុទ្ធវចនៈមានអង្គ ៩ ដោយអំណាចនៃអង្គ ដូចពណ៌នាមកដូច្នេះ ។

---

១. ខុទ្. ឥតិវុត្តក. ភាគ ៥៣ ខាងដើមសូត្រទាំងអស់ ។

២. ទីឃ. មហា. មហាបរិនិព្វានសូត្រ. ១៦. ១៣៦/៣០៣ ។

## ព្រះពុទ្ធវចនៈមាន ៨៤,០០០ ព្រះធម្មក្ខន្ធ

ព្រះពុទ្ធវចនៈ មាន ៨៤.០០០ យ៉ាង ដោយអំណាចនៃព្រះធម្មក្ខន្ធយ៉ាងណា ? ពិតមែន ព្រះពុទ្ធវចនៈនោះទាំងអស់នោះឯង មាន ៨៤.០០០ ប្រភេទ ដោយអំណាចនៃព្រះធម្មក្ខន្ធ ដែលព្រះអានន្ទត្ថេរសម្តែងទុកហើយយ៉ាងនេះថា

> "សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងហឫទ័យរបស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មានចំនួន ៨៤.០០០ ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨២.០០០ ធម្មក្ខន្ធ អំពីពួកភិក្ខុ ២.០០០ ធម្មក្ខន្ធ"[១] ដូច្នេះ ។

## វិធីគណនារាប់ព្រះធម្មក្ខន្ធចំពោះខន្ធមួយៗ

បណ្តាព្រះធម្មក្ខន្ធ ៨៤.០០០ នោះ ព្រះសូត្រដែលមានអនុសន្ធិតែមួយចាត់ជាមួយព្រះធម្មក្ខន្ធ ។ ក្នុងព្រះសូត្រដែលមានអនុសន្ធិច្រើនរាប់ព្រះធម្មក្ខន្ធដោយអំណាចនៃអនុសន្ធិ ។ ក្នុងគាថាព័ន្ធទាំងឡាយ ពាក្យសួរ (មួយសំនួរ) ចាត់ជាមួយព្រះធម្មក្ខន្ធ, ពាក្យឆ្លើយ (មួយចម្លើយ) ចាត់ជាមួយព្រះធម្មក្ខន្ធ ។

---

១. ខុទ្ទ. ថេរ. អានន្ទត្ថេរ. ៥៧. ២៦១/៩៤ ។

ក្នុងព្រះអភិធម្ម ការបែកតិកៈទុកៈតែតិកៈទុកៈនីមួយ ៗ និងការបែកវារចិត្តតែមួយវារចិត្ត ចាត់ជាមួយព្រះធម្មក្ខន្ធ ។

ក្នុងព្រះវិន័យ មានវត្ថុ មានមាតិកា មានបទភាជនី មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ មានកំណត់តិកៈ បណ្តាវត្ថុ និងមាតិកាជាដើមទាំងនោះ ចំណែកមួយ ៗ គប្បីជ្រាបថា ជាព្រះធម្មក្ខន្ធមួយ ៗ ព្រះពុទ្ធវចនៈ (ទាំងអស់) មាន ៨៤,០០០ យ៉ាង ដោយអំណាចនៃព្រះធម្មក្ខន្ធ ដូចពណ៌នាមកដូច្នេះ ។

## បឋមសង្គាយនាចាត់ព្រះពុទ្ធវចនៈទុកជាពួកៗ

ព្រះពុទ្ធវចនៈនោះ ដោយន័យដូចដែលពោលមកហើយ យ៉ាងនេះ ដោយការមិនផ្សេងគ្នា មានតែម្យ៉ាង ដោយអំណាចរស, ដោយសេចក្តីផ្សេងគ្នា មានប្រភេទ ២ យ៉ាងជាដើម ដោយអំណាចធម៌និងវិន័យជាដើម ដែលព្រះមហាថេរៈ អ្នកជាគណៈ ដែលជំនាញ មានព្រះមហាកស្សបជាប្រមុខ កាលនឹងសង្គាយនា ទើបកំណត់ប្រភេទនេះមុន ហើយចងក្រងទុកថា នេះព្រះធម៌, នេះព្រះវិន័យ, នេះបឋមពុទ្ធវចនៈ, នេះមជ្ឈិមពុទ្ធវចនៈ, នេះបច្ឆិមពុទ្ធវចនៈ, នេះព្រះវិន័យបិដក, នេះព្រះសុត្តន្តបិដក, នេះព្រះអភិធម្មបិដក, នេះទីឃនិកាយ, នេះមជ្ឈិមនិកាយ, នេះសំយុត្តនិកាយ, នេះអង្គុត្តរនិកាយ, នេះខុទ្ទកនិកាយ, នេះអង្គ ៩ មាន

សុត្តៈជាដើម, នេះ ៨៤.០០០ ព្រះធម្មក្ខន្ធ ។

ក៏លោកចងក្រងប្រភេទ តាមដែលពោលទុកហើយនេះប៉ុណ្ណោះតែម្យ៉ាងក៏ទេ នៅអាចកំណត់ប្រភេទដែលគួរប្រមូលរួបរួមទុកសូម្បីដទៃ ៗ ដែលមានច្រើនប្រភេទ មានឧទានសង្គហៈ វគ្គសង្គហៈ បេយ្យាលសង្គហៈ និបាតសង្គហៈ ដូចឯកនិបាត និងទុកនិបាតជាដើម សំយុត្តសង្គហៈ និងបណ្ណាសកសង្គហៈ ជាដើម ដែលប្រាកដនៅក្នុងព្រះត្រៃបិដក បានចងក្រង ៧ ខែ ទើបសម្រេច ដោយប្រការដូច្នេះ ។

## ព្រះពុទ្ធសាសនាអាចតាំងនៅបាន ៥,០០០ ឆ្នាំ

ក៏ក្នុងវេលាចប់ការចងក្រងព្រះពុទ្ធវចនៈនោះ មហាប្រថពីនេះ ដូចជាកើតបាមោជ្ជៈ ឱ្យសាធុការថា "ព្រះមហាកស្សបត្ថេរ ធ្វើព្រះសាសនារបស់ព្រះទសពលនេះ ឱ្យអាចប្រព្រឹត្តទៅបាន រហូតដល់អស់កាលប្រមាណ ៥.០០០ ព្រះវស្សា" ដូច្នេះ ក៏កម្រើក រញ្ជួយ ញាប់ញ័រ ជាអនេកប្បការ ដរាបដល់ទឹក ទ្រផែនដីជាទីបំផុត និងភាពអស្ចារ្យទាំងឡាយជាច្រើន ក៏បានប្រាកដមានហើយ ដោយប្រការដូច្នេះ ។

សង្គីតិណាក្នុងលោក លោកហៅថា បញ្ចសតាសង្គីតិ
ព្រោះព្រះធម្មសង្គាហកត្ថេរ ៥០០ រូបធ្វើ, និងហៅថា

ថេរិកាសង្គីតិ ព្រោះព្រះថេរៈទាំងឡាយនុ៎ះឯងធ្វើហើយ, សង្គីតិនេះ ឈ្មោះថា បឋមមហាសង្គីតិ ដោយប្រការដូច្នេះ ។

កាលបឋមមហាសង្គីតិនេះកំពុងប្រព្រឹត្តទៅ ព្រះមហាកស្សបៈ កាលនឹងសួរដល់ព្រះវិន័យ (ចំពោះព្រះឧបាលីថេរៈ) ទើបសួរដល់និទាន ដែលលោកពោលទុកក្នុងពាក្យនេះថា សួរដល់វត្ថុខ្លះ សួរដល់និទានខ្លះ សួរដល់បុគ្គលខ្លះ ដូច្នេះជាដើម ដែលជាទីបំផុតនៃពាក្យជាដើមយ៉ាងនេះថា “ម្នាលអាវុសោឧបាលី បឋមបារាជិក ព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយក្នុងទីណា ?” ជាដើម ពាក្យនិទាននោះ ព្រះឧបាលីថេរៈប្រាប្ថានឹងឱ្យពិស្តារតាំងពីដើម ហើយពោលដល់បុគ្គលជាដើម ដែលបញ្ញត្តិវិន័យបិដក និងហេតុដែលបញ្ញត្តិនោះទាំងអស់ ទើបពោលទុកហើយ ។

## អធិប្បាយសេចក្តីចាប់ផ្តើមនៃនិទានវិន័យ

ពាក្យនិទាន (ពាក្យចាប់ផ្តើម)ថា តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ ជាដើម បណ្ឌិតគួរពោលទុកទាំងអស់, ព្រោះពាក្យចាប់ផ្តើមនេះ ព្រះឧបាលីថេរៈពោលទុកយ៉ាងនេះ ។ ក៏ឯពាក្យ

ចាប់ផ្ដើមនោះ បណ្ឌិតគួរជ្រាបថា ព្រះឧបាលីថេរៈ ពោលទុកហើយក្នុងគ្រាធ្វើសង្គាយនាធំគ្រាដំបូង ។ ក៏សេចក្ដីនៃ បទនេះថា ក៏ពាក្យនេះអ្នកណាពោលនិងពោលក្នុងកាលណាជាដើម ជាការដែលខ្ញុំព្រះករុណាប្រកាសហើយ ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ។ ឥឡូវនេះ ខ្ញុំព្រះករុណានឹងពោលឆ្លើយ ក្នុងពាក្យថា **ពោលទុកព្រោះហេតុអ្វី** នេះតទៅ ៖

ព្រោះព្រះឧបាលីនេះ ត្រូវព្រះមហាកស្សបត្ថេរសួរដល់និទានហើយ ដូច្នោះ ទើបលោកបានពោលនិទាននោះឱ្យពិស្ដារ ហើយតាំងអំពីដើម ដោយប្រការដូច្នេះ ។

ពាក្យចាប់ផ្ដើមនេះ បណ្ឌិតគួរជ្រាបថា ព្រះឧបាលីថេរៈ សូម្បីកាលពោលក្នុងគ្រាធ្វើសង្គាយនាធំគ្រាដំបូងក៏បានពោលហើយ ព្រោះហេតុនេះ ដោយប្រការដូច្នេះ ។ ក៏សេចក្ដីនៃបទ មាតិកាទាំងនេះថា វុត្តំ យេន យទា យស្មា ដូច្នេះ ជាការដែលខ្ញុំព្រះករុណាប្រកាសហើយ ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្ដីនៃបទមាតិកាទាំងនេះថា ធារិតំ យេន ចាភតំ យត្ថ បតិដ្ឋិតមេតំ វត្វា វិធិំ ទើបបណ្ឌិតពោលពាក្យនេះទុក ។

## ព្រះមហាថេរៈទាំងឡាយ នាំព្រះវិន័យបិដកបន្តមក

សួរថា ក៏ព្រះវិន័យបិដកនោះ ដែលមាននិទានប្រដាប់ ដោយពាក្យជាដើមយ៉ាងនេះថា តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ ដូច្នេះ អ្នកណាទ្រទ្រង់ទុក ? អ្នកណានាំបន្តមក ? (និង) តាំងមាំនៅហើយក្នុងបុគ្គលណា ? ខ្ញុំព្រះករុណា នឹងឆ្លើយតទៅ ៖

ព្រះវិន័យបិដកនេះ ព្រះឧបាលីថេរៈទ្រទ្រង់ចាំទុក ចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគ ក្នុងខាងដើមមុន ។ កាលព្រះតថាគតមិនទាន់បរិនិព្វានទុំះឯង ភិក្ខុច្រើនពាន់រូប មានអ្នកបានអភិញ្ញា ៦ ជាដើម ទ្រទ្រង់ចាំទុកតពីព្រះឧបាលីថេរៈនោះ កាលព្រះតថាគតបរិនិព្វានហើយ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ មានព្រះមហាកស្សបជាប្រមុខ ក៏ទ្រទ្រង់ចាំគ្នាតមក ។

បទមាតិកាថា កេនាភដំ នេះខ្ញុំព្រះករុណានឹងពោលតទៅ ៖

ក្នុងជម្ពូទ្វីបមុន ព្រះវិន័យនោះ នាំបន្តមកដោយលំដាប់នៃអាចារ្យ ចាប់ផ្តើមតាំងពីព្រះឧបាលីថេរៈ ដរាបដល់សង្គាយនាលើក ទី ៣ ។ ក្នុងជម្ពូទ្វីបនោះមានលំដាប់អាចារ្យដូចតទៅនេះ ៖

ព្រះថេរៈ ៥ អង្គទាំងនេះ គឺ ព្រះឧបាលី ១ ព្រះទាសកៈ ១ ព្រះសោណកៈ ១ ព្រះសិគ្គវៈ ១ ព្រះមោគ្គលីបុត្តតិស្សៈ ១ អ្នកមានជ័យជំនះពិសេសបាននាំព្រះវិន័យ មកតាមលំដាប់មិនដាច់ខ្សែ ក្នុងសិរីជម្ពូទ្វីបដរាបដល់សង្គាយនាលើកទី ៣ ។

## ព្រះឧបាលីថេរៈរៀនព្រះវិន័យបិដកអំពីពុទ្ធ

សេចក្តីពិស្តារថា ព្រះឧបាលីរៀនយកវង្ស របៀបប្រពៃណី ព្រះវិន័យ ចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ហើយឱ្យតាំងនៅក្នុងហទយៈរបស់ភិក្ខុជាច្រើន ។ ពិតមែន បណ្តាបុគ្គលអ្នករៀន យកវិន័យវង្ស ក្នុងសំណាក់របស់លោកនោះ ហើយដល់ភាពជាអ្នកឆ្លាតវាងវៃក្នុងព្រះវិន័យ អ្នកដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី កំណត់រាប់មិនបាន ដែលជាព្រះខីណាស្រពបានមានចំនួន ១.០០០ រូប ។

## ព្រះទាសកត្ថេរជាសទ្ធិវិហារិករបស់ព្រះឧបាលីថេរៈ

ចំណែកព្រះទាសកត្ថេរ បានជាសទ្ធិវិហារិករបស់ព្រះឧបាលីថេរៈនោះឯង លោកបានរៀនព្រះវិន័យតពីព្រះឧបាលីថេរៈ ហើយក៏បង្រៀនព្រះវិន័យ (ដល់ភិក្ខុជាច្រើន) ដូចយ៉ាងនោះ ។ បុថុជ្ជនជាដើមអ្នករៀននូវព្រះវិន័យ ក្នុងសំណាក់របស់ព្រះថេរៈនោះ ហើយជាអ្នកឆ្លាត

វាងវៃក្នុងព្រះវិន័យកំណត់រាប់មិនបាន ដែលជាព្រះខីណាស្រព បានមានចំនួនដល់ ១.០០០ រូប ។

## ព្រះសោណកត្ថេរជាសទ្ធិវិហារិករបស់ព្រះទាសកត្ថេរ

ចំណែកព្រះសោណកត្ថេរ បានជាសទ្ធិវិហារិករបស់ព្រះទាសកត្ថេរ ។ សូម្បីលោកក៏រៀនយក ( ព្រះវិន័យ ) តពីព្រះទាសកត្ថេរ អ្នកជាព្រះឧបជ្ឈាយ៍របស់ខ្លួនហើយក៏បង្រៀនព្រះវិន័យ ( ដល់ភិក្ខុជាច្រើន ) ដូចយ៉ាងនោះ ។ បុថុជ្ជនជាដើម អ្នករៀនយក ( ព្រះវិន័យ ) ក្នុងសំណាក់របស់លោកសូម្បីនោះ ហើយ ដល់ភាពជាអ្នកឆ្លាតវាងវៃក្នុងព្រះវិន័យ កំណត់រាប់មិនបាន ដែលជាព្រះខីណាស្រពបានមានចំនួនដល់ ១.០០០ រូបដូចគ្នា ។

## ព្រះសិគ្គវត្ថេរជាសទ្ធិវិហារិករបស់ព្រះសោណកត្ថេរ

ចំណែកព្រះសិគ្គវត្ថេរ ជាសទ្ធិវិហារិករបស់ព្រះសោណកត្ថេរ រៀនយកព្រះវិន័យ ក្នុងសំណាក់របស់ព្រះថេរៈ ហើយបានជាអ្នកទទួលធុរៈរបស់ព្រះអរហន្ត ១.០០០ អង្គ ។ មួយទៀត បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីក្តី ព្រះខីណាស្រពក្តី អ្នករៀនយក ( ព្រះវិន័យ ) ក្នុងសំណាក់របស់លោកនោះ ហើយដល់សេចក្តីជាអ្នក

ឆ្លាតវាងវៃក្នុងព្រះវិន័យ ក៏កំណត់មិន បានថា ប៉ុណ្ណោះរយ ឬថា ប៉ុណ្ណោះពាន់ ។

បានឮថា វេលានោះ ក្នុងជម្ពូទ្វីបមានការប្រជុំភិក្ខុយ៉ាងច្រើន ។ អានុភាពរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរ នឹងមានប្រាកដច្បាស់ ក្នុងតតិយសង្គាយនា (ខាងមុខ) ។ ព្រះវិនយបិដកនេះ គប្បីជ្រាបថា លំដាប់ដំបូងក្នុងជម្ពូទ្វីប នាំបន្តគ្នាមកដោយលំដាប់នៃអាចារ្យនេះ ដរាប ដល់សង្គាយនាលើកទី ៣ ដោយ ប្រការដូច្នេះ ។

ចប់ បឋមសង្គីតិ

## ផ្ដើមធ្វើទុតិយសង្គាយនា

ក៏ដើម្បីដឹងទុតិយសង្គាយនាជាក់ច្បាស់ គួរជ្រាបលំដាប់ដូចតទៅនេះ ពិតមែន ក្នុងកាលណា ព្រះថេរៈទាំង ៥០០ មានព្រះមហាកស្សបៈជាដើម អ្នកមានអាសវៈអស់ហើយ មានបញ្ញាដ៏រុងរឿងទាំងនោះ គ្រាសង្គាយនាព្រះសទ្ធម្មនិងញុំាងព្រះសទ្ធម្ម ឱ្យរុងរឿងក្នុងទីទាំងពួងហើយ តាំងនៅដរាបដល់ទីបំផុតនៃជីវិត មិនមានអាល័យអស់ពូជរលត់ទៅ ដូចប្រទីបរលត់ទៅដូច្នោះ ។

## ភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ

ក្នុងកាលនោះ កាលយប់និងថ្ងៃកន្លងទៅដោយលំដាប់ ក្នុងកាលព្រះមានព្រះភាគ ស្ដេចបរិនិព្វានហើយបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលី សម្ដែងវត្ថុ ១០ ប្រការទាំងនេះ ក្នុងក្រុងវេសាលី គឺ ៖

កប្បតិ សិង្គិលោណកប្បោ ការកំណត់ដោយអម្បិល ក្នុងក្លាក់គួរ (ដល់ សមណៈ)

កប្បតិ ទ្វង្គុលកប្បោ ការកំណត់ដោយស្រមោល ព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់ គួរ,

កប្បតិ គាមន្តរកប្បោ ការកំណត់ដោយចន្លោះស្រុក គួរ,

កប្បតិ អាវាសកប្បោ ការកំណត់ដោយអាវាស គួរ,

កប្បតិ អនុមតិកប្បោ ការកំណត់ដោយអនុមតិ គួរ,

កប្បតិ អាចិណ្ណកប្បោ ការកំណត់ដោយអាចិណ្ណកប្ប (ប្រពៃណី) គួរ

កប្បតិ អមថិតកប្បោ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរ

កប្បតិ ជលោគឹ បាតុំ ការផឹកនូវសុរាឆៅ គួរ,

កប្បតិ អទសកំ និសីទនំ និសីទនៈដែលមិនមានជាយ ក៏គួរ,

កប្បតិ ជាតរូបរជតំ មាសនិងប្រាក់ គួរ ។[១]

ព្រះរាជាទ្រង់ព្រះនាមថា កាឡាសោក ជាព្រះរាជឱរស របស់ព្រះបាទសុសុនាគ ទ្រង់បានជាបក្ខពួករបស់ពួកភិក្ខុវជ្ជីបុត្រទាំងនោះហើយ ។

## ព្រះយសត្ថេរដឹងភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ

សម័យនោះ ព្រះយសកាកណ្ឌកបុត្តមានអាយុត្រាច់ទៅ កាន់ចារិកក្នុងដែនវជ្ជីជន, បានស្តាប់ថា ឮថា ពួកវជ្ជីបុត្តភិក្ខុដែលនៅក្នុងក្រុងវេសាលីសម្តែងវត្ថុ ១០ ប្រការ ក្នុងក្រុងវេសាលី ដូច្នេះ ទើបត្រិះរិះថា "ការដែលយើងបានស្តាប់នូវវិបត្តិនៃព្រះសាសនារបស់ព្រះទសពលហើយ នឹងគប្បីជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មិនសមគួរដល់យើងឡើយ

---

១. វិន. ចុល្ល. សត្តសតិកក្ខន្ធកៈ. ១១. ២៩៤/៣៨៤ ។

ណ្ហើយចុះ យើងនឹងសង្កត់សង្កិនពួកអធម្មវាទីចេញ ហើយនឹងលើកតម្កើងធម៌ ដូច្នេះ ទើបបានទៅកាន់ក្រុងវេសាលី ។

ដូចបានឮមកថា ព្រះយសកាកណ្ឌកបុត្រ សម្រាកនៅក្នុងកូដាគារសាលា នាព្រៃមហាវ័នជិតក្រុងវេសាលីនោះ ។ សម័យនោះឯង ពួកភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលី បានដងទឹកដាក់ពេញថាសសំរិទ្ធិ ហើយយកទៅតំកល់ទុកក្នុងកណ្ដាលភិក្ខុសង្ឃក្នុងថ្ងៃឧបោសថនោះ ហើយពោលពាក្យយ៉ាងនេះ ចំពោះពួកឧបាសក (ឧបាសិកា) នៅក្នុងក្រុងវេសាលី ដែលមកហើយ ៗ ទាំងអស់ថា "ហៃអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរប្រគេន មួយកហាបណៈក្ដី កន្លះកហាបណៈក្ដី មួយបាទក្ដី មួយមាសកក្ដីដល់សង្ឃចុះ សង្ឃមុខជានឹងមានកិច្ចដោយបរិក្ខារមិនខាន"[១] ដូច្នេះ ។

ពាក្យទាំងពួងគួរពោលដរាបដល់ពាក្យថា ក៏វិន័យសង្គីតិនេះ បានមានភិក្ខុ ៧០០ រូប មិនលើសមិនខ្វះ, ព្រោះដូច្នោះ វិន័យសង្គីតិនេះ ទើបលោកហៅថា សត្តសតិកា ។

ក៏ភិក្ខុមួយលានពីរសែនរូប ដែលព្រះយសកាកណ្ឌកបុត្តដឹកនាំបានប្រជុំគ្នាក្នុងសន្និបាតនេះ ។ វត្ថុ ១០ ប្រការទាំងនោះ ព្រះរេវតៈជាអ្នកសួរ ។ ព្រះសព្វកាមីថេរៈ ជាអ្នកវិសជ្ជនាព្រះវិន័យ វិនិច្ឆ័យរួចស្រេចក្នុងទីចំណោមភិក្ខុទាំងនោះ, អធិករណ៍ ជាការដែលរម្ងាប់ស្រេចហើយ ។

---

១. វិន. ចុល្ល. សត្តសតិកក្ខន្ធកៈ. ១១. ២៩៦/៣៨៥ ។

## ជ្រើសរើសព្រះថេរៈ ៧០០ រូប ធ្វើទុតិយសង្គាយនា

ខាងក្រោយព្រះថេរៈទាំងឡាយ ប្រឹក្សាគ្នាថា ពួកយើង នឹងសង្គាយនាព្រះធម៌និងព្រះវិន័យទៀត ដូច្នេះ ទើបបានជ្រើសរើសភិក្ខុ ៧០០ រូប អ្នកទ្រង់ព្រះត្រៃបិដក សម្រេចបដិសម្ភិទា ហើយអង្គុយប្រជុំគ្នាក្នុងវាលិការាមជិតក្រុងវេសាលី ជម្រះមន្ទិល នៃព្រះសាសនាទាំងពួង បានសង្គាយនាព្រះធម៌ និងវិន័យទាំងអស់ ដោយអំណាចបិដក និកាយ អង្គ និងធម្មក្ខន្ធដែលទៀត ដូចគ្នានឹងដែលព្រះមហាកស្សបត្ថេរសង្គាយនាហើយទុំនុះឯង ។

សង្គីតិណាក្នុងលោក (គឺក្នុងព្រះពុទ្ធសាសនា) លោកហៅថា សត្តសតសង្គីតិ ព្រោះព្រះថេរៈ ៧០០ រូបធ្វើ, និងហៅថា ទុតិយសង្គីតិ ព្រោះប្រៀបធៀបសង្គីតិដែលធ្វើមុន ។

សង្គីតិនេះធ្វើអស់រយៈកាល ៨ ខែទើបសម្រេច ដោយប្រការដូច្នេះ ។

ក៏ឯសង្គីតិនោះ ដែលព្រះថេរៈពួកណាចងក្រងទុកហើយ បណ្ដាព្រះថេរៈទាំងនោះ ព្រះថេរៈដែលប្រាកដ[១] គឺ ព្រះសព្វកាមី១ ព្រះសាឡ្ហៈ១ ព្រះរេវតៈ១ ព្រះខុជ្ជសោភិតៈ១ ព្រះយស១ ព្រះសោណសម្ភូតៈ១ ទាំងនេះ ជាសទ្ធិវិហារិករបស់ព្រះអានន្ទត្ថេរ ធ្លាប់ឃើញព្រះតថាគត ព្រះសុមនៈ ១ ព្រះវាសភគាមី ១, ២ រូប នេះ បណ្ឌិតគប្បីជ្រាបថា ជាសទ្ធិវិហារិករបស់ព្រះអនុរុទ្ធៈ ធ្លាប់ ឃើញព្រះតថាគត ក៏ឯព្រះថេរៈទាំងឡាយ ដែលធ្វើសង្គាយនាលើកទី ២ គ្រប់ ៗ រូបជាអ្នកដាក់ភារៈហើយ សម្រេចកិច្ចហើយ មិនមានអាសវៈ ដូច្នេះឯង ។

ចប់ ទុតិយសង្គីតិប៉ុណ្ណោះ

---

១. ដីកាសារត្ថទីបនី និងអត្ថយោជនា ជា តេសុ វិស្សុតា

## រឿងរ៉ាវមុនតតិយសង្គាយនា

ព្រះថេរៈទាំងឡាយនោះ កាលសង្គាយនាទុតិយសង្គីតិនេះ យ៉ាងនោះហើយ ទើបត្រួតមើលថា សូម្បីក្នុងអនាគតចម្រូងចម្រាស់បែបនេះនឹងកើតឡើងដល់ព្រះសាសនាឬហ្ន៎ ? ហើយបានឃើញហេតុនេះថា ក្នុងឆ្នាំទី ១៨ បន្ទាប់អំពី ១០០ ឆ្នាំនេះទៅ ព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទធម្មាសោក នឹងទ្រង់ឧប្បត្តិឡើងក្នុងព្រះនគរបាដលិបុត្រ គ្រប់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងអស់ ស្ដេចទ្រង់នឹងជ្រះថ្លាក្នុងព្រះពុទ្ធសាសនាហើយនឹងញ៉ាំងលាភនិងសក្ការៈជាច្រើនឱ្យប្រព្រឹត្តទៅ, ក្នុងគ្រានោះ ពួកតិរ្ថិយអ្នកប្រាថ្នាលាភ និងសក្ការៈ នឹងបួសក្នុងព្រះសាសនា ហើយសម្ដែងទិដ្ឋិរបស់ខ្លួន ចម្រូងចម្រាស់ធំ នឹងកើតឡើងក្នុងព្រះសាសនាដោយអាការយ៉ាងនេះ ។

## តិស្សមហាព្រហ្មនឹងដោះស្រាយវិបត្តិនៃព្រះសាសនា

គ្រានោះ ព្រះថេរៈទាំងនោះ បានមានសេចក្ដីបរិវិតក្កៈដូច្នេះថា "កាលចម្រូងចម្រាសនោះ កើតឡើងហើយ តើពួកយើងនឹងទាន់ដែរឬទេហ្ន៎ ?" លំដាប់នោះព្រះថេរៈទាំងអស់ទ្រុះឯង ជ្រាបសេចក្ដីដែលខ្លួនជាអ្នកមិនទាន់ (ហេតុការណ៍) ក្នុងវេលានោះ ទើបគិតថា អ្នកណាហ្ន៎ នឹងជាអ្នកអាចឱ្យអធិករណ៍នោះរម្ងាប់ បាន ហើយបានត្រួតមើលមនុស្សលោកនិងទេវលោកជាន់កាមាវចរទាំងអស់ ក៏មិនបានឃើញអ្នកណា ១ បាន

ឃើញតែស្តេចមហាព្រហ្មឈ្មោះតិស្សៈក្នុងព្រហ្មលោក អ្នកមានអាយុនៅសល់តិច បានអប់រំមគ្គដើម្បីកើតក្នុងព្រហ្មលោកជាន់ខ្ពស់ឡើងទៅ ។ លុះព្រះថេរៈទាំងឡាយនោះឃើញហើយ ទើបបានមានសេចក្តីត្រិះរិះដូច្នេះថា "បើពួកយើងគប្បីធ្វើសេចក្តីឧស្សាហ៍ ដើម្បីត្រូវការឱ្យព្រហ្មនោះកើតក្នុងមនុស្សលោកសោត, ព្រហ្មនោះ ក៏នឹងកាន់បដិសន្ធិក្នុងផ្ទះរបស់មោគ្គលីព្រាហ្មណ៍ ជាពិតប្រាកដ, និងតពីនោះ ក៏នឹងត្រូវលួងលោមដោយមន្តហើយចេញបួស, គ្រាតិស្សទារកនោះបួសហើយយ៉ាងនេះ រៀនសូត្រព្រះពុទ្ធវចនៈទាំងអស់ ជាអ្នកបានសម្រេចបដិសម្ភិទា នឹងញាំញីពួកតិរ្ថិយ វិនិច្ឆ័យអធិករណ៍នោះហើយ លើកស្ទួយព្រះសាសនា" ។

## ពួកព្រះថេរៈទៅអញ្ជើញតិស្សមហាព្រហ្ម

ព្រះថេរៈទាំងនោះទៅកាន់ព្រហ្មលោក ហើយបានពោលពាក្យនេះចំពោះស្តេចតិស្សមហាព្រហ្មថា "ម្នាលសម្លាញ់អ្នកនិរទុក្ខ ក្នុងឆ្នាំទី ១៨ បន្ទាប់ពី ១០០ ឆ្នាំ[១]នេះទៅ ចម្រូងចម្រាស់យ៉ាងធំ នឹងកើតឡើងក្នុងព្រះ

១. ប្រហែលជាទៅអញ្ជើញក្នុងកាលដែលទុតិយសង្គាយនាកន្លងផុត ២០ ឬ៣០ ហើយ ។ ព្រោះថា ព្រះសិគ្គវៈនិងព្រះចណ្ឌវជ្ជី នៅក្មេងអាយុ ៣០ទៅ ៤០ ឯពាក្យថា "បន្ទាប់អំពី ១០០ ឆ្នាំនេះទៅ" គឺ សតវត្សទីពីរនេះ( ដែលសល់៧០-៨០ឆ្នាំ )កន្លងទៅ ។ ព្រះថេរៈក៏ត្រូវមានអាយុ ជាងមួយរយ (១២០-១៣០)ឆ្នាំ ក៏សមល្មមឯតិស្សមហាព្រហ្ម ក៏នៅព្រហ្មលោកទៀតរវាងមួយរយឆ្នាំដែរ ។

សាសនា, និងពួកយើងបានត្រួតមើលឋាន មនុស្សនិងឋានទេវតាជាន់ឆកាមាវចរទាំងអស់ ក៏មិនបានឃើញអ្នកណា ៗ ដែលអាចដើម្បីនឹងលើកស្ទួយព្រះសាសនាបាន, គន់រកមើលរហូតដល់អស់ព្រហ្មលោក ទើបបានជួបលោកដ៏ចម្រើន, ដូចពួកអាត្មាសូមឱកាស លោកសប្បុរស សូមលោកឱ្យបដិញ្ញា (ដល់ពួកអាត្មា) ដើម្បីកើតក្នុងមនុស្សលោក ហើយលើកស្ទួយព្រះសាសនារបស់ព្រះទសពលផងចុះ" ។

## តិស្សមហាព្រហ្មទទួលបេ្តជ្ញាមកកើតឋានមនុស្ស

កាលព្រះថេរៈទាំងឡាយ ពោលអញ្ជើញយ៉ាងនោះហើយ ស្ដេចមហាព្រហ្មទើបត្រិះរិះថា "បានឮថា យើងនឹងជាអ្នកអាចដើម្បីជម្រះចម្រូងចម្រាស់ ដែលនឹងកើតឡើងក្នុងព្រះសាសនា ហើយលើកស្ទួយព្រះសាសនា" ដូច្នេះ ហើយជាអ្នករីករាយ សប្បាយចិត្ត បានឱ្យបដិញ្ញាទទួលថា "ល្អណាស់" ។ ព្រះថេរៈ ទាំងឡាយពិចារណាកិច្ចដែលគួរធ្វើនោះ ក្នុងព្រហ្មលោកសម្រេចហើយ ក៏នាំគ្នាត្រឡប់មកវិញ ។

## ពួកព្រះថេរៈដាក់ទណ្ឌកម្មដល់ព្រះសិគ្គវៈនិងព្រះចណ្ឌវជ្ជី

សម័យនោះឯង ព្រះថេរៈទាំង ២ រូបគឺ ព្រះសិគ្គវត្ថេរ និងព្រះចណ្ឌវជ្ជីថេរៈ នៅជាព្រះនវកៈ ។ ព្រះថេរៈទាំងនោះ ជាភិក្ខុកម្លោះ ទ្រទ្រង់ព្រះត្រៃបិដក សម្រេចបដិសម្ភិទា អស់អាសវៈហើយ ជាសទ្ធិវិហារិករបស់ព្រះសោណកៈ ។ ព្រះថេរៈទាំង ២ រូបនោះ មិនបានមកចូលរួមរម្ងាប់អធិករណ៍នោះ ។ ទើបព្រះថេរៈទាំងឡាយពោលថា "ម្នាលអាវុសោ ពួកលោកមិនបានជាអ្នក រួមគិតរបស់ពួកយើង ក្នុងអធិករណ៍នេះទេ, ព្រោះហេតុនោះ ទណ្ឌកម្មនេះ ចូរមានដល់ពួកលោក គឺ ស្ដេចមហាព្រហ្មឈ្មោះតិស្សៈ នឹងចុះមកកាន់បដិសន្ធិក្នុងផ្ទះរបស់មោគ្គលីព្រាហ្មណ៍, បណ្ដាលោកទាំងពីរ មួយរូបចូរដឹកនាំស្ដេចតិស្សមហាព្រហ្មនោះមកបួស, មួយរូបទៀត ចូរឱ្យរៀនព្រះពុទ្ធវចនៈ" ដូច្នេះ

ព្រះថេរៈសូម្បីទាំងនោះគ្រប់ ៗរូប មានព្រះសព្វកាមីជាដើម
ជាអ្នកមានឫទ្ធិច្រើន រុងរឿងហើយក្នុងលោក តាំងនៅដរាប
ដល់អស់អាយុហើយក៏បរិនិព្វាន ដូចគំនរភ្លើងឆេះសន្ធោស
ន្ធៅ រលត់ទៅហើយដូច្នោះ សូម្បីព្រះថេរៈទាំងនោះ អស់
អាសវៈហើយ ដល់ភាពជាអ្នកជំនាញបែកធ្លាយក្នុងបដិសម្ភិទា
គ្រាធ្វើទុតិយសង្គាយនា ជម្រះព្រះសាសនាឱ្យហ្មត់ចត់ ធ្វើ

ហេតុដើម្បីសេចក្តីចម្រើននៃព្រះសទ្ធម្ម សូម្បីក្នុងអនាគត ហើយ ក៏ចូលដល់អំណាចនៃភាពជាអ្នកមិនទៀង ធីរជន ជ្រាបសេចក្តីនូវសង្ខារជារបស់មិនទៀង ជារបស់លាមក ឈានកន្លងបានដោយលំបាកយ៉ាងនេះហើយ ក៏គួរប្រារព្ធ ព្យាយាម ដើម្បីសម្រេចអមតបទដែលជាបទឋិតថេររហូត ដូច្នេះហោង ។

ពណ៌នាទុតិយសង្គីតិ ក៏បានចប់ស្រេចហើយដោយអាកាសទាំងពួង តាម លំដាប់ពាក្យត្រឹមតែប៉ុណ្ណេះ ។

## ចាប់ផ្តើមរឿងតតិយសង្គាយនា

## តិស្សមហាព្រហ្មកើតក្នុងមនុស្សលោក

សូម្បីតិស្សមហាព្រហ្មនោះឯង ឃ្លាតចាកព្រហ្មលោកហើយ បានកាន់បដិសន្ធិក្នុងផ្ទះរបស់មោគ្គលីព្រាហ្មណ៍ ។ ចំណែកព្រះសិគ្គវត្ថេរ ចាប់ផ្តើមតាំងពីតិស្សមហាព្រហ្មនោះចាប់បដិសន្ធិ ក៏ចូលទៅបិណ្ឌបាតឯផ្ទះរបស់ព្រាហ្មណ៍រហូតដល់អស់ ៧ ឆ្នាំ ។ សូម្បីថ្ងៃណាមួយ លោកក៏មិនបានបបរត្រឹមតែមួយបោយឬបាយត្រឹមតែមួយវែក ។ ក៏កាលកន្លងទៅដល់ ៧ ឆ្នាំ ក្នុងថ្ងៃ មួយលោកបានត្រឹមតែពាក្យនិយាយថា "សូមនិមន្តទៅខាងមុខចុះ លោកម្ចាស់" ។

## ព្រាហ្មណ៍បិតារបស់តិស្សមហាព្រហ្មជួបព្រះសិគ្គវត្ថេរ

ក្នុងថ្ងៃនោះឯង សុម្បីព្រាហ្មណ៍ធ្វើកិច្ចដែលគួរធ្វើឯណាមួយយ៉ាង ខាងក្រៅស្រុកហើយ ដើរត្រឡប់មក ក៏ជួបព្រះថេរៈត្រង់មកសួន ទើបទូលសួរថា "បព្វជិតដ៏ចម្រើន លោកបានមកកាន់ផ្ទះរបស់ខ្ញុំព្រះករុណាហើយឬ ?"

ព្រះថេរៈ. "អើ អាត្មាបានទៅហើយ ព្រាហ្មណ៍"

ព្រាហ្មណ៍. "លោកបានអ្វីខ្លះឬ ?"

ព្រះថេរៈ. "អើ បាន ព្រាហ្មណ៍"

ព្រាហ្មណ៍នោះ ទៅដល់ផ្ទះហើយសួរថា អ្នកណាបានឱ្យអ្វី ៗ ដល់បព្វជិតនោះខ្លះឬ ? ពួកជនក្នុងផ្ទះឆ្លើយថា មិនបានឱ្យអ្វី ៗទេ ។

## មោគ្គលីព្រាហ្មណ៍ចាំចាប់មុសារបស់ព្រះថេរៈ

ក្នុងថ្ងៃទី ២ ព្រាហ្មណ៍អង្គុយនៅត្រង់ទ្វារផ្ទះនុ៎ះឯង ដោយគិតថា "ថ្ងៃនេះ យើងនឹងសង្កត់សង្កិនបព្វជិត ដោយការពោលកុហក" ។ ក្នុងថ្ងៃទី ២ ព្រះថេរៈ ក៏ទៅដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍លុះឃើញព្រះថេរៈ ក៏និយាយយ៉ាងនេះថា "ថ្ងៃម្សិលមិញ លោកមិនបានអ្វី ៗ ក្នុងផ្ទះរបស់ខ្ញុំព្រះករុណាឡើយ ក៏ប្រាប់ថា បាន ការពោលកុហកគួរដល់លោកឬហ្ន៎ ?"

ព្រះថេរៈ និយាយថា "ព្រាហ្មណ៍ ក្នុងផ្ទះរបស់លោក អាត្មាភាពមិនបានសូម្បីត្រឹមតែពាក្យនិយាយថា 'សូមនិមន្តទៅខាងមុខចុះ លោកម្ចាស់, ដូច្នេះ ដល់ ៧ ឆ្នាំ ថ្ងៃម្សិលមិញបានពាក្យនិយាយថា 'សូមនិមន្តទៅខាងមុខចុះ លោកម្ចាស់, កាលបើដូច្នោះ ទើបអាត្មានិយាយថាបានយ៉ាងនេះ សំដៅយកបាននូវការបដិសណ្ឋារៈនោះ" ។

## មោគ្គលិព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះថេរៈ

ចំណែកព្រាហ្មណ៍គិតថា "សមណៈទាំងនេះ បានសូម្បីត្រឹមតែការបដិសណ្ឋារៈក៏សរសើរថា បាន (បើ)បានរបស់ដែលគួរទំពា គួរបរិភោគអ្វីយ៉ាងដទៃហើយ រឿងអីថានឹងមិនសរសើរហ្ន៎" ។ ព្រាហ្មណ៍ជ្រះថ្លាយ៉ាងនេះហើយ ទើបបង្គាប់ឱ្យថ្វាយភិក្ខាមួយវែក និងព្រមទាំងបាយដែលគួរដល់ភិក្ខានោះអំពីភត្តដែលគេចាត់ទុកដើម្បីខ្លួន ហើយឆ្លើយប្រាប់ថា "លោកម្ចាស់នឹងបានភិក្ខាប្រភេទនេះគ្រប់វេលា" ដូច្នេះ ។ ចាប់ផ្ដើមតាំងពីថ្ងៃស្អែក ព្រាហ្មណ៍នោះ បានឃើញសេចក្ដីស្ងប់រៀបរយរបស់ព្រះថេរៈ ដែលកំពុងចូលទៅ ក៏ជ្រះថ្លាក្រៃលែងឡើង ហើយសូមអង្វរព្រះថេរៈ ដើម្បីត្រូវការឱ្យធ្វើភត្តកិច្ចក្នុងផ្ទះរបស់ខ្លួន រហូតដល់អស់កាលជានិច្ច ។ ព្រះថេរៈទទួលនិមន្តហើយ ក៏បានធ្វើភត្តកិច្ចរាល់ថ្ងៃ ៗ កាលនឹងត្រឡប់ ក៏បានសម្ដែងព្រះពុទ្ធវចនៈខ្លះបន្តិចបន្តួច ទើបត្រឡប់ទៅ ។

## ព្រះសិគ្គវត្ថេរចាប់ផ្ដើមប្រាស្រ័យនឹងតិស្សមាណព

សូម្បីមាណពនោះឯង មានអាយុបាន ១៦ ឆ្នាំប៉ុណ្ណោះ ក៏បានដល់ត្រើយ នៃត្រៃវេទ ។ អ្នកដទៃណា ៗ នឹងអង្គុយ ឬ ដេកលើអាសនៈ ឬទីដេករបស់សត្វបរិសុទ្ធិ ដែលមកពីព្រហ្មលោក មិនបាន ។ វេលាណា តិស្សមាណពនោះ ទៅផ្ទះរបស់អាចារ្យ, វេលានោះ ពួកអ្នកបម្រើ ក៏យកសំពត់សគ្រប គ្រែនិងតាំងរបស់គេព្យួរទុក ។ ព្រះថេរៈត្រិះរិះថា "ឥឡូវនេះ ជាកាលដែលនឹងឱ្យមាណពបួសបាន និងយើងក៏មកទីនេះយូរហើយ, ទាំងការនិយាយចរចាអ្វី ៗ នឹងមាណពក៏មិនបានកើតឡើង, ណ្ហើយចុះ ឥឡូវនេះការនិយាយ (នឹងមាណពនោះ) នឹងកើតឡើងបាន ព្រោះអាស្រ័យបល្ល័ង្ក (របស់គេ) ដោយឧបាយយ៉ាងនេះ" ។ ទើបលោកទៅផ្ទះ (របស់មាណពនោះ) ហើយអធិដ្ឋានឱ្យអាសនៈអ្វី ៗ យ៉ាងដទៃក្នុងផ្ទះនោះមិនប្រាកដ វៀរលែងតែបល្ល័ង្ករបស់មាណព ។ អ្នកក្នុងផ្ទះរបស់ព្រាហ្មណ៍ឃើញព្រះថេរៈហើយ កាលមិនឃើញទីអង្គុយណា ៗ យ៉ាងដទៃ ក៏ បានក្រាលបល្ល័ង្ករបស់មាណពថ្វាយព្រះថេរៈ ។ ព្រះថេរៈក៏អង្គុយ លើបល្ល័ង្ក ។ ចំណែកមាណព ក៏ត្រឡប់មកពីផ្ទះរបស់អាចារ្យក្នុងខណៈនោះឯង ឃើញព្រះថេរៈអង្គុយនៅលើបល្ល័ង្ករបស់ខ្លួន ក៏ខឹងក្រោធ អាក់អន់ចិត្ត ទើបនិយាយថា "អ្នកណា

ឱ្យក្រាលបល្ល័ង្ករបស់ខ្ញុំដល់សមណៈ ?" ព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ កាលមាណពមានសេចក្តីប្រទុសរ៉ាយស្ងប់ចុះហើយ ទើបបាននិយាយយ៉ាងនេះថា "ម្នាលមាណព ក៏អ្នកដឹងមន្តអ្វី ៗ ខ្លះឬ ?"

មាណពឆ្លើយប្រាប់ថា "បពិត្របព្វជិតដ៏ចម្រើន ក្នុងវេលានេះ កាលខ្ញុំព្រះករុណាមិនដឹងមន្ត, អ្នកដទៃឯណាហ្ន៎នឹងដឹងបាន" ដូច្នេះហើយ ក៏(បែរត្រឡប់) សួរព្រះថេរៈថា "ចុះចំណែកលោកម្ចាស់វិញ ដឹងមន្តឬ ?"

ព្រះថេរៈនិយាយថា "ចូរសួរចុះមាណព លោកសួរហើយ អាចនឹងដឹងបាន" ។

## តិស្សមាណពសួរបញ្ហានឹងព្រះថេរៈ

គ្រានោះឯង មាណពបានសួរព្រះថេរៈក្នុងសេចក្តីដែលជាចំណុច (កំបាំង) ដែលមាននៅក្នុងត្រៃវេទព្រមទាំងនិឃណ្ឌុសាស្ត្រ[១] កេដភសាស្ត្រ[២] ព្រមទាំងអក្សរប្បភេទមានឥតិហាស[៣] ជាគម្រប់ ៥ ដែលមាណពនោះឯង សូម្បីទាំងអាចារ្យរបស់គេក៏មិនឃើញន័យដោយខ្លួនឯង ។

១. និឃណ្ឌុសាស្ត្រ ពោលអំពីឈ្មោះវត្ថុមានដើមឈើជាដើម ។ ២. កេដភសាស្ត្រ ពោលអំពី កិរិយាជាប្រយោជន៍ដល់កវី ។ ៣. ឥតិហាស ឈ្មោះសៀវភៅពោលអំពី ពង្សាវតារវែងអន្លាយ មានភារតយុទ្ធជាដើម ដែលពោលប្រព័ន្ធទុកពីកាលមុន ។

ព្រះថេរៈ សុម្បីតាមប្រក្រតីក៏ជាអ្នកដល់ត្រើយនៃត្រៃវេទ និងឥឡូវនេះ ក៏បានសម្រេចបដិសម្ភិទា ព្រោះហេតុនោះ ក្នុងការដោះស្រាយបញ្ហាទាំងនោះ ទើបមិនធ្ងន់សម្រាប់លោក, ដូច្នោះ ទើបលោកដោះស្រាយបញ្ហាទាំងនោះ ក្នុងខណៈ នោះឯង ហើយបាននិយាយចំពោះមាណពថា "ម្នាលមាណព លោកសួរយើង ច្រើនល្មមហើយ គ្រានេះសុម្បីយើងក៏នឹងសួរបញ្ហានឹងលោកត្រឹមតែមួយប្រការ លោកនឹងព្យាករណ៍ដល់យើងទេ ?"

មាណពឆ្លើយប្រាប់ថា "បពិត្របព្វជិតដ៏ចម្រើន ចូរសួរចុះ លោកម្ចាស់ខ្ញុំព្រះករុណានឹងដោះស្រាយ" ។

## ព្រះសិគ្គវត្ថេរសួរបញ្ហានឹងមាណព

ទើបព្រះថេរៈសួរបញ្ហានេះ ក្នុងចិត្តយមកថា "ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ដូច្នេះ ។

មាណព មិនអាចនឹងកំណត់ (បញ្ហា)ទាំងខាងលើ ឬខាងក្រោមបាន ទើបទូលសួរថា "បពិត្របព្វជិតដ៏ចម្រើន នេះឈ្មោះមន្តអ្វី ?" ព្រះ

១. អភិ. យមក. ៩១. ១/១ ។

ថេរៈ “នេះឈ្មោះពុទ្ធមន្ត មាណព”

មាណព. “លោកម្ចាស់ដ៏ចម្រើន ក៏លោកអាចឱ្យពុទ្ធមន្តនេះ ដល់ខ្ញុំព្រះករុណាបានទេ ?”

ព្រះថេរៈ. “មាណព អាត្មាភាពអាចឱ្យដល់បុគ្គលដែលកាន់បព្វជ្ជាដូច អាត្មាភាព”

## តិស្សមាណពសូមអនុញ្ញាតមាតាបិតាបួស

តពីនោះ មាណពចូលទៅរកមាតាបិតាហើយនិយាយថា “បព្វជិតរូបនេះ រមែងដឹងពុទ្ធមន្ត និងលោកក៏មិនឱ្យដល់អ្នកដែលមិនបួសនៅក្នុងសំណាក់របស់លោក ខ្ញុំនឹងបួសក្នុងសំណាក់របស់លោកនោះ ហើយរៀនយកមន្ត” ។

គ្រានោះ មាតាបិតារបស់គេសម្គាល់ថា “កូនរបស់យើង សូម្បីបួសហើយចូររៀនមន្តចុះ គ្រារៀនហើយ ក៏នឹងត្រឡប់មកផ្ទះវិញ” ដូច្នេះទើបអនុញ្ញាតថា “ចូររៀនចុះ កូន” ។

ព្រះថេរៈប្រាប់កម្មដ្ឋាន គឺ អាការ ៣២ មុន ហើយឱ្យតិស្សកុមារបព្វជ្ជា ។ តិស្សសាមណេរនោះ ធ្វើបរិកម្មក្នុងកម្មដ្ឋាននោះ រយៈកាលមិនយូរប៉ុន្មានក៏តាំងនៅក្នុងសោតាបត្តិផល ។

# ព្រះថេរៈឱ្យសាមណេរទៅកាន់សំណាក់ព្រះចណ្ឌវជ្ជី

លំដាប់នោះ ព្រះថេរៈត្រិះរិះថា "សាមណេរតាំងនៅក្នុងសោតាបត្តិផលហើយ ឥឡូវនេះ លោកមិនគួរនឹងឃ្លាតចាកព្រះសាសនា ក៏បើយើងនឹងបង្រៀនកម្មដ្ឋានដល់លោក ឱ្យក្រៃលែងឡើងទៅ លោកក៏នឹងគប្បីសម្រេចជាព្រះអរហន្ត នឹងគប្បីជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ដើម្បីនឹងរៀនព្រះពុទ្ធវចនៈ, ឥឡូវនេះ ក៏ជាវេលាដែលនឹងបញ្ជូនលោក ទៅកាន់សំណាក់របស់ព្រះចណ្ឌវជ្ជីថេរៈ" ។

លំដាប់នោះ ព្រះថេរៈក៏និយាយចំពោះសាមណេរនោះថា "មកចុះសាមណេរ លោកចូរទៅកាន់សំណាក់របស់ព្រះថេរៈ រៀនយកព្រះពុទ្ធវចនៈចុះ ចូរសួរដល់ការមិនមានរោគតាមពាក្យបង្គាប់របស់យើង, និងចូរទូលយ៉ាងនេះថា 'ព្រះឧបជ្ឈាយ៍ (របស់ខ្ញុំព្រះករុណា) បញ្ជូនខ្ញុំព្រះករុណាមកកាន់សំណាក់របស់លោកម្ចាស់', កាលលោកសួរថា 'ព្រះឧបជ្ឈាយ៍របស់លោកឈ្មោះអ្វី ?, គប្បីឆ្លើយប្រាប់ថា 'ឈ្មោះព្រះសិគ្គវៈលោកម្ចាស់', កាលលោកសួរថា 'យើងឈ្មោះអ្វី ?, គប្បីទូលយ៉ាងនេះថា 'ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា ស្គាល់ឈ្មោះរបស់លោកម្ចាស់'" ។

## សាមណេរតិស្សៈទៅដល់សំណាក់ព្រះចណ្ឌវជ្ជីថេរៈ

សាមណេរតិស្សៈទទួលថា "ល្អណាស់ លោកម្ចាស់" ហើយក្រាបថ្វាយបង្គំធ្វើប្រទក្សិណព្រះថេរៈហើយ ធ្វើដំណើរទៅកាន់សំណាក់ព្រះចណ្ឌវជ្ជីថេរៈដោយលំដាប់ ថ្វាយបង្គំហើយ បានឈរក្នុងចំណែកមួយខាង ។

ព្រះថេរៈសួរថា. សាមណេរ លោកមកពីណា ?

សាមណេរ. ព្រះឧបជ្ឈាយ៍បញ្ជូនខ្ញុំព្រះករុណា ឱ្យមកកាន់សំណាក់របស់លោកម្ចាស់ ។

ព្រះថេរៈ. ព្រះឧបជ្ឈាយ៍របស់លោក ឈ្មោះអ្វី ?

សាមណេរ. ឈ្មោះព្រះសិគ្គវត្ថេរ លោកម្ចាស់ ។

ព្រះថេរៈ. យើងឈ្មោះអ្វី ?

សាមណេរ. ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា ស្គាល់ឈ្មោះរបស់លោកម្ចាស់ ។

ព្រះថេរៈ. ចូរទុកបាត្រនិងចីវរ ក្នុងឥឡូវនេះចុះ ។

សាមណេរ. ល្អណាស់ លោកម្ចាស់

## សាមណេរតិស្សៈ បដិបត្តិកិច្ចវត្តតាមរបៀបព្រះវិន័យ

សាមណេរ ទុកបាត្រនិងចីវរហើយ ក្នុងថ្ងៃស្អែកក៏បោសសំអាតបរិវេណ ហើយចូលទៅតាំងទឹកឆាន់និងឈើជម្រះធ្មេញទុក ។

ព្រះថេរៈបោសសំអាតស្ថានទី ដែលសាមណេរបោសជាដែលទៀត ចាក់ទឹកនោះចោល ហើយនាំទឹកដទៃមកទុក និងនាំឈើជម្រះធ្មេញនោះចេញទៅ ហើយកាន់យកឈើជម្រះធ្មេញដទៃ ។ ព្រះថេរៈធ្វើយ៉ាងនេះដល់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទើបសួរ (សាមណេរ) ជាដែលទៀត ។ សាមណេរ ក៏ទូលព្រះថេរៈជាដែលទៀត ដូចដែលបានពោលមកហើយក្នុងមុននោះឯង ។

## ព្រះចណ្ឌវជ្ជិថេរៈឱ្យសាមណេរតិស្សៈ រៀនព្រះពុទ្ធវចនៈ

ព្រះថេរៈ ដឹងបានល្អថា "ព្រាហ្មណ៍នេះ ជាអ្នកប្រដៅងាយហ្ន៎" ទើបសួរថា "លោកមកដើម្បីប្រាថ្នាអ្វី ?"

សាមណេរឆ្លើយប្រាប់ថា "ដើម្បីប្រាថ្នានឹងរៀនព្រះពុទ្ធវចនៈ លោកម្ចាស់"

ព្រះថេរៈបង្គាប់ថា "លោកចូររៀនក្នុងពេលឥឡូវនេះចុះ" ទើបសាមណេរ ចាប់ផ្តើមឱ្យរៀនព្រះពុទ្ធវចនៈ តាំងពីថ្ងៃស្អែកទៅ ។

## សាមណេរតិស្សៈ រៀនព្រះពុទ្ធវចនៈ ព្រមទាំងអដ្ឋកថា

តិស្សៈ ដែលនៅជាសាមណេរនុ៎ះឯង រៀនយកព្រះពុទ្ធវចនៈទាំងអស់ព្រមទាំងអដ្ឋកថា វៀរព្រះវិន័យបិដក ។ ក៏ក្នុងវេលាឧបសម្បទាហើយ មិនទាន់បាន ( ១ ) វស្សាឡើយ បានជាតិបិដកធរ ( អ្នកទ្រទ្រង់ត្រៃបិដក ) ។ អាចារ្យនិងឧបជ្ឈាយ៍ ប្រគល់ព្រះពុទ្ធវចនៈទាំងអស់ ទុកក្នុងដៃរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរហើយ តាំងនៅដរាបអស់អាយុ ក៏បរិនិព្វាន ។

ចំណែកព្រះមោគ្គលីបុត្តតិស្សត្ថេរ ចម្រើនកម្មដ្ឋានហើយ សម្រេចជាព្រះអរហន្ត ក្នុងសម័យតមក បង្រៀនព្រះធម៌ និងព្រះវិន័យដល់ភិក្ខុជាច្រើន ។

## ព្រះរាជប្រវត្តិរបស់ព្រះបាទអសោកមហារាជ

សម័យនោះឯង ព្រះបាទពិន្ទុសារមានព្រះរាជឱរស ១០១ ព្រះអង្គ ព្រះបាទអសោក ទ្រង់បង្គាប់ឱ្យសម្លាប់ព្រះរាជឱរសទាំងនោះចេញអស់ វៀរលែងតែតិស្សកុមារ អ្នករួមព្រះមាតា ជាមួយគ្នានឹងព្រះអង្គ ។ កាលស្តេចបង្គាប់ឱ្យសម្លាប់ មិនទាន់ទ្រង់បានអភិសេកឡើយ គ្រងរាជ្យដល់ទៅ ៤ ឆ្នាំ កាលកន្លងទៅបាន ៤ ឆ្នាំ ក្នុងឆ្នាំទី ១៨ បន្ទាប់ពី ២០០ ឆ្នាំ នៃឆ្នាំបរិនិព្វានរបស់ព្រះតថាគតមក ទើបទ្រង់ដល់ការអភិសេកជាឯករាជ្យ ក្នុងជម្ពូទ្វីបទាំងអស់ ។

## ព្រះរាជឫទ្ធិផ្សាយទៅខាងលើខាងក្រោម ១ យោជន៍

ក៏ដោយអានុភាពនៃការអភិសេករបស់ទ្រង់ ព្រះរាជឫទ្ធិទាំងឡាយនេះ បានមកហើយ ។ ព្រះរាជអំណាចផ្សាយទៅខាងក្រោម មហាប្រថពីប្រមាណមួយយោជន៍ ក្នុងអាកាសខាងលើ ក៏ដូចគ្នា ។

ព្រះរាជា ទ្រង់មានសទ្ធាកើតហើយក្នុងព្រះសាសនា ទ្រង់បាន (បែងចែក) ទឹក ៨ ឆ្នាំង អំពីទឹកផឹក ១៦ ឆ្នាំង ដែលពួកទេវតានាំមកពីស្រះអនោតត្តមួយថ្ងៃ ៨ អម្រែក ថ្វាយដល់ព្រះភិក្ខុសង្ឃ ថ្វាយដល់ភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ព្រះត្រៃបិដក ប្រមាណ ៦០ រូប (មួយថ្ងៃ) ២ ឆ្នាំង ព្រះរាជទានដល់ព្រះនាង អសន្ធិមិត្តា ដែលជាព្រះអគ្គមហេសី (មួយថ្ងៃ) ២ ឆ្នាំង ព្រះរាជទានដល់ពួកស្ត្រីរបាំ មួយម៉ឺនប្រាំមួយពាន់នាក់ (មួយថ្ងៃ) ២ ឆ្នាំង ទ្រង់ប្រើប្រាស់ដោយព្រះអង្គឯង (មួយថ្ងៃ) ២ ឆ្នាំង ។ កិច្ចគឺ ការជម្រះព្រះទន្តនិងការជម្រះធ្មេញរាល់ ៗ ថ្ងៃរបស់ព្រះរាជា ព្រះមហេសីរបស់ពួកស្ត្រីរបាំមួយម៉ឺនប្រាំមួយពាន់នាក់ និងរបស់ភិក្ខុប្រមាណប្រាំមួយម៉ឺនរូប រមែងសម្រេចបានដោយឈើជម្រះធ្មេញ ឈ្មោះនាគលតាដែលទន់ល្មៃ មានឱជារសដែលមាននៅក្នុងព្រៃ ហិមពាន្តដែលទេវតាទាំងឡាយនុ៎ះឯងនាំមកថ្វាយរាល់ ៗ ថ្ងៃ ។

មួយទៀត ទេវតាទាំងឡាយ នាំកន្ទួតព្រៃដែលជាព្រះឱសថ សម៉ ដែលជាព្រះឱសថ និងស្វាយទុំដែលមានពណ៌ដូចមាស ដែលសម្បូណ៌ដោយក្លិននិងរស មកថ្វាយចំពោះព្រះរាជានោះរាល់ ៗ ថ្ងៃដូចគ្នា ហើយបាននាំព្រះភូសាគ្រង ព្រះភូសាដណ្ដប់ បញ្ចពណ៌, សំពត់ជូតព្រះហស្ត ដែលមានពណ៌លឿង និងទឹកទិព្វអំពីស្រះឆទ្ទន្តមកថ្វាយរាល់ថ្ងៃយ៉ាងនោះដែរ ។

ចំណែកស្ដេចនាគទាំងឡាយ ក៏នាំគ្រឿងព្រះសុគន្ធសម្រាប់កក់ព្រះសិរសា ព្រះសុគន្ធសម្រាប់លាបព្រះវរកាយ សំពត់មានពណ៌ស្រដៀងផ្កាម្លិះ ដែលមិនបានត្បាញដោយអំបោះ ដើម្បីជាព្រះភូសាដណ្ដប់ និងថ្នាំបន្តក់ព្រះនេត្រដែលមានតម្លៃច្រើន អំពីនាគពិភពមកថ្វាយចំពោះព្រះរាជានោះរាល់ ៗ ថ្ងៃដូចគ្នា ។

សត្វសេកទាំងឡាយ ក៏ពាំស្រូវសាលី៩ពាន់រទេះដែលកើតឯង ក្នុងស្រះឆទ្ទន្តនុ៎ះឯង មកថ្វាយរាល់ ៗ ថ្ងៃ ។ កណ្ដុរទាំងឡាយ ក៏បន្ទិចស្រូវទាំងនោះឱ្យអស់អង្កាមនិងកន្ទក់ ។ អង្ករដែលបាក់សូម្បីតែមួយគ្រាប់ក៏មិនមាន ។ អង្ករនេះឯង ដល់ភាពជាព្រះក្រយាហារសោយនៃព្រះរាជា ក្នុងទីគ្រប់ស្ថាន ។ ឃ្មុំទាំងឡាយ ក៏ធ្វើទឹកឃ្មុំ ។ ពួកខ្លាឃ្មុំក៏ពុះឧសត្រង់រោងបាយ ។ ពួកសត្វការវិកក៏ហើរមកស្រែកបញ្ចេញសំឡេងយ៉ាងពីរោះ ធ្វើពលីកម្មថ្វាយចំពោះព្រះរាជា ។

## ស្ដេចកាឡនាគនិម្មិតព្រះពុទ្ធរូបទ្រង់ឱ្យមើល

ព្រះពលីរាជាដែលទ្រង់ប្រកបហើយដោយឫទ្ធិទាំងនេះ ថ្ងៃមួយទ្រង់ប្រើសន្ទលិកព័ន្ធ (ច្រវាក់)ដែលធ្វើពីមាស ឱ្យនាំស្ដេចនាគឈ្មោះកាឡៈ ដែលមានអាយុរហូតដល់មួយកប្ប អ្នកណា ឃើញព្រះរូបរបស់ព្រះពុទ្ធទាំង ៤ ព្រះអង្គអញ្ជើញឱ្យពៃនលើបល្ល័ង្ក ដែលមានតម្លៃច្រើនខាងក្រោមស្វេតឆត្រ ទ្រង់ធ្វើការបូជា ដោយផ្កាឈើទាំងឡាយដែលកើតក្នុងទឹក ទាំងដែលកើតលើគោក ច្រើនរយពណ៌និងដោយសុវណ្ណបុប្ផាទ្រង់ហែហមដោយនាងរបាំ ១៦.០០០ នាក់ប្រដាប់ហើយដោយអលង្ការទាំងពួងជុំវិញ ត្រាស់ថា "អញ្ជើញលោកធ្វើព្រះរូបរបស់ព្រះសម្មាសម្ពុទ្ធដែលទ្រង់ញ៉ាំងចក្រ គឺ ព្រះសទ្ធម្មដ៏ប្រសើរឱ្យវិលទៅ ទ្រង់ព្រះញាណដែលមិនមានទីបំផុត ឱ្យដល់គន្លងនៃកែវភ្នែកទាំងនេះរបស់ខ្ញុំចុះ" ដូច្នេះទតឃើញព្រះពុទ្ធរូបដែលស្ដេចនាគឈ្មោះកាឡៈនោះនិម្មិតហើយ ហាក់ដូចជាផ្ទៃទឹកដែលប្រដាប់ហើយដោយផ្កាឈូក ឧប្បល និងបុណ្ឌរិករីកស្គុះស្គាយ ហាក់ដូចជាផ្ទៃមេឃដែលព្រោងព្រាតដោយភាពចិញ្ចាចចិញ្ចែងដោយការសាយចេញនៃកាំរស្មីរបស់ក្រុមតារា ព្រោះសេចក្ដីដែលព្រះពុទ្ធរូបនោះ ទ្រង់មានព្រះសិរីដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការប្រដាប់ហើយដោយអនុព្យញ្ជនៈ ៨០ ប្រការ ដែលកើតហើយដោយ

អំណាចនៃបុណ្យដ៏ពណ្ណរាយពេញព្រះសរីរៈទាំងអស់ ស្រស់ល្អ ដោយព្រះសិរីសោភ័ណ្ឌឆើតឆាយដោយព្រះកេតុមាលា ដែលប្រាសចាកមន្ទិលពណ៌ផ្សេង ៗ ដូចជាកំពូលនៃភ្នំមាស ដែលឆ្វេតឆ្វាត់ ដោយពន្លឺរន្ទះនិងពន្លឺផ្លេកបន្ទោរ ដែលលាយចូលគ្នានឹងពន្លឺប្រាក់ ដូចជានឹងស្រូបទាញកែវភ្នែកនៃគណៈព្រហ្ម ពួកទេវតា ក្រុមមនុស្ស ហ្វូងនាគ និងពួកយក្ខ ព្រោះព្រះពុទ្ធរូបនោះ មានសេចក្ដីចិញ្ចាច ចិញ្ចែងដោយការឆ្វេតឆ្វាត់នៃព្រះរស្មីដែលផ្សាយចេញម្នាងមួយព្យាមវង់ព័ទ្ធជុំវិញ រស្មីដ៏វិចិត្រដោយពណ៌មានពណ៌ខៀវលឿងក្រហមជាដើម ទ្រង់បានធ្វើការបូជាដែលបាននាមថា បូជាដោយកែវ ភ្នែក រហូតដល់អស់ ៧ ថ្ងៃ ។

## ព្រះបាទអសោកទ្រង់មិនជ្រះថ្លាអ្នកបួសក្រៅសាសនា

បានឮថា ព្រះរាជាទ្រង់ទទួលការអភិសេកហើយ ទ្រង់បានរាប់អានលទ្ធិពាហិរបាសណ្ឌៈ[១] រហូតដល់អស់វេលា ៣ ឆ្នាំ មែនពិត ។ ក្នុងឆ្នាំទី ៤ ទើបទ្រង់បានជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ បានឮថា ព្រះបាទពិន្ទុសារព្រះជនករបស់ព្រះរាជាអង្គនោះ ទ្រង់បានរាប់អានពួកព្រាហ្មណ៍ ។

១. បាសណ្ឌៈ គឺ លទ្ធិដែលកាន់ខុស ឬមេលទ្ធិអ្នកកាន់ខុស ប្រែតាមរូបស័ព្ទថា លទ្ធិអន្ទាក់ គឺ អន្ទាក់ទាក់ចិត្តសត្វ មាន ២ គឺ តណ្ហាបាសៈ អន្ទាក់គឺ តណ្ហា ១ ទិដ្ឋិបាសៈ អន្ទាក់គឺ ទិដ្ឋិ ១ ។

ទ្រង់បានតាំងនិច្ចភត្តទុកដល់ ពួកព្រាហ្មណ៍ និងដល់តាបសនិង បរិព្វាជកជាដើម អ្នកកាន់លទ្ធិបាសណ្ឌៈដែលជារបស់ប្រចាំជាតិព្រាហ្មណ៍ មានប្រមាណ ៦ សែននាក់ ។ សូម្បីព្រះបាទអសោក ក៏ទ្រង់ថ្វាយទាន ដែលព្រះជនកឱ្យប្រព្រឹត្តទៅហើយ ខាងក្នុងបុរីរបស់ព្រះអង្គដូចយ៉ាងនោះ ក្នុងថ្ងៃមួយទ្រង់ប្រថាប់ឈរត្រង់សីហបញ្ជរ បានទតឃើញពួកព្រាហ្មណ៍ ទាំងនោះ អ្នកកំពុងបរិភោគ (អាហារ) ដោយមារយាទ ដែលឃ្លាតឆ្ងាយ អំពីសេចក្តីស្ងប់រៀបរយ មិនមានសេចក្តីសង្រួមឥន្ទ្រិយ ទាំងមិនបាន ទទួលហ្វឹកហាត់ឥរិយាបថ (កិរិយាមារយាទ) ទើបទ្រង់ត្រិះរិះថា "ការ ដែលយើងពិចារណាជាមុនហើយឱ្យទាន ដូច្នេះ ក្នុងខេត្តដែលសមរម្យ ទើបគួរ" គ្រាទ្រង់ត្រិះរិះយ៉ាងនេះហើយ ទើបត្រាស់ហៅពួកអាមាត្យថា "ទៅចុះលោក ពួកលោកចូរនាំសមណៈ និងព្រាហ្មណ៍របស់ខ្លួន ៗ ដែល គេសន្មតថា ល្អ មកកាន់ខាងក្នុងព្រះរាជវាំង យើងនឹងថ្វាយទាន" ។ ពួកអាមាត្យទទួលព្រះរាជឱង្ការថា "ល្អណាស់ ព្រះអង្គ" ហើយក៏បាននាំ អ្នកបួសក្រៅសាសនាមានតាបស បរិព្វាជក អាជីវក និងនិគ្រន្ថជាដើម នោះ ៗមកហើយទូលថា "បពិត្រមហារាជ លោកម្ចាស់ទាំងនេះ ជាព្រះ អរហន្តរបស់ទូលបង្គំទាំងឡាយ" ។ វេលានោះ ព្រះរាជាទ្រង់ត្រាស់ឱ្យ ក្រាលអាសនៈទាំងខ្ពស់ទាំងទាប ទុកខាងក្នុងព្រះរាជវាំង ហើយបង្គាប់ថា "អញ្ជើញចូលមកចុះ" ទើបទ្រង់អញ្ជើញពួកអ្នកបួសដែលមកហើយ ៗ

ថា "អញ្ជើញអង្គុយលើអាសនៈដែលសមគួរដល់ខ្លួន ៗ ចុះ" ដូច្នេះ ។

បណ្ដាអ្នកបួសទាំងនោះ ពួកខ្លះអង្គុយលើតាំងកទ្រូបិប ពួកខ្លះក៏អង្គុយលើតាំងផែនក្ដារ ។ ព្រះរាជាទតឃើញកិរិយាដែលអង្គុយនោះហើយ ក៏ទ្រង់ជ្រាបបានថា "អ្នកបួសទាំងនោះ មិនមានធម៌ដែលជាសារៈនៅខាងក្នុងឡើយ" បានថ្វាយរបស់គួរទំពា គួរបរិភោគដែលគួរដល់អ្នកបួសទាំងនោះហើយ ក៏ទ្រង់បញ្ជូន ត្រឡប់ទៅវិញ ។

កាលវេលាកន្លងទៅនៅយ៉ាងនោះ ថ្ងៃមួយ ព្រះបាទអសោកប្រថាប់ឈរជិតសីហបញ្ជរ បានទតឃើញនិគ្រោធសាមណេរ ជាអ្នកហ្វឹកហាត់ឃុំគ្រងខ្លួន មានឥន្ទ្រិយស្ងប់ សម្បូណ៌ដោយឥរិយាបថ កំពុងដើរឆ្លងកាត់ព្រះរាជវាំងទៅ ។

## ប្រវត្តិនិគ្រោធសាមណេរ

សួរថា ក៏ឈ្មោះថា និគ្រោធនេះ គឺ អ្វី ? ឆ្លើយថា និគ្រោធនេះជាព្រះឱរសរបស់សុមនរាជកុមារ ជាព្រះជេដ្ឋ ឱរសរបស់ព្រះបាទពិន្ទុសារ ។ ក្នុងរឿងនោះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

ដូចបានស្ដាប់មកថា ក្នុងវេលាដែលព្រះបាទពិន្ទុសារ (ដែលជាព្រះជនក) ទ្រង់ទុព្វលភាពទុំះឯង (ទ្រង់ព្រះប្រឈួនធ្ងន់) អសោកកុមារ បានលះបង់រាជសម្បត្តិក្នុងក្រុងឧជ្ជេនីដែលខ្លួនបាន ហើយស្ដេច

ត្រឡប់មកកាន់យកព្រះនគរទាំងអស់ទុកក្នុងកណ្ដាប់ដៃរបស់ខ្លួន ហើយបានចាប់សុមនរាជកុមារទុក ។ ក្នុងថ្ងៃនោះឯង ព្រះទេវីឈ្មោះសុមនា របស់សុមនរាជកុមារ ទ្រង់មានព្រះគភ៌ចាស់គ្រប់ខែហើយ ។ ព្រះនាងសុមនាទេវីនោះបន្លំភេទ ដើរជៀសចេញ ប្រាថ្នាទៅកាន់ស្រុកមនុស្សចណ្ឌាលមួយកន្លែងក្នុងទីមិនឆ្ងាយ ទ្រង់បានស្ដាប់សំឡេងរបស់ទេវតាដែលស្ថិតនៅត្រង់ ដើមនិគ្រោធមួយកន្លែងក្នុងទីមិនឆ្ងាយចាកផ្ទះរបស់ប្រធានពួកមនុស្សស្រុកចណ្ឌាល ដែលពោលអញ្ជើញថា "បពិត្រព្រះម៉ែម្ចាស់ សុមនា សូមស្ដេចចូលមកមកនេះចុះ" ក៏បានស្ដេចចូលទៅជិតទេវតានោះ ។ ទេវតាបាននិមិត្តសាលាមួយខ្នងដោយអានុភាពរបស់ខ្លួន ហើយបានថ្វាយថា "សូមព្រះម៉ែម្ចាស់ ចូរប្រថាប់នៅ ត្រង់សាលានេះចុះ" ។ ព្រះទេវីនោះបានស្ដេចចូលទៅកាន់សាលា នោះហើយ ។ ក្នុងថ្ងៃដែលព្រះនាងស្ដេចចូលទៅដល់នុ៎ះឯង ក៏ប្រសូតិព្រះឱរស ។ ព្រោះហេតុដែលទេវតាស្ថិតនៅត្រង់ដើមនិគ្រោធរក្សាព្រះឱរសនោះទុក ទើបព្រះនាងទេវីនោះ ទ្រង់ដាក់ព្រះនាមថា និគ្រោធ ។ ប្រធានពួកមនុស្សស្រុកចណ្ឌាល បានសម្គាល់ព្រះទេវីនោះ ដូចជាធីតានៃនាយរបស់ខ្លួន តាំងពីថ្ងៃដែលខ្លួនបានប្រទះឃើញហើយ ទើបបានតាំងវត្តប្រណិបត្តិជាប្រចាំរហូតមក ។ ព្រះរាជធីតា បានប្រថាប់នៅក្នុងស្ថានទីនោះអស់ ៧ ឆ្នាំ ។ ចំណែកនិគ្រោធកុមារ ក៏មានជន្មាយុបាន ៧ ឆ្នាំ ហើយ ។

## និគ្រោធកុមារបួសបានជាព្រះអរហន្តព្រះជន្ម ៧ ឆ្នាំ

ក្នុងគ្រានោះ ព្រះថេរៈមួយរូប ឈ្មោះមហាវរុណត្ថេរ ជាព្រះអរហន្ត បានឃើញសេចក្ដីដល់ព្រមនៃហេតុរបស់ទារក បានពិចារណាគិតថា “ឥឡូវនេះ ទារកមានជន្មាយុបាន ៧ ឆ្នាំ, ជាកាលសមគួរនឹងឱ្យគេបួសបាន” ទើបទូលព្រះរាជធីតាឱ្យទ្រង់ជ្រាប ហើយឱ្យនិគ្រោធកុមារនោះបួស ។ ក្នុងវេលាកោរសក់ រួចទុំះឯង ព្រះកុមារបានសម្រេចជាព្រះអរហន្ត ។ ថ្ងៃមួយ និគ្រោធសាមណេរនោះ បានជម្រះរាងកាយអំពីព្រឹកព្រលឹម ធ្វើអាចារិយវត្តនិងឧបជ្ឈាយ៍វត្តរួចស្រេចហើយ កាន់យកបាត្រនិង ចីវរ គិតថា “យើងនឹងទៅកាន់ទ្វារផ្ទះរបស់ញោមមាតា” ហើយក៏ចេញទៅ ។ ក៏និវាសស្ថាននៃញោមមាតារបស់និគ្រោធ សាមណេរនោះ ត្រូវដើរចូលទៅកាន់ព្រះនគរ មកទ្វារខាងទិសទក្សិណ ឆ្លងកាត់មកកណ្ដាលព្រះនគរ ទៅចេញតាមទ្វារខាងទិសបស្ចឹម ។ ក៏ដោយសម័យនោះ ព្រះបាទអសោកធម្មរាជ ទ្រង់ស្ដេចចង្ក្រមនៅត្រង់សីហបញ្ជរបែរព្រះភក្ត្រទៅខាងទិសបស្ចឹម(ខាងកើត) ។ ខណៈនោះឯង និគ្រោធសាមណេរ អ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ មានភ្នែកដាក់ចុះសម្លឹងមើលប្រមាណមួយជួរទឹម ដើរទៅដល់ព្រះរាជវាំង ។ ព្រោះហេតុនោះទើបខ្ញុំព្រះករុណាពោលទុកថា “ថ្ងៃមួយ ព្រះបាទអសោកប្រថាប់ឈរត្រង់សីហបញ្ជរ បានទតឃើញនិគ្រោធសាមណេរ ជាអ្នកហ្វឹកហាត់យុំ

គ្រងខ្លួន មានឥន្ទ្រិយស្ងប់ សម្បូណ៌ដោយឥរិយាបថ កំពុងដើរឆ្លងកាត់ព្រះរាជវាំងទៅ" ដូច្នេះ ។

## ព្រះបាទអសោកទ្រង់ជ្រះថ្លានិគ្រោធសាមណេរ

គ្រាទតឃើញហើយ ព្រះរាជាទ្រង់បានព្រះរំពឹង ដូច្នេះថា "ជនទាំងអស់នេះ មានចិត្តរវើរវាយ មានចំណែកប្រៀបដូចម្រឹគ ដែលរត់ឆ្វេរឆ្វាទៅ, ចំណែកទារកនេះ មិនមានចិត្តរវើរវាយ, ការសម្លឹងមើល ការក្រឡេកមើល ការបត់ដៃចូល និងការលាត ដៃចេញរបស់គេល្អក្រៃលែងណាស់, ខាងក្នុងរបស់ទារកនេះ គួរនឹងមានលោកុត្តរធម៌ពិតប្រាកដ" ដូច្នេះ ព្រមនឹងការទតឃើញរបស់ព្រះរាជានុ៎ះឯង ព្រះហឫទ័យក៏ជ្រះថ្លាក្នុងសាមណេរ, សេចក្ដីស្រឡាញ់ក៏បានតាំងឡើង ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបានឮថា សូម្បីក្នុងកាលមុន ក្នុងវេលាធ្វើបុណ្យនិគ្រោធសាមណេរនេះ គឺឈ្មួញដែលជាបងប្រុសធំរបស់ព្រះរាជា ។

សមពិត ដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកថា "សេចក្ដីស្រឡាញ់នោះ រមែងកើតព្រោះហេតុ ២ យ៉ាង គឺ ដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន១ ដោយការទំនុកបម្រុងគ្នា ក្នុងបច្ចុប្បន្ននេះ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុពីរយ៉ាង គឺ ទឹក ១ ភក់ ១"[១] ដូច្នោះ ។

---

១ ខុទ្ទ. ជាត. សាកេតជាតក. ៥៨. ៣២៤/១២៧ ។

## ព្រះបាទអសោកបង្គាប់ឱ្យនិមន្តសាមណេរចូលមក

លំដាប់នោះ ព្រះរាជាទ្រង់កើតសេចក្ដីស្រឡាញ់ មានសេចក្ដីរាប់អានច្រើន (ក្នុងសាមណេរនោះ) ទើបទ្រង់បង្គាប់ពួកអាមាត្យទៅថា "ពួកលោកចូរនិមន្តសាមណេរនោះមក" ។ ព្រះរាជាទ្រង់រំពឹងថា "អាមាត្យទាំងនោះ រវល់តែយឺតយូរ" ទើបទ្រង់បញ្ជូន ទៅ ២-៣ នាក់ទៀតថា "ចូរឱ្យសាមណេរនោះប្រញាប់មកចុះ" ។ សាមណេរបានដើរទៅតាមប្រក្រតីរបស់ខ្លួនទុំះឯង ។

ព្រះរាជាត្រាស់ថា "លោកស្គាល់អាសនៈដែលគួរហើយ និមន្តអង្គុយចុះ" ។ សាមណេរនោះ ក្រឡេកមើលខាងនេះ ខាងឯណោះហើយគិតថា "ឥឡូវនេះ មិនមានភិក្ខុពួកដទៃ" ទើបដើរចូលទៅជិតបល្ល័ង្ក ដែលលើកស្វេតឆត្របាំងទុក ហើយសម្ដែងអាការចំពោះព្រះរាជាដើម្បីត្រូវការឱ្យទ្រង់ទទួលបាត្រ ។ ព្រះរាជាទ្រង់ទតឃើញសាមណេរនោះ កំពុងដើរចូលទៅជិតបល្ល័ង្កទុំះឯង ទើបទ្រង់ត្រិះរិះថា "ថ្ងៃនេះឯងសាមណេររូបនេះ នឹងជាម្ចាស់របស់រាជមណ្ឌបនេះ ក្នុងឥឡូវនេះ" សាមណេរថ្វាយបាត្រ ក្នុងព្រះហស្តព្រះរាជា ហើយឡើងអង្គុយលើបល្ល័ង្ក ។ ព្រះរាជាទ្រង់បង្អោនថ្វាយអាហារគ្រប់ប្រភេទ គឺ បបររបស់គួរទំពា និងបាយ ដែលគេត្រៀមទុកដើម្បីប្រយោជន៍ដល់ព្រះអង្គ (ដល់

សាមណេរនោះ ) ។ សាមណេរទទួលអាហារល្មមញ៉ាំងអត្តភាពរបស់ខ្លួនឱ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។

## ព្រះបាទអសោកមហារាជត្រាស់សួរធម៌

ក្នុងទីបំផុតភត្តកិច្ច ព្រះរាជាត្រាស់សួរថា "សាមណេរ ដឹងព្រះឱវាទដែលព្រះសាស្ដាទ្រង់ប្រទានដល់ពួកសាមណេរឬ ?"

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អាត្មាភាព រមែងដឹងដោយឯកទេស (ប៉ុណ្ណោះ)" ។

ព្រះរាជាទ្រង់ត្រាស់ថា "សាមណេរ សូមសម្ដែងឱវាទដែលសាមណេរដឹងនោះ ដល់ញោមខ្លះ" ។

សាមណេរទូលតបថា "សម្ដែងបាន មហាបពិត្រ" ដូច្នេះហើយបានពោលអប្បមាទវគ្គក្នុងធម្មបទ តាមសមគួរចំពោះព្រះរាជាដើម្បីប្រយោជន៍ដល់ការអនុមោទនា ។

ព្រះរាជាល្មមទ្រង់បានស្ដាប់ថា "អប្បមាទោ អមតំបទំ បមាទោ មច្ចុនោបទំ : ការមិនប្រមាទ ជាមកមិនស្លាប់ សេចក្ដីប្រមាទ ជាមកនៃសេចក្ដីស្លាប់"[១] ដូច្នេះជាដើម ក៏ទ្រង់ត្រាស់ថា "សាមណេរ ចូរញ៉ាំងធម្មទេសនាដែលខ្ញុំព្រះករុណា បានដឹងហើយ ឱ្យចប់ទុកមុន" ដូច្នេះ ។

---

១. ខុទ្ទ. ធម្ម. អប្បមាទវគ្គ. ៥២. ១២/២៥ ។

## ព្រះបាទអសោកថ្វាយនិច្ចភត្តសាមណេរជាទេ្វគុណ

ក្នុងអវសាននៃការអនុមោទនា ព្រះរាជាទ្រង់ត្រាស់ថា "សាមណេរ ញោមនឹងថ្វាយធុវភត្តដល់សាមណេរ ៨ សម្រាប់" ។

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អាត្មាភាព នឹងថ្វាយធុវភត្តទាំងនោះ ដល់ព្រះឧបជ្ឈាយ៍ (របស់អាត្មាភាព)" ។

ព្រះរាជាត្រាស់សួរថា "សាមណេរ អ្នកដែលឈ្មោះថាឧបជ្ឈាយ៍នេះ តើបានដល់មនុស្សប្រភេទណា ?"

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អ្នកដែលឃើញទោសតូចធំ ហើយដាស់តឿន និងឱ្យរលឹក ឈ្មោះថា ព្រះឧបជ្ឈាយ៍" ។

ព្រះរាជាទ្រង់ត្រាស់ថា "សាមណេរ ញោមនឹងថ្វាយភត្ត ៨ សម្រាប់ សូម្បីដទៃទៀតដល់សាមណេរ ។

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អាត្មាភាពនឹងថ្វាយភត្តទាំងនោះ ដល់អាចារ្យ (របស់អាត្មាភាព)" ។

ព្រះរាជាត្រាស់សួរថា "សាមណេរ អ្នកដែលឈ្មោះថា អាចារ្យនេះ តើបានដល់មនុស្សប្រភេទណា ?"

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អ្នកដែលឱ្យអន្តេវាសិក និងសទ្ធិវិហារិក តាំងនៅក្នុងធម៌ដែលគួរសិក្សា ក្នុងព្រះសាសនានេះ

ឈ្មោះថា អាចារ្យ" ។

ព្រះរាជាទ្រង់ត្រាស់ថា "ល្អណាស់ សាមណេរ ញោមនឹងថ្វាយភត្ត ៨ សម្រាប់ សូម្បីដទៃទៀតដល់សាមណេរ" ។

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ អាត្មាភាព នឹងថ្វាយភត្តទាំងនោះ ដល់ព្រះភិក្ខុសង្ឃ" ។

ព្រះរាជាត្រាស់សួរថា "សាមណេរ អ្នកដែលឈ្មោះថា ភិក្ខុសង្ឃនេះ តើបានដល់មនុស្សប្រភេទណា ?"

សាមណេរថ្វាយព្រះពរថា "មហាបពិត្រ បព្វជ្ជា និងឧបសម្បទារបស់អាចារ្យនិងឧបជ្ឈាយ៍របស់អាត្មាភាព និងបព្វជ្ជារបស់អាត្មាភាពអាស្រ័យពួកភិក្ខុណា ពួកភិក្ខុនោះ ឈ្មោះថា ភិក្ខុសង្ឃ" ។

ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យយ៉ាងក្រៃលែង ហើយទ្រង់ត្រាស់ថា "សាមណេរ ញោមនឹងថ្វាយភត្ត ៨ សម្រាប់សូម្បីដទៃទៀតដល់សាមណេរ" ។

សាមណេរទូលថា "ល្អណាស់ ក្នុងថ្ងៃស្អែកបាន នាំយកភិក្ខុ ៣២ រូប ចូលទៅកាន់ខាងក្នុងព្រះរាជវាំង ឆាន់ភត្តាហារ" ។

## ព្រះបាទអសោកថ្វាយនិច្ចភត្តដល់ភិក្ខុ ៦ សែនរូប

ព្រះរាជា ទ្រង់បវារណាថា ភិក្ខុ ៣២ រូបសូម្បីដទៃ ព្រមទាំងពួកលោកចូរទទួលភិក្ខា ស្អែកនេះចុះ ដូច្នេះហើយ ទ្រង់ឱ្យបន្ថែមភិក្ខុច្រើនឡើងរាល់ថ្ងៃ ៗ ដោយឧបាយនោះឯង ទ្រង់បានកាត់ភត្តរបស់ពួកអ្នកបួសក្រៅសាសនា មានព្រាហ្មណ៍ និងបរិព្វាជកជាដើម ទាំង៦សែននាក់ចេញ ហើយទ្រង់បានតាំងនិច្ចភត្ត ទុកសម្រាប់ភិក្ខុ ៦សែនរូប ក្នុងខាងក្នុងព្រះរាជលំនៅ ព្រោះសេចក្ដីជ្រះថ្លាដែលប្រព្រឹត្តទៅក្នុងព្រះនិគ្រោធត្ថេរ[១]នុ៎ះឯង ។ ចំណែកព្រះនិគ្រោធត្ថេរ ក៏ឱ្យព្រះរាជាព្រមទាំងបរិស័ទតាំងនៅក្នុងត្រៃសរណគមន៍និងបញ្ចសីល ធ្វើឱ្យជាអ្នកមានសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ដោយសេចក្ដីជ្រះថ្លាយ៉ាងបុថុជ្ជន ហើយឱ្យតាំងមាំនៅក្នុងព្រះពុទ្ធសាសនា ។

## ព្រះបាទអសោកសាងវត្តនិងចេតិយ ៨៤,០០០ កន្លែង

ព្រះរាជាទ្រង់ត្រាស់ឱ្យជាងសាងមហាវិហារ ឈ្មោះថា អសោការាម ហើយក៏ទ្រង់តាំងភត្តទុកដើម្បីថ្វាយភិក្ខុ ៦ សែនរូបទៀត និងទ្រង់ត្រាស់ឱ្យសាងព្រះវិហារ ៨៤,០០០ ដែលប្រដាប់ដោយព្រះចេតិយ ៨៤,០០០ អង្គ ទុកក្នុងព្រះនគរ ៨៤,០០០ កន្លែង ទូទាំងជម្ពូទ្វីបទាំងអស់ ដោយ

---

១. ព្រះនិគ្រោធត្ថេរ ក៏គឺ និគ្រោធសាមណេរនុ៎ះឯង ។

ការប្រែបកតាមធម៌នុះឯង មិនមែនដោយការមិនប្រកបដោយធម៌ទេ ។

បានឮថា ក្នុងថ្ងៃមួយ ព្រះរាជាទ្រង់ថ្វាយមហាទានក្នុងអសោការាម ប្រថាប់អង្គុយនៅត្រង់កណ្ដាលព្រះភិក្ខុសង្ឃ ដែលរាប់បានប្រមាណ៦ សែនរូប ទ្រង់បវារណាសង្ឃដោយបច្ច័យ ៤ ហើយត្រាស់សួរបញ្ហានេះ ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឈ្មោះថា ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ មានប្រមាណប៉ុនណា ? ព្រះសង្ឃថ្វាយព្រះពរថា មហាបពិត្រ ឈ្មោះថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ នោះ ពោលដោយអង្គ មានអង្គ ៩ ពោលដោយខន្ធ មាន ៨៤,០០០ ព្រះធម្មក្ខន្ធ ។

ព្រះរាជាទ្រង់ជ្រះថ្លាក្នុងព្រះធម៌ ហើយទ្រង់ត្រាស់ថា "យើងនឹង បូជាព្រះធម្មក្ខន្ធ មួយខន្ធដោយវិហារមួយខ្នង ៗ ដូច្នេះ ក្នុងមួយថ្ងៃ ប៉ុណ្ណោះ ទ្រង់បានលះបង់ព្រះរាជទ្រព្យដល់ ៩៦ កោដិ ហើយទ្រង់បាន បង្គាប់ពួកអាមាត្យថា "ទៅចុះនាយ ពួកលោកកាលឱ្យសាងវិហារមួយក្នុង នគរមួយ ៗ ចូរឱ្យសាងព្រះវិហារ ៨៤,០០០ ទុកក្នុងព្រះនគរ ៨៤,០០០ ចុះ" ដូច្នេះ ចំណែកព្រះអង្គឯងទ្រង់បានចាប់ផ្ដើមការងារ ដើម្បីប្រយោជន៍ដល់អសោកមហាវិហារ ក្នុងអសោការាម ។ ព្រះសង្ឃ បានឱ្យព្រះថេរៈ ឈ្មោះថា ឥន្ទគុត្តត្ថេរ អ្នកមានឫទ្ធិច្រើន មានអានុភាព

ច្រើន អស់អាសវៈហើយ ជានវកម្មាធិដ្ឋាយី* ។ ព្រះថេរៈបានញ៉ាំងការងារដែលនៅមិនទាន់សម្រេចនោះ ៗ ឱ្យសម្រេចដោយអានុភាពរបស់ខ្លួន ។ ព្រះថេរៈបានឱ្យកសាងព្រះវិហាររួចស្រេច អស់រយៈកាល ៣ ឆ្នាំ សូម្បីដោយអានុភាពយ៉ាងនោះ ។

## ព្រះបាទអសោកទ្រង់ធ្វើការឆ្លងព្រះវិហារ

ដំណឹងគ្រប់នគរ បានមកដល់ថ្ងៃជាមួយគ្នានុ៎ះឯង ។ ពួកអាមាត្យបានក្រាបទូលចំពោះព្រះរាជាថា "សូមតេជៈព្រះវិហារ ៨៤,០០០ ខ្នង សាងសម្រេចហើយ" ។

ព្រះរាជា ទ្រង់ត្រាស់ឱ្យវាយស្គរដើរប្រកាសពេញព្រះនគរថា កន្លងទៅ ៧ ថ្ងៃ អំពីថ្ងៃនេះ នឹងមានការឆ្លងព្រះវិហារ សូមឱ្យប្រជាជនទាំងអស់ សមាទានអដ្ឋសីល ៨ ត្រៀមការឆ្លងព្រះវិហារ ទាំងខាងក្នុងព្រះនគរ និងខាងក្រៅព្រះនគរ កន្លងទៅ ៧ ថ្ងៃ តែការឆ្លងព្រះវិហារនោះ ព្រះរាជាហែហមដោយពួកសេនា មានអង្គ ៤ រាប់បានច្រើនសែន ដែលតែងខ្លួនដោយគ្រឿងអលង្ការគ្រប់យ៉ាង ស្តេចត្រាច់សរសើរព្រះនគរ ដែលមហាជន អ្នកមានសេចក្តីឧស្សាហ៍ប្រាថ្នានឹងតាក់តែងព្រះនគរបានតាក់តែង ប្រដាប់ប្រដាហើយ ឱ្យដូចជាមានសេចក្តីស្រស់ល្អក្រៃលែង

---

១. នវកម្មាធិដ្ឋាយី គឺ អ្នកថែរក្សាឃុំគ្រងការងារកសាងថ្មី ។

ជាង សិរីនៃរាជធានី ឈ្មោះអមរាវតីក្នុងទេវលោក ស្តេចព្រះរាជដំណើរទៅកាន់ព្រះវិហារ បានប្រថាប់ឈរនៅកណ្តាលភិក្ខុសង្ឃ ។ ក៏ភិក្ខុដែលប្រជុំគ្នាក្នុងខណៈនោះមានប្រមាណ ៨០ កោដិ ។

ក៏ឯពួកនាងភិក្ខុនីមានប្រមាណ ៩លាន ៦សែន ។ បណ្តាភិក្ខុទាំងនោះ ចំពោះភិក្ខុដែលជាព្រះខីណាស្រពរាប់បានប្រមាណ មួយសែនរូប ។ ភិក្ខុខីណាស្រពទាំងនោះ បានមានសេចក្តីវិតក្កៈ សេចក្តីនេះថា "បើព្រះរាជានឹងគប្បីទតឃើញអធិការ (ទានដែលក្រៃលែង) មិនមានចំណែកនៅសល់របស់ព្រះអង្គ ក៏នឹងគប្បីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាជាយ៉ាងក្រៃលែង" តពីនោះ ទើបបានធ្វើ បាដិហារ្យ ឈ្មោះថា លោកវិវរណៈ (គឺ ការបើកលោក) ។

## ព្រះបាទអសោកទតឃើញជម្ពូទ្វីបទាំងអស់

ព្រះរាជា ប្រថាប់ឈរត្រង់អសោការាមនោះឯង ទ្រង់ក្រឡេកមើលរហូតដល់អស់ទាំង ៤ ទិស បានទតឃើញជម្ពូទ្វីប ដែលមានមហាសមុទ្រជាទីបំផុតដោយជុំវិញ និងព្រះវិហារ ៨៤,០០០ ខ្នង ដែលរុងរោចន៍ដោយការបូជា ក្នុងការឆ្លងព្រះវិហារយ៉ាងឱឡារ ។

ព្រះរាជាកាលទតមើលសម្បត្តិនោះ ក៏ទ្រង់ប្រកបដោយបីតិបាមោជ្ជៈយ៉ាងឱឡារ ទ្រង់ព្រះត្រិះរិះថា ក៏មាននៅឬដែលបីតិ បាមោជ្ជៈ

បែបនេះ ធ្លាប់កើតឡើងដល់អ្នកណា ៗ ដទៃដែរទេ ? ទើបត្រាស់សួរភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងព្រះសាសនារបស់ព្រះទសពល លោកទាំងជាម្ចាស់របស់យើងទាំងឡាយ តើមានអ្នកណាខ្លះបានបរិច្ចាគយ៉ាងច្រើន តើការបរិច្ចាគរបស់អ្នកណាហ្នឹងធំក្រៃលែង ។ ភិក្ខុសង្ឃបានប្រគល់ ការវិសជ្ជនាបញ្ហាដែលព្រះរាជាត្រាស់សួរ ឱ្យជានាទីរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរ ។ ព្រះថេរៈថ្វាយព្រះពរថា "មហាបពិត្រដែលឈ្មោះថា អ្នកថ្វាយបច្ច័យ ក្នុងព្រះសាសនារបស់ព្រះទសពល ដូចនឹងព្រះអង្គ ក្នុងកាលព្រះតថាគតសូម្បីនៅមានព្រះជន្ម មិនមានអ្នកណាឡើយ ព្រះអង្គប៉ុណ្ណោះ ទ្រង់មានការបរិច្ចាគយ៉ាងធំក្រៃលែង" ។

## ព្រះបាទអសោកមិនទាន់ជាទាយាទនៃព្រះសាសនា

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ក៏មានព្រះវរកាយត្រូវបីតិ បាមោជ្ជៈយ៉ាងឱឡារិកប៉ះពាល់ហើយមិនមានចន្លោះ ទើបទ្រង់ព្រះត្រិះរិះថា "បានឮថា អ្នកដែលថ្វាយបច្ច័យដូចយើង មិនមាន, បានឮថា យើងមានការបរិច្ចាគច្រើនក្រៃលែង, បានឮថា យើងកំពុងលើកស្ទួយព្រះសាសនាដោយទេយ្យធម៌, ក៏កាលបើយ៉ាងនេះ យើងនឹងបានឈ្មោះថា ជាទាយាទនៃព្រះសាសនាឬទេ" ។ លំដាប់នោះ ទើបស្តេចត្រាស់សួរភិក្ខុសង្ឃថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ញោមជាទាយាទនៃ

ព្រះសាសនា ឬនៅទេហ្ន៎ ?” ក្នុងលំដាប់នោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ស្តាប់ព្រះរាជតម្រាស់នេះហើយ កាលសម្លឹងឃើញឧបនិស្ស័យសម្បត្តិនៃព្រះមហិន្ទអ្នកជាព្រះឱរស (របស់ស្តេច) ទើបត្រិះរិះថា “បើព្រះកុមារនេះ ទ្រង់សាងព្រះផ្នួសសោត ព្រះសាសនាក៏នឹងចម្រើនយ៉ាងក្រៃលែង” ទើបថ្វាយព្រះពររឿងនេះ ចំពោះព្រះរាជាថា “មហាបពិត្រ អ្នកដែលនឹងជាទាយាទនៃព្រះសាសនា មិនមែនដោយហេតុត្រឹមតែប៉ុណ្ណេះទេ ក៏ម្យ៉ាងទៀត អ្នកថ្វាយបច្ច័យដូច្នោះ រមែងដល់ការរាប់ថា បច្ច័យទាយក ឬថាអ្នកឧបដ្ឋាក (ប៉ុណ្ណោះ) មហាបពិត្រ” ពិតមែន សូម្បីអ្នកណា គប្បីថ្វាយគំនរបច្ច័យតាំងពីផែនដី រហូតទៅដល់ព្រហ្មលោក សូម្បីអ្នកនោះក៏មិនទាន់ដល់ការរាប់ថា ជាទាយាទក្នុងព្រះសាសនាបាន ។

## អ្នកដែលឱ្យបុត្របួសបានជាទាយាទនៃព្រះសាសនា

លំដាប់នោះ ព្រះរាជាត្រាស់សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ ទាយាទនៃព្រះសាសនា នឹងមានបានយ៉ាងណា ?” ព្រះថេរៈថ្វាយព្រះពរថា “មហាបពិត្រ បុគ្គលណាម្នាក់ ទោះជាអ្នកស្តុកស្តម្ភក៏ដោយ ទោះជាអ្នកក្រលំបាកក៏ដោយ ឱ្យបុត្រអ្នកជាឱរសរបស់ខ្លួនបួស (ក្នុងព្រះសាសនា) មហាបពិត្រ បុគ្គលនេះ លោកហៅថា ជាទាយាទនៃព្រះសាសនា” ។

កាលព្រះមោគ្គលីបុត្តតិស្សត្ថេរ ថ្វាយព្រះពរយ៉ាងនោះហើយ ព្រះបាទ អសោកធម្មរាជទ្រង់ព្រះត្រិះរិះថា "បានឮថា យើងសូម្បីធ្វើការបរិច្ចាគបែបនេះហើយ ក៏មិនទាន់ដល់ភាពជាទាយាទនៃព្រះសាសនាបានឡើយ" ទ្រង់ប្រាថ្នាភាពជាទាយាទក្នុងព្រះសាសនា ទើបទ្រង់ទតព្រះនេត្រក្រឡេកមើល ខាងឯណោះ និងខាងនេះ បានទតឃើញព្រះមហិន្ទកុមារ (អ្នកជាព្រះរាជឱរសរបស់ព្រះអង្គ) ដែលប្រថាប់ឈរក្នុងទីមិនឆ្ងាយ ។ គ្រាទតឃើញហើយ ព្រះរាជាក៏ទ្រង់ព្រះរំពឹងដូច្នេះថា "យើងប្រាថ្នានឹងស្ថាបនាព្រះកុមារអង្គនេះ ទុកក្នុងតំណែងឧបរាជ ចាប់ផ្តើមតាំងពីវេលាតិស្សកុមារព្រះផ្នួសហើយ ក៏ពិតមែន តែថា ការបព្វជ្ជានេះឯង ជាគុណជាតិឧត្តមជាងតំណែងឧបរាជនោះទៅទៀត" ។ លំដាប់នោះ ទើបព្រះរាជាទ្រង់ត្រាស់ចំពោះព្រះកុមារថា "តើកូនអាចបួសបានទេ ?" ព្រះកុមារសូម្បីតាមប្រក្រតី ចាប់ផ្តើមតាំងពីវេលាដែលព្រះតិស្សកុមារទ្រង់ព្រះផ្នួសហើយ ក៏មានព្រះបំណងចង់នឹងព្រះផ្នួសតែម្តង គ្រាន់តែទ្រង់បានស្តាប់ព្រះរាជតម្រាស់ភ្លាម ក៏កើតបាមោជ្ជៈយ៉ាងក្រៃលែង ហើយក្រាបទូលថា "បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងបួស, ព្រះបិតា ទ្រង់ព្រះបរមរាជានុញ្ញាត ឱ្យទូលបង្គំបួសហើយ នឹងបានជាទាយាទក្នុងព្រះសាសនា" ។

សម័យនោះឯង សុម្បីព្រះនាងសង្ឃមិត្តា ព្រះរាជធីតា (របស់ព្រះរាជា) ក៏ប្រថាប់ឈរក្នុងស្ថានទីនោះឯង ។ ព្រះកុមារទ្រង់ព្រះនាមថា អគ្គិព្រហ្មជាព្រះស្វាមីរបស់ព្រះនាងសង្ឃមិត្តានោះឯង ក៏បានព្រះផ្នួសរួមនឹងព្រះតិស្សកុមារជាឧបរាជហើយ ។ ព្រះរាជាទតឃើញព្រះនាងសង្ឃមិត្តានោះហើយ ទើបទ្រង់សួរថា "កូនស្រី សុម្បីកូនអាចនឹងបួសបានទេ ?" ព្រះនាងទូលតបថា ល្អណាស់ ព្រះបិតា ខ្ញុំព្រះករុណាម្ចាស់អាច" ។ ព្រះរាជាទ្រង់អរគុណព្រះរាជឱរសនិងធីតាហើយ មានព្រះរាជហឫទ័យរីករាយ ទើបត្រាស់ព្រះតម្រាស់នេះចំពោះព្រះភិក្ខុសង្ឃថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ចូរឱ្យទារកទាំងនេះ បួសហើយធ្វើឱ្យញោមជាទាយាទក្នុងព្រះសាសនាចុះ" ។ ព្រះសង្ឃទទួលព្រះរាជតម្រាស់ហើយ ក៏ឱ្យព្រះកុមារបព្វជ្ជា ដោយមានព្រះមោគ្គលីបុត្តតិស្សត្ថេរ ជាព្រះឧបជ្ឈាយ៍ និងមានព្រះមហាទេវត្ថេរជាអាចារ្យឱ្យឧបសម្បទា ដោយមានព្រះមជ្ឈន្តិកត្ថេរ ជាអាចារ្យ ។ បានឮថា គ្រានោះ ព្រះកុមារមានព្រះជន្មាយុបាន ២០ ឆ្នាំបរិបូណ៌ ។

## ព្រះមហិន្ទត្ថេរវេលាឧបសម្បទាសម្រេចព្រះអរហត្ត

លោកបានសម្រេចជាព្រះអរហន្ត ព្រមដោយបដិសម្ភិទា ក្នុងមណ្ឌលឧបសម្បទានោះឯង ។ អាចារ្យសូម្បីរបស់ព្រះនាងសង្ឃមិត្តារាជធីតា ឈ្មោះថា ព្រះអាយុបាលិតថេរី ចំណែកព្រះឧបជ្ឈាយ៍ ឈ្មោះព្រះធម្មបាលិតថេរី ។ បានឮថា គ្រានោះ ព្រះនាងសង្ឃមិត្តា មានព្រះជន្មាយុបាន ១៨ ឆ្នាំ ។ ភិក្ខុសង្ឃ ញុំាំងព្រះនាងសង្ឃមិត្តានោះ អ្នកល្មមបព្វជ្ជាហើយ ឱ្យតាំងនៅក្នុងសិក្ខាក្នុងរោងសីមានោះឯង ។

វេលាដែលព្រះឱរសនិងព្រះធីតាទាំង ២ អង្គព្រះផ្នួស ព្រះរាជាទ្រង់អភិសេកគ្រងរាជ្យបាន ៦ ឆ្នាំ ។ ខាងក្រោយតាំងពីវេលាដែលទ្រង់ព្រះផ្នួសហើយ ព្រះមហិន្ទត្ថេរ ក៏សិក្សារៀន សូត្រព្រះធម៌និងព្រះវិន័យនៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍របស់ខ្លួនទុំះឯង បានរៀនយកថេរវាទទាំងអស់ព្រមទាំងអដ្ឋកថា ដែលលោកសង្គ្រោះដោយព្រះត្រៃបិដក ដែលឡើងកាន់សង្គីតិ ទាំង ២ គ្រា ចប់ក្នុងខាងក្នុង ៣ វស្សា ហើយបានជាបាមោក្ខ(ប្រធាន) របស់ពួកភិក្ខុប្រមាណ ១,០០០ រូប អ្នកជាអន្តេវាសិក នៃឧបជ្ឈាយ៍របស់ខ្លួន ។ គ្រានោះ ព្រះបាទអសោកធម្មរាជទ្រង់អភិសេកគ្រងរាជ្យបាន ៩ ឆ្នាំ ។

## ព្រះបាទអសោកតាំងមូលនិធិថ្វាយសង្ឃ ៥ សែន

ក៏ក្នុងរជ្ជកាលដែលព្រះរាជាទ្រង់អភិសេកបាន ៨ ឆ្នាំនុ៎ះឯង ព្រះកោនតបុត្តតិស្សត្ថេរត្រាច់ទៅដើម្បីត្រូវការថ្នាំបំបាត់ព្យាធិ ដោយភិក្ខាចារវត្តក៏មិនបានទឹកដោះថ្លាត្រឹមតែមួយទូកដៃឡើយ អស់អាយុសង្ខារ ព្រោះកម្លាំងនៃព្យាធិ បានឱវាទភិក្ខុសង្ឃដោយការមិនប្រមាទ ហើយអង្គុយដោយបល្ល័ង្កក្នុងអាកាស ចូលតេជោធាតុបរិនិព្វានហើយ ។

ព្រះរាជាទ្រង់ជ្រាបព្រឹត្តការណ៍នោះហើយ ទ្រង់បានធ្វើសក្ការៈដល់ព្រះថេរៈ ហើយទ្រង់ត្រាស់ថា ដែលឈ្មោះថា កាលយើងនៅគ្រងរាជ្យពួកភិក្ខុរកបច្ច័យបានលំបាកយ៉ាងនេះ ហើយទ្រង់ត្រាស់ឱ្យសាងស្រះបោក្ខរណីទុកត្រង់ទ្វារទាំង ៤ នៃព្រះនគរ ឱ្យបញ្ចុះពេញដោយភេសជ្ជៈថ្វាយទុក ។ បានឮថា សម័យនោះ គ្រឿងបណ្ណាការទាំង ៥ សែនកើតឡើងដល់ព្រះរាជារាល់ថ្ងៃ ៗ គឺ ត្រង់ទ្វារទាំង ៤ នៃព្រះនគរបាតលីបុត្តបួនសែន ត្រង់សភាមួយសែន គ្រានោះ ព្រះរាជាទ្រង់លះបង់ថ្វាយព្រះនិគ្រោធត្ថេរមួយថ្ងៃមួយសែន ៗ, មួយសែនដើម្បីត្រូវការទ្រង់បូជាដោយវត្ថុមានរបស់ក្រអូប និងផ្កាឈើជាដើម ចំពោះពុទ្ធចេតិយ, មួយសែន ដើម្បីត្រូវការទ្រង់បូជាព្រះធម៌ គឺ ទ្រង់បង្អោនថ្វាយមួយសែននោះ ដើម្បីប្រយោជន៍ដល់បច្ច័យ ៤ ដល់ពួកភិក្ខុដែលទ្រទ្រង់ធម៌

ជាពហុស្សូត, មួយសែនថ្វាយភិក្ខុសង្ឃ, ថ្វាយមួយសែនទៀតដើម្បីប្រយោជន៍ដល់ភេសជ្ជៈក្នុងទ្វារទាំង ៤ ទិស ។ លាភ និងសក្ការៈដ៏ឱឡារិក កើតហើយក្នុងព្រះសាសនាដោយអាការយ៉ាងនេះ ។

## ពួកតិរ្ថិយបន្លំបួសក្នុងព្រះពុទ្ធសាសនា

តិរ្ថិយទាំងឡាយ សាបសូន្យលាភនិងសក្ការៈហើយ ដោយហោចទៅ សូម្បីត្រឹមតែរបស់ស៊ីនិងគ្រឿងស្លៀកដណ្តប់ ក៏មិនបាន កាលប្រាថ្នាលាភនិងសក្ការៈ ទើបបន្លំបួសក្នុងព្រះពុទ្ធសាសនា ហើយសម្តែងទិដ្ឋិ (លទ្ធិ) របស់ខ្លួន ៗ ថា "នេះធម៌ នេះវិន័យ" ។

ពួកតិរ្ថិយទាំងនោះ សូម្បីកាលមិនបានបួសក៏កោរសក់ដោយខ្លួនឯង ហើយស្លៀកសំពត់កាសាយៈ ត្រាច់ទៅក្នុងវិហារទាំងឡាយចូលទៅ (រួម) ឧបោសថខ្លះ បវារណាខ្លះ សង្ឃកម្មខ្លះ គណៈកម្មខ្លះ ។ ភិក្ខុទាំងឡាយមិនព្រមធ្វើឧបោសថ រួមនឹងពួកភិក្ខុតិរ្ថិយទាំងនោះ ។ គ្រានោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរត្រិះរិះថា "ឥឡូវនេះ អធិករណ៍កើតឡើងហើយមិនយូរឡើយ អធិករណ៍នោះនឹងអាក្រក់គ្រោតគ្រាតឡើង ក៏យើងនៅត្រង់កណ្តាលនៃភិក្ខុតិរ្ថិយទាំងនោះ នឹងមិនអាចរម្ងាប់អធិករណ៍នោះបាន" ដូច្នេះ ទើបប្រគល់ការគណៈថ្វាយព្រះមហិន្ទត្ថេរ ប្រាថ្នានឹងសម្រាកដោយផាសុកវិហារដោយខ្លួនឯង ហើយបានទៅកាន់អហោគង្គបព្វត ។

## ពួកតិរ្ថិយសម្តែងលទ្ធិក្រៅពុទ្ធសាសនា

ពួកតិរ្ថិយសូម្បីទាំងនោះឯង សូម្បីត្រូវភិក្ខុសង្ឃប្រៀនប្រដៅដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនា ក៏មិនព្រមតាំងនៅក្នុងវត្តបដិបត្តិដែលស្របតាមព្រះធម៌វិន័យ ទាំងបានឱ្យវិករវរ និងចម្រូងចម្រាស់តាំងឡើងដល់ព្រះសាសនា មិនមែនតែមួយប្រភេទ ពួកខ្លះបម្រើភ្លើង ពួកខ្លះអាំងខ្លួនឱ្យក្តៅនៅក្នុងគ្រឿងអប់ខ្លួន ៥ យ៉ាង ពួកខ្លះប្រព្រឹត្តវិលទៅតាមព្រះអាទិត្យ ពួកខ្លះក៏អះអាងនិយាយថា "ពួកយើងនឹងទម្លាយព្រះធម៌វិន័យ របស់ពួកលោក" ដូច្នេះ ។

គ្រានោះ ភិក្ខុសង្ឃមិនបានធ្វើឧបោសថឬបវារណា រួមនឹងតិរ្ថិយទាំងនោះឡើយ ។ ក្នុងវត្តអសោការាម ឧបោសថអាក់ខានទៅដល់ ៧ ឆ្នាំ ។ ពួកភិក្ខុបាន ក្រាបទូលរឿងនោះដល់ព្រះរាជា ។

## ព្រះបាទអសោកទ្រង់ប្រើអាមាត្យឱ្យរម្ងាប់អធិករណ៍

ព្រះរាជា ទ្រង់បង្គាប់អាមាត្យម្នាក់ទៅថា "លោកទៅ កាន់ព្រះវិហាររម្ងាប់អធិករណ៍ហើយ និមន្តភិក្ខុសង្ឃឱ្យធ្វើឧបោសថចុះ" ដូច្នេះ ។ អាមាត្យមិនអាចនឹងទូលសាកសួរព្រះរាជាបាន ទើបចូលទៅរកអាមាត្យពួកដទៃហើយពោលថា "ព្រះរាជាទ្រង់បញ្ជូនខ្ញុំទៅថា ចូរលោកទៅកាន់

ព្រះវិហាររម្ងាប់អធិករណ៍ហើយធ្វើឧបោសថចុះ ដូច្នេះ អធិករណ៍នឹងរម្ងាប់បានយ៉ាងណាហ្ន៎ ?” អាមាត្យទាំងនោះនិយាយថា “ពួកខ្ញុំកំណត់ចំណាំបាន ដោយឧបាយយ៉ាងនេះថា ពួករាជបុរស កាលនឹងបង្ក្រាបបច្ចន្តជនបទឱ្យស្ងប់ស្ងាត់ ក៏ត្រូវសម្លាប់ពួកចោរនេះយ៉ាងណា ភិក្ខុពួកណាមិនធ្វើឧបោសថ ព្រះរាជានឹងមានព្រះរាជប្រាថ្នាឱ្យសម្លាប់ភិក្ខុទាំងនោះចេញ ក៏យ៉ាងនោះដែរ” ។

លំដាប់នោះ អាមាត្យនោះ ទៅកាន់ព្រះវិហារ ណាត់ឱ្យភិក្ខុសង្ឃប្រជុំគ្នាហើយទូលបញ្ជាក់ថា “ព្រះរាជាទ្រង់បង្គាប់ខ្ញុំព្រះករុណាមកថា លោកចូរនិមន្តភិក្ខុសង្ឃឱ្យធ្វើឧបោសថចុះ បពិត្រលោកម្ចាស់ដ៏ចម្រើនឥឡូវនេះ សូមពួកលោកចូរធ្វើឧបោសថកម្មចុះ” ។ ពួកភិក្ខុនិយាយថា “អាត្មាភាពទាំងឡាយ នឹងមិនធ្វើឧបោសថរួមនឹងពួកតិរ្ថិយ” ។ អាមាត្យចាប់យកដាវកាត់សីសៈ (របស់ពួកភិក្ខុ) ឱ្យធ្លាក់ទៅ ចាប់ផ្ដើមតាំងពីអាសនៈរបស់ព្រះថេរៈចុះទៅ ។ ព្រះតិស្សត្ថេរបានឃើញអាមាត្យនោះអ្នកបដិបត្តិខុសយ៉ាងនោះឯង ។

# ប្រវត្តិរបស់ព្រះតិស្សត្ថេរចេញបួស

ឈ្មោះថា ព្រះតិស្សត្ថេរមិនមែនអ្នកជម្មតាសាមញ្ញ គឺ ព្រះភាតារួមព្រះរាជមាតាជាមួយនឹងព្រះរាជា មាននាមថា តិស្សកុមារ ។ បានឮថា ព្រះរាជាទ្រង់អភិសេកហើយ ទ្រង់បានតាំងតិស្សកុមារនោះទុក ក្នុងតំណែងឧបរាជ ។ ថ្ងៃមួយ តិស្សកុមារនោះ ស្ដេចយាងទៅកាន់ព្រៃបានទតឃើញពួកម្រឹគហ្វូងធំ ដែលលេងនៅ ដោយការលេងតាមសេចក្ដីគិត (គឺតាមសេចក្ដីប្រាថ្នារបស់ខ្លួន) ។ គ្រាទតឃើញហើយ តិស្សកុមារនោះទ្រង់បានមានព្រះរំពឹងដូច្នេះថា "ម្រឹគទាំងនេះមានស្មៅជាអាហារក៏នៅប្រលែងគ្នាបានយ៉ាងនេះ, ចំណែកព្រះសមណៈទាំងនេះ ឆាន់ភោជនដែលប្រណីត ក្នុងរាជត្រកូលហើយ ដេកនៅលើទីដេកដ៏ទន់ ៗ នឹងលេងល្បែងដែលគួរពេញចិត្តមិនបានឬ ?" ។ តិស្សកុមារនោះ ស្ដេចត្រឡប់មកពីព្រៃនោះហើយ បានក្រាបទូលសេចក្ដីរំពឹងរបស់ខ្លួននេះចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ព្រះត្រិះរិះថា "ព្រះកុមាររង្កៀសសង្ស័យក្នុងទីមិនមែនឋានៈ (មិនមែនហេតុ), ណ្ហើយចុះ យើងនឹងឱ្យគេយល់ព្រមដោយឧបាយយ៉ាងនេះ" ក្នុងថ្ងៃមួយ ទ្រង់ធ្វើដូចជាក្រោធដោយហេតុការណ៍មួយយ៉ាង ហើយទ្រង់គម្រាមដោយមរណភ័យថា "លោកចូរមកទទួលយករាជសម្បត្តិ រហូតដល់អស់ ៧ ថ្ងៃ, ក្រោយអំពីនោះយើងនឹង

សម្លាប់លោកចេញ” ដូច្នេះ ហើយឱ្យទទួលដឹងពាក្យបង្គាប់នោះ ។ បាន ឮថា ព្រះកុមារនោះទ្រង់ត្រិះរិះថា “ក្នុងថ្ងៃទី ៧ ព្រះរាជានឹងឱ្យសម្លាប់ យើងចោល” ដូច្នេះ មិនស្រេង់មិនសោយទាំងផ្ទុំក៏មិនលក់ តាមសមគួរ ដល់ព្រះហឫទ័យ បានមានព្រះសរីរៈសៅហ្មងយ៉ាងច្រើន ។ បន្ទាប់ពី នោះ ព្រះរាជាត្រាស់សួរតិស្សកុមារនោះថា “លោកជាអ្នកមានរូបរាង យ៉ាងនេះ ព្រោះហេតុអ្វី” ព្រះកុមារទូលថា “សូមតេជះ ព្រោះខ្លាច សេចក្តីស្លាប់” ។ ព្រះរាជាទ្រង់ត្រាស់ថា “ឱហ្ន៎ ខ្ទនអ្នកឯង គង់សម្លឹង ឃើញសេចក្តីស្លាប់ ដែលខ្ញុំដាក់ទោសហើយ អស់សេចក្តីខ្វល់ខ្វាយ អស់ការគិត នឹងមិនលេងឬ ពួកភិក្ខុសម្លឹងឃើញសេចក្តីស្លាប់ ជាប់ ដោយខ្យល់ដកដង្ហើម ចូលនិងដកដង្ហើមចេញ នឹងលេងបានយ៉ាងណា ?” ចាប់ផ្តើមតាំងពីនោះមក ព្រះកុមារក៏ទ្រង់ជ្រះថ្លាក្នុងព្រះសាសនា ។ កាល ថ្ងៃស្អែកឡើង ព្រះកុមារនោះស្តេចចេញទៅបាញ់ម្រឹគ ត្រាច់សញ្ចរទៅក្នុង ព្រៃ បានទតឃើញព្រះយោនកមហាធម្មរក្ខិតត្ថេរ អ្នកអង្គុយឱ្យស្តេចដំរី ណាមួយចាប់មែកសាលព្រឹក្សបក់ ។ ព្រះកុមារគ្រា ទតឃើញហើយក៏ កើតសេចក្តីបាមោជ្ជៈត្រិះរិះថា “កាលណាហ្ន៎ សូម្បីយើងនឹងគប្បីបួសដូច ព្រះមហាថេរៈនេះ, ថ្ងៃនោះ នឹងគប្បីមានឬហ្ន៎” ។ ព្រះថេរៈដឹង អធ្យាស្រ័យរបស់ព្រះកុមារនោះហើយ កាលព្រះកុមារនោះឃើញនុ៎ះឯង

បានហោះឡើងទៅក្នុងអាកាស ហើយបានឈរនៅលើផ្ទៃទឹកឯស្រះបោក្ខរណី ក្នុងវត្តអសោការាមព្យួរចីវរនិងសំពត់ឧត្តរាសង្គទុកលើអាកាស ហើយចាប់ផ្ដើមស្រង់ទឹក ។ ព្រះកុមារទតឃើញអានុភាពរបស់ព្រះថេរៈនោះ ហើយក៏ទ្រង់ជ្រះថ្លាជាយ៉ាងក្រៃលែងត្រិះរិះថា យើងនឹងបួសឱ្យបានក្នុងថ្ងៃនេះតែម្ដងហើយស្ដេចត្រឡប់ បានទូលលាព្រះរាជាថា "សូមតេជៈមហាបពិត្រ ទូលបង្គំនឹងបួស" ។ ព្រះរាជាទ្រង់ឃាត់ (ទ្រង់សូមអង្វរ) ជាអនេកប្រការ កាលទ្រង់មិនអាចដើម្បីនឹងឱ្យព្រះកុមារនោះត្រឡប់ (ព្រះទ័យ) បាន ទើបទ្រង់ត្រាស់ឱ្យតាក់តែងមគ្គាដែលជាមកទៅកាន់វត្តអសោការាម ឱ្យព្រះកុមារតែងអង្គជាភេទមហោស្រព ឱ្យហែហមដោយពួកសេនាដែលប្រដាប់ប្រដាហើយ ទ្រង់នាំទៅកាន់ព្រះវិហារ ។ ភិក្ខុជាច្រើនបានឮដំណឹងថា ព្រះយុវរាជ នឹងព្រះផ្នួស ក៏នាំគ្នាត្រៀមបាត្រនិងចីវរទុក ។ ព្រះកុមារស្ដេច យាងទៅកាន់ផ្ទះជាទីបំពេញព្យាយាម ហើយទ្រង់បានព្រះផ្នួស ព្រមនឹងបុរសមួយសែនក្នុងសំណាក់របស់ព្រះមហាធម្មរក្ខិតត្ថេរនុ៎ះឯង ។ ក៏កុលបុត្រទាំងឡាយ ដែលបួសតាមព្រះកុមារ នឹងកំណត់រាប់មិនបាន ។ ព្រះកុមារទ្រង់ព្រះផ្នួសក្នុងវេលា ដែលព្រះរាជាទ្រង់អភិសេកគ្រងរាជ្យបាន ៤ ឆ្នាំ ។ គ្រានោះ នៅមានព្រះកុមារអង្គដទៃ មានព្រះនាមថា អគ្គិព្រហ្ម ជាព្រះស្វាមីរបស់ព្រះនាងសង្ឃមិត្តា

ដែលជាព្រះភាគិនីរបស់ព្រះរាជា ។ ព្រះនាងសង្ឃមិត្តាប្រសូតិព្រះឱរស របស់អគ្គិព្រហ្មអង្គនោះត្រឹមតែមួយអង្គប៉ុណ្ណោះ ។ អគ្គិព្រហ្មសូម្បីអង្គនោះ បានឮដំណឹងថា ព្រះយុវរាជ ទ្រង់ព្រះផ្នួសហើយ ទើបចូលទៅគាល់ព្រះរាជា ហើយទូលសូមព្រះបរមរាជានុញ្ញាតថា "សូមតេជៈ សូម្បីទូលបង្គំ ក៏នឹងបួសដែរ" ដូច្នេះ ។ អគ្គិព្រហ្មអង្គ នោះ បានទទួលព្រះបរមរាជានុញ្ញាតថា "ចូរបួសចុះ បា" ក៏បានបួសក្នុងថ្ងៃនោះឯង ។ ព្រះថេរៈ ដែលខត្តិយជនមានសម្បត្តិយ៉ាងឱឡារ បួសតាមយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ព្រះតិស្សត្ថេរ អ្នកជាព្រះកនិដ្ឋភាតារបស់ព្រះរាជា ។

## ព្រះតិស្សត្ថេរអង្គុយឃាំងមិនឱ្យអាមាត្យកាត់សីសៈភិក្ខុ

ព្រះតិស្សថេរៈនោះ គ្រាឃើញអាមាត្យនោះ ដែលបដិបត្តិខុសយ៉ាងនោះហើយ ទើបត្រិះរិះថា "ព្រះរាជាគង់នឹងទ្រង់មិនបញ្ជូនមកដើម្បីឱ្យសម្លាប់ព្រះថេរៈ ទាំងឡាយ រឿងនេះ នឹងជារឿងដែលអាមាត្យនេះយល់ខុសពិតប្រាកដតែម្តង" ដូច្នេះ ទើបបានទៅអង្គុយលើអាសនៈជិតអាមាត្យនោះដោយខ្លួនឯង ។ អាមាត្យនោះចាំព្រះថេរៈនោះបាន ក៏មិនអាចផាសស្រ្តាកាប់បាន ទើបបានត្រឡប់ទៅក្រាបទូលចំពោះព្រះរាជាថា "សូមតេជៈ ទូលបង្គំបានកាត់សីសៈរបស់ពួកភិក្ខុឈ្មោះមានប្រមាណប៉ុណ្ណេះ ដែលមិនប្រាថ្នាធ្វើឧបោសថឱ្យដាច់ធ្លាក់ទៅខណៈនោះ ក៏មកដល់

លំដាប់នៃព្រះតិស្សត្ថេរជាម្ចាស់ តើទូលបង្គំនឹងធ្វើយ៉ាងណា ?" ព្រះរាជាលុះទ្រង់បានស្ដាប់ប៉ុណ្ណោះ ក៏ត្រាស់ថា "ហឺយ តើយើងបានបញ្ជូនលោកឱ្យទៅសម្លាប់ភិក្ខុទាំងឡាយឬ ?" ភ្លាមទុំះឯង ក៏កើតសេចក្ដីក្ដៅផ្សាឡើងក្នុងព្រះវរកាយ ទើបស្ដេចយាងទៅកាន់ព្រះវិហារ ត្រាស់សួរពួកភិក្ខុដែលជាព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន អាមាត្យនេះញៀមមិនបានបង្គាប់ឡើយ បានធ្វើកម្មយ៉ាងនេះ ហើយបាបនេះនឹងគប្បីមានដល់អ្នកណាហ្ន៎ ?"

## ពួកភិក្ខុថ្វាយយោបល់ចំពោះព្រះរាជា ២ ន័យ

ព្រះថេរៈពួកខ្លះ ថ្វាយព្រះពរថា "អាមាត្យនេះ បានធ្វើតាមព្រះតម្រាស់បង្គាប់របស់មហាបពិត្រហើយ, បាបនោះ ទើបមានដល់មហាបពិត្រផង" ។ ព្រះថេរៈពួកខ្លះ ថ្វាយព្រះពរថា "បាបនោះ រមែងមានចំពោះមហាបពិត្រ និង អាមាត្យសូម្បីទាំង ២ ផង" ។

ព្រះថេរៈពួកខ្លះថ្វាយព្រះពរយ៉ាងនេះថា "សូមថ្វាយព្រះពរ ក៏មហាបពិត្រទ្រង់មានសេចក្ដីគិតឬថា 'អាមាត្យនាយនេះ ចូរទៅសម្លាប់ភិក្ខុទាំងឡាយ'" ព្រះរាជាទ្រង់ត្រាស់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើនមិនមាន, ញៀមមានសេចក្ដីប្រាថ្នាជាកុសល ទើបបានបញ្ជូនគេទៅដោយបង្គាប់ថា 'សូមភិក្ខុសង្ឃសាមគ្គីគ្នាធ្វើឧបោសថចុះ'" ។ ព្រះថេរៈទាំង

ឡាយថ្វាយព្រះពរថា "បើថា មហាបពិត្រ មានព្រះរាជប្រាថ្នាជាកុសលសោត, បាបក៏មិនមានចំពោះមហាបពិត្រ, បាបនោះ រមែងមានដល់អាមាត្យប៉ុណ្ណោះ" ។ ព្រះរាជាទ្រង់កើតមានសេចក្តីសង្ស័យក្នុងចិត្តបែកជាពីរ ទើបត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន តើមានភិក្ខុរូបណាមួយដែរទេ ? អ្នកអាចដើម្បីនឹងកាត់សេចក្តីសង្ស័យបែកជាពីរនេះរបស់ញោម ហើយលើកតម្កើងព្រះសាសនា" ។ ភិក្ខុទាំងឡាយថ្វាយព្រះពរថា "មាន មហាបពិត្រ ភិក្ខុនោះឈ្មោះព្រះមោគ្គលីបុត្តតិស្សត្ថេរ, លោកអាចកាត់សេចក្តីសង្ស័យបែកជាពីរនេះរបស់មហាបពិត្រ ហើយលើកតម្កើងព្រះសាសនាបាន" ។ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់បានចាត់បញ្ជូនព្រះធម្មកថិក ៣ រូប ក្នុងមួយរូប ៗ មានភិក្ខុមួយពាន់ជាបរិវារ, និងអាមាត្យ ៤ នាក់ ក្នុងមួយនាក់ ៗ មានបុរសមួយពាន់ជាបរិវារ ដោយទ្រង់ត្រាស់ថា "សូមលោកទាំងឡាយ ចូរទទួលយកព្រះថេរៈមកចុះ" ។

## ព្រះមោគ្គលីបុត្តតិស្សត្ថេរមិនមកព្រោះអារាធនាខុស

ព្រះធម្មកថិកនិងអាមាត្យទាំងនោះទៅហើយ បានទូល (ព្រះថេរៈ) ថា "ព្រះរាជាបង្គាប់ឱ្យរកលោក" ដូច្នេះ ។ ព្រះថេរៈមិនព្រមមក ។ សូម្បីលើកទី ២ ព្រះរាជាក៏ទ្រង់បានចាត់បញ្ជូន ព្រះធម្មកថិក ៨ រូប និងអាមាត្យ ៨ នាក់ ដែលមានបរិវារម្នាក់មួយពាន់ ៗ ទៅ

ដោយបង្គាប់ថា "លោកទាំងឡាយចូរក្រាបទូល (ព្រះថេរៈនោះ) ថា 'បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះរាជាបង្គាប់ឱ្យរក, ហើយឱ្យនិមន្តព្រះថេរៈមក" ។

ព្រះធម្មកថិកនិងអាមាត្យទាំងនោះ បានក្រាបទូល (ព្រះថេរៈ) ដូចដែលទ្រង់ត្រាស់នោះឯង ។ សូម្បីលើកទី ២ ព្រះថេរៈ ក៏មិនបានមក ។ ព្រះរាជាត្រាស់សួរព្រះថេរៈទាំងឡាយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ញោមបានបញ្ជូនទូតទៅដល់ ២ ដងហើយ ព្រោះហេតុអ្វី ទើបព្រះថេរៈមិនបានមក ?" ព្រះថេរៈទាំងឡាយ ថ្វាយព្រះពរថា "មហាបពិត្រ ដែលលោកមិនមកនោះ ព្រោះទូត ទាំងនោះ ក្រាបទូលលោកថា 'ព្រះរាជាបង្គាប់ឱ្យរក', តែកាលទូតទាំងនោះក្រាបទូលលោកយ៉ាងនេះថា 'បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសាសនាសាបសូន្យថយចុះ, សូមលោកម្ចាស់មេត្តាបានជាសម្លាញ់ពួកខ្ញុំព្រះករុណា ដើម្បីលើកស្ទួយព្រះសាសនាចុះ' ដូច្នេះ, ព្រះថេរៈនឹងគប្បីមក" ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់ដូចយ៉ាងនោះហើយ ទើបទ្រង់ចាត់បញ្ជូនព្រះធម្មកថិក ១៦ រូប និងអាមាត្យ ១៦ នាក់ ដែលមានបរិវារម្នាក់មួយពាន់ ៗ ទៅ ទ្រង់បានសាកសួរភិក្ខុទាំងឡាយទៀតថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះថេរៈជាអ្នកចាស់ ឬនៅកម្លោះទេ ?"

ភិក្ខុ. "ចាស់ហើយ មហាបពិត្រ"

រាជា. "ព្រះថេរៈនោះ នឹងឡើងក្រស្នែងឬវ លោកម្ចាស់"

ភិក្ខុ. "លោកនឹងមិនឡើង ( ទាំង ២ យ៉ាង ) មហាបពិត្រ"

រាជា. "ព្រះថេរៈសម្រាកក្នុងទីណា ? លោកម្ចាស់" ។

ភិក្ខុ. "ក្បែរទន្លេគង្គាត្រើយខាងជើង មហាបពិត្រ" ។

ព្រះរាជា ទ្រង់ត្រាស់ថា "ម្នាលនាយ បើដូច្នោះ ពួកលោកចូរចង ទូកផែ ហើយអារាធនាឱ្យព្រះថេរៈអង្គុយលើទូកផែនោះឯង ចាត់ការរក្សា ត្រង់ប្រាំងទាំង ២ ផ្នែក នាំព្រះថេរៈមកចុះ" ។ ពួកភិក្ខុនិងពួកអាមាត្យ ទៅ ដល់សំណាក់របស់ព្រះថេរៈហើយ បានទូលឱ្យជ្រាបតាមព្រះរាជសាសន៍ ។

ព្រះថេរៈបានស្តាប់ ( ព្រះរាជសាសន៍នោះ ) ហើយគិតថា "ព្រោះ ហេតុដែលយើងបួសមក ក៏ដោយការតាំងចិត្តថា នឹងលើកស្ទួយព្រះ សាសនា តាំងពីដើម ដូច្នោះ កាលនោះក៏មកដល់យើងហើយ" ទើបបាន កាន់យកកំណាត់ស្បែកក្រោកឡើង ។

## ព្រះបាទអសោកទ្រង់ព្រះសុបិនឃើញដំរីសសុទ្ធ

គ្រានោះ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យហើយថា "ស្អែកនេះ ព្រះថេរៈ នឹងមកដល់ព្រះនគរបាតលីបុត្ត" ដូច្នេះ ក៏ទ្រង់ឃើញព្រះសុបិន ក្នុងចំណែករាត្រី បានមានព្រះសុបិនបែបនេះ គឺ ស្តេចដំរីសសុទ្ធមក

ស្ទាបអង្អែលព្រះរាជា ចាប់ផ្តើម តាំងពីព្រះសិរសា ហើយបានចាប់ព្រះរាជាត្រង់ព្រះហស្តខាងស្តាំ ។ ក្នុងថ្ងៃស្អែក ព្រះរាជាបានត្រាស់សួរពួកហោរអ្នកទោះទាយសុបិនថា "យើងយល់សប្តិឃើញសុបិនបែបនេះ នឹងមានអ្វីដល់យើង ?" ហោរទោះទាយសុបិនម្នាក់ ទូលថ្វាយសេចក្តីឃើញថា "សូមតេជះ ក្រោមល្អងធូលីព្រះបាទថ្ងៃវិសេស ព្រះសមណៈអ្នកប្រសើរ នឹងចាប់ក្រោមល្អងធូលីព្រះបាទត្រង់ព្រះហស្តខាងស្តាំ" ។ គ្រានោះ ព្រះរាជាក៏ទ្រង់បានជ្រាបដំណឹងថា "ព្រះថេរៈមកហើយក្នុងខណៈនោះឯង" ទើបស្តេចយាងទៅកាន់មាត់ច្រាំងទន្លេគង្គា ហើយស្តេចចុះលុយទឹកទន្លេជ្រៅទៅ ៗ ដរាបដល់ព្រះថេរៈ ក្នុងទឹកមានប្រមាណត្រឹមជានុ ហើយបានថ្វាយព្រះហស្តដល់ព្រះថេរៈអ្នកកំពុងចុះពីទូក ។ ព្រះថេរៈបានចាប់ព្រះរាជាត្រង់ព្រះហស្តខាងស្តាំហើយ ។

## រាជបុរសប្រុងកាត់សីសៈព្រះមោគ្គលីបុត្តតិស្សត្ថេរ

ពួករាជបុរសកាន់ដាវ ឃើញកិរិយានោះហើយ ក៏ហូតដាវចេញចាកស្រោម ដោយគិតថា "ពួកយើងនឹងកាត់សីសៈរបស់ព្រះថេរៈឱ្យធ្លាក់ទៅ" ដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបានឮថា ក្នុងរាជត្រកូលមានចារិកនេះថា "អ្នកណាចាប់ព្រះរាជាត្រង់ព្រះហស្ត រាជ

បុរសគប្បីយកដាវកាត់សីសៈរបស់អ្នកនោះ ឱ្យធ្លាក់ទៅ” ។ ព្រះរាជាទតឃើញស្រមោល (ដាវ) ប៉ុណ្ណោះ ក៏ទ្រង់ត្រាស់ថា “សូម្បីគ្រាមុនយើងមិនប្រសព្វសេចក្តីសប្បាយចិត្ត ព្រោះហេតុដែលខុសក្នុងភិក្ខុទាំងឡាយ ពួកលោកកុំធ្វើខុស ក្នុងព្រះថេរៈឡើយ” សួរថា ក៏ព្រោះហេតុអ្វីបានជាព្រះថេរៈបានចាប់ព្រះរាជាត្រង់ព្រះហស្ត ? ឆ្លើយថា ព្រោះហេតុដែលព្រះថេរៈនោះ ដែលព្រះរាជាឱ្យអារាធនាមក ដើម្បីត្រូវការទឹងត្រាស់ សួរបញ្ហា ដូច្នោះ ព្រះថេរៈដាក់ចិត្តថា “ព្រះរាជាព្រះអង្គនេះ ជាអន្តេវាសិករបស់យើង” ទើបបានចាប់ ។

## ព្រះបាទអសោកទ្រង់សង្ស័យព្រះមោគ្គលីបុត្តតិស្សត្ថេរ

ព្រះរាជាទ្រង់នាំព្រះថេរៈទៅកាន់រាជឧទ្យានរបស់ព្រះអង្គ ហើយទ្រង់ត្រាស់ឱ្យតាំងការរក្សាលោមព័ទ្ធទុក ពីខាងក្រៅដល់ ៣ ជាន់ ចំណែកព្រះអង្គឯង ក៏ទ្រង់លាងជើងព្រះថេរៈហើយ លាបប្រេង ឱ្យប្រថាប់អង្គុយនៅក្នុងសំណាក់របស់ព្រះថេរៈហើយ ទ្រង់ត្រិះរិះថា “ព្រះថេរៈនឹងជាអ្នកអាចទេហ្ន៎ ដើម្បីកាត់សេចក្តីសង្ស័យរបស់យើង រម្ងាប់អធិករណ៍ដែលកើតឡើងហើយ លើកស្ទួយព្រះសាសនា” ដូច្នេះ ដើម្បីត្រូវការទឹងទ្រង់សាកល្បងមើល ទើបទូលសួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ញោមមានសេចក្តីប្រាថ្នាចង់ឃើញបាដិហារ្យត្រឹមតែមួយយ៉ាង” ។

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ ប្រាថ្នាទតឃើញបាដិហារ្យប្រភេទណា ?”

ព្រះរាជា. “ចង់ឃើញផែនដីញ័រ លោកម្ចាស់”

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ ប្រាថ្នានឹងទតឃើញផែនដីញ័រទាំងអស់ ឬចង់ទតឃើញផែនដីញ័រផ្នែកខ្លះ ?”

ព្រះរាជា. “ក៏បណ្តា ២ យ៉ាងនេះ មួយណាធ្វើលំបាក លោកម្ចាស់” ។

ព្រះថេរៈ. “សូមថ្វាយព្រះពរ កាលថាសសំរិតពេញ ដោយទឹក ការធ្វើឱ្យទឹកនោះញ័រទាំងអស់ ឬឱ្យញ័រត្រឹមតែពាក់កណ្តាល តើណាជារបស់ធ្វើបានលំបាក(ជាង) ។

ព្រះរាជា. “ឱ្យញ័រត្រឹមតែពាក់កណ្តាល ជារបស់ធ្វើបានលំបាក (ជាង) លោកម្ចាស់” ។

ព្រះថេរៈ. “សូមថ្វាយព្រះពរ ដោយប្រការដូចថ្វាយព្រះពរ មកហើយនុ៎ះឯង ការឱ្យផែនដីញ័រផ្នែកខ្លះធ្វើបានលំបាក” ។

ព្រះរាជា. “បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ ញោម នឹងមើលផែនដីញ័រផ្នែកខ្លះ (ប៉ុណ្ណោះ)” ។

ព្រះថេរៈ "សូមថ្វាយព្រះពរ បើដូច្នោះក្នុងចម្ងាយមួយយោជន៍ ៗ ដោយជុំវិញរថចូរចតត្រង់ដែនដោយកង់ម្ខាង ខាងទិសបូព៌ា, សេះចូរឈរជាន់ដែន ដោយជើងទាំងពីរ ខាងទិសទក្សិណ, បុរសចូរឈរជាន់ដែនដោយជើងម្ខាង ខាងទិសបច្ឆិម, ថាស ( មាន ) ទឹកមួយ ចូរដាក់ចំត្រង់ចំណែកពាក់កណ្ដាលខាងទិសឧត្តរ ៗ ព្រះរាជាបង្គាប់ឱ្យធ្វើយ៉ាងនោះហើយ ។

## ព្រះមោគ្គលីបុត្តតិស្សត្ថេរអធិដ្ឋានឱ្យផែនដីញ័រ

ព្រះថេរៈចូលចតុត្ថជ្ឈានដែលមានអភិញ្ញាជាបាទ ចេញហើយបានអធិដ្ឋានឱ្យផែនដីញ័រ មានប្រមាណមួយយោជន៍ ដោយសេចក្ដីរំពឹងថា សូមឱ្យព្រះរាជាចូរទតឃើញ ដូច្នេះ ។ ខាងទិសបូព៌ាកង់រថដែលឋិតនៅខាងក្នុងព្រំប្រទល់ទុំះឯងញ័រហើយ ក្រៅនេះមិនញ័រ ។ ខាងទិសទក្សិណនិងទិសបច្ឆិម ជើងរបស់សេះ និង បុរសដែលជាន់នៅខាងក្នុងព្រំប្រទល់ប៉ុណ្ណោះ ញ័រហើយ និងខ្លួន ( របស់សេះនិងបុរស ) ក៏ញ័រត្រឹមតែពាក់កណ្ដាល ៗ ដោយប្រការយ៉ាងនេះ ។ ខាងទិសឧត្តរ ទឹកដែលឋិតនៅខាងក្នុងខេត្តនៃថាសទឹក ញ័រតែពាក់កណ្ដាលប៉ុណ្ណោះ ដែលនៅសល់មិនមានញ័រឡើយឯង ។

## ព្រះបាទអសោកសួរនូវសេចក្តីសង្ស័យក្នុងរឿងបាប

ព្រះរាជា ទតឃើញបាដិហារ្យនោះហើយ ក៏សម្រេចព្រះទ័យថា "ឥឡូវនេះ ព្រះថេរៈនឹងអាចដើម្បីនឹងលើកស្ទួយព្រះសាសនាបាន" ទើបត្រាស់សួរសេចក្តីសង្ស័យរបស់ព្រះអង្គថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ញោមបានបញ្ជូនអាមាត្យម្នាក់ទៅ ដោយបង្គាប់ថា 'លោកទៅកាន់ព្រះវិហារម្ងាប់អធិករណ៍ ហើយនិមន្តឱ្យភិក្ខុសង្ឃធ្វើឧបោសថចុះ" ដូច្នេះ គេទៅកាន់ព្រះវិហារហើយ បានផ្តាច់ជីវិតភិក្ខុអស់ចំនួនប៉ុណ្ណោះរូប បាបនោះ នឹងមានដល់អ្នកណា ?

ព្រះថេរៈ ទូលសួរថា "សូមថ្វាយព្រះពរ ក៏ព្រះអង្គមានគិតឬទេថា 'អាមាត្យនេះ ចូរទៅកាន់ព្រះវិហារហើយ នឹងសម្លាប់ភិក្ខុទាំងឡាយ'" ។

ព្រះរាជា. "ការគិតនោះមិនមានទេ លោកម្ចាស់" ។

ព្រះថេរៈ. "សូមថ្វាយព្រះពរ បើព្រះអង្គមិនមានការគិតបែបនេះទេ បាបក៏មិនមានដល់ព្រះអង្គឡើយ" ។

## ព្រះថេរៈអាងព្រះពុទ្ធវចនៈពោលអតីតនិទាន

លំដាប់នោះ ព្រះថេរៈ (ថ្វាយវិសជ្ជនា) ឱ្យព្រះរាជាទ្រង់យល់ច្បាស់នូវសេចក្ដីនេះដោយព្រះសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថា ជាកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចា ចិត្ត"[១] ដូច្នេះ ។ ដើម្បីសម្ដែងសេចក្ដីនោះឯង ទើបព្រះថេរៈនាំតិត្តិរជាតកមក[២] (ជាឧទាហរណ៍) ដូចតទៅនេះ ។

សូមថ្វាយព្រះពរ មហាបពិត្រ ក្នុងអតីតកាល សត្វទទា ឈ្មោះទីបកៈ ទូលសួរព្រះតាបសថា

"បពិត្រលោកម្ចាស់ដ៏ចម្រើន សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិរបស់ពួកយើងទំនៅ (ត្រង់ទីនោះ) ព្រានប៉ះពាល់(ធ្វើ)នូវបាណាតិបាតកម្ម ព្រោះអាស្រ័យ ខ្ញុំព្រះករុណា ចិត្តខ្ញុំព្រះករុណា ក៏រង្កៀសក្នុងរឿងនោះ" ។

ព្រះតាបសឆ្លើយថា ក៏អ្នកមានគិត (យ៉ាងនេះ) ឬថា "សូម

---

១. អង្គុ. ឆក្ក. មហាវគ្គ. ៤៦. ៦៣/២៧២ ។ ២. ខុទ្ទ. ជាត. តិត្តិរជាតក. ៥៨. ៥៧៦/២០៥; និងជាតកដ្ឋកថា ។

សត្វទាំងឡាយនោះមក ព្រោះសំឡេង និងព្រោះឃើញរូប របស់យើង ហើយចូរត្រូវជាប់អន្ទាក់ ឬចូរត្រូវសម្លាប់" ។

សត្វទា ឆ្លើយប្រាប់ថា "ការគិតនោះមិនមានទេ លោកម្ចាស់ដ៏ចម្រើន" ។

លំដាប់នោះ ទើបតាបសឱ្យសត្វទានោះយល់ព្រមថា "បើលោកមិនបានគិតសោត បាបក៏មិនមាន" ពិតមែន កម្ម រមែងពាល់ត្រូវបុគ្គលដែលគិតប៉ុណ្ណោះ មិនពាល់ត្រូវបុគ្គលដែលមិនគិតទេ ។

ព្រានមិនប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យអ្នកទេ
បើចិត្តអ្នកមិនប្រទូស្ត បាបក៏មិនប្រលាក់នូវអ្នកដ៏ចម្រើន
ដែលមិនមានសេចក្តីខ្វល់ខ្វាយឡើយ ។

## ព្រះរាជាទ្រង់ជម្រះអធិករណ៍នៃព្រះពុទ្ធសាសនា

ព្រះថេរៈ គ្រា( ថ្វាយវិសជ្ជនា )ឱ្យព្រះរាជាទ្រង់យល់ចូលចិត្តយ៉ាងនោះហើយ សម្រាកក្នុងព្រះរាជឧទ្យាននៃព្រះនគរនោះឯង រហូតអស់ ៧ ថ្ងៃ ហើយឱ្យព្រះរាជាទ្រង់រៀននូវលទ្ធិសម័យ ( នៃព្រះសម្មាសម្ពុទ្ធ ) ។ ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់ត្រាស់ឱ្យភិក្ខុសង្ឃប្រជុំគ្នាក្នុងវត្តអសោការាម

ឱ្យបាំងរាំងននយាំងទុក ហើយប្រថាប់អង្គុយនៅខាងក្នុងរាំងនន ទ្រង់ត្រាស់ឱ្យបាត់ពួកភិក្ខុ អ្នកមានលទ្ធិដូច ៗ គ្នាឱ្យនៅរួមគ្នាជាពួក ៗ ហើយត្រាស់ឱ្យនិមន្តពួកភិក្ខុមកម្តងមួយពួក ៗ ហើយត្រាស់សួរថា កិំវាទី សម្មាសម្ពុទ្ធោ ៖ ព្រះសម្មាសម្ពុទ្ធមានប្រក្រតីត្រាស់យ៉ាងណា ?

លំដាប់នោះ ពួកភិក្ខុសស្សតវាទី ទូលថា សស្សតវាទី ៖ មានប្រក្រតីត្រាស់ថា ទៀង ។

ពួកភិក្ខុឯកច្ចសស្សតិក: ទូលថា ឯកច្ចសស្សតិកវាទី ៖ មានប្រក្រតីត្រាស់ថា ទៀងខ្លះ មិនទៀងខ្លះ ។

ពួកភិក្ខុអន្តានន្តិក: ទូលថា អន្តានន្តិកវាទី ៖ មានប្រក្រតីត្រាស់ថា លោកមានទីបំផុត និងមិនមានទីបំផុត ។

ពួកភិក្ខុអមរាវិក្ខេបិក: ទូលថា អមរាវិក្ខេបិកវាទី ៖ មានប្រក្រតីត្រាស់ពាក្យបោះសំដីមិនស្លាប់ខ្លួន ។

ពួកភិក្ខុអធិច្ចសមុប្បន្និក: ទូលថា អធិច្ចសមុប្បន្និកវាទី ៖ មានប្រក្រតីត្រាស់ថា ខ្លួន និងលោកកើតឡើងឯង ៗ មិនមានហេតុ ។

ពួកភិក្ខុសញ្ញិវាទ: ទូលថា សញ្ញិវាទី ៖ មានប្រក្រតីត្រាស់ថា ខ្លួនមានសញ្ញា ។

ពួកភិក្ខុអសញ្ញិវាទៈ ទូលថា **អសញ្ញិវាទី** មានប្រក្រតី ត្រាស់ថា ខ្លួនមិនមានសញ្ញា ។

ពួកភិក្ខុនេវសញ្ញិនាសញ្ញិវាទៈ ទូលថា **នេវសញ្ញិនាសញ្ញិវាទី** : មានប្រក្រតីត្រាស់ថា ខ្លួនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ពួកភិក្ខុឧច្ឆេទវាទៈ ទូលថា **ឧច្ឆេទវាទី** : មានប្រក្រតីត្រាស់ថា ដាច់សូន្យ ។

ពួកភិក្ខុទិដ្ឋធម្មនិព្វានវាទៈ ទូលថា **ទិដ្ឋធម្មនិព្វានវាទី** : មានប្រក្រតីត្រាស់ថា ព្រះនិព្វានមាននៅក្នុងបច្ចុប្បន្ន (ភពបច្ចុប្បន្ន) ។[១]

## ព្រះរាជាទ្រង់ត្រាស់ឱ្យផ្សឹកពួកបន្លំជាភិក្ខុ ៦ ម៉ឺនរូប

ព្រះរាជាទ្រង់ជ្រាបថា ពួកនេះមិនមែនភិក្ខុ, ពួកនេះជា អន្យតិរ្ថិយ៍ ក៏ព្រោះព្រះអង្គទ្រង់បានរៀននូវលទ្ធិមកមុនទុំះឯង ទើបព្រះរាជទានសំពត់សដល់លោកពួកនោះ ហើយឱ្យសឹកចេញ ។ សូម្បីពួកតិរ្ថិយទាំងអស់

១. ទីឃ. សីល. ព្រហ្មជាលសូត្រ. ១៤. ២៧/៣១ ... : ទិដ្ឋិទាំង ១០ យ៉ាងនេះ គឺ ទិដ្ឋិ ៦២ នុ៎ះឯង ។

នោះមានចំនួនដល់ ៦ ម៉ឺននាក់ ។ លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់ឱ្យអារាធនាភិក្ខុពួកដទៃមក ហើយត្រាស់សួរថា ៖

កឹវាទី ភន្តេ សម្មាសម្ពុទ្ធោ : បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសម្មាសម្ពុទ្ធមានប្រក្រតីត្រាស់ថា យ៉ាងណា ?

ភិក្ខុទាំងឡាយទូលថា វិភជ្ជវាទី មានប្រក្រតីត្រាស់ចែក មហាបពិត្រ ។

កាលភិក្ខុទាំងឡាយទូលយ៉ាងនោះហើយ ទើបព្រះរាជាត្រាស់សួរព្រះថេរៈ ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសម្មាសម្ពុទ្ធជាវិភជ្ជវាទី (មានប្រក្រតីត្រាស់ចែកឬ ?)" ព្រះថេរៈទូលថា "សូមថ្វាយព្រះពរមហាបពិត្រ" លំដាប់នោះ ព្រះរាជាទ្រង់ត្រាស់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ព្រះសាសនា បរិសុទ្ធិហើយ, សូមភិក្ខុសង្ឃចូរធ្វើឧបោសថចុះ" ដូច្នេះ ព្រះរាជទានរក្សាទុកហើយ ស្តេចចូលទៅកាន់ព្រះនគរ ។ សង្ឃព្រមព្រៀង បានប្រជុំគ្នាធ្វើឧបោសថហើយ ។ ក្នុងសន្និបាតនោះមានភិក្ខុចំនួន ៦០ សែនរូប ។

# ព្រះថេរៈរើសភិក្ខុមួយពាន់រូបធ្វើតតិយសង្គាយនា

ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ កាលទឹងញាំញីពាក្យពោលតិះដៀលរបស់ជនពួកដទៃ ទើបបានសម្ដែង[១]កថាវត្ថុបករណ៍ក្នុងសមាគមនោះ ។ លំដាប់នោះ ព្រះថេរៈ បានជ្រើសរើស បណ្ដាភិក្ខុដែលរាប់បានមានចំនួន ៦០ សែនរូប យកចំពោះភិក្ខុមួយពាន់រូប អ្នកទ្រទ្រង់បរិយត្តិ គឺ ព្រះត្រៃបិដក បែកធ្លាយក្នុងបដិសម្ភិទា ជំនាញក្នុងត្រៃវិជ្ជាជាដើម កាលទឹងសង្គាយនាធម៌និងវិន័យ បានជម្រះមន្ទិលក្នុងព្រះសាសនាទាំងអស់ ទើបបានធ្វើតតិយសង្គីតិ ដូចយ៉ាងព្រះមហាកស្សបត្ថេរ និងព្រះយសត្ថេរ សង្គាយនាធម៌ និងវិន័យដូច្នោះ ។ ក្នុងទីបំផុតនៃសង្គីតិ បឋវីក៏បានញាប់ញ័រ ជាអនេកប្រការ ។

សង្គីតិដែលធ្វើអស់រយៈពេល ៩ ខែ ទើបចប់, សង្គីតិនេះ លោកហៅថា សហស្សិកសង្គីតិ ព្រោះធ្វើដោយភិក្ខុមួយពាន់ រូប និងហៅថា តតិយសង្គីតិ ព្រោះប្រៀបធៀបនឹងសង្គីតិដែលមានមក អំពីមុន ២ លើកហើយ ដោយប្រការដូច្នេះ ។

ចប់ តតិយសង្គីតិ

---

១. សារត្ថទីបនី ជា អភាសិ ។

## រឿងនាំព្រះវិន័យបិដកបន្តគ្នាមក

ក៏ដើម្បីទឹងវិសជ្ជនាបញ្ហានេះថា ព្រះវិន័យបិដក អ្នកណា នាំបន្តមក ខ្ញុំព្រះករុណាបានពោលពាក្យណាទុកថា ព្រះវិនយបិដកនេះ បាននាំបន្តគ្នាមកតាមលំដាប់អាចារ្យ តាំងអំពីព្រះឧបាលីថេរៈជាដំបូងក្នុងជម្ពូទ្វីបដរាបដល់តតិយសង្គីតិ, ក្នុងជម្ពូទ្វីបនោះ មានការនាំបន្តគ្នាមកតាមលំដាប់អាចារ្យដូច្នេះ ៖

ព្រះថេរៈទាំង ៥ រូបនេះ គឺ ព្រះឧបាលី ១ ព្រះទាសកៈ ១ ព្រះសោណកៈ ១ ព្រះសិគ្គវៈ ១ ព្រះមោគ្គលីបុត្តតិស្សៈ ១ អ្នកមានជ័យជំនះពិសេស បាននាំព្រះវិន័យ (ត ៗគ្នា)មក ក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី មិនឱ្យដាច់តាមលំដាប់អាចារ្យ ដរាបដល់តតិយសង្គាយនា ។

សេចក្ដីនៃពាក្យនោះ ខ្ញុំព្រះករុណា បានប្រកាសហើយ ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ ។

## រាយនាមព្រះថេរៈអ្នកនាំព្រះវិន័យបិដកបន្តដល់សព្វថ្ងៃ

មួយទៀត តពីតតិយសង្គាយនា ព្រះថេរៈទាំងឡាយមានព្រះមហិន្ទជាដើមបាននាំព្រះវិន័យបិដកមកកាន់កោះនេះ (គឺ កោះលង្កា), ព្រះថេរៈទាំងឡាយមានព្រះអរិដ្ឋត្ថេរជាដើម រៀនអំពីព្រះមហិន្ទហើយ

បាននាំបន្តគ្នាមកក្នុងរយៈពេលតិចតួច, តាំងពីពេលដែលព្រះអរិដ្ឋត្ថេរជាដើមនោះនាំតមក បណ្ឌិតគប្បីជ្រាបថា ព្រះវិន័យបិដកនេះ បាននាំបន្តគ្នាមកតាមលំដាប់អាចារ្យដែលចាត់ថា ជាលំដាប់អន្តេវាសិករបស់ព្រះថេរៈទាំងនោះ មានព្រះអរិដ្ឋត្ថេរជាដើម ដរាបដល់សព្វថ្ងៃនេះ សមដូចដែលព្រះបូរាណាចារ្យទាំងឡាយពោលទុកថា

តអំពីព្រះថេរៈទាំងនោះមក ព្រះមហិន្ទៈ១ ព្រះឥដ្ដិយៈ១ ព្រះឧត្តិយៈ១ ព្រះសម្ពលៈ១ ព្រះភទ្ទនាមជាបណ្ឌិត១ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើនមកពីជម្ពូទ្វីប ហើយបានមកនៅក្នុងលង្កាទ្វីប ព្រះថេរៈទាំងនោះ បានបង្រៀនវិនយបិដក បានបង្រៀននិកាយទាំង៥ គម្ពីរអភិធម្មទាំង៧ គម្ពីរ ក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា) ។ តអំពីនោះមក (មានព្រះថេរៈ ច្រើនអង្គទៀត គឺ) ព្រះអរិដ្ឋជាអ្នកមានប្រាជ្ញា១ ព្រះតិស្សទត្តជាបណ្ឌិត១ ព្រះកាឡសុមនត្ថេរជាអ្នកក្លៀវក្លា១ ព្រះទីឃនាមកៈ១ ព្រះទីឃសុមនៈជាបណ្ឌិត១, ព្រះកាឡសុមនៈ១ ព្រះនាគត្ថេរ១ ព្រះពុទ្ធរក្ខិត១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញា១ ព្រះទេវត្ថេរជាបណ្ឌិត១, ព្រះសុមនៈជាអ្នកក្លៀវក្លា ក្នុងព្រះវិន័យ១ ព្រះចូឡនាគៈជា

ពហុស្សូត១ ព្រះគជត្ថេរ ជាអ្នកកម្ចាត់បង់ទោសដ៏អាក្រក់១ ព្រះថេរៈនាមធម្មបាលិត ដែលគេបូជាហើយដោយប្រពៃក្នុងរោហណជនបទ១ សិស្សរបស់ព្រះធម្មបាលិតនោះ ឈ្មោះខេមៈ ជាអ្នកមានប្រាជ្ញាច្រើន ទ្រទ្រង់ព្រះត្រៃបិដក រុងរឿងដោយបញ្ញានៅក្នុងទ្វីប ដូចជាព្រះចន្ទ១ ព្រះថេរៈឈ្មោះឧបតិស្សៈជាអ្នកមានប្រាជ្ញា១ ព្រះបុស្សទេវៈដែលជាមហាធម្មកថិក១, ព្រះសុមនៈអ្នកមានប្រាជ្ញា១ ព្រះបុប្ផៈ (គឺ ព្រះមហាបទុមត្ថេរ)[១] ជាពហុស្សូត១ ព្រះមហាសីវៈជាមហាធម្មកថិក ឈ្លាសវៃក្នុងបិដកទាំងអស់១, ព្រះឧបាលិ ជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងព្រះវិន័យ១ ព្រះមហានាគជាអ្នកមានប្រាជ្ញាច្រើន ឈ្លាសវៃក្នុងវង្សព្រះសទ្ធម្ម១, ព្រះអភ័យ ជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងបិដកទាំងអស់១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញាដ៏ក្លៀវក្លាក្នុងព្រះវិន័យ១ សិស្សរបស់ព្រះតិស្សត្ថេរនោះ ឈ្មោះបុស្សៈ[២] ជាអ្នកមានប្រាជ្ញាច្រើន ជាពហុស្សូត ជាអ្នករក្សាព្រះសាសនាប្រតិស្ឋា

---

១. សារត្ថទីបនី. បុប្ផនាមោតិ មហាបទុមត្ថេរោ ។

២. ឱ.ម. បុប្ផនាមោតិ សុមនត្ថេរោ ។

នទុកក្នុងជម្ពូទ្វីប១ ព្រះចូឡាភ័យជាអ្នកមានប្រាជ្ញា ក្លៀវក្លាក្នុងព្រះវិន័យ១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញាឈ្លាសវៃក្នុងវង្សព្រះសទ្ធម្ម ១ ព្រះចូឡទេវៈ ជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងព្រះវិន័យ ១ ព្រះសិវត្ថេរ ជាអ្នកមាន ប្រាជ្ញាឈ្លាសវៃក្នុងព្រះវិន័យទាំងអស់១, ព្រះនាគត្ថេរទាំងនេះសុទ្ធតែជាអ្នកមានប្រាជ្ញាច្រើន ចេះព្រះវិន័យ ស្ទាត់ក្នុងមគ្គ (គឺ ឆ្លាតក្នុងមកសួគ, និងមកព្រះនិព្វាន) បានប្រកាសព្រះវិន័យបិដក ទុកក្នុងតម្ពបណ្ណិទ្វីប (លង្កាទ្វីប) ។[១]

## រឿងបញ្ជូនព្រះថេរៈទៅប្រទេសផ្សេងៗ

ក្នុងការនាំព្រះសាសនា បន្តមកតាមលំដាប់អាចារ្យនោះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

បានឮថា ព្រះមោគ្គលីបុត្តតិស្សត្ថេរ គ្រាធ្វើតតិយសង្គីតិនេះហើយ បានត្រិះរិះយ៉ាងនេះថា ក្នុងអនាគត ព្រះសាសនា នឹងគប្បីតាំងមាំនៅដោយល្អក្នុងប្រទេសណាហ្ន៎ ? លំដាប់នោះ កាលលោកកំពុងពិចារណា ទើបបានគិតដូច្នេះថា "ព្រះសាសនា នឹងតាំងមាំនៅដោយល្អ ក្នុងបច្ចន្តិ

១. វិន. បរិ. មហាវគ្គ. ១២. ៣/៦ ។

មជនបទទាំងឡាយ” ។ ទើបលោកប្រគល់សាសនកិច្ចនោះ ឱ្យជាភារៈរបស់ភិក្ខុទាំងនោះ ហើយបញ្ជូនភិក្ខុទាំងនោះ ៗ ទៅក្នុងរដ្ឋនោះ ៗ គឺបញ្ជូនព្រះមជ្ឈន្តិកត្ថេរ ទៅកាន់រដ្ឋកស្មីរគន្ធារៈដោយថេរវាចាថា “លោកទៅកាន់រដ្ឋនោះ ហើយចូរប្រតិស្ឋានព្រះសាសនាក្នុងរដ្ឋនោះ” ។ លោកបានប្រាប់ ព្រះមហាទេវត្ថេរយ៉ាងនោះដូចគ្នា ហើយបញ្ជូនទៅកាន់មហិសក្រមណ្ឌល, បញ្ជូនព្រះរក្ខិតត្ថេរទៅកាន់វនវាសីជនបទ បញ្ជូនព្រះយោនកធម្មរក្ខិតត្ថេរទៅកាន់អបរន្តកជនបទ បញ្ជូនព្រះមហាធម្មរក្ខិតត្ថេរទៅកាន់មហារដ្ឋជនបទ បញ្ជូនព្រះមហារក្ខិតត្ថេរ ទៅកាន់លោកជាទីនៅរបស់ជនអ្នកយោនក បញ្ជូនព្រះមជ្ឈិមត្ថេរទៅកាន់ជនបទ ដែលជាចំណែកមួយនៃហិមវន្តប្រទេស បញ្ជូនព្រះ សោណកត្ថេរ១ ព្រះឧត្តរត្ថេរ១ ទៅកាន់សុវណ្ណភូមិជនបទ បញ្ជូនព្រះមហិន្ទត្ថេរ អ្នកជាសទ្ធិវិហារិករបស់ខ្លួន នឹងព្រះឥដ្ឋិយត្ថេរ ព្រះឧត្តិយត្ថេរ ព្រះសម្ពលត្ថេរ ព្រះភទ្ទសាលត្ថេរ ទៅកាន់កោះតម្ពបណ្ណិទ្វីប ដោយបង្គាប់ថា ពួកលោកទៅកាន់ កោះតម្ពបណ្ណិទ្វីបហើយ ចូរប្រតិស្ឋានព្រះសាសនាក្នុងកោះនោះ ។ ព្រះថេរៈទាំងអស់កាលនឹងទៅកាន់ទិសាភាគនោះ ៗ ក៏យល់ថា ក្នុងបច្ចន្តិមជនបទទាំងឡាយ ត្រូវមានគណៈបញ្ចវគ្គ ទើបសមគួរ ធ្វើឧបសម្បទាកម្មបាន ដូច្នេះ ទើបនាំគ្នាទៅមួយពួក ៗ ៥ រូប រួមជាមួយនឹងខ្លួន ។

## ព្រះមជ្ឈន្តិកត្ថេរទៅកស្មីរគន្ធាររដ្ឋ

សម័យនោះឯង ក្នុងដែនកស្មីរគន្ធារៈ ក្នុងរដូវសន្ទូង មានស្ដេចនាគឈ្មោះអារវាឡ បានបណ្ដាលភ្លៀង ឈ្មោះថា ភ្លៀងគ្រាប់ព្រិល ឱ្យធ្លាក់ចុះមក ធ្វើសន្ទូងឱ្យអណ្ដែតទៅកាន់មហាសមុទ្រ ។ ព្រះមជ្ឈន្តិកត្ថេរហោះអំពីនគរបាតលីបុត្តឡើង ទៅតាមអាកាស ហើយទៅចុះខាងលើស្រះអារវាឡនាព្រៃហិមពាន្ត ដើរចង្ក្រមខ្លះ ឈរខ្លះ អង្គុយខ្លះ សម្រេចការសិងខ្លះ លើស្រះអារវាឡ ។ នាងនាគមាណវិកាទាំងឡាយ ឃើញព្រះថេរៈនោះហើយ ទើបប្រាប់ដល់ស្ដេចនាគអារវាឡថា "បពិត្រមហារាជ មានសមណៈត្រងោល មួយរូបទ្រទ្រង់ផ្ទាំងសំពត់ដែលកាត់ដាច់ដោយសស្ត្រា ស្លៀកដណ្ដប់សំពត់ជ្រលក់ទឹកអម្ចត់ ប្រទូសរ៉ាយ ទឹករបស់ពួកយើង" ។

## ស្ដេចនាគអារវាឡបញ្ចេញឫទ្ធិដេញព្រះថេរៈ

ស្ដេចនាគស្ដាប់ពាក្យនោះហើយ ក៏ត្រូវសេចក្ដីក្រោធគ្របសង្កត់បានចេញទៅជួបព្រះថេរៈក្នុងវេលានោះឯង កាលអត់ទ្រាំសេចក្ដីមើលងាយមិនបាន ទើបបាននិមិត្តរូបដែលគួរភ័យខ្លាចជាច្រើន លើអាកាសវេហា ។ (គឺ បណ្ដាលឱ្យ) ខ្យល់ព្យុះដ៏ខ្លាំងក្លា បក់អន្ទាមឱ្យហុយទៅ

ក្នុងទីនោះ ៗ ។ រុក្ខជាតិទាំងឡាយ ក៏បាក់ ដួលរលំចុះ ។ កំពូលភ្នំទាំងឡាយក៏បាក់បែកជាចំរៀលចុះ ផ្ទរទាំងឡាយក៏លាន់ឮជាខ្លាំង, ផ្លេកបន្ទោរទាំងឡាយក៏ឆ្វេតឆ្វាត់ ៗ ។ អសនីបាត( រន្ទះ )ក៏បាញ់ចុះមក, ឧទកវារីក៏ហូរចេញមក ដូចធ្លាយមេឃមកដូច្នោះ ។ កូននាគទាំងឡាយដែលមានរូបដ៏គួរភ័យខ្លាច ក៏ប្រជុំគ្នា ។ ចំណែកស្ដេចនាគនោះឯង ក៏បង្ហុយផ្សែងឱ្យហុយទ្រលោម បញ្ចេញភ្លៀងសស្ត្រា គម្រាមព្រះថេរៈដោយពាក្យគ្រោតគ្រាតជាដើមថា "សមណៈត្រងោល អ្នកឯងនេះស្លៀកដណ្ដប់សំពត់កណ្ដាច់ តើអ្នកឯងជានណា ?", បានបញ្ជាពួកពលនាគទៅថា "ពួកឯងចូរមកចាប់ ចូរសម្លាប់ ចូរបណ្ដេញនូវសមណៈនេះចេញទៅ" ។

## ព្រះថេរៈទូន្មានពួកនាគឱ្យអស់ភាពរឹងត្អឹងហើយ

ព្រះថេរៈទប់ស្កាត់កម្លាំងពលនាគ ដែលគួរភ័យខ្លាចទាំងអស់ដោយកម្លាំងឫទ្ធិរបស់ខ្លួន និយាយចំពោះស្ដេចនាគថា

"ម្នាលស្ដេចនាគ សូម្បីលោក ព្រមទាំងទេវលោក ទីងមក
ញុំាង យើងឱ្យរអើលខ្លាច, ក៏មិនមានអ្នកណា អាចទីងមក
បណ្ដាលនូវភ័យដែលគួរខ្លាច ឱ្យកើតដល់យើងបានឡើយ,

ម្នាលស្ដេចនាគ សូម្បីលោកប្រាថ្នានឹងលើកផែនដីឡើងទាំងអស់ ព្រមទាំងសមុទ្រ ទាំងបព្វត ហើយគ្រវែងទៅខាងលើយើង, លោកក៏មិនអាចនឹងបណ្ដាលភ័យដែលគួរខ្លាចឱ្យកើតដល់យើងបានសោះឡើយ, ម្នាលស្ដេចឧរគាធិបតី លោកប៉ុណ្ណោះ នឹងគប្បីមានការឈឺចាប់ ក្នុងចិត្តយ៉ាងពិតប្រាកដ ។

គ្រាកាលព្រះថេរៈពោលយ៉ាងនោះហើយ ស្ដេចនាគត្រូវព្រះថេរៈកម្ចាត់អានុភាពហើយ ជាអ្នកមានសេចក្ដីព្យាយាមគ្មានផល ក៏មានសេចក្ដីទុក្ខលំបាក អាក់អន់ចិត្ត ។

ព្រះថេរៈពន្យល់ឱ្យស្ដេចនាគនោះ ឱ្យយល់ ឱ្យសមាទាន ឱ្យអាចហាន ឱ្យរីករាយដោយធម្មីកថាដ៏សមគួរដល់ខណៈនោះ ហើយឱ្យតាំងនៅក្នុងត្រៃសរណគមន៍និងបញ្ចសីល ព្រមដោយនាគចំនួនប្រាំបីម៉ឺនបួនពាន់ ។ យក្ខ គន្ធព្វ និងកុម្ភណ្ឌ សូម្បីពួកដទៃជាច្រើន ដែលនៅព្រៃហិមពាន្តបានស្ដាប់ធម្មកថារបស់ព្រះថេរៈហើយ ក៏បានតាំងនៅក្នុងសរណៈនិងសីល ។ សូម្បីបញ្ចកយក្ខ ព្រមដោយនាងហារិតីយក្ខិណី និងបុត្រ ៥០០ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។

## ព្រះថេរៈឱ្យឱវាទពួកយក្ខនិងអារក្សទឹកជាដើម

លំដាប់នោះ ព្រះមជ្ឈន្តិកត្ថេរ ហៅពួកនាគនិងអារក្សទឹក ទាំងអស់មកហើយ ទើបពោលយ៉ាងនេះថា ៖

"ចាប់ផ្ដើមតាំងពីឥឡូវនេះជាដើមទៅ ពួកលោកកុំឱ្យសេចក្ដីក្រោធកើតឡើងដូចក្នុងកាលមុនឡើយ និងកុំបំផ្លាញស្រូវ (ឱ្យវិនាស) ព្រោះថា សត្វទាំងឡាយ ប្រាថ្នាសេចក្ដីសុខ ចូរផ្សាយមេត្តាទៅក្នុងសត្វ ទាំងឡាយថា សូមមនុស្សទាំងឡាយ នៅជាសុខចុះ" ។

ពួកនាគនិងយក្ខជាដើមទាំងអស់នោះ ទទួលឱវាទរបស់ព្រះថេរៈថា "ល្អណាស់ លោកម្ចាស់ដ៏ចម្រើន" បានបដិបត្តិតាមដែលលោកទូន្មានហើយ ។ ក៏ក្នុងថ្ងៃនោះឯង ជាសម័យធ្វើការបូជាស្ដេចនាគ ។ វេលានោះ ស្ដេចនាគ បង្គាប់ឱ្យនាំរតនបល្ល័ង្ករបស់ខ្លួន មកតែងតាំងថ្វាយព្រះថេរៈ ។ ព្រះថេរៈ ក៏អង្គុយលើបល្ល័ង្ក ។ ចំណែកស្ដេចនាគ បានឈរបក់ផ្លិតប្រគេនព្រះថេរៈនៅក្នុងទីជិត ។ ក្នុងខណៈនោះ មនុស្សទាំងឡាយ ដែលនៅក្នុងដែនកស្មីរគន្ធារៈមកឃើញព្រះថេរៈហើយ ក៏និយាយគ្នាថា "ព្រះថេរៈ មានឫទ្ធិច្រើនជាងស្ដេចនាគរបស់ពួកយើង" ហើយបានអង្គុយចុះសំពះព្រះថេរៈនុ៎ះឯង ។ ព្រះថេរៈ ក៏សម្ដែងអាសិវិសូបម

សូត្រ[១] ដល់មនុស្សទាំងនោះ ។ ក្នុងវេលាចប់ព្រះសូត្រ សត្វប្រមាណ ៨ ម៉ឺន បានសម្រេចធម្មាភិសម័យ ។ មនុស្សមួយសែនត្រកូលចេញបួសហើយ, ក៏ឯចាប់ផ្តើមតាំងពីកាលនោះមក ដែនកស្មីរគន្ធារៈ ក៏រុងរឿងទៅដោយសំពត់កាសាវពស្ត្រ អប់ក្លិនពិដោរទៅដោយខ្យល់ពួកឥសីដរាបដល់សព្វថ្ងៃនេះ ។

ក្នុងកាលនោះ ព្រះមជ្ឈន្តិកៈ ជាឥសីទៅកាន់ដែនកស្មីរគន្ធារៈ
ហើយ ឱ្យស្តេចនាគដែលកាចសាហាវ ជ្រះថ្លាហើយ បាន
ដោះលែងសត្វជាច្រើន ឱ្យផុតពីចំណងហើយនោះឯង ។

## ព្រះមហាទេវៈទៅមហិសរកមណ្ឌល

ចំណែកព្រះមហាទេវត្ថេរ ទៅកាន់មហិសរកមណ្ឌលហើយ ក៏សម្តែងទេវទូតសូត្រ[២]ក្នុងវេលាចប់ព្រះសូត្រ សត្វប្រមាណបួនម៉ឺន មានចក្ខុឃើញធម៌ហើយ ។ សត្វប្រមាណបួនម៉ឺនទុំះឯង ចេញបួសហើយ ។

ព្រះមហាទេវត្ថេរ អ្នកមានឫទ្ធិច្រើន ទៅកាន់មហិសរក
រដ្ឋហើយ ឱ្យឱវាទដាស់តឿន ដោយទេវទូតទាំងឡាយ
បានដោះលែងសត្វជាច្រើន ឱ្យផុតពីចំណងហើយឯង ។

១. សំយុ. សឡា. ៣៥. ៣០៧/៣៩៤ ។ ២. មជ្ឈិ. ឧប. ២៧. ១៧២/២០៧ ។

## ព្រះរក្ខិតត្ថេរទៅដែនវនវាសី

ចំណែកព្រះរក្ខិតត្ថេរ ទៅកាន់ដែនវនវាសីជនបទហើយ ឈរលើអាកាសឱ្យជនអ្នកវនវាសីជនបទជ្រះថ្លា ដោយអនមតគ្គបរិយាយកថា[១] ។ ក៏ក្នុងវេលាចប់កថា របស់ព្រះថេរៈនោះ សត្វប្រមាណ ៦ ម៉ឺន បានសម្រេចធម៌ហើយ ។ ប្រជាជនប្រមាណ ៣ ម៉ឺន ៧ ពាន់ បួសហើយ ។ វិហារ ៥០០ ក៏ប្រតិស្ឋានឡើង ហើយ ។ ព្រះថេរៈនោះបានប្រតិស្ឋានព្រះសាសនាឱ្យតាំងមាំនៅក្នុងដែនវនវាសីជនបទនោះហើយដោយប្រការដូច្នេះ ។

ព្រះរក្ខិតត្ថេរ អ្នកមានឫទ្ធិច្រើន ទៅកាន់វនវាសី ជនបទ
ហើយ បានឈរលើអាកាស ហើយសម្ដែងអនមតគ្គិយ
កថា (ដល់មហាជន) ក្នុងវនវាសីជនបទនោះឯង ។

## ព្រះយោនកធម្មរក្ខិតត្ថេរទៅអបរន្តកជនបទ

ចំណែកព្រះយោនកធម្មរក្ខិតត្ថេរ ទៅកាន់អបរន្តកជនបទ ហើយឱ្យពួកជនអ្នកអបរន្តកជនបទជ្រះថ្លា ដោយអគ្គិក្ខន្ធូបមសុត្តន្តកថា[២]ហើយ ក៏ឱ្យសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ ផឹកអមតធម៌ ។ បុរសចេញបព្វជ្ជា

---

១. សំយុ. និទាន. ៣២ ៨៩-៩៦/៧៩-៨៥ ។ ២. អង្គុ. សត្ត. ៤៧. ៦៩/២៣០ ។

អំពីខត្តិយត្រកូលមួយពាន់ នាក់ ។ និងស្ត្រីចេញបព្វជ្ជា ៦ ពាន់គត់ ។ ព្រះថេរៈនោះ បានប្រតិស្ឋានព្រះសាសនាឱ្យតាំងមាំនៅក្នុងអបរន្តកជនបទនោះហើយ ដោយប្រការដូច្នេះ ។

ព្រះយោនកធម្មរក្ខិតត្ថេរ ឈានចូលកាន់អបរន្តកជនបទ
ហើយ ក៏ឱ្យជនជាច្រើនក្នុងអបរន្តកជនបទនោះជ្រះថ្លា
ហើយដោយអគ្គិខន្ធូបមសូត្រ ដូច្នេះឯង ។

## ព្រះមហាធម្មរក្ខិតត្ថេរទៅមហារដ្ឋ

ចំណែកព្រះមហាធម្មរក្ខិតត្ថេរ ទៅកាន់មហារដ្ឋជនបទ ហើយឱ្យពួកជនអ្នកមហារដ្ឋជនបទជ្រះថ្លា ដោយមហានារទកស្សបជាតកកថា[១]ហើយក៏ឱ្យសត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ តាំងនៅ ក្នុងមគ្គនិងផល ។ ប្រជាជនចំនួន ១ ម៉ឺន ៣ ពាន់នាក់បួសហើយ ។ ព្រះថេរៈនោះ បានប្រតិស្ឋានព្រះសាសនាឱ្យតាំងមាំ នៅក្នុងមហារដ្ឋ ជនបទនោះហើយដោយប្រការដូច្នេះ ។

ព្រះមហាធម្មរក្ខិតត្ថេរ ជាឥសីនោះ ទៅកាន់មហារដ្ឋ ជនបទ
ហើយ ក៏សម្តែងជាតកឱ្យមហាជនជ្រះថ្លា ហើយនោះឯង ។

---

១. ខុទ្. ជាត. ៦៣. ១/១ ។

## ព្រះមហាធម្មរក្ខិតត្ថេរទៅរដ្ឋយោនក

ចំណែកព្រះមហាធម្មរក្ខិតត្ថេរ ទៅកាន់រដ្ឋយោនកហើយ ឱ្យអ្នកស្រុកយោនកជ្រះថ្លា ដោយកាឡការាមសុត្តន្តកថា ហើយបានឱ្យគ្រឿងអលង្ការ គឺ មគ្គ និងផលដល់សត្វប្រមាណ ១ សែន ៣ ម៉ឺន ៧ ពាន់ ក៏ប្រជាជនប្រមាណ ១ ម៉ឺន បួសក្នុងសំណាក់ របស់ព្រះថេរៈនោះហើយ ។ សូម្បីព្រះថេរៈនោះ ក៏បានប្រតិស្ឋាន ព្រះសាសនាឱ្យតាំងមាំនៅក្នុងរដ្ឋយោនកនោះហើយ ដោយប្រការដូច្នេះ ។

ក្នុងកាលនោះ ព្រះមហាធម្មរក្ខិតត្ថេរ ជាឥសីនោះ ទៅ
កាន់រដ្ឋយោនកហើយ ក៏ឱ្យជនអ្នកយោនកទាំងនោះជ្រះថ្លា
ដោយកាឡការាមសូត្រ ។

## ព្រះមជ្ឈិមត្ថេរទៅហិមវន្តប្រទេស

ចំណែកព្រះមជ្ឈិមត្ថេរ នឹងព្រះកស្សបគោត្តត្ថេរ ១ ព្រះអឡកទេវត្ថេរ ១ ព្រះទុន្ទុភិស្សរត្ថេរ ១ ព្រះសហស្សទេវត្ថេរ ១ ទៅកាន់ជនបទជាចំណែកហិមវន្តប្រទេសហើយ ឱ្យអ្នកប្រទេសនោះជ្រះថ្លាដោយធម្មចក្កប្បវត្តនសុត្តន្តកថា[១] ហើយ ឱ្យសត្វប្រមាណ ៨០ កោដិ

១. សំយុ. មហា. ៣៩. ៣៦៥/២៣៩ ។

បានរតនៈ គឺ មគ្គនិងផលហើយ ។ ក៏ព្រះថេរៈទាំង ៥ រូបនោះ បាន ញ៉ាំងរដ្ឋទាំង ៥ ឱ្យជ្រះថ្លាហើយ ។ ប្រជាជនដែលបួស ក្នុងសំណាក់របស់ព្រះថេរៈមួយរូប ៗ មានប្រមាណ ១ សែន ។ ព្រះថេរៈទាំង ៥ រូប នោះ បានប្រតិស្ឋាន ព្រះសាសនាឱ្យតាំងមាំនៅក្នុងហិមវន្តប្រទេសនោះហើយ ដោយប្រការដូច្នេះ ។

ព្រះមជ្ឈិមត្ថេរ ទៅកាន់ហិមវន្តប្រទេសហើយប្រកាស
នូវធម្មចក្កប្បវត្តនសូត្រ ឱ្យយក្ខនិងសេនាយក្ខ ជ្រះថ្លា
ហើយ ។

## ព្រះសោណកៈនិងព្រះឧត្តរៈ ទៅសុវណ្ណភូមិ

ចំណែកព្រះសោណកត្ថេរ និងព្រះឧត្តរត្ថេរ បានទៅកាន់ដែនសុវណ្ណភូមិ ។ សម័យនោះ ក្នុងដែនសុវណ្ណភូមិនោះ មានពួកនាងអារក្សទឹក[២] មួយក្រុម ឡើងមកពីសមុទ្រខាំស៊ីទារកទាំងឡាយដែលកើតក្នុងរាជត្រកូល ។ ក្នុងថ្ងៃនោះឯង មានក្មេងម្នាក់ កើតក្នុងរាជត្រកូល ។ មនុស្សទាំងឡាយឃើញព្រះថេរៈហើយ សម្គាល់ថា អ្នកនេះនឹងជា

---

២. រាក្ស៍ស, យក្ខ, ខ្មោចទឹក, បីសាច, ខ្មោចព្រៃ ជា ឈ្មោះរបស់ពួកអសុរយ៉ាងអាក្រក់ មាននិស្ស័យកាច ពេញចិត្តត្រាច់តាមព្រៃបំផ្លាញពិធី និងស៊ី មនុស្ស បឺតឈាមរបស់សត្វជាអាហារ, ស្ថានទីនៅរបស់ពួកនេះ នៅក្នុងសមុទ្របូស្រះធំ ។

សម្លាញ់របស់ពួកអារក្សទឹក ទើបនាំគ្នា កាន់យកអាវុធទៅ បំណងនឹងប្រហារព្រះថេរៈ ។

ព្រះថេរៈ និយាយថា "អ្នកទាំងឡាយ នាំគ្នាកាន់អាវុធមក ធ្វើអ្វី ?"

មនុស្សទាំងនោះ និយាយថា "ពួកអារក្សទឹក តែងចាប់ ស៊ីនូវក្មេងទាំងឡាយដែលកើតហើយក្នុងរាជត្រកូល, ពួកលោក ជាសម្លាញ់របស់អារក្សទឹកទាំងនោះ" ។

ព្រះថេរៈនិយាយថា "ពួកអាត្មា មិនមែនជាសម្លាញ់របស់អារក្សទឹកទេ, ពួកអាត្មាឈ្មោះថា ជាសមណៈ វៀរចាកការធ្វើជីវិតសត្វឱ្យធ្លាក់កន្លងទៅ វៀរចាកការកាន់យកវត្ថុដែលម្ចាស់របស់មិនបានឱ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកពីការនិយាយកុហក វៀរចាកការផឹកទឹកស្រវឹង ជាអ្នកឆាន់តែមួយពេល មានសីល ប្រព្រឹត្តព្រហ្មចរិយមានកល្យាណធម៌" ។

## ព្រះថេរៈបណ្តេញពួកអារក្សទឹកហើយការពារកោះ

ក៏ក្នុងខណៈនោះឯង នាងអារក្សទឹកមួយ ព្រមដោយបរិវារឡើងមកពីសមុទ្រដោយគិតថា "ក្មេងកើតក្នុងរាជត្រកូល, ពួកយើងនឹងចាប់ស៊ីនូវក្មេងនោះ" ។ ពួកមនុស្សឃើញនាងអារក្ស ទឹកនោះហើយ ក៏ខ្លាចស្រែក

សំឡេងខ្លាំងថា "នាងអារក្សទឹកនេះ កំពុងមកលោកម្ចាស់" ព្រះថេរៈនិមិត្តអត្តភាពយ៉ាងច្រើនជាងពួក អារក្សទឹកជាពីរដង បិទលោមព័ទ្ធទាំងពីរខាងដោយអត្តភាពទាំងនោះ យាំងនាងអារក្សទឹកនោះ ព្រមទាំងបរិវារទុកឱ្យនៅកណ្តាល ។ នាងអារក្សទឹកនោះ ព្រមទាំងបរិស័ទ បានគិតដូច្នេះថា "ស្ថានទីនេះនឹងជារបស់ដែលអារក្សទឹកទាំងនេះ បានហើយពិតប្រាកដ, ចំណែកពួកយើងក៏នឹងជាភក្ខារបស់អារក្សទឹកទាំងនេះ" ។ ពួកអារក្ស ទឹកទាំងអស់បានប្រញាប់គេចចេញទៅហើយ ។ ចំណែកព្រះថេរៈបណ្តេញអារក្សទឹកទាំងនោះឱ្យជៀសចេញទៅហើយ ដរាបមើលមិនឃើញទើបបានតាំងរក្សាកោះទុកដោយជុំវិញ ។ មួយទៀត លោកឱ្យពួកមហាជនដែលប្រជុំព្រមគ្នានៅក្នុងសម័យនោះជ្រះថ្លា ដោយព្រហ្មជាលសុត្តន្តកថា[១] ទាំងឱ្យតាំងនៅក្នុងសរណគមន៍ និងសីលហើយ ។ ក៏ក្នុងសន្និបាតនេះ ប្រជាជនប្រមាណ ៦ ម៉ឺន បានសម្រេចធម៌ហើយ ។ ពួកក្មេងក្នុងត្រកូលប្រមាណ ៣.៥០០ នាក់ បួសហើយ ។ កុលធីតាប្រមាណ ១.៥០០ នាក់ ក៏បួសហើយ ។ ព្រះថេរៈនោះ បានប្រតិស្ឋានព្រះសាសនាឱ្យតាំងមាំនៅក្នុងដែនសុវណ្ណភូមិនោះហើយ ដោយប្រការដូច្នេះ ។ ចាប់ផ្តើមតាំងពីនោះមក ជនអ្នកសុវណ្ណភូមិ ក៏បានតាំងឈ្មោះពួកក្មេង ដែល

---

១. ទីឃ. សីល. ព្រហ្មជាលសូត្រ. ១៤. ១/១ ។

កើតក្នុងរាជត្រកូលថា សោណុត្តរៈ (សោណុត្តរ) បន្តមក ។
ព្រះសោណៈនិងព្រះឧត្តរៈ អ្នកមានឫទ្ធិច្រើន ទៅកាន់ដែនសុវណ្ណភូមិ ហើយបណ្តេញបិសាចទាំងឡាយ ឱ្យជៀសចេញទៅ បានសម្តែងព្រហ្មជាលសូត្រហើយ ដូច្នេះឯង ។

## ព្រះមហិន្ទត្ថេរទៅកោះលង្កា

ចំណែកព្រះមហិន្ទត្ថេរ អ្នកដែលព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃអារាធនាថា "សូមលោកទៅប្រតិស្ឋានព្រះសាសនាឯកោះតម្ពបណ្ណិទ្វីបចុះ" ដូច្នេះ ទើបត្រិះរិះថា "ជាកាលដែលយើងគួរ នឹងទៅកាន់កោះតម្ពបណ្ណិទ្វីបឬនៅទេហ្ន៎ ?" គ្រានោះកាលលោក កំពុងពិចារណា ក៏មានសេចក្តីឃើញថា "មិនទាន់ជាកាល ដែលគួរនឹងទៅទេ" ។

សួរថា ក៏ព្រះថេរៈនោះបានមានសេចក្តីឃើញដូច្នេះ ព្រោះឃើញហេតុការណ៍អ្វី ?

ឆ្លើយថា ព្រោះឃើញថា ព្រះបាទមុដសីវៈ ទ្រង់ព្រះជរាភាពច្រើន ។

## ព្រះមហិន្ទត្ថេរត្រាច់សួរសុខទុក្ខញាតិ

លំដាប់នោះ ព្រះថេរៈត្រិះរិះថា "ព្រះរាជាព្រះអង្គនេះ ទ្រង់ព្រះជរាភាពច្រើន យើងមិនអាចកាន់យកព្រះរាជានេះ លើកស្ទួយព្រះសាសនាបានទេ ក៏ឥឡូវនេះ ព្រះរាជឱរសរបស់ព្រះអង្គ ទ្រង់ព្រះនាមថាទេវានម្បិយតិស្ស នឹងសោយរាជ្យ (តទៅ) យើងនឹងអាចកាន់យកព្រះរាជានោះ នឹងលើកស្ទួយព្រះសាសនាបាន ណ្ហើយចុះ យើងនឹងសួរសុខទុក្ខពួកញាតិសិនចុះ ទម្រាំតែដល់វេលានោះ, ឥឡូវនេះ យើងនឹងគប្បីបានត្រឡប់មកកាន់ជនបទនេះទៀតឬទេ" ។ ព្រះថេរៈនោះ គ្រាត្រិះរិះយ៉ាងនោះ ហើយទើបថ្វាយបង្គំព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃចេញទៅអំពីវត្តអសោការាម ត្រាច់ចារិកទៅមកទក្ខិណាគិរីជនបទ ដែលនៅជុំវិញនគររាជគ្រឹះទៅព្រមនឹងព្រះថេរៈ ៤ រូប មានព្រះឥដ្ដិយៈជាដើមនោះសុមនសាមណេរ អ្នកជាឱរសរបស់ព្រះនាងសង្ឃមិត្តា និងភណ្ឌុកឧបាសកសួរសុខទុកពួកញាតិជរាបវេលាកន្លងទៅ ៦ ខែ ។ គ្រានោះ ព្រះថេរៈបានទៅដល់នគរឈ្មោះវេទិសនគរ ដែលជាស្ថានទីប្រថាប់របស់ព្រះមាតាដោយលំដាប់ ។

## ប្រវត្តិសង្ខេបរបស់ព្រះមហិន្ទត្ថេរ

បានឮថា ព្រះបាទអសោកទ្រង់បានជនបទ (មកគ្រប់គ្រង) ក្នុងវេលាទ្រង់ជាព្រះយុវរ័យ កាលស្ដេចយាងទៅក្រុងឧជ្ជេនីឆ្លងកាត់វេទិសនគរ ទ្រង់បានទទួលធីតារបស់វេទិសសេដ្ឋី (ជាអគ្គមហេសី), ក្នុងថ្ងៃនោះឯង ព្រះនាងក៏ទ្រង់គភ៌ហើយ បានប្រសូតិមហិន្ទកុមារនៅក្រុងឧជ្ជេនី ។ ក្នុងវេលាដែលព្រះកុមារ មានព្រះជន្មបាន ១៤ វស្សា ព្រះរាជាទ្រង់បានទទួលការអភិសេកឡើងគ្រងរាជ្យ ។ សម័យនោះ ព្រះនាងដែលជាមាតារបស់មហិន្ទកុមារនោះ ក៏រស់នៅក្នុងដំណាក់របស់ព្រះញាតិវង្ស ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលទុកថា "ព្រះថេរៈបានទៅដល់ក្រុងឈ្មោះវេទិសនគរ ដែលជាស្ថានទីរស់នៅរបស់ព្រះមាតាដោយលំដាប់" ។

ក៏ឯព្រះទេវីជាព្រះមាតា ទតឃើញព្រះថេរៈដែលមកដល់ហើយ ក៏ទ្រង់សំពះព្រះបាទាទាំងពីរដោយសិរសា ហើយថ្វាយភិក្ខាទ្រង់ប្រគល់ថ្វាយវត្តឈ្មោះ វេទិសគិរីមហាវិហារ ដែលខ្លួនសាងថ្វាយព្រះថេរៈ ។ ព្រះថេរៈអង្គុយគិតនៅក្នុងវិហារនោះថា "កិច្ចដែលយើងគួរធ្វើក្នុងទីនេះរួចស្រេចហើយ, ឥឡូវនេះ ជាវេលាដែលគួរនឹងទៅកាន់កោះលង្កាឬនៅទេហ្ន៎" ។ លំដាប់នោះ ព្រះថេរៈត្រិះរិះថា "សូមឱ្យព្រះរាជកុមារព្រះនាមថា ទេវានម្បិយតិស្ស អភិសេកសោយរាជ្យ ដែលព្រះជនករបស់យើង

ទ្រង់បញ្ជូនទៅថ្វាយជាមុនសិនចុះ, សូមឱ្យបានស្ដាប់គុណព្រះរតនត្រ័យ និងស្ដេចចេញចាកព្រះនគរទៅ ស្ដេចឡើងកាន់មិស្សកបព្វត មានមហោស្រពជាទីប្រាថ្នា, វេលានោះ យើងនឹងជួបព្រះអង្គក្នុងទីនោះ ។ ព្រះថេរៈ ក៏សម្រេចការសម្រាកនៅវេទិសគិរីមហាវិហារនោះឯង អស់ខែមួយតទៅទៀត ។ ដោយកន្លងទៅខែមួយ គណៈសង្ឃនិងឧបាសកទាំងអស់ ដែលប្រជុំគ្នានៅក្នុងថ្ងៃឧបោសថ ក្នុងតិថីពេញបូរមីនៃខែ ៨ ដើម (គឺ ថ្ងៃ ពេញបូណ៌មីខែ ៧) បានប្រឹក្សាគ្នាថា "ជាកាលសមគួរដល់ពួក យើងនឹងទៅកាន់កោះតម្ពបណ្ណិទ្វីបឬនៅទេហ្ន៎ ?" ព្រោះហេតុនោះ ទើបព្រះបូរាណាចារ្យទាំងឡាយពោលថា

> ក្នុងកាលនោះ បានមានព្រះសង្ឃត្ថេរ ឈ្មោះមហិន្ទ ដោយនាម១ ព្រះឥដ្ដិយត្ថេរ១ ព្រះឧត្តិយត្ថេរ១ ព្រះភទ្ទសាលត្ថេរ១ ព្រះសម្ពលត្ថេរ១ សុមនសាមណេរ អ្នកបានឆឡភិញ្ញា មានឫទ្ធិច្រើន១ ភណ្ឌុកឧបាសក ដែលបានឃើញសច្ចៈជាគម្រប់ ៧ នៃព្រះថេរៈទាំងនោះ១, លោកមហានាគទាំងនោះឯង សម្រាកក្នុងទីស្ងៀមស្ងាត់ បានប្រឹក្សាគ្នាហើយ ដោយប្រការដូច្នេះឯង ។

## ព្រះឥន្ទ្រពោលរឿងពុទ្ធព្យាករណ៍ថ្វាយព្រះមហិន្ទ

វេលានោះ ស្តេចសក្កៈជាស្តេចនៃពួកទេវតា យាងចូលទៅរកព្រះមហិន្ទត្ថេរ ហើយបានត្រាស់ពាក្យនេះថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះបាទមុដសីវៈ សុគតហើយ, ឥឡូវនេះ ព្រះបាទទេវានម្បិយតិស្សមហារាជសោយរាជ្យហើយ, និងសម្តេចព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ព្យាករណ៍លោកទុកហើយថា 'ក្នុងអនាគតភិក្ខុឈ្មោះមហិន្ទ នឹងញុំាងអ្នកកោះតម្ពបណ្ណិទ្វីបឱ្យជ្រះថ្លា, បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុដូច្នោះឯង ជាកាលសមគួរដល់លោកម្ចាស់ នឹងទៅកាន់កោះដ៏ប្រសើរហើយ សូម្បីខ្ញុំព្រះករុណា ក៏នឹងរួមជាសម្លាញ់របស់លោកម្ចាស់ផង" ។

សួរថា ក៏ព្រោះហេតុអ្វី បានជាស្តេចសក្កៈត្រាស់យ៉ាងនោះ ?

ឆ្លើយថា ព្រោះបានឮថា ព្រះមានព្រះភាគ ទ្រង់ត្រួតមើល លោកដោយពុទ្ធចក្ខុ ត្រង់គល់នៃពោធិព្រឹក្សនុ៎ះឯង បានទតឃើញសម្បត្តិនៃកោះនេះក្នុងអនាគត ទើបបានត្រាស់ប្រាប់សេចក្តីនោះ ដល់ស្តេចសក្កៈនោះ និងទ្រង់ត្រាស់ទុកដែរថា "ក្នុងវេលានោះ សូម្បីបពិត្រក៏គួររួមជាសម្លាញ់ផង" ដូច្នេះ ; ព្រោះហេតុនោះ ទើបបានស្តេចសក្កៈត្រាស់យ៉ាងនោះ ។

## ព្រះមហិន្ទត្ថេរព្រមនឹងគណៈទៅកោះលង្កា

ព្រះថេរៈ ទទួលពាក្យរបស់ស្ដេចសក្កៈនោះហើយ អ្នកទាំង ៧ ហោះឡើងទៅកាន់អាកាសចាកពីវេទិសបព៌ត ហើយតាំងនៅលើមិស្សកបព៌ត ដែលមនុស្សទាំងឡាយសព្វថ្ងៃនេះ ចំណាំបានថា ចេតិយបព៌តខ្លះនៅខាងទិសបូព៌ានៃអនុរាធបុរី, ព្រោះហេតុនោះ ទើបព្រះបូរាណាចារ្យទាំងឡាយបានពោលទុកថា ៖

ព្រះថេរៈទាំងឡាយ សម្រាកត្រង់វេទិសគិរីបព៌ត ជិតក្រុងរាជគ្រឹះ អស់ ៣០ រាត្រី បានត្រិះរិះថា ជាកាលសមគួរ ដើម្បីទៅកាន់កោះដ៏ប្រសើរ, ពួកយើងនឹងនាំគ្នាទៅកាន់កោះដ៏ឧត្ដមដូច្នេះ ហើយបានហោះឡើងចាកពីជម្ពូទ្វីបទៅក្នុងអាកាស ដូចស្ដេចហង្សហើរទៅលើផ្ទៃមេឃ ដូច្នោះ ។ ព្រះថេរៈទាំងឡាយហោះឡើងទៅហើយយ៉ាងនោះ ក៏ចុះលើកំពូលភ្នំហើយឈរលើភ្នំ ដែលលំអទៅដោយពពក ដែលតាំងនៅខាងមុខនៃបុរីដ៏ប្រសើរ ហាក់ដូចជាពួកហង្ស ទំនៅលើភ្នំដូច្នោះ ។

ក៏ព្រះមហិន្ទត្ថេរ អ្នកមករួមនឹងព្រះថេរៈទាំងឡាយ មានព្រះឥដ្ឋិយៈជាដើម ឈរយ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា បានឈរហើយក្នុងកោះនេះ ក្នុងឆ្នាំទី ២៣៦ វស្សា រាប់តាំងពីឆ្នាំដែលសម្ដេចព្រះសម្មាសម្ពុទ្ធបរិនិព្វានមក ។

## លំដាប់រាជវង្សក្នុងកោះលង្កានិងជម្ពូទ្វីប

សេចក្តីពិស្តារថា សម្តេចព្រះសម្មាសម្ពុទ្ធ ស្តេចបរិនិព្វាន ហើយ ក្នុងឆ្នាំទី ៨ នៃ(រជ្ជកាល) ព្រះបាទអជាតសត្តុរាជ (សោយរាជ្យ) ។ ក្នុងឆ្នាំនោះឯង ព្រះរាជឱរសរបស់ព្រះបាទ សីហកុមារ អ្នកទ្រង់ជាស្តេចផែនដីដើមវង្សនៃកោះតម្ពបណ្ណិទ្វីប ទ្រង់ព្រះនាមថា វិជ័យកុមារ ស្តេចមកកាន់កោះនេះហើយ ទ្រង់បានធ្វើកោះនេះ ឱ្យជាទីនៅរបស់មនុស្ស ។ ព្រះបាទវិជ័យកុមារ (សោយរាជ្យនៅក្នុងកោះនេះ ៣៨ ឆ្នាំ)[១] ហើយ សុគតលើកោះនេះ ក្នុងឆ្នាំទី ១៤ នៃ(រជ្ជកាល) ព្រះបាទឧទ្ទេយ្យភទ្ទក្នុងជម្ពូទ្វីប ។ ព្រះរាជាទ្រង់ព្រះនាមថា បណ្ឌុវាសុទេព ឡើងគ្រងរាជ្យក្នុងកោះនេះ ក្នុងឆ្នាំទី១៥ នៃ(រជ្ជកាល)ព្រះបាទឧទ្ទេយ្យភទ្ទ (ដែលសោយរាជ្យនៅក្នុងជម្ពូទ្វីប) ។ ព្រះបាទបណ្ឌុវាសុទេព បានសុគតនៅកោះនេះ ក្នុងឆ្នាំទី២១ នៃ(រជ្ជកាល) ព្រះបាទនាគទស្សកៈ (ដែលសោយរាជ្យ) ក្នុងជម្ពូទ្វីបនោះ ។ ព្រះរាជកុមារ ទ្រង់ព្រះនាមថា អភ័យ ឡើងគ្រងរាជ្យក្នុងកោះនេះ ក្នុងឆ្នាំនោះឯង ។ ព្រះបាទអភ័យ (សោយរាជ្យនៅ) ក្នុងកោះនេះគ្រប់ ២០ ឆ្នាំ បរិបូណ៌, ក្នុងឆ្នាំទី១៧ នៃ(រជ្ជកាល) ព្រះបាទសុសូនាគៈ (ដែលសោយរាជ្យនៅ) ក្នុងជម្ពូទ្វីបនោះ គ្រានោះ

---

១. សារត្ថទីបនី ។

ទាមរិកៈ ព្រះនាមថា បណ្ឌុកាភ័យ បានដណ្តើមយករាជសម្បត្តិ ក្នុងឆ្នាំទី ២០ នៃ(រជ្ជកាល)ព្រះបាទអភ័យ (អ្នកគ្រងរាជ្យនៅក្នុងគ្រានោះ) ។ ព្រះបាទបណ្ឌុកាភ័យ (គ្រងរាជ្យនៅ) ក្នុងកោះនេះ គ្រប់ ១៧ ឆ្នាំបរិបូណ៌, ក្នុងឆ្នាំទី ១៦ នៃ(រជ្ជកាល)ព្រះបាទកាឡាសោក (ដែលសោយរាជ្យនៅ) ក្នុងជម្ពូទ្វីបនោះ ។ ១៧ ឆ្នាំទាំងនោះ រួមគ្នា ១ ឆ្នាំទៀត បន្ទាប់មក ទើបជា ១៨ ឆ្នាំ ព្រះបាទបណ្ឌុកាភ័យ បានសុគតក្នុងកោះនេះ ក្នុងឆ្នាំទី ១៤ នៃ (រជ្ជកាល) ។ ព្រះបាទចន្ទ្រគុត (ដែលនៅសោយរាជ្យ) ក្នុងជម្ពូទ្វីបនោះ ។

(តពីនោះ) ព្រះបាទមុដ្ឋសីវៈក៏ឡើងគ្រងរាជ្យ (ក្នុងកោះនេះ) ព្រះបាទមុដ្ឋសីវៈ បានសុគតក្នុងកោះនេះ ក្នុងឆ្នាំទី ១៧ នៃ(រជ្ជកាល) ព្រះបាទអសោកធម្មរាជ (ដែលសោយរាជ្យនៅ) ក្នុងជម្ពូទ្វីបនោះ ។ (តពីនោះ) ព្រះបាទទេវានម្បិយតិស្សក៏ឡើងគ្រងរាជ្យ(ក្នុងកោះនេះ) ។

មួយទៀត កាលសម្តេចព្រះសម្មាសម្ពុទ្ធ ស្តេចបរិនិព្វានហើយ ព្រះបាទអជាតសត្តុសោយរាជ្យបាន ២៤ ឆ្នាំ ។ ចំណែកព្រះបាទឧទ្ទយភទ្ទ សោយរាជ្យបាន ១៦ ឆ្នាំ ។ (តពីនោះ) ព្រះបាទអនុរុទ្ធៈនិងព្រះបាទមុណ្ឌៈ សោយរាជ្យបាន ៨ ឆ្នាំ ។ ព្រះបាទនាគទស្សកៈ សោយរាជ្យបាន ២៤ ឆ្នាំ ។ ព្រះបាទសុសុនាគៈ សោយរាជ្យបាន ១៨ ឆ្នាំ ។ ព្រះបាទកាឡាសោក ព្រះរាជឱរសរបស់ព្រះបាទសុសុនាគៈនោះឯង

សោយរាជ្យបាន ២៨ ឆ្នាំ ។ ព្រះរាជាជាបងប្អូនគ្នា ១០ ព្រះអង្គ[១] ដែលជាព្រះរាជឱរសរបស់ព្រះបាទកាឡាសោកសោយរាជ្យបាន ២២ឆ្នាំ ។ ខាងក្រោយពីកាលនៃព្រះរាជាអ្នកជាព្រះបាទបងប្អូនគ្នា ១០អង្គនោះ មានព្រះរាជា ៩ព្រះអង្គ[២] ទ្រង់មានព្រះនាមថា នន្ទៈ (តខ្សែព្រះនាមគ្រប់ ៗ ទាំង៩ព្រះអង្គ) សោយរាជ្យបាន ២២ ឆ្នាំ ប៉ុណ្ណោះ ព្រះបាទចន្ទ្រគុត សោយរាជ្យបាន ២៤ឆ្នាំ ។ ព្រះបាទវិន្ទុសារសោយរាជ្យបាន ២៨ឆ្នាំ ។

ក្នុងទីបំផុតនៃ(រជ្ជកាល)ព្រះបាទវិន្ទុសារនោះ ព្រះបាទអសោកក៏ឡើងគ្រងរាជ្យ ។ ក្នុងកាលមុនអំពីទ្រង់អភិសេក ព្រះបាទអសោកនោះគ្រងរាជ្យបាន ៤ឆ្នាំ ។ ក្នុងឆ្នាំទី១៨ អំពីវេលាដែលព្រះបាទអសោកទ្រង់អភិសេកហើយ ព្រះមហិន្ទត្ថេរក៏មកឈរត្រង់កោះនេះ ។ ពាក្យនេះថា ព្រះមហិន្ទត្ថេរមកឈរ ត្រង់កោះនេះ ក្នុងឆ្នាំទី២៣៦ វស្សា រាប់តាំងពីឆ្នាំដែលសម្តេចព្រះសម្មាសម្ពុទ្ធបរិនិព្វានមក ដូច្នេះ បណ្ឌិតគប្បីជ្រាបតាមខ្សែរាជវង្ស(របស់ព្រះរាជាក្នុងជម្ពូទ្វីប)នោះ ដូចពណ៌នាមក ដូច្នេះ ។

---

(១) ព្រះរាជាអ្នកជាព្រះបាទបងប្អូនគ្នា ១០ អង្គ នោះគឺ ភទ្ទសេន១ កោរណ្ឌវណ្ណៈ១ មង្គុរៈ១ សព្វញ្ជនៈ១ ជាលិកៈ១ ឧភកៈ១ សញ្ជយ១ កោរព្វៈ១ នន្ទិវឌ្ឍនៈ១ និងបញ្ចមកៈ១ ។ (២) ព្រះរាជា ៩ ព្រះអង្គដែលមានខ្សែព្រះនាមថា នន្ទៈ នោះគឺ ឧគ្គសេននន្ទៈ១ បណ្ឌុកនន្ទៈ១ បណ្ឌុគតិនន្ទៈ១ ភូសបាលនន្ទៈ១ គោវិសាណកនន្ទៈ១ ទសសិទ្ធិកនន្ទៈ១ កេវដ្តកនន្ទៈ១ និងធននន្ទៈ១ (សារត្ថទីបនី) ។

# ព្រះបាទទេវានម្បិយតិស្សទ្រង់ជួបព្រះមហិន្ទត្ថេរ

ក៏ក្នុងថ្ងៃនោះ នៅកោះតម្ពបណ្ណិទ្វីប មានបុណ្យនក្ខត្តឫក្ស ក្នុងជេដ្ឋមាសដើម (គឺខែ៧) ព្រះរាជាទ្រង់ត្រាស់ឱ្យឃោសនានក្ខត្តឫក្ស ហើយទ្រង់បង្គាប់ពួកអាមាត្យថា "ពួកលោក ចូរលេងមហោស្រពចុះ" ដូច្នេះ មានរាជបុរសចំនួនដល់បួនម៉ឺនជាបរិវារ ស្ដេចចេញចាកព្រះនគរទៅ មានព្រះបំណងនឹងបាញ់ម្រឹគ ទើបស្ដេចយាងតាមមកជាទីទៅមិស្សកបព៌ត ។ វេលានោះ មានទេវតាមួយរូប ដែលស្ថិតនៅលើបព៌តនោះ គិតថា "យើងនឹងសម្ដែងព្រះថេរៈទាំងឡាយ ដល់ព្រះរាជា" ទើបប្លែងជារមាំងធ្វើជាដើរស៊ីស្មៅនិងស្លឹកឈើនៅក្នុងទីមិនឆ្ងាយ (ពីព្រះថេរៈនោះ) ។

ព្រះរាជាទ្រង់ទតឃើញរមាំងនោះហើយ ទើបទ្រង់ត្រិះរិះថា "ឥឡូវនេះ នៅមិនទាន់សមគួរនឹងបាញ់ម្រឹគ ដែលនៅប្រហែស" ទើបទ្រង់យឹតធ្នូ ។ ម្រឹគចាប់ផ្ដើមនឹងរកមកជៀសចេញ ទៅតាមមកដែលបានកំណត់ទុកដោយដើមស្វាយ ។ ព្រះរាជាស្ដេចដេញតាមពីក្រោយ ហើយស្ដេចឡើងមកកាន់ទីដែលកំណត់ដោយដើមស្វាយនុ៎ះឯង ។ ចំណែកម្រឹគ ក៏បាត់ខ្លួនទៅក្នុងទីមិនឆ្ងាយពីព្រះថេរៈទាំងឡាយ ។ ព្រះមហិន្ទត្ថេរ ឃើញព្រះរាជាកំពុងស្ដេចមក ក្នុងទីមិនឆ្ងាយ ទើបអធិដ្ឋានចិត្តថា "សូមឱ្យព្រះរាជាទតឃើញតែយើងប៉ុណ្ណោះ កុំទាន់ឃើញពួកជនក្រៅនេះឡើយ

ទើបហៅព្រះរាជាថា "តិស្សៈ តិស្សៈ សូមស្តេចមកមកនេះ" ។ ព្រះរាជា ទ្រង់ស្តាប់ហើយ ក៏ត្រិះរិះថា "ដែលឈ្មោះថា ជនដែលកើតក្នុងកោះនេះ អាចនឹងហៅយើងចំឈ្មោះថា តិស្សៈ មិនមាន ក៏សមណៈត្រងោលរូបនេះទ្រទ្រង់ផ្ទាំងសំពត់ដែលកាត់ដាច់ (ដោយសស្ត្រា) ស្លៀកដណ្តប់សំពត់កាសាវៈ អាចហៅយើងចំឈ្មោះ តើអ្នកនេះ គឺជានណាហ្ន៎ នឹងជាមនុស្ស ឬអមនុស្ស ?" ទើបព្រះថេរៈថ្វាយព្រះពរថា "សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពទាំងឡាយ ឈ្មោះថា សមណៈជាសាវករបស់ព្រះធម្មរាជា ចេញពីជម្ពូទ្វីបមកកាន់កោះនេះ ក៏ដើម្បីអនុគ្រោះមហាបពិត្រប៉ុណ្ណោះ" ។

## ឫស្សី ៣ ដើមកើតដល់ព្រះបាទទេវានម្បិយតិស្ស

សម័យនោះឯង ព្រះបាទទេវានម្បិយតិស្សមហារាជ និង ព្រះបាទអសោកធម្មរាជា ទ្រង់ជាព្រះអទិដ្ឋសម្លាញ់គ្នា (គឺសម្លាញ់ដែលនៅមិនធ្លាប់ប្រទះឃើញគ្នា) ។ ក៏ដោយព្រះបុញ្ញានុភាពរបស់ព្រះបាទទេវានម្បិយតិស្សមហារាជ មានឫស្សី ៣ ដើម មានប្រមាណប៉ុនដងចន្ទោលរថ កើតឡើងត្រង់គុម្ពឫស្សីមួយកន្លែង ត្រង់ជើងភ្នំឆាតកៈ មួយដើមឈ្មោះលតាយដ្ឋិ មួយដើមឈ្មោះ បុប្ផយដ្ឋិ មួយដើមឈ្មោះសកុណយដ្ឋិ ។

បណ្ដាឫស្សី ៣ នោះ ដើមដែលឈ្មោះថា លតាយដ្ឋិ (គឺ ដើមឫស្សីវល្លិ) មានពណ៌ដូចប្រាក់ វល្លិដែលកើតរុំព័ទ្ធដើមឫស្សីនោះ ក៏មានពណ៌ប្រាកដដូចមាស ។ ចំណែកក្នុងដើមដែលឈ្មោះថា បុប្ផយដ្ឋិ (គឺ ដើមឫស្សីមានផ្កា) ក៏មានផ្កាពណ៌ខៀវ លឿង ក្រហម ស និង ខ្មៅប្រាកដ មានទង ស្លឹក និង កេសរដែលចែកទុកល្អ ។ ចំណែកដើមដែលឈ្មោះថា សកុណយដ្ឋិ (គឺ ដើមឫស្សីសកុណជាតិ) ក៏មានពួកសកុណាច្រើនចំពូក មានហង្ស មាន់ និងសត្វត្រដក់ (សត្វតាដក់) ជាដើម និងមានសត្វជើង ៤ មានប្រភេទផ្សេង ៗ (ឫស្សីនោះ) ប្រាកដដូចជាមានជីវិត រស់នៅ (ជាមួយនឹងសត្វទាំងនោះដែរ) ។ សមពិតដូចដែលអាចារ្យអ្នកសីហឡ ពោលទុកក្នុងគម្ពីរទីបវង្សថា

ឫស្សី ៣ ដើម បានកើតហើយត្រង់ជើងភ្នំឈ្មោះឆាតកៈ ដើមដែលជាវល្លិ មានពណ៌ស និងល្អ ដូចពណ៌មាស ប្រាកដនៅចំត្រង់ដើម[១] ពណ៌ប្រាក់, ផ្កាពណ៌ខៀវជាដើមមាននៅយ៉ាងណា, ផ្កាដូច្នោះ ក៏ប្រាកដនៅក្នុងដើមដែលមានផ្កា, សកុណជាតិច្រើនចំពូកក៏នាំគ្នាទំ នៅលើដើមសកុណជាតិ ដោយរូបរបស់ខ្លួនទុំៈឯង ។

១. ន័យអត្ថយោជនា. រជតយដ្ឋី ជាបឋមាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។

## រតនៈ ៨ ប្រភេទ កើតដល់ព្រះបាទទេវានម្បិយតិស្ស

រតនៈ (គឺ កែវ) មានច្រើនប្រភេទ មានកែវមុក្តា កែវមណី និងកែវពិទូរ្យជាដើម កើតឡើងស្ងប្បីអំពីសមុទ្រ ដល់ព្រះបាទទេវានម្បិយតិស្សព្រះអង្គនោះ ។ ចំណែកក្នុងកោះតម្ពបណ្ណិទ្វីប មានកែវមុក្តាកើតឡើង ៨ ប្រភេទ គឺ កែវមុក្តា មានសណ្ឋានដូចរូបសេះ ១ កែវមុក្តាមានសណ្ឋានដូចរូបដំរី ១ កែវមុក្តាមានសណ្ឋានដូចរូបរថ ១ កែវមុក្តាមានសណ្ឋានដូចផ្លែកន្ទួតព្រៃ ១ កែវមុក្តាមានសណ្ឋានដូចកងដៃ ១ កែវមុក្តាមានសណ្ឋានដូចវង់ចិញ្ចៀន ១ កែវមុក្តាមានសណ្ឋានដូចផ្លែថ្ងាន់ ១ កែវមុក្តាប្រក្រតី ១ ។ ព្រះរាជាបានបញ្ជូនដើមឫស្សី កែវមុក្តានោះ ៗ នឹងរតនៈដទៃជាច្រើនយ៉ាងទៅថ្វាយ ដើម្បីជាគ្រឿងបណ្ណាការចំពោះព្រះបាទអសោកធម្មរាជ ។

## ព្រះបាទអសោកបញ្ជូនបញ្ចរាជកកុធភ័ណ្ឌ ទៅថ្វាយ

ព្រះបាទអសោកទ្រង់ជ្រះថ្លា ហើយទ្រង់បញ្ជូនគ្រឿងរាជក កុធភ័ណ្ឌ ៥ យ៉ាង ទៅថ្វាយចំពោះព្រះរាជា គឺ ស្វេតឆត្រ១ ផ្លិតចាមរី (វាលវីជនី)១ ព្រះខាន់១ រតនៈប្រដាប់ព្រះមោលី (គឺ ព្រះឧណ្ហិស្ស ជាប់ព្រះមហាពិជ័យមកុដ)១ ស្បែកព្រះបាទ១ និងគ្រឿងបណ្ណាការយ៉ាងដទៃច្រើនប្រភេទ ដើម្បីប្រយោជន៍ដល់ការអភិសេក ។ គឺ យ៉ាងណា ។ គឺ

សង្ខ១ គង្គោទកភារី (ទឹកទន្លេគង្គា ឬទឹកដែលកើតពីស្រះអនោតត្ត)១ វឌ្ឍនមានៈ (លំអិតសម្រាប់ស្រង់ទឹក)១ វដំសកៈ (ព្រះមាលាសម្រាប់ប្រដាប់ព្រះកណ្ណ គ្រឿងប្រដាប់ត្រចៀក)១ ភិង្គារ (ព្រះកុណ្ឌីមាស)១ នន្ទិយាវដ្តៈ (ភាជន៍មាសធ្វើទុកដើម្បីការមង្គល មានសណ្ឋានដូចរូបកាកបាទ)១ សិវិកៈ (វល្លិ៍គ្រែស្នែង)១ កញ្ញា (ខត្តិយកុមារី)១ អធោវិមទុស្សយុគៈ (គូព្រះភូសាដែលមិនត្រូវបោកគក់)១ ហត្ថបុញ្ឆនៈ (សំពត់សម្រាប់ជូតព្រះហស្ត)១ ហរិចន្ទនៈ (ខ្លឹមចន្ទក្រហម)១ អរុណវណ្ណមត្តិកៈ (ដីពណ៌អរុណ)១ អញ្ជនៈ[1] (ថ្នាំបន្តក់ព្រះនេត្រ)១ ហរីតកៈ (ព្រះឱសថសម៉)១ អាមលកៈ (ព្រះឱសថកន្ទួតព្រៃ)១ ដូច្នេះឯង ។

សូម្បីពាក្យនេះ ក៏សមដូចពាក្យដែលអាចារ្យអ្នកសីហឡ ពោលទុកក្នុងគម្ពីរទីបវង្សថា

ព្រះរាជាទ្រង់ព្រះនាមថា អសោកទ្រង់បញ្ជូនគ្រឿងបណ្ណាការ
ដែលកើតឡើង ព្រោះបុញ្ញកម្ម (របស់ព្រះអង្គ) ទៅ
(ថ្វាយចំពោះព្រះបាទទេវានម្បិយតិស្ស) គឺ ផ្លិតវាលវីជនី១

១. អញ្ជនៈ ប្រែថា ត្រកៀតក៏បាន, ផ្កាអញ្ជ័នក៏បាន ផ្កាអង្កាបក៏បាន ឬថ្នាំបន្តក់ភ្នែកក៏បាន ក្នុងទីនេះបានប្រែថា ថ្នាំបន្តក់ភ្នែក ។

ព្រះឧណ្ហិសរ្ស (ព្រះមហាពិជយមង្កុដ)១ ស្វេតឆត្រ១ ព្រះខាន់១ ស្បែកព្រះបាទ១ វេឋនៈសំពត់ជូត ព្រះសិរសា១ សារបាមង្គៈ ខ្សែសង្វារ១ ភិង្ការ ព្រះកុណ្ឌីមាស១ នន្ទិវដ្តកៈ ភាជន៍មាស១ សិវិកៈ (វយ្ហ៍ឬគ្រែស្នែង)១ សង្ខៈ (ស័ង្ខសម្រាប់ប្រួចទឹកក្នុងវេលាអភិសេក)១ វដង្សកៈ (ព្រះមាលា ត្រងសម្រាប់ប្រដាប់ព្រះកណ្ណ ឬក្រវិលសម្រាប់ប្រដាប់ត្រចៀក)១ អជោវិមវត្តកោដិកៈ ព្រះភូសាមួយគូមិនត្រូវបោកគក់១ សោវណ្ណបាតី ថាសមាស១ កដច្ឆុ វែក១ មហគ្ឃហត្ថបុញ្ឆនៈ សំពត់សម្រាប់ជូតព្រះហស្តដែលមានតម្លៃច្រើន១ អនោតត្តោទកកាជៈ អម្រែកទឹកស្រះអនោតត្ត១ ឧត្តមហរិចន្ទនៈ ខ្លឹមចន្ទក្រហមដ៏ល្អលើស១ អរុណវណ្ណ មត្តិកៈ ដីពណ៌អរុណ១ អញ្ជនៈ ថ្នាំបន្តក់ព្រះនេត្រដែលនាគនាំមកថ្វាយ១ ហរីតកៈ ព្រះឱសថសម៉១ អាមលកៈ ព្រះឱសថកន្ទួតព្រៃ១ មហគ្ឃអមតោសថៈ ព្រះឱសថព្យាបាលរោគដែលមានតម្លៃច្រើន១ ស្រូវសាលីមានក្លិនក្រអូប ៦,០០០ រទេះ ដែលសត្វសេកនាំមកថ្វាយ ១ ។

[៨]ក៏ព្រះបាទអសោក ទ្រង់បញ្ជូនគ្រឿងបណ្ណាការ ដែលជាអាមិស

នោះទៅថ្វាយតែម្យ៉ាង ក៏ទេ, បានពួថា ទ្រង់បានបញ្ជូន សូម្បីធម្ម បណ្ណាការនេះទៅថ្វាយទៀត ដូច្នេះគឺ "ទូលបង្គំ បានដល់ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ថា ជាសរណៈទីពឹងហើយ បានសម្តែងខ្លួនជាឧបាសក ក្នុងព្រះសាសនានៃសក្យបុត្រ, បពិត្រព្រះអង្គដ៏ខ្ពស់បំផុតជាងនរជន សូម្បីព្រះអង្គ ក៏ចូរញ៉ាំងចិត្តឱ្យជ្រះថ្លា ក្នុងវត្ថុដ៏ឧត្តមទាំង ៣ នេះចុះ សូមឱ្យទ្រង់ដល់រតនៈទាំង ៣ នោះថា ជាសរណៈទីពឹងដោយព្រះសទ្ធាចុះ" ។

ក្នុងថ្ងៃនោះ ព្រះរាជាព្រះអង្គនោះ ទ្រង់ទទួលមុទ្ធាភិសេក ១ ខែ ដោយគ្រឿងឧបករណ៍ការអភិសេក ដែលព្រះបាទអសោក ទ្រង់បញ្ជូនទៅថ្វាយ ។ ពិតមែន ពួកអាមាត្យបានធ្វើការអភិសេក ថ្វាយចំពោះព្រះរាជា ក្នុងតិថីថ្ងៃពេញបូណ៌មីនៃខែវិសាខៈ (គឺ ថ្ងៃពេញបូណ៌មីខែ ៦) ។

ព្រះរាជាព្រះអង្គនោះ កាលទ្រង់អនុស្សរណៈដល់សាសន ប្រវត្តិនោះ ដែលព្រះអង្គទ្រង់បានស្តាប់មកមិនយូរ គ្រាទ្រង់បាន ស្តាប់ពាក្យនោះ របស់ព្រះថេរៈថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពទាំងឡាយ ឈ្មោះថា សមណៈ ជាសាវករបស់ព្រះធម្មរាជា ដូច្នេះ ជាដើម ហើយទ្រង់ត្រិះរិះថា "លោកម្ចាស់ទាំងឡាយ មកហើយហ្ន៎ ទើបទ្រង់ចោលអាវុធក្នុងវេលានោះឯង ហើយប្រថាប់អង្គុយសន្ទនាសម្មោទនីយក

ថា នៅក្នុងចំណែកម្ខាង ៗ ដូចដែលព្រះបូរាណាចារ្យ ពោលទុកថា ៖

ព្រះរាជាទ្រង់ចោលអាវុធហើយ ស្ដេចគង់ប្រថាប់ក្នុងចំណែកម្ខាង លុះគង់ប្រថាប់ហើយ បានត្រាស់ព្រះតម្រាស់ប្រកបដោយប្រយោជន៍ ជាច្រើន ដែលគួររីករាយ ។

ក៏កាលព្រះរាជាព្រះអង្គនោះ ទ្រង់នៅសន្ទនាសម្មោទនីយកថានុ៎ះឯង រាជបរិវារចំនួនបួនម៉ឺនទាំងនោះ ក៏នាំគ្នាមកហែហម ព្រះអង្គហើយ ។

## ព្រះថេរៈសម្ដែងឱ្យព្រះរាជាទតឃើញជន ៦ រូបទៀត

គ្រានោះ ព្រះថេរៈក៏សម្ដែងជន ៦ នាក់ក្រៅនេះ ។ ព្រះរាជាទតឃើញហើយទើបទ្រង់ត្រាស់សួរថា "តើអ្នកទាំងនេះ មកតាំងពីកាលណា ?"

ព្រះថេរៈ. "មកជាមួយនឹងអាត្មាភាពនុ៎ះឯង មហាបពិត្រ"

ព្រះរាជា. "ក៏ឥឡូវនេះ សមណៈសូម្បីពួកដទៃ ដែលមានសភាពបែបនេះ មាននៅក្នុងជម្ពូទ្វីបខ្លះឬ ?"

ព្រះថេរៈ. "មាននៅក្នុងជម្ពូទ្វីបខ្លះដែរ មហាបពិត្រ ឥឡូវនេះជម្ពូទ្វីបរុងរឿងទៅដោយសំពត់កាសាវពស្ត្រ បក់ផ្សាយទៅ ដោយខ្យល់ឥសី, ក្នុងជម្ពូទ្វីបនោះ មានព្រះអរហន្ត ពុទ្ធសាវកជាច្រើនដែលជាអ្នកមានវិជ្ជា ៣ និងបានសម្រេចឫទ្ធិ ស្ទាត់ជំនាញ មកចេតោបរិយញ្ញាណអស់អាសវៈហើយ" ។

ព្រះរាជា. “បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនាំគ្នាមកដោយមកណា ?”

ព្រះថេរៈ. “មហាបពិត្រ អាត្មាភាពទាំងឡាយ មិនបានមកមកទឹកនិងមកគោកឡើយ” ។

ព្រះរាជា. ក៏ទ្រង់យល់ក្នុងព្រះទ័យបានល្អថា “លោកម្ចាស់ ទាំងនេះមកតាមអាកាស” ។

## ព្រះថេរៈសួរបញ្ហាដើម្បីដឹងព្រះបញ្ញារបស់ព្រះរាជា

ព្រះថេរៈ. ដើម្បីនឹងសាកល្បងមើលថា “តើព្រះរាជាទ្រង់មានសេចក្ដីវាងវៃដោយព្រះប្រាជ្ញាឬហ្ន៎ ?” ទើបទូលសួរបញ្ហាប្រារព្ធដើមស្វាយ ដែលនៅជិតថា “មហាបពិត្រ ដើមឈើនេះ ឈ្មោះអ្វី ?”

ព្រះរាជា. “ឈ្មោះដើមស្វាយ លោកម្ចាស់ដ៏ចម្រើន”

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ ក៏ក្រៅពីដើមស្វាយនេះហើយដើមស្វាយដទៃទៀត មានឬទេ ?”

ព្រះរាជា. “មានទៀត លោកម្ចាស់ដ៏ចម្រើន ដើមស្វាយ សូម្បីពួកដទៃមានច្រើនសន្ធឹកសន្ធាប់” ។

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ វៀរលែងស្វាយដើមនេះនិងស្វាយពួកដទៃចេញហើយ ដើមឈើប្រភេទដទៃទៀត មានឬហ្ន៎ ?”

ព្រះរាជា. “មានទៀត លោកម្ចាស់ដ៏ចម្រើន តែដើមឈើទាំងនោះមិនមែនដើមស្វាយ” ។

ព្រះថេរៈ. “វៀរលែងដើមស្វាយ ( ឯទៀត ) និងមិនមែនដើមស្វាយពួកដទៃចេញ ក៏ដើមឈើប្រភេទដទៃ មានឬទេ ?”

ព្រះរាជា. “មាន គឺ ស្វាយដើមនេះឯង លោកម្ចាស់ដ៏ចម្រើន”

ព្រះថេរៈ. “ល្អណាស់ មហាបពិត្រ ព្រះអង្គទ្រង់ជាបណ្ឌិត, ក៏ព្រះញាតិវង្សរបស់ព្រះអង្គ មានដែរឬ ? មហាបពិត្រ”

ព្រះរាជា. “ជនអ្នកជាញាតិរបស់ខ្ញុំព្រះករុណា មានច្រើនសន្ធឹកសន្ធាប់ លោកម្ចាស់ដ៏ចម្រើន”

ព្រះថេរៈ. “វៀរលែងជនជាព្រះញាតិវង្សរបស់ព្រះអង្គទាំងនេះចេញហើយ ជនពួកខ្លះពួកដទៃ សូម្បីអ្នកដែលមិនមែនព្រះញាតិវង្ស មានឬទេ ? មហាបពិត្រ”

ព្រះរាជា. “លោកម្ចាស់ដ៏ចម្រើន ជនដែលមិនមែនញាតិ មានច្រើនជាងជនដែលជាញាតិ”

ព្រះថេរៈ. “សូមថ្វាយព្រះពរ; វៀរជនជាព្រះញាតិវង្សរបស់ព្រះអង្គ និងជនមិនមែនព្រះញាតិវង្សចេញហើយ អ្នកណា ៗដទៃ មានឬ ?”

ព្រះរាជា. “លោកម្ចាស់ដ៏ចម្រើន មាន គឺ ខ្ញុំព្រះករុណានេះឯង”

ព្រះថេរៈ. “ល្អណាស់ មហាបពិត្រ ដែលឈ្មោះថា ខ្លួន មិនចាត់ថា ជាញាតិរបស់ខ្លួន និងមិនចាត់ថា មិនមែនជាញាតិ” ។

## ព្រះរាជានិងរាជបរិវារតាំងនៅក្នុងត្រៃសរណគមន៍

លំដាប់នោះ ព្រះថេរៈគិតថា ព្រះរាជាជាបណ្ឌិត នឹងទ្រង់អាចដឹងធម៌បាន ដូច្នេះហើយ ទើបសម្ដែងចូឡហត្ថិបទោបមសូត្រ[១] ។ ក្នុងវេលាចប់កថា ព្រះរាជាព្រមដោយរាជបរិវារប្រមាណបួនម៉ឺន តាំងនៅក្នុងត្រៃសរណគមន៍ហើយ ។ ក៏ក្នុងខណៈនោះឯង អ្នកកាន់ការខាងគ្រឿងអាហារ ក៏នាំព្រះក្រយាហារមក ទូលថ្វាយចំពោះព្រះរាជា ។ ចំណែកព្រះរាជាទ្រង់កំពុងនៅស្ដាប់ព្រះសូត្រ ទ្រង់បានយល់ព្រះហឫទ័យល្អហើយយ៉ាងនេះថា “សមណសក្យបុត្រទាំងនេះ មិនគួរនឹងឆាន់ក្នុងវេលានេះ” ។ តែព្រះរាជាទ្រង់ត្រិះរិះថា ក៏ការដែលយើងមិនសួរហើយបរិភោគមិនគួរ ដូច្នេះហើយ ទើបត្រាស់សួរថា “លោកម្ចាស់ដ៏ចម្រើន ពួកលោកនឹងឆាន់ឬ ?”

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ ពួកអាត្មាភាពមិនគួរឆាន់ក្នុងវេលានេះ” ។

---

១. មជ្ឈិ. មូល. ២១ ៦៧/១៦៩ ។

ព្រះរាជា. “គួរឆាន់ក្នុងវេលាណាហ្ន៎ លោកម្ចាស់ ? ”

ព្រះថេរៈ. “សូមថ្វាយព្រះពរ គួរឆាន់តាំងពីព្រះអាទិត្យរះឡើងទៅ ដរាបដល់វេលាថ្ងៃត្រង់”

ព្រះរាជា. “ពួកយើងនាំគ្នាទៅកាន់ព្រះនគរចុះ លោកម្ចាស់ដ៏ចម្រើន”

ព្រះថេរៈ. “កុំឡើយ មហាបពិត្រ ពួកអាត្មាភាពនឹងសម្រាកក្នុងទីនេះឯង” ។

ព្រះរាជា. “បពិត្រលោកម្ចាស់ដ៏ចម្រើន បើពួកលោកម្ចាស់ នឹងសម្រាក (ក្នុងទីនេះ) សោត, សូមក្មេងនេះមក ទៅជាមួយនឹងខ្ញុំព្រះករុណា” ។

ព្រះថេរៈ. “សូមថ្វាយព្រះពរ មហាបពិត្រ ក្មេងនេះ សម្រេចផលហើយដឹងច្បាស់ព្រះសាសនាហើយ ជាបព្វជ្ជាបេក្ខៈ (គឺ អ្នកប្រាថ្នានឹងបព្វជ្ជា) នឹងបព្វជ្ជាក្នុងឥឡូវនេះ” ។

ព្រះរាជា. ទ្រង់ត្រាស់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ ស្អែកនេះ ខ្ញុំព្រះករុណានឹងបញ្ជូនរថមក (ទទួលពួកលោកម្ចាស់), សូមលោកម្ចាស់ទាំងឡាយ គប្បីឡើងរថនោះមកចុះ” ដូច្នេះ ថ្វាយបង្គំហើយក៏ស្ដេចជៀសទៅ ។

## សុមនសាមណេរប្រកាសវេលាស្តាប់ធម៌ពេញកោះលង្កា

ព្រះថេរៈ កាលព្រះរាជាស្តេចជៀសទៅមិនយូរប៉ុន្មាន ទើបហៅសុមនសាមណេរមកបង្គាប់ថា "សុមនៈ លោកចូរទៅឃោសនាវេលាស្តាប់ធម៌ចុះ" ។

សុមនសាមណេរទូលសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា នឹងឃោសនាឱ្យបានឮដរាបដល់អស់ទីមានប្រមាណប៉ុនណា ?"

ព្រះថេរៈបង្គាប់ថា "ចូរឃោសនាឱ្យបានឮពេញកោះតម្ពបណ្ណិទ្វីបចុះ" ។

សាមណេរទទួលថេរបញ្ជាថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ល្អណាស់" ហើយក៏ចូលចតុត្ថជ្ឈានមានអភិញ្ញាជាបាទ ចេញចាកឈានហើយ អធិដ្ឋានមានចិត្តតាំងមាំ ឃោសនាវេលាស្តាប់ធម៌ឱ្យបានឮទូទៅកោះតម្ពបណ្ណិទ្វីបអស់វារៈ ៣ ដងហើយ ។

ព្រះរាជា ទ្រង់ស្តាប់សំឡេងនោះហើយ ទើបទ្រង់បញ្ជូនដំណឹងទៅកាន់សំណាក់របស់ព្រះថេរៈទាំងឡាយថា "មានឧបទ្រវៈអ្វី ៗ ឬ ? លោកម្ចាស់ដ៏ចម្រើន"

ព្រះថេរៈទូលថា "អាត្មាភាពទាំងឡាយ មិនមានឧបទ្រវៈអ្វី អាត្មាភាពទាំងឡាយ បានឱ្យសាមណេរឃោសនាវេលាស្តាប់ធម៌, អាត្មាភាពទាំងឡាយ មានសេចក្តីប្រាថ្នានឹងសម្តែងព្រះពុទ្ធវចនៈ (ប៉ុណ្ណោះ)" ។

## សំឡេងប្រកាសឱស្សុះសាយទៅដល់ព្រហ្មលោក

ក៏ឯពួកភុម្មទេវតា បានស្តាប់សំឡេងរបស់សាមណេរនោះហើយ ក៏បានប្រកាសសំឡេងឱ្យបន្លឺលាន់ឮហើយ សំឡេងបានឮស្សុះសាយឡើងទៅដរាបដល់ព្រហ្មលោក ដោយឧបាយនោះព្រោះសំឡេងនោះ ក៏មានទេវតាមកសន្និបាតគ្នាយ៉ាងច្រើន ។ ព្រះថេរៈឃើញទេវតា មកសន្និបាតគ្នាយ៉ាងច្រើន ទើបសម្តែងសមចិត្តសូត្រ ។ ក្នុងវេលាចប់កថា ពួកទេវតាប្រមាណមួយអសង្ខេយ្យ បានសម្រេចធម៌ហើយ ។ នាគនិងសុបណ្ណជាច្រើនសន្ធឹកសន្ធាប់ ក៏បានតាំងនៅក្នុងសរណគមន៍ហើយ ។ ក៏កាលព្រះសារីបុត្តត្ថេរសម្តែងព្រះសូត្រនេះ ការសន្និបាតរបស់ពពួកទេវតាបានមានហើយយ៉ាងណា, ទេវតាសន្និបាតដូច្នោះ ក៏បានមានហើយសូម្បីកាលព្រះមហិន្ទត្ថេរ ( សម្តែងព្រះសូត្រនេះ ) ។

## ព្រះបឋមចេតិយក្រុងអនុរាធបុរី

គ្រានោះ ដោយកន្លងទៅនៃរាត្រីនោះ ព្រះរាជា ក៏ទ្រង់បញ្ជូនរថទៅដើម្បី ( ទទួល ) ព្រះថេរៈទាំងឡាយ ។ នាយសារថី បញ្ឈប់រថទុកក្នុងទីមួយ ហើយទូលប្រាប់ដល់ព្រះថេរៈទាំងឡាយថា "រថមកហើយ លោកម្ចាស់ មេត្តាឡើងរថចុះ, ពួកយើងនឹងទៅជាមួយគ្នា" ។

ព្រះថេរៈទាំងឡាយនិយាយថា "ពួកយើងនឹងមិនឡើងរថ, លោកចូរទៅចុះ ពួកយើងនឹងទៅខាងក្រោយ" ដូច្នេះហើយ បានហោះឡើងកាន់អាកាស ហើយទៅចុះក្នុងបឋមចេតិយស្ថាន ក្នុងខាងទិសបូព៌ានៃក្រុងអនុរាធបុរី ។ ពិតមែន ព្រះចេតិយនោះ គេហៅថា ព្រះបឋមចេតិយ ព្រោះជាចេតិយដែលប្រជាជនសាងទុក ក្នុងស្ថានទីព្រះថេរៈទាំងឡាយចុះគ្រាដំបូងនុ៎ះឯង ។

## ព្រះរាជាទ្រង់ត្រាស់ឱ្យត្រៀមការទទួលព្រះថេរៈ

ចំណែកព្រះរាជា គ្រាបញ្ជូននាយសារថីទៅហើយ ទើបទ្រង់បង្គាប់ពួកអាមាត្យថា "សូមឱ្យនាំគ្នាតាក់តែងមណ្ឌបខាងក្នុងព្រះរាជនិវេសន៍ចុះ" ។ ក្នុងវេលានោះឯង អាមាត្យទាំងពួង ក៏ត្រេកអររីករាយ តាក់តែងមណ្ឌបជាទីគួរជ្រះថ្លាក្រៃលែង ។ ព្រះរាជាទ្រង់ត្រិះរិះទៀតថា "ថ្ងៃម្សិលមិញ ព្រះថេរៈកាលសម្តែងពួកសីល ក៏ពោលថា 'ទីដេកខ្ពស់ និងទីដេកដ៏ប្រសើរ រមែងមិនគួរ (ដល់ពួកភិក្ខុ)' ដូច្នេះ, លោកម្ចាស់ទាំងឡាយនឹងអង្គុយលើអាសនៈទាំងឡាយ ឬនឹងមិនអង្គុយហ្ន៎" កាលព្រះរាជា ទ្រង់ត្រិះរិះយ៉ាងនោះឯង នាយសារថីនោះ ក៏មកដល់ទ្វារព្រះនគរ (ល្មម) ។ វេលានោះនាយសារថីបានឃើញព្រះថេរៈទាំងឡាយ ចងវត្តពន្ធចង្កេះដណ្តប់ចីវរ មកដល់មុនហើយ ។ គ្រាលោកឃើញហើយ ក៏ជាអ្នកមាន

ចិត្តជ្រះថ្លាក្រៃលែង ហើយត្រឡប់មកទូលចំពោះព្រះរាជាថា "សូមទេជៈក្រោមល្អងធូលីព្រះបាទ ព្រះថេរៈទាំងឡាយមកដល់ហើយ" ។

ព្រះរាជា ត្រាស់សួរថា "ព្រះថេរៈទាំងឡាយ ឡើងរថមកឬ ?"

នាយសារថីក្រាបទូលថា "មិនឡើងរថមកទេ ក្រាបទូល, ម្យ៉ាងទៀត ព្រះថេរៈទាំងឡាយចេញពេលក្រោយទូលបង្គំ តែលោកម្ចាស់មកដល់មុន បានឈរត្រង់ទ្វារខាងទិសបស្ចឹម" ។

ព្រះរាជាទ្រង់ស្តាប់ថា ព្រះថេរៈទាំងឡាយមិនឡើងសូម្បីនូវរថទើបទ្រង់ត្រិះរិះថា "ឥឡូវនេះ លោកម្ចាស់ទាំងឡាយ នឹងមិនត្រេកអរអាសនៈខ្ពស់" ហើយត្រាស់បង្គាប់ថា "នែនាយ បើដូច្នោះ ពួកលោកចូរក្រាលអាសនៈ ដោយអាការត្រឹមតែកម្រាលផ្ទៃ ដើម្បីព្រះថេរៈទាំងឡាយ" ដូច្នេះហើយ បានស្តេចត្រឡប់ទៅ ។ ពួកអាមាត្យក្រាលកន្ទេលទន់លើផែនដីហើយក្រាលកម្រាលដ៏វិចិត្រមានសំពត់ព្រំជាដើមខាងលើ ។ ពួកហោរអ្នកទាយនិមិត្តឃើញ (ហេតុការណ៍នោះ)ហើយ នាំគ្នាព្យាករណ៍ថា "ផែនដីនេះត្រូវព្រះថេរៈទាំងនេះ គ្រប់គ្រងហើយក្នុងកាលនេះ, លោកទាំងនេះ នឹងជាម្ចាស់របស់នៃកោះតម្ពបណ្ណិទ្វីប" ។ ចំណែកព្រះរាជាបានស្តេចមកថ្វាយបង្គំព្រះថេរៈទាំងឡាយហើយ ទ្រង់ទទួលយកបាត្រអំពីព្រះហស្តរបស់ព្រះមហិន្ទត្ថេរ ហើយនិមន្តពួកព្រះថេរៈឱ្យចូលទៅក្នុង

ក្រុង ដោយការបូជានិងសក្ការៈដ៏ច្រើន ឱ្យចូលទៅកាន់ខាងក្នុងព្រះរាជនិវេសន៍ ។ ព្រះថេរៈឃើញការឱ្យក្រាលអាសនៈហើយ អង្គុយគិតបណ្ដើរទៅថា “សាសនារបស់យើងនឹងផ្សាយទៅទូទាំងលង្កាទ្វីប និងតាំងមាំមិនញាប់ញ័រដូចផែនដី” ។ ព្រះរាជាទ្រង់អង្គៀសព្រះថេរៈទាំងឡាយ ឱ្យឆ្អែតគ្រប់គ្រាន់ ដោយខាទនិយៈភោជនិយៈដ៏ប្រណីត ដោយព្រះហស្ថរបស់ព្រះអង្គសម្រេចរៀបរយហើយ បានបង្គាប់ឱ្យហៅស្ត្រី ៥០០ នាក់ មានព្រះនាងអនុឡាទេវីជាប្រមុខមកដោយព្រះតម្រាស់ថា “ពួកនាងចូរធ្វើការអភិវាទ និងបូជាសក្ការៈព្រះថេរៈទាំងឡាយចុះ” ដូច្នេះ ហើយបានស្ដេចប្រថាប់អង្គុយក្នុងទីសមគួរមួយ ។

## ព្រះថេរៈសម្ដែងធម៌ប្រោសព្រះរាជានិងអ្នកកោះ

ក្នុងវេលាសម្រេចភត្តកិច្ច ព្រះថេរៈកាលនឹងឱ្យភ្លៀងរតនៈ គឺព្រះធម៌ធ្លាក់ដល់ព្រះរាជាព្រមទាំងជនជាបរិវារ ទើបសម្ដែងពេតវត្ថុ វិមានវត្ថុ និងសច្ចសំយុត្ត ។ ស្ត្រីទាំង ៥០០ ទាំងនោះ ស្ដាប់ធម្មទេសនារបស់ព្រះថេរៈនោះ បានធ្វើឱ្យច្បាស់នូវសោតាបត្តិផល ។ សូម្បីពួកមនុស្សដែលបានជួបនឹងព្រះថេរៈ លើភ្នំមិស្សកបព្វតក្នុងថ្ងៃមុន ក៏នាំគ្នាពោលសរសើរគុណរបស់ព្រះថេរៈក្នុងទីនោះ ៗ ។ ពួកមហាជនស្ដាប់ (អំពីសំណាក់) របស់ជនទាំងនោះ បានប្រជុំគ្នាបញ្ចេញសំឡេងអឺងកង

នៅឯព្រះរាជវាំង ។

ព្រះរាជាត្រាស់សួរថា "នោះជាសំឡេងអ្វី" ។ ពួកនគរក្រាបទូលថា "ពួកមហាជនស្រែកថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមិនបានឃើញព្រះថេរៈ" ព្រះរាជាទ្រង់ព្រះត្រិះរិះថា "បើពួកមហាជននឹងចូលមកក្នុងទីនេះសោត ឱកាសនឹងមិនមាន" ទើបត្រាស់ថា "នែនាយ ពួកលោកចូរទៅជម្រះរោងដំរី កៀរខ្សាច់ រោយផ្កាឈើ ៥ ពណ៌, ចងពិតានសំពត់ហើយក្រាលអាសនៈ ដើម្បីព្រះថេរៈទាំងឡាយលើទីរបស់ដំរីមង្គល" ។ ពួករាជអាមាត្យបានធ្វើយ៉ាងនោះហើយ ។ ព្រះថេរៈបានទៅអង្គុយសម្តែងទេវទូតសូត្រក្នុងទីនោះ ។ ក្នុងវេលាចប់កថា មនុស្សប្រមាណមួយពាន់ បានតាំងនៅក្នុងសោតាបត្តិផល ។

ក្នុងវេលានោះ ជនទាំងឡាយគិតថា "រោងដំរីចង្អៀតពេកណាស់" ទើបតាក់តែងអាសនៈក្នុងឧទ្យាននន្ទវ័ន ជិតទ្វារខាងទិសទក្សិណ ។ ព្រះថេរៈ (ទៅ) អង្គុយសម្តែងអាសិវិសូបមសូត្រ ក្នុងឧទ្យាននន្ទវ័ននោះ ។ ព្រោះស្តាប់អាសិវិសូបមសូត្រ សូម្បីនោះ មនុស្សប្រមាណមួយពាន់ បានសោតាបត្តិផល ។ ក្នុងថ្ងៃទីពីរអំពីថ្ងៃដែលព្រះថេរៈមកហើយ ធម្មាភិសម័យ (ការត្រាស់ដឹងធម៌ ការសម្រេចធម៌) បានមានដល់មនុស្សប្រមាណ ២,៥០០ នាក់ ។

## ព្រះរាជាថ្វាយឧទ្យានសាងវត្ត

កាលព្រះថេរៈនៅសំណេះសំណាលជាមួយនឹងពួកស្ត្រីក្នុងត្រកូល កូនប្រសាក្នុងត្រកូល កុមារីក្នុងត្រកូល ដែលគេមកហើយជាបន្តបន្ទាប់ ក្នុងឧទ្យាននន្ទវ័នទុំះឯង វេលាក៏ល្ងាច ។ ព្រះថេរៈសង្កេតវេលាហើយ ក្រោកឡើង និយាយបណ្តើរថា "ដល់វេលាហើយ ពួកយើងនឹងទៅកាន់មិស្សកបព្វត" ។

ពួកអាមាត្យទូលសួរថា "ពួកលោកម្ចាស់នឹងនិមន្តទៅណា ?" ព្រះថេរៈពោលថា "នឹងទៅកាន់ទីសម្រាករបស់ពួកយើង" ។ អាមាត្យទាំងនោះ ក្រាបទូលឱ្យព្រះរាជាទ្រង់ជ្រាបហើយ ក្រាបទូលតាមព្រះបរមរាជានុមតិថា "លោកម្ចាស់ដ៏ចម្រើន វេលានេះ មិនមែនវេលាដែលនឹងទៅក្នុងទីនោះ ឧទ្យាននន្ទវ័ននេះឯង ចូរជាទីសម្រាករបស់លោកម្ចាស់" ។ ព្រះថេរៈពោលថា "កុំឡើយ ពួកអាត្មានឹងទៅ" ។ ពួកអាមាត្យពិតទូលតាមព្រះរាជតម្រាស់ទៀតថា "លោកម្ចាស់ ព្រះរាជាត្រាស់ថា ឧទ្យានឈ្មោះមេឃវ័ននេះ ជារបស់ព្រះជនកយើងនៅមិនឆ្ងាយមិនជិត ពីព្រះនគរសម្បូណ៏ដោយមកទៅមក សូមព្រះថេរៈទាំងឡាយ មេត្តាសម្រេចការនៅក្នុងឧទ្យានមេឃវ័ននេះ" ។ ព្រះថេរៈទាំងឡាយ ទើបសម្រាកក្នុងឧទ្យានមេឃវ័ន ។ ចំណែកព្រះរាជានោះឯង កាលរាត្រីនោះកន្លងទៅ ទ្រង់

យានទៅកាន់សំណាក់របស់ព្រះថេរៈ បានត្រាស់សួរដល់ការសឹងជាសុខសប្បាយហើយ ត្រាស់សួរតទៅថា "បពិត្រលោកម្ចាស់ដ៏ចម្រើន អារាមនេះ សមគួរដល់ព្រះភិក្ខុសង្ឃឬ ?" ព្រះថេរៈថ្វាយព្រះពរថា "សមគួរមហាបពិត្រ ហើយទើបនាំព្រះសូត្រនេះមកថា 'អនុជានាមិ ភិក្ខវេ អារាមំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអារាម'[១]" ដូច្នេះជាដើម ។ ព្រះរាជាទ្រង់ពេញព្រះទ័យ ទ្រង់ចាប់ព្រះសុវណ្ណភិង្ការ (ព្រះកុណ្ឌីមាស) ប្រចទឹកឱ្យធ្លាក់ទៅលើដៃរបស់ព្រះថេរៈ បានថ្វាយឧទ្យានមហាមេឃវ័ន ព្រមនឹងទឹកធ្លាក់ ផែនដីក៏ញាប់ញ័រ ។ នេះជាការញ័រនៃផែនដីលើកដំបូងក្នុងមហាវិហារ ។ ព្រះរាជាទ្រង់ស្លុតព្រះទ័យខ្លាច ទើបត្រាស់សួរព្រះថេរៈថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបផែនដីញ័រ" ។

ព្រះថេរៈទូលថ្វាយព្រះពរថា "មហាបពិត្រ កុំស្លុតព្រះទ័យឡើយ សាសនារបស់ព្រះទសពលនឹងតាំងមាំក្នុងកោះនេះ និងទឹកន្លែងនេះ នឹងជាទីតាំងមហាវិហារជាដំបូង ផែនដីញ័រនោះជាបុព្វនិមិត្តនៃការប្រតិស្ឋានព្រះសាសនា និងការដែលត្រូវសាងវិហារនោះ" ។ ព្រះរាជាទ្រង់ជ្រះថ្លាពេញចិត្តយ៉ាងក្រៃលែង ។

១. វិន. មហា. មហាខន្ធក. ៦. ៦៣/១២០ ។

## ព្រះថេរៈសម្ដែងធម៌ប្រោសអ្នកកោះជាប់តគ្នាទៅ

សូម្បីក្នុងថ្ងៃស្អែក ព្រះថេរៈឆាន់ក្នុងព្រះរាជមណ្ឌបតាមទម្លាប់ ហើយសម្ដែងអនមតគ្គិយសូត្រ ក្នុងឧទ្យាននន្ទវ័ន ។ ថ្ងៃស្អែកសម្ដែងអគ្គិខន្ធោបមសូត្រ ព្រះថេរៈសម្ដែងដោយឧបាយនេះឯង រហូតដល់ ៧ ថ្ងៃ ។ ធម្មាភិសម័យ បានមានដល់សត្វប្រមាណ ៨,៥០០ នាក់ ។ តាំងពីនោះមក ឧទ្យាននន្ទវ័ន ក៏បានឈ្មោះថា ជោតិវ័ន ព្រោះអធិប្បាយថា ជាស្ថានទីដែលព្រះសាសនាប្រាកដនូវភាពរុងរឿងឡើង ។ ចំណែកក្នុងថ្ងៃទី ៧ ព្រះថេរៈសម្ដែងអប្បមាទសូត្រ ប្រោសព្រះរាជាក្នុងខាងក្នុងព្រះរាជវាំងហើយ ក៏ហួសទៅកាន់ចេតិយគិរីបព្វត ។ គ្រានោះឯង ព្រះរាជាត្រាស់សួរពួកអាមាត្យថា "ព្រះថេរៈប្រៀនប្រដៅពួកយើង ដោយឱវាទធ្ងន់ហើយ គប្បីចេញទៅឬហ្ន៎ ?" ពួកអាមាត្យក្រាបទូលថា "បពិត្រសម្មតិទេវ ព្រះអង្គមិនបាននិមន្តព្រះថេរៈមកទេ ព្រះថេរៈនិមន្តមកដោយខ្លួនឯង ព្រោះដូច្នោះ សូម្បីការមិនទូលលាព្រះអង្គឡើយចេញទៅ ក៏បាន" ។

## ព្រះរាជាទ្រង់រថធ្វើដំណើរទៅតាមព្រះថេរៈ

លំដាប់នោះ ព្រះរាជាស្ដេចឡើងទ្រង់រថ និងទ្រង់លើកព្រះទេវីទាំងពីរឱ្យឡើងហើយបានស្ដេចយាងទៅកាន់ចេតិយគិរីបព្វត ដោយរាជានុភាពធំ ។ ព្រះរាជាត្រាស់ស្ដេចយាងទៅហើយ ឱ្យព្រះទេវីទាំងពីរសម្រាកក្នុងទីសមគួរមួយ ទ្រង់ក៏ចូលទៅកាន់សំណាក់របស់ព្រះថេរៈទាំងឡាយស្ដេចចូលទៅទាំងដែលមានព្រះវរកាយហត់នឿយខ្លាំងណាស់ ។ ក្នុងវេលានោះ ព្រះថេរៈទូលព្រះរាជាថា មហាបពិត្រ ព្រោះហេតុអ្វី ទើបទ្រង់យាងមកទាំងនឿយលំបាកព្រះវរកាយយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមកដើម្បីជ្រាបថា ពួកលោកឱ្យឱវាទយ៉ាងធ្ងន់ដល់ខ្ញុំព្រះករុណាហើយ ប្រាថ្នានឹងទៅវិញក្នុងឥឡូវនេះឬហ្ន៎ ?" ព្រះថេរៈទូលថា "មហាបពិត្រ ពួកអាត្មាភាពមិនមែនត្រូវការនឹងទៅទេ តែថា វេលានេះ ជាវស្សូបនាយិកកាល (កាលចូលចាំវស្សា) មហាបពិត្រ ក្នុងវស្សូបនាយិកកាលនោះ សមណៈបានទីកន្លែងចាំវស្សា ទើបសមគួរ" ។

## អរិដ្ឋអាមាត្យសូមព្រះបរមរាជានុញ្ញាតបួស

ក្នុងថ្ងៃនោះឯង អាមាត្យឈ្មោះអរិដ្ឋៈនឹងបងប្រុសនិងប្អូនប្រុសរួម ៥៥ នាក់ឈរក្នុងទីជិតព្រះរាជាក្រាបទូលថា "សូមតេជៈ ក្រោមល្អងធូលីព្រះបាទ ទូលបង្គំចង់បួសក្នុងសំណាក់របស់ព្រះថេរៈ" ។ ព្រះរាជាត្រាស់ថា "ល្អណាស់ នាយ ចូរបួសចុះ" ។ ព្រះរាជាគ្រាទ្រង់អនុញ្ញាតហើយ បានប្រគល់ថ្វាយឱ្យព្រះថេរៈ ។ ព្រះថេរៈក៏ឱ្យគេបួសក្នុងថ្ងៃនោះឯង ។ ទាំងអស់បានសម្រេចព្រះអរហត្ត ក្នុងវេលាកោរសក់រួចស្រេចដូចគ្នា ។ ចំណែកព្រះរាជា ទ្រង់យកបន្ទាលោមព័ទ្ធលានព្រះចេតិយ ក្នុងខណៈនោះឯង ហើយទ្រង់ចាប់ផ្តើមតាំងការងារទុកត្រង់ល្អាង ៦៨ ល្អាង បានស្តេចត្រឡប់កាន់ព្រះនគរដូចដើម ។ ព្រះថេរៈសូម្បីទាំងនោះ ញុំាងរាជត្រកូលប្រកបដោយម្ចាស់បងនិងម្ចាស់ប្អូន ១០ អង្គ ឱ្យជ្រះថ្លាហើយ នៅចាំវស្សាក្នុងចេតិយគិរីបព្វត ប្រៀនប្រដៅមហាជនសូម្បីក្នុងវេលានោះ មានព្រះអរហន្ត ៦២ រូប ចូលចាំវស្សាដំបូងក្នុងចេតិយគិរីបព្វត ។

## ព្រះថេរៈណែនាំឱ្យរកវត្ថុដែលគួរក្រាបថ្វាយបង្គំបូជា

គ្រានោះ ព្រះមហាមហិន្ទ នៅចាំវស្សាបវារណាហើយ បានទូលពាក្យនេះ នឹងព្រះរាជា ក្នុងថ្ងៃឧបោសថ ខែកត្តិកាពេញបូណ៌មីថា "មហាបពិត្រ ពួកអាត្មាភាព បានគាល់ព្រះសម្មាសម្ពុទ្ធមកយូរហើយ[១] រស់នៅដូចជាគ្មានទីពឹង អាត្មាប្រាថ្នានឹងទៅកាន់ជម្ពូទ្វីប" ។ ព្រះរាជាត្រាស់ថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបម្រើពួកលោកម្ចាស់ដោយបច្ច័យ ៤ និងមហាជននេះ អាស្រ័យលោកម្ចាស់ តាំងនៅក្នុងសរណៈទាំងឡាយ ព្រោះហេតុអ្វី ទើបពួកលោកនឿយណាយ" ។ ព្រះថេរៈទូលថា "មហាបពិត្រ ពួកអាត្មាភាព បានគាល់ព្រះសម្មាសម្ពុទ្ធមកយូរហើយ ស្ថានទីគួរធ្វើការអភិវាទ ការក្រោកទទួលអញ្ជលីកម្ម និងសាមីចិកម្មមិនមាន ព្រោះហេតុនោះ ទើបពួកអាត្មាភាពនឿយណាយ" ។ ព្រះរាជាត្រាស់ថា "លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បាននិយាយហើយមិនមែនឬថា ព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ" ។ ព្រះថេរៈទូលថា "មហាបពិត្រ បរិនិព្វានក៏ពិតមែនហើយ តែថា ព្រះសរីរធាតុរបស់ព្រះអង្គនៅមាន" ។ ព្រះរាជាត្រាស់ថា "ខ្ញុំព្រះករុណាដឹង លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់បំណងប្រាថ្នាការសាងព្រះសថូប" ហើយត្រាស់តទៅ

១. ព្រះថេរៈធ្លាប់នៅថ្វាយបង្គំពីមុន ឥឡូវនេះមិនបាន ទើបចង់ទៅថ្វាយបង្គំទៀត ។

ថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានឹងសាងព្រះសថូប និមន្តលោកម្ចាស់ជ្រើសរើសផ្ទៃដី ក្នុងពេលឥឡូវនេះចុះ មួយទៀត ខ្ញុំព្រះករុណានឹងបានព្រះធាតុមកអំពីទីណា លោកម្ចាស់" ព្រះថេរៈទូលថា "មហាបពិត្រ សូមទ្រង់ប្រឹក្សាជាមួយនឹងសុមនសាមណេរទៅមើល៍" ។

## សុមនសាមណេរទទួលរាប់រងរកព្រះធាតុ

ព្រះរាជាទ្រង់ទទួលថា "ល្អណាស់ លោកម្ចាស់ដ៏ចម្រើន" ហើយចូលទៅរកសុមនសាមណេរត្រាស់សួរថា "លោកម្ចាស់ ឥឡូវនេះ ពួកយើងនឹងបានព្រះធាតុមកអំពីណា ?"

សុមនសាមណេរទូលថា "ទ្រង់ខ្វល់ខ្វាយតិចចុះ មហាបពិត្រ សូមទ្រង់បញ្ជាឱ្យជម្រះមក ឱ្យប្រដាប់តាក់តែងដោយគ្រឿងប្រដាប់មានទង់ជ័យ ទង់បដា និងឆ្នាំងទឹកពេញជាដើម ហើយព្រមដោយជនបរិវារសមាទានអដ្ឋឧបោសថ ឱ្យពួកអ្នកកាន់ការខាងតូរ្យតន្ត្រីទាំងពួងប្រជុំគ្នា បន្ទាប់ឱ្យតាក់តែងដំរីមង្គល ប្រដាប់ប្រដាដោយគ្រឿងអលង្ការគ្រប់យ៉ាង និងឱ្យលើកស្វេតឆត្រឡើងខាងលើដំរីមង្គលនោះ រួចស្រេចហើយវេលាល្ងាច សូមឱ្យទ្រង់បែរព្រះភ័ក្ត្រតម្រង់ទៅកាន់ឧទ្យានមហានាគវ័ន ព្រះអង្គនឹងទ្រង់បានព្រះធាតុក្នុងទីនោះពិតប្រាកដ" ។ ព្រះរាជាទ្រង់ទទួលថា សាធុ ។ ព្រះថេរៈទាំងឡាយ ក៏បានទៅកាន់ចេតិយគិរីបព្វតនុ៎ះឯង ។

## ព្រះថេរៈឱ្យសុមនសាមណេរទៅអារាធនាព្រះធាតុ

ក្នុងចេតិយគិរីបព្វតនោះ ព្រះមហិន្ទត្ថេរ ពោលនឹងសុមនសាមណេរថា "សាមណេរ អ្នកចូរទៅចុះ ទៅគាល់ព្រះបាទអសោកធម្មរាជ អ្នកជាស្តេចតារបស់អ្នកក្នុងជម្ពូទ្វីប ទូលតាមពាក្យរបស់យើងយ៉ាងនេះថា 'មហាបពិត្រ ព្រះបាទទេវានម្បិយតិស្សព្រះសម្លាញ់របស់ព្រះអង្គទ្រង់ជ្រះថ្លាក្នុងព្រះសាសនា ប្រាថ្នានឹងឱ្យសាងព្រះសថូប បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងព្រះហស្ត (ក្នុងគ្រប់គ្រង) សូមព្រះអង្គទ្រង់បានព្រះករុណា មេត្តាព្រះរាជទានព្រះធាតុនោះដល់អាត្មាភាពចុះ' ដូច្នេះហើយទទួលយកព្រះធាតុនោះ ចូរចូលទៅគាល់ស្តេចសក្កទេវរាជទូលយ៉ាងនេះថា 'បពិត្រមហារាជ បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងព្រះហស្ត ២ អង្គ គឺ ព្រះធាតុចង្កូមខាងស្តាំ ១ ព្រះធាតុដងកាំបិតខាងស្តាំ ១ ព្រោះដូច្នោះ សូមព្រះអង្គមេត្តាបូជាព្រះធាតុចង្កូមខាងស្តាំ តែព្រះរាជទានព្រះធាតុដងកាំបិត ខាងស្តាំដល់អាត្មាភាព' និងចូរទូលស្តេចសក្កៈនោះយ៉ាងនេះថា 'បពិត្រមហារាជ ព្រោះហេតុអ្វី ព្រះអង្គទ្រង់បញ្ជូនពួកអាត្មាភាពទៅកាន់កោះតម្ពបណ្ណិទ្វីប ហើយទ្រង់មិនយកចិត្តទុកដាក់សោះ'" ដូច្នេះ ។

# សុមនសាមណេរទៅនាំព្រះធាតុមកកោះលង្កា

សុមនសាមណេរទទួលពាក្យរបស់ព្រះថេរៈថា "ល្អណាស់ លោកម្ចាស់" ដូច្នេះហើយ កាន់យកបាត្រនិងចីវរហោះឡើងកាន់អាកាស ក្នុងខណៈនោះឯង ចុះជិតទ្វារនគរបាតលីបុត្តទៅកាន់រាជសំណាក់ទូលរឿងនោះឱ្យទ្រង់ជ្រាប ។ ព្រះមហារាជា ទ្រង់ត្រេកអរទទួលបាត្រពីដៃសាមណេរ អប់ដោយរបស់ក្រអូបហើយបានដាក់ព្រះធាតុចូលទៅ ដូចនឹងកែវមុក្តាដ៏ប្រសើរថ្វាយ ។ សាមណេរនោះ ទទួលយកព្រះធាតុនោះហើយ ចូលទៅគាល់ស្តេចសក្កទេវរាជ ។ ស្តេចសក្កទេវរាជឃើញសាមណេរហើយត្រាស់ថា "សុមនៈដ៏ចម្រើន លោកនិមន្តមក ព្រោះមានហេតុអ្វី ?"

សាមណេរ. "បពិត្រមហារាជ ព្រះអង្គទ្រង់បញ្ជូនពួកអាត្មាភាពទៅកាន់កោះតម្ពបណ្ណិទ្វីបហើយ ទ្រង់មិនយកចិត្តទុកដាក់សោះ ព្រោះហេតុអ្វី" ។

ស្តេចសក្កៈ. "មិនបានលះបោលឡើយ លោកម្ចាស់ដ៏ចម្រើននិយាយមកចុះ នឹងឱ្យខ្ញុំព្រះករុណាធ្វើអ្វី ?"

សាមណេរ. "បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងព្រះហស្ត ២ អង្គ គឺ ព្រះធាតុចង្កូមខាងស្តាំ ១ ព្រះធាតុដងកាំបិតខាងស្តាំ ១ ដូច្នោះ

សូមឱ្យមហាបពិត្រ ទ្រង់បូជាព្រះធាតុចង្កូមខាងស្តាំ តែទ្រង់ព្រះរាជទានព្រះធាតុដងកាំបិតខាងស្តាំដល់អាត្មាភាព” ។ ស្តេចសក្កៈជាធំជាងពួកទេវតាត្រាស់ថា “ល្អណាស់ លោកម្ចាស់ដ៏ចម្រើន” ហើយទ្រង់បើកព្រះសថូបកែវមណីប្រមាណ ១ យោជន៍ បាននាំព្រះធាតុដងកាំបិតខាងស្តាំចេញមកហើយ ថ្វាយដល់សុមនសាមណេរ ។ សុមនសាមណេរនោះទទួលយកព្រះធាតុនោះហើយប្រតិស្ឋានទុក ក្នុងចេតិយបព្វតនុ៎ះឯង ។

## ព្រះថេរៈនិងព្រះរាជាព្រមទាំងអ្នកកោះទទួលព្រះធាតុ

គ្រានោះឯង ព្រះមហានាគទាំងអស់នោះ មានព្រះមហិន្ទជាប្រមុខប្រតិស្ឋានព្រះធាតុ ដែលព្រះបាទអសោកធម្មរាជ ទ្រង់ព្រះរាជទានមកទុកត្រង់ចេតិយបព្វតនុ៎ះឯង ហើយយាងព្រះធាតុដងកាំបិតខាងស្តាំ ទៅកាន់មហានាគវ័នឧទ្យានក្នុងវេលារសៀល ។ ចំណែកព្រះរាជា ទ្រង់ធ្វើការបូជាសក្ការៈមានប្រការដូចដែលសុមនសាមណេរពោលហើយ ប្រថាប់លើ-កដំរីដ៏ប្រសើរ ទ្រង់បាំងស្វេតឆត្រដោយព្រះអង្គឯង លើសិរសារបស់ដំរីមង្គល ស្តេចយាងទៅដល់មហានាគវ័នឧទ្យានហើយ ។ គ្រានោះ ទ្រង់បានមានព្រះរំពឹងដូច្នេះថា “បើធាតុនេះ ជាព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធពិតប្រាកដ ចូរស្វេតឆត្របែរផាកចេញទៅ ចូរដំរីមង្គលលុតជង្គង់ចុះលើផែនដី សូមឱ្យប្រអប់បញ្ចុះព្រះធាតុ មកប្រតិស្ឋាននៅលើក្បាល

របស់យើង" ។ ព្រមដោយចិត្តប្បាទរបស់ព្រះរាជាឆត្របានបែរផាកចេញទៅ ដំរីលុតក៏ជន្គង់ចុះលើផែនដី ប្រអប់បញ្ចុះព្រះធាតុ បានមកប្រតិស្ថាននៅលើសីសៈរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រកបដោយព្រះបីតិបាមោជ្ជៈយ៉ាងក្រៃលែង ដូចមានព្រះអង្គដែលទឹកអម្រឹតទុំះឯង ស្រោចស្រប់ហើយ ទើបត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា នឹងបដិបត្តិព្រះធាតុយ៉ាងណា ។ ព្រះថេរៈទូលថា "សូមព្រះអង្គទ្រង់ដាក់លើពោងដំរីទុំះចុះ មហាបពិត្រ" ព្រះរាជាទ្រង់បានលើកប្រអប់បញ្ចុះព្រះធាតុដាក់លើពោងដំរី ។ ដំរីមានសេចក្តីសប្បាយចិត្ត បានបន្លឺសំឡេងដូចសំឡេងសត្វក្រៀល ។ មហាមេឃ តាំងអ័ព្ទខ្មៅឡើងហើយ បានញុំាងភ្លៀងបោក្ខរពស័ឱ្យធ្លាក់ចុះមក ។ ផែនដីធំក៏បានញ័រដរាបដល់ទឹកជាទីបំផុត មានការឱ្យដឹងថា សូម្បីព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ ក៏នឹងប្រតិស្ថាននៅក្នុងបច្ចន្តជនបទ ដូច្នេះជាហេតុ ពួកទេវតា និងមនុស្សបានរីករាយសប្បាយចិត្តគ្រប់ ៗ គ្នា ។

ព្រះមហាវីរៈ ( អ្នកមានសេចក្តីព្យាយាមធំ ) ស្តេចមកក្នុងកោះលង្កានេះ ចាកទេវលោក បានប្រតិស្ឋាននៅលើពោងដំរី ក្នុងតិថីពេញបូរមីជាគម្រប់៤ខែ ( កណ្តាលខែ ១២ ) ។

បន្តឱ្យកើតបីតិដល់ពួកទេវតា និងពួកមនុស្សទាំងឡាយ ដោយសិរី គឺ អានុភាពនៃឫទ្ធិដោយប្រការដូច្នេះឯង ។

## ដំរីនាំព្រះធាតុទៅកាន់ទីដែលនឹងត្រូវសាងព្រះចេតិយ

គ្រានោះ ដំរីនោះ ដែលពួកតូរ្យតន្ត្រីជាច្រើនហែហមហើយ មានពួកនគរសក្ការៈ ដោយការបូជាសក្ការៈយ៉ាងឱឡារក្រៃលែង ដើរតម្រង់ទៅខាងទិសបច្ចិម មិនថយក្រោយដរាបដល់ទ្វារនគរខាងទិសបូព៌ាហើយ ចូលកាន់នគរតាមទ្វារខាងទិសបូព៌ា មានពួកនគរទូទៅទាំងក្រុងធ្វើការបូជាយ៉ាងឱឡារ ចេញ (ពីក្រុង) តាមប្រកទ្វារខាងទិសទក្សិណ ដើរទៅត្រង់ទេវាល័យ (ទេវស្ថាន) របស់មហេជយក្ខ ន័យថា មាននៅក្នុងខាងទិសបច្ចិមនៃថូបារាម ហើយបែរត្រឡប់តម្រង់ទៅកាន់ថូបារាមនុ៎ះឯងទៀត ។ ក៏សម័យនោះ ថូបារាមជាទីតាំងបរិភោគចេតិយ របស់ព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ៣ ព្រះអង្គ ។

## ប្រវត្តិកោះលង្កាជាប់ទាក់ទងនឹងព្រះពុទ្ធ

ដូចបានស្តាប់មក ក្នុងអតីតកាល ទ្វីបនេះ (កោះលង្កា) បានមានឈ្មោះថា ឱជទ្វីប ។ ព្រះរាជាមានព្រះនាមថា អភ័យ ។ រាជធានីឈ្មោះថា អភយបុរៈ ។ ចេតិយបព្វតមានឈ្មោះថា ទេវកូដបព្វត ។ ថូបារាមមាននាមថា បដិយារាម ។ ក៏សម័យនោះឯង ព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ ទ្រង់ឧប្បត្តិហើយក្នុងលោក ។ សាវករបស់ព្រះ

មានព្រះភាគអង្គនោះ ឈ្មោះថា មហាទេវៈ បានឈរលើទេវកូដបព្វតជាមួយនឹងភិក្ខុមួយពាន់រូប ប្រាកដដូចព្រះមហិន្ទត្ថេរឈរលើចេតិយបព្វតដូច្នោះ ។ សម័យនោះ ពួកសត្វលើកោះឱជទ្វីបដល់នូវសេចក្ដីវិបត្តិអន្តរាយ ព្រោះរោគឈ្មោះ បជ្ជរកៈ ( គ្រុនក្ដៅ ) ព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ ទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ បានទតឃើញហើយនូវសត្វទាំងនោះដែលដល់សេចក្ដីវិបត្តិវិនាស គ្រាទតឃើញហើយ មានភិក្ខុ ៤ ម៉ឺនហែហមបានស្ដេចយាងទៅ ( កោះនោះ ) ។ ដោយអានុភាពរបស់ព្រះមានព្រះភាគនោះ រោគបជ្ជរកបានស្ងប់រម្ងាប់ក្នុងខណៈនោះឯង ។ កាលរោគស្ងប់រម្ងាប់ហើយ ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ប្រោស ។ ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគបានប្រទានធម្មក្រកទុកហើយស្ដេចជៀសទៅ ។ អ្នកក្រុងសាងព្រះចេតិយក្នុងបដិយារាម បញ្ចុះធម្មក្រកនោះទុកខាងក្នុង ។ ព្រះមហាទេវៈ បាននៅប្រៀនប្រដៅអ្នកកោះ ។

ចំណែកក្នុងសម័យកាលរបស់ព្រះមានព្រះភាគ ព្រះនាមថា កោនាគមនៈ ទ្វីបនេះ មានឈ្មោះថា វរទ្វីប ។ ព្រះរាជាមានព្រះនាមថា សមិទ្ធិ ។ រាជធានីឈ្មោះថា វឌ្ឍមាន ។ បព្វតឈ្មោះថា សុវណ្ណកូដ ។ ក៏ឯសម័យនោះ កើតមានរាំងភ្លៀង លំបាកដោយ

ភិក្ខាហារ ស្រូវវិនាសអស់ក្នុងវរទ្វីប ។ ពួកសត្វដល់សេចក្ដីវិបត្តិដោយរោគ គឺ សេចក្ដីស្រេកឃ្លាន ។ ព្រះមានព្រះភាគព្រះនាមថា កោនាគមនៈ ទ្រង់ទតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងនោះ ជាអ្នកដល់សេចក្ដីវិបត្តិ លុះទ្រង់ទតឃើញហើយ មានភិក្ខុបីម៉ឺនរូបហែហមបានស្ដេចយាងទៅ (កាន់កោះនោះ) ។ ដោយពុទ្ធានុភាព ភ្លៀងបានធ្លាក់ត្រូវតាមរដូវកាល ។ ភិក្ខាហារក៏រកបានងាយ ។ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ប្រោស (ដល់មនុស្សក្នុងទ្វីបនោះ) ។ ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគ ឃាត់ព្រះថេរៈនាមថា មហាសុមនដែលមានភិក្ខុ ១.០០០ រូប ជាបរិវារទុកឱ្យនៅក្នុងកោះ បានប្រទានវត្ថពន្ធចង្កេះនោះទុក ហើយស្ដេចជៀសទៅ ។ ជនទាំងឡាយបានសាងព្រះចេតិយបញ្ចុះវត្ថពន្ធចង្កេះនោះទុកខាងក្នុង ។

មួយទៀត ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមថា កស្សបៈ កោះនេះមានឈ្មោះថា មណ្ឌទ្វីប ។ មានព្រះរាជាទ្រង់ព្រះនាមថា ជយន្ត ។ នគរឈ្មោះថា វិសាល ។ ភ្នំមានឈ្មោះថា សុភកូដ ។ ក៏សម័យនោះឯង មានការឈ្លោះវិវាទធំក្នុងមណ្ឌទ្វីប ។ សត្វជាច្រើនកើតឈ្លោះវិវាទទាស់ទែងគ្នា រមែងដល់សេចក្ដីវិបត្តិ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សបៈ ទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ បានទតឃើញសត្វទាំង

នោះអ្នកដល់សេចក្ដីវិបត្តិវិនាស លុះទតឃើញហើយ មានភិក្ខុពីរម៉ឺនរូប ហែហមស្ដេចមករម្ងាប់ការវិវាទ ហើយសម្ដែងធម៌ប្រោស ៗ ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគញុំាងព្រះថេរៈនាមថា សព្វនន្ទី ដែលមានភិក្ខុមួយពាន់រូបជាបរិវារឱ្យនៅក្នុងកោះ បានប្រទានឧទកសាដិកទុក ហើយស្ដេចជៀសទៅ ។ អ្នកកោះបានសាងព្រះចេតិយ បញ្ចុះឧទកសាដិកនោះទុកខាងក្នុង ។ បរិភោគចេតិយរបស់ព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ៣ ព្រះអង្គបានប្រតិស្ឋាននៅហើយក្នុងថូបារាមដោយប្រការយ៉ាងនេះ ។ ចេតិយទាំងនោះ រមែងសាបសូន្យទៅ ព្រោះការអន្តរធានទៅនៃព្រះសាសនា នៅសល់ត្រឹមតែឋានប៉ុណ្ណោះ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលពាក្យនេះថា សម័យនោះថូបារាមជាទីតាំងនៃបរិភោគចេតិយ របស់ព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ៣ ព្រះអង្គ ។

ទីកន្លែងនោះ កាលព្រះចេតិយសាបសូន្យទៅហើយ ត្រូវហ៊ុំព័ទ្ធនៅដោយគុម្ពឈើផ្សេង ៗ ដែលមានមែកតូច ៗ ខ្ទាត់ខ្វែងទៅដោយបន្លា ដោយអានុភាពរបស់ទេវតា ដោយតាំងចិត្តថា អ្នកណា ៗ កុំបានប្រទូសរ៉ាយទីនោះ ដោយរបស់ជាសំណល់ របស់មិនស្អាត មន្ទិល និងសម្រាម ។

## ដំរីមិនព្រមឱ្យលើកព្រះធាតុចុះអំពីពោង

គ្រានោះ ពួករាជបុរសដើរទៅមុនដំរីនោះ កាប់ឆ្ការគុម្ពឈើទាំងអស់ពង្រាបដីទីនោះឱ្យរាបដូចបាតដៃ ។ ស្ដេចដំរីដើរបែរមុខទៅកាន់ទីនោះ បានឈរត្រង់ឋានដើមពោធិព្រឹក្សខាងទិសបច្ឆិមនៃទីនោះ ។ គ្រានោះ ពួករាជបុរសប្រារព្ធនឹងលើកព្រះធាតុចុះចាកពីពោងដំរីនោះ ។ ស្ដេចដំរីមិនព្រមឱ្យលើកចុះ ។

ព្រះរាជាត្រាស់សួរព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន ចុះហេតុអ្វីទើបដំរីមិនព្រមឱ្យលើកព្រះធាតុចុះ" ។

ព្រះថេរៈថ្វាយព្រះពរថា "មហាបពិត្រ ព្រះធាតុដែលលើកឡើងហើយទើងលើកចុះមិនសមគួរ" ។ ក៏ក្នុងកាលនោះ ទឹកក្នុងបឹងអភ័យវាបីស្ងួតអស់ទៅ ។ ផែនដីដោយជុំវិញបែកក្រហែងជុំដីស្អិត លើកឡើងបានងាយ មហាជនប្រញាប់ប្រញាល់ជួយគ្នានាំដីពីបឹងអភ័យវាបីនោះ មកធ្វើផ្ទៃដី (ឋាន) ប្រមាណប៉ុនពោងដំរី ។ ក្នុងខណៈនោះឯង ជនទាំងឡាយចាប់ផ្ដើមរៀបឥដ្ឋ ដើម្បីសាងព្រះសថូប ។ ស្ដេចដំរីឈរក្នុងរោងដំរី ជិតឋានរបស់ដើមពោធិព្រឹក្សក្នុងពេលថ្ងៃ ពេលយប់រក្សាផ្ទៃដីដែលនឹងសាងព្រះសថូប ២-៣ ថ្ងៃ ដរាបដល់ឥដ្ឋសម្រេច ។

គ្រានោះ ព្រះរាជាបង្គាប់ឱ្យសាងផ្ទៃដី (ឋាន, ទីតាំង) ហើយ

ត្រាស់សួរព្រះថេរៈថា "ខ្ញុំព្រះករុណាគប្បីសាងព្រះសថូប មានរូបលក្ខណៈយ៉ាងណា លោកម្ចាស់ដ៏ចម្រើន ?"

ព្រះថេរៈថ្វាយព្រះពរថា "ដូចទីងគំនរស្រូវ មហាបពិត្រ" ព្រះរាជាទ្រង់បង្គាប់ថា "ល្អណាស់ លោកម្ចាស់ដ៏ចម្រើន" បង្គាប់ឱ្យកសាងព្រះសថូបប្រមាណ ត្រឹមស្មង[1]ហើយ ឱ្យធ្វើសក្ការៈធំ ដើម្បីត្រូវការលើកព្រះធាតុឡើង ។

## ព្រះធាតុសម្តែងបាដិហារ្យដល់មហាជន

ពួកនគរទាំងអស់ និងអ្នកជនបទប្រជុំគ្នាហើយ ដើម្បីសរសើរការឆ្លងព្រះធាតុ ។ ក៏កាលពួកមហាជននោះប្រជុំគ្នាហើយ ព្រះធាតុរបស់ព្រះទសពល បានហោះឡើងកាន់អាកាសប្រមាណប្រវែង ៧ ដើមត្នោត អំពីពោងដំរី សម្តែងយមកបាដិហារ្យ ។ ធារទឹកនិងអណ្តាតភ្លើងមានរស្មី ៦ ពណ៌, ក៏ជះសាយចេញពីព្រះធាតុទាំងឡាយនោះ ៗ ។ បានមានបាដិហារ្យដូចទីងបាដិហារ្យ ដែលព្រះមានព្រះភាគទ្រង់សម្តែងទៀបគល់ស្វាយ ជិតក្រុងសាវត្ថី ។ ក៏ឯបាដិហារ្យនោះ មិនមែនដោយអានុភាពរបស់ព្រះថេរៈ មិនមែនដោយអានុភាពរបស់ទេវតាឡើយ តាមពិត កើត

១. ដីកា. ត្រឹមទីតម្កល់ផ្កា ។

ដោយពុទ្ធានុភាពប៉ុណ្ណោះ ។

បានឮថា ព្រះមានព្រះភាគ កាលទ្រង់នៅមានព្រះជន្មនុ៎ះឯង ទ្រង់បានអធិដ្ឋានថា "កាលតថាគតបរិនិព្វានហើយ យមកបាដិហារ្យចូរមានក្នុងថ្ងៃប្រតិស្ឋានព្រះធាតុដងកាំបិតខាងស្តាំរបស់យើង លើទីតាំងបរិភោគចេតិយរបស់ព្រះពុទ្ធអង្គមុន ៗ ៣ អង្គ ខាងទិសទក្សិណនៃអនុរាធបុរីក្នុងកោះតម្ពបណ្ណិទ្វីប" ដូច្នេះ ។

ព្រះពុទ្ធជាអចិន្ត្រៃយ៍ ព្រះធម៌របស់ព្រះពុទ្ធក៏ជាអចិន្ត្រៃយ៍ វិបាករបស់ពួកជនអ្នកជ្រះថ្លាក្នុងព្រះពុទ្ធ និង ព្រះគុណរបស់ព្រះពុទ្ធដែលជាអចិន្ត្រៃយ៍ ក៏ជាអចិន្ត្រៃយ៍ ដោយន័យដូចពោលមកដូច្នេះឯង ។

## ព្រះពុទ្ធធ្លាប់ស្តេចយាងទៅកោះលង្កា

បានជ្រាបថា ព្រះសម្មាសម្ពុទ្ធ បានស្តេចយាងទៅកាន់កោះនេះ (កោះលង្កា) ដល់ ៣ ដង សូម្បីក្នុងគ្រានៅមានព្រះជន្ម គឺ គ្រាដំបូងស្តេចមកព្រះអង្គតែមួយប៉ុណ្ណោះ ដើម្បីទូន្មានយក្ខ គ្រាទូន្មានយក្ខហើយទ្រង់តាំងការរក្សាកោះតម្ពបណ្ណិទ្វីប ស្តេចជុំវិញកោះ ៣ ជុំវិញ តាំងព្រះទ័យថា "កាលយើងបរិនិព្វានហើយ សាសនារបស់តថាគត នឹងប្រតិស្ឋាននៅលើកោះនេះ" ។

គ្រាទីពីរ ស្ដេចមកព្រះអង្គតែមួយដូចគ្នា ដើម្បីត្រូវការទូន្មានស្ដេចនាគអ្នកជាអ៊ំនិងជាក្មួយនឹងគ្នា គ្រាទូន្មាននាគទាំងនោះហើយ បានស្ដេចយាងទៅ ។ គ្រាទីបី ស្ដេចមកមានភិក្ខុ ៥០០ រូបជាបរិវារ ប្រថាប់អង្គុយចូលនិរោធសមាបត្តិក្នុងទីតាំងមហាចេតិយ ទីតាំងថូបារាមចេតិយ ដែលប្រតិស្ឋានដើមមហាពោធិព្រឹក្ស ទីតាំងមុតិង្គណចេតិយ ទីតាំងទីឃវាបីចេតិយ និងទីតាំងកល្យាណិយចេតិយ ។ ការមកដោយព្រះសរីរធាតុគ្រានេះ ជាលើកទី ៤ របស់ព្រះមានព្រះភាគអង្គនោះ ។ ក៏ឯដែលឈ្មោះថា ឱកាសតិចមួយលើផែនដីកោះតម្ពបណ្ណិទ្វីប ដែលតំណក់ទឹកខ្មាតខ្ចាយចេញចាកព្រះសរីរធាតុរបស់ព្រះមានព្រះភាគនោះ មិនពាល់ត្រូវមិនមានទេ ។ ព្រះសរីរធាតុនោះ របស់ព្រះមានព្រះភាគអង្គនោះ ញ៉ាំងកម្ដៅរបស់ផ្ទៃផែនដីកោះតម្ពបណ្ណិទ្វីប ឱ្យស្ងប់រម្ងាប់ដោយគ្រាប់ភ្លៀងសម្ដែងបាដិហារ្យដល់មហាជនហើយ ចុះប្រតិស្ឋាននៅលើក្បាលរបស់ព្រះរាជា ដោយប្រការយ៉ាងនេះ ។ ព្រះរាជាទ្រង់សម្គាល់ការបានអត្តភាពជាមនុស្ស ដែលមានផលទ្រង់ធ្វើសក្ការៈធំ ឱ្យបញ្ចុះព្រះធាតុហើយ ព្រមដោយការបញ្ចុះព្រះធាតុ បានកើតមានការញាប់ញ័រផែនដី ។

## កុលបុត្រអ្នកកោះចេញបួសក្នុងព្រះសាសនា

ក៏ឯរាជកុមារព្រះនាមថា អភ័យជាព្រះកនិដ្ឋភាតារបស់ព្រះរាជា ញ៉ាំងព្រះហឫទ័យឱ្យជ្រះថ្លាក្នុងបាដិហារ្យនៃព្រះធាតុនោះហើយ ទ្រង់ព្រះផ្នួសព្រមនឹងបុរសប្រមាណមួយពាន់ ។ ពួកកុមារ ៥០០ នាក់ចេញបួសអំពីស្រុកវេតាលិ, អំពីពួកស្រុក ដូចស្រុកទ្វារមណ្ឌលជាដើម ពួកកុមារចេញបួសក្នុងស្រុកមួយ ៗ៥០០ នាក់ ដូចគ្នា ។ ពួកកុមារច្រើនរយនាក់ចេញបួសអំពីខាងក្នុងក្រុងនិងខាងក្រៅក្រុង រួមទាំងអស់ជាភិក្ខុ ៣ ម៉ឺនរូប ។ ក៏កាលព្រះសថូបសម្រេចហើយ ព្រះរាជា រាជអាមាត្យ និងព្រះទេវីបានធ្វើការបូជាយ៉ាងគួរឱ្យចម្លែកមនុស្សមួយផ្នែក ៗ សូម្បីដល់ពួកទេវតានាគនិងយក្ខ ។ មួយទៀត កាលការបូជាព្រះធាតុ( និង )ព្រះធាតុចេតិយរួចហើយ ព្រះមហិន្ទត្ថេរទៅកាន់ឧទ្យានមេឃវ័ន ដើម្បីសម្រេចការនៅទុំះឯង ។

## ព្រះនាងអនុឡាទេវីទ្រង់មានព្រះបំណងនឹងបួស

សម័យនោះឯង ព្រះនាងអនុឡាទេវី មានព្រះបំណងនឹងបួសក្រាបទូលចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ព្រះនាងហើយ បានត្រាស់ព្រះតម្រាស់នេះចំពោះព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន ព្រះនាងអនុឡាទេវីមានព្រះបំណងនឹងបួស, សូមលោកម្ចាស់ឱ្យព្រះនាងបួសចុះ" ។ ព្រះថេរៈថ្វាយព្រះពរថា "មហាបពិត្រ ការឱ្យមាតុគ្រាមបួស

មិនសមគួរដល់ពួកអាត្មាភាព, តែក្នុងនគរបាតលីបុត្ត មានព្រះថេរីនាមថា សង្ឃមិត្តា ជាប្អូនស្រីរបស់អាត្មាភាព, សូមព្រះអង្គទ្រង់បានមេត្តាឱ្យនិមន្ត ព្រះថេរីនោះមក មហាបពិត្រ ក៏ឯពោធិព្រឹក្ស (ដើមឈើជាទីត្រាស់ដឹង) របស់ព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ទាំង ៣ ព្រះអង្គ បានប្រតិស្ឋាននៅត្រង់កោះនេះ, ពោធិព្រឹក្សដែលបញ្ចេញបណ្តាញគឺ រស្មីថ្មី ៗ របស់ព្រះមានព្រះភាគនៃយើង ក៏គួរប្រតិស្ឋាននៅលើកោះនេះ ព្រោះដូច្នោះ ព្រះអង្គគប្បីបញ្ជូនព្រះរាជសាសន៍ទៅនិមន្ត ដោយប្រការដែលព្រះថេរីសង្ឃមិត្តា នឹងអារាធនាមែកពោធិព្រឹក្សមកផង" ។

## ព្រះរាជាបញ្ជូនទូតទៅកាន់ជម្ពូទ្វីប

ព្រះរាជាទ្រង់ទទួលពាក្យរបស់ព្រះថេរៈថា "ល្អណាស់ លោកម្ចាស់" ដូច្នេះ ទ្រង់ប្រឹក្សានឹងពួកអាមាត្យហើយ ត្រាស់ចំពោះអាមាត្យអ្នកជាក្មួយរបស់ព្រះអង្គនាមថា អរិដ្ឋៈថា "លោកនឹងអាចទៅកាន់នគរបាតលីបុត្ត និមន្តព្រះម៉ែម្ចាស់សង្ឃមិត្តាថេរីមកព្រមទាំងមហាពោធិព្រឹក្សឬ ?" អរិដ្ឋអាមាត្យក្រាបទូលថា "អាចសម្មតិទេព បើព្រះអង្គនឹងទ្រង់អនុញ្ញាតឱ្យទូលបង្គំបួស" ។ ព្រះរាជាត្រាស់ថា "ទៅចុះ អ្នកឯងនាំព្រះថេរីមកហើយ ចូរបួសចុះ" ។ អាមាត្យនោះកាន់យកព្រះរាជសាសន៍និងថេរសាសន៍ហើយ ទៅកាន់កំពង់ឈ្មោះជម្ពុកោលបដ្តនៈ តែមួយថ្ងៃ

ប៉ុណ្ណោះ ដោយកម្លាំងនៃការអធិដ្ឋានរបស់ព្រះថេរៈ ចុះទូកឆ្លងសមុទ្រទៅកាន់ក្រុងបាតលីបុត្តនោះឯង ។ ចំណែកព្រះនាងអនុឡាទេវី ព្រមដោយស្រី ៗ ៥០០ នាក់ និងស្រីក្នុងព្រះរាជវាំង ៥០០ នាក់ទៀត សមាទានសីល ១០ គ្រងសំពត់កាសាវពស្ត្រ ឱ្យសាងសំណាក់អាស្រ័យក្នុងចំណែកមួយនៃព្រះនគរ ហើយសម្រេចការនៅអាស្រ័យ ។

## ទូតថ្វាយព្រះរាជសាសន៍និងថេរសាសន៍

ចំណែកអរិដ្ឋអាមាត្យក៏ទៅដល់ក្នុងថ្ងៃនោះឯង បានក្រាបទូលថ្វាយព្រះរាជសាសន៍ និងក្រាបទូលយ៉ាងនេះថា "បពិត្រសម្មតិទេព ព្រះមហិន្ទត្ថេរព្រះឱរសរបស់ព្រះអង្គ ទូលយ៉ាងនេះថា បានឮថា ព្រះទេវីព្រះនាមថា អនុឡា ព្រះជាយារបស់ព្រះកនិដ្ឋភាតានៃព្រះបាទទេវានម្បិយតិស្សជាសម្លាញ់របស់ព្រះអង្គ មានព្រះបំណងនឹងបួស ដើម្បីឱ្យព្រះនាងបានបួស សូមព្រះអង្គទ្រង់បានព្រះករុណាមេត្តា បញ្ជូនព្រះម៉ែម្ចាស់សង្ឃមិត្តាថេរី និងដើមមហាពោធិព្រឹក្សទៅជាមួយនឹងព្រះម៉ែម្ចាស់ផង" ។ អរិដ្ឋអាមាត្យគ្រាទូលថ្វាយថេរសាសន៍ហើយ ចូលគាល់ព្រះថេរីសង្ឃមិត្តាក្រាបទូលយ៉ាងនេះថា "បពិត្រព្រះម៉ែម្ចាស់ ព្រះមហិន្ទត្ថេរ ជា ម្ចាស់បងរបស់ព្រះម៉ែម្ចាស់ បញ្ជូនខ្ញុំព្រះករុណាមកក្នុងសំណាក់របស់ព្រះម៉ែម្ចាស់ ដោយបង្គាប់ថា ព្រះនាងអនុឡាទេវី ព្រះជាយារបស់ព្រះកនិដ្ឋភាតានៃព្រះ

បាទទេវានម្បិយតិស្ស ព្រមទាំងស្រី ៗ ៥០០ នាក់ និងស្រីក្នុងរាជវាំង ៥០០ នាក់ មានសេចក្ដីប្រាថ្នានឹងបួស សូមព្រះម៉ែម្ចាស់ទៅឱ្យព្រះនាងអនុឡាទេវីនោះបួស" ។ ក្នុងវេលានោះឯង ព្រះថេរីនោះ ប្រញាប់ប្រញាល់ទៅកាន់រាជសំណាក់ ហើយក្រាបទូលយ៉ាងនេះថា "បពិត្រមហារាជ ព្រះមហិន្ទត្ថេរ ជាម្ចាស់បងរបស់អាត្មាភាព បញ្ជូនដំណឹងមកយ៉ាងនេះថា បានឮថា ព្រះនាងអនុឡាទេវី ព្រះជាយារបស់ព្រះកនិដ្ឋភាតានៃព្រះរាជា ព្រមដោយស្រី ៗ ៥០០ នាក់ និងស្រីក្នុងរាជវាំង ៥០០ នាក់ មានសេចក្ដីប្រាថ្នានឹងបួស នៅរង់ចាំការនិមន្តមករបស់អាត្មា បពិត្រមហារាជ អាត្មាប្រាថ្នានឹងទៅកាន់កោះតម្ពបណ្ណិទ្វីប" ។ ព្រះរាជាត្រាស់ថា "បពិត្រព្រះនាង ព្រះមហិន្ទត្ថេរជាកូនរបស់យើង និងសុមនសាមណេរចៅរបស់យើង ក៏ទៅកាន់កោះតម្ពបណ្ណិទ្វីប ធ្វើឱ្យយើងដូចជាមនុស្សដាច់ដៃ ខ្ញុំព្រះករុណានោះ កាលមិនឃើញកូន និងចៅទាំងនោះ ក៏កើតសេចក្ដីសោកសៅ កាលឃើញមុខព្រះនាងក៏បាត់សោក កុំឡើយព្រះនាង ព្រះនាងកុំទៅ" ។ ព្រះថេរីទូលថា "បពិត្រមហារាជ ពាក្យរបស់ម្ចាស់បងនៃអាត្មាធ្ងន់ណាស់ សូម្បីព្រះនាងអនុឡាខត្តិយានី ដែលស្ត្រីទាំងមួយពាន់នាក់ហែហមហើយ ប្រាថ្នាចំពោះបព្វជ្ជានៅរង់ចាំអាត្មា អាត្មានឹងត្រូវទៅ" ព្រះរាជាត្រាស់ថា "ព្រះនាង បើដូច្នោះ ព្រះនាងអារាធនាដើមមហាពោធិព្រឹក្សទៅផងចុះ" ។

## ព្រះបាទអសោកបញ្ជូនមហាពោធិព្រឹក្សទៅកោះលង្កាមុន

សួរថា ព្រះរាជាបានដើមមហាពោធិព្រឹក្សមកពីណា ? ឆ្លើយថា បានជ្រាបថា ព្រះរាជាទ្រង់មានព្រះបំណងនឹងបញ្ជូនដើម មហាពោធិព្រឹក្សទៅកាន់កោះលង្កា កាលសុមនសាមណេរមិនទាន់មក ដើម្បីត្រូវការទទួលយកព្រះធាតុ មុនពេលដែលព្រះសង្ឃមិត្តាថេរីទៅនោះឯង ក៏ទ្រង់ព្រះត្រិះរិះថា "យើងនឹងបញ្ជូនដើមមហាពោធិព្រឹក្ស ដែលមិនគួរនឹងកាត់ដោយសស្ត្រាទៅបានយ៉ាងណាហ្ន៎" កាលមិនឃើញឧបាយ ទើបត្រាស់សួរអាមាត្យឈ្មោះមហាទេវ ។ អាមាត្យនោះក្រាបទូលថា បពិត្រសម្មតិទេព មានភិក្ខុបណ្ឌិតជាច្រើន ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ បន្ទាប់ឱ្យត្រៀមភត្ត ដើម្បីភិក្ខុសង្ឃ ក្នុងទីបំផុតនៃភត្តកិច្ចបានត្រាស់សួរព្រះសង្ឃថា "លោកម្ចាស់ដ៏ចម្រើន ដើមមហាពោធិព្រឹក្សរបស់ព្រះមានព្រះភាគ គួរទៅកាន់កោះលង្កាឬទេហ្ន៎ ?" ព្រះសង្ឃប្រគល់ឱ្យជាភារៈរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរ ។ ព្រះថេរៈថ្វាយព្រះពរថា "ដើមមហាពោធិព្រឹក្សគួរទៅកាន់កោះលង្កាពិត មហាបពិត្រ" ដូច្នេះហើយ បានទូលប្រាប់មហាអធិដ្ឋាន ៥ ប្រការរបស់ព្រះមានព្រះភាគ ។

## មហាអធិដ្ឋាន ៥ ប្រការ របស់ព្រះមានព្រះភាគ

មហាអធិដ្ឋាន ៥ ប្រការដូចម្តេច ? គឺ បានជ្រាបថា ព្រះមានព្រះភាគទ្រង់ផ្ទំលើគ្រែបរិនិព្វាន ទ្រង់បានអធិដ្ឋានថា "ដើម្បីត្រូវការឱ្យដើមមហាពោធិព្រឹក្ស ប្រតិស្ឋាននៅក្នុងលង្កាទ្វីប ព្រះបាទអសោកមហារាជនឹងស្តេចមកទទួលយកដើមមហាពោធិព្រឹក្ស ក្នុងវេលានោះ មែកមហាពោធិព្រឹក្សខាងទិសទក្សិណ ចូរដាច់ឯងតែម្តង ហើយប្រតិស្ឋាននៅក្នុងផើងមាស" នេះជាអធិដ្ឋានប្រការទីមួយ ។ ទ្រង់អធិដ្ឋានថា "ក៏ក្នុងវេលាប្រតិស្ឋាននៅក្នុងផើងមាសនោះ មហាពោធិព្រឹក្សចូរអណ្តែតចូលទៅកាន់ស្រទាប់ហិមវលាហក (ពពកត្រជាក់)តាំងនៅ" នេះជាអធិដ្ឋានប្រការទីពីរ ។ ទ្រង់អធិដ្ឋានថា "ក្នុងថ្ងៃទី ៧ ដើមមហាពោធិព្រឹក្សចូរអណ្តែតចុះមកពីស្រទាប់ហិមវលាហក តាំងនៅក្នុងផើងមាស បញ្ចេញឆព្វណ្ណរង្សីអំពីស្លឹកនិងផ្លែទាំងឡាយ" នេះជាអធិដ្ឋានប្រការទីបី ។ ទ្រង់អធិដ្ឋានថា "ព្រះធាតុដងកាំបិតខាងស្តាំ ចូរធ្វើយមកបាដិហារ្យក្នុងថ្ងៃប្រតិស្ឋាននៅឯព្រះចេតិយក្នុងថូបារាម" នេះជាអធិដ្ឋានប្រការទីបួន ។ ទ្រង់អធិដ្ឋានថា "ព្រះធាតុរបស់យើងប្រមាណមួយទោណៈ ក្នុងកោះលង្កានេះឯង ក្នុងវេលាប្រតិស្ឋាននៅក្នុងមហាចេតិយ ចូរប្លែងភេទជាព្រះពុទ្ធហើយហោះឡើងកាន់អាកាស ធ្វើយមកបាដិហារ្យ" នេះជាអធិដ្ឋានប្រការទីប្រាំ ។

# វិស្សុកម្មទេវបុត្របន្លំខ្លួនជាជាងនិម្មិតផើងមាស

ព្រះរាជាទ្រង់ស្តាប់មហាអធិដ្ឋាន ៥ សេចក្តីនេះហើយ មានព្រះហឫទ័យជ្រះថ្លាបង្គាប់ឱ្យចាត់ការជម្រះមក តាំងពីក្រុងបាតលិបុត្តរាបដល់ដើមមហាពោធិព្រឹក្សហើយ ឱ្យនាំមាសជាច្រើនចេញមក ដើម្បីត្រូវការឱ្យសាងផើងមាស ។ ក្នុងខណៈនោះឯង វិស្សុកម្មទេវបុត្រ ជ្រាបព្រះរាជហឫទ័យបាននិមិត្តជាជាងមាស ឈរនៅចំព្រះភក្រ្ត (របស់ព្រះរាជា) ។ ព្រះរាជាទតឃើញគេហើយ ទើបត្រាស់ថា "អ្នកឯងចូរយកមាសនេះទៅធ្វើផើង" ។ គេទូលថា "បពិត្រសម្មតិទេព សូមព្រះអង្គទ្រង់ប្រាប់ខ្នាតឱ្យទូលបង្គំបានដឹងផង" ។ ព្រះរាជាត្រាស់ថា "អ្នកនុ៎ះឯងជ្រាប និងចូរធ្វើឱ្យបានខ្នាត" ។ គេទូលថា "ល្អណាស់ សម្មតិទេព ទូលបង្គំនឹងធ្វើ" ទើបកាន់មាសយកដៃស្ទាបអង្អែល ដោយអានុភាពរបស់ខ្លួន និមិត្តផើងមាស វាស់ដោយជុំវិញប្រមាណ ៩ហត្ថ កំពស់ ៥ហត្ថ ទទឹង ៣ហត្ថ កម្រាស់ ៨ ធ្នាប់ កណ្តាប់មាត់មានខ្នាតប៉ុនគល់ភ្លុកដំរី ។

# ស្ដេចយាងទៅកាន់ដើមមហាពោធិព្រឹក្ស

គ្រានោះ ព្រះរាជា ស្ដេចចេញចាកនគរបាតលីបុត្តដោយសេនាធំប្រវែងប្រមាណ ៧ យោជន៍ ទទឹងប្រមាណ ៣ យោជន៍ នាំយកព្រះអរិយសង្ឃ ស្ដេចបានយាងទៅកាន់ទីជិតដើមមហាពោធិព្រឹក្ស ។ សេនាលោមព័ទ្ធដើមមហាពោធិព្រឹក្ស ដែលមានទង់ជ័យនិងទង់ផ្ទាំងសំពត់លើកឡើងទុកហើយ វិចិត្រដោយរតនៈផ្សេង ៗ ប្រដាប់ដោយគ្រឿងអលង្ការជាច្រើន ដេរដាស់ទៅដោយផ្កាឈើមានប្រភេទផ្សេង ៗ ប្រគំដោយគ្រឿងដូរ្យតន្ត្រីច្រើនចំរុះ ។ ព្រះរាជានិមន្តយកព្រះមហាថេរៈអ្នកជាគណៈបាមោក្ខ ប្រមាណមួយពាន់រូប ហើយឱ្យព្រះរាជាអ្នកបានទទួលការអភិសេកទូទាំងជម្ពូទ្វីបចំនួនមួយពាន់អង្គ ហែហមព្រះអង្គ និងដើមមហាពោធិព្រឹក្ស បានប្រថាប់ឈរក្បែរគល់ដើមមហាពោធិព្រឹក្សទតមើលដើមមហាពោធិព្រឹក្ស ។ ចំណែកដែលសល់វៀរដើម (ពីគល់ដល់មែក) របស់មហាពោធិព្រឹក្ស និងចំណែកនៃមែកធំខាងទិសទក្សិណប្រមាណ ៤ ហត្ថមិនប្រាកដឱ្យឃើញ ព្រះរាជាទ្រង់ឃើញបាដិហារ្យនោះ កើតបីតិបាមោជ្ជៈត្រាស់ដល់ភិក្ខុសង្ឃថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឃើញបាដិហារ្យនេះហើយ ត្រេកអរ នឹងបូជាដើមមហាពោធិព្រឹក្សដោយរាជសម្បត្តិក្នុងទ្វីប" ទើបបានថ្វាយការអភិសេក ។

# ព្រះរាជាទ្រង់ធ្វើសច្ចាធិដ្ឋាន

គ្រានោះ ព្រះរាជាទ្រង់បូជា(ដើមមហាពោធិព្រឹក្ស)ដោយផ្កាឈើ និងរបស់ក្រអូបជាដើម ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំក្នុងទិសទាំង ៨ ស្តេចក្រោកឡើងហើយ ប្រថាប់ឈរផ្គងអញ្ជលី មានព្រះបំណងនឹងយាង យកដើមមហាពោធិព្រឹក្ស ដោយការធ្វើពាក្យសត្យៈ បង្គាប់ឱ្យតម្កល់ផើង មាសខាងលើតាំង ដែលធ្វើដោយរតនៈគ្រប់យ៉ាង ដែលតម្កល់ឱ្យខ្ពស់ឡើង តាំងពីផែនដីដរាបដល់មែកផ្ទែកស្តាំរបស់មហាពោធិព្រឹក្សហើយ ស្តេចឡើងលើរតនបិឋទ្រង់កាន់ព្រះសុវណ្ណតុលិកា (ជក់មាស)ធ្វើស្នាម គូសដោយមនោសិលា ហើយទ្រង់បានធ្វើសច្ចវចនកិរិយាថា "បើដើម មហាពោធិព្រឹក្សគួរប្រតិស្ឋាននៅក្នុងកោះលង្កា និងបើថា ខ្ញុំព្រះករុណា គប្បីជាអ្នកអស់សេចក្តីសង្ស័យក្នុងព្រះពុទ្ធសាសនាសោត សូមឱ្យដើម មហាពោធិព្រឹក្សប្រតិស្ឋាននៅក្នុងផើងមាសដោយខ្លួនឯងចុះ" ។ ព្រមគ្នា នឹងការដែលទ្រង់ធ្វើសច្ចវចនៈ មែកពោធិព្រឹក្សដាច់ត្រង់ដែលទ្រង់យក មនោសិលាកំណត់ទុក ហើយតាំងនៅខាងលើផើងមាស ដែលពេញ ដោយភក់ផ្សំដោយរបស់ក្រអូប ។ ដើមពោធិព្រឹក្សនោះ មានដើមកម្ពស់ ១០ ហត្ថ មែកធំ ៥ មែក ប្រមាណ ៤ ហត្ថ ប្រដាប់ដោយផ្លែ ៥ ផ្លែ ប៉ុន ៗ គ្នា ។ ចំណែកមែកតូច ៗ មានចំនួនមួយពាន់មែក ។ គ្រានោះ

ព្រះរាជាទ្រង់កំណត់កាត់ស្នាមគូសក្នុងប្រទេស (ទី, ប្រវែង) ប្រមាណ ៣ ធ្នាប់ ខាងលើស្នាមគូសពីដើម ។ ខណៈនោះឯង ឫសធំ ១០ សរសៃ ដុះជាពន្លកដូចតំណក់ទឹកចេញចាកស្នាមគូសនោះ ។ ព្រះរាជាទ្រង់កំណត់កាត់ស្នាមគូសដទៃ ៗ ៩ កន្លែងទៀត ក្នុងទីបន្តបន្ទាប់ទៅ ប្រវែង ៣ ធ្នាប់ ៗ ។ ឫស ៩០ ឫសដុះជាបណ្តុល ដូចជាតំណក់ទឹកចេញចាកស្នាមគូសទាំងនោះ ស្នាមមួយ ៗ មានឫស ១០ សរសៃ ។ ឫសធំ ១០ សរសៃដំបូង ដុះចេញមកប្រមាណ ៤ ធ្នាប់ ។ ឫស ៩០ សរសៃ ក្រៅនេះ ក៏ដុះជាប់ប្រទាក់គ្នា ដូចជារោមគោត្រង់ក្រយៅ ។ ព្រះរាជា ប្រថាប់ឈរលើបំផុតតាំងរតនៈនុ៎ះឯង ទតឃើញបាដិហារ្យប្រមាណប៉ុណ្ណោះ ទ្រង់បានផ្គងអញ្ជលីបន្លឺវាចាលាន់ឮ ។ ភិក្ខុចំនួនច្រើនពាន់រូប ក៏បានស្រែកបន្លឺសាធុការ ។ រាជសេនាទាំងអស់ ក៏បានបន្លឺសំឡេងកងរំពង ។ ទង់សំពត់ដែលលើកឡើងទុកទាំងសែនទង់ បានរលាស់បោកបក់រវិច ។ ពួកទេវតាតាំងពីភូម្មដ្ឋកទេវតា បានឱ្យសាធុការប្រព្រឹត្តទៅ ដរាបដល់ពួកទេវព្រហ្មកាយិកា ។

កាលព្រះរាជា ទតឃើញបាដិហារ្យនេះ មានព្រះវរកាយដែលបីតិពាល់ត្រូវមិនមានចន្លោះ នៅប្រថាប់ឈរផ្គងអញ្ជលីនុ៎ះឯង, មហាពោធិព្រឹក្សក៏បានប្រតិស្ឋាននៅក្នុងផើងមាស ដោយចំនួនឫសទាំងរយ ។ ឫសធំ ១០ ឫសបានចាក់ចុះទល់ផ្ទៃផើងមាស ។ ឫសដែលនៅសល់ ៩០

ឫសក៏ចម្រើនលូតលាស់ល្អឡើងដោយលំដាប់ ចាក់ចុះត្រាំទៅក្នុងភក់ដែលផ្សំដោយរបស់ក្រអូប ៗ កាលដើមមហាពោធិព្រឹក្ស គ្រាន់តែប្រតិស្ឋាននៅក្នុងផើងមាសយ៉ាងនោះហើយ មហាប្រថពីក៏ញាប់ញ័រ ៗ ពួកភេរីរបស់ពួកទេវតាបន្លឺលាន់ឮទៅក្នុងអាកាស ៗ ភាពកោលាហលដូចគ្នា តាំងពីផែនបឋវីដរាបដល់ព្រហ្មលោកក៏បានគឹកកងដូចគ្នាដែរ ព្រោះសេចក្ដីទោរទន់ទៅមកនៃពួកបព្វត ព្រោះសំឡេងសាធុការនៃពួកទេវតា ព្រោះការធ្វើសំឡេងគ្រហឹមនៃពួកយក្ខ ព្រោះការពោលសរសើរនៃពួកអសុរ ព្រោះការទះដៃនៃពួកព្រហ្ម ព្រោះការលាន់ឮនៃពួកផ្គរ ព្រោះការស្រែកនៃពួកសត្វបួនជើង ព្រោះការរងាវនៃពួកបក្សី ( ទិង ) ព្រោះការឈ្លាសវៃវៀងៗខ្លួន នៃពួកតូរ្យតន្ត្រីទាំងពួង ៗ ឆព្វណ្ណរង្សីផ្សាយចេញអំពីផ្លែមួយក្នុងមែកទាំង ៥ ហើយក៏ជះផ្សាយឡើងទៅដរាបដល់ព្រហ្មលោក ដូចធ្វើចក្រវាឡទាំងអស់ ឱ្យតជាប់គ្នាដូចបង្កង់ផ្ទុះកែវ ដូច្នោះ ៗ

## មែកមហាពោធិព្រឹក្ស អណ្ដែតឡើងទៅនៅលើផ្ទៃមេឃ

ចាប់តាំងអំពីខណៈនោះទៅ ដើមមហាពោធិព្រឹក្សក៏ចូលទៅកាន់ស្រទាប់ពពក ដែលពេញទៅដោយសន្សើម ហើយតាំងនៅអស់ ៧ ថ្ងៃ ៗ អ្នកណា ៗ ក៏មិនឃើញដើមមហាពោធិព្រឹក្ស ៗ ព្រះរាជាស្ដេចចុះពីបិឋរតនៈហើយ ទ្រង់ត្រាស់ឱ្យធ្វើការបូជាមហាពោធិព្រឹក្សអស់ ៧

ថ្ងៃ ។ ក្នុងថ្ងៃទី ៧ សនៀមនិងស្ត្រីទាំងឡាយក៏វិលត្រឡប់អំពីទិសទាំងពួងចូលទៅកាន់ដើមមហាពោធិព្រឹក្សនុ៎ះឯង ។

កាលបន្ទប់ចក្រវាឡ ប្រាសចាកហិមវលាហក ភ្លឺស្រឡះហើយ ដើមមហាពោធិព្រឹក្សដែលមានដើម មែកធំនិងមែកតូចបរិបូរណ៍ ដែលប្រដាប់ទៅដោយផ្លែទាំង ៥ បានប្រាកដតាំងនៅក្នុងផើងមាសនុ៎ះឯង ។

ព្រះរាជាទតឃើញដើមមហាពោធិព្រឹក្សហើយ មានព្រះបីតិបាមោជ្ជៈដែលបាដិហារ្យទាំងនោះឱ្យកើតហើយ ទើបទ្រង់ត្រិះរិះថា "យើងនឹងបូជាដើមមហាពោធិព្រឹក្សជំទង់ ដោយរាជសម្បត្តិក្នុងសាកលជម្ពូទ្វីប" ដូច្នេះហើយ ទ្រង់បានប្រទានការអភិសេក (ដល់ដើមមហាពោធិព្រឹក្សនោះ) ហើយបានប្រថាប់ឈរត្រង់ឋានដើមមហាពោធិព្រឹក្សនុ៎ះឯង អស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃបវារណាខែកត្តិកាដើម វេលាល្ងាច ដើមមហាពោធិព្រឹក្សក៏ប្រតិស្ឋាននៅក្នុងផើងមាសមុន ។ ក្រោយពីនោះមក ព្រះរាជាទ្រង់នៅសម្រាក អស់សប្ដាហ៍ដែលមហាពោធិព្រឹក្សនៅក្នុងស្រទាប់ពពក និងសប្ដាហ៍ដែលព្រះរាជទានអភិសេក ទើបស្ដេចចូលទៅកាន់ព្រះនគរបាតលីបុត្ត ក្នុងថ្ងៃឧបោសថនៃកាឡបក្ខតែមួយថ្ងៃប៉ុណ្ណោះ, ក្នុងថ្ងៃបាដិបទ (មួយរោច) នៃជុណ្ហបក្ខខែកត្តិកា ទ្រង់ទុកដើមមហាពោធិព្រឹក្ស ក្បែរគល់សាលព្រឹក្សធំទិសខាងកើត ។

## មហាពោធិព្រឹក្សបែកពន្លកចេញថ្មី

ក្នុងថ្ងៃទី ១៧ តាំងពីថ្ងៃដែលមហាពោធិព្រឹក្សប្រតិស្ឋាននៅក្នុងផើងមាសពន្លកថ្មី ៗ នៃដើមមហាពោធិព្រឹក្សក៏បានប្រាកដឡើង ។ ព្រះរាជា សូម្បីទតឃើញពន្លកទាំងនោះហើយ ក៏ទ្រង់ជ្រះថ្លា កាលនឹងទ្រង់បូជាមហាពោធិព្រឹក្សដោយរាជសម្បត្តិទៀត ទ្រង់បានថ្វាយការអភិសេកក្នុងសាកលជម្ពូទ្វីប ។ សុមនសាមណេរទៅដើម្បីទទួលយកព្រះធាតុ ក្នុងថ្ងៃពេញបូណ៌មីខែកត្តិក (គឺថ្ងៃពេញបូណ៌មី ខែ១២) បានឃើញការបូជាដល់ដើមមហាពោធិព្រឹក្សជាមហោស្រព ខែកត្តិក ។

ព្រះបាទអសោកមហារាជ ទ្រង់សំដៅដល់ដើមពោធិព្រឹក្សដែលនាំមកអំពីមហាពោធិមណ្ឌល ហើយផ្សាំទុកត្រង់នគរបាតលីបុត្តដោយន័យដូចពោលមកនេះ ទើបត្រាស់ (ចំពោះព្រះនាងសង្ឃមិត្តាថេរី) ថា ព្រះនាង បើដូច្នោះសូមឱ្យព្រះនាងទទួលយកដើមមហាពោធិព្រឹក្សទៅផងចុះ” ។ ព្រះនាងសង្ឃមិត្តាថេរីនោះ ទូលទទួលថា “សាធុ” ។

# ព្រះបាទអសោកតាំងត្រកូលផ្សេងៗ រក្សាមហាពោធិព្រឹក្ស

ព្រះរាជា ទ្រង់ព្រះរាជទានត្រកូលទេវតា ១៨, ត្រកូលអាមាត្យ ៨, ត្រកូលព្រាហ្មណ៍ ៨, ត្រកូលកុដុម្ពី ៨, ត្រកូលចិញ្ចឹមគោ ៨, ត្រកូលខ្លាជំបង ៨, និងត្រកូលអ្នកកាលិង្គ: ៨, ទុកដើម្បីរក្សាដើមមហាពោធិព្រឹក្ស និងព្រះរាជទានឆ្នាំងមាស ៨ ឆ្នាំងប្រាក់ ៨ ទុកដើម្បីស្រោចទឹក (ដើមមហាពោធិព្រឹក្ស) ហើយទ្រង់ឱ្យលើកមហាពោធិព្រឹក្សឡើងកាន់ទូក ព្រមដោយបរិវារនេះក្នុងទន្លេគង្គា ។ ចំណែកព្រះអង្គឯងស្តេចចេញចាកព្រះនគរ ឆ្លងព្រៃឈ្មោះវិជ្ឈាដវី ហើយស្តេចយាងទៅដល់កំពង់ឈ្មោះតម្ពលិត្តី អស់រយ:កាល ៧ ថ្ងៃ ដោយលំដាប់ ។ ក្នុងចន្លោះមក ពួកទេវតា នាគ និងមនុស្ស បាននាំគ្នាបូជាមហាពោធិព្រឹក្សយ៉ាងមហោឡារិក ។ ចំណែកព្រះរាជា ទ្រង់តម្កល់មហាពោធិព្រឹក្សទុកលើប្រាំងសមុទ្រ ៧ ថ្ងៃ ហើយទ្រង់បានថ្វាយរាជសម្បត្តិយ៉ាងធំក្នុងសាកលជម្ពូទ្វីប ។ គ្រានេះ ជាការទ្រង់ថ្វាយរាជសម្បត្តិក្នុងជម្ពូទ្វីបលើកទី ៣ ដល់ដើមមហាពោធិព្រឹក្សនោះ ។

## ព្រះបាទអសោកទ្រង់លុយទឹកបញ្ជូនមហាពោធិព្រឹក្សទៅកោះលង្កា

ព្រះបាទអសោកធម្មរាជា គ្រាទ្រង់បូជា (ដើមមហាពោធិព្រឹក្ស) ដោយរាជសម្បត្តិយ៉ាងធំយ៉ាងនោះហើយ ក្នុងថ្ងៃបាដិបទដំបូង (គឺ ១ រោច) នៃខែមិគសិរ (គឺ ខែទី១) ទើបទ្រង់លើកដើមមហាពោធិព្រឹក្សឡើង ស្តេចលុយទឹកទៅប្រមាណត្រឹមព្រះសូរង ទ្រង់ដាក់ទុកលើទូក ហើយទ្រង់ត្រាស់ឱ្យព្រះនាងសង្ឃមិត្តាថេរីព្រមដោយបរិវារឡើងទូក ទើបបានត្រាស់ពាក្យនេះចំពោះអរិដ្ឋអាមាត្យថា "នែបា ខ្ញុំបូជាមហាពោធិព្រឹក្សដោយរាជសម្បត្តិក្នុងសាកលជម្ពូទ្វីបដល់ ៣ ដង ត្រូវលុយទឹកទៅប្រមាណត្រឹម-ក បញ្ជូន(ដើមមហាពោធិព្រឹក្ស) ទៅ ឱ្យសម្លាញ់របស់ខ្ញុំ, សូម្បីសម្លាញ់របស់ខ្ញុំនោះ ក៏ចូរទ្រង់បូជាដើមមហាពោធិព្រឹក្សយ៉ាងនេះដែរ" ។

លុះទ្រង់ព្រះរាជទានដំណឹងដល់ព្រះសម្លាញ់យ៉ាងនោះហើយ ទ្រង់ក៏រៀបរាប់ត្អូញត្អែរផ្គងអញ្ជលី ប្រថាប់ឈរបង្ហូរព្រះអស្សុជលថា "មហាពោធិព្រឹក្សរបស់ព្រះទសពល ដែលបញ្ចាំងព្រះរស្មីដូចមានជីវិតរស់នៅទៅហើយហ្ន៎" ដូច្នេះ ។ នាវាដែលដើមមហាពោធិព្រឹក្សឡើងប្រតិស្ឋាននោះឯង កាលមហាជនកំពុងផ្តោតនេត្រាសម្លឹងមើល ក៏រសាត់អណ្តែត

បេញទៅកាន់ផ្ទៃសមុទ្រដ៏ធំធេង ។ ពួករលកក្នុងមហាសមុទ្រស្ងប់ស្ងៀម ប្រមាណមួយយោជន៍ដោយជុំវិញ ។ ពួកបទុមជាតិបញ្ចពណ៌ក៏រីកស្គុះស្គាយ ។ ទិព្វដូរ្យតន្ត្រីទាំងឡាយ ក៏បន្លឺលាន់ឮនៅលើអាកាសវេហា ។ បានមានការបូជាដ៏ឱឡារិកក្រៃលែងណាស់ ដែលពពួកទេវតាអាស្រ័យនៅក្នុងអាកាស មកទឹក លើគោកនិងលើដើមឈើជាដើម បណ្ដាលឱ្យប្រព្រឹត្តទៅហើយ ។ ព្រះនាងសង្ឃមិត្តាថេរី ធ្វើឱ្យត្រកូលនាគទាំងឡាយក្នុងមហាសមុទ្រតក់ស្លុតខ្លាចហើយ ដោយ ( ប្លែងជា ) រូបសុបណ្ណ ( គឺនិមិត្តជារូបគ្រុឌ ) ។ ក៏នាគទាំងនោះតក់ស្លុតខ្លាច ចូលមកឃើញសម្បត្តិនោះ ទើបទូលសូមព្រះថេរី ហើយនាំដើមមហាពោធិព្រឹក្សទៅកាន់នាគពិភព បូជាដោយរាជសម្បត្តិនៃនាគអស់ ៧ថ្ងៃហើយ ( នាំត្រឡប់មក ) ឱ្យប្រតិស្ឋាននៅលើទូកវិញ ។ នាវាបានរសាត់ទៅដល់កំពង់ជម្ពូកោលបដ្ដនៈក្នុងថ្ងៃនោះឯង ។ ចំណែកព្រះបាទអសោកមហារាជ ទ្រង់កើតទុក្ខព្រោះវិយោគចាកដើមមហាពោធិព្រឹក្ស ទ្រង់រៀបរាប់តួញត្អែរព្រះកន្សែងផង ព្រះនេត្រមើលដរាបដល់ទីបំផុតទស្សនវិស័យ ហើយក៏ស្ដេចត្រឡប់ ។

## ព្រះបាទទេវានម្បិយតិស្ស ត្រៀមទទួលមហាពោធិព្រឹក្ស

ចំណែកព្រះបាទទេវានម្បិយតិស្សមហារាជនោះឯង ចាប់តាំងពីថ្ងៃបាដិបទដំបូងនៃខែមិគសិរមាស (គឺខែទី១) ទ្រង់ត្រាស់ឱ្យជម្រះតាក់តែងមគ្គាតាំងពីទ្វារខាងទិសឧត្តរ (នៃអនុរាធបុរី) ដរាបដល់កំពង់ជម្ពុកោលបដ្ដនៈ តាមពាក្យរបស់សុមនសាមណេរ, ក្នុងថ្ងៃដែលស្ដេចចេញចាកព្រះនគរ បានប្រថាប់ឈរក្នុងទីតាំងសាលាដែលមាននៅក្បែរប្រាំងសមុទ្រជិតទ្វារខាងទិសឧត្តរនុ៎ះឯង បានទតឃើញដើមមហាពោធិព្រឹក្ស ដែលកំពុងមកនៅក្នុងមហាសមុទ្រនុ៎ះឯង ដោយសម្បត្តិនោះ ព្រោះអានុភាពរបស់ព្រះថេរៈ ទ្រង់គាប់ព្រះរាជហឫទ័យស្ដេចចេញទៅ បន្ទាប់ឱ្យយកផ្កាឈើបញ្ចពណ៌, រោយចុះរហូតដល់អស់មក ទ្រង់តាំងគ្រឿងបូជាផ្កាឈើ[១] ដែលមានតម្លៃទុកក្នុងចន្លោះ ៗហើយ ស្ដេចយាងទៅកំពង់ជម្ពុកោលបដ្ដនៈ តែមួយថ្ងៃប៉ុណ្ណោះ ដែលពួកអ្នកតូរ្យតន្ត្រីទាំងពួងហែហមហើយ ទ្រង់បូជា (ដើមមហាពោធិព្រឹក្ស) នៅដោយគ្រឿងសក្ការៈទាំងឡាយ មានផ្កាឈើធូបនិងរបស់ក្រអូបជាដើម ស្ដេចលុយទឹកទៅប្រមាណត្រឹមព្រះសូរង ហើយទ្រង់ត្រាស់ថា "ដើមមហាពោធិព្រឹក្សរបស់ព្រះទសពល ដែល

---

១. ដីកាសារត្ថទីបនី.ថា ឱ្យធ្វើចេតិយផ្កាឈើទុកក្នុងចន្លោះមកទាំង ២ ខាង, ប្រហែលជា គុម្ពផ្កាឈើដែលរចនាឱ្យចេតិយនោះឯង ។

បញ្ចាំងព្រះរស្មី ដូចមានជីវិតរស់នៅមកហើយហ្ន៎” មានព្រះហឫទ័យជ្រះថ្លាហើយ ទើបទ្រង់លើកដើមមហាពោធិព្រឹក្សឡើងហើយ ដាក់ចុះលើព្រះសិរសា ដែលជាអវយវៈខ្ពស់បំផុត ព្រមដោយពួកត្រកូលដែលសម្បូណ៌ដោយជាតិ ១៦ ត្រកូល អ្នកហែហមដើមមហាពោធិព្រឹក្ស ស្ដេចឡើងពីសមុទ្រហើយទ្រង់តម្កល់ដើមមហាពោធិព្រឹក្សទុកត្រង់មាត់ច្រាំងមហាសមុទ្រ ទ្រង់បូជាដោយរាជសម្បត្តិក្នុងកោះតម្ពបណ្ណិទ្វីបទាំងមូលអស់ ២ ថ្ងៃ ។ ព្រះរាជាទ្រង់ឱ្យត្រកូលដែលសម្បូណ៌ដោយជាតិ ១៦ ត្រកូលសម្រេចរាជការជំនួស ។ ខាងក្រោយតមកក្នុងថ្ងៃទី ៤ ព្រះរាជាទ្រង់ទទួលយកដើមមហាពោធិព្រឹក្សហើយ ទ្រង់ធ្វើការបូជាយ៉ាងឱឡារស្ដេចយាងដល់ក្រុងអនុរាធបុរីដោយលំដាប់ ។

## ព្រះរាជាតម្កល់មហាពោធិព្រឹក្សក្នុងបូជនីយស្ថាន ៤ កន្លែង

ព្រះរាជា គ្រាទ្រង់ធ្វើសក្ការៈយ៉ាងធំ សូម្បីក្នុងក្រុងអនុរាធបុរីក្នុងថ្ងៃចាតុទ្ទសី (គឺ ថ្ងៃ ១៤កើត) នុ៎ះឯង បន្ទាប់ឱ្យបញ្ជូនដើមមហាពោធិព្រឹក្ស ចូលទៅតាមទ្វារខាងទិសឧត្ដរ ក្នុងវេលាល្ងាច ហែតម្រង់ទៅកណ្ដាលព្រះនគរ ចេញតាមទ្វារទិសទក្សិណ ហើយទ្រង់ឱ្យតាំងដើមមហាពោធិព្រឹក្សទុកលើឋានសុមព្រះទ្វារនៃរាជឧទ្យាន ដែលធ្វើបរិកម្មផ្ទៃដីទុកពីដំបូងនោះឯង តាមពាក្យរបស់សុមនសាមណេរ ដែលជាផ្ចិត

កណ្តាលនៃរាជឧទ្យានមហាមេឃវ័ន ជាស្ថានទីដែលសម្តេចព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយ ប្រថាប់អង្គុយចូលនិរោធសមាបត្តិ និងសម្តេចព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ៣ ព្រះអង្គ ធ្លាប់ប្រថាប់អង្គុយចូលសមាបត្តិ, ទាំងជាស្ថានទីមានដើមប្រែសធំ ដែលជាដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា កកុសន្ធៈ, ដើមឧទុម្ពរ (ដើមល្វា) ដែលជាដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមថាកោនាគមនៈ និងដើមនិគ្រោធ (ដើមជ្រៃ) ដែលជាដើមឈើត្រាស់ដឹងរបស់សម្តេចព្រះកស្សបសម្មាសម្ពុទ្ធ ប្រតិស្ឋាននៅក្នុងទីប្រមាណ ៥០០ ជួរធ្នូ (១គីឡូ) វាស់អំពីទ្វារខាងទិសទក្សិណ ។

សួរថា ព្រះរាជាទ្រង់ត្រាស់ឱ្យតម្កល់មហាពោធិព្រឹក្សនោះ ទុកយ៉ាងណា ?

ឆ្លើយថា ទ្រង់ត្រាស់ឱ្យតម្កល់ទុកយ៉ាងនេះ គឺ ៖

បានឮថា ត្រកូលដែលសម្បូណ៌ដោយជាតិទាំង ១៦ ត្រកូល ដែលមកហែហមដើមពោធិព្រឹក្សទាំងនោះ កាន់យកភេទជាព្រះរាជា, ព្រះរាជាក៏ទ្រង់កាន់យកភេទជានាយទ្វារបាល ។ ត្រកូលទាំង ១៦ ត្រកូល យកដើមមហាពោធិព្រឹក្សចុះ ដាំហើយ (ត្រង់បូជនីយស្ថាន ៤ កន្លែង ដូចពោលហើយនោះ) ។

# មហាពោធិព្រឹក្សសម្តែងឥទ្ធិបាដិហារ្យ

ក្នុងខណៈដែលផុតពីដៃរបស់ត្រកូលទាំង ១៦ នោះឯង មហាពោធិព្រឹក្ស ក៏អណ្តែតឡើងទៅកាន់អាកាសកំពស់ប្រមាណ ៨០ ហត្ថ ហើយបញ្ចេញរស្មី ៦ ពណ៌ ។ រស្មីទាំងឡាយក៏ជះផ្សាយគ្របដណ្តប់ទៅទូទាំងកោះ បានតាំងនៅទល់ដល់ព្រហ្មលោកខាងលើ ។ បុរសប្រមាណមួយម៉ឺននាក់ ឃើញបាដិហារ្យមហាពោធិព្រឹក្សហើយកើតសេចក្តីជ្រះថ្លា ចាប់ផ្តើមចម្រើនអនុបុព្វវិបស្សនា បានសម្រេចជាព្រះអរហន្តហើយបួស ។ ដើមមហាពោធិព្រឹក្សបានប្រតិស្ឋាននៅលើអាកាស ដរាបដល់ព្រះអាទិត្យអស្តង្គត ក៏កាលព្រះអាទិត្យអស្តង្គតហើយ ទើបត្រឡប់ (ចុះមក) ប្រតិស្ឋាននៅលើប្រថពី ដោយរោហិណីនក្ខត្តឫក្ស ។ ព្រមដោយមហាពោធិព្រឹក្សប្រតិស្ឋាននោះឯង មហាប្រថពីបានញ័ររដរាបដល់ទីបំផុតទឹក (ទូផែនដី) ។ ក៏ឯ ដើមមហាពោធិព្រឹក្ស គ្រាប្រតិស្ឋាននៅហើយ ក៏ឈប់នៅក្នុងស្រទាប់ពពក (ហ៊ុំព័ទ្ធ) រហូតដល់ ៧ ថ្ងៃ ។ ដើមមហាពោធិព្រឹក្ស បានដល់ នូវការមើលមិនឃើញរបស់មនុស្សលោក (គឺ មនុស្សមើលមិនឃើញនូវដើមមហាពោធិព្រឹក្ស) ។ ក្នុងថ្ងៃ

ទី ៧ នភាកាសបានប្រាសចាកពពកហ៊ុំព័ទ្ធហើយ, រស្មីដែលមានពណ៌, ៦ ប្រការ ក៏ជះផ្សាយចេញចិញ្ចែងចិញ្ចាច ។ ដើម មែក ស្លឹក និងផ្លែ ទាំង៥ នៃដើមមហាពោធិព្រឹក្សក៏ប្រាកដឱ្យឃើញ ។ ព្រះមហិន្ទត្ថេរ ព្រះនាងសង្ឃមិត្តាថេរី និងព្រះរាជា ព្រមដោយរាជបរិវារបានស្តេចយាងទៅដល់ស្ថានទីតាំងនៃដើមមហាពោធិព្រឹក្សនុ៎ះឯង ។ ឯប្រជាជនក្នុងកោះទាំងអស់ក៏ប្រជុំគ្នាហើយដោយចំណែកច្រើន ។ កាលជនទាំងនោះនៅសម្លឹងមើលនុ៎ះឯង ផ្លែមួយនៅមែកខាងទិសឧត្តរទុំហើយក៏ជ្រុះចាកពីមែក ។ ព្រះថេរៈលូកព្រះហស្តចូលទ្រទុក ។ ផ្លែក៏បានតាំងនៅលើព្រះហស្តរបស់ព្រះថេរៈ ។ ព្រះថេរៈបានថ្វាយផ្លែនោះចំពោះព្រះរាជា ដោយថ្វាយព្រះពរថា "សូមព្រះអង្គទ្រង់ដាំចុះ មហាបពិត្រ" ។

## ពូជមហាពោធិព្រឹក្សបែកសាខា ៨_៣២ ដើម

ព្រះរាជាទ្រង់ទទួលហើយ ក៏ទ្រង់រោយលំអិតដែលមានរសល្អចុះក្នុងផើងមាស ដាក់ភក់ដែលផ្សំដោយរបស់ក្រអូបឱ្យពេញ ហើយបណ្តុះទុកក្នុងទីជិតដើមមហាពោធិព្រឹក្ស ។ កាលជនទាំងអស់កំពុងមើលនុ៎ះឯង កូនពោធិព្រឹក្សតូច ៗ ៨ ដើម ដែលមានប្រមាណ ៤ ហត្ថ បានដុះ

ឡើងហើយ ។ ព្រះរាជាទតឃើញអស្ចារ្យនោះ ហើយក៏ទ្រង់បូជាកូនពោធិព្រឹក្សតូច ៗ ៨ ដើមដោយស្វេតឆត្រ ហើយថ្វាយការអភិសេក (ដល់កូនពោធិព្រឹក្សតូច ៗ ទាំង៨ ដើមនោះ) ។ ប្រជាជនដាំកូនពោធិព្រឹក្សមួយដើម (ដែលបែក) អំពីកូនពោធិព្រឹក្សតូច ៗ ទាំង ៨ ដើមនោះទុកត្រង់កំពង់ឈ្មោះជម្ពូកោលបដ្ដនៈ ក្នុងឱកាសដែលដើមមហាពោធិព្រឹក្សប្រតិស្ឋាននៅក្នុងពេលមកដល់ដំបូង ។ ដាំមួយដើមទុកត្រង់មុខទ្វារស្រុករបស់តវក្កព្រាហ្មណ៍,[១] មួយដើមទៀត ដាំក្នុងថូបារាម, មួយដើមទៀត ដាំក្នុងក្បែរ ឥស្សរនិម្មានវិហារ,[២] មួយដើមទៀត ដាំជិតទីតាំងព្រះបឋមចេតិយ, មួយដើមទៀត ដាំលើចេតិយបព្វត, មួយដើមទៀត ដាំក្នុងស្រុកកាជរគ្រាមក្នុងរោហណជនបទ, មួយដើមទៀត ដាំក្នុងស្រុកចន្ទនគ្រាម ក្នុងរោហណជនបទនុ៎ះឯង ។ ប្រជាជនទាំងឡាយបានដាំកូនពោធិព្រឹក្សតូច ៗទាំង ៣២ ដើម ដែលកើតអំពីពូជនៃផ្លែទាំង ៤ គ្រាប់ ក្រៅនេះទុកក្នុងអារាមដែលតាំងនៅក្នុងចម្ងាយមួយយោជន៍ ។

១. ដីកាសារត្ថទីបនីជាតវក្កព្រាហ្មណ៍ ។ ២. សារត្ថ ពាក្យថា ឥស្សរនិម្មានវិហារ បានដល់ កស្សបគិរីវិហារ គឺ វិហារដែលឥស្សរជនសាងទុក ។

## ព្រះនាងអនុឡាទេវី និងអរិដ្ឋអាមាត្យបួស

កាលដើមមហាពោធិព្រឹក្ស ដែលជាទង់ជ័យនៃព្រះសទ្ធម្មរបស់ព្រះទសពលប្រតិស្ឋាននៅហើយ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនក្នុងកោះដោយជុំវិញ ដោយការបន្តលំដាប់នៃកូនចៅយ៉ាងនេះហើយ ព្រះនាងអនុឡាទេវី ព្រមទាំងមាតុគ្រាមមួយពាន់ គឺ ស្រី ៗ (ជាបាទបរិចារិការបស់ខ្លួន) ៥០០នាក់ និងស្រីក្នុងរាជវាំង ៥០០នាក់ទៀត ព្រះផ្នួសក្នុងសំណាក់របស់ព្រះនាងសង្ឃមិត្តាថេរី មិនយូរប៉ុន្មាន ព្រះនាងព្រមទាំងបរិវារ ក៏តាំងនៅក្នុងភាពជាព្រះអរហន្ត ។ ចំណែកព្រះរាជភាគិនីយ៍ឈ្មោះអរិដ្ឋៈនោះឯង ព្រមទាំងបុរស ៥០០ នាក់ បួសក្នុងសំណាក់របស់ព្រះថេរៈ, អរិដ្ឋភិក្ខុព្រមទាំងបរិវារ បានតាំងនៅក្នុងភាពជាព្រះអរហន្ត ក្នុងកាលមិនយូរដូចគ្នាដែរ ។

## សាសនាតាំងមាំព្រោះកុលបុត្រក្នុងកោះលង្កាបួសរៀន

តមកថ្ងៃមួយ ព្រះរាជាថ្វាយបង្គំដើមមហាពោធិព្រឹក្សហើយ ស្តេចយាងទៅកាន់ថូបារាមព្រមទាំងព្រះថេរៈ ។ កាលព្រះរាជាស្តេចយាងទៅដល់ស្ថានទីដែលត្រូវសាងលោហប្រាសាទ ពួករាជបុរសក៏បាននាំផ្កាឈើទាំងឡាយមកទូលថ្វាយ ។ ព្រះរាជាបានថ្វាយផ្កាឈើទាំងឡាយដល់ព្រះថេរៈ ។ ព្រះថេរៈក៏យកផ្កាឈើបូជាទីដែលត្រូវសាងលោហប្រាសាទ ។

ល្មមកាលផ្កាឈើទាំងឡាយ ដែលធ្លាក់ចុះលើផែនដី ផែនដីបានកើតការញាប់ញ័រយ៉ាងខ្លាំង ។

ព្រះរាជាត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វីទើបផែនដីញ័រ ?"

ព្រះថេរៈ ទូលថា "មហាបពិត្រ ក្នុងអនាគត រោងព្រះឧបោសថនឹងមានដល់សង្ឃក្នុងឱកាសនេះ នេះនឹងជាបុព្វនិមិត្តនៃរោងព្រះឧបោសថនោះ" ។ ព្រះរាជាទ្រង់យាងទៅព្រមនឹងព្រះថេរៈ បានយាងទៅដល់អម្ពង្គណស្ថាន ។ ក្នុងអម្ពង្គណស្ថាននោះ រាជបុរសបាននាំផ្លែស្វាយទុំមួយ សម្បូណ៌ដោយពណ៌, និងក្លិន មានរសឆ្ងាញ់ក្រៃលែង មកទូលថ្វាយចំពោះព្រះរាជាព្រះអង្គនោះ ។ ព្រះរាជាបានថ្វាយផ្លែស្វាយនោះដល់ព្រះថេរៈដើម្បីទំពាឆាន់ ។ ព្រះថេរៈក៏ឆាន់ក្នុងទីនោះឯង ហើយទូលថា "សូមព្រះអង្គទ្រង់ដាំគ្រាប់ស្វាយនេះទុកក្នុងទីនេះឯង" ។ ព្រះរាជា ទ្រង់ទទួលយកគ្រាប់ស្វាយនោះហើយ ទ្រង់បណ្ដុះទុកក្នុងទីនោះឯង ហើយទ្រង់ស្រោចទឹក ។ ព្រមនឹងការទ្រង់បណ្ដុះគ្រាប់ស្វាយ ផែនដីក៏ញាប់ញ័រហើយ ។ ព្រះរាជាត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបបឋវីញ័រ ?" ព្រះថេរៈទូលថា "មហាបពិត្រ ក្នុងអនាគតទីប្រជុំសង្ឃ ឈ្មោះអម្ពង្គណៈ នឹងមានក្នុងឱកាសនេះ នេះនឹងជាបុព្វនិមិត្តនៃសន្និបាតស្ថាននោះ" ។ ព្រះរាជាទ្រង់រាយផ្កាឈើ ៨ ក្ដាប់ចុះក្នុងទី

នោះ ទ្រង់ថ្វាយបង្គំហើយក៏ស្តេចបន្តរាជដំណើរទៅព្រមនឹងព្រះថេរៈទៀត ស្តេចបានយាងទៅដល់ស្ថានទីដែលនឹងត្រូវសាងមហាចេតិយ ។ ក្នុងស្ថានទីនោះ ពួករាជបុរស បាននាំផ្កាចម្បាទាំងឡាយ មកថ្វាយចំពោះព្រះរាជាអង្គនោះ ។ ព្រះរាជាបានថ្វាយផ្កាចម្បាទាំងនោះដល់ព្រះថេរៈ ។ ព្រះថេរៈក៏យកផ្កាឈើបូជាត្រង់ទីដែលត្រូវសាងមហាចេតិយហើយថ្វាយបង្គំ ។ ក្នុងវេលានោះឯង មហាប្រថពីក៏ញាប់ញ័រ ។ ព្រះរាជាត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបបានបរវីញ័រ" ។

ព្រះថេរៈទូលថា "មហាបពិត្រ ក្នុងអនាគត ព្រះមហាសថូបដែលមិនមានទីណាដូចទីរបស់ព្រះមានព្រះភាគនឹងមានក្នុងឱកាសនេះ នេះនឹងជាបុព្វនិមិត្ត នៃមហាសថូបនោះ" ។

ព្រះរាជា ទ្រង់ត្រាស់ថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានេះឯង នឹងសាង"

ព្រះថេរៈ ទូលថា "កុំឡើយ មហាបពិត្រ ព្រះអង្គនៅមានការងារដទៃច្រើន តែព្រះនត្តារបស់ព្រះអង្គ ព្រះនាមថា ទុដ្ឋគាមណីអភ័យនឹងទ្រង់ឱ្យសាង" ។

គ្រានោះ ព្រះរាជាទ្រង់ត្រាស់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន បើព្រះនត្តារបស់ខ្ញុំព្រះករុណានឹងសាងសោត ក៏នឹងសាងវត្ថុដែលខ្ញុំព្រះ

ករុណាសាងទុកហើយទុំះឯង” ដូច្នេះហើយ ទើបបង្គាប់ឱ្យនាំសសរសេរថ្ម មានប្រមាណ ១២ ហត្ថមក ហើយឱ្យចារឹកអក្សរទុកថា “ព្រះនគ្គាររបស់ព្រះបាទទេវានម្បិយតិស្សព្រះនាមថា ទុដ្ឋគាមណីអភ័យ ចូរសាងព្រះសថូបទុកក្នុងប្រទេសនេះចុះ” ដូច្នេះ បង្គាប់ឱ្យប្រតិស្ឋានទុកហើយ ទើបត្រាស់សួរព្រះថេរៈថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសាសនា តាំងមាំហើយក្នុងកោះលង្កាទ្វីបឬនៅទេ ?”

ព្រះថេរៈទូលថា “សូមថ្វាយព្រះពរ មហាបពិត្រ ព្រះសាសនាតាំងមាំហើយ ប៉ុន្តែថា ឫសគល់នៃព្រះសាសនានោះ មិនទាន់ចាក់ចុះនៅឡើយ” ។

ព្រះរាជាត្រាស់សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏កាលណាឫសគល់ (នៃព្រះសាសនានោះ) នឹងឈ្មោះថា ជាការដែលធ្លាក់ចុះហើយ ?”

ព្រះថេរៈទូលថា “មហាបពិត្រ ក្នុងកាលណា ក្មេងកើតក្នុងកោះតម្ពបណ្ណិទ្វីប មានមាតាបិតាជាមនុស្សក្នុងកោះតម្ពបណ្ណិទ្វីប នឹងចេញបួសក្នុងកោះតម្ពបណ្ណិទ្វីប ហើយរៀនព្រះវិន័យក្នុងកោះតម្ពបណ្ណិទ្វីបទុំះឯងចេញផ្សព្វផ្សាយបង្រៀន (ព្រះវិន័យ) ក្នុងកោះតម្ពបណ្ណិទ្វីបបាន ក្នុងកាលនោះឫសគល់នៃព្រះសាសនានឹងឈ្មោះថា ជាការដែលចាក់ចុះហើយ” ។

ព្រះរាជា ត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏ភិក្ខុដូច្នេះ មាននៅក្នុងកោះតម្ពបណ្ណិទ្វីប ឬ ?"

ព្រះថេរៈ ទូលថា "នៅក្នុងកោះតម្ពបណ្ណិទ្វីបនេះ មាន មហាបពិត្រ ព្រះមហាអរិដ្ឋភិក្ខុជាអ្នកអាចក្នុងកម្មនោះ" ។

ព្រះរាជា ត្រាស់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាគួរធ្វើអ្វីខ្លះ ក្នុងកម្មនេះ" ។

ព្រះថេរៈ ទូលថា "គួរសាងមណ្ឌប មហាបពិត្រ"

## ព្រះរាជាសាងមណ្ឌបដើម្បីធ្វើចតុត្ថសង្គាយនា

ព្រះរាជា ទ្រង់ទទួលថា "ល្អណាស់ លោកម្ចាស់" ហើយបង្គាប់ឱ្យសាងមណ្ឌបដោយរាជានុភាព ដូចគ្នានឹងមណ្ឌបដែលព្រះបាទអជាតសត្តុមហារាជ ទ្រង់សាងក្នុងគ្រាធ្វើមហាសង្គីតិ (គឺ សង្គាយនាលើកដំបូង) ទុកក្នុងផ្ទៃដីរបស់អាមាត្យ ឈ្មោះមេឃវណ្ណាភ័យ (របស់ព្រះបាទមេឃវណ្ណាភ័យ) ហើយទ្រង់ត្រាស់ឱ្យពួកអ្នកតូរ្យតន្ត្រីទាំងពួង ហ្វឹកហាត់ក្នុងសិល្បៈរបស់ខ្លួន ៗ ទុក (បង្គាប់ឱ្យត្រៀមហាត់តន្ត្រីទុកឱ្យជំនាញ (ហើយទ្រង់ត្រាស់ថា ខ្ញុំព្រះករុណា នឹងមើលឫសគល់នៃព្រះសាសនា ដែលចាក់ចុះហើយ ដូច្នេះ មានបុរសចំនួនច្រើនពាន់ហែហមហើយ បានស្ដេចយាងទៅដល់ថូបារាម ។

# ចតុត្ថសង្គាយនា

សម័យនោះ ភិក្ខុ ៦៨,០០០ រូប ប្រជុំគ្នាក្នុងថូបារាម ។ អាសនៈរបស់ព្រះមហាមហិន្ទត្ថេរ គេក្រាលបែរមុខទៅមកខាងទិសទក្សិណ ។ ធម្មាសនៈរបស់ព្រះមហាអរិដ្ឋត្ថេរ គេចាត់តាំងបែរមុខទៅមកខាងទិសឧត្តរ ។ គ្រានោះឯង ព្រះមហាអរិដ្ឋត្ថេរ ដែលព្រះមហិន្ទត្ថេរ និមន្តហើយក៏គង់លើធម្មាសនៈ ដោយលំដាប់ដែលដល់ខ្លួន តាមសមគួរ ។ ព្រះមហាថេរៈ៦៨រូប ដែលមានព្រះមហិន្ទត្ថេរជាប្រមុខ ក៏គង់ព័ទ្ធជុំវិញធម្មាសនៈ ។ ព្រះកនិដ្ឋភាតា សូម្បីរបស់ព្រះរាជា ព្រះនាមថា មត្តាភយត្ថេរ ជាអ្នកយកធុរៈការងារ (គឺ តាំងចិត្តសិក្សារៀនសូត្រ) រួមនឹងភិក្ខុ ៥០០ រូប គង់ជុំវិញធម្មាសនៈរបស់ព្រះមហាអរិដ្ឋត្ថេរនោះឯង ដោយតាំងចិត្តថានឹងរៀនយកព្រះវិន័យ ។ ពួកភិក្ខុសូម្បីដែលសល់ និងបរិស័ទព្រមដោយព្រះរាជា ក៏បានអង្គុយលើទីអង្គុយដែលដល់ខ្លួន ៗ ហើយ ។

គ្រានោះ ព្រះមហាអរិដ្ឋត្ថេរ បានសម្ដែងនិទាននៃព្រះវិន័យថា "សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្ដៅជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា" ដូច្នេះជាដើម ។ ក៏ឯកាលព្រះអរិដ្ឋត្ថេរ សម្ដែងនិទាននៃព្រះវិន័យហើយ អាកាសក៏ស្រែកគ្រហឹមមក

ផែនដីនោះ ។ ផ្លេកបន្ទោរខុសរដូវកាលក៏ប្រវាត់ឆ្វាត់ឆ្វែង ។ ពួកទេវតាបានថ្វាយសាធុការហើយ ។ មហាប្រថពីរញ្ជួយញាប់ញ័រ ដរាបដល់ទីបំផុតទឹកទ្រផែនដី ។

កាលបាដិហារ្យច្រើនយ៉ាងប្រព្រឹត្តទៅនៅយ៉ាងនោះ ព្រះអរិដ្ឋត្ថេរ ដែលមានព្រះមហាថេរៈជាខីណាស្រព ៦៨ រូប ជាមេគណៈមួយ ៗ ដែលមានព្រះមហាមហិន្ទជាប្រមុខ និងភិក្ខុ ៦ ម៉ឺន រូបក្រៅអំពីនោះ ហែហមហើយ បានប្រកាសព្រះវិន័យបិដក ដែលសម្ដែងនូវគុណមានព្រះករុណារបស់ព្រះសាស្ដាជាដើម ដែលកម្ចាត់សេចក្ដីក្ដៅក្រហាយមកកាយកម្ម វចីកម្មរបស់ពួកជនអ្នកធ្វើតាមពាក្យទូន្មាន របស់ព្រះមានព្រះភាគត្រង់កណ្ដាលនៃមហាវិហារថូបារាម ក្នុងថ្ងៃបវារណាខែកត្តិកាដំបូង ។ ក៏ព្រះអរិដ្ឋត្ថេរដ៏មានអាយុ គ្រាប្រកាសហើយ បង្រៀនដល់ភិក្ខុជាច្រើន គឺ ឱ្យតាំងនៅក្នុងហទយៈរបស់ភិក្ខុច្រើនសន្ធឹកសន្ធាប់ តាំងនៅដរាបអស់អាយុ ហើយក៏បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

ព្រះមហាថេរៈ ៦៨ រូប សូម្បីទាំងនោះឯងដែលមាន
ព្រះមហាមហិន្ទជាប្រមុខ អ្នកយកធុរៈការងារមកប្រជុំ
ព្រមគ្នាហើយ ក្នុងសមាគមនោះ, ទាំងអស់ជាមេគណៈ

មួយ ៗ ជាសាវករបស់ព្រះធម្មរាជា មានអាសវៈអស់ហើយ បានសម្រេចវសី មានវិជ្ជា ៣ ឆ្លាតក្នុងឥទ្ធិឫទ្ធិ ដឹងច្បាស់នូវអត្ថដ៏ឧត្តម បានប្រៀនប្រដៅព្រះរាជា ព្រះថេរៈ អ្នកស្វែងរកគុណធំសម្តែងបំភ្លឺ (គឺសេចក្តីភ្លឺនៃញាណ) ឱ្យឃើញច្បាស់ ញុំាងផែនដី (គឺ កោះលង្កា) នេះឱ្យរុងរឿងហើយ ក៏បរិនិព្វាន ដូចគំនរភ្លើងឆេះសន្ធោសន្ធៅហើយរលត់ទៅ ដូច្នោះ ។

ចំណេរកាលតមក បន្ទាប់ពីកាលបរិនិព្វាននៃព្រះមហាថេរៈទាំងនោះ លំដាប់បន្តគ្នាមកនៃអាចារ្យ ដែលមានប្រការដូចពោលហើយក្នុងផ្នែកខាងដើមយ៉ាងនេះ គឺ ព្រះមហាថេរៈសូម្បីពួកដទៃ អ្នកជាអន្តេវាសិករបស់ព្រះថេរៈទាំងនោះ និងព្រះថេរៈទាំងឡាយ មានព្រះតិស្សទត្តៈ ព្រះកាឡសុមនៈ និងព្រះទីឃសុមនៈជាដើម អ្នកជាអន្តេវាសិកនៃអន្តេវាសិកទាំងឡាយ របស់ព្រះមហាអរិដ្ឋត្ថេរ បាននាំព្រះវិន័យបិដកនេះមក ដរាបដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលទុកថា ក៏បន្ទាប់ពីតតិយសង្គាយនា មកព្រះថេរៈទាំងឡាយ មានព្រះមហិន្ទជាដើម បាននាំ

ព្រះវិន័យបិដកមកកាន់កោះនេះ, ព្រះថេរៈទាំងឡាយ មានព្រះអរិដ្ឋត្ថេរជាដើម រៀនអំពី (សំណាក់) ព្រះមហិន្ទហើយ បាននាំមករហូតអស់រយៈវេលាតិចតួច តាំងពីវេលាព្រះអរិដ្ឋត្ថេរជាដើមនោះនាំមកព្រះវិន័យបិដកនោះ គប្បីជ្រាបថា បាននាំបន្តមកដោយលំដាប់អាចារ្យ ដែលជាការបន្តលំដាប់អន្តេវាសិករបស់ព្រះអរិដ្ឋត្ថេរជាដើមទាំងនោះឯង ដរាបដល់សព្វថ្ងៃនេះ ។

## ពន្យល់បទមាតិកាថា ព្រះវិន័យបិដកតាំងនៅហើយក្នុងបុគ្គលណា

បទមាតិកាថា ព្រះវិន័យបិដកតាំងនៅហើយក្នុងបុគ្គលណា ខ្ញុំព្រះករុណានឹងឆ្លើយតទៅ ៖

ព្រះវិន័យបិដករបស់បុគ្គលពួកណា រមែងប្រព្រឹត្តទៅមិនចន្លោះដោយបាលីនិងដោយអត្ថ គឺ មិនបាត់បង់សូម្បីតិចតួច ដូចប្រេងល្ងដែលដាក់ទុកក្នុងឆ្នាំងកែវមណី រមែងមិនជ្រាបចេញដូច្នោះ គប្បីជ្រាបថា ព្រះវិន័យបិដកតាំងនៅហើយក្នុងបុគ្គលបែបនោះ ដែលជាអ្នកមានសតិ គតិ និង ធិតិ មានប្រមាណក្រៃលែង អ្នកជាលជ្ជី ច្រើនមានសេចក្ដីរង្កៀស ប្រាថ្នាចំពោះការសិក្សា ។

# អានិសង្សនៃការរៀនព្រះវិន័យ ៥ ប្រការ

ព្រោះដូច្នោះ ដើម្បីឱ្យព្រះវិន័យតាំងមាំ ដែលភិក្ខុកំណត់ដឹងនូវអានិសង្សនៃវិន័យបរិយត្តិ (ការរៀនព្រះវិន័យ) ប្រាថ្នាចំពោះការសិក្សាក៏គួររៀនព្រះវិន័យ ។ ក្នុងអធិការពោលដោយការពណ៌នានិទាននោះ មានអានិសង្សនៃវិន័យបរិយត្តិ (ការរៀនព្រះវិន័យ) ដូចតទៅនេះ ៖

ពិតមែន បុគ្គលអ្នកឆ្លាតក្នុងវិន័យបរិយត្តិ រមែងជាអ្នកតាំងនៅក្នុងឋានជាមាតាបិតារបស់ពួកកុលបុត្រ អ្នកបានសទ្ធាក្នុងព្រះសាសនា ព្រោះថា បព្វជ្ជាឧបសម្បទា ខបដិបត្តិ វត្តធំនិងវត្តតូច ភាពជាអ្នកឆ្លាតក្នុងអាចារៈនិងគោចររបស់កុលបុត្រទាំងនោះ ជាប់ដោយសេចក្តីឆ្លាតក្នុងវិន័យបរិយត្តិនោះ ។

មួយទៀត ព្រោះអាស្រ័យវិន័យបរិយត្តិ កងសីលរបស់ខ្លួនរមែងជារបស់ដែលបុគ្គលនោះ ឃុំគ្រងរក្សាល្អហើយ រមែងជាទីពឹងពំនាក់របស់ពួកកុលបុត្រ ដែលត្រូវសេចក្តីសង្ស័យគ្របសង្កត់ រមែងក្លៀវក្លានិយាយនៅកណ្តាលសង្ឃ រមែងសង្កត់សង្កិនពួកសត្រូវបានដោយល្អ ដោយសហធម៌ រមែងជាអ្នកបដិបត្តិ ដើម្បីការតាំងមាំនៃព្រះសទ្ធម្ម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ភិក្ខុទ្រទ្រង់វិន័យតែងបានអានិសង្ស ៥ ប្រការ គឺ សីលក្ខន្ធរបស់ខ្លួន ឈ្មោះថា ភិក្ខុ

នោះ បានឃុំគ្រងរក្សាដោយល្អ១ ភិក្ខុនោះ តែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្ដីសង្ស័យជាប្រក្រតី១ ភិក្ខុនោះ ជាអ្នកក្លៀវក្លានិយាយក្នុងកណ្ដាលជំនុំសង្ឃ១ ភិក្ខុនោះរមែងសង្កត់សង្កិនដោយល្អ នូវពួកសត្រូវដោយសហធម៌ គឺសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុក១ ភិក្ខុនោះឈ្មោះថា ជាអ្នកប្រតិបត្តិ ដើម្បីញុំាងព្រះសទ្ធម្មឱ្យតាំងនៅមាំ១”[១] ។

## បដិបត្តិវិន័យ នាំឱ្យបានរួចផុតពីកិលេសជាទីបំផុត

មួយទៀត កុសលធម៌ពួកណា ដែលមានសំវរៈជាមូល ដែលព្រះមានព្រះភាគត្រាស់ទុកហើយ, បុគ្គលអ្នកទ្រង់វិន័យនុ៎ះឯង ឈ្មោះថាជាទាយាទនៃកុសលធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ មានវិន័យជាមូល ។ សមពិត ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

“វិន័យ ដើម្បីប្រយោជន៍ដល់សេចក្ដីសង្រួម, សេចក្ដីសង្រួមដើម្បីប្រយោជន៍ដល់ការមិនក្ដៅក្រហាយចិត្ត, ការមិនក្ដៅក្រហាយចិត្តដើម្បីប្រយោជន៍ដល់បាមោជ្ជៈ គឺសេចក្ដីរីករាយទន់, បាមោជ្ជៈ ដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្ដីរីករាយដ៏ក្លា, បីតិ ដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្ដីស្ងប់រម្ងាប់, បស្សទ្ធិ ដើម្បីប្រយោជន៍ដល់សុខៈ, សុខៈ

១. វិន. បរិ. ឯកុត្តរិក. ១៣. ៦៩/៧៣ ។

ដើម្បីប្រយោជន៍ដល់សមាធិ, សមាធិ ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ (វិបស្សនាទន់ខ្ចី), យថាភូតញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់និព្វិទា (វិបស្សនាមានកម្លាំង), និព្វិទា ដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ, វិរាគៈ ដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល វិមុត្តិ ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរលត់មិនឱ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ, ព្រះអរហត្តផល ឬព្រះនិព្វានជាគ្រឿងរួចចាកសេចក្តីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា ការពោលនូវព្រះវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍ ការប្រឹក្សានូវព្រះវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍ ការប្រុងស្តាប់នូវព្រះវិន័យ ក៏មានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍”[១] ។

ព្រោះដូច្នោះ គួរធ្វើសេចក្តីព្យាយាមដោយអើពើក្នុងការរៀនសូត្រព្រះវិន័យ ដូច្នេះឯង ។

---

១. វិន. បរិ. ចូឡសង្គាម. ១៣. ១៦៧/១៩៤-៥ ។

## គាថាសរុបរឿង

ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ជាការដែលខ្ញុំព្រះករុណាប្រកាសសេចក្ដីនៃគាថានេះថា ៖

"ព្រះវិន័យបិដកនេះ អ្នកណាពោលទុក, ពោលក្នុងកាលណា, ពោលទុកព្រោះហេតុអ្វី, អ្នកណាទ្រទ្រង់ទុក, អ្នកណានាំបន្តមក, និងតាំងនៅហើយ ក្នុងបុគ្គលណា, ខ្ញុំព្រះករុណាពោលវិធីនេះហើយខាងក្រោយ (នឹងពណ៌នាអត្ថនៃព្រះវិន័យ) ដូច្នេះ ។

ក្នុងមាតិកាដែលខ្ញុំព្រះករុណាតាំងទុក ដើម្បីពណ៌នាព្រះន័យនោះមុន និងការពណ៌នាពាហិរនិទាននៃព្រះវិន័យ ក៏ជាការដែលខ្ញុំព្រះករុណាពណ៌នាហើយ តាមដែលបានអធិប្បាយមកដូច្នេះឯង ។

## ពាហិរនិទានវណ្ណនា ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ពាហិរនិទាន

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ទេរញ្ជកណ្ឌ

## បឋមភាគ

# វេរញ្ជកណ្ឌវណ្ណនា

[១] ឥឡូវនេះ ខ្ញុំព្រះករុណានឹងធ្វើការពណ៌នាសេចក្ដីនៃបទទាំងឡាយ មានបទថា តេន សមយេន ពុទ្ធោ ភគវា : សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ ដ៏មានជោគ ជាដើម ព្រោះបានពោលទុកហើយថា នឹងធ្វើការពណ៌នាអត្ថនៃវិន័យ សម្ដែងសេចក្ដីនៃបាលីថា តេន ជាដើម ដោយប្រការផ្សេង ៗ ។ ខ្ញុំព្រះករុណា នឹងធ្វើអត្ថវណ្ណនាយ៉ាងណា ។

## អធិប្បាយបទថា តេន ជាដើម

បទថា តេន ជាពាក្យសម្ដែងចេញដោយមិនចំពោះ ។ បណ្ឌិតគប្បីជ្រាបបដិនិទ្ទេសនៃបទថា តេន នោះ ដោយពាក្យថា យេន នេះ ដែលជាពាក្យសរុប សូម្បីមិនពោលទុកតែសម្រេចបានដោយសេចក្ដីក្នុងកាលខាងក្រោយ ។ ពិតមែន សេចក្ដីរំពឹងរបស់ព្រះសារីបុត្រ ដែលជាហេតុនៃការទូលអង្វរឱ្យបញ្ញត្តិព្រះវិន័យ សម្រេចបានក្នុងកាលខាងក្រោយ ព្រោះហេតុនោះ គប្បីជ្រាបសម្ពន្ធក្នុងពាក្យថា តេន សមយេន ជាដើម នេះយ៉ាងនេះថា សេចក្ដីរំពឹងនោះកើតឡើង ដោយសម័យណា សម័យនោះ ព្រះមានព្រះភាគស្ដេចប្រថាប់នៅជិតស្រុកវេរញ្ជា ។

ពិតមែន វិធីនេះជាវិធីដែលសមគួរស្នួមស្រ្កក្នុងវិន័យទាំងអស់ គឺពាក្យថា តេន លោកពោលទុកក្នុងទីណា ៗ ក្នុងទីនោះ ៗ បណ្ឌិតគប្បីធ្វើបដិនិទ្ទេសដោយពាក្យថា យេន នេះដែលសម្រេចដោយសេចក្តីក្នុងកាលមុនឬខាងក្រោយ ។ ឧទាហរណ៍ល្មមជាមកក្នុងវិធីដែលសមគួរតាមដែលពោលនោះដូច្នេះ ភិក្ខុសុទិន្នសេពមេថុនធម្ម ព្រោះហេតុអ្វី ភិក្ខុទាំងឡាយ ព្រោះហេតុនោះឯង តថាគតនឹងបញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយមានពាក្យអធិប្បាយថា ភិក្ខុសុទិន្នសេពមេថុនធម្ម ព្រោះហេតុអ្វី ព្រោះហេតុនោះ តថាគតនឹងបញ្ញត្តិ ។ បដិនិទ្ទេស រមែងសមគួរដោយពាក្យថា យេន នេះ ដែលសម្រេចដោយសេចក្តីក្នុងកាលមុន យ៉ាងនេះមុន ។ បដិនិទ្ទេស រមែងសមគួរដោយពាក្យថា យេន នេះ ដែលសម្រេចដោយសេចក្តីក្នុងកាលខាងក្រោយ យ៉ាងនេះថា "ធនិយដ៏មានអាយុជាកូនស្មូនឆ្នាំងទៅយករបស់ដែលគេមិនបានឱ្យ គឺ ឈើរបស់ស្តេច" ដោយសម័យណា សម័យនោះ ព្រះមានព្រះភាគស្តេចនៅជិតក្រុងរាជគ្រឹះ ។ សេចក្តីនៃពាក្យថា តេន ជាការដែលខ្ញុំព្រះករុណាពោលហើយ ដោយប្រការដូច្នេះ ។

## អធិប្បាយបទថា សមយេន ជាដើម

ចំណែក សមយសព្ទ ដែលមានក្នុងបទថា សមយេន នេះ រមែងប្រាកដក្នុងអត្ថ ៩ យ៉ាង គឺ

សមវាយៈ ១ ខណៈ ១ កាលៈ ១ សមូហៈ ១
ហេតុ ១ ទិដ្ឋិ ១ បដិលាភៈ ១ បហានៈ ១
បដិវេធៈ ១ មុន ។

ពិតមែន សមយសព្ទមានសមវាយៈជាអត្ថ ក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ : បើដូច្នោះ ចាំយើងពិចារណានូវកាលនិងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក"[១] ។

មានខណៈជាអត្ថ ក្នុងពាក្យទាំងឡាយ មានជាដើមយ៉ាងនេះថា "ឯកោវ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ : ម្នាលភិក្ខុទាំងឡាយ ខណៈនិងសម័យនៃការនៅប្រព្រឹត្តព្រហ្មចរ្យ មានតែមួយ"[២] មាន កាលៈ ជាអត្ថ ក្នុងពាក្យទាំងឡាយ ជាដើមយ៉ាងនេះថា

---

១. ទីឃ. សីល. សុភសូត្រ. ១៥. ១១៨/១៦២ ។

២. អង្គ. អដ្ឋ. គហបតិវគ្គ. ៤៨. ២៩/១៤១ ។

"ឧណ្ហសមយោ បរិឡាហសមយោ : សម័យក្ដៅ សម័យស្អុះស្អាប់"[១] ។ មានសមុហៈជាអត្ថក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "មហាសមយោ បវនស្មឹ : ថ្ងៃនេះ ជាថ្ងៃប្រជុំធំក្នុងដងព្រៃ"[២] ។ មានហេតុជាអត្ថ ក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ : ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ : ភទ្ទាលិ នាម ភិក្ខុ សត្ថុសាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ : ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុផលថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្ដា ដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯង ជាហេតុដែលអ្នកមិនបានដឹង"[៣] ។ មានទិដ្ឋិជាអត្ថក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "តេន ខោ បន សមយេន ឧគ្គហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិន្ទុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ

១. វិន. បាចិ. សុរាបានវគ្គ. ៤. ២២៩/២៣០ ។ ២. ទីឃ. មហា. មហាសមយសូត្រ. ១៧. ៧៤/១៧០ ។ ៣. មជ្ឈិ. មជ្ឈិ. ភទ្ទាលិសូត្រ. ២៣ ១៦៣/២៨០ ។

បដិវសតិ : សម័យនោះឯង បរិញ្វាជកឈ្មោះឧគ្គាហមានៈ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវីដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ"[១] ។ មានបដិលាភៈជាអត្ថ ក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ : ប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណា ដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថាបណ្ឌិត ព្រោះការបាននូវប្រយោជន៍ទាំងពីរនោះ"[២] ។ មានបហានៈជាអត្ថ ក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្ស : ធ្វើទីបំផុតទុក្ខបានហើយ ព្រោះត្រាស់ដឹងនូវការលះសេចក្តីប្រកាន់តាមហេតុ"[៣] ។ មានបដិវេធៈជាអត្ថ ក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា "ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ : ទុក្ខសច្ច មានអត្ថថា បៀតបៀន មានអត្ថថា ក្តៅក្រហាយ មានអត្ថថា បច្ច័យតាក់តែង មានអត្ថថា

---

១. មជ្ឈិ. មជ្ឈិ. សមណមុណ្ឌិកសូត្រ. ២៤. ១១៧/១៨៨ ។ ២. សំយុ. សគា. ២៩. ៣៨៤/២៣៦ ។ ៣. អង្គុ. ចតុ. សញ្ចេតនិយវគ្គ. ៤៣. ២៨/៥៩ ។

ប្រែប្រួល មានអត្ថថា គួរកំណត់ដឹង"[១] ។

តែក្នុងទីនេះ សមយ ស័ព្ទនោះមានកាលៈជាអត្ថ ព្រោះហេតុនោះ គប្បីឃើញសេចក្ដីក្នុងបទថា តេន សមយេន នេះ យ៉ាងនេះថា សេចក្ដីរំពឹងជាហេតុទូលអង្វរឱ្យទ្រង់បញ្ញត្តិវិន័យ កើតឡើងដល់ព្រះសារីបុត្រ ដោយកាលណា ដោយកាលនោះ ។

ក្នុងបទថា តេន សមយេន នេះ ចោទជំទាស់ថា កាលជាដូច្នោះ ហេតុអ្វី ក្នុងវិន័យនេះ ទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិថា តេន សមយេន មិនធ្វើដោយទុតិយាវិភត្តិថា ឯកំ សមយំ ដូចក្នុងសុត្តន្ត: និងដោយសត្តមីវិភត្តិថា យស្មឹ សមយេ កាមាវចរំ ដូចក្នុងអភិធម្មហ្ន៎ ? ឆ្លើយថា ព្រោះសេចក្ដីសមទឹងសេចក្ដី ដោយប្រការយ៉ាងនោះ ក្នុងសុត្តន្ត:និងអភិធម្មនោះ និងព្រោះសេចក្ដីសមទឹងសេចក្ដី ដោយប្រការដទៃក្នុងវិន័យនេះ សមទឹងសេចក្ដីយ៉ាងណា ? សមយស័ព្ទមានអច្ចន្តសំយោគជាអត្ថ សមគួរក្នុងសុត្តន្ត:មុន ។ ពិតមែន ព្រះមានព្រះភាគស្ដេចនៅដោយករុណាវិហារ រហូតដល់អស់ទីបំផុតសម័យដែលទ្រង់សម្ដែងព្រះសុត្តន្ត:ទាំងឡាយ មានព្រហ្មជាលសូត្រជាដើមតែម្ដង ព្រោះ

---

១. ខុទ្. បដិ. មហាវគ្គ. ៦៩. ២៦៤/២៦៦ ។

ហេតុនោះ ក្នុងសុត្តន្តៈនោះ ទើបលោកធ្វើឧបយោគនិទ្ទេស ដើម្បីបំភ្លឺសេចក្ដីនោះ ។ ក៏ឯសមយសព្ទមានអធិករណៈជាអត្ថ និងសេចក្ដីកំណត់ភាវៈដោយភាវៈជាអត្ថ រមែងសមគួរ ក្នុងអភិធម្ម ។ ពិតមែន សមយសព្ទមានកាលៈជាអត្ថ និងមានសមូហៈជាអត្ថ ជាអធិករណ៍នៃធម៌ទាំងឡាយមានផស្សៈជាដើម ដែលព្រះមានព្រះភាគត្រាស់ក្នុងអភិធម្មនោះ ភាវៈនៃធម៌ទាំងនោះ ដែលលោក រមែងកំណត់ដោយសេចក្ដីមាននៃសម័យ ពោលគឺ ខណៈ សមវាយៈ និងហេតុ ព្រោះហេតុនោះ ក្នុងអភិធម្មនោះ ទើបលោកធ្វើនិទ្ទេសដោយសត្តមីវិភត្តិ ដើម្បីបំភ្លឺសេចក្ដីនោះ ។ ចំណែកក្នុងវិន័យនេះ សមយសព្ទមានហេតុជាអត្ថ និងមានករណៈជាអត្ថ ទើបសមគ្នា ។

ក៏សម័យបញ្ញត្តិសិក្ខាបទណានោះ ជាសម័យដែលព្រះសារីបុត្រជាដើមដឹងបានលំបាក, ដោយសម័យនោះ ដែលជាហេតុនិងករណៈ ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ និងទ្រង់ពិចារណាមើលហេតុនៃការបញ្ញត្តិសិក្ខាបទ បានស្ដេចប្រថាប់នៅក្នុងទីនោះ ៗ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិក្នុងវិន័យនេះ ដើម្បី

បំភ្លឺសេចក្ដីនោះ ។ ក៏ក្នុងទីនេះមានគាថា (ដោយអំណាចនៃការសង្គ្រោះសេចក្ដីតាមដែលពោលហើយ) ដូចតទៅនេះថា ព្រោះពិចារណាសេចក្ដីនោះ ៗ ទើបព្រះថេរៈទាំងឡាយពោល សមយ ស័ព្ទ ក្នុងព្រះសូត្រ និងព្រះអភិធម្មកន្លែងណាមួយដោយតតិយាវិភត្តិ និងសត្តមីវិភត្តិ, សមយស័ព្ទនោះ លោកពោលក្នុងព្រះវិន័យនេះ ដោយតតិយាវិភត្តិប៉ុណ្ណោះ ។

ចំណែកព្រះបូរាណាចារ្យពណ៌នាទុកថា សេចក្ដីផ្សេងគ្នានេះថា តំ សមយំ រហូតដល់អស់សម័យនោះក្ដី ថា តស្មឹ សមយេ ក្នុងសម័យនោះក្ដី ថា តេន សមយេន សម័យនោះឯងក្ដី ប្លែកគ្នាតែត្រឹមតែពាក្យ, ក្នុងគ្រប់ ៗ បទមានសត្តមីវិភត្តិប៉ុណ្ណោះ ជាអត្ថ ។ ព្រោះដូច្នោះ តាមលទ្ធិរបស់ព្រះបូរាណាចារ្យនោះ សូម្បីកាលលោកពោលពាក្យថា តេន សមយេន : សម័យនោះឯង ក៏គប្បីឃើញសេចក្ដីថា តស្មឹ សមយេ : ក្នុងសម័យនោះ ។

ខ្ញុំព្រះករុណានឹងពណ៌នាអត្ថនៃបទទាំងនេះថា ពុទ្ធោ ភគវា ដូច្នេះ ជាដើមខាងមុខ ។

## អត្ថាធិប្បាយពាក្យថា វេរញ្ជាយំ វិហរតិ

ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វេរញ្ជាយំ វិហរតិ នេះ ដូចតទៅនេះ ៖

ពាក្យថា វេរញ្ជាយំ នេះ ជាឈ្មោះក្រុងមួយ ក្នុងស្រុកវេរញ្ជានោះ ។ ពាក្យថា វេរញ្ជាយំ នេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត ។ ពាក្យថា វិហរតិ ជាការសម្តែងដល់ភាពជាអ្នកប្រកបព្រមដោយធម៌ ជាគ្រឿងនៅយ៉ាងណាមួយ បណ្តាធម៌ជាគ្រឿងនៅ គឺ ឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារដោយមិនប្លែកគ្នា ។ តែក្នុងទីនេះសម្តែងដល់ការប្រកបដោយឥរិយាបថយ៉ាងណាមួយបណ្តាឥរិយាបថមានប្រភេទ គឺ ការឈរ ការដើរ ការអង្គុយ និងការដេក ។ ព្រោះដូច្នោះព្រះមានព្រះភាគប្រថាប់ឈរក្តី ស្តេចយាងទៅក្តី ប្រថាប់អង្គុយនៅក្តីផ្ទំក្តី បណ្ឌិតគប្បីជ្រាបថា ស្តេចប្រថាប់នៅទាំងនោះ ។ ពិតមែន ព្រះមានព្រះភាគអង្គនោះ ទ្រង់បំបាត់សេចក្តីលំបាកនៃឥរិយាបថមួយ ដោយឥរិយាបថមួយទៀត ទ្រង់នាំ គឺ ទ្រង់ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅមិនឱ្យទ្រុឌទ្រោម ព្រោះដូច្នោះ ទើបលោកហៅថា ស្តេចប្រថាប់នៅ ។

## អត្ថាធិប្បាយពាក្យថា នឡេរុបុចិមន្ទមូលេ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា នឡេរុបុចិមន្ទមូលេ នេះ ដូចតទៅនេះ ៖

យក្សឈ្មោះ នឡេរុ ។ ដើមស្ដៅឈ្មោះថា បុចិមន្ទៈ ។ បទថា មូលំ : មូល គឺ គល់, ក្នុងទីជិត ។ ពិតមែន មូលសព្ទនេះ រមែងប្រាកដក្នុងឫសគល់ ក្នុងពាក្យទាំងឡាយជាដើមដូចថា "មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡិមត្តានិបិ : ក៏គេីចយកឫសទាំងឡាយដោយហោចទៅសូម្បីប៉ុនលំពង់ស្បូវភ្លាំង (ក៏មិនឱ្យសល់)"[១] ។ ក្នុងហេតុដែលមិនទូទៅក្នុងពាក្យជាដើមថា "លោភោ អកុសលមូលំ : លោភៈ ជាឫសនៃអកុសល"[២] ។ ក្នុងទីជិត ក្នុងពាក្យទាំងឡាយជាដើមថា "យាវ មជ្ឈន្ហិកេ កាលេ ឆាយា ផរតិ, និវាតេ បណ្ណានិ បតន្តិ, ឯត្តាវតា រុក្ខមូល : ម្លប់រមែងជះទៅក្នុងវេលាថ្ងៃត្រង់, ស្លឹកឈើទាំងឡាយ រមែងធ្លាក់ទៅក្នុងពេលស្ងប់ខ្យល់ បានត្រឹមទីណា ដោយទីត្រឹមតែប៉ុណ្ណោះ ឈ្មោះថា រុក្ខមូល (គល់ឈើ)" ។ តែក្នុងបទថា មូលេនេះ

---

១. អង្គុ តិក. មហាវគ្គ. ៤១. ៧១/២៥៧ ។ ២. ទីឃ. បាជិ. សង្គីតិសុត្ត. ១៩. ៩៩/១៣៤ ។

លោកប្រាថ្នាយកទីជិត ។ ព្រោះដូច្នោះ គប្បីឃើញសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ទីជិតដើមស្តៅដែលនឡេរុយក្សស្ថិតនៅហើយ ។ បានឮថា ដើមស្តៅនោះ គួររីករាយ គួរជ្រះថ្លា ធ្វើហាក់ដូចជាម្ចាស់ធំនៃដើមឈើជាច្រើន មាននៅក្នុងទីដែលដល់ព្រមដោយមកទៅមកមិនឆ្ងាយអំពីនគរនោះ ។

គ្រានោះឯង ព្រះមានព្រះភាគស្តេចយាងទៅស្រុកវេរញ្ជា កាលនឹងប្រថាប់នៅក្នុងស្ថានដែលសមគួរ ទើបប្រថាប់នៅក្នុងទីជិត គឺ ចំណែកខាងក្រោមនៃដើមឈើនោះ ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលថា "ទ្រង់គង់នៅក្បែរដើមស្តៅជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា" ។ បើនឹងមានពាក្យជំទាស់ក្នុងសេចក្តីនោះថា បើព្រះមានព្រះភាគគង់នៅក្នុងស្រុកវេរញ្ជាមុន, ពាក្យថា នៅក្បែរដើមស្តៅជាលំនៅរបស់នឡេរុយក្សដែលព្រះឧបាលីថេរៈមិនគួរពោល, បើស្តេចប្រថាប់នៅក្បែរដើមស្តៅជាលំនៅរបស់នឡេរុយក្សនោះ, ពាក្យថា ក្នុងស្រុកវេរញ្ជា ព្រះថេរៈក៏មិនគួរពោល, ព្រោះថា ព្រះមានព្រះភាគ មិនអាចស្តេចប្រថាប់នៅក្នុងពីរកន្លែងព្រម ៗ គ្នា ដោយសម័យតែមួយនោះបាន ។ តែពាក្យថា វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ នោះ បណ្ឌិតមិនគប្បីឃើញ

យ៉ាងនោះឡើយ, ខ្ញុំព្រះករុណាបានពោលហើយមិនមែនឬថា បទថា វេរញ្ជាយំ ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលស្តេចគង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ក្នុងទីជិតស្រុកវេរញ្ជា ទើបព្រះឧបាលីថេរៈពោលថា "ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា" សូម្បីក្នុងព្រះបាលី ស្រុកនេះ ដូចហ្វូងគោទាំងឡាយ កាលត្រាច់ទៅក្នុងទីជិតនៃទន្លេគង្គានិងយមុនាជាដើម ជនទាំងឡាយ រមែងពោលថា "ត្រាច់ទៅជិតទន្លេគង្គា ត្រាច់ទៅជិតទន្លេយមុនា" ដូច្នោះ ។

## អធិប្បាយពាក្យថា វេរញ្ជាយំ និង នឡេរុបុចិមន្ទមូលេ

ក្នុងពាក្យថា វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ : ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា នេះ បណ្ឌិតគប្បីជ្រាបអត្ថយោជនា ដោយន័យជាដើម យ៉ាងនេះថា ពិតមែន ពាក្យថា វេរញ្ជាមានការសម្តែងគោចរគ្រាមរបស់ព្រះមានព្រះភាគនោះជាប្រយោជន៍ ។ ពាក្យថា នឡេរុបុចិវាទមូល មានការសម្តែងស្ថានជាទីនៅដែលសមគួរដល់បព្វជិតជាប្រយោជន៍ ។

ព្រះឧបាលីថេរៈសម្តែងការដែលព្រះមានព្រះភាគ ទ្រង់ធ្វើការ

អនុគ្រោះពួកគ្រហស្ថ ក្នុងបណ្ដាពាក្យកំណត់ទាំងពីរនោះ ដោយពាក្យកំណត់ថា វេរញ្ជ សម្ដែងការដែលទ្រង់អនុគ្រោះបព្វជិត ដោយពាក្យកំណត់ថា នឡេរុបុចិមន្ទមូល ។

មួយទៀត សម្ដែងសេចក្ដីវៀរអត្តកិលមថានុយោគ ព្រោះការទទួលបច្ច័យ ដោយពាក្យកំណត់ដើម, សម្ដែងឧទាហរណ៍នៃឧបាយ ក្នុងការវៀរកាមសុខល្លិកានុយោគ ព្រោះលះវត្ថុកាមចេញ ដោយពាក្យកំណត់ក្រោយ ។ មួយទៀត សម្ដែងការដែលព្រះមានព្រះភាគទ្រង់ប្រកបក្រៃលែងដោយធម្មទេសនា ដោយពាក្យកំណត់ដើម, សម្ដែងការដែលព្រះមានព្រះភាគទ្រង់បង្អោនទៅដើម្បីវិវេក ដោយពាក្យកំណត់ក្រោយ ។ សម្ដែងការដែលព្រះមានព្រះភាគទ្រង់ប្រកបដោយព្រះករុណា ដោយពាក្យកំណត់ដើម, សម្ដែងការដែលទ្រង់ប្រកបដោយព្រះបញ្ញា ដោយពាក្យកំណត់ក្រោយ ។ សម្ដែងភាពដែលព្រះមានព្រះភាគទ្រង់បង្អោនព្រះទ័យទៅ ក្នុងការញ៉ាំងហិតសុខឱ្យសម្រេចដល់សត្វទាំងឡាយ ដោយពាក្យកំណត់ដើម, សម្ដែងប្រការដែលព្រះមានព្រះភាគមិនចូលទៅជាប់ក្នុងការធ្វើហិតសុខដល់សត្វដទៃ ដោយពាក្យកំណត់ក្រោយ ។ សម្ដែងការដែលព្រះមានព្រះភាគ ទ្រង់នៅសប្បាយមានការមិនលះបង់សុខដែលប្រកបដោយធម៌ជាគ្រឿងកំណត់ ដោយពាក្យកំណត់ដើម, សម្ដែង

ភាពដែលព្រះមានព្រះភាគទ្រង់នៅសប្បាយ មានសេចក្ដីតាមប្រកបក្នុងឧត្តរិមនុស្សធម្មជាគ្រឿងកំណត់ ដោយពាក្យកំណត់ក្រោយ ។ សម្ដែងភាពដែលព្រះមានព្រះភាគ ទ្រង់ច្រើនដោយឧបការៈដល់មនុស្សទាំងឡាយ, ដោយពាក្យកំណត់ដើម, សម្ដែងភាពដែលព្រះអង្គជាអ្នកច្រើន ដោយឧបការៈដល់ទេវតាទាំងឡាយ ដោយពាក្យកំណត់ក្រោយ ។ សម្ដែងប្រការដែលព្រះមានព្រះភាគ ស្ដេចឧប្បត្តិឡើងក្នុងលោកហើយចម្រើនព្រមក្នុងលោកដោយពាក្យកំណត់ដើម, សម្ដែងភាពដែលព្រះមានព្រះភាគមិនចូលទៅជាប់នៅក្នុងលោក ដោយពាក្យកំណត់ក្រោយ ។ ដោយពាក្យកំណត់ដើម សម្ដែងការដែលព្រះអង្គទ្រង់ញុំាងប្រយោជន៍ជាទីស្ដេចឧប្បត្តិឱ្យសម្រេចរៀបរយ តាមព្រះបាលីថា "ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ឯកបុគ្គលោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ : ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកកាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ, បុគ្គលឯក តើគឺនរណា គឺ ព្រះតថាគត

អរហន្តសម្មាសម្ពុទ្ធ”[១] ដោយពាក្យកំណត់ខាងក្រោយ សម្តែងសេចក្តីនៅសមគួរដល់ស្ថានទីស្តេចឧប្បត្តិ ។ ពិតមែន ព្រះមានព្រះភាគស្តេចឧប្បត្តិក្នុងព្រៃប៉ុណ្ណោះ ដោយសេចក្តីឧប្បត្តិទាំងដែលជាលោកិយៈ និងលោកុត្តរៈ គឺ គ្រាដំបូងត្រង់លុម្ពិនីវ័ន គ្រាទីពីរត្រង់ពោធិមណ្ឌល ដោយហេតុនោះ ព្រះឧបាលីថេរៈ ទើបសម្តែងទីនៅរបស់ព្រះអង្គក្នុងព្រៃទាំងនោះ ។

## អធិប្បាយពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ : ជាមួយនឹងភិក្ខុសង្ឃ មានចំនួនច្រើន នេះតទៅ ៖

បទថា មហតា មានសេចក្តីថា ធំដោយភាពជាអ្នកមានគុណធំខ្លះ ធំដោយភាពជាអ្នកមានចំនួនច្រើនខ្លះ ។ ពិតមែន ភិក្ខុសង្ឃនោះ បានជាធំដោយគុណទាំងឡាយខ្លះ ព្រោះហេតុថា ភិក្ខុដែលមានគុណយ៉ាងទាបក្នុងភិក្ខុសង្ឃនោះ បានជាព្រះសោតាបន្នបុគ្គល បានជាធំដោយចំនួនខ្លះ ព្រោះមានចំនួន ៥០០ ។ ពួកនៃភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ។ ដោយភិក្ខុសង្ឃនោះ ។ អធិប្បាយថា ដោយពួកសមណៈអ្នកស្មើគ្នាដោយ

---

១. អង្គុ. ឯក. ឯកបុគ្គលបាលី. ៤០. ១៣៩/៤៩ ។

គុណពោលគឺ ភាពជាអ្នកមានទិដ្ឋិនិងសីលស្មើគ្នា ។ បទថា សទ្ធឹ : ជាមួយនឹង គឺ ដោយភាពជាពួកតែមួយ ។ ពាក្យថា បញ្ចមត្តេហិ ភិក្ខុសតេហិ : ប្រមាណ ៥០០ រូប មានវិគ្រោះថា ចំនួន ៥ ជាប្រមាណរបស់ភិក្ខុទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា បញ្ចមត្តា ។ ប្រមាណលោកហៅថា មត្តា ។ ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញសេចក្តីសូម្បីក្នុងបាលីប្រទេសនេះយ៉ាងនេះថា រយនៃភិក្ខុទាំងនេះ មានចំនួន ៥ គឺ មានប្រមាណ ៥ ដូចយ៉ាងកាលលោកពោលថា ភោជនេ មត្តញ្ញូ រមែងមានអត្ថថា ដឹងចំនួន គឺ ស្គាល់ប្រមាណក្នុងភោជនដូច្នោះ ។ រយនៃភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសតានិ. ដោយរយនៃភិក្ខុ ដែលមានចំនួនប្រាំទាំងនោះ ។ ក្នុងពាក្យដែលព្រះថេរៈពោលថា មហតា ភិក្ខុសង្ឃេន សទ្ធឹ នេះ ជាការដែលលោកសម្តែងសេចក្តីដែលភិក្ខុសង្ឃធំនោះ ជាអ្នកធំដោយចំនួន ដោយពាក្យថា បញ្ចមត្តេហិ ភិក្ខុសតេហិ នេះ ។ ចំណែកសេចក្តីដែលភិក្ខុសង្ឃនោះ ជាអ្នកធំដោយគុណ នឹងមានច្បាស់ខាងមុខដោយពាក្យថា "ម្នាលសារីបុត្រ ពីព្រោះ (ឥឡូវនេះ) សង្ឃនៅមិនទាន់មានពុត (ហានលបធ្វើអាក្រក់) នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ

ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ ផង់ចិត្តស្ថិតនៅក្នុងធម៌មានខ្លឹមនៅឡើយ, ម្នាលសារីបុត្រ ក៏បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុត ក៏គង់បានសម្រេចត្រឹមថ្នាក់សោតាបន្នបុគ្គល"[១] ដូច្នេះ ។

## អធិប្បាយពាក្យថា អស្សោសិ ខោ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អស្សោសិ ខោ វេរញ្ជោ ព្រាហ្មណោ : វេរញ្ជព្រាហ្មណ៍ បានឮច្បាស់នូវដំណឹងនោះហើយ ដូចតទៅនេះ ៖

បទថា អស្សោសិ : បានឮច្បាស់ សេចក្ដីថា ស្ដាប់ គឺ បានស្ដាប់ បានដល់ បានជ្រាបតាមទំនងនៃសំឡេងរបស់ពាក្យនិយាយ ដែលដល់សោតទ្វារ ។ សព្ទថា ខោ ជានិបាតចុះក្នុងអត្ថត្រឹមតែធ្វើបទឱ្យពេញ ឬចុះក្នុងអត្ថនៃអវធារណៈ ។ បណ្ដាអត្ថទាំងពីរនោះ ដោយអត្ថនៃអវធារណៈ គប្បីជ្រាបសេចក្ដីដូច្នេះថា បានស្ដាប់ពិត ៗ អន្តរាយនៃការស្ដាប់អ្វី ៗ មិនបានមានដល់ព្រាហ្មណ៍នោះ ។ ដោយអត្ថថា ធ្វើបទឱ្យ

---

១. វិន. បារា. មេថុនធម្មសិក្ខាបទ. ១. ៨/៣០ ។

ពេញ គប្បីជ្រាបថា ត្រឹមតែជាសេចក្ដីពីរោះរណ្ដំនៃបទទសិនព្យញ្ជនៈ ប៉ុណ្ណោះ ។ ព្រាហ្មណ៍អ្នកកើតក្នុងស្រុកវេរញ្ជា ឈ្មោះថា វេរញ្ជៈ ។ ព្រាហ្មណ៍មានក្នុងស្រុកវេរញ្ជា ឈ្មោះថា វេរញ្ជៈ ។ ម្យ៉ាងទៀត ស្រុកវេរញ្ជាជាទីនៅរបស់ព្រាហ្មណ៍នោះ ព្រោះដូច្នោះ ព្រាហ្មណ៍នោះ ទើបឈ្មោះថា វេរញ្ជៈ ។ ប៉ុន្តែថា ព្រាហ្មណ៍នេះ អ្នកក្រុងហៅថា ឧទ័យ ដោយអំណាចឈ្មោះដែលមាតាបិតាតាំងឱ្យ ។ អ្នកណា រមែងស្វាធ្យាយព្រះវេទ អធិប្បាយថា ស្វាធ្យាយមន្តទាំងឡាយ ហេតុនោះ អ្នកនោះឈ្មោះថា ព្រាហ្មណ៍ ។ ពិតមែន ពាក្យថា ព្រាហ្មណ៍នេះឯង ជាពាក្យហៅពួកព្រាហ្មណ៍ដោយជាតិ ។ តែព្រះអរិយៈទាំងឡាយ លោកហៅថាព្រាហ្មណ៍ ព្រោះភាពជាអ្នកមានបាប បានអណ្ដែតចេញហើយ ។

## អធិប្បាយរឿងដែលព្រាហ្មណ៍បានស្ដាប់

ឥឡូវនេះ ព្រះឧបាលីថេរៈកាលនឹងប្រកាសរឿងដែលវេរញ្ជព្រាហ្មណ៍បានស្ដាប់ ទើបបានពោលពាក្យមានថា សមណោ ខលុ ភោ គោតមោ : ទើបប្រកាសសេចក្ដីថា ម្នាលគ្នាយើង បានឮថា សមណគោតម ជាដើម ។ ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគឈ្មោះថា សមណៈ ព្រោះជាអ្នកមានបាបស្ងប់ហើយ ។ សេចក្ដីនេះ សមពិតដូច

ពាក្យដែលព្រះអង្គត្រាស់ទុកថា "អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍[១] អ្នកដែលតថាគត ហៅថា សមណៈ ព្រោះ(បាបទាំងឡាយដែល)បុគ្គលនោះរម្ងាប់បានហើយ[២]" ។ ក៏ព្រះមានព្រះភាគ ចាត់ថា ជាអ្នកមានបាបដែលអរិយមគ្គយ៉ាងកំពូលឱ្យស្ងប់ហើយ ។ ព្រោះដូច្នោះ ព្រះនាម គឺ សមណៈនេះ ព្រះអង្គទ្រង់សម្រេចហើយ ដោយគុណតាមសេចក្ដីពិត ។

បទថា ខលុ ជានិបាត ចុះក្នុងអត្ថថា បានស្ដាប់មក ។

ពាក្យថា ភោ ត្រឹមតែជាពាក្យហៅដែលមកហើយដោយជាតិ នៃពួកជនអ្នកមានជាតិជាព្រាហ្មណ៍ ។ សូម្បីសេចក្ដីនេះ ក៏សមពិតដូចពាក្យដែលព្រះអង្គត្រាស់ទុកថា "ភោវាទី នាមសោ ហោតិ សចេ ហោតិ សកិញ្ចនោ : បុគ្គល នោះ គ្រាន់តែបានទាមថា ភោវាទី (អ្នកពោលថាចម្រើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសគ្រឿងកង្វល់នៅឡើយ"[៣] ។ ដោយពាក្យថា គោតមោ នេះ វេរញ្ជព្រាហ្មណ៍ ទូលហៅព្រះមានព្រះភាគ ដោយអំណាចនៃព្រះគោត្រ ។ ព្រោះដូច្នោះ បណ្ឌិត

---

១. ខុទ្ទ. ធម្ម. ព្រាហ្មណវគ្គ. ៥២. ៣៦/១០៣ ។ ២. ខុទ្ទ. ធម្ម. ធម្មដ្ឋវគ្គ. ៥២. ២៩/៧៦ ។ ៣. ខុទ្ទ. ធម្ម. ព្រាហ្មណវគ្គ. ៥២. ៣៦/១០៥ ។

គប្បីឃើញសេចក្ដីក្នុងពាក្យថា សមណោ ខលុ ភោ គោតមោ នេះ យ៉ាងនេះថា បានឮថា ព្រះសមណគោតមគោត្រដ៏ចម្រើន ។ ចំណែកពាក្យថា សក្យបុត្តោ ជាសក្យបុត្តនេះ សម្ដែងដល់ត្រកូលដែលខ្ពស់របស់ព្រះមានព្រះភាគ ។ ពាក្យថា សក្យកុលា បព្វជិតោ : ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស សម្ដែងសេចក្ដីដែលព្រះមានព្រះភាគទ្រង់ព្រះផ្នួសដោយសទ្ធា ។ មានពាក្យអធិប្បាយថា ព្រះអង្គមិនមានសេចក្ដីសាបសូន្យ ណាមកគ្របសង្កត់ ទ្រង់លះបោលត្រកូលនោះ ដែលមិនមានសេចក្ដីវិនាសបាត់បង់សោះឡើយ ហើយទ្រង់ព្រះផ្នួសដោយសទ្ធា ។ ពាក្យដទៃក្រៅពីនោះមានអត្ថដែលខ្ញុំព្រះករុណាពោលហើយឯង ។

ទុតិយាវិភត្តិដែលមាននៅក្នុងបទថា តំ ខោ បន នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថដែលពោលដល់ឥត្ថម្ភូត ។ សេចក្ដីថា ក៏ (កិត្តិសព្ទដ៏ពីរោះ) របស់ព្រះគោតមដ៏ចម្រើននោះឯង (សុសសាយទៅហើយយ៉ាងនេះថា ...) ។

បទថា កល្យាណោ គឺ ប្រកបដោយគុណដែលល្អ អធិប្បាយថា ប្រសើរ ។ កិត្តិសព្ទនោះឯង ឬសំឡេងពោលសរសើរ ឈ្មោះថា កិត្តិសព្ទ ។

# អធិប្បាយពុទ្ធគុណ

ក៏ក្នុងពាក្យទាំងឡាយមានអាទិថា ឥតិបិ សោ ភគវា : ព្រះដ៏មានព្រះភាគ អង្គនោះ ជាដើម មានយោជនាដូចតទៅនេះជាដំបូងថា "ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រោះហេតុយ៉ាងនេះ, ជាសម្មាសម្ពុទ្ធ ព្រោះហេតុយ៉ាងនេះ, ជាអ្នកដល់ព្រមដោយវិជ្ជានិងចរណៈ ព្រោះហេតុយ៉ាងនេះ, ជាអ្នកមានដំណើរល្អទៅហើយ ព្រោះហេតុយ៉ាងនេះ, ជាអ្នកជ្រាបច្បាស់នូវត្រៃលោក ព្រោះហេតុយ៉ាងនេះ, ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ព្រោះហេតុយ៉ាងនេះ, ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុយ៉ាងនេះ, ជាអ្នកត្រាស់ដឹងហើយ ព្រោះហេតុយ៉ាងនេះ, ជាអ្នកចែកធម៌ ព្រោះហេតុយ៉ាងនេះ" ។ មានអធិប្បាយដែលលោកពោលទុកថា "ព្រោះហេតុនេះ និងហេតុនេះ" ។

ឥឡូវនេះ នឹងធ្វើការពណ៌នាដោយន័យពិស្ដារនៃបទទាំងនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងសុត្តន្តន័យ និងដើម្បីរីករាយនៃចិត្តដោយធម្មីកថា ដែលប្រកបដោយពុទ្ធគុណ ក្នុងវារៈប្រារព្ធខាងដើមនៃការពណ៌នាព្រះវិន័យរបស់ព្រះវិន័យធរទាំងឡាយ ។ ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យដែលលោកពោលទុកថា ៖

"ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រោះហេតុយ៉ាងនេះ" ដូច្នេះជាដើម ។

## ព្រះនាមថា អរហំ

ព្រះមានព្រះភាគអង្គនោះ បណ្ឌិតគប្បីជ្រាបថា ជាព្រះអរហន្ត (ព្រះអង្គ ឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង) ព្រោះហេតុទាំងនេះជាមុន គឺព្រោះជាអ្នកឆ្ងាយ និងទ្រង់កំចាត់សត្រូវទាំងឡាយ និងទ្រង់កាច់បំបាក់នូវកាំនៃចក្រទាំងឡាយ ព្រោះជាអ្នកគួរដល់បច្ច័យជាដើម ព្រោះមិនមានការលាក់បាំងក្នុងការធ្វើបាប ។

សេចក្ដីពិត ព្រះមានព្រះភាគនោះ ជាអ្នកឆ្ងាយ គឺ ទ្រង់តាំងនៅក្នុងព្រះគុណ ដែលឆ្ងាយសែនឆ្ងាយចាកសព្វកិលេស ព្រោះទ្រង់កម្ចាត់បេញនូវកិលេសទាំងឡាយ ព្រមទាំងវាសនា ដោយមគ្គ ព្រោះហេតុនោះទើបទ្រង់ព្រះនាមថា អរហំ ព្រោះជាអ្នកឆ្ងាយ ។ មួយទៀត សត្រូវ គឺកិលេសទាំងឡាយ ព្រះមានព្រះភាគនោះ ទ្រង់ទម្លាយចេញហើយដោយមគ្គ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា អរហំ សូម្បីព្រោះទ្រង់ទម្លាយសត្រូវទាំងឡាយចេញ ។ មួយទៀត កាំទាំងអស់នៃសង្សារចក្រ មានដុំដែលសម្រេចដោយអវិជ្ជា និងភវតណ្ហា មានកម្ម គឺ អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម មានកង់ គឺ ជរាមរណៈ ដែលចងទុកដោយភ្លៅដែលសម្រេចដោយអាសវសមុទ័យ ផ្ដុំទុកក្នុងរថពោល គឺភពបី ដែលប្រព្រឹត្តទៅហើយ អស់កាលជាអង្វែង មិនមានទីបំផុតខាងដើម ដែល

ព្រះមានព្រះភាគអង្គនោះ ទ្រង់ឈរនៅហើយ លើផែនដី គឺសីល ដោយព្រះយុគលបាទ គឺវិរិយៈ ទ្រង់កាន់ពូថៅ គឺញាណដែលធ្វើនូវការអស់ទៅនៃកម្ម ដោយព្រះហស្ត គឺសទ្ធា ទ្រង់កាច់បំបាក់បានហើយ ទៀបគល់ពោធិព្រឹក្ស ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា អរហំ សូម្បីព្រោះទ្រង់កាច់បំបាក់កាំនៃចក្រចេញ ។

## សង្សារវដ្ត គឺបដិច្ចសមុប្បាទជាបច្ច័យតគ្នា

ម្យ៉ាងទៀត សង្សារវដ្តមានខាងដើម និងខាងចុង គេមិនអាចដឹងបាន ព្រះមានព្រះភាគ ត្រាស់ហៅថា សង្សារចក្រ ។ ក៏អវិជ្ជា ជាដុំរបស់សង្សារចក្រនោះ ព្រោះជាមូលហេតុ, មានជរាមរណៈ ជាកង់ព្រោះជាទីបំផុត, ធម៌ ១០ យ៉ាង ដ៏សេសជាកាំ ព្រោះមានអវិជ្ជាជាមូលហេតុ និងព្រោះមានជរាមរណៈជាទីបំផុត ។

បណ្តាធម៌ មានអវិជ្ជាជាដើមនោះ ការមិនដឹងក្នុងអរិយសច្ចៈ មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ។ ក៏អវិជ្ជាក្នុងកាមភព រមែងជាបច្ច័យដល់សង្ខារទាំងឡាយ ក្នុងកាមភព ។ អវិជ្ជាក្នុងរូបភព រមែងជាបច្ច័យដល់សង្ខារទាំងឡាយក្នុងរូបភព ។ អវិជ្ជាក្នុងអរូបភពជាបច្ច័យដល់សង្ខារទាំងឡាយក្នុងអរូបភព ។ សង្ខារក្នុងកាមភព រមែងជាបច្ច័យ

ដល់បដិសន្ធិវិញ្ញាណក្នុងកាមភព ។ ក្នុងរូបភពនិងអរូបភព ក៏ន័យនេះ ។ បដិសន្ធិវិញ្ញាណក្នុងកាមភព រមែងជាបច្ច័យដល់នាមរូបក្នុងកាមភព ។ ក្នុងរូបភព ក៏ដូចគ្នា ។ បដិសន្ធិវិញ្ញាណក្នុងរូបភព រមែងជាបច្ច័យដល់នាមតែម្យ៉ាង ក្នុងអរូបភព ។ នាមរូបក្នុងកាមភព ជាបច្ច័យដល់អាយតនៈ៦ ក្នុងកាមភព ។ នាមរូបក្នុងរូបភព រមែងជាបច្ច័យដល់អាយតនៈ ទាំង៣ ក្នុងរូបភព ។ នាមក្នុងអរូបភព រមែងជាបច្ច័យដល់មនាយតនៈតែម្យ៉ាង ក្នុងអរូបភព ។ អាយតនៈ៦ ក្នុងកាមភព រមែងជាបច្ច័យដល់ផស្សៈ៦ ក្នុងកាមភព ។ អាយតនៈ៣ ក្នុងរូបភព រមែងជាបច្ច័យដល់ផស្សៈ៣ ក្នុងរូបភព ។ អាយតនៈ១ ក្នុងរូបភព រមែងជាបច្ច័យដល់ផស្សៈ១ ក្នុងអរូបភព ។ ផស្សៈ៦ ក្នុងកាមភព រមែងជាបច្ច័យដល់វេទនា៦ ក្នុងកាមភព ។ ផស្សៈ៣ ក្នុងរូបភពជាបច្ច័យដល់ផស្សៈ៣ ក្នុងរូបភពនោះឯង ។ ផស្សៈ១ ក្នុងអរូបភព រមែងជាបច្ច័យដល់វេទនា១ ក្នុងអរូបភពនោះឯង ។ វេទនា៦ ក្នុងកាមភព រមែងជាបច្ច័យដល់តណ្ហាកាយ៦ ក្នុងកាមភព ។ វេទនា៣ ក្នុងរូបភព ជាបច្ច័យដល់តណ្ហាកាយ៣ ក្នុងរូបភពនោះឯង ។ វេទនា១ ក្នុងអរូបភព រមែងជាបច្ច័យដល់តណ្ហាកាយ១ ក្នុងអរូបភព ។ តណ្ហានោះ ៗ ក្នុងកាមភពជាដើមនោះ ៗ រមែងជាបច្ច័យដល់ឧបាទាននោះ ៗ ។ ឧបាទានជាដើម

រមែងជាបច្ច័យដល់ភពជាដើម ។

គឺយ៉ាងណា ? គឺថា បុគ្គលខ្លះក្នុងលោកនេះគិតថា នឹងបរិភោគកាម រមែងប្រព្រឹត្តទុច្ចរិត ដោយកាយប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ព្រោះកាមុបាទានជាបច្ច័យ ព្រោះការពេញបរិបូរណ៍នៃទុច្ចរិត គេរមែងកើតក្នុងអបាយ ។ កម្មជាហេតុឱ្យកើតក្នុងអបាយនោះរបស់បុគ្គលនោះ ជាកម្មភព, ការកើតឡើងនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់គ្រាំគ្រា ជាជរា, ការបែកធ្លាយ ជាមរណៈ ។

បុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងសួគ, ប្រព្រឹត្តសុចរិតយ៉ាងនោះដូចគ្នា ព្រោះការបរិបូរណ៍នៃសុចរិត គេរមែងកើតក្នុងសួគ៌ ។ ពាក្យថា កម្មជាហេតុកើតក្នុងសួគ៌នោះរបស់គេ ជាកម្មភពជាដើម ក៏មានន័យដូចគ្នានោះ ។ ចំណែកបុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងព្រហ្មលោក រមែងចម្រើនមេត្តា ចម្រើនករុណា មុទិតា ឧបេក្ខា ព្រោះកាមុបាទានជាបច្ច័យ គេរមែងកើតក្នុងព្រហ្មលោក ព្រោះការបរិបូរណ៍នៃភាវនា ។ ពាក្យថា កម្មជាហេតុកើតក្នុងព្រហ្មលោកនោះរបស់គេ ជាកម្មភពជាដើម ក៏មានន័យដូចគ្នានោះ ។ បុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងអរូបភព ទើបចម្រើនសមាបត្តិទាំងឡាយ មានអាកាសានញ្ចាយតនៈជាដើម យ៉ាងនោះឯង ព្រោះការបរិបូរណ៍នៃ

ភាវនា គេរមែងកើតក្នុងអរូបភពនោះ ៗ ។ កម្មជាហេតុកើតក្នុងអរូបភព នោះរបស់គេ ជាកម្មភព ។ ខន្ធទាំងឡាយ ដែលកើតពីកម្ម ជាឧប្បត្តិភព, ការកើតនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់គ្រាំគ្រា ជាជរា, ការបែកធ្លាយ ជាមរណៈ ។ ក្នុងយោជនាទាំងឡាយ សូម្បីមានឧបាទាន ដែលសល់ ជាមូល ក៏ន័យនេះ ។

## ធម្មដ្ឋិតិញ្ញាណ

បញ្ញាក្នុងការកំណត់បច្ច័យ ដោយន័យដែលលោកពោលទុកយ៉ាងនេះថា អវិជ្ជានេះ ជាហេតុ សង្ខារទាំងឡាយកើតមកពីហេតុ អវិជ្ជានិងសង្ខារសូម្បីទាំង២ នេះ ក៏ជាហេតុសមុប្បន្នធម៌ (ធម៌ដែលជាហេតុនិងកើតពីហេតុ) ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។ បញ្ញាក្នុងការកំណត់បច្ច័យ ដោយន័យដែលលោកពោលយ៉ាងនេះថា អវិជ្ជាទាំងដែលជាអតីតទ្ធា (អតីតកាល) ទាំងដែលជាអនាគតទ្ធា (អនាគតកាល) ជាហេតុ សង្ខារទាំងឡាយកើតមកពីហេតុ អវិជ្ជា និងសង្ខារសូម្បីទាំងពីរនេះ ក៏ជាហេតុសមុប្បន្នធម៌ (ធម៌ដែលជាហេតុ និងកើតពីហេតុ) ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។ គ្រប់ ៗបទអ្នកសិក្សាគប្បីឱ្យពិស្ដារដោយន័យនេះ ។

## សង្ខេប និង អទ្ធាក្នុងបដិច្ចសមុប្បាទ

បណ្តាអង្គនៃបដិច្ចសមុប្បាទនោះ អវិជ្ជានិងសង្ខារ ជាសង្ខេបមួយ ៗ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និង វេទនា ជាសង្ខេបមួយ ៗ តណ្ហា ឧបាទាន និងភព ជាសង្ខេបមួយ ៗ ជាតិ និងជរាមរណៈ ជាសង្ខេបមួយ ៗ ក៏ក្នុងសង្ខេប ៤ នោះ សង្ខេបដើម ជាអតីតទ្ធា ១ ២ សង្ខេបកណ្តាល ជាបច្ចុប្បន្នទ្ធា ១ ជាតិ និងជរាមរណៈ ជាអនាគតទ្ធា ១

## វដ្តៈ និងសន្ធិ ៣ ក្នុងបដិច្ចសមុប្បាទ

ម្យ៉ាងទៀត ក្នុងសង្ខេបដើមនោះ តណ្ហា ឧបាទាន និងភពរមែងជាសភាពដែលលោកកាន់យកហើយ ដោយសភាព គឺអវិជ្ជា និងសង្ខារនុ៎ះឯង ព្រោះហេតុនោះ ធម៌ទាំង៥នេះ ចាត់ជាកម្មវដ្តៈក្នុងអតីត ១ ធម៌៥យ៉ាង មានវិញ្ញាណជាដើម ចាត់ជាវិបាកវដ្តៈក្នុងបច្ចុប្បន្ន ១ អវិជ្ជានិងសង្ខារ ជាសភាពដែលលោកកាន់យកហើយ ដោយសភាព គឺ តណ្ហាឧបាទាន និងភពនុ៎ះឯង ព្រោះហេតុនោះ ធម៌ទាំង៥ នេះ ចាត់ជាកម្មវដ្តៈក្នុងកាលឥឡូវនេះ (ក្នុងបច្ចុប្បន្ន) ១ ធម៌ទាំង៥ នេះ ចាត់ជាវិបាកវដ្តៈតទៅ (ក្នុងអនាគត) ព្រោះអង្គបដិច្ចសមុប្បាទ មានវិញ្ញាណជាដើមលោកសម្តែងដោយអាងដល់ជាតិ ជរា មរណៈ ១ បដិច្ចសមុប្បាទ

មានអវិជ្ជាជាដើមនោះ ពោលអំពីអាការ មាន ២០ យ៉ាង ។

ម្យ៉ាងទៀត ក្នុងអង្គបដិច្ចសមុប្បាទ មានសង្ខារជាដើមនេះ ចន្លោះសង្ខារនិងវិញ្ញាណ ជាសន្ធិមួយ ។ ចន្លោះវេទនានិងតណ្ហា ជាសន្ធិមួយ ។ ចន្លោះភពនិងជាតិ ជាសន្ធិមួយ ដូច្នេះឯង ។ ព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ជ្រាប ទ្រង់ចាក់ធ្លុះនូវបដិច្ចសមុប្បាទនេះ ដែលមានសង្ខេប ៤ អទ្ធា ៣ អាការ ២០ សន្ធិ ៣ ដោយអាការគ្រប់យ៉ាងដោយប្រការដូច្នេះ ។ ការដឹងនោះ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង (នូវសភាពពិត) ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងច្បាស់ ។ ព្រោះហេតុនោះ ទើបលោកពោលថា បញ្ញាក្នុងការកំណត់បច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ។ ព្រះមានព្រះភាគ ទ្រង់ដឹងធម៌ទាំងនោះ តាមសេចក្តីពិត ដោយធម្មដ្ឋិតិញ្ញាណនេះហើយ ទ្រង់នឿយណាយចាកតម្រេក និងរួចផុតចាកធម៌ មានអវិជ្ជាជាដើមនោះ ទើបបានកាច់បំបាក់ ទម្លាយកម្ទាត់នូវកាំទាំងឡាយនៃសង្សារចក្រចេញ មានប្រការដូចពោលហើយនេះ ។ ព្រះអង្គទ្រង់ព្រះនាមថា អរហំ ព្រោះទ្រង់កាច់បំបាក់នូវកាំនៃសង្សារចក្រចេញ សូម្បីដោយប្រការយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់គួរទទួលនូវបច្ច័យ មានចីវរជាដើម និងបូជាពិសេស ព្រោះទ្រង់ជាអគ្គទក្ខិណេយ្យបុគ្គល ។ ព្រោះ

ហេតុនោះឯង កាលព្រះតថាគតស្ដេចឧប្បត្តិឡើងហើយ ទេវតានិង មនុស្សអ្នកមានស័ក្ដិធំទាំងឡាយ ទើបមិនធ្វើការបូជាក្នុងទីដទៃ ។ ពិតមែន ស្ដេចសហម្បតិព្រហ្ម ទ្រង់បូជាព្រះតថាគត ដោយកម្រងរតនៈ (កែវ) ប៉ុនភ្នំសិណេរុ ។ ម្យ៉ាងទៀត ពួកទេវតា និង មនុស្សដទៃ ៗ មានព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសលជាដើម ក៏ទ្រង់បូជាហើយតាមកម្លាំង ។ ម្យ៉ាងទៀត ព្រះបាទអសោកមហារាជ ក៏ទ្រង់លះបង់ព្រះរាជទ្រព្យ ៩៦ កោដិ សាងវិហារប្រាំបីម៉ឺនបួនពាន់(៨៤,០០០) វិហារ ក្នុងសកលជម្ពូទ្វីប ឧទ្ទិសព្រះមានព្រះភាគ សូម្បីព្រះអង្គបរិនិព្វានហើយ ចាំបាច់ពោលទៅថ្វី ដល់ការបូជាពិសេសរបស់អ្នកដទៃ ៗ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ សូម្បីព្រោះព្រះអង្គគួរដល់បច្ច័យជាដើម ។ ម្យ៉ាងទៀត ពួកជនពាលដែលប្រកាន់ខ្លួនថា ជាបណ្ឌិតពួកណាមួយក្នុងលោក រមែងធ្វើបាបក្នុងទីកំបាំង ព្រោះខ្លាចការតិះដៀលយ៉ាងណា ព្រះមានព្រះភាគនោះ រមែងទ្រង់ធ្វើយ៉ាងនោះក្នុងគ្រាខ្លះក៏ទេ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា អរហំ ព្រោះមិនមានការធ្វើបាប សូម្បីក្នុងទីកំបាំង ។ ក៏ក្នុងព្រះនាមនេះ មានគាថាព័ន្ធ[១] មានសេចក្ដីដូច្នេះថា ៖

---

១. បរម. សុត្ត. មហាវគ្គ; សទ្ធម្ម. មហា. គុហដ្ឋកសុត្តនិទ្ទេស; សទ្ធម្ម. បដិ. ញាណកថា; ខុទ្ទកសិក្ខា បូរាណដីកា; វិសុទ្ធិមគ្គ; សទ្ទនីតិបករណ៍ ។

ព្រះមុនីអង្គនោះ ព្រោះហេតុតែទ្រង់ឃ្លាតឆ្ងាយ និងទ្រង់កំចាត់នូវសត្រូវ គឺកិលេសទាំងឡាយ ទ្រង់ជាអ្នកកាច់បំបាក់កាំនៃសង្សារចក្រ ជាអ្នកគួរដល់បច្ច័យជាដើម ទ្រង់រមែងមិនធ្វើបាបក្នុងទីកំបាំង ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា អរហំ ។

## ព្រះនាមថា សម្មាសម្ពុទ្ធោ

ម្យ៉ាងទៀត ព្រះមានព្រះភាគនោះ សម្មាសម្ពុទ្ធោ : ព្រះអង្គត្រាស់ដឹងនូវ ញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ គឺ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ ពិតមែនព្រះមានព្រះភាគនោះ ត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯងនូវធម៌ទាំងពួង គឺត្រាស់ដឹងធម៌ដែលគួរដឹងក្រៃលែង ដោយសភាពជាធម៌ដែលគួរដឹងក្រៃលែង, ត្រាស់ដឹងធម៌ ដែលគួរកំណត់ដឹង ដោយសភាពជាធម៌ដែលគួរកំណត់ដឹង, ត្រាស់ដឹងធម៌ដែលគួរលះ ដោយសភាពជាធម៌ដែលគួរលះ, ត្រាស់ដឹងធម៌ ដែលគួរធ្វើឱ្យច្បាស់ ដោយភាពជាធម៌ដែលគួរធ្វើឱ្យច្បាស់, ត្រាស់ដឹងធម៌ដែលគួរធ្វើឱ្យចម្រើន ដោយភាពជាធម៌ ដែលគួរធ្វើឱ្យចម្រើន ។ ព្រោះហេតុនោះឯង ទើបព្រះអង្គត្រាស់ថា ៖

វិជ្ជានិងវិមុត្តិដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ មគ្គសច្ចៈដែលគប្បីចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ចដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគត ឈ្មោះថា ពុទ្ធ ។[១]

ម្យ៉ាងទៀត ព្រះមានព្រះភាគនោះ ត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង សូម្បីដោយការលើកឡើងម្ដងមួយបទយ៉ាងនេះថា ចក្ខុជាទុក្ខសច្ចៈ តណ្ហាក្នុងភពមុន ដែលញ៉ាំងចក្ខុនោះឱ្យកើតដោយភាពជាមូលហេតុនៃចក្ខុនោះ ជាសមុទយសច្ចៈ ការមិនប្រព្រឹត្តទៅនៃចក្ខុនិងហេតុកើតនៃចក្ខុទាំងពីរ ជានិរោធសច្ចៈ ការបដិបត្តិជាហេតុឱ្យដឹងនិរោធ ជាមគ្គសច្ចៈ ។ ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ និងមនៈក៏មានន័យដូចគ្នា ។

បណ្ឌិតគប្បីប្រកបអាយតនៈ ៦ មានរូបជាដើម វិញ្ញាណកាយ ៦ មានចក្ខុវិញ្ញាណជាដើម, ផស្សៈ ៦ មានចក្ខុសម្ផស្សៈជាដើម, វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម, សញ្ញា ៦ មានរូបសញ្ញាជាដើម, ចេតនា ៦ មានរូបសញ្ចេតនាជាដើម, តណ្ហាកាយ ៦ មានរូបតណ្ហាជា

---

១. មជ្ឈិ. មជ្ឈិ. ២៣. ១២/២៨; ខុទ្ទ. សុត្ត. សេកសូត្រ. ៥៤. ៦៤/១៩៧; ខុទ្ទ. ថេរ. សេលត្ថេរ ៥៧. ២៥៤/៦៦ ។

ដើម, វិតក្កៈ ៦ មានរូបវិតក្កៈជាដើម, វិចារៈ ៦ មានរូបវិចារៈជាដើម, ខន្ធ ៥ មានរូបខន្ធជាដើម, កសិណ ១០ អសុភៈ ១០ អនុស្សតិ ១០ សញ្ញា១០ ដោយអំណាចឧទ្ធុមាតកសញ្ញាជាដើម[១] អាការ ៣២ មានសក់ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩ មានកាមភពជាដើម ឈាន ៤ មានបឋមឈានជាដើម អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម អរូបសមាបត្តិ ៤ មានអាកាសានញ្ចាយតនៈជាដើម និងអង្គនៃបដិច្ចសមុប្បាទ ដោយបដិលោម មានជរាមរណៈជាដើម ដោយអនុលោមមានអវិជ្ជាជាដើម ដោយន័យនេះនុ៎ះឯង ៗ ក្នុងជរាមរណៈជាដើមនោះ មានការប្រកបបទតែមួយដូចតទៅនេះ ៖

---

១. អង្គ. ទស. សចិត្តវគ្គ. ៥០ ៥៧/២៣០ សញ្ញា១០ គឺ អនិច្ចសញ្ញា, អនត្តសញ្ញា, មរណសញ្ញា, អាហារេ បដិកូលសញ្ញា, សព្វលោកេ អនភិរតសញ្ញា, អដ្ឋិកសញ្ញា, បុឡវកសញ្ញា វិនីលកសញ្ញា, វិច្ឆិទ្ទកសញ្ញា, ឧទ្ធុមាតកសញ្ញា, ឃើញតែនៅខាងចុង ៗ

សញ្ញាដទៃទៀត គឺ អង្គ. ទស. សចិត្តវគ្គ. (គិរិមានន្ទ) ៥០ ៦០/២៣៥ : សញ្ញា ១០ ប្រការ គឺ អនិច្ចសញ្ញា, អនត្តសញ្ញា, អសុភសញ្ញា, អាទីនវសញ្ញា, បហានសញ្ញា, វិរាគសញ្ញា, និរោធសញ្ញា, សព្វលោកេ អនភិរតសញ្ញា, សព្វសង្ខារេសុ អនិច្ចាសញ្ញា, អានាបានស្សតិ ៗ ទីឃ. បាដិ. ទសុត្តរសុត្រ. ១៩. ៣៤៤/៣៥១: សញ្ញា ១០ យ៉ាង គឺ អសុភសញ្ញា, មរណសញ្ញា, អាហារេ បដិកូលសញ្ញា, សព្វលោកេ អនភិរតិសញ្ញា, អនិច្ចសញ្ញា, អនិច្ចេ ទុក្ខសញ្ញា, ទុក្ខេ អនត្តសញ្ញា, បហានសញ្ញា, វិរាគសញ្ញា, និរោធសញ្ញា; អង្គ. ទស. ៥០ ៥៦/២២៩ ក៏ដូចគ្នា ៗ

ព្រះមានព្រះភាគនោះ ត្រាស់ដឹង គឺ ត្រាស់ដឹងតាមសមគួរ បានដល់ ចាក់ធ្លុះនូវធម៌ទាំងពួង ដោយប្រពៃ និងដោយព្រះអង្គឯង ដោយការលើកឡើងនូវបទមួយ ៗ យ៉ាងនេះថា ជរាមរណៈ ជាទុក្ខសច្ចៈ ជាតិជាសមុទយសច្ចៈ ការរលាស់ចេញនូវជរាមរណៈ និងហេតុកើតនៃជរាមរណៈនោះ សូម្បីទាំងពីរជានិរោធសច្ចៈ ការបដិបត្តិជាហេតុឱ្យដឹងនិរោធជាមគ្គសច្ចៈ ។ ព្រោះដូច្នោះ ទើបខ្ញុំបានពោលថា ម្យ៉ាងទៀត ព្រះមានព្រះភាគនោះ ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួង ដោយប្រពៃ និងដោយព្រះអង្គឯង ។

## ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ

ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា វិជ្ជាចរណ-សម្បន្នោ : ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺ ក៏ព្រោះទ្រង់ប្រកបព្រមដោយវិជ្ជា និង ចរណៈ ។ ក្នុងវិជ្ជានិងចរណៈនោះ វិជ្ជា ៣ក្តី វិជ្ជា ៨ ក្តី ឈ្មោះថា វិជ្ជា ។ វិជ្ជា ៣ គប្បីជ្រាបតាមន័យដែលត្រាស់ទុកក្នុងភយភេរវសូត្រនុ៎ះឯង ។ វិជ្ជា ៨ ក្នុងអម្ពដ្ឋសូត្រ ។ ក៏ក្នុងវិជ្ជា ៣ និងវិជ្ជា ៨ នោះ វិជ្ជា ៨ ព្រះអង្គត្រាស់ប្រមូលអភិញ្ញា ៦និងវិបស្សនាញាណ និងមនោមយិទ្ធិចូលផង ។ ធម៌ ១៥ នេះ គឺសីលសំវរៈ ជាអ្នកមានទ្វារដែលគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ

ជាអ្នកដឹងប្រមាណក្នុងភោជន ជាគរិយានុយោគ សទ្ធម្ម ៧ ឈាន ៤ គប្បីជ្រាបថា ឈ្មោះថា ចរណៈ ។ ពិតមែន ធម៌ ១៥ នេះឯង ព្រះអង្គត្រាស់ ហៅថា ចរណៈ ព្រោះហេតុថា ជាគ្រឿងធ្វើដំណើរ គឺជាគ្រឿងទៅកាន់ទិសដែលមិនស្លាប់របស់ព្រះអរិយសាវ័ក ។ ដូចសេចក្ដីដែលព្រះអានន្ទសម្ដែងទុកថា "បពិត្រមហានាម ព្រះអរិយសាវកក្នុងសាសនានេះ ជាអ្នកមានសីល"[១] ដូច្នេះជាដើម ។

អ្នកសិក្សាគប្បីជ្រាបសេចក្ដីពិស្ដារ ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយវិជ្ជាទាំងនេះ និងដោយចរណៈនេះ ព្រោះដូច្នោះ ទើបលោកហៅថា អ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ក្នុងការដល់ព្រមដោយវិជ្ជា និងចរណៈនោះ ការដល់ព្រមដោយវិជ្ជា ញុំាងភាពដែលព្រះមានព្រះភាគជាព្រះសព្វញ្ញូឱ្យពេញ ។ ការដល់ព្រមដោយចរណៈ ញុំាងសេចក្ដីដែលព្រះអង្គ ជាអ្នកប្រកបដោយព្រះមហាករុណាឱ្យពេញ ។ ព្រះមានព្រះភាគនោះ ទ្រង់ស្គាល់វត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍ ដល់សព្វសត្វ ដោយភាពជាសព្វញ្ញូហើយ ទ្រង់វៀរវត្ថុដែលមិនមែនប្រយោជន៍ចេញ ដោយភាពជាអ្នកប្រកបដោយព្រះមហាករុណា ទ្រង់ដឹកនាំក្នុងវត្ថុដែលជាប្រយោជន៍ ដូចអ្នកដែលដល់ព្រមដោយវិជ្ជា និងចរណៈ ដូច្នោះ

---

១. មជ្ឈិ. មជ្ឈិ. សេក្ខប្បដិបទាសូត្រ. ២៣. ២៧/៤៣ ។

៦៥ ។ ព្រោះហេតុនោះ ពួកសាវករបស់ព្រះមានព្រះភាគនោះ ទើបជាអ្នកបដិបត្តិល្អ មិនជាអ្នកបដិបត្តិអាក្រក់ទេ ។ ពួកសាវករបស់ព្រះមានព្រះភាគអង្គនោះ មិនជាអ្នកបដិបត្តិអាក្រក់ ដូចពួកសាវករបស់ពួកបុគ្គលអ្នកមានវិជ្ជា និងចរណៈវិបត្តិ ផ្ញើខ្លួនឱ្យក្តៅក្រហាយជាដើមដូច្នោះទេ ។

## ទ្រង់ព្រះនាមថា សុគតោ

សម្តេចព្រះមានព្រះភាគ ទ្រង់ព្រះនាមថា សុគតោ គឺ

| | |
|---|---|
| សោភនគមនត្តា | ព្រោះភាវៈដែលទ្រង់មានដំណើរទៅល្អ |
| សុន្ទរំ ឋានំ | ព្រោះភាវៈដែលស្តេចទៅកាន់ស្ថានទីល្អ |
| គតត្តា | ព្រោះភាវៈដែលស្តេចទៅដោយប្រពៃ |
| សម្មាគតត្តា | ព្រោះភាវៈដែលត្រាស់ទុកដោយប្រពៃ ។ |

ក៏សូម្បី គមនំ នឹងពោលថា គតំ ក៏បាន ។ និងការយាងនោះរបស់ព្រះមានព្រះភាគល្អស្អាត មិនមានទោស ក៏ការទ្រង់យាងទៅនោះបានដល់អ្វី ? បានដល់ មកដ៏ប្រសើរ ។ ក៏ព្រះមានព្រះភាគអង្គនោះស្តេចយាងទៅ កាន់ទិសដ៏ក្សេម មិនទើសទាក់ដោយការដែលយាងទៅនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះភាវៈដែលទ្រង់មានដំណើរទៅល្អ ។ ម្យ៉ាងទៀត ព្រះអង្គស្តេចទៅកាន់ស្ថានទីដែល

ល្អ គឺ អមតនិព្វាន ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះស្តេចទៅកាន់ស្ថានទីដ៏ល្អ ។ម្យ៉ាងទៀត ព្រះអង្គស្តេចទៅដោយប្រពៃ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះមិនត្រឡប់មករកពួកកិលេស ដែលមគ្គនោះៗ លះបានហើយ ។ សមពិត ដូចពាក្យដែលលោកពោលទុកថា ព្រះអង្គទ្រង់ព្រះនាមថា សុគតោ ព្រោះអត្ថថា មិនត្រឡប់មក មិនបែរឆ្ពោះមក មិនវិលត្រឡប់មករកពួកកិលេស ដែលសោតាបត្តិមគ្គលះបានហើយ ។ល។ ព្រះអង្គទ្រង់ព្រះនាមថា សុគតោ ព្រោះអត្ថថា មិនត្រឡប់មក មិនបែរឆ្ពោះមក មិនវិលមករកពួកកិលេស ដែលអរហត្តមគ្គលះបានហើយ ។

ម្យ៉ាងវិញទៀត ព្រះអង្គយាងទៅដោយប្រពៃ គឺ ទ្រង់យាងទៅធ្វើប្រយោជន៍ និងសេចក្តីសុខដល់លោកទាំងអស់តែម្យ៉ាង ដោយការបដិបត្តិប្រពៃ ដែលទ្រង់បំពេញមកដោយអំណាចព្រះបារមី ៣០ កំណត់ចាប់តាំងពីទៀបព្រះបាទរបស់ព្រះពុទ្ធទីបង្ករ ដរាបដល់គល់ឈើពោធិព្រឹក្ស និងមិនស្តេចចូលទៅជិតចំណែកទីបំផុតទាំងនេះ គឺ សស្សត (យល់ឃើញថា សត្វទៀង លោកទៀង) ឧច្ឆេទ (យល់ថា សត្វស្លាប់ទៅសូន្យ) សេចក្តីសុខក្នុងកាម ការធ្វើខ្លួនឱ្យលំបាក ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ សូម្បីព្រោះស្តេចទៅដោយប្រពៃ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនោះ ត្រាស់ទុកដោយប្រពៃ គឺត្រាស់ព្រះវាចាដែលគួរ ក្នុងឋានៈដែលគួរប៉ុណ្ណោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ សូម្បីព្រោះត្រាស់ដោយប្រពៃ ។

ក្នុងសេចក្តីនោះ មានព្រះសូត្រជាសាធកដូចតទៅនេះថា "(ម្នាលរាជកុមារ យ៉ាងហ្នឹងឯង) តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ; តថាគតដឹងនូវវាចាណាពិតទៀង តែមិនប្រកបដោយប្រយោជន៍ និងវាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង, ព្រះតថាគតក៏មិនពោលនូវវាចានោះ ; មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិតទៀង ប្រកបដោយប្រយោជន៍ តែថា វាចានោះ មិនជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតស្គាល់កាលគួរនឹងពោលវាចានោះ ក្នុងព្យាករណ៍នោះដែរ; តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះឡើយ ។ តថាគត ដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះដែរ ។ មួយវិញ

ទៀត តថាគតដឹងនូវវាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ វាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាលគួរ ទឹងពោលនូវវាចានោះ ក្នុងព្យាករណ៍នោះ (ម្នាលរាជកុមារ ព្រោះហេតុអ្វី ព្រោះថា តថាគតមានសេចក្ដីអនុគ្រោះចំពោះសត្វទាំងឡាយ)”[១] ។

ព្រះមានព្រះភាគនោះ បណ្ឌិតគប្បីជ្រាបថា សុគតោ សូម្បីព្រោះត្រាស់ព្រះវាចាប្រពៃ ដោយប្រការដូច្នេះ ។

## ទ្រង់ព្រះនាមថា លោកវិទូ

ម្យ៉ាងទៀត ព្រះមានព្រះភាគ ឈ្មោះថា លោកវិទូ : ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក គឺ ព្រោះព្រះអង្គទ្រង់ដឹងច្បាស់នូវលោកដោយប្រការគ្រប់យ៉ាង ។ ពិតមែន ព្រះមានព្រះភាគនោះ ទ្រង់ដឹង គឺទ្រង់ដឹងទូទៅ ទ្រង់ចាក់ធ្លុះនូវលោកដោយប្រការទាំងពួង ដោយសភាវៈខ្លះ ដោយសមុទយខ្លះ ដោយនិរោធខ្លះ ដោយឧបាយជាហេតុដល់និរោធខ្លះ ។

សមដូចដែលព្រះអង្គត្រាស់ទុកថា “ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកនា តថាគត

១. ម. ម. ២៣. ៩៤/១៥៧ ។

មិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុតនៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ (ដោយជើង)បានឡើយ ។ ម្នាលអាវុសោ មួយទៀត បើតថាគត មិនបានដល់នូវទីបំផុតនៃសង្ខារលោកហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោកផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង (ការបដិបត្តិជាដំណើរទៅកាន់ទីរំលត់នៃលោក) ក្នុងអត្តភាព ប្រមាណមួយព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្ត ។

> ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់បានដោយការដើរទៅ (ដោយជើង) ក្នុងកាលណាមួយឡើយ មួយទៀត ការមិនទាន់ដល់នូវទីបំផុតនៃលោក ឈ្មោះថា មិនបានរួចចាកទុក្ខឡើយ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់ នូវទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។ ទ្រង់មានបាបរម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់នូវទីបំផុតនៃលោកហើយ មិនប្រាថ្នានូវលោកនេះ និងលោកខាងមុខឡើយ”[១] ។

---

១. អង្គុ. ចតុ. រោហិតស្សវគ្គ. ៤២. ៤៧/១២១ ។

## អធិប្បាយ លោក ៣

ម្យ៉ាងទៀត លោកមាន ៣ គឺ សង្ខារលោក (លោកគឺសង្ខារ) សត្តលោក (លោក គឺ ពួកសត្វ) ឱកាសលោក (លោក គឺ ផែនដី) ។

បណ្ដាលោកទាំង ៣ នោះ លោកក្នុងអនាគតស្ថានថា លោក ១ បានដល់ ពួកសត្វទាំងអស់តាំងនៅបានដោយអាហារ[១] ដូច្នេះ គប្បីជ្រាបថា ជាសង្ខារលោក ។ លោកក្នុងអនាគតស្ថានថា លោកទៀង ឬថា លោកមិនទៀង ដូច្នេះជាដើម គប្បីជ្រាបថាជាសត្តលោក ។ លោកក្នុងអនាគតស្ថានថា

"ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយឱ្យភ្លឺបានត្រឹមណា, លោក គឺចក្រវាឡទាំងមួយពាន់ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានត្រឹមតែមួយពាន់ចក្រវាឡនុ៎ះ"[២] ដូច្នេះ ។

គប្បីជ្រាបថា ជាឱកាសលោក ។

១. ខុទ្ទ. បដិ. មហាវគ្គ. ៦៩. ២៧៥/២៧១ ។ ២. មជ្ឈិ. មូល. ព្រហ្មនិមន្តនិកសូត្រ. ២២. ១៩៤/៣៦៨ ។

## ព្រះមានព្រះភាគទ្រង់ដឹងច្បាស់លោកទាំង ៣

ព្រះមានព្រះភាគ បានទ្រង់ជ្រាបច្បាស់លោក សូម្បីទាំង ៣ នោះ ដោយប្រការទាំងពួង ។ ពិតមែន ព្រះមានព្រះភាគអង្គនោះ ទ្រង់បានដឹងច្បាស់នូវសង្ខារលោកនេះ ដោយប្រការទាំងពួង គឺ ៖

"លោក១ គឺពួកសត្វទាំងអស់តាំងនៅបានដោយអាហារ, លោក២ បានដល់ នាម១ រូប១, លោក៣ បានដល់ វេទនា៣, លោក៤ បានដល់ អាហារ៤, លោក៥ បានដល់ ឧបាទានខន្ធ៥, លោក៦ បានដល់ អាយតនៈខាងក្នុង៦, លោក៧ បានដល់ ទីតាំងនៃវិញ្ញាណ៧, លោក៨ បានដល់ លោកធម៌៨, លោក៩ បានដល់ ទីនៅរបស់សត្វ៩, លោក ១០ បានដល់ អាយតនៈ១០, លោក១២ បានដល់ អាយតនៈ១២, លោក១៨ បានដល់ ធាតុ១៨'"[១] ។

មួយទៀត ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបអាសយៈ (គឺឆន្ទៈជាទីមកដេក) អនុស័យ (គឺកិលេសដែលដេកនៅក្នុងសន្ដាន) ចរិត (គឺការប្រព្រឹត្ត) អធិមុត្តិ (គឺអធ្យាស្រ័យ) របស់ពួកសត្វសូម្បីទាំងពួង, (និង) ទ្រង់រមែងជ្រាបសត្វទាំងឡាយ អ្នកមានធូលី គឺកិលេសក្នុងបញ្ញាចក្ខុតិច អ្នកមានធូលី គឺ កិលេសក្នុងបញ្ញាចក្ខុច្រើន អ្នកមាន

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៦៩. ២៧៥/២៧៦ ។

ឥន្ទ្រិយចាស់ក្លា អ្នកមានឥន្ទ្រិយទន់ខ្សោយ អ្នកមានអាការល្អ អ្នកមានអាការអាក្រក់ អ្នកនឹងគប្បីឱ្យដឹងបានងាយ អ្នកនឹងគប្បីឱ្យដឹងបានលំបាក អ្នកគួរ (នឹងត្រាស់ដឹង) អ្នកមិនគួរ (នឹងត្រាស់ដឹង) ព្រោះដូច្នោះ សូម្បីសត្វលោក ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់ហើយដោយប្រការទាំងពួង ។ ដូចជាថា ព្រះអង្គទ្រង់ដឹងច្បាស់សត្វលោកយ៉ាងណា, សូម្បីឱកាសលោក (ផែនដី) ក៏ទ្រង់ដឹងច្បាស់ហើយយ៉ាងនោះ ។ ពិតមែន ព្រះមានព្រះភាគអង្គនោះ ទ្រង់បានដឹងច្បាស់ គឺ ទ្រង់បានជ្រាប បានដល់ ទ្រង់ចាក់ធ្លុះហើយនូវលោកធាតុ ដែលមិនមានទីបំផុតដោយព្រះពុទ្ធញាណ ដែលមិនមានទីបំផុត វេហុតអនន្តចក្រវាឡយ៉ាងនេះ គឺ ចក្រវាឡមួយ ពោលដោយចំណែកបណ្តោយ និងចំណែកទទឹងមានប្រមាណ ១,២០៣,៤៥០ (មួយលាន ពីរសែន បីពាន់ បួនរយហាសិប) យោជន៍, លោកពោលប្រមាណទុកដោយជុំវិញ ។

ចក្រវាឡ មានបរិមណ្ឌលទាំងអស់ ៣,៦១០,៣៥០ (បីលានប្រាំមួយសែនមួយម៉ឺនបីរយហាសិប) យោជន៍, ផែនដីនេះ ក្នុងចក្រវាឡនោះ បណ្ឌិតពោលទុកដោយកម្រាស់មានប្រមាណ ពីរសែនបួនម៉ឺនយោជន៍ ។

ទឹកសម្រាប់ទ្រផែនដី ដែលមានប្រមាណ បួនសែនប្រាំបីម៉ឺនយោជន៍នោះឯងទុក ដោយកម្រាស់ ក៏មានប្រមាណប៉ុណ្ណោះ តាំងនៅលើខ្យល់, ខ្យល់សម្រាប់ទ្រទឹកសូម្បីនោះទុក បក់ឡើងដល់ផ្ទៃមេឃ កម្ពស់ ៩ សែន ៦ ម៉ឺនយោជន៍, ការតាំងនៅនៃលោកដូច្នេះ ។

ក៏ក្នុងចក្រវាឡនេះ ដែលតាំងនៅហើយយ៉ាងនេះ មានភ្នំសិណេរុ ខ្ពស់ជាងបណ្តាភ្នំទាំងឡាយ ចាក់ចុះក្នុងបាតមហាសមុទ្រជម្រៅ (៨៤០០០) ប្រាំបីម៉ឺនបួនពាន់យោជន៍, ខ្ពស់ឡើងទៅ (ខាងលើ) ក៏មាន ប្រមាណប៉ុណ្ណោះដូចគ្នា ។

ភ្នំធំទាំង ៧ នេះ គឺ ភ្នំយុគន្ធរ១ ភ្នំឥសិន្ធរ១ ភ្នំករវិកៈ១ ភ្នំសុទស្សនៈ១ ភ្នំនេមិន្ធរ១ ភ្នំវិនត្តកៈ១ ភ្នំអស្សកណ្ណៈ១ ជារបស់ទិព្វ វិចិត្រដោយរតនៈផ្សេង ៗ ចាក់ចុះ (ក្នុងបាតមហាសមុទ្រ) និងខ្ពស់ឡើងទៅ (ខាងលើ) តាមលំដាប់ដោយប្រមាណពាក់កណ្តាល ៗ អំពីប្រមាណនៃភ្នំសិណេរុដែលពោលហើយ ទាំងខាងក្រោម និងខាងលើនោះ ជាស្ថានទីនៅរបស់ស្តេចមហារាជ (ទាំង ៤) មានទេវតា និងយក្ខអាស្រ័យនៅហើយ តាំងនៅរៀងគ្នាជុំវិញភ្នំសិណេរុ ដោយអំណាចជាគ្រឿងលោមព័ទ្ធ ។

ភ្នំហិមវន្តកម្ពស់ ៥០០ យោជន៍ ដោយចំណែកបណ្តោយនិងទទឹង បីពាន់យោជន៍ ប្រដាប់ដោយកំពូលប្រាំបីម៉ឺនបួនពាន់កំពូល ។

ជម្ពូទ្វីបលោកប្រកាសហើយ ដោយអានុភាពនៃដើមជម្ពូណា ដើមជម្ពូដែលឈ្មោះថា នគៈនោះ ទំហំដោយជុំវិញដើមប្រមាណ ១៥ យោជន៍ ផ្នែកបណ្តោយរបស់ដើម និងមែកប្រមាណ ៥០ យោជន៍ ទទឹងដោយជុំវិញប្រមាណ ១០០ យោជន៍ និងកម្ពស់ឡើងទៅ(ខាងលើ) ក៏មានប្រមាណប៉ុណ្ណោះនុ៎ះឯង ។

ភ្នំចក្រវាឡ ចាក់ចុះក្នុងបាតមហាសមុទ្រ ជម្រៅ ១៦០.០០០ (មួយ សែនប្រាំមួយម៉ឺន)[១] យោជន៍ ខ្ពស់ឡើងទៅ(ខាងលើក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ភ្នំចក្រវាឡនេះ តាំងនៅលោមព័ទ្ធជុំវិញ លោកធាតុទាំងអស់នោះ ។

---

១. បាលីថា : ទ្វេ អសីតិ សហស្សានិ ខ្វះប្រែថា ៨២០០០ ព្រោះភ្នំសិណេរុខ្ពស់ជាងភ្នំទាំងឡាយ ។

## ទំហំព្រះចន្ទជាដើម

ក្នុងលោកធាតុនោះ ព្រះចន្ទ (វាស់ដោយត្រង់ ផ្នែកបណ្ដោយ ផ្នែកទទឹងនិងកំពស់) ៤៩ យោជន៍ ព្រះអាទិត្យប្រមាណ ៥០ យោជន៍ ភពតាវត្តិង្សប្រមាណ មួយម៉ឺនយោជន៍ ភពអសុរ អវិចិមហានរក និងជម្ពូទ្វីប ក៏មានប្រមាណប៉ុណ្ណោះ អបរគោយានទ្វីប ប្រមាណ ៧ ពាន់យោជន៍ បុព្វវិទេហទ្វីប ក៏មានប្រមាណប៉ុណ្ណោះ ឧត្តរកុរុទ្វីប ប្រមាណ ៨,០០០ យោជន៍ ក៏ឯទ្វីបធំ ៗ ក្នុងលោកធាតុនេះ ទ្វីបមួយ ៗ មានទ្វីបតូច ៗ ជាបរិវារប្រាំរយ ៗ ចក្រវាឡមួយសព្វទាំងអស់នោះ ឈ្មោះថាលោកធាតុមួយ ក្នុងចន្លោះនៃចក្រវាឡនោះ ជាលោកន្តរិកនរក ។ សព្វឱកាសលោក (លោកគឺ ផែនដី) ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់ហើយដោយប្រការទាំងពួង ដោយប្រការយ៉ាងនេះ ។ ព្រះមានព្រះភាគនោះ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះសេចក្ដីដែលព្រះអង្គទ្រង់ដឹងច្បាស់នូវលោក ដោយប្រការទាំងពួង សព្វដូចពណ៌នាមកដោយប្រការដូច្នេះ ។

## ទ្រង់ព្រះនាមថា អនុត្តរោ

បទថា អនុត្តរោ : ព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយ ស្មើគ្មាន សេចក្ដីថា បុគ្គលក្រៃលែងជាង ឈ្មោះថា រមែងមិនមានដល់ព្រះមានព្រះភាគអង្គនោះ ព្រោះមិនមានអ្នកណា ៗ ដែលល្អវិសេសជាងព្រះអង្គ ដោយគុណរបស់ខ្លួន ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា អនុត្តរោ (មិនមានអ្នកដទៃក្រៃលែងជាង) ។ ពិតមែន ព្រះមានព្រះភាគអង្គនោះ រមែងគ្របសង្កត់ លោកទាំងអស់ ដោយព្រះគុណ គឺ សីលខ្លះ ដោយព្រះគុណ គឺសមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈខ្លះ ។ ព្រះមានព្រះភាគអង្គនោះ មិនមានអ្នកស្មើ រកអ្នកស្មើដូចមិនបាន រកអ្នកប្រៀបផ្ទឹមមិនបាន មិនមានអ្នកប្រៀបធៀប រកបុគ្គលអ្នកប្រៀបផ្ទឹមមិនបាន ដោយព្រះគុណ គឺសមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈខ្លះ ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ... តែក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញសមមណៈឬព្រាហ្មណ៍ ដែលបរិបូរណ៍ដោយសីលជាងតថាគត"[១] ។ គួរជ្រាបសេចក្ដីពិស្តារ( នៃ

---

១. សំយុ. សគា. ២៩. ២២/៥០ ។

ព្រះសូត្រនោះ) ។ ព្រះសូត្រទាំងឡាយ មានអគ្គប្បសាទសូត្រ[២]ជាដើម និង គាថាមានជាដើមថា "តថាគតមិនមានអាចារ្យទេ"[៣] ដូច្នេះ ក៏គួរឱ្យពិស្តារ តាមន័យដែលពោលមកហើយនោះ ។

## ទ្រង់ព្រះនាមថា បុរិសទម្មសារថិ

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ : ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រោះអត្ថវិគ្រោះថា ញ៉ាំងបុរសអ្នកល្មមនឹងទូន្មានបាន ឱ្យត្រាច់ទៅ ។ មានអធិប្បាយទុកថា រមែងទូន្មានគឺណែនាំ ។ សត្វតិរច្ឆានក្តី មនុស្សប្រុសក្តី អមនុស្សប្រុសក្តី អ្នកដែលនៅមិនបានទូន្មាន គួរដើម្បីនឹងទូន្មានបាន ឈ្មោះថា បុរិសទម្មា ក្នុងពាក្យថា បុរិសទម្មសារថិ នោះ ។ ពិតមែន សូម្បីសត្វតិរច្ឆាន មានជាដើមយ៉ាងនេះ គឺ អបលាលនាគរាជ ចូឡោទរនាគរាជ មហោទរនាគរាជ អគ្គិសិខនាគរាជ ធូមសិខនាគរាជ អាលវាឡនាគរាជ (និង) ដំរីឈ្មោះធនបាលក៍ ដែលព្រះមានព្រះភាគទ្រង់ទូន្មានហើយ គឺ ទ្រង់ធ្វើឱ្យអស់រឹងត្អឹងហើយ ឱ្យតាំងនៅក្នុងសរណៈនិងសីលទាំងឡាយ ។ សូម្បីមនុស្សប្រុសមានសច្ចកនិគណ្ឋបុត្ត អម្ពដ្ឋមាណព

---

២. អង្គុ. ចតុ. ៤២. ៣៥/៨៤ ; ខុទ្ទ. ឥតិ. តិកនិបាត. ៥៣. ៩២/១១៦ ។ ៣. មជ្ឈិ. មូល. បាសរាសិសូត្រ. ២១. ៦៣/១៥៤ ។

បោក្ខរសាតិព្រាហ្មណ៍ សោណទណ្ឌព្រាហ្មណ៍ និងកូដទន្តព្រាហ្មណ៍ជាដើម ដែលព្រះមានព្រះភាគ ទ្រង់ទូន្មានហើយ ។ សូម្បីអមនុស្សប្រុសមានអាឡវកយក្ខ សូចិលោមយក្ខ ខរលោមយក្ខ និងស្ដេចសក្កទេវរាជជាដើម ដែលព្រះមានព្រះភាគ ទ្រង់ទូន្មានហើយ គឺ ទ្រង់ណែនាំហើយ ដោយឧបាយ គ្រឿងណែនាំយ៉ាងវិចិត្រ ។ ក៏ឯក្នុងអត្ថនេះ គួរញ៉ាំងព្រះសូត្រនេះឱ្យពិស្ដារដូច្នេះ "ម្នាលកេសី តថាគត រមែងណែនាំបុរសដែលគួរទូន្មានដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អនិងអាក្រក់ខ្លះ"[១] ។

ម្យ៉ាងទៀត ពីរបទថា អនុត្តរោ បុរិសទម្មសារថិ នេះ រួមជាបទតែមួយក៏បាន ។ ពិតមែន ព្រះមានព្រះភាគទ្រង់ញ៉ាំងបុរសគួរនឹងទូន្មានបានឱ្យត្រាច់ទៅដូចព្រះពុទ្ធទាំងឡាយ ទ្រង់គង់នៅដោយបល្ល័ង្កតែមួយប៉ុណ្ណោះ ទ្រង់ត្រាច់ទៅបានមិនទើសទាក់រហូតអស់ទិសទាំង ៨ ដូច្នោះ ព្រោះហេតុដូច្នោះ ទើបបណ្ឌិតហៅព្រះមានព្រះភាគថា អនុត្តរោ បុរិសទម្មសារថិ (ជាសារថីទូន្មានបុរសដែលគួរទូន្មានបាន មិនមានអ្នកដទៃក្រៃលែងជាង) ។ ក៏ឯក្នុងអត្ថនេះ គួរញ៉ាំងព្រះសូត្រនេះឱ្យពិស្ដារដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ដំរីទូន្មានដែលទម័កដំរី បានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសខាងកើតក្ដី ខាងលិចក្ដី ខាងជើងក្ដី ខាងត្បូងក្ដី តែម្ដងបាន"[២] ។

១. អង្គុ. ចតុ. កេសីវគ្គ. ៤២. ១១១/២៨៣ ។ ២. មជ្ឈិ. ឧប. សឡាយតនវិភង្គសូត្រ. ២៨. ១១២/១១៤ ។

## ទ្រង់ព្រះនាមថា សត្ថា

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សត្ថា : ព្រះអង្គជាគ្រូ ព្រោះអត្ថវិគ្រោះថា ទ្រង់ប្រៀនប្រដៅ (សព្វសត្វ)ដោយប្រយោជន៍ក្នុងបច្ចុប្បន្ន ដោយប្រយោជន៍ខាងមុខ និងប្រយោជន៍យ៉ាងក្រៃលែងតាមសមគួរ ។ ម្យ៉ាងទៀត ក៏ក្នុងបទថា សត្ថា នេះ គប្បីជ្រាបសេចក្តីនិទ្ទេសន័យជាដើមដូច្នេះថា ពាក្យថា សត្ថា បានដល់ ព្រះមានព្រះភាគទ្រង់ដូចជាអ្នកនាំពួក ។ ដូចជានាយពួក រមែងញុំាងពួកឱ្យឆ្លងមកកន្តារ (មកលំបាក) គឺ ឱ្យឆ្លងមកកន្តារគឺចោរ ឱ្យឆ្លងមកកន្តារគឺសត្វសាហាវ ឱ្យឆ្លងមកកន្តារគឺការអត់បាយ តែងឱ្យឆ្លង ឱ្យឆ្លងឡើង ឱ្យឆ្លងចេញ ឱ្យឆ្លងផុតមកកន្តារគឺការមិនមានទឹក ឱ្យបានដល់ទីដ៏ក្សេម យ៉ាងណាមិញព្រះមានព្រះភាគ ជាអ្នកនាំពួក តែងនាំពួកសត្វឱ្យឆ្លងមកកន្តារ គឺ ឱ្យឆ្លងមកកន្តារគឺជាតិ (ឱ្យឆ្លងមកកន្តារគឺជរា ឱ្យឆ្លងមកកន្តារគឺព្យាធិ ឱ្យឆ្លងមកកន្តារ គឺ មរណៈ សោកៈ) ជាដើម ។

## ទ្រង់ព្រះនាមថា ទេវមនុស្សានំ

បទថា ទេវមនុស្សានំ : នៃទេវតានិងមនុស្សទាំងឡាយ គឺ របស់ទេវតាទាំងឡាយផង របស់មនុស្សទាំងឡាយផង ។ ពាក្យថា ទេវមនុស្សានំ នោះ ខ្ញុំព្រះករុណាពោលទុកដោយអំណាចកំណត់សត្វជាន់ខ្ពស់ និងដោយអំណាចការកំណត់ភព្វបុគ្គល (បុគ្គលគួរត្រាស់ដឹងមគ្គផល) ។ មួយទៀត ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ជាព្រះសាស្ដាសូម្បីរបស់ពួកសត្វតិរច្ឆាន ព្រោះទ្រង់ប្រទានអនុសាសនីឱ្យដូចគ្នា ។ មែនពិត សូម្បីសត្វតិរច្ឆានទាំងនោះ សម្រេចឧបនិស្សយសម្បត្តិ ក៏ព្រោះបានស្ដាប់ធម៌របស់ព្រះមានព្រះភាគ រមែងជាអ្នកមានចំណែកនៃមគ្គនិងផលក្នុងភពទី ២ ឬទី ៣ ព្រោះឧបនិស្ស័យ សម្បត្តិនោះឯង ។ ក៏ក្នុងភាពជាព្រះសាស្ដារបស់ពួកសត្វតិរច្ឆាននេះ មានមណ្ឌូកទេវបុត្រជាដើមជាឧទាហរណ៍ ។

## រឿងកង្កែបស្ដាប់ធម៌របស់ព្រះពុទ្ធបានជាទេវបុត្រ

បានឮថា កាលព្រះមានព្រះភាគទ្រង់សម្ដែងធម៌ដល់អ្នកនគរចម្បានៅក្បែរមាត់ប្រាំងស្រះបោក្ខរណី ឈ្មោះគគ្គរា មានកង្កែបមួយ បានកាន់យកនិមិត្តក្នុងព្រះសូរសៀងរបស់ព្រះមានព្រះភាគ (ដែលកំពុងទ្រង់សម្ដែង

ធម៌ ) ។ ( ខណៈនោះ ) មានអ្នកចិញ្ចឹមគោម្នាក់ កាលទឹងឈរប្រេត់ឈើប្រេត់ បាន ( ឈរ ) សន្កត់ចុះត្រង់ក្បាលកង្កែបនោះ ។ កង្កែបនោះ ក៏ស្លាប់ក្នុងវេលានោះឯង ហើយកើតក្នុងវិមានមាសប្រមាណ ១២ យោជន៍ ក្នុងភពតាវត្តិង្ស ដូចដេកលក់ហើយភ្ញាក់ឡើងដូច្នោះ ។

ក្នុងភពតាវត្តិង្សនោះ មណ្ឌូកទេវបុត្រ ឃើញខ្លួនឯងដែលពួកស្រីអប្សរចោមរោមហើយ ពិចារណាថា ឱយើងមកកើតក្នុងទីនេះ បានធ្វើកម្មអ្វីហ្ន៎ ? ក៏មិនបានឃើញកម្មអ្វី ៗ យ៉ាងដទៃ ក្រៅពីការកាន់យកនិមិត្ត ក្នុងព្រះសូរសៀងរបស់ព្រះមានព្រះភាគ ( ប៉ុណ្ណោះ ) ។ មណ្ឌូកទេវបុត្រ ទើបមកព្រមទាំងវិមានក្នុងវេលានោះឯង ហើយថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគ ដោយសិរសា ។ ព្រះមានព្រះភាគទាំងដែលទ្រង់ជ្រាប ( តែ ) ត្រាស់សួរថា

អ្នកណាហ្ន៎រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ
ញុំាងទិសទាំងពួងឱ្យភ្លឺ កំពុងថ្វាយបង្គំបាទានៃតថាគត ។
( មណ្ឌុកទេវបុត្រក្រាបទូលថា ) ក្នុងកាលមុន ខ្ញុំព្រះអង្គជា
កង្កែបនៅក្នុងទឹកមានវារីជាទីគោចរ កាលខ្ញុំព្រះអង្គកំពុងតែ
ស្តាប់ធម៌របស់ព្រះអង្គ នាយគោបាល បានសម្លាប់ខ្ញុំ [១] ។

---

១. ខុទ្ទ. វិមា. មណ្ឌុកទេវបុត្តវិមាន. ៥៥. ៥១/១១០ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់មណ្ឌកទេវបុត្រនោះហើយ ។ សត្វចំនួនប្រាំបីម៉ឺនបួនពាន់ បានសម្រេចធម៌ ។ ចំណែកទេវបុត្រ ក៏តាំងនៅក្នុងព្រះសោតាបត្តិផល បានធ្វើការញញឹមហើយក៏ជៀសទៅ ។

## ទ្រង់ព្រះនាមថា ពុទ្ធោ

ក៏ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា ពុទ្ធោ : ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ដោយអំណាចព្រះញាណដែលកើតក្នុងទីបំផុតនៃវិមោក្ខ ព្រោះដែលឈ្មោះថា ញេយ្យធម៌ណា ៗ ដែលមានទាំងអស់ គឺព្រះអង្គត្រាស់ដឹងហើយ ។ ម្យ៉ាងទៀត ព្រោះព្រះអង្គត្រាស់ដឹងអរិយសច្ចៈ ៤ ដោយព្រះអង្គឯងខ្លះ ទ្រង់ញ៉ាំងពួកសត្វដទៃឱ្យត្រាស់ដឹងខ្លះ, ដូច្នោះ ទើបព្រះអង្គទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះហេតុមានជាដើមយ៉ាងនេះខ្លះ ។ ដើម្បីឱ្យជ្រាបសេចក្តីនេះបានជាក់ច្បាស់ បណ្ឌិត គួរពង្រីកនិទ្ទេសន័យ ឬបដិសម្ភិទាន័យ សូម្បីទាំងអស់ដែលប្រព្រឹត្តទៅហើយ ឱ្យពិស្តារយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះត្រាស់ដឹងសច្ចៈទាំងឡាយ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះទ្រង់ញ៉ាំងពួកសត្វឱ្យត្រាស់ដឹង ដូច្នេះ ។

## ទ្រង់ព្រះនាមថា ភគវា

ក៏ពាក្យថា ភគវា : ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតនេះ ជាពាក្យហៅព្រះអង្គដោយភាពជាអ្នកវិសេសដោយព្រះគុណ ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសត្វ និងជាអ្នកគួរគោរពដោយឋានៈជាគ្រូ ។ ព្រោះហេតុនោះ ទើបព្រះបូរាណាចារ្យទាំងឡាយពោលថា ៖

ពាក្យថា **ភគវា** ជាពាក្យប្រសើរបំផុត ពាក្យថា **ភគវា**
ជាពាក្យខ្ពស់បំផុត ព្រោះហេតុដែលព្រះអង្គគួរដល់ការ
គោរពដោយឋានៈជាគ្រូ ទើបបណ្ឌិតហៅថា **ភគវា** ។

## នាមមាន ៤ យ៉ាង

ពិតមែន នាមមាន ៤ យ៉ាង គឺ អាវត្ថិកនាម លិង្គិកនាម នេមិត្តកនាម អធិច្ចសមុប្បន្ននាម ។ មានពាក្យអធិប្បាយថា នាមដែលតាំងឡើងតាមសេចក្តីប្រាថ្នា តាមលោកវោហារ ឈ្មោះថា **អធិច្ចសមុប្បន្ននាម** ។ ក្នុងនាម ៤ យ៉ាងនោះ ពាក្យមានអាទិយ៉ាងនេះ គឺកូនគោ គោជំទង់ គោធំ ជា **អាវត្ថិកនាម** (នាមដែលបញ្ញត្តិ អាស្រ័យការកំណត់) ។ ពាក្យមានអាទិយ៉ាងនេះ គឺ មានឈើច្រត់ មានឆត្រ មានសិរ មានប្រមោយ ជា **លិង្គិកនាម** (នាមដែលហៅតាមហេតុ ឬលក្ខណៈ) ។ ពាក្យមានអាទិយ៉ាងនេះ គឺ មានវិជ្ជា ៣ មានអភិញ្ញា ៦

ជានេមិត្តកនាម (នាមដែលកើតឡើងដោយគុណនិមិត្ត) ។ ពាក្យមានអាទិយ៉ាងនេះគឺ ចម្រើនដោយសិរី ចម្រើនទ្រព្យ ដែលប្រព្រឹត្តទៅមិនទឹកដល់សេចក្តីរបស់ពាក្យជាអធិច្ចសមុប្បន្ននាម (នាមដែលតាំងតាមពេញចិត្ត) ។ ក៏ប៉ុន្តែថា ព្រះនាមថា ភគវា នេះ ជានេមិត្តកនាម ព្រះនាងមហាមាយាក៏ទ្រង់មិនបានថ្វាយ ព្រះបាទសុទ្ធោទនមហារាជក៏ទ្រង់មិនបានថ្វាយព្រះញាតិ ៨ ម៉ឺនក៏មិនបានថ្វាយ ទេវតាវិសេសទាំងឡាយ មានស្តេចសក្កៈនិងស្តេចសន្តុសិតជាដើម ក៏ទ្រង់មិនបានថ្វាយ (ព្រះនាមនេះ)ទេ ។ ពិតមែន ពាក្យនេះ ព្រះធម្មសេនាបតីពោលហើយថា ៖

"ពាក្យថា ព្រះមានព្រះភាគ នេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនមិត្រនិងអាមាត្យថ្វាយ មិនមែនញាតិសាលោហិតថ្វាយ មិនមែនសមណៈ និងព្រាហ្មណ៍ថ្វាយ មិនមែនទេវតាថ្វាយទេ ពាក្យថា ព្រះមានព្រះភាគនុ៎ះ កើតក្នុងទីបំផុតវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ, ទ្រង់មានភាគ ។ បញ្ញត្តិថា ព្រះមានព្រះភាគនេះ (កើតហើយ) ដោយកិរិយាធ្វើឱ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវព្រះសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស"[១] ។

---

១. ខុទ្ទ. មហា. តិស្សមេត្តេយ្យសុត្តនិទ្ទេស. ៦៤. ២៣១/២៧១; ខុទ្ទ. ចុល្ល. អជិតមាណវកបញ្ហា. ៦៧. ៦១/១៦ ។

ក៏ដើម្បីនឹងប្រកាសព្រះគុណ ដែលកើតអំពីគុណនៃមិត្តកនាមនេះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយ ពោលគាថានេះទុកថា ៖

ភគី ភជី ភាគី វិភត្តវាតិ អកាសិ ភគ្គន្តិ គរូតិ ភាគវា
ពហូហិ ញាយេហិ សុភាវិតត្តនោ ភវន្តគោ សោ ភគវាតិ វុច្ចតិ ។

ព្រះមានព្រះភាគអង្គណា ទ្រង់មានព្រះឥស្សរិយយស ទ្រង់សេព (អរិយគុណ) មានចំណែក (នៃចតុប្បច្ច័យ) ទ្រង់ចែក (ធម្មរតនៈ) ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា, ព្រះមានព្រះភាគអង្គណា បានទ្រង់ធ្វើការបំបាក់បង់កិលេស, ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា, ព្រះមានព្រះភាគអង្គណា ទ្រង់ជាគ្រូ ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា, ព្រះមានព្រះភាគអង្គណា ជាអ្នកមានជោគ ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា, ព្រះមានព្រះភាគអង្គណា មានខ្លួនព្រះអង្គ អប់រំល្អហើយ ដោយញេយ្យធម៌ជាច្រើន ស្ដេចដល់ទីបំផុតនៃភព, ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះ

នាមថា ភគវា ។

មួយទៀត ក្នុងព្រះគាថានេះ បណ្ឌិតគប្បីឃើញសេចក្ដីនៃបទទាំងនោះ ៗ តាមន័យដែលពោលហើយក្នុងនិទ្ទេសនោះឯង ។ ចំណែកន័យដទៃទៀត មានដូច្នេះគឺ ៖

ព្រះមានព្រះភាគអង្គណា ជាអ្នកមានជោគ (គឺមានចំណែកនៃបារមីធម៌) ទ្រង់បំបាក់បង់កិលេស ទ្រង់ប្រកប ដោយភគ្គធម៌ ទ្រង់ចែក ទ្រង់សេព និងទ្រង់មានដំណើរ ទៅក្នុងភពទាំងឡាយខ្ជាក់ចោលហើយ, ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា ភគវា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថានោះតទៅ ៖

អ្នកសិក្សាគប្បីជ្រាបអត្ថរូបថា ព្រោះភាគ្យធម៌ (គឺកុសល) ដែលដល់នូវត្រើយនៃព្រះបារមី មានទាន និងសីលជាដើម ដែលញ៉ាំងសុខទាំងជាលោកិយៈ ទាំងជាលោកុត្តរៈឱ្យកើត មានចំពោះព្រះមានព្រះភាគអង្គនោះ, ដូច្នោះ ក្នុងកាលគួរនឹងថ្វាយព្រះនាមថា ភាគ្យវា តែលោកកាន់យកលក្ខណៈនៃនិរុត្តិថា ចុះអក្សរថ្មី ប្ដូរអក្សរជាដើម ឬកាន់យកលក្ខណៈ គឺ រួមចូលក្នុងសព្ទ មានបិសោទរសព្ទជាដើម តាមន័យនៃសព្ទ ទើបថ្វាយព្រះនាមថា ភគវា ដូច្នេះ ។

## ព្រះមានព្រះភាគទ្រង់បំបាក់បង់កិលេសបាននាំងសែនយ៉ាង

មួយទៀត ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់បានបំបាក់បង់កិលេស គ្រឿងក្តៅផ្សា ខ្វល់ខ្វាយគ្រប់យ៉ាង ទាំងសែនយ៉ាង មានប្រភេទគឺ លោភៈ ទោសៈ មោហៈ វិបរិត មនសិការៈ អហិរិកៈ អនោត្តប្បៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ តណ្ហា អវិជ្ជា, អកុសលមូល៣ ទុច្ចរិត៣ សង្កិលេស៣ មន្ទិល៣ វិសមៈ៣ សញ្ញា៣ វិតក្កៈ៣ បបញ្ចៈ៣, វិបរិយេសៈ៤ អាសវៈ៤ គណ្ឋៈ៤ ឱឃៈ៤ យោគៈ៤ អគតិ៤ តណ្ហុប្បាទៈ៤, ចេតោខីលៈ៥ វិនិពន្ធៈ៥ នីវរណៈ៥ អភិនន្ទៈ៥, វិវាទមូល៦ តណ្ហាកាយ៦, អនុស័យ៧, មិច្ឆត្តៈ៨, តណ្ហាមូលកៈ៩, អកុសលកម្មបថ១០, ទិដ្ឋិ៦២, និងតណ្ហាវិបរិត១០៨, ឬដោយសង្ខេប ទ្រង់បានបំបាក់បង់មារ ៥ គឺ កិលេសមារខន្ធមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ, ដូច្នោះ ក្នុងកាលគួរនឹងថ្វាយព្រះនាមថា ភគ្គវា តែលោកថ្វាយព្រះនាមថា ភគវា ព្រោះព្រះអង្គទ្រង់បំបាក់បង់អន្តរាយទាំងនោះបានហើយ ។

មួយទៀត ក្នុងផ្នែកនេះលោកពោលទុកថា ៖

ព្រះមានព្រះភាគអង្គនោះ ទ្រង់បំបាក់បង់រាគៈ បានហើយ

ទ្រង់បំបាក់បង់ទោសៈបានហើយ ទ្រង់បំបាក់បង់មោហៈបានហើយ មិនមានអាសវៈ, ធម៌ដែលជាបាបទាំងឡាយ ក៏ទ្រង់បំបាក់បង់ចេញហើយ, ព្រោះហេតុនោះ ទើបថ្វាយព្រះនាមថា ភគវា ។

ក៏សេចក្ដីដល់ព្រមដោយរូបកាយ របស់ព្រះមានព្រះភាគអង្គនោះ ទ្រទ្រង់បុញ្ញលក្ខណៈរាប់រយ រមែងជាការដែលលោកសម្ដែងហើយ ដោយសេចក្ដីដែលព្រះអង្គ ទ្រង់មានព្រះកាយសមល្អ ។ សេចក្ដីដល់ព្រមដោយព្រះធម្មកាយ រមែងជាការដែលលោកសម្ដែងហើយ ដោយសេចក្ដីដែលព្រះអង្គ ទ្រង់បំបាក់បង់ទោសៈបានហើយ ។ ភាពនៃព្រះអង្គជាបុគ្គលដែលពួកអ្នកស្គាល់ហេតុជាលោកិយរាប់អានច្រើន ភាពនៃព្រះអង្គ ជាបុគ្គលដែលគ្រហស្ថនិងបព្វជិតគប្បីចូលគាល់ ភាពនៃព្រះអង្គទ្រង់អាចក្នុងការបំបាត់ទុក្ខមកកាយ និងមកចិត្តរបស់គ្រហស្ថ និងបព្វជិតទាំងនោះ អ្នកចូលគាល់ហើយ សេចក្ដីដែលព្រះអង្គ ទ្រង់មានឧបការៈដោយអាមិសទាន និងធម្មទាន និងសេចក្ដីដែលព្រះអង្គ ទ្រង់អាចក្នុងការដឹកនាំដោយសេចក្ដីសុខ ទាំងជាលោកិយៈ ទាំងជាលោកុត្តរៈ ក៏ឈ្មោះថា លោកសម្ដែងហើយដូចគ្នា ។

មួយទៀត ព្រោះ ភគៈ សព្ទ រមែងប្រព្រឹត្តទៅក្នុងធម៌ ៦ ប្រការ

គឺ ភាពជាធំ ធម៌ យស សិរី កាម និងសេចក្ដីព្យាយាមក្នុងលោក ។ ក៏ឯភាពជាធំក្នុងចិត្តនៃព្រះអង្គ របស់ព្រះមានព្រះភាគអង្គនោះប្រសើរ ឬភាពជាធំដែលគេសន្មតមកលោកិយៈ មានការធ្វើកាយឱ្យតូចល្អិត និងធ្វើកាយឱ្យអណ្ដែតទៅបាន (មានការបាត់ខ្លួន និងការសោត់បាត់)ជាដើម ក៏ទ្រង់មានយ៉ាងបរិបូរណ៍ ដោយអាការទាំងពួង ។ ព្រះលោកុត្តរធម៌ ក៏ដូចគ្នា គឺ ទ្រង់មានយ៉ាងបរិបូរណ៍ដោយអាការទាំងពួង ។ ព្រះយសដែលគ្របដណ្ដប់លោក ៣ ដែលទ្រង់សម្រេចដោយព្រះគុណតាមពិត បរិសុទ្ធិក្រៃលែង ។ ព្រះសិរីនៃព្រះអង្គាវយវៈតូចធំគ្រប់ចំណែកបរិបូរណ៍ដោយអាការទាំងពួង អាចញ៉ាំងសេចក្ដីជ្រះថ្លានៃកែវភ្នែក និងចិត្តរបស់ជនអ្នកខ្វល់ខ្វាយ ក្នុងការមើលព្រះរូបកាយឱ្យកើត ។ កាមដែលជនទាំងឡាយ សំគាល់ដឹងថា សេចក្ដីសម្រេចនៃប្រយោជន៍ ដែលប្រាថ្នា (ក៏មាន) ព្រោះសេចក្ដីប្រាថ្នា ដែលព្រះអង្គតាំងទុកជាប្រយោជន៍ដល់ព្រះអង្គ ឬជាប្រយោជន៍ ដល់អ្នកដទៃនោះ ៗ សម្រេចហើយយ៉ាងនោះតែម្ដង ឬថា សេចក្ដីព្យាយាម ពោលគឺ សេចក្ដីព្យាយាមដោយប្រពៃ ដែលជាហេតុនៃការកើតឡើងនៃភាពជាសាស្ដា នៃលោកទាំងពួង ក៏ទ្រង់មានហេតុនោះ សូម្បីព្រោះព្រះអង្គទ្រង់ប្រកបហើយដោយភគៈធម៌ទាំងនេះ ក៏ថ្វាយព្រះនាមបានថា **ភគវា** ដោយអត្ថនេះថា ភគៈ

ធម៌ ទាំងឡាយរបស់ព្រះអង្គមាន ដូច្នេះ ។

មួយទៀត ព្រោះព្រះអង្គទ្រង់ជាអ្នកចែក មានអធិប្បាយថា ទ្រង់ចែក គឺបើក សម្តែងនូវធម៌ទាំងពួង ដោយប្រភេទ មានកុសលជាដើម ឬនូវធម៌មានកុសលជាដើមដោយប្រភេទ មានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬនូវអរិយសច្ចៈ គឺ ទុក្ខ ដោយអត្ថថា ជាវត្ថុបៀតបៀន ជាវត្ថុត្រូវតាក់តែង ជាវត្ថុដុតរោល និងជាវត្ថុប្រែប្រួល, នូវសមុទយ ដោយអត្ថថា ក្រសោបទុក្ខមកឱ្យជាដើម ជាគ្រឿងរុំព័ទ្ធ និងជាគ្រឿងចងឆ្មាក់, នូវនិរោធ ដោយអត្ថថា ជាគ្រឿងរលាស់ចេញ ជាសភាពស្ងាត់មិនត្រូវតាក់តែង និងជាអមតៈ, នូវមគ្គ ដោយអត្ថថា ជាធម៌នាំចេញចាកទុក្ខ ជាហេតុជាគ្រឿងចង្អុលបង្ហាញ និងភាពជាធំ, ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា **វិភត្តវា** ក៏ថ្វាយព្រះនាមបានថា **ភគវា** ។

មួយទៀត ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់គប់ គឺ ទ្រង់សេពសំដៅសេចក្តីថា ទ្រង់បានធ្វើឱ្យច្រើននូវទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ និងឧត្តរិមនុស្សធម្មពួកដទៃ ទាំងជាលោកិយៈ ទាំងជាលោកុត្តរៈ, ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា

ភគ្គវា ក៏ថ្វាយព្រះនាមបានថា ភគវា ។

មួយទៀត ព្រោះការទៅ ពោលគឺ តណ្ហាក្នុងភពទាំង ៣ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ខ្ជាក់ចោលហើយ, ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា ភវេសុ វន្តគមនោ (អ្នកមានការទៅក្នុងភពទាំងឡាយដែលខ្ជាក់ចោលហើយ) តែថ្វាយព្រះនាមថា ភគវា ព្រោះកាន់យក ភ អក្សរតែ ភវ សព្ទ គ អក្សរពី គមន សព្ទ និង វ អក្សរពីវន្តសព្ទ ធ្វើឱ្យជាទីឃៈ ប្រៀបដូចពាក្យក្នុងមកលោក កាលគួរនឹងពោលថា មេហនស្ស ខស្ស មាលា (របៀបនៃឱកាសដែលកំបាំង) គេពោលថា មេខលា ដូច្នោះ ។

## អធិប្បាយ សទេវក សព្ទជាដើម

ត្រើនបទថា សោ ឥមំ លោកំ : ព្រះអង្គដឹងនូវលោកនេះ សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើលោកនេះ ឱ្យជាក់ច្បាស់ដោយបញ្ញា ដ៏ក្រៃលែងខ្លួនឯង ។ ឥឡូវនេះ នឹងពន្យល់នូវពាក្យដែលគួរពោលតទៅ ៖

បទថា សទេវកំ : ព្រមទាំងទេវលោក គឺ ព្រមទាំងទេវតាទាំងឡាយ ឈ្មោះ សទេវក (ព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើលោកនេះ) ព្រមទាំងមារ ដែលឈ្មោះថា សមារក មារលោក, ព្រមទាំងព្រហ្ម

ដែលឈ្មោះថា **សព្រហ្មកៈ** ព្រហ្មលោក, ព្រមដោយសមណៈនិង ព្រាហ្មណ៍ ដែលឈ្មោះថា សស្សមណព្រាហ្មណី **:** ព្រមទាំងសមណៈ និងព្រាហ្មណ៍ (ឱ្យច្បាស់លាស់) ដោយអាការយ៉ាងនេះ ។ ដែលឈ្មោះថា បជា **:** ពពួកសត្វ ព្រោះភាពជាអ្នកកើតអំពីកម្មកិលេសរបស់ខ្លួន ។ នូវពពួកសត្វនោះ ព្រមទាំងមនុស្សទេព និងមនុស្សទាំងឡាយ ឈ្មោះថា សទេវមនុស្ស **:** ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។

បណ្តាពាក្យថា សទេវកំ ជាដើម គប្បីជ្រាបការកាន់យកទេវតាជាន់កាមាវចរ ៥ ជាន់ ដោយពាក្យថា សទេវកំ (ព្រមទាំងទេវតា) ។ គប្បីជ្រាបការកាន់យកទេវតាជាន់កាមាវចរជាន់ទី ៦ ដោយពាក្យថា សមារកំ ។ គប្បីជ្រាបការកាន់យកព្រហ្ម មានព្រហ្មជាន់ព្រហ្មកាយិកាជាដើម ដោយពាក្យថា សព្រហ្មកំ ។ គប្បីជ្រាបការកាន់យកសមណៈនិងព្រាហ្មណ៍ ជាសត្រូវចំពោះព្រះសាសនា និងការកាន់យកសមណៈ និងព្រាហ្មណ៍អ្នកមានបាបដែលស្ងប់ហើយ និងអ្នកមានបាបដែលបណ្តេតចោលហើយ ដោយពាក្យថា សស្សមណព្រាហ្មណី ។ គប្បីជ្រាបការកាន់យកសត្វលោក ដោយពាក្យថា បជំ ។ គប្បីជ្រាប

ការកាន់យក សម្មតិទេវ និងមនុស្សដ៏សេស ដោយពាក្យថា សទេវមនុស្ស ។

បណ្ដាបទទាំង ៥ នេះ ដូចពណ៌នាមកនេះ ឱកាសលោក គប្បីជ្រាបថា លោកកាន់យកហើយដោយបទទាំង ៣ (គឺសទេវក ១ សមារក ១ សព្រហ្មក ១) សត្វលោក គប្បីជ្រាបថា លោកកាន់យកហើយដោយបទទាំង ២ (គឺ សស្សមណព្រាហ្មណី និងទេវមនុស្ស)ដោយអំណាចនៃពួកសត្វ ។

ន័យមួយទៀត អរូបាវចរលោក លោកកាន់យកហើយដោយ សទេវក ស័ព្ទ ។ កាមាវចរទេវលោក ៦ ជាន់ លោកកាន់យក ហើយដោយ សមារក ស័ព្ទ ។ ព្រហ្មលោកដែលមានរូប លោកកាន់យកហើយដោយ សព្រហ្មក ស័ព្ទ, មនុស្សលោក នឹងពួកសម្មតិទេព ឬសត្វលោកទាំងអស់ដ៏សេស លោកកាន់យកហើយដោយ ស័ព្ទមាន សស្សមណព្រាហ្មណី ជាដើមដោយអំណាចនៃបរិស័ទ ៤ ។

ម្យ៉ាងទៀត ក្នុងពាក្យទាំងឡាយ មានពាក្យថា សទេវក ជាដើម នេះ ព្រះ កិត្តិស័ព្ទរបស់ព្រះមានព្រះភាគអង្គនោះ ប្រកាសសេចក្ដីនៃលោកសូម្បីទាំងពួង ដែលព្រះអង្គទ្រង់ធ្វើឱ្យជាក់ច្បាស់ហើយ ដោយកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា សទេវក ខ្វះខ្វាយទៅហើយ ។

ព្រោះហេតុនោះ ជនពួកណា គប្បីមានសេចក្ដីសង្ស័យថា មារឈ្មោះវសវត្តី អ្នកមានអានុភាពច្រើន ជាធំជាងទេវតាជាន់ឆកាមាវចរ, សូម្បីមារនោះ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើឱ្យច្បាស់បានយ៉ាងណា ? ព្រះកិត្តិស័ព្ទខ្ចរខ្ចាយទៅទម្លាយ សេចក្ដីសង្ស័យរបស់ជនទាំងនោះ ដោយពាក្យថា **សមារកំ** (ព្រមទាំងមារ) ។

មួយទៀត ជនពួកណាគប្បីមានសេចក្ដីសង្ស័យថា ព្រហ្ម មានអានុភាពច្រើន រមែងភ្លឺស្វាងទៅក្នុង១ ពាន់ចក្រវាឡ ដោយអង្គុលី (ម្រាមដៃ)មួយ ក្នុង២ ពាន់ចក្រវាឡ ដោយពីរអង្គុលី ។ល ។ រមែងភ្លឺស្វាងទៅក្នុង១ ម៉ឺនចក្រវាឡដោយម្រាម ១០ និងបានសោយសុខ ដែលកើតពីឈានសមាបត្តិដ៏ប្រសើរ, សូម្បីព្រហ្មនោះ ដែលព្រះមានព្រះភាគ ទ្រង់ធ្វើឱ្យច្បាស់បានយ៉ាងណា ? ព្រះកិត្តិស័ព្ទខ្ចរខ្ចាយទៅទម្លាយសេចក្ដីសង្ស័យរបស់ជនទាំងនោះ ដោយពាក្យថា **សស្សមណព្រាហ្មណឹ បជំ** : ក្នុងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ។

ព្រះកិត្តិស័ព្ទ (របស់ព្រះមានព្រះភាគ) កាលប្រកាសសេចក្ដីដែលជាឋានៈយ៉ាងឧក្រិដ្ឋទាំងឡាយ ដែលព្រះអង្គទ្រង់ធ្វើឱ្យច្បាស់ហើយយ៉ាងនោះ ក្នុងលំដាប់នោះ កាលនឹងប្រកាសភាវៈនៃសត្វលោកដ៏សេសដែលព្រះអង្គ ទ្រង់ធ្វើឱ្យច្បាស់ហើយ ដោយអំណាចការកំណត់យ៉ាង

ឧក្រិដ្ឋ ដរាបដល់សម្មតិទេព និងពួកមនុស្សដ៏សេសខ្វះខ្វាយទៅហើយ ដោយពាក្យថា សទេវមនុស្សំ : ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ ក្នុងបទទាំងឡាយ មានបទថា សទេវកំ ជាដើមនេះ មានលំដាប់អនុសន្ធិប៉ុណ្ណេះ ។

## អធិប្បាយ សយំ សំព្ទជាដើម

មួយទៀត ក្នុងពាក្យថា សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ : បានត្រាស់ដឹង បានធ្វើឱ្យជាក់ច្បាស់ចំពោះព្រះអង្គ នេះគប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា សយំ : ខ្លួនឯង គឺ ដោយព្រះអង្គឯង, សយំ សព្ទនេះ ជាសព្ទមានសេចក្តីដែលអ្នកដទៃនឹងគប្បីនាំទៅមិនបាន ។ បទថា អភិញ្ញា : ដឹងក្រៃលែង សេចក្តីថា ទ្រង់ដឹងដោយសេចក្តីដឹងក្រៃលែង គឺដោយព្រះញាណដ៏ក្រៃលែង ។ បទថា សច្ឆិកត្វា : ធ្វើឱ្យជាក់ច្បាស់ គឺទ្រង់ធ្វើឱ្យប្រចក្ស ។ ដោយបទថា សច្ឆិកត្វា នោះ ជាការដែលលោកធ្វើការហាមកិច្ច មានការអនុមាណជាដើមចេញ ។ បទថា បវេទេតិ : ទ្រង់ប្រាប់ហើយ សេចក្តីថា គឺ ទ្រង់ញុំាងពួកសត្វឱ្យត្រាស់ដឹង គឺឱ្យដឹង បានដល់ ទ្រង់ប្រកាសឱ្យដឹង ។

## ព្រះធម៌លំអខាងដើម កណ្តាល និងទីបំផុត

ពាក្យថា សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ : ទ្រង់សម្តែងធម៌ ពីរោះបទដើម បទកណ្តាល និងបទចុង មានអធិប្បាយថា ព្រះមានព្រះភាគ ព្រះអង្គនោះ សូម្បីត្រូវលះបង់សុខដែលកើតពីវិវេកដ៏ប្រសើរហើយ ទ្រង់សម្តែងធម៌ ក៏ព្រោះទ្រង់អាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយ ។ ក៏ឯព្រះអង្គកាលទ្រង់សម្តែងធម៌នោះ ទោះតិចឬច្រើនក៏ដោយ ទ្រង់សម្តែងគ្រប់ទាំង ៣ ប្រការ មានសេចក្តីលំអខាងដើមជាដើមប៉ុណ្ណោះ ។ គឺយ៉ាងណា ? គឺយ៉ាងនេះ សេចក្តីពិស្តារថា សូម្បីតែមួយព្រះគាថា ក៏មានសេចក្តីលំអបទដើម ដោយបាទដំបូង មានសេចក្តីលំអបទកណ្តាល ដោយបាទទីពីរនិងទីបី មានសេចក្តីលំអបទទីបំផុតដោយបាទទីបំផុត ព្រោះព្រះធម៌មានសេចក្តីលំអជុំវិញ ។ ព្រះសូត្រមានអនុសន្ធិតែមួយ មានសេចក្តីលំអខាងដើម ដោយពាក្យនិទាន, មានសេចក្តីលំអទីបំផុត ដោយពាក្យនិគម, មានសេចក្តីលំអផ្នែកកណ្តាលដោយពាក្យដ៏សេស ។ ព្រះសូត្រដែលមានអនុសន្ធិផ្សេង ៗ មានសេចក្តីលំអខាងដើម ដោយអនុសន្ធិដំបូង, មានសេចក្តីលំអទីបំផុត ដោយអនុសន្ធិក្នុងទីបំផុត, មានសេចក្តីលំអ ត្រង់កណ្តាលដោយអនុសន្ធិដ៏សេស ។

សាសនធម៌ សូម្បីទាំងអស់ មានសេចក្ដីលំអខាងដើម ដោយសីលដែលជាអត្ថរបស់ខ្លួនខ្លះ, មានសេចក្ដីលំអផ្នែកកណ្ដាល ដោយសមថៈនិងវិបស្សនា មគ្គ និង ផលខ្លះ, មានសេចក្ដីលំអក្នុងទីបំផុត ដោយព្រះនិព្វានខ្លះ ។

ម៉្យាងទៀត មានសេចក្ដីលំអខាងដើម ដោយសីល និងសមាធិ, មានសេចក្ដីលំអផ្នែកកណ្ដាល ដោយវិបស្សនា និងមគ្គ, មានសេចក្ដីលំអទីបំផុត ដោយផលនិងព្រះនិព្វាន ។

ម៉្យាងទៀត មានសេចក្ដីលំអខាងដើម ដោយការត្រាស់ដឹងដ៏ប្រពៃរបស់ព្រះពុទ្ធ មានសេចក្ដីលំអផ្នែកកណ្ដាល ដោយភាពជាធម៌ដ៏ល្អនៃព្រះធម៌ មានសេចក្ដីលំអក្នុងទីបំផុត ដោយការបដិបត្តិល្អរបស់ព្រះសង្ឃ ។

ម៉្យាងទៀត មានសេចក្ដីលំអខាងដើម ដោយព្រះអភិសម្ពោធិញ្ញាណដែលអ្នកស្ដាប់សាសនធម៌នោះហើយ បដិបត្តិតាមដូច្នោះ នឹងគប្បីសម្រេច មានសេចក្ដីលំអផ្នែកកណ្ដាលដោយបច្ចេកពោធិញ្ញាណ មានសេចក្ដីលំអក្នុងទីបំផុត ដោយសាវកពោធិញ្ញាណ ។

មួយទៀត សាសនធម៌នោះ កាលសាធុជនស្ដាប់ រមែងនាំមកនូវសេចក្ដីល្អតែម៉្យាង សូម្បីដោយការស្ដាប់ ព្រោះនឹងគ្របសង្កត់នីវរណធម៌

បាន ព្រោះដូច្នោះ ទើបឈ្មោះថា មានសេចក្ដីល្អខាងដើម កាលសាធុជនបដិបត្តិ ក៏រមែងនាំមកនូវសេចក្ដីល្អតែម៉្យាង សម្បីដោយការបដិបត្តិ ព្រោះនឹងនាំមកនូវសេចក្ដីសុខដែលកើតពីសមថៈ និងវិបស្សនា ព្រោះដូច្នោះ ទើបឈ្មោះថា មានសេចក្ដីល្អត្រង់កណ្ដាល ។ និងកាលសាធុជនបដិបត្តិហើយ ដោយប្រការនោះ ក៏រមែងនាំមកតែសេចក្ដីល្អដូចគ្នា សម្បីដោយផលនៃការបដិបត្តិ ព្រោះនឹងនាំមកតែសេចក្ដីល្អ ក្នុងកាលបានសម្រេចផលនៃការបដិបត្តិហើយ ព្រោះដូច្នោះ ទើបឈ្មោះថា មានសេចក្ដីល្អក្នុងទីបំផុត ។

មួយទៀត មានសេចក្ដីល្អក្នុងខាងដើម ដោយសេចក្ដីបរិសុទ្ធិនៃដែនកើត ព្រោះសាសនធម៌មានទីពឹងជាដែនកើត មានសេចក្ដីល្អត្រង់កណ្ដាល ដោយសេចក្ដីបរិសុទ្ធិនៃអត្ថ មានសេចក្ដីល្អក្នុងទីបំផុត ដោយសេចក្ដីបរិសុទ្ធិនៃកិច្ច ។ ព្រោះដូច្នោះ ព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្ដែងធម៌ នឹងតិចឬច្រើនក៏ដោយ គប្បីជ្រាបថា ទ្រង់សម្ដែងគ្រប់ទាំង ៣ ប្រការ មានសេចក្ដីល្អខាងដើមជាដើម ។

# អធិប្បាយសព្ទថា សាត្ថំ សព្យញ្ជនំ

ក៏ក្នុងពាក្យជាដើមយ៉ាងនេះថា សាត្ថំ សព្យញ្ជនំ : ព្រមទាំងអត្ថ និង ព្យញ្ជនៈ ដូច្នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ព្រោះព្រះមានព្រះភាគ ព្រះអង្គនោះ កាលទ្រង់សម្តែងព្រះធម៌នេះ ឈ្មោះថា ទ្រង់ប្រកាស គឺទ្រង់សម្តែងសាសនព្រហ្មចរិយនិងមគ្គព្រហ្មចរិយដោយន័យផ្សេង ៗ ។ ក៏សាសនព្រហ្មចរិយនិងមគ្គព្រហ្មចរិយនោះ ឈ្មោះថា ប្រកបដោយអត្ថ ព្រោះដល់ព្រមដោយអត្ថ, ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈ តាមសមគួរ ។ ឈ្មោះថា ព្រមទាំងអត្ថ ព្រោះប្រកបព្រមទាំងអត្ថបទដែលសម្តែង ប្រកាស បើក ចែក ធ្វើឱ្យងាយ និងបញ្ញត្តិ, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះដល់ព្រមដោយអក្សរ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេស, ឈ្មោះថា ព្រមទាំងអត្ថ ព្រោះសេចក្តីដែលសាសនព្រហ្មចរិយជាដើមនោះ ជ្រៅដោយអត្ថ និង ជ្រៅដោយបដិវេធ, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះសេចក្តីដែលសាសនព្រហ្មចរិយនោះ ជ្រៅដោយធម៌ និងជ្រៅដោយទេសនា, ឈ្មោះថា ព្រមទាំងអត្ថ ព្រោះភាពជាវិស័យ (គឺអារម្មណ៍) នៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះភាពជាវិស័យ (គឺអារម្មណ៍)

នៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ។

ព្រហ្មចរិយនោះ ឈ្មោះថា ព្រមទាំងអត្ថ ព្រោះហេតុថា ជាទីជ្រះថ្លានៃជនអ្នកជាអ្នកប្រាជ្ញ ព្រោះជាវត្ថុដែលបណ្ឌិតគប្បីដឹង, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះហេតុថា ជាទីជ្រះថ្លានៃលោកិយជន ព្រោះជាវត្ថុគួរជឿ, ឈ្មោះថា ព្រមទាំងអត្ថ ព្រោះមានសេចក្តីអធិប្បាយជ្រៅ, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះមានបទងាយយល់, ឈ្មោះថា បរិសុទ្ធិទាំងអស់ ព្រោះមានសេចក្តីពេញបរិបូរណ៍ ហេតុមិនមានវត្ថុដែលនឹងត្រូវបន្ថែមចូល, ឈ្មោះថា បរិសុទ្ធិ ព្រោះជារបស់រកទោសមិនបាន ហេតុមិនមានវត្ថុដែលនឹងត្រូវនាំចេញ, ឈ្មោះថា ព្រហ្មចរិយ ព្រោះដែលបុគ្គលជាធំ គឺអ្នកប្រសើរគប្បីបដិបត្តិ ហេតុដែលព្រហ្មចរិយនោះ ដែលលោកកំណត់ដោយត្រៃសិក្ខា និងព្រោះជាចរិយារបស់លោកទាំងនោះ, ដូច្នោះ ទើបព្រះឧបាលីពោលថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រកាសព្រហ្មចរិយ ព្រមដោយអត្ថ ព្រមទាំងព្យញ្ជនៈ បរិសុទ្ធបរិបូរទាំងអស់ ។

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ មានហេតុនិងរឿងដែលកើតឡើង ឈ្មោះថា ទ្រង់សម្តែង(ធម៌នោះ) មានសេចក្តីល្អខាងដើម និងឈ្មោះថា ទ្រង់សម្តែង(ធម៌នោះ) មានសេចក្តីល្អផ្នែកកណ្តាល ព្រោះសេចក្តីមិនវិបរិត និងព្រោះប្រកបដោយហេតុ

និងឧទាហរណ៍ ដោយសមគួរដល់វេនេយ្យសត្វ និងឈ្មោះថា ទ្រង់សម្តែង(ធម៌នោះ) មានសេចក្តីល្អក្នុងទីបំផុត ព្រោះធ្វើឱ្យពួកអ្នកស្តាប់បានសទ្ធា និងសេចក្តីទុកចិត្ត ។ ក៏កាលទ្រង់សម្តែងធម៌យ៉ាងនោះ ឈ្មោះថា ទ្រង់ប្រកាសព្រហ្មចរិយ ។

ក៏ព្រហ្មចរិយ ឈ្មោះថា ព្រមទាំងអត្ថ ព្រោះជ្រាបច្បាស់ ក្នុងធម៌ដែលគួរសម្រេចបាន ក៏ដោយការបដិបត្តិ, ឈ្មោះថា ព្រមទាំងព្យញ្ជនៈ ព្រោះស្ទាត់ជំនាញក្នុងគម្ពីរ ក៏ដោយបរិយត្តិ, ឈ្មោះថា បរិបូរណ៍ទាំងអស់ ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម, ឈ្មោះថា បរិសុទ្ធិ ព្រោះមិនមានគ្រឿងសៅហ្មង ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងលះបង់ទុក្ខក្នុងវដ្តៈ និងព្រោះមិនមានសេចក្តីប្រាថ្នាលោកាមិសៈ, ហៅថា ព្រហ្មចរិយ ព្រោះជាចរិយារបស់លោកអ្នកធំ ដោយអត្ថថា ជាអ្នកប្រសើរ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវក ។ សូម្បីព្រោះដូច្នោះ ព្រះមានព្រះភាគអង្គនោះ ទើបពោលបានថា ទ្រង់សម្តែងធម៌មានសេចក្តីល្អខាងដើម មានសេចក្តីល្អផ្នែកកណ្តាល មានសេចក្តីល្អទីបំផុត ទ្រង់ប្រកាសព្រហ្មចរិយបរិសុទ្ធិបរិបូរណ៍ទាំងអស់ ព្រមទាំងអត្ថ និងព្យញ្ជនៈ ។

ពាក្យថា សាធុ ខោ បន : ជាការប្រពៃពេក សេចក្ដីថា មួយទៀត (ការឃើញព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង) ជាការល្អប្រពៃ ។ មានពាក្យអធិប្បាយថា នាំប្រយោជន៍មកឱ្យនាំសេចក្ដីសុខមកឱ្យ ។

ពាក្យថា តថារូបានំ អរហតំ : នឹងព្រះអរហន្តទាំងឡាយមានសភាពយ៉ាងហ្នឹង សេចក្ដីថា (ដំណើរដែលបានឃើញ) ព្រះអរហន្តទាំងឡាយ អ្នកដែលបានជឿថា ជាព្រះអរហន្តក្នុងលោក ព្រោះបានសម្រេចគុណតាមពិត ឃើញព្រះគោតមដ៏ចម្រើននោះ (ជាការប្រពៃពេក) ។

ខថា ទស្សនំ ហោតិ : ដំណើរដែលបានឃើញ បានជួបសេចក្ដីថា វេរញ្ជព្រាហ្មណ៍ ធ្វើអធ្យាស្រ័យទុកយ៉ាងនេះថា "សូម្បីគ្រាន់តែការបើកភ្នែកទាំងពីរដ៏ថ្លាដោយចិត្តជ្រះថ្លា ហើយសម្លឹងមើល ក៏ជាការល្អប្រពៃ" ដូច្នេះ (ទើបចូលទៅគាល់ជាខាងក្រោយ) ។

## វេរញ្ជព្រាហ្មណ៍ចូលទៅគាល់ព្រះពុទ្ធ
## អត្ថាធិប្បាយវិសេសនសព្ទនាមថា យេន តេន

[២] ពាក្យថា យេន ក្នុងខថា អថខោ វេរញ្ជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះដូច្នោះ ក្នុងពីរបទថា យេន តេន នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ព្រះមានព្រះភាគប្រថាប់នៅក្នុងទីណា វេរញ្ជព្រាហ្មណ៍ បានចូលទៅគាល់ក្នុងទីនោះ ។

ម្យ៉ាងទៀត ក្នុងពីរបទថា យេន តេន នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ព្រះមានព្រះភាគដែលទេវតានិងមនុស្សទាំងឡាយគប្បីចូលទៅគាល់ ដោយហេតុណា វេរញ្ជព្រាហ្មណ៍ ក៏ចូលទៅគាល់ដោយហេតុនោះ ។

ក៏ព្រះមានព្រះភាគ ដែលទេវតានិងមនុស្សទាំងឡាយ គប្បីចូលទៅគាល់ ព្រោះហេតុអ្វី ?

គប្បីចូលទៅគាល់ ព្រោះមានសេចក្តីប្រាថ្នា ក្នុងការសម្រេចគុណវិសេសមានប្រការផ្សេង ៗ ដូចដើមឈើធំដែលបញ្ចេញផ្លែជានិច្ច ដែលពួកបក្សីទាំងឡាយ គប្បីហើរចូលទៅរក ព្រោះមានសេចក្តីប្រាថ្នាក្នុងការចិកស៊ីផ្លែដែលល្អដូច្នោះ ។

មួយទៀត បទថា ឧបសង្កមិ : ចូលទៅ មានអធិប្បាយថា ទៅហើយ ។

ពាក្យថា ឧបសង្កមិត្វា : លុះចូលទៅដល់ហើយ ជាពាក្យសម្តែងបរិយោសានកាលកិរិយានៃការចូលទៅគាល់ ។

ម្យ៉ាងទៀត លោកពោលអធិប្បាយទុកថា វេរញ្ជព្រាហ្មណ៍ ទៅហើយយ៉ាងនោះ គឺ ទៅកាន់ស្ថានទីជិតកៀកជាងនោះ បានដល់ ដែលរាប់ថា ជិតនឹងព្រះមានព្រះភាគ ដូច្នេះខ្លះ ។

ប្រើបទថា ភគវតា សទ្ធិំ សម្មោទិ : សំណេះសំណាលទៅរកព្រះមានព្រះភាគ សេចក្តីថា ព្រះមានព្រះភាគ កាលត្រាស់សួរដល់សេចក្តីសុខទុក្ខជាដើម[១] ទ្រង់បានមានសេចក្តីរីករាយប្រព្រឹត្តទៅជាមួយនឹងព្រាហ្មណ៍នោះហើយ យ៉ាងណា ដល់សូម្បីព្រាហ្មណ៍នោះ ក៏យ៉ាងនោះ បានមានសេចក្តីរីករាយប្រព្រឹត្តទៅជាមួយនឹងព្រះមានព្រះភាគ គឺ បានដល់ ភាពជាអ្នករីករាយ បានដល់ ភាពជាពួកតែមួយ ដូចទឹកត្រជាក់និងទឹកក្តៅលាយចូលគ្នា ជាទឹកតែមួយ ដូច្នោះ ។

---

១. សារត្ថទីបនីក្តី អត្ថយោជនាក្តី ជា ខមនយាទិនិ បានប្រែតាមនោះ ។

## អធិប្បាយសំព្ទថា សម្មោទនីយំ និង សារាណីយំ

ក៏វេរញ្ជព្រាហ្មណ៍ បានរីករាយ (នឹងព្រះមានព្រះភាគ) ដោយពាក្យជាដើមថា “បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គល្មមអត់ធន់បានឬ ? ល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបានឬ ? និងព្រះសាវកទាំងឡាយរបស់ព្រះគោតមដ៏ចម្រើន មិន មានអាពាធឬ ? មិនមានទុក្ខឬ ? នៅរហ័សរហួនឬ ? នៅមានកម្លាំងឬ ? នៅមានសេចក្តីសុខសប្បាយឬ ?” ដូច្នេះ យ៉ាងណា ពាក្យយ៉ាងនោះ ឈ្មោះថា សម្មោទនីយៈ (គឺ ពាក្យជាទីតាំងនៃសេចក្តីរីករាយ) ព្រោះឱ្យកើតសេចក្តីរីករាយពោលគឺ បីតិ និងបាមោជ្ជៈ និងព្រោះជាពាក្យសមគួរដើម្បីសេចក្តីរីករាយ ឈ្មោះថា សារាណីយៈ (គឺ ពាក្យជាទីតាំងនៃសេចក្តីរលឹកដល់គ្នា) ព្រោះជាពាក្យដែលសមគួរ និងព្រោះជាពាក្យដែលគួររលឹកដល់ ដើម្បីឱ្យរលឹកដល់រហូតអស់កាលយូរដោយល្អ គឺ ដើម្បីឱ្យប្រព្រឹត្តទៅដោយមិនមានចន្លោះ ព្រោះជាពាក្យផ្អែមល្ហែម ដោយអត្ថនិងព្យញ្ជនៈ ។

មួយទៀត ឈ្មោះថា សម្មោទនីយៈ ព្រោះបានស្តាប់ហើយ ក៏នៅជាសុខ ។ ឈ្មោះថា សារាណីយៈ ព្រោះតាមរលឹកដល់ ក៏នៅជាសុខ, ម្យ៉ាងទៀត ឈ្មោះថា សម្មោទនីយៈ ព្រោះជាពាក្យបរិសុទ្ធិដោយព្យញ្ជនៈ ឈ្មោះថា សារាណីយៈ ព្រោះជាពាក្យបរិសុទ្ធិដោយអត្ថ ដោយប្រការដូច្នេះឯង ។

## អត្ថាធិប្បាយពីរសព្ទថា ឯកមន្តំ និសីទិ

វេរញ្ជព្រាហ្មណ៍ ញ៉ាំងពាក្យដែលជាទីតាំងនៃសេចក្ដីរីករាយ គឺពាក្យជាទីតាំងនៃសេចក្ដីរលឹកដល់គ្នា ឱ្យកន្លងទៅ គឺ ឱ្យចប់ស្រេច បានដល់ ឱ្យសម្រេចអស់ ដោយបរិយាយមិនមែនតិចយ៉ាងនោះហើយ មានបំណងនឹងទូលសួរដល់ប្រយោជន៍ដែលជាហេតុឱ្យខ្លួនមក ទើបអង្គុយហើយក្នុងទីមួយដ៏សមគួរ ។

សព្ទថា ឯកមន្តំ នេះ ជាសព្ទសម្ដែងភាវៈនបុំសកលិង្គ ។ (សព្ទថា ឯកមន្តំ នេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ) ដូចក្នុងពាក្យទាំងឡាយជាដើមថា ព្រះចន្ទ និងព្រះអាទិត្យ រមែងដើរវិលជុំវិញទៅក្នុងទីដែលមិនស្មើ ដូច្នេះ ព្រោះហេតុនោះ ក្នុងពាក្យថា ឯកមន្តំ និសីទិ នេះ គប្បីឃើញសេចក្ដីយ៉ាងនេះថា វេរញ្ជព្រាហ្មណ៍នោះអង្គុយហើយ នឹងឈ្មោះថា ជាអ្នកអង្គុយក្នុងទីមួយដ៏សមគួរ ដោយប្រការណាក៏អង្គុយហើយដោយសេចក្ដីនោះ ។

មួយទៀត ពាក្យថា ឯកមន្តំ នោះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា និសីទិ : អង្គុយ គឺ ចូលទៅជិតហើយ ។ ពិតមែន បុរសទាំងឡាយ ដែលឆ្លាត ចូលទៅរកគរុដ្ឋានីយបុគ្គល (គឺបុគ្គលអ្នកតាំងនៅក្នុងឋានៈជាគ្រូ) ឈ្មោះថា រមែងអង្គុយនៅក្នុងទីមួយ

ដ៏សមគួរ ព្រោះភាពជាអ្នកឆ្លាតក្នុងការអង្គុយ ក៏បណ្ដាបុរសអ្នកឆ្លាតទាំងនោះ វេរញ្ជព្រាហ្មណ៍នេះ ក៏ជាអ្នកឆ្លាតម្នាក់ដែរ, ព្រោះដូច្នោះ ទើបព្រាហ្មណ៍នោះ អង្គុយហើយក្នុងទីមួយដ៏សមគួរ ។

## ការអង្គុយវៀរទោស ៦ យ៉ាង

សួរថា ក៏បុគ្គលអង្គុយយ៉ាងណា ទើបឈ្មោះថា ជាអ្នកអង្គុយហើយក្នុងទីមួយ ដ៏សមគួរ ?

ឆ្លើយថា ត្រូវអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង ទើបឈ្មោះថា ជាអ្នកអង្គុយហើយ ក្នុងទីមួយដ៏សមគួរ ទោសនៃការអង្គុយ ៦ យ៉ាងដូចម្ដេច ? ទោសនៃការអង្គុយ ៦ យ៉ាងនោះ គឺ អង្គុយឆ្ងាយពេក ១ អង្គុយជិតគ្នាពេក ១ អង្គុយលើខ្យល់ ១ អង្គុយទីខ្ពស់ ១ អង្គុយត្រង់មុខពេក ១ អង្គុយខាងក្រោយពេក ១ ។

ពិតមែន បុគ្គលអង្គុយនៅក្នុងទីឆ្ងាយគ្នាពេក បើមានសេចក្ដីប្រាថ្នានឹងនិយាយ នឹងត្រូវនិយាយដោយសំឡេងខ្លាំង ។ អង្គុយក្នុងទីជិតគ្នាពេក រមែងធ្វើសេចក្ដីប្រៀតបៀតគ្នា ។ អង្គុយក្នុងទីលើខ្យល់ រមែងរុកកួន (អ្នកដទៃ) ដោយក្លិនរបស់ខ្លួន ។ អង្គុយក្នុងទីខ្ពស់ រមែងប្រកាសការមិនគោរព ។ អង្គុយក្នុងទីត្រង់មុខពេក បើមានសេចក្ដីប្រាថ្នានឹងមើល នឹងត្រូវសម្លឹងមើលទល់ភ្នែកគ្នានឹងគ្នា ។ អង្គុយខាងក្រោយ

ពេក បើមានសេចក្ដីប្រាថ្នានឹងមើល នឹងត្រូវអើត-កចេញទៅមើល ។ ព្រោះដូច្នោះ វេរញ្ជព្រាហ្មណ៍ សូម្បីនេះ ទើបអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង ពួកនុ៎ះឯង ហេតុដូច្នោះ ព្រះឧបាលិថេរៈ ទើបពោលទុកថា "ព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ" ។

## អធិប្បាយសំព្ទផ្សេងៗ មាន ឯតំ សំព្ទជាដើម

វេរញ្ជព្រាហ្មណ៍ អង្គុយហើយក្នុងទីគួរចំណែកមួយខាងនោះឯង ទើបបានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគ ។ ដោយបទថា **ឯតំ** ជាដើម អាចារ្យសម្ដែងសេចក្ដីដែលគួរនឹងពោលក្នុងពេលឥឡូវនេះ ។ ឧ អក្សរ ធ្វើការតភ្ជាប់បទ ។ បទថា **អវោច : បានពោលហើយ** គឺ បានក្រាបទូលហើយ ។ ប្រជុំបទថា **សុតម្មេតំ** កាត់បទជា **សុតំ មេ តំ : ខ្ញុំបានឮពាក្យនោះ** គឺ សេចក្ដីនោះ ខ្ញុំព្រះអង្គបានស្ដាប់មកហើយ ។ អាចារ្យសម្ដែងក្នុងសេចក្ដីដែលគួរពោលក្នុងកាលឥឡូវនេះ ដោយពាក្យថា **ឯតំ មយា សុតំ** ជាដើម ។

វេរញ្ជព្រាហ្មណ៍ រមែងទូលហៅព្រះមានព្រះភាគ ដោយព្រះគោត្រថា **ភោ គោតម : បពិត្រព្រះគោតមដ៏ចម្រើន,** ឥឡូវនេះ ព្រះឧបាលិថេរៈ កាលនឹងសម្ដែងសេចក្ដីដែលវេរញ្ជព្រាហ្មណ៍នោះ បានស្ដាប់ហើយ

ទើបបានពោលពាក្យជាដើមយ៉ាងនេះថា ន សមណោ គោតមោ ។ ក្នុងពាក្យថា សមណោ គោតមោ ជាដើមនោះ មានការពណ៌នាបទដែលមិនជាក់ច្បាស់ដូចតទៅនេះ ៖

បទថា ព្រាហ្មណេ : ព្រាហ្មណ៍ទាំងឡាយ បានដល់ ព្រាហ្មណ៍ដោយជាតិ ។

បទថា ជិណ្ណេ : ដែលចាស់គ្រាំគ្រា បានដល់ ជាអ្នកចាស់គ្រាំគ្រា គឺ ត្រូវជរាបញ្ចូនឱ្យទៅរកភាពជាអ្នកមានអវយវៈដាច់ជាកំណាត់ ៗជាដើម ។

បទថា វុឌ្ឍេ : ជាព្រឹទ្ធាចារ្យ បានដល់ អ្នកចូលខេត្តដែននៃការចម្រើនលូតលាស់នៃអវយវៈតូចធំ ។

បទថា មហល្លកេ : មានអាយុច្រើន គឺ អ្នកមកតាមព្រមហើយ ដោយភាពជាអ្នកចាស់ដោយជាតិ ។ មានពាក្យអធិប្បាយថា អ្នកកើតមកយូរហើយ ។

បទថា អទ្ធគតេ : រស់នៅយូរឆ្នាំមកហើយ បានដល់ អ្នកកន្លងកាលមកយូរហើយ ។ អធិប្បាយថា អ្នកកន្លងមក ២-៣ រជ្ជកាល (ជំនាន់)ហើយ ។

បទថា វយោអនុប្បត្តេ : មានអាយុក៏ជ្រលចូលមកក្នុងបច្ឆិមវ័យហើយ បានដល់ អ្នកឈានចូលបច្ឆិមវ័យហើយ ។ ចំណែកទី ៣

ដែលមានក្នុងទីបំផុតនៃអាយុមួយរយឆ្នាំ ឈ្មោះថា បច្ឆិមវ័យ (គឺ វ័យចុងបង្អស់) ។

ម្យ៉ាងទៀត ក្នុងបទទាំងឡាយមានបទថា ជិណ្ណេ ជាដើមនេះ គប្បីជ្រាបយោជនាយ៉ាងនេះថា បទថា ជិណ្ណេ បានដល់ អ្នកកើតមុន ។ មានអធិប្បាយថា អ្នកប្រព្រឹត្តទៅតាមត្រកូល ដែលប្រព្រឹត្តទៅរហូតដល់អស់កាលយូរ ។

បទថា វុឌ្ឍេ បានដល់ អ្នកប្រកបដោយសេចក្តីចម្រើននៃគុណមានសីលនិងមារយាទជាដើម ។

បទថា មហល្លកេ គឺ អ្នកមកតាមព្រមហើយ ដោយភាពជាអ្នកមានសម្បត្តិច្រើន គឺ អ្នកមានទ្រព្យច្រើន មានភោគៈច្រើន ។

បទថា អទ្ធគតេ បានដល់ អ្នកដំណើរទៅរហូតដល់អស់មកហើយ គឺ អ្នកប្រព្រឹត្តមិនឈានកន្លងព្រំប្រទល់នៃគុណ មានវត្តចរិយាជាដើម របស់ពួកព្រាហ្មណ៍ ។

បទថា វយោអនុប្បត្តេ បានដល់ អ្នកឈានចូលដល់ភាពជាអ្នកចាស់ដោយជាតិគឺ វ័យខាងចុងបំផុត ។

ឥឡូវនេះ បណ្ឌិតគប្បីប្រកបបទទាំងឡាយជាដើមយ៉ាងនេះថា អភិវាទេតិ ដោយ ន អក្សរ ដែលលោកពោលទុកក្នុងពាក្យថា ន

សមណោ គោតមោ នេះ ហើយជ្រាបតាមសេចក្តីយ៉ាងនេះថា ព្រះសមណគោតមមិនក្រាបថ្វាយបង្គំ មិនក្រោកទទួល ទាំងមិនអញ្ជើញដោយអាសនៈយ៉ាងនេះថា "លោកដ៏ចម្រើនទាំងឡាយ ចូរអង្គុយលើអាសនៈនេះ" ។ ពិតមែន វា សព្ទដែលមាននៅក្នុងពាក្យជាដើមថា អភិវាទេតិ នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថឈ្មោះថា វិភាវនៈ (គឺ ពាក្យប្រកាសតាមប្រក្រតីក្នុងលោក) ដូច វា សព្ទក្នុងប្រយោគជាដើមថា រូបទៀង ឬមិនទៀង ។

វេរញ្ជព្រាហ្មណ៍ គ្រាក្រាបទូលយ៉ាងនោះហើយ លំដាប់នោះ ឃើញព្រះមានព្រះភាគ អ្នកទ្រង់មិនធ្វើសាមីចិកម្មមានការក្រាបថ្វាយបង្គំជាដើមដល់ខ្លួន ទើបក្រាបទូលថា "បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដ" អធិប្បាយថា ពាក្យនោះណា ដែលខ្ញុំព្រះអង្គបានស្តាប់មកហើយ, ពាក្យនោះ រមែងជាយ៉ាងនោះប្រាកដពិត គឺសេចក្តីដែលខ្ញុំព្រះអង្គបានស្តាប់មកនិងបានឃើញមកនោះ រមែងសមគ្នា គឺ ស្មើគ្នា បានដល់ ដល់សភាពតែម្យ៉ាងដូចគ្នាដោយអត្ថន័យមែន ។ វេរញ្ជព្រាហ្មណ៍ ពោលដដែលនូវរឿងដែលខ្លួនបានស្តាប់មកព្រមទាំងដែលខ្លួនបានឃើញមក យ៉ាងនេះថា "ព្រះគោតមដ៏ចម្រើន មិនសំពះមិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ

មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ថា សូម្បីត្រឹមតែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះឱ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ)" កាលទីងតិះដៀល (ព្រះសម្ពុទ្ធ) ទើបក្រាបទូលថា "តយិទំ ភោ គោតម ន សម្បន្នមេវ : បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ" ដូច្នេះ ។ មានអធិប្បាយថា ការដែលព្រះអង្គទ្រង់មិនធ្វើសាមីចិកម្ម មានការសំពះជាដើមនោះ មិនសមគួរឡើយ ។

## ព្រះមានព្រះភាគទ្រង់ជំទាស់

លំដាប់នោះ ព្រះមានព្រះភាគទ្រង់មិនចូលទៅអាស្រ័យទោស គឺការពោលលើកខ្លួនគ្រប សង្កត់អ្នកដទៃ តែមានព្រះបំណងនឹងទ្រង់កម្ចាត់ការមិនដឹងនោះ ដោយព្រះហឫទ័យដ៏ត្រជាក់ព្រោះករុណា ហើយសម្តែងសេចក្តីសមរម្យដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា "ម្នាលព្រាហ្មណ៍ ក្នុងលោក(នេះ) ទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយ ល្មមឱ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឱ្យអង្គុយលើអាសនៈនោះឡើយ, ម្នាល

ព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅរកអ្នកណាឱ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញចាកក” ។

ក្នុងពាក្យថា ឆាហន្តំ ជាដើមនោះ មានសេចក្តីសង្ខេបដូច្នេះគឺ ៖

ម្នាលព្រាហ្មណ៍ សូម្បីតថាគតត្រួតមើលនៅដោយចក្ខុគឺ សព្វញ្ញុតញ្ញាណ ដែលមិនមានអ្វីបិទបាំងបាន ក៏មិនឃើញអ្នកណាមួយដែលល្មមឱ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឱ្យអង្គុយលើអាសនៈ ក្នុងលោកផ្សេង ៗ មានទេវលោកជាដើមនេះឡើយ, ម្យ៉ាងទៀត ដែលយើងបានសម្រេចភាពជាសព្វញ្ញូក្នុងថ្ងៃនេះ មិនឃើញបុគ្គលដែលគួរធ្វើការសំពះបែបនោះ មិនជាអស្ចារ្យឡើយ, មួយទៀតនោះឯង សូម្បីក្នុងកាលណាតថាគតកើតបានតែមួយរំពេចប៉ុណ្ណោះ ក៏បែរមុខទៅមកខាងទិសឧត្តរ ដើរទៅបាន ៧ ជំហាន ហើយបានត្រួតមើលម៉ឺនលោកធាតុទាំងអស់, សូម្បីក្នុងកាលនោះ តថាគតក៏មិនបានឃើញបុគ្គលដែល តថាគតគួរសំពះ គួរក្រោកទទួល ឬគួរអញ្ជើញហៅរកឱ្យអង្គុយលើអាសនៈ ក្នុងលោកផ្សេង ៗ មានទេវលោកជាដើមនេះឡើយ, គ្រានោះឯង សូម្បីស្តេចមហាព្រហ្មជាព្រះខីណាស្រព ដែលមានអាយុបានមួយម៉ឺន៦ពាន់កប្ប ក៏បានផ្គងអញ្ជលី កើតសេចក្តីសោមនស្សទទួល

តថាគតថា "ព្រះអង្គជាមហាបុរសក្នុងលោក, ព្រះអង្គជាមនុស្សច្បងនិងប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោក, មិនមានបុគ្គលដែលខ្ពស់ជាងព្រះអង្គ, មួយទៀត សូម្បីក្នុងកាលនោះ តថាគតកាលមិនឃើញបុគ្គលដែលខ្ពស់ជាងខ្លួន ទើបបានថ្លែងអាសភិវាចាថា "អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស : អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គលប្រសើរបំផុតរបស់លោក"[១] ដូច្នេះ, បុគ្គលអ្នកដែលគួរដល់សាមីចិកម្ម មានការក្រាបថ្វាយបង្គំជាដើម របស់តថាគត សូម្បីកើតបានតែមួយរំពេច ក៏មិនមាន ដោយប្រការដូច្នេះ, ឥឡូវនេះ តថាគតបានសម្រេច ភាពជាសព្វញ្ញូហើយ តើអ្នកណាដែលល្មមឱ្យតថាគតសំពះ ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅរកអ្នកណាឱ្យអង្គុយលើអាសនៈហ្ន៎ ? ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកកុំប្រាថ្នាការធ្វើសេចក្ដីគោរពបែបនោះអំពីតថាគតឡើយ, ម្នាលព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញអ្នកណាឱ្យអង្គុយលើអាសនៈ, ក្បាលរបស់អ្នកនោះនឹងដាច់ចេញចាកកផ្លាក់ចុះទៅលើផែនដីភ្លាម ដូចផ្លែត្នោតដែលមានគ្រៀងស្អិតជាប់តិច ព្រោះទុំ តែងជ្រុះចាកទងក្នុងទីបំផុតនៃរាត្រី ដូច្នោះ ។

---

១. ទីឃ. មហា. មហាបទានសូត្រ. ១៦. ២៦/៣១ ។

# វេរញ្ជព្រាហ្មណ៍ពោលមួលបន្ទាប់ព្រះពុទ្ធ

## ព្រាហ្មណ៍ពោលថា ជាមនុស្សសោះកក្រោះ ឥតរសជាតិ

សូម្បីកាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍ក៏កំណត់មិនបាន នូវភាវៈដែលព្រះតថាគតជាចម្បងក្នុងលោក ព្រោះបញ្ញាទន់ខ្សោយ មិនព្រមអត់ទ្រាំព្រះតម្រាស់នោះទេ ទើបពោលថា "ព្រះគោតមដ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិទេតើ" ។ បានឮថា ព្រាហ្មណ៍នោះមានសេចក្ដីប្រាថ្នាដូច្នេះថា សាមីចិកម្មគឺ ការក្រាបថ្វាយបង្គំ ការក្រោកទទួល និងលើកដៃប្រណមសំពះយ៉ាងណា ដែលគេហៅថា សាមគ្គីរស សាមីចិកម្មមានការក្រាបថ្វាយបង្គំជាដើមនោះ របស់ព្រះគោតមដ៏ចម្រើន រមែងមិនមាន, ព្រោះដូច្នោះ ព្រះគោតមដ៏ចម្រើន ទើបជាមនុស្សសោះកក្រោះឥតរសជាតិ គឺ មានព្រះជីវជាតិមិនមានរស មានសភាពគ្មានរស ( ក្រៀមក្រោះ ) ។

លំដាប់នោះ ព្រះមានព្រះភាគ ដើម្បីនឹងឱ្យព្រាហ្មណ៍នោះកើតចិត្តទោរទន់ ទើបទ្រង់ជៀសវាងអំពីភាពជាសត្រូវដោយត្រង់ចេញ ទ្រង់ទទួលព្រមសេចក្ដីនៃពាក្យនោះ ដោយប្រការដទៃក្នុងព្រះអង្គ ទើបត្រាស់ថា "ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឱ្យអ្នកផងគេថា" ដូច្នេះជាដើម ។

## បរិយាយសព្ទចុះក្នុងអត្ថ ៣ យ៉ាង

ក្នុងពាក្យថា បរិយាយោ ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការណៈឈ្មោះថា បរិយាយ ។ ពិតមែន បរិយាយសព្ទនេះ រមែងប្រព្រឹត្តទៅក្នុងទេសនា វារៈ និងការណៈ ។

សេចក្ដីពិត បរិយាយសព្ទនោះ រមែងប្រព្រឹត្តទៅក្នុងទេសនា ក្នុងពាក្យទាំងឡាយមានអាទិថា "មធុបិណ្ឌិកបរិយាយោត្វេវ នំ ធារេហិ : ចូរអ្នកចាំទុកនូវសេចក្ដីនោះថា ធម្មបរិយាយនេះ ឈ្មោះមធុបិណ្ឌិកបរិយាយដូច្នេះចុះ"[១] ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងវារៈ(វេន) ក្នុងពាក្យទាំងឡាយជាដើមថា "កស្ស នុ ខោ អានន្ទ អជ្ជ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ ម្នាលអានន្ទ ថ្ងៃនេះជាវេនភិក្ខុណាហ្ន៎ ដែលត្រូវឱ្យឱវាទភិក្ខុនីតាមវេន"[២] ។ ប្រព្រឹត្តទៅក្នុងការណៈ(ហេតុ) ក្នុងពាក្យទាំងឡាយជាដើមថា "សាធុ ភន្តេ ភគវា អញ្ញំ បរិយាយំ អាចិក្ខតុ យថាយំ ភិក្ខុសង្ឃោ អញ្ញាយ សណ្ឋហេយ្យ : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ ភិក្ខុសង្ឃ

---

១. មជ្ឈិ. មូល. មធុបិណ្ឌិកសូត្រ. ២០ ២៥០/៤២៦ ។ ២. មជ្ឈិ. ឧប. ២៨. ២៤២/២៧២ ។

នេះ គប្បីស្តិតស្ថេរនៅបាន ដោយហេតុណា សូមព្រះមានព្រះភាគ ទ្រង់សម្តែងហេតុនោះដទៃទៀត”[១] ។

ក្នុងទីនេះ បរិយាយសព្ទនោះ រមែងប្រព្រឹត្តទៅក្នុងការណៈ (ហេតុ) ។ ព្រោះដូច្នោះ ក្នុងបទថា **បរិយាយោ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បុគ្គលពោលរកយើងនៅថា **ព្រះគោតមជ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិ** ដូច្នេះ គប្បីនិយាយត្រូវ គឺ គប្បីដល់ការរាប់ថា ជាអ្នក និយាយមិនខុស ព្រោះហេតុអ្វី ហេតុនោះ មានប្រាកដពិត ។

សួរថា ក៏បរិយាយ (ហេតុ) នោះ ដូចម្តេច ?

ឆ្លើយថា ម្នាលព្រាហ្មណ៍ រសក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈទាំងនោះណា, រសក្នុងរូបជាដើមទាំងនោះ តថាគតលះបានហើយ ។

សួរថា ព្រះមានព្រះភាគ ត្រាស់អធិប្បាយទុកយ៉ាងណា ?

ឆ្លើយថា ត្រាស់អធិប្បាយទុកយ៉ាងនេះ គឺ រសក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ពោលគឺ សេចក្តីត្រេកអរក្នុងកាមសុខ ទាំងនោះណា រមែងកើតឡើង ដល់បុថុជ្ជនទាំងឡាយ សូម្បីអ្នកដែលគេសន្មតថា ជាអ្នកប្រសើរ ដោយអំណាចជាតិ ឬដោយអំណាចសេចក្តីឧប្បត្តិ អ្នកនៅ

---

១. វិន. បារា. ១. ១៧៧/២២៧ ; សំយុ. មហា. ៣៩. ៥១/២៥ ។

គ្រែកអរ ភ្លើតភ្លើន តម្រេកក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម, សេចក្តីត្រេកអរ ក្នុងរូបជាដើម ។ ពួកណា រមែងអូសទាញលោកនេះទុកដូចចងត្រង់ក និងបណ្ឌិតហៅ ថា សាមគ្គីរសេ ព្រោះកាលមានសេចក្តីព្រមព្រៀងគ្នានៃវត្ថុ និងអារម្មណ៍ ជាដើម ក៏កើតឡើងបាន សូម្បីរសទាំងអស់នោះ ព្រះតថាគតលះបាន ហើយ ។

សូម្បីកាលព្រះមានព្រះភាគគួរនឹងត្រាស់ថា ដែលតថាគតលះបាន ហើយ ក៏ទ្រង់សម្តែងធម៌ មិនលើកខ្លួនព្រះអង្គឡើង (មកគ្របសង្កត់ អ្នកដទៃ)ដោយមមង្ការ "ពោលថា របស់តថាគត" ។ ន័យមួយទៀត នោះជាសេចក្តីវិលាស(លំនាំ) នៃទេសនារបស់ព្រះមានព្រះភាគ ។

## ព្រះសម្ពុទ្ធទ្រង់លះរសក្នុងរូបជាដើមបានដាច់ហើយ

បណ្តាបទទាំងនោះ បទថា **បហីនា** សេចក្តីថា រសក្នុងរូបជា ដើមប្រាសចាកពីចិត្តសន្តាន (របស់ព្រះតថាគត)ទៅ ឬដែលព្រះតថាគត ទ្រង់លះបានហើយ ។ តែក្នុងអត្ថនេះ គប្បីឃើញឆដ្ឋីវិភត្តិ ចុះក្នុងអត្ថ តតិយាវិភត្តិ ។ រសក្នុងរូបជាដើមឈ្មោះថា មានឫសគល់ដែលព្រះមាន ព្រះភាគទ្រង់កាត់ផ្តាច់ហើយ ព្រោះអត្ថថា ឫសគល់នៃការហួងហែងក្នុង រូបជាដើមទាំងនោះ ដែលសម្រេចមកពីតណ្ហានិងអវិជ្ជា ដែលព្រះអង្គ ទ្រង់កាត់ផ្តាច់ហើយ ដោយសស្ត្រាគឺ អរិយមគ្គ ។ ឈ្មោះថា ដែលព្រះ

អង្គទ្រង់ធ្វើឱ្យដូចជាត្នោតកំបុត-ក ព្រោះអត្ថថា វត្ថុនៃរូបរសជាដើមទាំងនោះ ដែលព្រះអង្គទ្រង់ធ្វើឱ្យដូចជាគល់ត្នោតដូច្នោះ ។ ដូចឧបមាថា កាលបុគ្គលគាស់រំលើងដើមត្នោតឡើងព្រមទាំងឫសហើយ ធ្វើប្រទេសនោះឱ្យនៅត្រឹមតែគល់នៃដើមត្នោតនោះ ការកើតឡើងនៃដើមត្នោតនោះរមែងប្រាកដមិនបានទៀត យ៉ាងណា, កាលព្រះមានព្រះភាគ ទ្រង់ដករសក្នុងរូបជាដើមឡើងព្រមទាំងឫស ដោយសស្ត្រាគឺ អរិយមគ្គហើយ ទ្រង់ធ្វើចិត្តសន្តានឱ្យនៅត្រឹមតែទីតាំងនៃរសក្នុងរូបជាដើមនោះ ដោយភាពជាស្ថានទីធ្លាប់កើតមកក្នុងកាលមុន សូម្បីរសក្នុងរូបជាដើមទាំងអស់នោះ លោកហៅថា តាលាវត្ថុកតា (ធ្វើឱ្យដូចត្នោតកំបុត-ក) ដូច្នោះ ។

ម្យ៉ាងទៀត រូបាទិរសជាដើមទាំងនោះ មានការមិនដុះឡើងជាធម្មតា ដែលព្រះមានព្រះភាគ ទ្រង់ធ្វើឱ្យដូចត្នោតកំបុត-កដូច្នោះ ព្រោះហេតុនោះ ទើបឈ្មោះថា តាលាវត្ថុកតា (ដែលព្រះអង្គទ្រង់ធ្វើ ឱ្យដូចជាត្នោតកំបុត-កហើយ) ។ មួយទៀត ព្រោះរូបាទិរសជាដើម ព្រះអង្គទ្រង់ធ្វើឱ្យដូចជាត្នោត កំបុត-ក ដោយន័យដែលពោលហើយយ៉ាងនោះ ឈ្មោះថា ជាការដែលព្រះអង្គទ្រង់ធ្វើមិនឱ្យមាន ក្នុងកាលខាងក្រោយ គឺទ្រង់ធ្វើដោយអាការដែលរូបាទិរសជាដើមទាំងនោះ នឹងមានក្នុងកាលខាងក្រោយ មិនបាន, ដូច្នោះ ទើបព្រះអង្គត្រាស់ថា អនភាវំ កតា (ធ្វើមិនឱ្យមានក្នុងកាលខាងក្រោយ) ។

## អធិប្បាយសព្ទ អនភាវំ គតា

ក្នុងបទថា អនភាវំ កតា នេះ កាត់បទដូច្នេះ គឺ អនុ អភាវំ កតា ភ្ជាប់បទជា អនភាវំ កតា : ធ្វើមិនឱ្យមានក្នុងកាលខាងក្រោយ ។ បាលីថា អនភាវំ គតា ដូច្នេះក៏មាន ។ សេចក្ដីនៃបាលីនោះថា ដល់ហើយនូវការមិនមានក្នុងកាលខាងក្រោយ ។ ក្នុងបទថា អនភាវំ គតា នោះ កាត់បទដូច្នេះ គឺ អនុ អភាវំ គតា ភ្ជាប់បទជា អនភាវំ គតា : ឱ្យលែងដុះតទៅទៀតហើយ គឺ ដល់ហើយនូវការមិនមានតទៅខាងមុខទៀត ដូចការកាត់បទក្នុងប្រយោគថា អនុអច្ឆរិយា ភ្ជាប់បទជា អនច្ឆរិយា ប្រែថា ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យសមគួរនេះ ព្រះមានព្រះភាគ មិនមែនបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គ”[១] ។

ពីរបទថា អាយតឹ អនុប្បាទធម្មា : ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ គឺ មានការមិនកើតឡើងក្នុងអនាគតជាសភាព ។ ពិតមែន រូបរសជាដើមពួកណា ដែលដល់ការមិនមានហើយ

---

១. វិន. មហា. មហាខន្ធក. ៦. ៧/១៤; ទីឃ. មហា. មហាបទានសូត្រ. ១៦. ៤២/៧៧ : ឥមា អនច្ឆរិយា គាថាយោ បដិភំសុ បុព្វេ អស្សុតបុព្វា ។

រូបរសជាដើមទាំងនោះ នឹងកើតឡើងបានយ៉ាងណា ? ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ថា ដល់ហើយនូវការមិនមានក្នុងកាលខាងក្រោយ មានការមិនកើតឡើងទៀតទៅ ។

ប្រើនបទថា អយំ ខោ ព្រាហ្មណ បរិយាយោ : ម្នាលព្រាហ្មណ៍ អ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង សេចក្តីថា ម្នាលព្រាហ្មណ៍ អ្នកផងគេតែងពោលមករកតថាគតថា ព្រះសមណគោតម ជាអ្នកមិនមានរស ដូច្នេះ ឈ្មោះថា គប្បីនិយាយត្រូវដោយហេតុណា, ហេតុនេះមាននៅពិត ៗ ។

ប្រើនបទថា នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ : ប៉ុន្តែមិនមែនត្រង់ហេតុដែលអ្នកឯងនិយាយសំដៅនោះទេ សេចក្តីថា ឯហេតុដែលអ្នកឯងនិយាយសំដៅចំពោះតថាគតមិនមានទេ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ត្រាស់យ៉ាងនោះ ? កាលព្រះអង្គត្រាស់យ៉ាងនោះ រមែងជាការដែលទ្រង់ទទួលទ្រសេចក្តីដែលសាមគ្គីរស ដែលព្រាហ្មណ៍ពោលនោះមាននៅក្នុងព្រះអង្គមិនមែនឬ ?

ខ្ញុំព្រះករុណានឹងពោលឆ្លើយតទៅ ៖ សាមគ្គីរសដែលព្រាហ្មណ៍ពោលមិនមានទេ ។ ពិតមែន អ្នកណា ជាអ្នកគួរដើម្បីធ្វើសាមគ្គីរសនោះ តែមិនធ្វើ, អ្នកនោះ គប្បីជាអ្នកត្រូវពោលរកថា ជាអ្នកមានរូបមិន

មានរស ព្រោះមិនមានការធ្វើសាមគ្គីរសនោះ ។ ចំណែកព្រះមានព្រះភាគ មិនគួរដើម្បីទ្រង់ធ្វើសាមគ្គីរសនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទឹងទ្រង់ប្រកាសសេចក្ដីដែលព្រះអង្គជាអ្នកមិនគួរ ក្នុងការធ្វើសាមគ្គីរសនោះ ទើបបានត្រាស់ថា **នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ : ប៉ុន្តែ មិនមែនត្រង់ហេតុដែលអ្នកឯងនិយាយសំដៅនោះទេ** អធិប្បាយថា លោកប្រាថ្នាសំដៅដល់ហេតុយ៉ាងណា ទើបពោលទឹងតថាគតថា ជាអ្នកមិនមានរស ហេតុយ៉ាងនោះ លោកមិនគួរនិយាយក្នុងតថាគតឡើយ ។

## ព្រាហ្មណ៍ពោលថា គ្មានគ្រឿងបរិភោគៈ

ព្រាហ្មណ៍មិនអាចទឹងលើកសេចក្ដីដែលព្រះមានព្រះភាគ ជាអ្នកមិនមានរស (ឡើងប្រកាស) តាមដែលខ្លួនប្រាថ្នាយ៉ាងនោះ ទើបពោលពាក្យដទៃតទៅទៀតថា "ព្រះគោតមដ៏ចម្រើន គ្មានគ្រឿងបរិភោគៈ" ។

មួយទៀត បណ្ឌិតគ្រាជ្រាបលំដាប់យោជនា ដោយន័យដូចពោលហើយនោះឯង ក្នុងបរិយាយទាំងពួងក្នុងព្រះបាលីនេះ ក៏គួរជ្រាបសេចក្ដីតាមដែលព្រាហ្មណ៍ប្រាថ្នាពោលទុក ដោយន័យដូចទឹងពោលតទៅនេះ ៖

ព្រាហ្មណ៍ សម្គាល់សាមីចិកម្មមានការក្រាបថ្វាយបង្គំពួកជនអ្នកចម្រើនវ័យជាដើមនោះឯងថា ជាសាមគ្គីបរិភោគក្នុងលោក ទើបបាន

ពោលនឹងព្រះមានព្រះភាគថា ជាមនុស្សគ្មានភោគៈ ព្រោះការមិនមានសាមីចិកម្ម មានការក្រាបថ្វាយបង្គំជាដើមនោះ ។

ព្រះមានព្រះភាគ ទ្រង់ពិចារណាមិនឃើញមានការបរិភោគដោយអំណាចឆន្ទរាគៈ (ដូច)របស់សត្វទាំងឡាយ ក្នុងរូបារម្មណ៍ជាដើម ក្នុងព្រះអង្គ ទើបទ្រង់ទទួលទ្រង់បរិយាយដទៃទៀត ។

## ព្រាហ្មណ៍ថា ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ

ព្រាហ្មណ៍ ពិចារណាឃើញការមិនធ្វើកម្ម គឺ មារយាទសម្រាប់ត្រកូល មានការក្រាបថ្វាយបង្គំពួកជនអ្នកចម្រើនវ័យជាដើម ដែលពួកជនក្នុងលោកនាំគ្នាធ្វើ ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះគោតមដ៏ចម្រើន ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើទេតើ" ។ តែព្រះមានព្រះភាគទ្រង់ពិចារណាឃើញការពោល ការមិនធ្វើនោះ មានប្រាកដក្នុងព្រះអង្គ ព្រោះព្រះអង្គត្រាស់ការមិនធ្វើកាយទុច្ចរិតជាដើម ទើបទ្រង់ទទួលយកបរិយាយដទៃទៀត ។

ក៏ចេតនាក្នុងការធ្វើជីវិតសត្វឱ្យធ្លាក់កន្លងទៅ ក្នុងការកាន់យកវត្ថុដែលម្ចាស់របស់គេមិនបានឱ្យនិងក្នុងមិច្ឆាចារ គប្បីជ្រាបថា កាយទុច្ចរិតក្នុងបណ្ដាបទទាំងនោះ ។ ចេតនាក្នុងការនិយាយកុហក ការនិយាយស៊កសៀត និយាយពាក្យគ្រោតគ្រាត និងនិយាយផ្ដេសផ្ដាស គប្បីជ្រាបថា

វចីទុច្ចរិត ។ សេចក្ដីលោភចង់បាន សេចក្ដីប្រទូសរ៉ាយ សេចក្ដីឃើញខុស គប្បីជ្រាបថា មនោទុច្ចរិត ។ អកុសលធម៌ទាំងឡាយដែលនៅសល់ វៀរធម៌ទាំងនោះចេញ គប្បីជ្រាបថា អកុសលធម៌ដ៏លាមកមានចំណែកមិនមែនតិច ។

## ព្រាហ្មណ៍ពោលថា ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល

ព្រាហ្មណ៍មិនឃើញកម្ម មានការក្រាបថ្វាយបង្គំជាដើមនោះឯងក្នុងព្រះមានព្រះភាគ យល់ថា អាស្រ័យព្រះមានព្រះភាគនេះ បែបផែនប្រពៃណីរបស់លោកនេះ ក៏នឹងដាច់សូន្យ ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិលទេតើ" ។ តែព្រះមានព្រះភាគទ្រង់ពិចារណាឃើញការពោលការផ្ដាច់ផ្ដិលនោះ មាននៅក្នុងព្រះអង្គ ព្រោះព្រះអង្គត្រាស់ការផ្ដាច់ផ្ដិលនៃរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ក្នុងចិត្តប្បាទដែលសហគតដោយលោភៈ ៨ និងទោសៈដែលកើតឡើងក្នុងអកុសលចិត្ត ២ ដោយអនាគាមិមគ្គ ។ មួយទៀត ត្រាស់ការផ្ដាច់ផ្ដិលនៃមោហៈដែលកើតអំពីអកុសលទាំងអស់មិនមានសេសសល់ ដោយអរហត្តមគ្គ ត្រាស់ការផ្ដាច់ផ្ដិលនៃអកុសលធម៌ដ៏លាមកដែលសេសសល់ ក្រៅពីលោភៈ ទោសៈ មោហៈ ទាំង ៣ នោះ ដោយមគ្គ ៤ តាមសមគួរ ទើបទ្រង់ទទួលបរិយាយដទៃទៀត ។

# ព្រាហ្មណ៍ពោលថា ជាអ្នកខ្ពើមរអើមណាស់

ព្រាហ្មណ៍យល់ថា ព្រះសមណគោតម មុខជានឹងទ្រង់ឃាត់កម្មគឺមារយាទសម្រាប់ត្រកូលមានការក្រាបថ្វាយបង្គំពួកជនដែលចម្រើនវ័យជាដើមនេះ ព្រោះហេតុនោះ ទើបព្រះអង្គមិនធ្វើកម្មនោះ ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះគោតមដ៏ចម្រើន ជាអ្នកខ្ពើមរអើមណាស់ ទេតើ" ។ តែព្រះមានព្រះភាគទ្រង់ពិចារណាឃើញការខ្ពើមរអើមនោះ មាននៅក្នុងព្រះអង្គ ព្រោះព្រះអង្គទ្រង់ខ្ពើមរអើមចំពោះកាយទុច្ចរិតជាដើម ។ ព្រះអង្គត្រាស់អធិប្បាយទុកយ៉ាងណា ? ត្រាស់អធិប្បាយទុកថា ទ្រង់ខ្ពើមទ្រង់ខ្មាស កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ និងការចូលដល់ភាពជាអ្នកមានសេចក្តីសម្បូណ៌, ដោយធម៌ទាំងឡាយ(ដទៃ) ដែលសេសសល់ វៀរទុច្ចរិតទាំងនោះ ដែលឈ្មោះថា អាក្រក់គ្រោតគ្រាត ព្រោះអត្ថថា អាក្រក់ថោកទាប ដែលឈ្មោះថា អកុសល ព្រោះអត្ថថា ជាអំពើមិនឆ្លាតទាំងអស់ ដូចបុរសមានជាតិជាអ្នកប្រជាប់ ខ្ពើមលាមកដូច្នោះ ទើបទ្រង់ទទួលបរិយាយដទៃទៀត ។

បណ្ដាបទទាំងនោះ បទថា **កាយទុច្ចរិតេន** ជាដើម គប្បីឃើញតតិយាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។

## ព្រាហ្មណ៍ពោលថា ជាអ្នកបំផ្លាញ

ព្រាហ្មណ៍ កាលមិនសម្លឹងឃើញកម្ម មានការក្រាបថ្វាយបង្គំជាដើមនោះឯង ក្នុងព្រះមានព្រះភាគ យល់ថា ព្រះគោតមនេះ រមែងទ្រង់បំផ្លាញ គឺ ទ្រង់ធ្វើកម្មដែលគួរធ្វើដល់មនុស្សប្រសើរក្នុងលោកនេះ ឱ្យវិនាស, ម្យ៉ាងទៀត ព្រោះទ្រង់មិនធ្វើសាមីចិកម្មនោះ ដូច្នោះ ព្រះគោតមនេះ ទើបគួរត្រូវកម្ចាត់ គឺ គួរត្រូវសង្កត់សង្កិន ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះគោតមដ៏ចម្រើន ជាអ្នកបំផ្លាញទេតើ" ។

ក្នុងបទថា វេនយិកោ នោះ មានសេចក្តីតបទ ដូចតទៅនេះ ៖

ឧបាយដែលឈ្មោះថា វិន័យ ព្រោះអត្ថថា រមែងបំផ្លាញ ។ អធិប្បាយថា រមែងធ្វើឱ្យវិនាស ។ វិន័យនុ៎ះឯង ឈ្មោះ វេនយិកៈ ។ ម្យ៉ាងទៀត បុគ្គលរមែងគួរដល់ការបំផ្លាញ ហេតុនោះ ទើបឈ្មោះថា វេនយិកៈ (អ្នកគួរបំផ្លាញ) ។ មានអធិប្បាយថា រមែងគួរដល់ការសង្កត់សង្កិន ។ តែព្រះមានព្រះភាគ ក៏ឈ្មោះថា ទ្រង់បំផ្លាញ ព្រោះព្រះអង្គទ្រង់សម្តែងធម៌ដើម្បីបំផ្លាញ គឺ ដើម្បីសេចក្តីស្ងប់កិលេសទាំងឡាយមានរាគៈជាដើម ។ ក្នុងបទថា វេនយិកោ នេះ មានសេចក្តីចំពោះបទប៉ុណ្ណោះឯង ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា វេនយិកៈ ព្រោះអត្ថថា រមែងទ្រង់សម្តែងធម៌ដើម្បីបំផ្លាញ (កិលេសទាំងឡាយមានរាគៈជាដើម) ។

ពិតមែន វិធីព្រឹទ្ធិនៃសត្តុតទ្ធិត ជារបស់វិចិត្រ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ពិចារណាឃើញភាពជាអ្នកកម្ចាត់នោះ (មាននៅ) ក្នុងព្រះអង្គ ទើបទ្រង់ទទួលបរិយាយដទៃទៀត ។

## ព្រាហ្មណ៍ពោលថា ជាអ្នកដុតកំដៅ

ព្រាហ្មណ៍យល់ថា ព្រះមានព្រះភាគនេះ រមែងដុតកំដៅពួកជនអ្នកចម្រើនវ័យ ព្រោះជនទាំងឡាយកាលធ្វើសាមីចិកម្មមានការក្រាបថ្វាយបង្គំជាដើម រមែងធ្វើពួកជនអ្នកចម្រើនវ័យឱ្យត្រេកអរ ឱ្យរីករាយ តែកាលមិនធ្វើ រមែងធ្វើឱ្យក្តៅក្រហាយឱ្យជំទាស់ ឱ្យកើតទោមនស្សដល់ពួកគេ និងព្រះមានព្រះភាគ រមែងមិនធ្វើសាមីចិកម្មទាំងនោះ ។ ម្យ៉ាងទៀត យល់ថា ព្រះមានព្រះភាគនេះ ជាមនុស្សកំព្រា ព្រោះជាអ្នកវៀរចាកមារយាទរបស់មនុស្សល្អ ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះសមណគោតមដ៏ចម្រើន ជាអ្នកដុតកំដៅទេតើ" ។

ក្នុងអត្ថវិកប្បជំបូងនោះ មានសេចក្តីចំពោះបទដូចតទៅនេះ ៖

ធម៌ដែលឈ្មោះថា តបៈ ព្រោះអត្ថថា ដុតកំដៅ ។ មានពាក្យអធិប្បាយថា រមែងរុកកួន គឺ រមែងបៀតបៀន ។ ពាក្យថា តបៈ នេះ ជាឈ្មោះនៃការធ្វើសាមីចិកម្ម ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា តបស្សី ព្រោះអត្ថថា ទ្រង់មានតបៈ ។ ក្នុងអត្ថវិកប្បទីពីរ បណ្ឌិតមិនត្រូវ

ពិចារណាដល់ព្យញ្ជនៈទាំងឡាយទេ ហៅមនុស្សកំព្រាក្នុងលោកថា តបស្សី ។ តែព្រះមានព្រះភាគទ្រង់ពិចារណាឃើញការដុតកំដៅនោះមាននៅក្នុងព្រះអង្គ ព្រោះព្រះអង្គដល់ការរាប់ថា ជាអ្នកដុតកំដៅ ព្រោះទ្រង់លះពួកអកុសលធម៌ដែលហៅថា ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ព្រោះដុតកំដៅសត្វលោក ទើបទ្រង់ទទួលបរិយាយដទៃទៀត ។

ក្នុងបទថា តបស្សី នោះ មានសេចក្តីចំពោះបទ ដូចតទៅនេះ ៖

អកុសលធម៌ទាំងឡាយ ឈ្មោះថា តបៈ ព្រោះអត្ថថា ដុតកំដៅ ។ ពាក្យថា តបៈ នោះ ជាឈ្មោះនៃអកុសលធម៌ទាំងឡាយ ។ សូម្បីសេចក្តីនេះ ក៏សមពិត ដូចព្រះតម្រាស់ដែលព្រះអង្គត្រាស់ទុកក្នុងគាថាថា ៖

ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺ ក្តៅក្រហាយក្នុងលោកនេះ១ ក្តៅក្រហាយក្នុងលោកខាងមុខ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង”[១] ដូច្នេះ ។

១. ខុទ្ទ. ធម្ម. យមកវគ្គ. ៥២. ១១/២៤ ។

ព្រះមានព្រះភាគ ឈ្មោះថា តបស្សី ព្រោះអត្ថថា ទ្រង់គេវែង ទ្រង់រលាស់ ទ្រង់លះបង់ គឺ ទ្រង់កម្ចាត់តបៈធម៌ទាំងនោះចេញ ។

## ព្រាហ្មណ៍ពោលថា ជាមនុស្សឥតកំណើត

ព្រាហ្មណ៍យល់ថា កម្មមានការក្រាបថ្វាយបង្គំជាដើមនោះ រមែងប្រព្រឹត្តទៅ ដើម្បីចូលដល់ព្រមនៃកំណើតក្នុងទេវលោក ដើម្បីបានចំពោះនូវបដិសន្ធិក្នុងទេវលោក និងឃើញកម្មនោះមិនមានក្នុងព្រះមានព្រះភាគ ទើបពោលនឹងព្រះមានព្រះភាគទៀតថា "ព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ" ។ ម្យ៉ាងទៀត ព្រាហ្មណ៍ សូម្បីកាលសម្តែងទោសព្រោះការកាន់បដិសន្ធិក្នុងផ្ទៃនៃមាតារបស់ព្រះមានព្រះភាគ ដោយអំណាចសេចក្តីក្រោធ ទើបពោលយ៉ាងនោះ ។

ក្នុងបទថា អប្បគព្ភោ នោះ មានសេចក្តីចំពោះបទ ដូចតទៅនេះ ៖

ព្រះសមណគោតម ឈ្មោះថា អប្បគព្ភៈ ព្រោះអត្ថថា ប្រាសចាកការកើត អធិប្បាយថា ព្រះសមណគោតម មិនសមគួរដល់ការកើតនៅទេវលោក ។ ម្យ៉ាងទៀត កំណើតរបស់ព្រះសមណគោតមនោះអាក្រក់

ហេតុនោះ ទើបលោកឈ្មោះ អបគព្ភោ ។ អធិប្បាយថា ព្រះសមណគោតម ឈ្មោះថា ជាអ្នកមានចំណែកបានតែកើតក្នុងទីអាក្រក់ថោកថយតទៅ ព្រោះជាអ្នកឃ្លាតឆ្ងាយចាកពីកំណើតក្នុងទេវលោក, ព្រោះហេតុនោះ ការចាប់កំណើតក្នុងផ្ទៃនៃមាតារបស់ព្រះសមណគោតមនោះ ទើបជាកំណើតអាក្រក់ខ្លះ ។ ក៏ព្រោះការដេកក្នុងគភ៌តទៅរបស់ព្រះមានព្រះភាគប្រាសចាកទៅហើយ ដូច្នោះ ព្រះអង្គកាលទ្រង់ពិចារណាឃើញសេចក្ដីប្រាសចាកកំណើតនោះ មាននៅក្នុងព្រះអង្គ ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

ក៏បណ្ដាបទទាំងនោះសេចក្ដីនៃបទទាំងនេះថា យស្ស ខោ ព្រាហ្មណ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា : ម្នាលព្រាហ្មណ៍ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត បើអ្នកណា បានលះបង់ស្រឡះហើយ គប្បីជ្រាបយ៉ាងនេះ ៖

ម្នាលព្រាហ្មណ៍ ការដេកក្នុងគភ៌ក្នុងអនាគត និងការកើតក្នុងភពថ្មីរបស់បុគ្គលណា ឈ្មោះថា លះបានហើយ ព្រោះមានហេតុដែលមគ្គប្រសើរកំចាត់ចេញហើយ ។ ក៏ក្នុងអធិការនេះ ជលាពុជៈកំណើត ព្រះ

មានព្រះភាគ ទ្រង់កាន់យកដោយគព្ភសេយ្យសត្វ ។ កំណើត ៣ ក្រៅនេះទៀត ទ្រង់កាន់យកដោយ បុនព្ភវាភិនិព្វត្តិ សត្វ ។

ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងពីរបទថា គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ នេះ យ៉ាងនេះថា ការដេកនៃសត្វអ្នកកើតក្នុងគភ៌ ឈ្មោះថា គព្ភសេយ្យា ការកើត គឺ ភពថ្មី ឈ្មោះថា បុនព្ភវាភិនិព្វត្តិ ដូចសេចក្តីថា សូម្បីកាលពោលថា វិញ្ញាណឋិតិ ទីតាំងដទៃក្រៅពីវិញ្ញាណទៅ រមែងមិនមាន យ៉ាងណា សូម្បីក្នុងទីនេះ ក៏យ៉ាងនោះ មិនគប្បីចូលការដេកដទៃក្រៅពីសត្វអ្នកកើតក្នុងគភ៌តទៅ ។ ក៏ដែលឈ្មោះថា ការកើតដែលជាភពថ្មីក៏មាន ដែលមិនមែនភពថ្មីក៏មាន តែក្នុងទីនេះប្រាថ្នាយកដែលជាភពថ្មី ព្រោះដូច្នោះ ទើបខ្ញុំព្រះករុណាពោលថា ការកើត គឺ ភពថ្មី ឈ្មោះ បុនព្ភវាភិនិព្វត្តិ ។

## ព្រះតថាគតជាច្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក

[៣] ព្រះមានព្រះភាគ ព្រះអង្គអ្នកជាព្រះធម្មិស្សរ(ធំជាងគេក្នុងការដឹងធម៌) ព្រះធម្មរាជា(ស្ដេចដឹងធម៌) ព្រះធម្មស្វាមី(ម្ចាស់លើគេក្នុងការដឹងធម៌) ព្រះតថាគត ទ្រង់ទតមើលព្រាហ្មណ៍ សុមេធ្បអ្នកកំពុងដេរដោយអក្កោសវត្ថុ៨ មានសេចក្ដីដែលព្រះអង្គមិនមានរសជារូបជាដើម ចាប់ផ្ដើមតាំងពីកាលដែលខ្លួនមកដល់ដោយប្រការដូច្នេះ ដោយព្រះចក្ខុដែលត្រជាក់ដោយព្រះមហាករុណាតែម្យ៉ាង ទ្រង់កំចាត់សេចក្ដីងងឹតក្នុងហទយៈរបស់ព្រាហ្មណ៍ ដូចព្រះចន្ទពេញបូណ៌មី និងដូចព្រះអាទិត្យក្នុងសរទកាល អណ្ដែតនៅក្នុងអាកាសដែលប្រាសចាកពពក ដូច្នោះ ព្រោះព្រះអង្គទ្រង់ចាក់ធ្លុះធម្មធាតុ យ៉ាងណា ហើយដល់សេចក្ដីល្អនៃទេសនាធម្មធាតុនោះព្រះអង្គចាក់ធ្លុះល្អហើយ ទ្រង់សម្ដែងអក្កោសវត្ថុទាំងនោះឯងដោយប្រការយ៉ាងដទៃចាកពីបរិយាយនោះ ៗ ហើយ កាលទឹងប្រកាសសេចក្ដីផ្សាយទៅនៃព្រះមហាករុណារបស់ព្រះអង្គ លក្ខណៈនៃតាទិគុណដែលព្រះអង្គទ្រង់បានហើយ ដោយទ្រង់មិនបានញាប់ញ័រ ព្រោះលោកធម៌ ៨ ព្រះអង្គមានចិត្តស្មើដោយផែនដី និងព្រះអង្គមានការមិនកម្រើកជាធម៌ដដែលទៀត ទ្រង់ព្រះត្រិះរិះថា "ព្រាហ្មណ៍នេះ រមែងជ្រាបសេចក្ដី

ដែលខ្លួនជាមនុស្សចាស់ ដោយហេតុមានសភាពជាអ្នកមានសក់ស្កូវលើសីសៈ មានធ្មេញបាក់ មានស្បែកជ្រួញស្វិតជាដើមតែម្យ៉ាង តែមិនដឹងនូវខ្លួនដែលជាតិជាប់តាម ជរារួបរឹត ព្យាធិគ្របសង្កត់ មរណៈកម្ចាត់សោះទេ ដូចជាឫសគល់ក្នុងវដ្តៈដែលនឹងគប្បីស្លាប់ក្នុងថ្ងៃនេះហើយ ដល់ភាពជាទារកដេកផ្ងារក្នុងស្អែកនេះទៀត ក៏ព្រាហ្មណ៍នេះមកកាន់សំណាក់របស់យើងដោយសេចក្តីឧស្សាហ៍ធំនោះឯង ការមករបស់ព្រាហ្មណ៍នោះចូរប្រព្រឹត្តទៅព្រមដោយប្រយោជន៍ចុះ" ដូច្នេះហើយ កាលនឹងសម្តែងសេចក្តីដែលព្រះអង្គជាអ្នកកើតមុន ដែលមិនមានអ្នកណាប្រៀបផ្ទឹមនឹងព្រះអង្គបាន ក្នុងលោកនេះ ទើបញុំាងព្រះធម្មទេសនាឱ្យចម្រើនដល់ព្រាហ្មណ៍ ដោយន័យថា សេយ្យថាបិ ព្រាហ្មណ : ម្នាលព្រាហ្មណ៍ ប្រៀបដូចជា ជាដើម បណ្តាបទទាំងនោះ បទថា សេយ្យថា ជានិបាតចុះក្នុងអត្ថគឺ ឧបមា ។ បិ សទ្ទ ជានិបាត ចុះក្នុងអត្ថ គឺ សម្ភាវនៈ ។

ព្រះមានព្រះភាគទ្រង់សម្តែងថា យថា ឆាម ព្រាហ្មណ ដោយនិបាតទាំងពីរ, ក៏ក្នុងពាក្យថា ពងមាន់ ៨ ក្តី ១០ ក្តី ១២ ក្តី នេះសួម្បីថា ពងមាន់មានចំនួនតិចឬច្រើនជាងពីចំនួន (៨. ១០. ១២) ដូចដែលពោលហើយ ក៏ពិតមែនហើយ តែថា ក៏គួរជ្រាបថា ព្រះមាន

ព្រះភាគត្រាស់ពាក្យយ៉ាងនេះ ព្រោះជាសេចក្តីពីរោះរណ្តំនៃពាក្យ ។ ពិតមែន ពាក្យដូច្នោះ ចាត់ថា ជាពាក្យពីរោះរណ្តំ ក្នុងមកលោក ។

បទថា តានិស្សុ កាត់បទជា តានិ អស្សុ : ពងមាន់ទាំងនោះ អធិប្បាយថា ពងមាន់ទាំងនោះគប្បីមាន ។

ច្រើនបទថា កុក្កុដិយា សម្មា អធិសយិតានិ : គឺ មេមាន់ក្រាបដោយប្រពៃហើយ សេចក្តីថា ពងទាំងឡាយដែលមេមាន់ឱ្យកំណើតនោះ ត្រដាងស្លាបចេញមកដេកក្រាបនៅខាងលើនៃពងទាំងនោះ ឈ្មោះថា ក្រាបដោយប្រពៃហើយ ។

ពីរបទថា សម្មា បរិសេទិតានិ : ធ្វើឱ្យកក់ក្តៅដោយប្រពៃហើយ សេចក្តីថា កាលមេមាន់ឱ្យពងបានទទួលឧណ្ហភូមិតាមកាលវេលាដ៏សមគួរ ឈ្មោះថា ធ្វើឱ្យកក់ក្តៅ ។ មានពាក្យអធិប្បាយថា ធ្វើឱ្យមានចំហាយក្តៅ ។

ពីរបទថា សម្មា បរិភាវិតានិ : ឱ្យចាប់ក្លិនវាជាមេ ដោយប្រពៃហើយ សេចក្តីថា ពងទាំងឡាយដែលមេមាន់ឱ្យចាប់ក្លិនពាល់ត្រូវដោយទូទៅ តាមកាលវេលាដ៏សមគួរ ឈ្មោះថា ឱ្យចាប់ក្លិនវាជាមេ ។ អធិប្បាយថា ឱ្យបានទទួលក្លិនរបស់វាជាមេ ។

# កូនមាន់ញាស់ចេញមុនហៅថា កូនច្បង

ឥឡូវនេះ ព្រោះពងទាំងនោះ ដែលមេមាន់នោះ កាលរក្សាដោយវិធីទាំង ៣ យ៉ាងនេះ ទើបជាពងមិនស្អុយ ស្ងួមស្ងៃអិលនៃពងទាំងនោះ ដែលមាននៅ ក៏នឹងអស់ទៅ សំបកពងនឹងស្តើង ចុងក្រចកជើងនិងចំពុះនឹងរឹង ។ កូនមាន់ទាំងឡាយ (ដែលនៅខាងក្នុងសំបក) រមែងដល់ការប្រែប្រួល(ធំ) ពន្លឺខាងក្រៅ រមែងប្រាកដដល់ខាងក្នុងព្រោះសំបកស្តើង វេលាពន្លឺប្រាកដនោះ កូនមាន់ទាំងនោះមានគំនិតគិតឡើងថា "ពួកយើងដេកបត់ស្លាប និងជើងនៅក្នុងទីចង្អៀតអស់កាលដ៏យូរពិតហ្ន៎ ឯពន្លឺខាងក្រៅក៏កំពុងប្រាកដ ឥឡូវនេះ ការនៅយ៉ាងសប្បាយ នឹងមានដល់ពួកយើងក្នុងពន្លឺនេះ" ដូច្នេះ មានសេចក្តីប្រាថ្នានឹងចេញមក ទើបយកជើងបោះទម្លាយសំបកពងអើត-កចេញមក ។ តពីនោះសំបកពងនោះ ក៏បែកចេញជាពីរ ។ កូនមាន់ទាំងឡាយ ក៏ចេញមករលាស់ស្លាបបណ្តើរស្រែកបណ្តើរ តាមសមគួរដល់ខណៈនោះ ។ ក៏បណ្តាកូនមាន់ទាំងនោះ ដែលចេញមកនៅយ៉ាងនោះ កូនណាចេញមកមុនគេ កូននោះគេហៅថា បង ព្រោះដូច្នោះ ព្រះមានព្រះភាគ មានព្រះបំណងនឹងញ៉ាំងសេចក្តីដែលព្រះអង្គជាអ្នកធំជាងគេឱ្យសម្រេចដោយឧបមានោះ ទើបត្រាស់សួរព្រាហ្មណ៍

ថា "ក៏បណ្តាកូនមាន់ទាំងនោះ កូនមាន់ណា ទម្លាយសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះហើយញាស់ចេញមកបាន ដោយស្រួលមុនគេបំផុត បើដូច្នោះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅ ?" ។

បណ្តាបទទាំងនោះ បទថា កុក្កុដច្ឆាបកានំ : បណ្តាកូនមាន់ គឺ បណ្តាកូនមាន់ទាំងឡាយ ។

ច្រើនបទថា កិន្តិ ស្វាស្ស វចនីយោ : បើដូច្នោះ តើអ្នកផងគួរហៅកូនមាន់នោះ សេចក្តីថា កូនមាន់នោះគួរហៅថា យ៉ាងដូចម្តេច ? តើគួរហៅថា កូនច្បង ឬកូនពៅហ្ន៎ ? ពាក្យដែលសល់មានសេចក្តីងាយទាំងអស់នោះឯង ។

លំដាប់នោះ ព្រាហ្មណ៍ ក្រាបទូលថា "បពិត្រព្រះគោតមដ៏ចម្រើន (កូនមាន់នោះ) គេគួរហៅថា កូនច្បង" មានអធិប្បាយថា បពិត្រព្រះគោតមដ៏ចម្រើន កូនមាន់នោះ គួរហៅថា ច្បង ។

បើនឹងមានពាក្យសួរថា ព្រោះហេតុអ្វី ទើបហៅថា ច្បង ?

ឆ្លើយថា ព្រោះកូនមាន់នោះ វាចាស់ជាងគេ អធិប្បាយថា ព្រោះកូនមាន់នោះ ធំជាង (កូនមាន់ដែលញាស់ក្រោយ ៗ) ។ លំដាប់នោះ

ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រៀបធៀបសេចក្ដីឧបមាដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា "ម្នាលព្រាហ្មណ៍ កាលបើពួកសត្វដូចជាពងមាន់កើតហើយ មានអវិជ្ជា គឺសេចក្ដីល្ងង់ ដូចជាសម្បកពង កំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទម្លាយសម្បកពង គឺ សេចក្ដីល្ងង់ហើយត្រាស់ដឹងខ្លួនឯងដោយប្រពៃនូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀតប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតនេះឯងជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក" ។ ការមិនដឹង លោកហៅថា អវិជ្ជា ក្នុងបទថា **អវិជ្ជាគតាយ** នេះ បណ្ដាពួកសត្វអ្នកធ្លាក់នៅក្នុងអវិជ្ជានោះ ។ ពាក្យថា **បជាយ** នោះ ជាឈ្មោះរបស់សត្វ ។ ព្រោះដូច្នោះ ក្នុងពាក្យថា **អវិជ្ជាគតាយ បជាយ : កាលបើពួកសត្វមានអវិជ្ជាគឺសេចក្ដីល្ងង់ ដូចជាសំបកពង** នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា បណ្ដាសត្វទាំងឡាយ ដែលធ្លាក់ចូលទៅក្នុងកំណើតខាងក្នុងនៃសំបកពងគឺ អវិជ្ជា ។

បទថា **អណ្ឌភូតាយ : ដូចពងមាន់កើតហើយ** សេចក្ដីថា អ្នកមានហើយ អ្នកកើតហើយ គឺ អ្នកកើតព្រមហើយក្នុងពង ដូចជាសត្វពួកខ្លះអ្នកកើតក្នុងពង គេហៅថា អណ្ឌភូតា យ៉ាងណា ពួកសត្វទាំង

អស់នេះ ក៏យ៉ាងនោះ លោកហៅថា អណ្ឌភូតា ព្រោះភាវៈដែលខ្លួនកើតក្នុងសំបកពងគឺ អវិជ្ជា ។

បទថា បរិយោនទ្ធាយ : កំពុងរួបរឹត សេចក្ដីថា អ្នកដែលសំបកពងគឺ អវិជ្ជានោះ រួបរឹត គឺ ព័ទ្ធព័ន្ធដោយជុំវិញ ។

បទថា អវិជ្ជណ្ឌកោសំ បទាលេត្វា : ទំលាយសម្បកពង គឺសេចក្ដីល្ងង់ សេចក្ដីថា តថាគតបានទម្លាយសំបកពងដែលសម្រេចមកអំពីអវិជ្ជានោះហើយ ។

ពីរបទថា ឯកោវ លោកេ : ក្នុងលោកមានតែម្នាក់ឯង សេចក្ដីថា ក្នុងលោកសន្និវាសទាំងអស់ មានតែតថាគតម្នាក់ឯង គឺ មិនមានជនជាគម្រប់ពីរ ។

បទថា អនុត្តរំ : មិនប្រសើរជាង ក្នុងពាក្យថា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ នេះ សេចក្ដីថា វៀរចាកអរិយមគ្គដ៏ប្រសើរចេញហើយ គឺប្រសើរជាងធម៌ទាំងពួង ។

បទថា សម្មាសម្ពោធឹ : ត្រាស់ដឹងខ្លួនឯងដោយប្រពៃ គឺ ការត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត គឺ ការត្រាស់ដឹង ដែលអ្នកប្រាជ្ញគួរសរសើរផង ល្អផង ។

# ពោធិសំព្ទសំដៅសេចក្ដីដល់ ៤ន័យ

ដើមឈើក្ដី មគ្គក្ដី សព្វញ្ញុតញ្ញាណក្ដី និព្វានក្ដី ហៅថា ពោធិ ។

ពិតមែន លោកហៅដើមឈើថា ពោធិ ក្នុងទីទាំងឡាយដែលមកហើយថា "ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ : បានត្រាស់ដឹងជាដំបូងទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស"[១] និងថា "អន្តរា ច គយំ អន្តរា ច ពោធឹ : ក្នុងចន្លោះនៃគយាប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង"[២] ។

មគ្គ លោកហៅថា ពោធិ ក្នុងទីដែលមកហើយថា "ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ : ញាណក្នុងមគ្គទាំង ៤ លោកហៅថា ពោធិ"[៣] ។

សព្វញ្ញុតញ្ញាណ លោកហៅថា ពោធិ ក្នុងទីដែលមកហើយថា "បប្បោតិ ពោធឹ វរភូរិមេធសោ : ជាអ្នកមានប្រាជ្ញាដ៏ប្រសើរប្រៀបដូចផែនដី ទើងបានដល់(សម្រេច)ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរក្នុងមកប្រាជ្ញា"[៤] ។

---

១. វិន. មហា. មហាខន្ធកៈ. ៦. ១/១ ។ ២. វិន. មហា. មហាខន្ធកៈ. ៦. ១១/២២ ។ ៣. ខុទ្ទ. ចុល្ល. ខគ្គវិសាណសុត្តនិទ្ទេស. ៦៨. ២៣៩/១៩៧ ។ ៤. ទីឃ. បាដិ. លក្ខណសុត្រ. ១៩. ១៨/៣០ ។

ព្រះនិព្វាន លោកហៅថា ពោធិ ក្នុងទីដែលមកហើយថា "**បត្វាន ពោធឹ អមតំ អសង្ខតំ :** ព្រះសិទ្ធត្ថពោធិសត្វ ទ្រង់សម្រេច ពោធិ ដែលជាអមតៈ ជាអសង្ខតៈ"[១] ។

តែក្នុងបទថា សម្មាសម្ពោធឹ នេះ លោកប្រាថ្នាយកអរហត្ត មគ្គញ្ញាណរបស់ព្រះមានព្រះភាគ ។ អាចារ្យពួកខ្លះពោលថា ប្រាថ្នាយក សព្វញ្ញុតញ្ញាណខ្លះ ។

សួរថា ព្រះអរហត្តមគ្គ របស់ពួកបុគ្គលដទៃ ចាត់ជាពោធិ (សេចក្តីត្រាស់ដឹង) ដ៏កំពូលឬទេ ?

ឆ្លើយថា មិនចាត់ជាពោធិដ៏កំពូលទេ ។

សួរថា ព្រោះហេតុអ្វី ទើបមិនចាត់ជាពោធិដ៏កំពូល ?

ឆ្លើយថា ព្រោះព្រះអរហត្តមគ្គរបស់ពួកបុគ្គលដទៃនោះ មិនផ្តល់ នូវគុណគ្រប់យ៉ាង ។

ពិតមែន ព្រះអរហត្តមគ្គរបស់បណ្តាបុគ្គលទាំងនោះ បុគ្គលខ្លះឱ្យ តែព្រះអរហត្តផលប៉ុណ្ណោះ ។ របស់បុគ្គលខ្លះឱ្យតែវិជ្ជា៣ ។ របស់ បុគ្គលខ្លះឱ្យតែអភិញ្ញា៦ ។ របស់បុគ្គលខ្លះតែបដិសម្ភិទា៤ ។ របស់

---

១. អដ្ឋកថា : បបញ្ច. មូល.; សារត្ថ. និទា. ; វិមល. ចរិ. ; មធុរ. ពុទ្ធ. ។

បុគ្គលខ្លះឱ្យតែសាវកបារមីញាណ ។ សូម្បីរបស់ព្រះបច្ចេកពុទ្ធទាំងឡាយក៏ឱ្យត្រឹមតែបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ។ ចំណែកព្រះអរហត្តមគ្គរបស់ព្រះពុទ្ធទាំងឡាយ រមែងឱ្យគុណសម្បត្តិគ្រប់យ៉ាង ដូចការអភិសេករបស់ព្រះរាជាឱ្យភាពជាធំក្នុងលោកទាំងអស់ ដូច្នោះ ។ ព្រោះដូច្នោះព្រះអរហត្តមគ្គ សូម្បីរបស់បុគ្គលដទៃពួកខ្លះ ទើបមិនចាត់ជាពោធិ (សេចក្ដីត្រាស់ដឹង) ដ៏កំពូល ដោយប្រការដូច្នេះ ។

បទថា អភិសម្ពុទ្ធោ : ដឹងក្រៃលែង សេចក្ដីថា តថាគតបានដឹងក្រៃលែង ហើយ គឺ បានចាក់ធ្លុះអស់ហើយ អធិប្បាយថា តថាគតបានសម្រេចហើយ គឺ បានដល់ រួចហើយ ។

## ប្រៀបធៀបការបំពេញអនុបស្សនាដូចការភ្ញាស់ពង

ឥឡូវនេះ បណ្ឌិតគួរប្រៀបធៀបពាក្យឧបមា ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា **ឯវមេវ ខោ អហំ ព្រាហ្មណ : ម្នាលព្រាហ្មណ៍ មាន តែតថាគត** ហើយគប្បីជ្រាបដោយសេចក្ដី ដោយន័យដូចដែលនឹងពោលតទៅនេះ ៖

ដូចការដែលមេមាន់នោះ ធ្វើកិរិយាទាំង ៣ មានដេកក្រាបនៅលើពងទាំងឡាយជាដើមរបស់ខ្លួន យ៉ាងណា ការដែលព្រះមានព្រះភាគ នៅ

ជាព្រះពោធិសត្វ ប្រថាប់អង្គុយលើពោធិបល្ល័ង្ក ហើយទ្រង់បំពេញអនុបស្សនាទាំង ៣ គឺ មិនទៀង ជាទុក្ខ ជាអនត្តា ក្នុងចិត្តសន្តានរបស់ព្រះអង្គ ក៏យ៉ាងនោះ ។

ការមិនសាបសូន្យទៅនៃវិបស្សនាញាណ ក៏ព្រោះព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចពងទាំងឡាយមិនស្អុយ ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ឱ្យដល់ព្រមដូច្នោះ ។

ការអស់ទៅនៃសេចក្តីស្នេហា គឺ ភាពជាប់ចិត្តទៅតាមត្រៃភព ក៏ព្រោះព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចការអស់រំអិលនៃពងទាំងឡាយ ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

សេចក្តីដែលសំបកពងគឺ អវិជ្ជា ជាធម្មជាតិស្តើង ក៏ព្រោះព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចភាវៈដែលសំបកពងជាផុំងស្តើង ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

សេចក្តីដែលវិបស្សនាញាណជាគុណជាតិខ្លាំងក្លា ថ្លាផូរផង់ និងអង់អាច ក៏ព្រោះព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញ

អនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចភាវៈដែលក្រចកជើង និង ចំពុះនៃកូនមាន់ជាអវយវៈគ្រោតគ្រាតនិងរឹងមាំ ក៏ព្រោះមេមាន់ធ្វើកិរិយា ទាំង ៣ ដូច្នោះ ។

គួរជ្រាបវេលាដែលវិបស្សនាញាណចាស់ក្លា វេលាចម្រើន (និង) វេលាកាន់យកបន្ទប់ ក៏ព្រោះព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វទ្រង់បំពេញអនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចវេលាដែលកូនមាន់ចម្រើនហើយ ក៏ព្រោះមេមិនធ្វើកិរិយាទាំង ៣ ដូច្នោះ ។

ព្រោះហេតុនោះ គួរជ្រាបវេលាដែលព្រះមានព្រះភាគ ទ្រង់ឱ្យវិបស្សនាញាណកាន់យកបន្ទប់ ហើយទម្លាយសំបកពង គឺ អវិជ្ជាដោយព្រះអរហត្តមគ្គ ដែលព្រះអង្គទ្រង់បានសម្រេចដោយលំដាប់ ហើយទ្រង់ទទះស្លាប គឺ អភិញ្ញា ទើបទ្រង់ធ្វើឱ្យច្បាស់នូវព្រះពុទ្ធគុណទាំងអស់ដោយសេចក្តីសួស្តី ក៏ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឱ្យដល់ព្រម ប្រៀបដូចវេលាដែលកូនមាន់យកចុងក្រចកជើង និងចុងចំពុះចោះទម្លាយសំបកពង ហើយទទះស្លាបចេញមកបាន ដោយសេចក្តីសួស្តី ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

ប្រើនបទថា ស្វាហំ ព្រាហ្មណ ជេដ្ឋោ សេដ្ឋោ លោកស្ស :

ម្នាលព្រាហ្មណ៍ តថាគតហ្នឹងឯងជាចម្បង ជាបុគ្គលប្រសើរបំផុតជាង សត្វលោក សេចក្តីថា ម្នាលព្រាហ្មណ៍ បណ្តាពួកសត្វ ដែលធ្លាក់នៅក្នុង អវិជ្ជាតថាគតនោះឯង បានទម្លាយសំបកពង គឺ អវិជ្ជានោះ ហើយដល់ ការរាប់ថា ជាអ្នកដែលចម្រើនបំផុត គឺ ចម្រើនយ៉ាងខ្ពស់បំផុត ព្រោះជា អ្នកកើតហើយដោយអរិយជាតិមុនគេបង្អស់ ប្រៀបដូចបណ្តាកូនមាន់ ទាំងនោះ កូនមាន់ដែលចោះទម្លាយសំបកពង ចេញមកបានមុនគេបង្អស់ រមែងជាមាន់ច្បង ដូច្នោះ, ចំណែកព្រះមានព្រះភាគ ឈ្មោះថា ដល់ការ រាប់ថា ជាអ្នកប្រសើរបំផុត ព្រោះមិនមានអ្នកណាប្រៀបផ្ទឹមបានដោយ ព្រះគុណទាំងពួង ។

## ព្រះមានព្រះភាគទ្រង់ប្រសើរព្រោះបំពេញព្យាយាម

លុះព្រះមានព្រះភាគ ទ្រង់ប្រកាសភាវៈនៃព្រះអង្គ ជាអ្នក ចម្បងនិងប្រសើរបំផុត យ៉ាងកំពូលដល់ព្រាហ្មណ៍យ៉ាងនោះហើយ ឥឡូវ នេះ ដើម្បីនឹងទ្រង់សម្តែងបដិបទា ដែលជាហេតុឱ្យព្រះអង្គទ្រង់សម្រេច ភាពជាអ្នកចម្រើនបំផុតជាដើមនោះ ចាប់ផ្តើមតាំងពីចំណែកខាងដើម ទើបត្រាស់ថា អារទ្ធំ ខោ បន មេ ព្រាហ្មណ : ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានតាំងផ្តើមហើយ ជាដើម ។

ម្យ៉ាងទៀត ព្រោះបានស្តាប់សេចក្តីដែលព្រះមានព្រះភាគ ជាអ្នកចម្រើនទីបំផុតនិងប្រសើរបំផុត យ៉ាងកំពូលនេះហើយ ទើបព្រាហ្មណ៍កើតសេចក្តីគិតយ៉ាងនេះថា "ព្រះមានព្រះភាគ ទ្រង់បានសម្រេចភាពជាអ្នកចម្រើនបំផុត និងប្រសើរបំផុតដោយបដិបទា អ្វីហ្ន៎ ?" ដូច្នេះ ; ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីគិតរបស់ព្រាហ្មណ៍នោះហើយ កាលនឹងទ្រង់សម្តែងថា "តថាគតបានសម្រេចភាពជាចម្បង និងប្រសើរបំផុតយ៉ាងកំពូលនេះ ដោយបដិបទានេះ" ទើបបានត្រាស់យ៉ាងនោះ ។

បណ្តាបទទាំងនោះ ប្រើនបទថា អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ : ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានតាំងផ្តើមហើយ សេចក្តីថា ម្នាលព្រាហ្មណ៍ ការដែលតថាគតជាចម្បងនិងប្រសើរបំផុត យ៉ាងកំពូលនេះ តថាគតមិនបានសម្រេចដោយការខ្ជិលច្រអូស ដោយការវង្វេងភ្លេចសតិ ដោយការមានកាយរសាប់រសល់ ( និង ) ដោយភាពជាអ្នកមានចិត្តរវើរវាយទេ ។

ម្យ៉ាងទៀត ព្រោះតថាគតបានប្រារព្ធសេចក្តីព្យាយាមហើយ ដើម្បីសម្រេចភាពជាចម្បង និងប្រសើរបំផុតនោះ គឺ តថាគតអង្គុយហើយនៅក្នុងពោធិមណ្ឌល បានប្រារព្ធសេចក្តីព្យាយាមប្រកបដោយអង្គ ៤

មានពាក្យអធិប្បាយថា បានផ្គង គឺ ឱ្យប្រព្រឹត្តទៅមិនធូរថយ ។ ក៏ឯសេចក្តីព្យាយាមនោះ បានឈ្មោះថា ជាគុណជាតិមិនធូរថយ ព្រោះតថាគតបានប្រារព្ធហើយយ៉ាងពិតប្រាកដ ទាំងមិនមែនត្រឹមតែសេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ សូម្បីសតិក៏តថាគតបានចូលទៅតាំងទុកចំពោះហើយ ដោយភាពជាគុណធម៌បែរមុខត្រង់ចំពោះអារម្មណ៍ និងឈ្មោះថាជាការមិនវង្វេងភ្លេច ព្រោះប្រាកដនៅចំពោះមុខដោយពិត ។

ពីរបទថា បស្សទ្ធោ កាយោ : កាយសោតក៏ស្ងប់រម្ងាប់ សេចក្តីថា សូម្បីកាយរបស់តថាគតក៏ជារបស់ស្ងប់ហើយ ដោយអំណាចនៃសេចក្តីស្ងប់កាយនិងចិត្ត ។ ព្រោះកាលនាមកាយស្ងប់ហើយ សូម្បីរូបកាយ ក៏ស្ងប់ហើយដែរ, ដូច្នោះ ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគមិនត្រាស់ឱ្យពិសេសឡើយថា នាមកាយ រូបកាយ ត្រាស់ត្រឹមតែកាយស្ងប់ប៉ុណ្ណោះ ។

បទថា អសារទ្ធោ : មិនក្រវល់ក្រវាយ សេចក្តីថា ក៏កាយនោះឈ្មោះថា មិនមានសេចក្តីសោប់សេល់ ព្រោះជាកាយដែលស្ងប់ហើយនុ៎ះឯង, មានពាក្យអធិប្បាយថា ជាកាយដែលប្រាសចាកសេចក្តីខ្វល់ខ្វាយហើយ ។

ប្រើនបទថា **សមាហិតំ ចិត្តំ ឯកគ្គំ ចិត្តក៏នឹងល្អ ជាចិត្តមាន អារម្មណ៍តែមួយ** សេចក្ដីថា សូម្បីចិត្តរបស់តថាគតក៏តាំងនៅដោយប្រពៃហើយ គឺ តាំងមាំល្អហើយ ដូចជាថា ណែនស្អិតហើយ, និងចិត្តរបស់តថាគតនោះ ឈ្មោះថា មានអារម្មណ៍តែមួយ, គឺ មិនញាប់ញ័របានដល់ មិនមានសេចក្ដីក្ដៅក្រហាយ ព្រោះជាចិត្តតាំងមាំល្អនុ៎ះឯង ។ វត្តបដិបត្តិជាចំណែកខាងដើមនៃឈាន ជាបដិបទាដែលព្រះមានព្រះភាគត្រាស់ហើយ ដោយលំដាប់ត្រឹមតែប៉ុណ្ណេះ ។

## បឋមជ្ឈានកថា

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងគុណវិសេសចាប់ផ្ដើមតាំងពីបឋមជ្ឈាន (រហូតដល់)មានវិជ្ជា ៣ ជាទីបំផុត ដែលព្រះអង្គបានសម្រេចហើយដោយបដិបទានេះ ទើបត្រាស់ថា **សោ ខោ អហំ : តថាគតនោះឯង** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងនោះ សេចក្ដីនៃបទជាដើមថា **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ : លុះដល់ប្រាកដជាស្ងាត់ចាកកាមទាំងឡាយ ប្រាកដជាស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ**, ព្រះមានព្រះភាគ ត្រាស់ទុកហើយក្នុងឈានវិភង្គនុ៎ះឯង ដោយន័យជាដើមថា

“បណ្តាធម៌ទាំងនោះ កាមទាំងឡាយ តើដូចម្តេច គឺ ឆន្ទៈ ឈ្មោះថា កាម, រាគៈ ឈ្មោះថា កាម, ឆន្ទរាគៈ ឈ្មោះថា កាម, ការត្រិះរិះ ឈ្មោះថា កាម, រាគៈ ឈ្មោះថា កាម, ការត្រិះរិះនិងរាគៈ ឈ្មោះថា កាម, កិលេសទាំងអស់នេះ ហៅថា កាម ។ បណ្តាធម៌ទាំងនោះ ពួកធម៌ជាអកុសល តើដូចម្តេច ។ ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា, ពួកកិលេសទាំងនេះ ហៅថា អកុសលធម៌ ។ ភិក្ខុជាអ្នកស្ងាត់ចាកកាមទាំងនេះផង ចាកអកុសលធម៌ទាំងនេះផង ព្រោះហេតុនោះ ទើបពោលថា ស្ងាត់ចាកកាមទាំងឡាយ ចាកអកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះ”[១] ដូច្នេះ ក៏ពិតមែនហើយ, តែថា សេចក្តី (នៃបទទាំងនោះ) វៀរនូវន័យរបស់អដ្ឋកថាចេញ នឹងប្រាកដដោយល្អមិនបាន ខ្ញុំព្រះករុណានឹងប្រកាសសេចក្តីនោះតាមន័យរបស់អដ្ឋកថាទុំះឯងតទៅ ៖

សេចក្តីនេះយ៉ាងណា ? យ៉ាងនេះគឺ ពីរបទថា **វិវិច្ចេវ កាមេហិ** : ស្ងាត់ ចាកកាមទាំងឡាយ គឺ ស្ងាត់ហើយ វៀរ គេចចេញហើយ ពីកាមទាំងឡាយ ។

១. អភិ. វិភ. ឈានវិភង្គ. ៨១ ៣៩៧/២៧៤; បាលីបិដកមិនមាន **បវិវិត្តោ** : គឺស្ងប់ហើយ ។

# អធិប្បាយ ៦១ អក្សរ

ក៏ ៦៧ អក្សរនេះ ក្នុងបទថា វិវិច្ចេវ នេះ គប្បីជ្រាបថា មានសេចក្ដីកំណត់ជាអត្ថ ។ ក៏ព្រោះ ៦៧ អក្សរ មានសេចក្ដីកំណត់ជាអត្ថនោះ, ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់សម្ដែងសេចក្ដីដែលកាមទាំងឡាយ សូម្បីមិនមាននៅក្នុងវេលាចូលបឋមជ្ឈានទោះ ក៏ជាសត្រូវដល់បឋមជ្ឈាននោះ និងការសម្រេចបឋមជ្ឈាននោះបាន ក៏ដោយការលះបង់កាមនុ៎ះឯង ។

សួរថា សេចក្ដីនោះ គឺ យ៉ាងណា ?

ឆ្លើយថា គឺ ស្ងាត់ហើយចាកកាមទាំងឡាយ ដោយពិតអធិប្បាយថា ពិតមែន កាលធ្វើសេចក្ដីនិយមទុកយ៉ាងនោះ ពាក្យនេះរមែងប្រាកដច្បាស់ថា កាមទាំងឡាយ រមែងជាសត្រូវចំពោះឈានទេះយ៉ាងពិតប្រាកដ, កាលកាមពួកណានៅមាន បឋមជ្ឈានទេះ រមែងប្រព្រឹត្តទៅមិនបាន ដូចកាលមានងងឹត ពន្លឺប្រទីបក៏មិនមានដូច្នោះ និងការសម្រេចបឋមជ្ឈាននោះ ទឹងមានបានក៏ដោយការលះបង់កាមទាំងនោះចេញបាន ប្រៀបដូចការទៅដល់ត្រើយនាយបាន ក៏ដោយការលះត្រើយអាយដូច្នោះ, ព្រោះដូច្នោះ ទើបលោកធ្វើសេចក្ដីកំណត់ទុក ។

ក្នុងពាក្យថា វិវិច្ចេវ កាមេហិ នោះ គប្បីមានពាក្យសួរថា ក៏ព្រោះហេតុអ្វី ? ព្រះមានព្រះភាគ ទើបត្រាស់ ឯវ អក្សរនោះ ទុកចំពោះបទដើមប៉ុណ្ណោះ មិនត្រាស់ ទុកក្នុងបទចុងហ្ន៎, ព្រះយោគាវចរសូម្បីមិនស្ងាត់ចាកពីអកុសលធម៌ទាំងឡាយ ក៏គប្បីបានសម្រេចឈានដែរឬ ?

ឆ្លើយថា ក៏ឯ ឯវ អក្សរ ដែលជាអវធារណៈនោះ បណ្ឌិតមិនគួរឃើញយ៉ាងនោះ ។ ព្រោះថា ឯវ អក្សរនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងបទដើម ក៏ព្រោះឈានជាគ្រឿងរលាស់ចេញនូវកាមនោះ ។ ពិតមែន ឈាននេះ ឈ្មោះថា រលាស់ចេញនូវកាមទាំងឡាយ ព្រោះឈានកន្លងកាមធាតុចេញបាន និងព្រោះជាសត្រូវចំពោះកាមរាគៈ ។ ដូចដែលព្រះសារីបុត្រពោលទុកថា "កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ : ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់នេក្ខម្មៈ គឺ បឋមជ្ឈាន"[១] ដូច្នេះ ។

ក៏ ឯវ អក្សរនោះ បណ្ឌិតគួរពោលទុកសូម្បីក្នុងបទខាងចុង ដូចយ៉ាង ឯវ អក្សរ ដែលព្រះមានព្រះភាគទ្រង់នាំមកត្រាស់ទុកក្នុងពាក្យនេះថា "ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ

---

១. ខុទ្. ឥតិ. តិកនិបាត. ៥៣. ៧២/៨២ ។

ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ : ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ (គឺសោតាបន្ន) មានតែក្នុងសាសនានេះ សមណៈទី ២ (គឺសកទាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ (គឺអនាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈ ទី ៤ (គឺអរហន្ត) ក៏មានតែក្នុងសាសនានេះ”[១] ដូច្នេះ ។ ពិតមែន អ្នកណា ៗ មិនស្ងាត់ហើយចាកពីអកុសលធម៌ទាំងឡាយពោលគឺ នីវរណៈ សូម្បីដទៃចាកកាមឆន្ទៈនេះ មិនអាចនឹងសម្រេចឈានបានឡើយ, ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញនិយមនេះ សូម្បីក្នុងបទទាំងពីរ យ៉ាងនេះថា ព្រះយោគាវចរស្ងាត់ហើយចាកកាមទាំងឡាយ ពិតប្រាកដមែន ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយពិតប្រាកដមែន ដូច្នេះ ។

មួយទៀត វិវេកទាំងអស់ មានតទង្គវិវេក និងកាយវិវេកជាដើម រមែងដល់ការសង្គ្រោះចូលក្នុងបទទាំងពីរ ដោយពាក្យដែលជាសាធារណៈនេះថា វិវិច្ច ក៏ពិតមែនហើយ, តែថា ក្នុងអធិការនេះ ក៏គួរឃើញវិវេកត្រឹមតែ ៣ ប៉ុណ្ណោះ គឺ កាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក ។

ក៏ពួកវត្ថុកាម ដែលព្រះសារីបុត្តត្ថេរ ពោលទុកក្នុងនិទ្ទេស ដោយ

១. មជ្ឈិ. មូល. ចូឡសីហនាទសូត្រ. ២០. ១៥៤/២៤២; អង្គុ. ចតុក្ក. កម្មវគ្គ. ៤៣. ៩១/២៤៥ ។

ន័យជាដើមថា "កតមេ វត្ថុកាមា មនាបិយា រូបា : ពួកវត្ថុកាមដូចម្តេច ។ រូបជាទីគាប់ចិត្ត"[១] និងពួកកិលេសកាម ដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងវិភង្គនៃនិទ្ទេសនោះឯង ដោយន័យជាដើមថា "ឆន្ទោ កាមោ : សេចក្តីប្រាថ្នា ឈ្មោះថា កាម"[២] ទាំងអស់នោះ បណ្ឌិតគប្បីឃើញថា លោកសង្គ្រោះចូលដោយបទថា កាមេហិ នេះឯង ។ ក៏កាលបើដូច្នោះ ពីរបទថា វិវិច្ចេវ កាមេហិ សេចក្តីថា ស្ងាត់ហើយ សូម្បីចាកពីវត្ថុកាមទាំងឡាយពិតប្រាកដមែន ដូច្នេះក៏ប្រើបាន ។ កាយវិវេក រមែងជាបទដែលលោកពោលហើយ ដោយសេចក្តីស្ងាត់ចាកពីវត្ថុកាមនោះ ។

ច្រើនបទថា វិវិច្ច អកុសលេហិ ធម្មេហិ : ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ សេចក្តីថា ស្ងាត់ហើយចាកកិលេសកាមទាំងឡាយ ឬចាកអកុសលធម៌ទាំងពួង ដូច្នេះ ក៏ប្រើបាន ។ ចិត្តវិវេករមែងជាបទដែលលោកពោលហើយ ដោយសេចក្តីស្ងាត់ចាកកិលេសកាម ឬចាកអកុសលធម៌ទាំងពួងនោះ ។

---

១. ខុទ្ទ. មហា. កាមសុត្តនិទ្ទេស. ៦៤. ២/១ ។ ២. ខុទ្ទ. មហា. កាមសុត្តនិទ្ទេស. ៦៤. ២/២ ។

ក៏បណ្ដាកាយវិវេកនិងចិត្តវិវេក ២ យ៉ាងនេះ ការលះបង់កាមសុខជាបទដែលលោកប្រកាសហើយ ដោយកាយវិវេកដែលជាបទដើម ព្រោះពោលដល់សេចក្ដីស្ងាត់ចាកវត្ថុកាមទាំងឡាយនុ៎ះឯង, ការផ្គងនេក្ខម្មសុខជាបទដែលលោកប្រកាសហើយ ដោយចិត្តវិវេកដែលជាបទទី ២ ព្រោះពោលដល់សេចក្ដីស្ងាត់ចាកពីកិលេសកាមទាំងឡាយ ។

មួយទៀត បណ្ដាបទទាំង ២ តាមដែលពោលហើយនោះ ការលះសង្កិលេសវត្ថុ គប្បីដឹងថា លោកប្រកាសហើយ ដោយបទដំបូង, ការលះសង្កិលេស គប្បីដឹងថា លោកប្រកាសហើយដោយបទទី ២ ។ ការលះហេតុនៃចំណង់ គប្បីដឹងថា លោកប្រកាសហើយ ដោយបទដំបូង, ការលះហេតុនៃសេចក្ដីល្ងង់ខ្លៅ គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ២, សេចក្ដីបរិសុទ្ធនៃការប្រកបសេចក្ដីព្យាយាម គប្បីដឹងថា លោកប្រកាសហើយ ដោយបទដំបូង, និងសេចក្ដីអប់រំលើអធ្យាស្រ័យ គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ២ ព្រោះពោលដល់សេចក្ដីស្ងាត់ចាកពីវត្ថុកាម និងកិលេសកាមនុ៎ះឯង ដូចពណ៌នាមកដូច្នេះ ។

បណ្ដាកាមតាមដែលពោលក្នុងបទថា កាមេហិ នេះ ក្នុងចំណែកវត្ថុកាមមានន័យប៉ុណ្ណេះសិន ។ ឯក្នុងផ្នែកកិលេសកាម កាមឆន្ទៈនុ៎ះឯងដែលមានច្រើនប្រភេទណាស់ លោកបំណងថា កាម ដោយន័យជាដើម

យ៉ាងនេះថា ឆន្ទៈ ឈ្មោះថា កាម និងថា រាគៈ ឈ្មោះថា កាម ។ សូម្បីកាមឆន្ទៈនោះ ដល់ការរាប់បញ្ចូលក្នុងអកុសលក៏ដោយ ក៏ព្រះមានព្រះភាគត្រាស់ទុកក្នុងគម្ពីរវិភង្គមួយផ្នែក ព្រោះជាសត្រូវចំពោះឈាន ដោយន័យជាដើមថា "តត្ថ កតមោ កាមឆន្ទោ បណ្ដាធម៌ទាំងនោះ សេចក្ដីពេញចិត្តក្នុងកាម ដូចម្ដេច ? គឺ កាម" ដូច្នេះ ។

ម្យ៉ាងទៀត កាមឆន្ទៈនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងបទដើម ព្រោះជាកិលេសកាម ។ ត្រាស់ទុកក្នុងបទទី ២ ព្រោះជាកាមរាប់បញ្ចូលក្នុងអកុសល ។

មួយទៀត មិនបានត្រាស់ថា **កាមតោ** តែត្រាស់ថា **កាមេហិ** ព្រោះកាមឆន្ទៈនោះមានច្រើនប្រភេទ ។ ក៏កាលសេចក្ដីដែលធម៌ទាំងឡាយសូម្បីពួកដទៃដែលជាអកុសលនៅមាន ។ នីវរណៈទាំងឡាយប៉ុណ្ណោះ ព្រះមានព្រះភាគ ត្រាស់ទុកក្នុងគម្ពីរវិភង្គ ព្រោះទ្រង់សម្ដែងនូវនីវរណៈជាសត្រូវដោយត្រង់ចំពោះអង្គឈានជាន់ខ្ពស់ឡើងទៅ ដោយន័យជាដើមថា "តត្ថ កតមេ អកុសលា ធម្មា ។ កាមច្ឆន្ទោ ។បេ ។ : បណ្ដាធម៌ទាំងនោះ ពួកធម៌ជាអកុសល ដូចម្ដេច ។ កាមឆន្ទៈ ..."[១] ដូច្នេះ ។ ពិតមែន នីវរណៈទាំងឡាយ រមែងជាសត្រូវដោយត្រង់ចំពោះ

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៣៩៧/២៧៤ ។

អន្តរាយ ។ មានពាក្យអធិប្បាយថា អន្តរាយទាំងឡាយប៉ុណ្ណោះជាបដិបក្ខ គឺ ជាគ្រឿងកម្ចាត់នីវរណៈទាំងនោះ ។ ពិតមែន ព្រះមហាកច្ចាយនត្ថេរ ក៏បានពោលទុកក្នុងបេដកបករណ៍ថា សមាធិ ជាបដិបក្ខចំពោះកាមឆន្ទៈ បីតិ ជាបដិបក្ខចំពោះព្យាបាទ វិតក្កៈ ជាបដិបក្ខចំពោះថីនមិទ្ធៈ សុខ ជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ វិចារៈ ជាបដិបក្ខចំពោះវិចិកិច្ឆា ។

បណ្ដាបទទាំង ២ នេះ សេចក្ដីស្ងាត់ដោយអំណាចការគ្របសង្កត់កាមឆន្ទៈទុក រមែងជាវិវេក ដែលព្រះមានព្រះភាគត្រាស់ហើយដោយបទនេះថា វិវិច្ចេវ កាមេហិ ។ សេចក្ដីស្ងាត់ដោយអំណាចការគ្របសង្កត់នីវរណៈសូម្បីទាំង ៥ ទុក ជាវិវេកដែលព្រះអង្គត្រាស់ដោយបទនេះថា វិវិច្ច អកុសលេហិ ធម្មេហិ ដោយន័យដូចពោលមកដូច្នេះ ។

មួយទៀត សេចក្ដីស្ងាត់ ដោយអំណាចការគ្របសង្កត់កាមឆន្ទៈទុក រមែងជាវិវេកដែលព្រះមានព្រះភាគត្រាស់ទុកដោយបទដំបូង ដោយសព្ទដែលលោកមិនបានកាន់យក, សេចក្ដីស្ងាត់ដោយអំណាចការគ្របសង្កត់នីវរណៈដែលសល់ទុក ជាវិវេកដែលត្រាស់ដោយបទទី ២ ។ មួយទៀត បណ្ដាអកុសលមូលទាំង ៣ សេចក្ដីស្ងាត់ដោយអំណាចការ

គ្របសង្កត់លោភ: ដែលផ្សេងគ្នានៃបញ្ចកាមគុណជាអារម្មណ៍ ជាវិវេកដែលត្រាស់ទុកដោយបទដំបូង, សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់ទោស: និងមោហ: ដែលមានប្រភេទនៃអាឃាតវត្ថុជាដើមជាអារម្មណ៍ ជាវិវេកដែលត្រាស់ទុកដោយបទទី ២ ។

ម្យ៉ាងទៀត បណ្តាធម៌ទាំងឡាយ មានឱឃ:ជាដើម សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់សញ្ញោជន: គឺ កាមឱឃ: កាមយោគ: កាមាសវ: កាមុបាទាន អភិជ្ឈាកាយគន្ថ: និងកាមរាគ:ទុក ជាវិវេកដែលព្រះមានព្រះភាគត្រាស់ដោយបទដំបូង ។ សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់សញ្ញោជន: គឺ ឱឃ: យោគ: អាសវ: ឧបាទាន និងគន្ថ: ដែលសល់ទុក រមែងជាវិវេកដែលព្រះអង្គត្រាស់ ដោយបទទី ២ ។ មួយទៀត សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់តណ្ហា និងកិលេសដែលសម្បយុត្តដោយតណ្ហានោះទុក ជាវិវេកដែលព្រះអង្គត្រាស់ដោយបទដំបូង, សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់អវិជ្ជា និងកិលេសដែលសម្បយុត្តដោយអវិជ្ជានោះទុក ជាវិវេកដែលព្រះអង្គត្រាស់ ដោយបទទី ២ ។

ម្យ៉ាងទៀត សេចក្តីស្ងាត់ដោយអំណាចការគ្របសង្កត់ចិត្តុប្បាទ ៨ ដែលសម្បយុត្តដោយលោភ:ទុក គប្បីជ្រាបថា ជាវិវេកដែលព្រះអង្គ

ត្រាស់ដោយបទដំបូង, សេចក្ដីស្ងាត់ដោយអំណាចការគ្របសង្កត់អកុសលចិត្តបា្បទ ៤ ដែលសល់ទុក គប្បីជ្រាបថា ជាវិវេកដែលព្រះអង្គត្រាស់ដោយបទទី ២ ។ ការប្រកាសសេចក្ដីក្នុងពាក្យថា វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ នេះ មានត្រឹមតែប៉ុណ្ណេះសិន ។

## អត្ថាធិប្បាយអង្គ ៥ នៃបឋមជ្ឈាន

ក៏ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងអង្គសម្រាប់លះនៃបឋមជ្ឈានដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះហើយ គ្រានេះ កាលនឹងទ្រង់សម្ដែងអង្គប្រកប ទើបត្រាស់ពាក្យជាដើមថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។

ក្នុងពាក្យថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

សេចក្ដីត្រិះរិះ ឈ្មោះថា វិតក្កៈ, លោកអធិប្បាយថា សេចក្ដីត្រិះរិះ, វិតក្កៈនោះ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការធ្វើចិត្តឱ្យប៉ះខ្ទប់អារម្មណ៍រឿយ ៗ ជាកិច្ច ។ ពិតមែន ព្រះយោគាវចរលោកហៅថា ធ្វើអារម្មណ៍ឱ្យជាធម្មជាតិដែលវិតក្កៈធ្វើចិត្តឱ្យប៉ះខ្ទប់រឿយ ៗ

ហើយដោយវិតក្កៈនោះ ។ វិតក្កៈនោះមានការនាំចិត្តមកក្នុងអារម្មណ៍ ជាបច្ចុប្បដ្ឋាន ។ សេចក្ដីពិចារណា ឈ្មោះថា វិចារៈ, លោកអធិប្បាយថាការដែលចិត្តត្រាច់អន្ទោលទៅរឿយ ៗ ។ វិចារៈនោះ មានការស្ទាបអង្អែល (ពិចារណា) អារម្មណ៍ ជាលក្ខណៈ មានការតាមប្រកបសហជាតធម៌ក្នុងអារម្មណ៍នោះជាកិច្ច មានការតាមចងចិត្តទុកក្នុងអារម្មណ៍ ជាបច្ចុប្បដ្ឋាន ។

ក៏ការមិនប្រាសចាកគ្នានៃវិតក្កៈវិចារៈទាំងនោះ ក្នុងចិត្តប្បាទខណៈខ្លះ វិតក្កៈ ក៏គឺ ការធ្លាក់ទៅកាន់អារម្មណ៍គ្រាដំបូងរបស់ចិត្ត ដូចសំឡេងគោះរគាំង ព្រោះសំដៅសេចក្ដីថា ជាសភាពដែលគ្រោតគ្រាត និងព្រោះអត្ថន័យថា ជាសភាពចាប់ផ្ដើមមុន ។ វិចារៈ ក៏គឺ ការដែលចិត្តតាមចងព័ទ្ធជាប់បន្ត ដូចសំឡេងខ្ទរបស់រគាំង ព្រោះសំដៅសេចក្ដីថា ជាសភាពដែលល្អិត ។ ក៏ក្នុងវិតក្កៈវិចារៈទាំងនេះ វិតក្កៈ មានការផ្សាយទៅ (ឬរញ្ជួយញាប់ញ័រ) ជាសេចក្ដីញ័ររបស់ចិត្ត (ក្នុងវេលាដែលកើតសេចក្ដីគិតឡើងគ្រាដំបូង) ដូចការទទះស្លាបរបស់សត្វបក្សី ដែលត្រូវការនឹងហើរឡើងទៅក្នុងអាកាស និងដូចការហើរចុះមកត្រង់ផ្កាឈូកធំរបស់មេឃ្មុំដែលមានចិត្តផ្ដោតទៅនៅត្រង់ក្លិន, វិចារៈមានការប្រព្រឹត្តទៅស្ងប់ មិនមែនសេចក្ដីញ័រយ៉ាងខ្លាំងរបស់ចិត្ត ដូចការត្រដាងស្លាបរបស់សត្វ ដែលហើរទៅហើយក្នុងអាកាស និងដូចការហើរវែ្ធលនៅក្នុងចំណែកខាងលើផ្កាឈូក

ធំរបស់មេឃ្មុំ ដែលហើរចុះបែរមុខកាន់ផ្កាឈូកធំដូច្នោះ ។ ចំណែក សេចក្តីប្លែកគ្នានៃវិតក្កៈវិចារៈទាំងនោះ នឹងប្រាកដក្នុងបឋមជ្ឈាន និង ទុតិយជ្ឈាន ។

ឈាននេះ រមែងប្រព្រឹត្តទៅព្រមដោយវិតក្កៈនេះ និងដោយវិចារៈ នេះ ដូចដើមឈើ រមែងប្រព្រឹត្តទៅដោយផ្កានិងផ្លែដូច្នោះ ដោយប្រការ ដូច្នេះ ព្រោះដូច្នោះ ឈាននេះ ទើបព្រះមានព្រះភាគត្រាស់ថា "សវិតក្កំ សវិចារំ : ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ" ។ តែក្នុងគម្ពីរវិភង្គ ព្រះអង្គទ្រង់ធ្វើទេសនាជាបុគ្គលាធិដ្ឋាន ដោយន័យជា ដើមថា "ឥមិនា ច វិតក្កេន ឥមិនា ច វិចារេន ឧបេតោ ហោតិ សមុបេតោ : ភិក្ខុជាអ្នកព្រមព្រៀង ។បេ ។ ប្រកបព្រមដោយវិតក្កៈ នេះផង ដោយវិចារៈនេះផង"[១] សូម្បីសេចក្តីក្នុងគម្ពីរវិភង្គនោះ ក៏គប្បី ឃើញយ៉ាងនេះឯង ។

ក្នុងបទថា វិវេកជំ នេះ មានវិនិច្ឆ័យដូច្នេះ ៖

សេចក្តីស្ងាត់ ឈ្មោះថា វិវេក ។

អធិប្បាយថា សេចក្តីប្រាសចាកនីវរណៈ ។ ម្យ៉ាងទៀត ធម៌

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៣៩៨/២៧៥ ។

ដែលស្ងាត់ចាកពីនីវរណៈ ឈ្មោះថា វិវេក ព្រោះអត្ថថា ស្ងាត់ហើយ, អធិប្បាយថា កងនៃធម៌ដែលសម្បយុត្តដោយឈាន ។ បីតិ និងសុខ កើតអំពីវិវេកនោះ ឬកើតក្នុងវិវេកនោះ ព្រោះហេតុនោះ ទើបឈ្មោះថា វិវេកជំ ។

## អត្ថាធិប្បាយអង្គឈាន គឺ បីតិ និងសុខ

ក្នុងបទថា បីតិសុខំ មានវិនិច្ឆ័យដូច្នេះ ៖

ធម្មជាតិដែលឈ្មោះថា បីតិ ព្រោះអត្ថថា ធ្វើឱ្យឆ្អែតស្កប់ស្កល់ ។ បីតិនោះ មានការឆ្អែត ជាលក្ខណៈ មានការធ្វើកាយនិងចិត្តឱ្យឆ្អែត ជាកិច្ច, ម្យ៉ាងទៀត មានសេចក្ដីផ្សាយទៅ ជាកិច្ច មានការរីកសាយចិត្ត ជាបច្ចុប្បដ្ឋាន ។ សេចក្ដីសប្បាយ ឈ្មោះថា សេចក្ដីសុខ ។ ម្យ៉ាងទៀត ធម្មជាតិដែលឈ្មោះថា សេចក្ដីសុខ ព្រោះអត្ថថា រមែងទំពាស៊ី និងជីកចេញដោយល្អ នូវអាពាធមកកាយនិងចិត្ត ។ សេចក្ដីសុខនោះ មានសេចក្ដីសប្បាយជាលក្ខណៈ មានការចូលទៅកពូននូវធម៌ដែលសម្បយុត្ត ដោយសេចក្ដីសុខនោះ ជាកិច្ច មានសេចក្ដីអនុគ្រោះជាគ្រឿងប្រាកដ ។

ក៏កាលការមិនប្រាសចាកគ្នានៃបីតិនិងសុខទាំងនោះ ក្នុងចិត្តុប្បាទខណៈ

ខ្វះ ។ មិនស្មើគ្នា សូម្បីមានបីតិ គឺ សេចក្តីត្រេកអរដោយការបាន ឥដ្ឋារម្មណ៍, សុខ គឺការសោយរសនៃអារម្មណ៍ដែលខ្លួនបានហើយ ។ បីតិមាននៅក្នុងចិត្តុប្បាទណា សុខក៏មាននៅក្នុងចិត្តុប្បាទនោះ ។ សុខមាន នៅក្នុងចិត្តុប្បាទណា, ក្នុងចិត្តុប្បាទនោះ មិនប្រាកដជាមានបីតិ ។ បីតិ លោកសង្គ្រោះចូលជាសង្ខារក្ខន្ធ, សុខ លោកសង្គ្រោះចូលជាវេទនាខន្ធ, បីតិ ប្រៀបដូចសេចក្តីឆ្អែតចិត្តរបស់បុគ្គលអ្នកនឿយហត់ក្នុងផ្លូវកន្តារ ព្រោះបានឃើញនិងបានស្តាប់ថា មានព្រៃឈើនិងមានទឹក, សុខ ប្រៀប ដូចសេចក្តីសប្បាយចិត្តរបស់បុគ្គលអ្នកនឿយហត់ក្នុងផ្លូវកន្តារ ព្រោះបាន ចូលទៅកាន់ម្លប់នៃព្រៃឈើនិងបានបរិភោគទឹក ដូច្នោះ ។ បណ្ឌិតគប្បី ជ្រាបសន្និដ្ឋានថា ក៏ពាក្យដែលអាចារ្យទាំងឡាយ ពោលទុកថា បីតិ គឺ សេចក្តីត្រេកអរដោយការបានឥដ្ឋារម្មណ៍ជាដើមនោះ ក៏ព្រោះមានបីតិ ប្រាកដនៅក្នុងសម័យនោះ ៗ ។ បីតិនេះផង សុខនេះផង មានប្រាកដ ដល់ឈាននោះ ឬមានប្រាកដក្នុងឈាននោះ ព្រោះហេតុនោះ ឈាននេះ ព្រះមានព្រះភាគ ទើបត្រាស់ថា **បីតិសុខំ** ។

ម្យ៉ាងទៀត បីតិផង សុខផង ឈ្មោះថា បីតិនិងសុខ ដូចធម៌និង វិន័យជាដើមដូច្នោះ ។ បីតិនិងសុខកើតពីវិវេក មានប្រាកដដល់ឈាន

នោះ ឬមានប្រាកដក្នុងឈាននោះ ព្រោះហេតុនោះ ទើបឈ្មោះថា បីតិនិងសុខ កើតពីវិវេក ដូចពណ៌នាមកដូច្នេះ ។ ដូចជាថា ឈានកើតពីវិវេកយ៉ាងណា, ក៏ក្នុងឈាននេះ បីតិនិងសុខ រមែងជារបស់កើតពីវិវេកដូចគ្នា យ៉ាងនោះ ។ មួយទៀត បីតិនិងសុខនោះ មានប្រាកដដល់ឈាននោះ ព្រោះហេតុដូច្នេះ[១] ឈាននោះ ទើបឈ្មោះថា បីតិនិងសុខ ព្រោះហេតុនោះ ទឹងពោលរួមដោយបទតែមួយរួមគ្នាថា វិវេកជបីតិសុខំ ដូច្នេះខ្លះ ក៏ប្រើបាន ។ តែក្នុងគម្ពីរវិភង្គ ព្រះមានព្រះភាគត្រាស់បីតិសុខនោះទុក ដោយន័យថា "ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ បីតិសុខន្តិ : សេចក្តីសុខនេះ ជាធម្មជាតិប្រព្រឹត្តទៅជាមួយ កើតជាមួយ ច្រឡំប្រែកបដោយបីតិនេះ ព្រោះហេតុនោះ ទើបពោលថា បីតិនិងសុខ"[២] ដូច្នេះ ។ ក៏សេចក្តីសួម្បីក្នុងគម្ពីរវិភង្គនោះ គប្បីឃើញដូចយ៉ាងនេះឯង ។

---

១. វិសុទ្ធិមគ្គ. ១/១៨៥. មិនមាន ឥតិ ។ (២) អភិ. វិភ. ឈានវិភង្គ. ៨១. ៤០០/២៧៦ ។

## ឈាន រមែងកម្ចាត់ធម៌ដែលជាសត្រូវ

បទថា បឋមំ គឺ ជាទីមួយ ព្រោះជាលំដាប់នៃការគណនា ។

ឈាននេះ ឈ្មោះថា ទីមួយ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចជាគ្រាដំបូង ។

គុណធម៌ ឈ្មោះថា ឈាន ព្រោះអត្ថថា កំចាត់ធម៌ដែលជាសត្រូវ (មាននីវរណៈជាដើម) ។ ព្រះយោគីទាំងឡាយ រមែងកំចាត់ (ធម៌ដែលជាសត្រូវមាននីវរណៈជាដើមនោះ) ដោយឈាននេះ សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា ឈាន ។ អធិប្បាយថា ព្រះយោគីទាំងឡាយ រមែងដុតធម៌ដែលជាសត្រូវ ឬ រមែងគិតដល់គោចរ (គឺអារម្មណ៍សម្រាប់គោងមានកសិណជាដើម) ។ ម្យ៉ាងទៀត ឈ្មោះថា ឈាន ព្រោះអត្ថថា សម្លឹង គឺ ចូលទៅសម្លឹងអារម្មណ៍នោះដោយខ្លួនឯង ព្រោះហេតុនោះឯង ឈាននោះ ទើបលោកហៅថា មានការចូលទៅសម្លឹងជាលក្ខណៈ ។

## ឈានមាន ២ ន័យ

ឈាននោះ មាន ២ យ៉ាង គឺ អារម្មណូបនិជ្ឈាន (ចូលទៅសម្លឹងអារម្មណ៍) លក្ខណូបនិជ្ឈាន (ចូលទៅសម្លឹងលក្ខណៈ) ។ បណ្ដាឈានទាំង ២ នោះ សមាបត្តិ ៨ ព្រមដោយឧបចារៈ លោកហៅថា អារម្មណូបនិជ្ឈាន ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះចូលទៅសម្លឹងអារម្មណ៍គឺ កសិណ ។

វិបស្សនាមគ្គនិងផល លោកហៅថា លក្ខណូបនិជ្ឈាន ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះចូលទៅសម្លឹងលក្ខណៈ ។

ពិតមែន បណ្ដាវិបស្សនាមគ្គនិងផលទាំងនេះ វិបស្សនា រមែងចូលទៅសម្លឹងត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ ក៏កិច្ចគឺ ការចូលទៅសម្លឹង ដោយវិបស្សនា រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ មគ្គលោកហៅថា លក្ខណូបនិជ្ឈាន ។ ចំណែកផល លោកក៏ហៅថា លក្ខណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្លឹងលក្ខណៈដែលពិតនៃនិរោធ ។ តែក្នុងអត្ថនេះ លោកប្រាថ្នាយកអារម្មណូបនិជ្ឈានប៉ុណ្ណោះថា ឈាន ។

ក្នុងអធិការពោលអំពីឈាននេះ អាចារ្យអ្នកចោទជំទាស់ថា ឈ្មោះថា ឈាន ដែលគួរនឹងគប្បីអាងដល់យ៉ាងនេះថា ប្រព្រឹត្តទៅព្រមដោយ

វិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។ល។ មានបីតិនិងសុខ ដូច្នេះ នោះដូចម្ដេចហ្ន៎ ?

ខ្ញុំព្រះករុណា នឹងពោលឆ្លើយតទៅ ៖

ប្រៀបដូចបុរសដទៃវៀរទ្រព្យ និងជនជាបរិវារចេញ រមែងជាអ្នកមិនសមគួរភាវៈដែលនឹងគប្បីអាងដល់ ក្នុងប្រយោគជាដើមថា អ្នកមានទ្រព្យ អ្នកមានបរិជន យ៉ាងណា ឈានដទៃ វៀរធម៌មានវិតក្កៈជាដើមចេញ គួរនឹងគប្បីអាងដល់ គឺរមែងមិនមាន យ៉ាងនោះ ។ ដូចគ្នានឹងការសន្មតថា សេនា ក្នុងអង្គសេនាទាំងឡាយ ដែលគេពោលថា សេនាមានពលរថ មានពលថ្មើរជើង ដូច្នេះនុ៎ះឯង បណ្ឌិតគួរជ្រាបយ៉ាងណា ក្នុងអធិការនេះ ក៏គួរជ្រាបការសន្មតថា ឈាន ក្នុងអង្គ ៥ នោះឯង ដូច្នោះ ។ គួរជ្រាបក្នុងអង្គ ៥ ពួកណា ? ក្នុងអង្គ ៥ ទាំងនេះ គឺ វិតក្កៈ សេចក្ដីត្រិះរិះ វិចារៈ សេចក្ដីពិចារណា បីតិ សេចក្ដីឆ្អែតចិត្ត សុខ សេចក្ដីសប្បាយចិត្ត ចិត្តេកគ្គតា សេចក្ដីដែលចិត្តមានអារម្មណ៍តែមួយ ។ ពិតមែន អង្គ ៥ ទាំងនេះឯង ព្រះមានព្រះភាគត្រាស់ទុកដោយភាពជាអង្គនៃឈាននោះ ដោយន័យជាដើមថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។

ប្រសិនបើអាចារ្យអ្នកចោទគប្បីតវ៉ាថា ឯកគ្គតា ចាត់ជាអង្គ (នៃ

ឈាន ) មិនបាន ព្រោះព្រះមានព្រះភាគមិនបានត្រាស់ទុក ( ក្នុងបាលីនៃឈាន ) មិនមែនឬ ?

ឆ្លើយថា ក៏ពាក្យដែលលោកពោលនោះ រមែងមិនត្រូវ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះចិត្តេកគ្គតាសម្បយុត្តនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងបាលីនៃឈានទាំងឡាយ ។

ពិតមែន ចិត្តេកគ្គតាសម្បយុត្តនោះ ព្រះមានព្រះភាគត្រាស់ទុកពិតប្រាកដក្នុងគម្ពីរវិភង្គយ៉ាងនេះថា "ឈានន្តិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា : ត្រង់ពាក្យថា ឈាន គឺ វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតា នៃចិត្ត"[១] ។ ព្រោះដូច្នោះ ពាក្យដែលលោកពោលទុកថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ដូច្នេះ យ៉ាងណា សម្បយុត្តកាលព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងអធិការនេះថា សចិត្តេកគ្គតា សម្បយុត្តចិត្តេកគ្គតា ក៏គួរជ្រាបថា ជាអង្គ ( នៃឈាន ) តែម្តង តាមព្រះបាលីក្នុងគម្ពីរវិភង្គនេះ ដូច្នោះ ។ ពិតមែន ឧទ្ទេស ព្រះមានព្រះភាគទ្រង់ធ្វើទុកហើយដោយព្រះបំណងណា ឧទ្ទេសនោះឯង ក៏ព្រះអង្គទ្រង់ប្រកាសទុកហើយ សម្បយុត្តក្នុងគម្ពីរវិភង្គ ដោយព្រះបំណងនោះឯង ។

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤០២/២៧៦ ។

# អត្ថន័យនៃឧបសម្បជ្ជស័ព្ទ

បទថា ឧបសម្បជ្ជ : ចូលដល់ គឺ ចូលទៅជិតហើយ ។ លោកអធិប្បាយថា សម្រេចហើយ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ឱ្យចូលដល់ព្រមហើយ គឺ ឱ្យសម្រេចហើយ ។ តែក្នុងគម្ពីរវិភង្គ ព្រះមានព្រះភាគត្រាស់ទុកថា "ឧបសម្បជ្ជាតិ យោ បឋមស្ស ឈានស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា : ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឱ្យជាក់ច្បាស់ ការបំពេញនូវបឋមជ្ឈាន"[១] ។ សេចក្ដីនៃពាក្យសូម្បីនោះ ក៏គប្បីជ្រាបដូចយ៉ាងនោះឯង ។

បទថា វិហាសិ សេចក្ដីថា តថាគត ជាអ្នកប្រកបព្រមដោយឈានមានប្រការដូចពោលហើយយ៉ាងនេះ ទើបញុំាងការបន្តជាប់គ្នា ការប្រព្រឹត្ត ការរក្សា ការប្រព្រឹត្តទៅ ការឱ្យប្រព្រឹត្តទៅ ការត្រាច់ទៅ ការសម្រាកនៃអត្តភាពឱ្យសម្រេច ដោយឥរិយាបថវិហារ ពោលគឺ ការអង្គុយនៅក្នុងពោធិមណ្ឌល ។ សេចក្ដីនេះ សមពិតដូចដែលព្រះអង្គត្រាស់ទុកក្នុងគម្ពីរវិភង្គថា "វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ : ត្រង់

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤០៣/២៧៦ ។

ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាង អត្តភាពឱ្យប្រព្រឹត្តទៅ ត្រាច់ទៅ ព្រោះហេតុនោះ ទើបពោលថា សម្រេច ឥរិយាបថ"[១] ។

សួរថា ក៏ព្រះមានព្រះភាគ ទ្រង់ធ្វើអ្វី ទើបទ្រង់ចូលឈាននេះ ? ឆ្លើយថា ទ្រង់ចម្រើនកម្មដ្ឋាន ។ សួរថា ទ្រង់ចម្រើនកម្មដ្ឋានអ្វី ? ឆ្លើយថា ទ្រង់ចម្រើនអានាបានស្សតិកម្មដ្ឋាន ។ សួរថា អ្នកដទៃ អ្នកមានសេចក្ដីត្រូវការអានាបានស្សតិកម្មដ្ឋាននោះគួរធ្វើយ៉ាងណា ? ឆ្លើយថា សូម្បីអ្នកដទៃ ក៏គួរចម្រើនកម្មដ្ឋាននោះ ឬបណ្ដាកម្មដ្ឋានទាំងឡាយមានបឋវីកសិណជាដើម យ៉ាងណាមួយ ។

ន័យនៃការចម្រើនអានាបានស្សតិកម្មដ្ឋានជាដើមទាំងនោះ គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។ ក៏កាលខ្ញុំព្រះករុណានឹងពោលន័យនៃការចម្រើន ទុកក្នុងអធិការនេះ និទាននៃព្រះវិន័យក៏នឹងជាភារៈធ្ងន់ក្រៃលែង ។ ព្រោះដូច្នោះ ខ្ញុំព្រះករុណា នឹងធ្វើត្រឹមតែការប្រកាសសេចក្ដីនៃព្រះបាលីប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

បឋមជ្ឈានកថា ចប់ ។

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៣៧៣/២៦៥ ។

## ទុតិយជ្ឈានកថា

ពីរបទថា វិតក្កវិចារានំ វូបសមា : ចូលទៅជិតរម្ងាប់ វិតក្កៈ វិចារៈ សេចក្ដីថា ព្រោះចូលទៅស្ងប់ គឺ ព្រោះឈានកន្លងអង្គទាំង ២ ទាំងនេះ គឺ វិតក្កៈនិងវិចារៈ ។ មានអធិប្បាយថា ព្រោះវិតក្កៈវិចារៈមិនប្រាកដក្នុងខណៈនៃទុតិយជ្ឈាន ។

គប្បីជ្រាបសន្និដ្ឋានថា ក្នុងបណ្ដាឈានទាំង ២ នោះ ធម៌ក្នុងបឋមជ្ឈានទាំងអស់ មិនមាននៅក្នុងទុតិយជ្ឈាន ដោយថា ធម៌ទាំងឡាយមានផស្សៈជាដើម មាននៅក្នុងបឋមជ្ឈានតែមួយ ក្នុងទុតិយជ្ឈាននេះ ក៏តែមួយទៀត ក៏ពិតមែនហើយ តែថា ព្រះមានព្រះភាគក៏ត្រាស់យ៉ាងនេះថា ព្រោះចូលទៅស្ងប់វិតក្កៈ វិចារៈ ដើម្បីនឹងទ្រង់សម្ដែងថា ការសម្រេចឈានដទៃក្រៅពីបឋមជ្ឈាន មានទុតិយជ្ឈានជាដើម នឹងមានបានព្រោះឈានកន្លងអង្គដែលគ្រោតគ្រោតបាន ។

## អត្ថាធិប្បាយអជ្ឈត្តសំព្ទ

ក្នុងអធិការនេះ បណ្ឌិតប្រាថ្នាយក និយកជ្ឈត្តំ ឈ្មោះថា អជ្ឈត្តំ ។ តែក្នុងគម្ពីរវិភង្គ ព្រះមានព្រះភាគត្រាស់ទុកត្រឹមតែប៉ុណ្ណោះថា

"អជ្ឈត្តំ បច្ចត្តំ ជាក់ច្បាស់ខាងក្នុងសន្ដាន"[១] ប៉ុណ្ណោះ ។ ក៏ព្រោះបណ្ឌិតប្រាថ្នាយកនិយកជ្ឈត្តំ ឈ្មោះថា អជ្ឈត្តំ ដូច្នោះ ក្នុងបទថា អជ្ឈត្តំ នេះ បណ្ឌិតគប្បីឃើញសេចក្ដីដូច្នេះថា កើតហើយក្នុងខ្លួន គឺកើតហើយក្នុងសន្ដានរបស់ខ្លួន ។

## អត្ថាធិប្បាយ សម្បសាទនសព្ទ

សទ្ធា (សេចក្ដីជឿ) ព្រះមានព្រះភាគត្រាស់ហៅថា សម្បសាទនៈ ក្នុងបទថា សម្បសាទនំ នេះ សូម្បីឈាន ក៏ត្រាស់ហៅថា សម្បសាទនៈ ព្រោះប្រកបដោយសេចក្ដីថ្លាផូរផង់ ដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ដូច្នោះ ។ ម្យ៉ាងទៀត ព្រោះឈាននោះរមែងញ៉ាំងចិត្តឱ្យជ្រះថ្លាដោយល្អ ព្រោះប្រកបដោយសទ្ធា ដែលជាគ្រឿងញ៉ាំងចិត្តឱ្យថ្លាផូរផង់ (និង) ព្រោះស្ងប់រម្ងាប់សេចក្ដីកម្រើកនៃវិតក្កៈនិងវិចារៈចេញបាន ព្រោះហេតុសូម្បីនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សម្បសាទនំ ។ ក៏ក្នុងអត្ថវិកប្បនេះ គប្បីជ្រាបសម្ពន្ធចំពោះបទយ៉ាងនេះថា សម្បសាទនំ ចេតសោ (ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុងចិត្ត) ។ តែក្នុងអត្ថវិកប្បដើម គប្បីប្រកបបទថា ចេតសោ នោះចូលនឹង ឯកោទិភាវៈ ។

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤០៦/២៧៧ ។

# អត្ថាធិប្បាយ ឯកោទិភាវសព្ទ

ក្នុងបទថា **ឯកោទិភាវំ** នោះ មានអត្ថយោជនាដូចតទៅនេះ ៖

សមាធិ ឈ្មោះថា ឯកោទិ ព្រោះអត្ថថា ជាធម៌ឯកផើបឡើង ។ អធិប្បាយថា ឈ្មោះថា ជាធម៌ដ៏ប្រសើរ គឺ ធម៌ប្រសើរបំផុត ផើបឡើង ព្រោះវិតក្កៈ វិចារៈមិនផើបឡើង ។ ពិតមែន សូម្បីអ្នកដែលប្រសើរបំផុត គេក៏ហៅថា ជាឯក ក្នុងលោក ។ម្យ៉ាងទៀត ទឹងពោលថា សមាធិដែលវៀរចាកវិតក្កៈ និងវិចារៈ ឈ្មោះថា ជាធម៌ឯក គឺ មិនមានសម្លាញ់ ដូច្នេះខ្លះ ក៏គួរ បរិយាយមួយទៀត សមាធិ ឈ្មោះថា ឧទិ ព្រោះអត្ថថា រមែងញ៉ាំងសម្បយុត្តធម៌ឱ្យផើបឡើង អធិប្បាយថា ឱ្យតាំងឡើង ។ សមាធិនោះ ជាឯក ព្រោះអត្ថថា ប្រសើរនិងផើបឡើង ព្រោះហេតុនោះ ទើបឈ្មោះថា ឯកោទិ ។ ពាក្យថា ឯកោទិ នោះ ជាឈ្មោះរបស់សមាធិ ។ ទុតិយជ្ឈាន រមែងញ៉ាំងសមាធិដែលឈ្មោះថា **ឯកោទិ** នេះ ដូចពោលនេះឱ្យកើត គឺ ឱ្យចម្រើន ។ ហេតុនោះ ទុតិយជ្ឈាននេះ ទើបឈ្មោះថា **ឯកោទិភាវ** ។ ក៏ព្រោះសមាធិដែលឈ្មោះថា **ឯកោទិ** នោះ រមែងមានដល់ចិត្ត មិនមានដល់សត្វ ដល់ជីវៈទេ ដូច្នោះ ទុតិយជ្ឈាននោះ ទើបព្រះមានព្រះភាគត្រាស់ថា ចេតសោ **ឯកោទិភាវំ**

មានសភាពជាចិត្តខ្ពស់ឯក ។

មានពាក្យសួរថា ក៏សទ្ធានេះ និងសមាធិដែលមានឈ្មោះថាឯកោទិនេះមាននៅក្នុងបឋមជ្ឈានមិនមែនឬ ? កាលជាដូច្នោះ ព្រោះហេតុអ្វី ទុតិយជ្ឈាននេះប៉ុណ្ណោះ ទើបព្រះមានព្រះភាគត្រាស់ថា "សម្បសាទនំ ចេតសោ ឯកោទិភាវំ ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុងមានសភាពជាចិត្តខ្ពស់ឯក" ។

ខ្ញុំព្រះករុណាទឹងពោលឆ្លើយតទៅ ៖

ដោយថា បឋមជ្ឈានឯណោះ ឈ្មោះថា មិនទាន់ថ្លាផូរផង់ល្អ ព្រោះវិតក្កៈនិងវិចារៈនៅកម្រើកបាន ដូចទឹកដែលល្អក់កករព្រោះរលកផ្កាត្រែង និងរលកតូច ៗ ដូច្នោះ ព្រោះហេតុនោះ សូម្បីកាលសទ្ធាមាននៅក៏គប្បីជ្រាបថា បឋមជ្ឈាននោះ ព្រះមានព្រះភាគមិនបានត្រាស់ថា ជាគ្រឿងញ៉ាំងចិត្តឱ្យថ្លាផូរផង់ ។ មួយទៀត ព្រោះសេចក្ដីដែលបឋមជ្ឈានមិនទាន់ថ្លាផូរផង់ដោយល្អនុ៎ះឯង សូម្បីសមាធិក្នុងបឋមជ្ឈាននេះ ក៏មិនជាធម៌ប្រាកដដោយល្អទេ ព្រោះដូច្នោះ គប្បីជ្រាបថា បឋមជ្ឈាននោះព្រះមានព្រះភាគ មិនបានត្រាស់ថា ជាឯកោទិភាពខ្លះ ។ ចំណែកសទ្ធាមានកម្លាំង បានឱកាសហើយ ព្រោះក្នុងឈាននេះមិនមានហេតុគ្រឿងកង្វល់ គឺ វិតក្កៈ វិចារៈ សូម្បីសមាធិក៏ប្រាកដ ព្រោះត្រឡប់បានសម្លាញ់ គឺ

សទ្ធាមានកម្លាំង ព្រោះដូច្នោះ គប្បីជ្រាបថា ទុតិយជ្ឈានរនេះប៉ុណ្ណោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកយ៉ាងនេះ ។ តែក្នុងគម្ពីរវិភង្គ ព្រះមានព្រះភាគ ត្រាស់ទុកត្រឹមតែប៉ុណ្ណោះទុំះឯងថា "សម្បសាទនំ យា សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ : ពាក្យថា ជ្រះថ្លាស៊ប់ គឺ សទ្ធា អាការជឿ អាការចុះចិត្តស៊ប់ សេចក្តីជ្រះថ្លាក្រៃលែង ។ ចេតសោ ឯកោទិភាវន្តិ យា ចិត្តស្ស ឋិតិ ។បេ ។* សម្មាសមាធិ : ត្រង់ពាក្យថា មានភាពជាចិត្តខ្ពស់ឯក បានដល់ ការឋិតនៅនៃចិត្ត ។ បេ ។* សម្មាសមាធិ"[១] ដូច្នេះ ។ ក៏អត្ថវណ្ណនានេះរួមជាមួយបាលីក្នុងគម្ពីរវិភង្គនោះ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនោះ រមែងមិនខុស គឺ រមែងប្រៀបធៀប និងស្មើគ្នាបានដោយពិត យ៉ាងណា បណ្ឌិតគប្បីជ្រាបអត្ថវណ្ណនានេះ ដូច្នោះ ។

---

១. អភិ. វិភ. ឥន្ទ្រិយវិភង្គ ៨០. ២៤០/២៥០; * ខុទ្. ចូឡ. ខគ្គវិសាណសុត្តនិទ្ទេស. ៦៨. ៣៥៨/៣៥៦ ថា : សមថោតិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ : ពាក្យថា សមថៈ បានដល់ ការតាំងនៅ ការតាំងនៅព្រម ការតាំងនៅខ្ជាប់ ការមិនរសេមរសាម ការមិនរាយមាយ ការមិនអណ្តែតអណ្តូង នៃចិត្ត សមថៈ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ។

## អត្ថាធិប្បាយទុតិយជ្ឈានមិនមានវិតក្កៈនិងវិចារៈ

ក្នុងពាក្យថា អវិតក្កំ អវិចារំ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ទុតិយជ្ឈានឈ្មោះថា មិនមានវិតក្កៈ ព្រោះអត្ថថា វិតក្កៈមិនមានក្នុងទុតិយជ្ឈាននេះ ឬដល់ទុតិយជ្ឈាននេះ ព្រោះលះវិតក្កៈបានដោយភាវនា ។ ទុតិយជ្ឈាន ឈ្មោះថា មិនមានវិចារៈក៏ដោយន័យនេះឯង ។ សូម្បីក្នុងគម្ពីរវិភង្គ ព្រះមានព្រះភាគក៏ត្រាស់ទុកហើយថា "ឥតិ អយញ្ច វិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ អវិតក្កំ អវិចារន្តិ ៈ វិតក្កៈនេះផង វិចារៈនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឱ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា មិនមានវិតក្កៈ មិនមានវិចារៈ ដោយប្រការដូច្នេះ"[១] ។

ក្នុងអធិការនេះ អាចារ្យដែលជំទាស់ថា ក៏សេចក្ដីនេះ សម្រេចហើយសូម្បីដោយបទថា ព្រោះស្ងប់រម្ងាប់វិតក្កៈ និងវិចារៈ ដូច្នេះមិនមែនឬ ? កាលជាដូច្នោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់ទុកទៀតថា មិនមានវិតក្កៈ មិនមានវិចារៈដូច្នេះហ្ន៎ ?

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤០៥/២៧៧ ។

ខ្ញុំព្រះករុណានឹងពោលឆ្លើយតទៅ ៖

សេចក្ដីនេះសម្រេចហើយយ៉ាងនោះ ពិតមែន តែពាក្យថា ព្រោះរម្ងាប់វិតក្កៈ និងវិចារៈនេះ សម្ដែងអត្ថ ពោលគឺ ការមិនមានវិតក្កៈវិចារៈនោះ ។ ខ្ញុំព្រះករុណាបានពោលហើយមិនមែនឬថា តែព្រះមានព្រះភាគ ក៏ត្រាស់ទុកយ៉ាងនេះថា "ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ" ដើម្បីនឹងទ្រង់សម្ដែងថា ការសម្រេចឈានជាដើមដទៃក្រៅពីបឋមជ្ឈាន រមែងមាន ព្រោះឈានកន្លងអង្គដែលគ្រោតគ្រាតបាន ម្យ៉ាងទៀត ទុតិយជ្ឈាននេះ ឈ្មោះថា **សម្បសាទនៈ** ព្រោះស្ងប់វិតក្កៈនិងវិចារៈចេញបាន មិនមែនព្រោះចូលទៅស្ងប់នូវការកម្រើកឡើងនៃទោស ពោលគឺ កិលេសទេ និងទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាព** ព្រោះស្ងប់វិតក្កៈនិងវិចារៈ និងទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាព** ព្រោះលះនីវរណៈចេញបាន មិនដូចឧបចារៈឈាន និងទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាព** ព្រោះមានអង្គប្រាកដ មិនដូចបឋមជ្ឈាន ។

ព្រោះហេតុនោះ ពាក្យថា **ព្រោះរម្ងាប់វិតក្កៈវិចារៈ** នេះ រមែងជាពាក្យសម្ដែងដល់ហេតុនៃទុតិយជ្ឈាន ដែលជាគ្រឿងញ៉ាំងចិត្តឱ្យថ្លាផូរផង់ និង ជាធម៌ឯកញ៉ាំងសមាធិឱ្យរើបឡើង ដូចពោលមកហើយនេះ ។ មួយទៀត ទុតិយជ្ឈាននេះ ឈ្មោះថា មិនមានវិតក្កៈមិនមានវិចារៈព្រោះស្ងប់វិតក្កៈនិងវិចារៈ ចេញបាន, ទុតិយជ្ឈាននេះ ឈ្មោះថា អវិតក្កវិចារៈ

ព្រោះមិនមានទាំងវិតក្កៈ និងវិចារៈ មិនដូចតតិយជ្ឈានចតុត្ថជ្ឈាន និងដូចវិញ្ញាណមានចក្ខុវិញ្ញាណជាដើមដូច្នោះទេ ព្រោះហេតុនោះ ពាក្យថា ព្រោះស្ងប់វិតក្កៈវិចារៈនេះ ជាពាក្យសម្តែងដល់ហេតុនៃសេចក្តីដែលទុតិយជ្ឈានមិនមានទាំងវិតក្កៈ មិនមានទាំងវិចារៈ និងមិនមែនជាពាក្យសម្តែងត្រឹមតែការមិនមាននៃវិតក្កៈនិងវិចារៈទេ ដូចពោលមកដូច្នេះ ។ តែពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈនេះ ក៏ជាពាក្យសម្តែងត្រឹមតែការមិនមាននៃវិតក្កៈនិងវិចារៈប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ សូម្បីត្រាស់ពាក្យដើមហើយ ក៏គួរត្រាស់ ពាក្យចុងក្រោយទៀត ។

បទថា **សមាធិជំ : កើតអំពីសមាធិ** សេចក្តីថា កើតអំពីបឋមជ្ឈានសមាធិ ឬអំពីសមាធិដែលសម្បយុត្តគ្នា ។ ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគត្រាស់ទុតិយជ្ឈាននេះប៉ុណ្ណោះថា កើតអំពីសមាធិ ដើម្បីសរសើរទុតិយជ្ឈាននេះ ព្រោះដល់សូម្បីបឋមជ្ឈាន នឹងកើតអំពីសមាធិដែលសម្បយុត្ត ក៏ពិតមែនហើយ, តែថា សមាធិនេះប៉ុណ្ណោះ គួរហៅបានថា សមាធិ ព្រោះជាសមាធិដែលមិនញាប់ញ័រ និងថ្លាផូរផង់យ៉ាងក្រៃលែង ព្រោះវៀរចាកការកម្រើកនៃវិតក្កៈវិចារៈ ។

ពាក្យថា **បីតិសុខំ** នេះ មានន័យដូចពោលមកហើយទុំះឯង ។

បទថា **ទុតិយំ** គឺ ជាទី ២ ដោយលំដាប់នៃការគណនា ។

ឈាននេះឈ្មោះថា ទី ២ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចជាលើកទី ២ ដូច្នេះខ្លះ ។

## បឋមជ្ឈានមានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៣

ក៏ក្នុងពាក្យថា ឈានំ នេះ គប្បីជ្រាបថា បឋមជ្ឈានមានអង្គ៥ ព្រោះអង្គទាំងឡាយមានវិតក្កៈជាដើម យ៉ាងណា, ទុតិយជ្ឈាននេះ ក៏មានអង្គ ៤ ព្រោះអង្គទាំងឡាយ មានសម្បសាទៈជាដើម យ៉ាងនោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ឈានន្តិ សម្បសាទោ បីតិ សុខំ ចិត្តស្សេកគ្គតា : ត្រង់ពាក្យថា ឈាន គឺ សេចក្ដីថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត"[១] យ៉ាងនោះជាន័យដោយអមប៉ុណ្ណោះ ។ តែដោយន័យត្រង់ទុតិយជ្ឈាននោះ វៀរអង្គគឺ សម្បសាទៈចេញហើយ មានត្រឹមតែអង្គ ៣ ប៉ុណ្ណោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ ។ បីតិ សុខំ ចិត្តស្សេកគ្គតា : ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន"[២] ពាក្យដែលសល់មានន័យដូចពោលហើយនោះឯង ។

ទុតិយជ្ឈានកថា ចប់

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤១២/២៧៩ ។ ២. អភិ. វិភ. ឈានវិភង្គ. ៨១. ៤៥៨/២៩២; វិសុទ្ធិ : មានពាក្យថា : កតមំ តើដូចម្ដេច ។

# តតិយជ្ឈានកថា

បីតិក្នុងពាក្យថា បីតិយា ច វិរាគា នេះ មានសេចក្ដីដូចពោលហើយខ្ពុំះឯង ។ សេចក្ដីស្អប់ខ្ពើម ឬសេចក្ដីឈានកន្លងបីតិនោះ ឈ្មោះថា វិរាគៈ (សេចក្ដីបន្ទោបង់) ។ ច សព្ទ ក្នុងចន្លោះបទទាំង២ មានការប្រមូលមកជាអត្ថ ។ ច សព្ទ ប្រមូលមកនូវសេចក្ដីស្ងប់ ឬសេចក្ដីចូលទៅស្ងប់វិតក្កៈ វិចារៈ ។ គប្បីជ្រាបយោជនាយ៉ាងនេះថា ក្នុងការប្រមូលទាំងពីរយ៉ាងនោះ ក្នុងកាលណាប្រមូលសេចក្ដីស្ងប់មកតែម្យ៉ាង ក្នុងវេលានោះ ព្រោះបន្ទោបង់បីតិ និងព្រោះស្ងប់បានទៀតបន្តិចបន្តួច ។ ក៏ក្នុងយោជនានេះ វិរាគៈ សព្ទ មានការខ្ពើមជាអត្ថ ព្រោះដូច្នោះ គប្បីឃើញសេចក្ដីដូច្នេះថា ព្រោះស្អប់ខ្ពើម និងព្រោះរម្ងាប់បីតិ ។

គប្បីជ្រាបយោជនាយ៉ាងនេះថា ក៏ក្នុងវេលាណា ប្រមូលសេចក្ដីស្ងប់រម្ងាប់វិតក្កៈ វិចារៈមក ក្នុងវេលានោះ ព្រោះប្រាសចាកបីតិ និងព្រោះចូលទៅស្ងប់វិតក្កៈ វិចារៈ ការខ្ពើមរមែងមានឡើងខ្លះទៀត ។ និងក្នុងយោជនានេះ វិរាគៈ សព្ទ មានសេចក្ដីឈានកន្លងជាអត្ថ ព្រោះដូច្នោះ គប្បីឃើញសេចក្ដីដូច្នេះថា ព្រោះឈានកន្លងបីតិ និងព្រោះស្ងប់រម្ងាប់វិតក្កៈ វិចារៈ ។

មួយទៀត វិតក្កៈ វិចារៈទាំងនេះ ស្ងប់ហើយក្នុងទុតិយជ្ឈានតែម្ដងក៏ពិត, តែថា ពាក្យថា ព្រោះចូលទៅស្ងប់វិតក្កៈ វិចារៈនេះ ព្រះមានព្រះភាគត្រាស់ទុកហើយ ក៏ដើម្បីនឹងទ្រង់សម្ដែងឧបាយគ្រឿងសម្រេចឈាននេះ និងដើម្បីពោលសរសើរ (ឈាននេះ) ។

សួរថា ពិតមែន កាលព្រះអង្គត្រាស់ថា និងព្រោះសេចក្ដីស្ងប់រម្ងាប់វិតក្កៈ វិចារៈ ពាក្យនេះ រមែងប្រាកដថា សេចក្ដីស្ងប់រម្ងាប់វិតក្កៈ វិចារៈ ក៏ជាឧបាយគ្រឿងសម្រេចឈាននេះ មិនមែនឬ ?

ឆ្លើយថា ដូចយ៉ាងថា ក្នុងអរិយមគ្គទី ៣ លោកពោលការលះទុកយ៉ាងនេះថា ព្រោះលះឱរម្ភាគិយសញ្ញោជនៈទាំង ២ មានសក្កាយទិដ្ឋិជាដើម សូម្បីដែលលះមិនទាន់បាន រមែងជាការពោលសរសើរ (អរិយមគ្គទី ៣) ដើម្បីនឹងឱ្យកើតសេចក្ដីឧស្សាហ៍ ដល់ពួកជនអ្នកមានសេចក្ដីខ្វល់ខ្វាយ ដើម្បីសម្រេចអរិយមគ្គទី ៣ នោះ យ៉ាងណា, ក្នុងតតិយជ្ឈាននេះ លោកពោលសេចក្ដីស្ងប់រម្ងាប់វិតក្កៈវិចារៈ សូម្បីដែលនៅមិនស្ងប់អស់ ជាការពោលសរសើរ (ឈាននេះ) ដូច្នោះដូចគ្នា ។ ព្រោះហេតុនោះ ទើបលោកពោលសេចក្ដីនេះទុកថា ព្រោះឈានកន្លងបីតិ និងព្រោះសេចក្ដីស្ងប់រម្ងាប់វិតក្កៈវិចារៈ ដូច្នេះ ។

ក្នុងពាក្យថា ឧបេក្ខកោ ច វិហាសិ : ជាបុគ្គលព្រងើយនៅហើយ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ធម្មជាតិដែលឈ្មោះថា ឧបេក្ខា ព្រោះអត្ថថា សម្លឹងដោយការកើតឡើង ។ អធិប្បាយថា រមែងឃើញស្មើ គឺ រមែងឃើញមិនធ្លាក់ទៅជាពួក ជាក្រុម ។ បុគ្គលអ្នកប្រកបព្រមដោយតតិយជ្ឈាន លោកហៅថា អ្នកមានឧបេក្ខា ។ ព្រោះភាពជាអ្នកប្រកបដោយឧបេក្ខានោះដែលពីរោះរណ្តំបរិបូណ, មានកម្លាំង ។

## ឧបេក្ខា ១០ យ៉ាង

ក៏ឧបេក្ខាមាន ១០ យ៉ាង គឺ

១. ឆឡង្គុបេក្ខា ឧបេក្ខាក្នុងអង្គ (គឺ អារម្មណ៍) ៦ ។
២. ព្រហ្មវិហារុបេក្ខា ឧបេក្ខាក្នុងព្រហ្មវិហារ ។
៣. ពោជ្ឈង្គុបេក្ខា ឧបេក្ខាក្នុងពោជ្ឈង្គ ។
៤. វីរិយុបេក្ខា ឧបេក្ខាក្នុងវីរិយៈ ។
៥. សង្ខារុបេក្ខា ឧបេក្ខាក្នុងសង្ខារ ។
៦. វេទនុបេក្ខា ឧបេក្ខាក្នុងវេទនា ។
៧. វិបស្សនុបេក្ខា ឧបេក្ខាក្នុងវិបស្សនា ។

៨. **តត្រមជ្ឈត្តុបេក្ខា** ឧបេក្ខាក្នុងការតម្កល់ខ្លួនជាកណ្ដាលក្នុងធម៌នោះ ៗ ។

៩. **ឈានុបេក្ខា** ឧបេក្ខាក្នុងឈាន ។

១០. **បារិសុទ្ធុបេក្ខា** ឧបេក្ខាក្នុងសេចក្ដីបរិសុទ្ធិ ។

ឧបេក្ខាសូម្បីទាំង ១០ យ៉ាង ដូចពោលមកនេះ គប្បីជ្រាបតាមន័យដែលលោកពោលទុកហើយ ក្នុងវណ្ណនានៃភយភេរវសូត្រ ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ឬក្នុងអដ្ឋកថា ធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី ដោយន័យដែលមកហើយក្នុងទីនោះ ៗ និងដោយអំណាចនៃសង្ខេប គឺ ភូមិ បុគ្គល ចិត្ត អារម្មណ៍ ខន្ធសង្គហៈ ឯកខណចិត្តនិងកុសលតិកៈ ។ ក៏ឧបេក្ខា កាលខ្ញុំព្រះករុណានឹងពោលទុកក្នុងអធិការនេះ រមែងធ្វើនិទាននៃព្រះវិន័យឱ្យជាភារៈធ្ងន់ក្រៃលែង, ព្រោះហេតុនោះទើបខ្ញុំព្រះករុណាមិនពោល ។

## អត្ថាធិប្បាយលក្ខណៈនៃឧបេក្ខា

ចំណែកឧបេក្ខា ដែលប្រាថ្នាយកក្នុងអធិការនេះ ដោយលក្ខណៈជាដើម គប្បីជ្រាបថា មានសេចក្ដីមធ្យ័ត (ភាពជាកណ្ដាល) ជាលក្ខណៈ មានការមិនទីកដល់ ជាកិច្ច មានការមិនខ្វល់ខ្វាយជាបច្ចុប្បដ្ឋាន មាន

សេចក្តីបន្ទោបង់បីតិជាបទដ្ឋាន ។

ក្នុងអធិការពោលអំពីតតិយជ្ឈាននេះ អាចារ្យអ្នកតវ៉ា ជំទាស់ថា ក៏ឈានុបេក្ខានេះ ដោយអត្ថក៏គឺ តត្រមជ្ឈត្តុបេក្ខានុ៎ះឯង និងឈានុបេក្ខានោះ ក៏មាននៅសូម្បីក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន ព្រោះដូច្នោះ ឈានុបេក្ខានេះ ព្រះមានព្រះភាគ ក៏គួរនឹងត្រាស់ទុកសូម្បីក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ យ៉ាងនេះថា ឧបេក្ខកោ ច វិហាសិ ដូច្នេះ មិនមែនឬ ? ព្រោះហេតុអ្វី ទើបមិនត្រាស់ឈានុបេក្ខានោះទុកហ្ន៎ ?

ឆ្លើយថា ព្រោះមានកិច្ចមិនប្រាកដច្បាស់ ។ ពិតមែន កិច្ចនៃឈានុបេក្ខានោះ ក្នុងបឋមជ្ឈាននិងទុតិយជ្ឈាននោះ ឈ្មោះថា មិនទាន់ប្រាកដច្បាស់ ព្រោះត្រូវបដិបក្ខធម៌ មានវិតក្កៈជាដើមគ្របសង្កត់ ។ ចំណែកក្នុងតតិយជ្ឈាននេះ ឈានុបេក្ខានេះ កើតមានកិច្ចប្រាកដច្បាស់ ដូចជាលើកសីសៈឡើងបានហើយ ព្រោះវិតក្កៈវិចារៈនិងបីតិគ្របសង្កត់មិនបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ឈានុបេក្ខានោះទុកឯង ។

ការពណ៌នាបទថា ឧបេក្ខកោ ច វិហាសិ នេះ ចប់ហើយ ។

# អធិប្បាយលក្ខណៈនៃសតិ និងសម្បជញ្ញៈ

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងបាលីនេះថា សតោ ច សម្បជានោ : មានសតិ មានសេចក្ដីដឹងច្បាស់ ។ ឈ្មោះថា សតោ ព្រោះអត្ថថា រលឹកបាន ។ ឈ្មោះថា សម្បជានោ ព្រោះអត្ថថា ដឹងច្បាស់ដោយប្រពៃ សតិនិងសម្បជញ្ញៈត្រាស់ដោយបុគ្គល ។ ក្នុងសតិ និងសម្បជញ្ញៈនោះ សតិមានសេចក្ដីរលឹកបានជាលក្ខណៈ មានការមិនវង្វេងភ្លេចជាកិច្ច មានការឃុំគ្រងជាអាការប្រាកដ ។ សម្បជញ្ញៈ មានការមិនវង្វេងជាលក្ខណៈ មានសេចក្ដីពិចារណាជាកិច្ច មានសេចក្ដីស៊ើកបំភ្លឺជាអាការប្រាកដ ។ ក៏សតិនិងសម្បជញ្ញៈនេះ គប្បីជ្រាបដោយពិស្ដារ តាមន័យដែលខ្ញុំព្រះករុណាពោលទុកហើយ ក្នុងវណ្ណនានៃសតិប្បដ្ឋានសូត្រ ក្នុងអដ្ឋកថា មជ្ឈិមនិកាយនុ៎ះឯង ។

បណ្ដាធម៌ក្នុងតតិយជ្ឈាននោះ សតិនិងសម្បជញ្ញៈនេះមាននៅសូម្បីក្នុងឈានមុន ៗដោយពិត ព្រោះថា សូម្បីគុណជាតិត្រឹមតែឧបចារៈ រមែងមិនសម្រេចដល់ព្រះយោគាវចរអ្នកមានសតិវង្វេង មិនមានសម្បជញ្ញៈ, នឹងពោលទៅថ្វីដល់អប្បនា ។ តែថា ព្រោះសេចក្ដីដែលឈានទាំងនោះ

គ្រោតគ្រាត ការដំណើរទៅរបស់ចិត្តទើបមានសេចក្តីសប្បាយ ដូចការដំណើរទៅលើភូមិភាគផែនដីរបស់បុរសដូច្នោះ កិច្ចនៃសតិនិងសម្បជញ្ញៈក្នុងឈានទាំងនោះ ទើបមិនទាន់ប្រាកដច្បាស់ ៗ ក៏ព្រោះសេចក្តីដែលឈាននេះល្អិត ព្រោះលះអង្គដែលគ្រោតគ្រាតបានការដំណើរទៅរបស់ចិត្តដែលកិច្ចនៃសតិនិងសម្បជញ្ញៈគ្រប់គ្រងហើយនោះឯង ចាំបាច់ត្រូវប្រាថ្នាដូចការដើរជិតមុខកាំបិតកោររបស់បុរសដូច្នោះ ព្រោះហេតុនេះ ទើបត្រាស់ទុកក្នុងតតិយជ្ឈាននេះ ៗ នៅមានសេចក្តីដែលទឹងគប្បីពោលបន្ថែមត្រឹមតែបន្តិចបន្តួចទៀត ៗ

អ្នកប្រាជ្ញគប្បីជ្រាបសន្និដ្ឋានថា ពាក្យនេះថា សតោ ច សម្បជានោ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងតតិយជ្ឈាននេះប៉ុណ្ណោះក៏ដើម្បីសម្តែងសេចក្តីពិសេសសូម្បីនេះថា កូនគោដែលនៅជាប់មេគោត្រូវប្រាសចាកមេគោ កាលមិនធ្លាប់ឃុំគ្រងទុក រមែងចូលរកមេគោទៀតទុំៈឯងយ៉ាងណា សេចក្តីសុខក្នុងតតិយជ្ឈាននេះក៏យ៉ាងនោះ ត្រូវប្រាសចាកបីតិហើយសេចក្តីសុខនោះ កាលមិនធ្លាប់ឃុំគ្រងដោយគ្រឿងឃុំគ្រងគឺ សតិ និងសម្បជញ្ញៈ គប្បីចូលរកបីតិទៀតតែម្តង គប្បីជាសុខដែល

សម្បយុត្តដោយបីតិនោះឯង ។ ដល់សូម្បីថា សត្វទាំងឡាយ រមែងតម្រេកខ្វាំងក្នុងសេចក្ដីសុខ និងសេចក្ដីសុខនេះ ក៏ជាសុខផ្អែមក្រៃលែងណាស់ ព្រោះមិនមានសុខក្រៃលែងជាងនោះ តែការមិនតម្រេកខ្វាំងក្នុងសេចក្ដីសុខ រមែងមានក្នុងតតិយជ្ឈាននេះ ដោយអានុភាពនៃសតិ និងសម្បជញ្ញៈ មិនមែនមានដោយប្រការដទៃដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សុខញ្ច កាយេន បដិសំវេទេសិ : សោយសុខដោយកាយផង នេះតទៅ ៖

ព្រះយោគីដែលប្រកបព្រមដោយតតិយជ្ឈាន មិនមានសេចក្ដីរំពឹងក្នុងការសោយសេចក្ដីសុខ ក៏ពិតមែនហើយ តែថា ព្រះយោគីនោះសូម្បីចេញចាកឈានហើយ ក៏គប្បីសោយសុខបាន ព្រោះហេតុដែលរូបកាយរបស់លោក ដែលរូបដ៏ប្រណីតក្រៃលែង ដែលមានសេចក្ដីសុខដែលសម្បយុត្តដោយនាមកាយរបស់លោក ឬសេចក្ដីសុខដែលប្រកបនាមកាយនោះ ជាសមុដ្ឋានពាល់ត្រូវផ្សព្វផ្សាយហើយ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងសេចក្ដីនោះទើបត្រាស់ថា សុខញ្ច កាយេន បដិសំវេទេសិ ដូច្នេះ ។

ឥឡូវនេះ ទីងវិនិច្ឆ័យក្នុងពាក្យថា យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី : អរិយបុគ្គលទាំងឡាយ តែង សម្តែងនូវបុគ្គលដែលបានតតិយជ្ឈានណាថា ជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ នេះតទៅ ៖

ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងប្រាប់ គឺ រមែង សម្តែង រមែងបញ្ញត្តិ រមែងតែងតាំង រមែងបើកផ្សាយ រមែងចែក រមែងធ្វើឱ្យងាយស្រួល, អធិប្បាយថា រមែងប្រកាស គឺ រមែងសរសើរ នូវបុគ្គលដែលមានសេចក្តីប្រកបព្រមដោយតតិយជ្ឈាននោះ ព្រោះហេតុ នៃឈានណា គឺ ព្រោះឈានណាជាហេតុ ។ រមែងសរសើរថា យ៉ាង ណា ? រមែងសរសើរថា ជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ដូច្នេះ ។ យើងចូលដល់តតិយជ្ឈាននោះហើយ, យោជនាក្នុងពាក្យថា យន្តំ អរិយា ជាដើមនេះ គប្បីជ្រាបដូចពណ៌នាមកយ៉ាងនេះ ដោយ ប្រការដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះអរិយៈទាំងនោះ ទើបសរសើរបុគ្គល ដែលមានសេចក្តីប្រកបព្រមដោយតតិយជ្ឈាននោះទុកយ៉ាងនោះ ?

ឆ្លើយថា ព្រោះជាអ្នកដែលគួរសរសើរ ។

ពិតមែន ព្រោះព្រះយោគីនេះ ជាអ្នកមានសេចក្តីប្រងើយក្នុងតតិយជ្ឈាន ដែលមានសេចក្តីសុខដ៏ផ្អែមក្រៃលែងណាស់ ដែលដល់ត្រើយនៃសេចក្តីសុខហើយក៏ដោយ មិនត្រូវសេចក្តីប្រាថ្នាក្នុងសុខទាញទៅក្នុងតតិយជ្ឈាននោះបានទេ និងឈ្មោះថា ជាអ្នកមានសតិព្រោះជាអ្នកមានសតិតាំងមាំដោយអាការដែលបីតិនឹងកើតឡើងមិនបាន, និងព្រោះលោកបានសោយសេចក្តីសុខដែលមិនសៅហ្មង ដែលជាអរិយកន្ត និងដែលអរិយជនសេពសោយហើយនុ៎ះឯង ដោយនាមកាយ ដូច្នោះ ទើបជាអ្នកដែលគួរសរសើរ ។

គប្បីជ្រាបសន្និដ្ឋានថា ព្រោះជាអ្នកដែលគួរសរសើរ ព្រះអរិយៈទាំងឡាយ កាលនឹងប្រកាសគុណដែលជាហេតុដែលគួរសរសើរទាំងនោះទើបសរសើរបុគ្គលដែលប្រកបព្រមដោយតតិយជ្ឈាននោះ យ៉ាងនេះថា ជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ដូចពណ៌នាមកដូច្នេះ ។

បទថា តតិយំ : ទី៣ គឺ ជាទី ៣ តាមលំដាប់នៃការគណនា ។ ឈាននេះ ឈ្មោះថា ទី ៣ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចលើកទី ៣ ដូច្នេះខ្លះ ។

## ទុតិយជ្ឈានមានអង្គ ៤ តតិយជ្ឈានមានអង្គ ៥

ក្នុងពាក្យថា ឈានំ នេះ គប្បីជ្រាបវិនិច្ឆ័យថា ទុតិយជ្ឈានមានអង្គ ៤ ដោយអង្គទាំងឡាយមានសម្បសាទៈជាដើម យ៉ាងណា, តតិយជ្ឈានមានអង្គ ៥ ដោយអង្គទាំងឡាយ មានឧបេក្ខាជាដើម ដូច្នោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ឈានន្តិ ឧបេក្ខា សតិ សម្បជញ្ញំ សុខំ ចិត្តស្ស ឯកគ្គតា : ត្រង់ពាក្យថា ឈាន ឧបេក្ខា សតិ សម្បជញ្ញៈ សុខ ឯកគ្គតានៃចិត្ត"[១] ដូច្នេះ ។ យ៉ាងនោះជានិយអមប៉ុណ្ណោះ ។ តែដោយន័យត្រង់ តតិយជ្ឈាននោះ វៀរអង្គ គឺ ឧបេក្ខា សតិ និងសម្បជញ្ញៈចេញ រមែងប្រកបដោយអង្គ ២ ប៉ុណ្ណោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ។ សុខំ ចិត្តស្សេកគ្គតា : ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន"[២] ពាក្យដែលនៅសល់ មានន័យដូចពោលមកហើយនោះឯង ។

តតិយជ្ឈានកថា ចប់

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤២៣/២៨៣ ។ ២. អភិ. វិភ. ឈានវិភង្គ. ៨១. ៤៥៩/២៩២; វិសុទ្ធិ. មានពាក្យថា : កតមំ ។

# ចតុត្ថជ្ឈានកថា

ពាក្យថា សុខស្ស ច បហានា ទុក្ខស្ស ច បហានា : ព្រោះលះបង់នូវសេចក្ដីសុខផង ព្រោះលះបង់នូវសេចក្ដីទុក្ខផង ដូច្នោះ គឺព្រោះលះសុខមកកាយនិងទុក្ខមកកាយ ។ ពាក្យថា បុព្វេវ : អំពីមុនផង សេចក្ដីថា ក៏ការលះសុខនិងទុក្ខនោះឯង បានមានហើយអំពីមុនពិតមិនមែនមានក្នុងខណៈចតុត្ថជ្ឈាន ។ ពាក្យថា សោមនស្សទោមនស្សានំ អត្ថង្គមា : ព្រោះរំលត់នូវសោមនស្សនិងទោមនស្ស នោះ សេចក្ដីថា ព្រោះដល់សេចក្ដីតាំងនៅមិនបាន មានពាក្យអធិប្បាយថា ព្រោះលះបាននូវធម៌ទាំង ២ ប្រការនេះ គឺ សុខមកចិត្តនិងទុក្ខមកចិត្ត អំពីមុនពិតមែន ។

សួរថា ក៏ទីងលះសុខនិងទុក្ខសោមនស្សនិងទោមនស្សទាំងនោះបាន កាលណា ?

ឆ្លើយថា ក្នុងខណៈនៃឧបចារៈនៃឈានទាំង ៤ ។

ពិតមែន សោមនស្សដែលព្រះយោគាវចរលះបង់បានក្នុងខណៈនៃឧបចារៈ នៃឈានទី ៤ នោះឯង ។ ទុក្ខទោមនស្សនិងសុខលះបង់បានក្នុងខណៈនៃឧបចារៈ នៃឈានទី ១ ទី ២ និងទី ៣ ។ ដោយប្រការ

ដូចពោលមកនេះ គប្បីជ្រាបការលះសុខទុក្ខសោមនស្សនិងទោមនស្សទាំងនេះ ដែលព្រះមានព្រះភាគមិនបានត្រាស់ទុកដោយលំដាប់នៃការលះតែម្តង, តែក៏បានត្រាស់ទុក សូម្បីក្នុងទីនេះ ដោយលំដាប់ឧទ្ទេសនៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គនុ៎ះឯង ។

មានពាក្យសួរថា ក៏បើសុខទុក្ខជាដើមទាំងនេះ ព្រះយោគាវចរលះបានក្នុងខណៈនៃឧបចារៈនៃឈាននោះ ៗ សោត, កាលបើដូច្នោះព្រោះហេតុអ្វី ទើបត្រាស់ការរលត់ (សុខទុក្ខជាដើម) ទុកក្នុងឈានទាំងឡាយនុ៎ះឯងយ៉ាងនេះថា "ចុះទុក្ខិន្ទ្រិយ កើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅមិនមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ រមែងចូលកាន់បឋមជ្ឈាន, ដែលប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក ។ ទុក្ខិន្ទ្រិយកើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់"[១] "ចុះទោមនស្សិន្ទ្រិយ ..."[២] "ចុះសុខិន្ទ្រិយ ..."[៣] "សោមនស្សិន្ទ្រិយ ... កើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់"[៤] ។

---

១-៤. សំយុ. មហា. សុខិន្ទ្រិយវគ្គ. ៣៨. ២៨០/១៨១; ២៨១/១៨២; ២៨២/១៨៣; ២៨៣/១៨៥ ។

មានពាក្យឆ្លើយថា ព្រោះជាសេចក្ដីរលត់យ៉ាងប្រសើរ ។ ពិតមែន សេចក្ដីរលត់ទុក្ខជាដើមទាំងនោះ ក្នុងឈានទាំងឡាយមានបឋមជ្ឈានជាដើម ជាសេចក្ដីរលត់យ៉ាងប្រសើរ ។ តែសេចក្ដីរលត់ក្នុងខណៈនៃឧបចារៈប៉ុណ្ណោះ មិនជាសេចក្ដីរលត់យ៉ាងប្រសើរទេ ។ ពិតមែន ទុក្ខិន្ទ្រិយសូម្បីរលត់ហើយក្នុងឧបចារៈនៃបឋមជ្ឈានដែលមានអាវជ្ជនៈផ្សេង ៗ គ្នា តែគប្បីកើតឡើងបានទៀត ព្រោះសម្ផស្សមានរបោមនិងមូសជាដើម ឬព្រោះសេចក្ដីក្ដៅក្រហាយដែលកើតអំពីការអង្គុយមិនស្មើ, តែនឹងកើតក្នុងខាងក្នុងអប្បនាមិនបានឡើយ ។ម្យ៉ាងទៀត ទុក្ខិន្ទ្រិយនោះ សូម្បីរលត់ហើយក្នុងឧបចារៈ នៅរលត់មិនស្អិទល្អ ព្រោះធម៌ដែលជាសត្រូវនៅកម្ចាត់មិនបាន ។ ចំណែកខាងក្នុងអប្បនា កាយទាំងអស់ឈានចុះកាន់សេចក្ដីសុខ ព្រោះមានបីតិជ្រួតជ្រាប និងទុក្ខិន្ទ្រិយរបស់ព្រះយោគាវចរដែលមានកាយឈានចុះកាន់សេចក្ដីសុខ ចាត់ថា រលត់ទៅហើយដោយល្អ ព្រោះធម៌ដែលជាសត្រូវត្រូវកម្ចាត់ចេញបាន ។

ក៏ទោមនស្សិន្ទ្រិយ ដែលព្រះយោគាវចរលះបានហើយ ក្នុងឧបចារៈនៃទុតិយជ្ឈានដែលមានអាវជ្ជនៈផ្សេង ៗ គ្នាទុំះឯង តែគប្បីកើតឡើងបានទៀត ព្រោះទោមនស្សិន្ទ្រិយនោះ កាលមានសេចក្ដីលំបាកកាយនិងសេចក្ដីចង្អៀតចង្អល់ចិត្តសូម្បីដែលមានវិតក្កៈវិចារៈជាបច្ច័យ រមែង

កើតឡើងបាន តែនឹងកើតមិនបានឡើយក្នុងការមិនមានវិតក្កៈវិចារៈ, តែទោមនស្សិន្ទ្រិយនឹងកើតក្នុងចិត្តុប្បាទណា ព្រោះមានវិតក្កៈវិចារៈ ទើបកើតឡើងក្នុងចិត្តុប្បាទនោះ, វិតក្កៈ វិចារៈក្នុងឧបចារៈនៃទុតិយជ្ឈានលោកនៅលះមិនបានឡើយ ព្រោះដូច្នោះ ទោមនស្សិន្ទ្រិយនោះ គប្បីកើតបានក្នុងឧបចារៈនៃទុតិយជ្ឈាននោះ ព្រោះមានបច្ច័យដែលនៅលះមិនបាន តែក្នុងទុតិយជ្ឈាននឹងកើតឡើងមិនបានឡើយ ព្រោះមានបច្ច័យដែលលះបានហើយ ។

មួយទៀត សុខិន្ទ្រិយ សូម្បីដែលលះបានហើយក្នុងឧបចារៈនៃតតិយជ្ឈាន ក៏គប្បីកើតឡើងដល់ព្រះយោគាវចរអ្នកមានកាយដែលរូបដ៏ប្រណីត ដែលមានបីតិជាសមុដ្ឋានពាល់ត្រូវហើយ តែក្នុងតតិយជ្ឈានកើតឡើងមិនបានឡើយ ។ ពិតមែន បីតិដែលជាបច្ច័យនៃសេចក្តីសុខក្នុងតតិយជ្ឈាន រលត់ទៅហើយដោយប្រការទាំងពួង ។ មួយទៀត សោមនស្សិន្ទ្រិយ សូម្បីដែលលះបានហើយក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏គប្បីកើតឡើងទៀតបាន ព្រោះជិតនឹងបីតិ និងព្រោះមិនកន្លងទៅដោយល្អ ព្រោះមិនមានឧបេក្ខាដែលដល់អប្បនា, តែក្នុងចតុត្ថជ្ឈាននឹងកើតឡើងមិនបានឡើយ ។ ព្រោះហេតុដូចដែលពោលមកនោះឯង ទើបព្រះមានព្រះភាគទ្រង់ធ្វើអបរិសេសសព្ទទុកក្នុងទីនោះ ៗ ថា ទុក្ខិន្ទ្រិយកើត

ឡើងហើយ រលត់មិនមានសេសសល់ក្នុងឈានទេះ ដូច្នេះឯង ។

ក្នុងអធិការនៃចតុត្ថជ្ឈានទេះ អាចារ្យអ្នកចោទជំទាស់ថា បើកាលជាយ៉ាងនោះ វេទនាទាំងនោះ សូម្បីដែលលះបានហើយក្នុងឧបចារៈនៃឈាននោះ ៗ ព្រោះហេតុអ្វី ទើបក្នុងចតុត្ថជ្ឈានទេះ ព្រះមានព្រះភាគទ្រង់ប្រមូលមកទុកទៀតហ្ន៎ ?

ឆ្លើយថា ដើម្បីឱ្យកាន់យកសប្បាយ ( ដើម្បីយល់ងាយ ) ។

ពិតមែន អទុក្ខមសុខវេទនា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងអង្គឈានទេះថា អទុក្ខមសុខំ ( មិនមែនទុក្ខមិនមែនសុខ ) នេះ ជារបស់ល្អិត ដឹងបានដោយលំបាកមិនអាចនឹងកាន់យកបានដោយសប្បាយ, ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ប្រមូលវេទនាទាំងនោះមកទុកទាំងអស់ ដើម្បីឱ្យកាន់យកសប្បាយ ប្រៀបដូចដើម្បីនឹងចាប់គោកាច ដែលអ្នកណា ៗ មិនអាចនឹងចូលទៅចាប់ជិត ៗ បាន ដោយប្រការណា ទើបអ្នកចិញ្ចឹមគោកៀរគ្រប់គោមកទុកក្នុងក្រោលជាមួយគ្នា ខាងក្រោយទើបលែងចេញមកម្តងមួយ ៗ ឱ្យចាប់យកគោនោះ ដែលចេញមកតាមលំដាប់ ដោយបង្គាប់ថា នេះគឺ គោនោះ ពួកលោកចូរចាប់វា ដូច្នោះ ។

ពិតមែន ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងវេទនាទាំងនោះ ដែលព្រះអង្គប្រមូលមកហើយយ៉ាងនោះ រមែងទ្រង់អាច ដើម្បីឱ្យកាន់យកវេទនានេះ

ថា ធម្មជាតិដែលមិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្សនេះ គឺ អទុក្ខមសុខវេទនា, មួយទៀត វេទនាទាំងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់ទុក ក៏ដើម្បីនឹងសម្ដែងបច្ច័យនៃអទុក្ខមសុខចេតោវិមុត្តិ ។ ពិតមែន ធម៌ទាំងឡាយមានការលះសុខជាដើម[១] ជាបច្ច័យនៃចេតោវិមុត្តិនោះ ។ ដូចដែលព្រះធម្មទិន្នាថេរី ពោលទុកថា "ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្ដីសុខ១ ព្រោះលះបង់នូវសេចក្ដីទុក្ខ១ ព្រោះរំលត់នូវសោមនស្ស និងទោមនស្សក្នុងកាលមុន១ ចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធិដោយឧបេក្ខា ហើយសម្រេចសម្រាននៅដោយឥរិយាបថទាំងបួន១ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង[២] ។

ម្យ៉ាងទៀត សញ្ញោជនៈទាំងឡាយមានសក្កាយទិដ្ឋិជាដើម សូម្បីដែលលះបានហើយក្នុងមគ្គដទៃមានសោតាបត្តិមគ្គជាដើម ព្រះអង្គត្រាស់ថា លះបានហើយក្នុងមគ្គទី ៣ នោះ ដើម្បីត្រាស់សរសើរមគ្គទី ៣ យ៉ាងណា វេទនាមានសុខជាដើមទាំងនោះគួរជ្រាបថា ព្រះអង្គត្រាស់ទុក

---

១. វិសុទ្ធិមគ្គ. ១/២១៣ ជាដើម ទុក្ខប្បហានាទយោ. ដីកាសារត្ថទីបនី ១/៥៩០ ក៏ដូចគ្នា ។ ២. មជ្ឈិ. មូល. មហាវេទល្លសូត្រ. ២២. ១៤៣/២៨០ ។

ក្នុងចតុត្ថជ្ឈាននេះ សូម្បីដើម្បីត្រាស់សរសើរឈាននោះដូច្នោះ ។

ន័យមួយទៀត វេទនាមានសុខជាដើមទាំងនោះ គប្បីជ្រាបថា ព្រះអង្គត្រាស់ទុកក្នុងចតុត្ថជ្ឈាននេះ សូម្បីដើម្បីនឹងទ្រង់សម្តែងសេចក្តីដែលរាគៈ និងទោសៈ ជាធម្មជាតិដែលនៅឆ្ងាយក្រៃលែង ព្រោះសម្លាប់បច្ច័យចេញបាន ។ ពិតមែន បណ្តាវេទនាមានសុខជាដើមទាំងនោះ សុខ ជាបច្ច័យនៃសោមនស្ស, សោមនស្ស ជាបច្ច័យនៃរាគៈ, ទុក្ខ ជាបច្ច័យនៃទោមនស្ស, ទោមនស្ស ជាបច្ច័យនៃទោសៈ, និងរាគៈទោសៈព្រមទាំងបច្ច័យ ជាការដែលចតុត្ថជ្ឈាននោះកម្ចាត់ហើយ ព្រោះសម្លាប់សេចក្តីសុខជាដើមចេញបាន ព្រោះហេតុនោះ រាគៈ និងទោសៈទើបមាននៅក្នុងទីឆ្ងាយក្រៃលែង ដូច្នេះឯង ។

## អត្ថាធិប្បាយឧបេក្ខាក្នុងចតុត្ថជ្ឈាន

បទថា អទុក្ខមសុខំ សេចក្តីថា ឈ្មោះថា អទុក្ខ ព្រោះមិនមានទុក្ខ ឈ្មោះថា អសុខ ព្រោះមិនមានសុខ ។ ក្នុងពាក្យថា អទុក្ខមសុខំនេះ ព្រះមានព្រះភាគទ្រង់សម្តែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខនិងសុខដោយព្រះតម្រាស់នេះ ទ្រង់មិនសម្តែងត្រឹមតែការមិនមាននៃទុក្ខនិងសុខទេ ។ អទុក្ខ និងអសុខ ឈ្មោះថា វេទនា ទី ៣ លោកហៅថា

ឧបេក្ខា ខ្វះ ។ ឧបេក្ខានោះ បណ្ឌិតគប្បីជ្រាបថា **ឥដ្ឋានិដ្ឋវិបរីតានុភវនលក្ខណា មជ្ឈត្តរសា អវិក្ខេបបច្ចុបដ្ឋានា សុខនិរោធបទដ្ឋានា** មានការសោយអារម្មណ៍ដែលខុសប្លែកអំពីអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាលក្ខណៈ មានភាពជាកណ្ដាល ជាកិច្ច មានអារម្មណ៍មិនជាក់ច្បាស់ជាគ្រឿងប្រាកដមានសេចក្ដីរលត់សុខ ជាបទដ្ឋាន ។

បទថា ឧបេក្ខាសតិបារិសុទ្ធិ មានសតិដ៏ស្អាត ព្រោះឧបេក្ខា សេចក្ដីថា មានសតិជាធម្មជាតិ បរិសុទ្ធិ ដែលឧបេក្ខាឱ្យកើតហើយ ។ ពិតមែន ក្នុងឈាននេះ សតិជាធម្មជាតិបរិសុទ្ធិដោយល្អនិងសេចក្ដីបរិសុទ្ធិនៃសតិនោះ ដែលឧបេក្ខាធ្វើហើយ មិនមែនធម៌យ៉ាងដទៃធ្វើទេ, ព្រោះហេតុនោះ ឈាននោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា មានសតិបរិសុទ្ធិដែលឧបេក្ខាឱ្យកើតហើយ ដូច្នេះ ។ សូម្បីក្នុងគម្ពីរវិភង្គព្រះអង្គក៏បានត្រាស់ទុកថា "អយំ សតិ ឥមាយ ឧបេក្ខាយ វិសទា ហោតិ បរិសុទ្ធា បរិយោទាតា តេន វុច្ចតិ : ឧបេក្ខាសតិបារិសុទ្ធិ សតិនេះ ជាធម្មជាតិបើក បរិសុទ្ធិ ផូរផង់ ដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានសតិបរិសុទ្ធិដោយឧបេក្ខា"[១] ។ ក៏សេចក្ដី

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤២៩/២៨៥ ។

បរិសុទ្ធិនៃសតិក្នុងចតុត្ថជ្ឈាននេះ រមែងមានព្រោះឧបេក្ខាណា, ឧបេក្ខានោះ ដោយអត្ថគប្បីជ្រាបថា មានភាពជាកណ្ដាលក្នុងធម៌នោះ ៗ មួយទៀត ក្នុងចតុត្ថជ្ឈាននេះ សតិប៉ុណ្ណោះ ជាធម្មជាតិបរិសុទ្ធិព្រោះឧបេក្ខានោះតែម្យ៉ាងក៏ទេ, ម្យ៉ាងទៀត សូម្បីសម្បយុត្តធម៌ទាំងអស់ ក៏បរិសុទ្ធិព្រោះឧបេក្ខានោះ (ដូចគ្នា) ។ តែទេសនា ព្រះអង្គត្រាស់ទុកដោយលើកសតិឡើងជាប្រធាន ។

បណ្ដាធម៌ក្នុងចតុត្ថជ្ឈាននោះ ឧបេក្ខានេះ មាននៅក្នុងឈានទាំង ៣ សូម្បីក្នុងកាលក្រោយ ក៏ពិតមែនហើយ តែថា ចន្ទលេខា ពោលគឺ តត្រមជ្ឈត្តុបេក្ខានេះ សូម្បីមាននៅក្នុងសេចក្ដីផ្សេងគ្នានៃឈានមានបឋមជ្ឈានជាដើម រមែងឈ្មោះថា ជាធម្មជាតិមិនបរិសុទ្ធិ ព្រោះត្រូវតេជៈនៃធម៌ដែលជាសត្រូវ មានវិតក្កៈជាដើមគ្របសង្កត់ទុក និងព្រោះមិនបានរាត្រី ពោលគឺ ឧបេក្ខាវេទនា ដែលជាសភាគគ្នា ប្រៀបដូចចន្ទលេខា (ព្រះចន្ទ) សូម្បីមាននៅក្នុងពេលថ្ងៃ ក៏ឈ្មោះថា ជារបស់មិនបរិសុទ្ធិ មិនថ្លាផូរផង់ ព្រោះត្រូវរស្មីព្រះអាទិត្យគ្របសង្កត់ក្នុងពេលថ្ងៃ ឬ ព្រោះមិនបានពេលយប់ដែលជាសភាគគ្នា ដោយភាពជារបស់ដែលមានឧបការៈដល់ខ្លួន ដោយភាពជារបស់ស្អាតល្អដូច្នោះ ។ ក៏កាលតត្រមជ្ឈត្តុ

បេក្ខានោះមិនបរិសុទ្ធិ ធម៌ទាំងឡាយមានសតិជាដើមសម្បយុត្តដែលកើតរួមគ្នាក៏ជាធម្មជាតិមិនបរិសុទ្ធិពិត ដូចរស្មីនៃព្រះចន្ទដែលមិនបរិសុទ្ធិក្នុងពេលថ្ងៃដូច្នោះ ។ ព្រោះហេតុនោះ ឈានសម្បយុត្តមួយយ៉ាងក្នុងបណ្ដាបឋមជ្ឈានជាដើមទាំងនោះ ព្រះមានព្រះភាគក៏មិនត្រាស់ថា មានសតិបរិសុទ្ធិព្រោះឧបេក្ខា ចំណែកក្នុងចតុត្ថជ្ឈាននេះ ព្រះចន្ទពោលគឺ តត្រមជ្ឈត្តុបេក្ខានេះជាធម្មជាតិបរិសុទ្ធិយ៉ាងក្រៃលែង ព្រោះមិនត្រូវតេជៈនៃធម៌ដែលជាសត្រូវមានវិតក្កៈជាដើមគ្របសង្កត់ និងព្រោះបានពេលយប់ គឺ ឧបេក្ខាវេទនាដែលជាសភាគគ្នា ។ ព្រោះសេចក្ដីដែលតត្រមជ្ឈត្តុបេក្ខានោះជាធម្មជាតិបរិសុទ្ធិ ធម៌ទាំងឡាយមានសតិជាដើម សម្បយុត្តដែលកើតរួមគ្នាក៏ជាធម្មជាតិបរិសុទ្ធិផូរផង់ ដូចរស្មីនៃព្រះចន្ទដែលបរិសុទ្ធិដូច្នោះ ព្រោះហេតុនោះ ចតុត្ថជ្ឈាននេះប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកថា មានសតិបរិសុទ្ធិព្រោះឧបេក្ខា ។

បទថា ចតុត្ថំ : ទី៤ គឺ ជាទី ៤ តាមលំដាប់នៃការគណនា ។ ឈាននេះ ឈ្មោះថា ទី ៤ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចជាលើកទី ៤ ។

## តតិយជ្ឈានមានអង្គ ៥ ចតុត្ថជ្ឈានមានអង្គ ៣

ក្នុងពាក្យថា ឈានំ នេះ មានវិនិច្ឆ័យដូច្នេះគឺ ៖ តតិយជ្ឈានមានអង្គ ៥ ដោយអង្គទាំងឡាយមានឧបេក្ខាជាដើមយ៉ាងណា ចតុត្ថជ្ឈាននេះ ក៏មានអង្គ ៣ ដោយអង្គទាំងឡាយមានឧបេក្ខាជាដើមយ៉ាងនោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ឈានន្តិ ឧបេក្ខា សតិ ចិត្តស្សេកគ្គតា : ត្រង់ពាក្យថា ឈាន គឺ ឧបេក្ខា សតិ ឯកគ្គតានៃចិត្ត"[១] ដូច្នេះ ។ យ៉ាងនោះជាន័យអមប៉ុណ្ណោះ ។ តែដោយន័យត្រង់ ចតុត្ថជ្ឈាននេះ វៀរអង្គ គឺ សតិចេញ ព្រោះកាន់យកអង្គ គឺ ឧបេក្ខាវេទនាទុំះឯង ទើបប្រកបដោយអង្គ ២ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្សេកគ្គតា : ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា"[២] ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។

ចតុត្ថជ្ឈានកថា ចប់ ។

---

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤៣១/២៨៥ ។ ២. អភិ. វិភ. ឈានវិភង្គ. ៨១. ៤៦០/២៩៣ ។

## អត្ថាធិប្បាយឈាន ៤ របស់បុគ្គល ៥ ប្រភេទ

ឈាន ៤ យ៉ាងទាំងនេះ ដូចពណ៌នាមកនេះ របស់បុគ្គលពួកខ្លះ មានសេចក្តីដែលចិត្តមានអារម្មណ៍តែមួយជាប្រយោជន៍ របស់ពួកបុគ្គលខ្លះជាបាទនៃវិបស្សនារបស់ពួកបុគ្គលខ្លះ ជាបាទនៃអភិញ្ញា របស់ពួកបុគ្គលខ្លះ ជាបាទនៃនិរោធរបស់ពួកបុគ្គលខ្លះ មានការឈានចុះកាន់ភពជាប្រយោជន៍ ។

បណ្តាបុគ្គលទាំង ៥ ប្រភេទនោះ ឈានទាំង ៤ របស់ព្រះខីណាស្រពទាំងឡាយ មានចិត្តដែលមានអារម្មណ៍តែមួយជាប្រយោជន៍ ។ ពិតមែន ព្រះខីណាស្រពទាំងនោះ តាំងចិត្តទុកយ៉ាងនេះថា "យើងចូលឈានហើយ មានចិត្តមានអារម្មណ៍តែមួយ នឹងនៅជាសុខរហូតដល់អស់មួយថ្ងៃ" ដូច្នេះ ហើយធ្វើបរិកម្មក្នុងកសិណឱ្យសមាបត្តិទាំង ៨ កើតឡើង ។

ឈានទាំងឡាយរបស់ពួកព្រះសេក្ខៈ និងបុថុជ្ជនអ្នកចេញចាកសមាបត្តិហើយតាំងចិត្តទុកថា យើងមានចិត្តតាំងមាំហើយ នឹងឃើញច្បាស់ ហើយឱ្យកើតឡើង ចាត់ថា ជាបាទនៃវិបស្សនា ។

ចំណែកបុគ្គលពួកណា ឱ្យសមាបត្តិទាំង ៨ កើតឡើងហើយ ទើបចូលឈានដែលមានអភិញ្ញាជាបាទ ហើយចេញចាកសមាបត្តិ ប្រាថ្នាអភិញ្ញា មានន័យដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ឯកោបិ ហុត្វា

ពហុធា ហោតិ : មនុស្សម្នាក់ ធ្វើ(និម្មិត)ឱ្យទៅជាច្រើននាក់ ក៏បាន"[១] ដូច្នេះ ទើបឱ្យកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំងនោះ រមែងជាបាទនៃអភិញ្ញា ។

ចំណែកបុគ្គលពួកណា ឱ្យសមាបត្តិទាំង ៨ កើតឡើង ទើបចូលនិរោធសមាបត្តិហើយតាំងចិត្តទុកថា "យើងនឹងជាអ្នកមិនមានចិត្តសម្រេចនិរោធនិព្វាន នៅជាសុខក្នុងទិដ្ឋធម៌នោះឯង រហូតដល់អស់ប្រាំពីរថ្ងៃ ហើយឱ្យឈានកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំងនោះ រមែងជាបាទនៃនិរោធ ។

ចំណែកបុគ្គលពួកណា ឱ្យសមាបត្តិទាំង ៨ កើតឡើងហើយ តាំងចិត្តទុកថា យើងជាអ្នកមានឈានមិនសាបសូន្យ នឹងកើតឡើងក្នុងព្រហ្មលោក ហើយឱ្យឈានកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំងនោះ មានការឈានចុះកាន់ភពជាប្រយោជន៍ ។

ក៏ចតុត្ថជ្ឈាននេះ ព្រះមានព្រះភាគទ្រង់ឱ្យកើតឡើងហើយក្បែរគល់ពោធិព្រឹក្ស ចតុត្ថជ្ឈាននោះ របស់ព្រះមានព្រះភាគអង្គនោះ បានជាបាទនៃវិបស្សនាផង ជាបាទនៃអភិញ្ញាផង ជាបាទនៃនិរោធផង បណ្តាល

១. ទីឃ. សីល. សាមញ្ញផលសូត្រ. ១៤. ១៣៣/១៩៤; ទីឃ. បាដិ. សម្បសាទនីយសូត្រ. ១៨. ៩០/២២៨ ។ អង្គុ. តិក. ព្រាហ្មណវគ្គ. ៤១. ៦២/១៧១ ។

កិច្ចទាំងពួងឱ្យសម្រេចផង បណ្ឌិតគប្បីជ្រាបថា ផ្តល់ឱ្យគុណដែលជាលោកិយៈ និងដែលជាលោកុត្តរៈគ្រប់យ៉ាង ។

## បុព្វេនិវាសញ្ញាណកថា

ក៏ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងឯកទេសនៃគុណទាំងឡាយ ដែលចតុត្ថជ្ឈានជាហេតុផ្តល់ឱ្យទាំងនោះ ទើបត្រាស់ថា **ឯវំ សមាហិតេ ចិត្តេ : កាលដែលចិត្តខ្ជាប់ខ្ជួន** ដូច្នេះជាដើម ។

ក្នុងពាក្យថា សោ ឯវំ ជាដើមទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា សោ : នោះ គឺ សោ អហំ : តថាគតនោះឯង ។

បទថា ឯវំ នោះ ជាបទសម្តែងលំដាប់នៃចតុត្ថជ្ឈាន ។ មានអធិប្បាយថា យើងបានចំពោះចតុត្ថជ្ឈាន ដោយលំដាប់នេះ ។

បទថា សមាហិតេ សេចក្តីថា (កាលចិត្តរបស់តថាគត) តាំងមាំហើយដោយសមាធិក្នុងចតុត្ថជ្ឈាននេះ ។

ចំណែកក្នុងពាក្យថា បរិសុទ្ធេ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា បរិសុទ្ធិ ព្រោះមានសតិជាធម្មជាតិបរិសុទ្ធិ ដែលឧបេក្ខា

ឱ្យកើតហើយ ។ មានពាក្យអធិប្បាយទុកថា ឈ្មោះថា ផូរផង់ គឺ ភ្លឺថ្លា ព្រោះភាពជាធម្មជាតិបរិសុទ្ធិនុ៎ះឯង ។

ឈ្មោះថា **មិនមានកិលេស** ព្រោះសេចក្ដីដែលកិលេសដូចទីទួលមានរាគៈ ជាដើម ដែលមគ្គកំចាត់ហើយ ព្រោះសម្លាប់នូវបច្ច័យមានសុខជាដើមចេញបាន ។

ឈ្មោះថា **ប្រាសចាកសេចក្ដីសៅហ្មង** ព្រោះការមិនមានកិលេសដូចទីទួលនុ៎ះឯង ។ ពិតមែន ចិត្ត រមែងសៅហ្មង ព្រោះកិលេសដូចទីទួល ។

ឈ្មោះថា **ជាចិត្តទន់** ព្រោះអប់រំល្អហើយ មានពាក្យអធិប្បាយថា ដល់សេចក្ដីជំនាញ ។ ពិតមែន ចិត្តដែលប្រព្រឹត្តទៅនៅក្នុងអំណាច លោកហៅថា មុទុ (ទន់) ។ មួយទៀត ឈ្មោះថា **សមគួរដល់កម្ម** ព្រោះភាពជាចិត្តទន់នុ៎ះឯង មានពាក្យអធិប្បាយថា សមគួរដល់ការងារ គឺ គួរប្រកបក្នុងការងារ ។ ពិតមែន ចិត្តដែលទន់ រមែងជារបស់គួរដល់ការងារ ដូចមាសដែលជម្រះមន្ទិលចេញល្អហើយ ដូច្នោះ ។ ក៏ចិត្តសូម្បីទាំង២ (គឺ ចិត្តទន់និងចិត្តដែលគួរដល់ការងារ) នោះនឹងមានបានក៏ព្រោះជាចិត្តដែលបានទទួលអប់រំល្អហើយនុ៎ះឯង ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈ

ដទៃសូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ ជាសភាវៈទន់ផង គួរដល់ការងារផង ដូចចិត្តនេះសោះឡើយ”[១] ។

ឈ្មោះថា **ជាចិត្តនឹងធឹង** ព្រោះតាំងនៅក្នុងធម៌ទាំងឡាយ មានសេចក្តីបរិសុទ្ធិជាដើមទាំងនោះ

ឈ្មោះថា **មិនញាប់ញ័រ** ព្រោះភាពជាចិត្តតាំងមាំទាំងឯង មានអធិប្បាយថា ជាចិត្តមិនញាប់ញ័រ គឺ អស់សេចក្តីញាប់ញ័រ ។

ម្យ៉ាងទៀត ឈ្មោះថា **ជាចិត្តនឹងធឹង** ព្រោះភាពជាចិត្តតាំងនៅហើយក្នុងអំណាចរបស់ខ្លួន ដោយភាពជាចិត្តទន់និងគួរដល់ការងារ ។ ឈ្មោះថា **មិនញាប់ញ័រ** ព្រោះភាពជាចិត្តដែលធម៌ទាំងឡាយមានសទ្ធាជាដើម ផ្គងទុកហើយ ។

## ចិត្តមិនញាប់ញ័រដោយធម៌ ៦ យ៉ាង

ពិតមែន ចិត្តដែលសទ្ធាផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះអសទ្ធិយៈ (ការមិនមានសទ្ធា) ដែលវីរិយៈផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) ដែលសតិផ្គងទុកហើយ

១. អង្គុ. ឯក. បាលីពួកធម៌មួយ. ៤០. ៤៨/១៨ ។

រមែងមិនញាប់ញ័រ ព្រោះសេចក្ដីប្រមាទ (សេចក្ដីធ្វេសប្រហែស) ដែលសមាធិគ្គងទុកហើយ រមែងមិនញាប់ញ័រព្រោះឧទ្ធច្ចៈ (សេចក្ដីរវើរវាយ) ដែលបញ្ញាគ្គងទុកហើយ រមែងមិនញាប់ញ័រព្រោះអវិជ្ជា (ការមិនដឹង) ដែលដល់សេចក្ដីភ្លឺ រមែងមិនញាប់ញ័រ ព្រោះសេចក្ដី ងងឹតគឺកិលេស ចិត្តដែលធម៌ ៦ យ៉ាងទាំងនេះគ្គងទុកហើយ ជាចិត្តដល់ការមិនញាប់ញ័រ ។ ចិត្តដែលប្រកបដោយអង្គ ៨ ប្រការ ដូចពណ៌នាមកហើយនេះ រមែងជារបស់គួរដល់អភិនិហារ ដើម្បីការធ្វើឱ្យច្បាស់ដោយអភិញ្ញា ដែលធម៌ទាំងឡាយដែលគួរធ្វើឱ្យច្បាស់ដោយអភិញ្ញា ។

សូម្បីន័យមួយទៀត កាលចិត្តតាំងមាំហើយដោយសមាធិក្នុងចតុត្ថជ្ឈាន

ឈ្មោះថា **បរិសុទ្ធិ** ព្រោះជាចិត្តឆ្ងាយចាកនីវរណៈ,

ឈ្មោះថា **ផូរផង់** ព្រោះឈានកន្លងអង្គឈានមានវិតក្កៈជាដើម,

ឈ្មោះថា **មិនមានកិលេស** ព្រោះមិនមានការប្រព្រឹត្តក្រោមដោយសេចក្ដីប្រាថ្នាដ៏លាមក ដែលជាសត្រូវចំពោះការត្រឡប់បានឈាន[១] អធិប្បាយថា ឈ្មោះថា **មិនមានកិលេស** ព្រោះមិនមានការប្រព្រឹត្តក្រោម

---

១. វិសុទ្ធិមគ្គ. ២/២០៣ ជា **ឈានបដិលាភបច្ចនីកានំ** ឃើញថា ត្រូវ ទើបប្រែតាមនោះ ។

ដោយសេចក្ដីប្រាថ្នាគឺ ព្រោះមិនមានបច្ច័យនៃកាមរាគៈមានប្រការផ្សេង ៗ ដែលធ្លាក់ចុះហើយ គឺ ប្រព្រឹត្តទៅហើយដោយអំណាចសេចក្ដីប្រាថ្នា ។

ឈ្មោះថា ប្រាសចាកសេចក្ដីសៅហ្មង ព្រោះសេចក្ដីប្រាសចាកទៅនៃសេចក្ដីសៅហ្មងរបស់ចិត្ត មានអភិជ្ឈាជាដើម ។ ក៏សូម្បីធម៌ទាំង ២ (គឺ ការមិនមានកិលេសដូចទីទួល និងមានកិលេសប្រាសចាកទៅ) នោះ បណ្ឌិតគប្បីជ្រាបតាមផ្លូវនៃអនង្គណសូត្រ[១]និងវត្ថុសូត្រ[២] ។

ឈ្មោះថា ជាចិត្តទន់ ព្រោះដល់សេចក្ដីជំនាញ ។

ឈ្មោះថា សមគួរដល់កម្ម ព្រោះចូលដល់ភាពជាបាទនៃឫទ្ធិ,

ឈ្មោះថា ជាចិត្តនឹងធឹង មិនញាប់ញ័រ ព្រោះចូលដល់ភាពជាធម្មជាតិប្រណីត ដោយសេចក្ដីពេញបរិបូណ៌នៃភាវនា, អធិប្បាយថា ចិត្តរមែងមិនញាប់ញ័រ យ៉ាងណា, ជាចិត្តនឹងធឹង ក៏យ៉ាងនោះ ។

ចិត្តដែលប្រកបដោយអង្គ ៨ ប្រការ សូម្បីដូចពណ៌នាមកហើយនេះ រមែងជារបស់គួរដល់អភិនិហារ ជាបាទ ជាបទដ្ឋាន នៃការធ្វើឱ្យច្បាស់ដោយអភិញ្ញា ដែលធម៌ទាំងឡាយដែលគួរធ្វើឱ្យច្បាស់ដោយអភិញ្ញា ដោយប្រការដូច្នេះ ។

---

១. មជ្ឈិ. មូល. អនង្គណសូត្រ. ២០. ៥៣/៧៨ ។ ២. សំយុ. និទា. ២៩. ១៦៦/៩៦ ។

បទថា បុព្វេនិវាសានុស្សតិញ្ញាណាយ សេចក្ដីថា កាលចិត្តនោះដែលជាបាទនៃអភិញ្ញា កើតហើយយ៉ាងនោះ, ( យើងបានបង្អោនចិត្តទៅ ) ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុស្សតិញ្ញាណនោះ ។

## អត្ថាធិប្បាយវិគ្រោះ បុព្វេនិវាសសព្ទ

ក្នុងបណ្ដាបទថា បុព្វេនិវាសា ជាដើមនេះ គប្បីជ្រាបវិគ្រោះសព្ទដូច្នេះ ៖

ខន្ធដែលខ្លួនធ្លាប់នៅហើយក្នុងកាលមុន គឺ ក្នុងអតីតជាតិ ឈ្មោះថា បុព្វេនិវាស ( ខន្ធដែលខ្លួនធ្លាប់នៅហើយក្នុងកាលមុន ) ។

ខន្ធដែលខ្លួនធ្លាប់នៅរួចហើយ គឺ ដែលខ្លួនតាមសោយហើយបានដល់ ដែលកើតឡើងក្នុងសន្ដានរបស់ខ្លួនហើយរលត់ទៅ ឬធម៌ដែលខ្លួនធ្លាប់នៅហើយ ឈ្មោះថា និវុត្ថា ( ខន្ធឬធម៌ដែលខ្លួនធ្លាប់នៅរួចហើយ ) ។

ធម៌ទាំងឡាយដែលខ្លួនធ្លាប់នៅ ដោយការនៅដោយភាពជាគោចរ គឺ ដែលខ្លួនដឹងច្បាស់ បានដល់ ដែលខ្លួនកំណត់ហើយ ដោយវិញ្ញាណរបស់ខ្លួន ឬ សូម្បីដែលខ្លួនដឹងច្បាស់ហើយដោយវិញ្ញាណរបស់អ្នកដទៃក្នុងញាណទាំងឡាយ មានការតាមរលឹកដល់សង្សារវដ្ដដែលខ្លួនកាត់បាន

ដាច់ហើយ ឈ្មោះថា **និវុត្ថា** ។

ព្រះយោគាវចរ រមែងតាមរលឹក បានដល់ ខន្ធ ដែលខ្លួនធ្លាប់នៅក្នុងកាលមុនដោយសតិណា[១] សតិនោះ ឈ្មោះថា បុព្វេនិវាសានុស្សតិ ក្នុងពាក្យថា **បុព្វេនិវាសានុស្សតិ** នេះ ។

ញាណដែលសម្បយុត្តដោយសតិនោះ ឈ្មោះថា ញាណ ។ ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុសតិញ្ញាណនេះ, មានពាក្យអធិប្បាយថា (យើងបានបង្អោនចិត្តទៅ) ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺដើម្បីសម្រេច បានដល់ ដើម្បីដល់ញាណនោះ ដោយប្រការដូច្នេះ ។

បទថា **អភិនិន្នាមេសិ : ទើបតថាគតបង្អោនចូលទៅ** គឺតថាគតបានបង្អោនទៅចំពោះហើយ ។ បទថា **សោ** គឺ **សោ អហំ : តថាគត**នោះ ។ បទថា **អនេកវិហិតំ : មិនមែនតែមួយវិហិត** គឺ មិនមែនតែមួយជាតិ, ម្យ៉ាងទៀត អធិប្បាយថា ដែលយើងឱ្យប្រព្រឹត្តទៅហើយ គឺពណ៌នាទុកហើយដោយអនេកប្រការ ។ បទថា **បុព្វេនិវាសំ : អាស្រ័យនៅអំពីមុន** បានដល់ សន្តានដែលយើងធ្លាប់នៅប្រចាំ ។ ក្នុងភពនោះ ៗ ចាប់តាំងពីភពដែលកន្លងហើយជាលំដាប់ទៅ ។ ដោយបទថា អនុស្សរាមិ

---

១. វិសុទ្ធិមគ្គ. ២/២១ ។

: តថាគតរលឹក នេះព្រះមានព្រះភាគ រមែងទ្រង់សម្ដែងថា តថាគតបាន តាមរលឹកទៅ ៗ ដល់លំដាប់នៃជាតិបានយ៉ាងនេះ គឺ មួយជាតិខ្លះ ពីរជាតិខ្លះ បីជាតិខ្លះជាដើម, ម្យ៉ាងទៀត យើងរលឹកតាមបានពិត ៗ គឺ កាលចិត្តគ្រាន់តែយើងបានបង្អោនទៅចំពោះហើយប៉ុណ្ណោះ យើងក៏រលឹកបាន ។ ពិតមែន ព្រះមហាបុរសទាំងឡាយ ដែលមានបារមីពេញប្រៀបហើយ មិនមានការធ្វើបរិកម្ម ព្រោះហេតុនោះ មហាបុរសទាំងនោះ លុះបង្អោនចិត្តបែរត្រង់ទៅប៉ុណ្ណោះ ក៏រមែងរលឹក (ជាតិ) បាន ។ ចំណែកកុលបុត្រអ្នកជាអាទិកម្មិកទាំងឡាយ ត្រូវធ្វើបរិកម្មទើបរលឹក (ជាតិ) បាន ព្រោះហេតុនោះ ការបរិកម្មដោយអំណាចនៃកុលបុត្រទាំងនោះ ទើបគួរពោលទុកផង ។ តែកាលខ្ញុំព្រះករុណានឹងពោលការបរិកម្មនោះ នឹងធ្វើនិទាននៃព្រះវិន័យឱ្យជាភារៈធ្ងន់ក្រៃលែង ព្រោះដូច្នោះ ខ្ញុំព្រះករុណានឹងមិនពោលការបរិកម្មនោះទុក តែអ្នកសិក្សាដែលមានសេចក្ដីត្រូវការ គួរកាន់យកបរិកម្មនោះ តាមន័យដែលខ្ញុំព្រះករុណាពោលទុកហើយ ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ[១] ។ ក៏ក្នុងនិទាននៃព្រះវិន័យនេះ ខ្ញុំព្រះករុណានឹងពណ៌នាទុកចំពោះបាលីប៉ុណ្ណោះ ។

---

១. វិសុទ្ធិមគ្គ. ២/២៥១-២៥៣ ។

បទថា សេយ្យថីទំ ជានិបាត ចុះក្នុងអត្ថនៃការសម្តែងប្រការដែលព្រះអង្គទ្រង់ចាប់ផ្តើមទុកហើយ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងប្រការដែលផ្សេងគ្នានៃបុព្វេនិវាស ដែលព្រះអង្គទ្រង់ចាប់ផ្តើមទុកហើយ នោះ ទើបត្រាស់ពាក្យជាដើមថា **ឯកម្បិ ជាតឹ** ជាដើម ។ ក្នុងពាក្យថា **ឯកម្បិ ជាតឹ** ជាដើមនោះមានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **ឯកម្បិ ជាតឹ : មួយជាតិខ្លះ** សេចក្តីថា មួយខន្ធសន្តានដែលរាប់បញ្ចូលក្នុងភពមួយ ដែលមានបដិសន្ធិជាមូល មានចុតិជាទីបំផុត ។ បទថា **ទ្វេបិ ជាតិយោ : ពីរជាតិខ្លះ** ជាដើម ក៏ន័យនេះ ។

## អត្ថាធិប្បាយ អំពីកប្ប

មួយទៀត ក្នុងបទថា **អនេកេបិ សំវដ្តកប្បេ** ជាដើម គប្បីជ្រាបថា កប្បដែលកំពុងវិនាស ឈ្មោះថា សំវដ្តកប្ប, កប្បដែលកំពុងចម្រើនឡើង ឈ្មោះថា វិវដ្តកប្ប ។ បណ្តាសំវដ្តកប្បនិងវិវដ្តកប្បទាំង ២ នោះ សំវដ្តឋាយីកប្ប ឈ្មោះថា ជាការដែលលោកកាន់យកហើយដោយសំវដ្តកប្ប ព្រោះសំវដ្តកប្បជាមូលដើមនៃសំវដ្តឋាយីកប្បនោះ និងវិវដ្តឋាយីកប្ប ក៏ជាការដែលលោកកាន់យកហើយដោយវិវដ្តកប្ប ។

ពិតមែន កាលកាន់យកដូច្នោះ កប្បទាំងឡាយដែលព្រះមានព្រះភាគត្រាស់ទុកថា "យំ យាវតា វា បន អាកង្ខេយ្យា : ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ (កាលដែលយូររាប់មិនបាន)នៃកប្បនេះ មាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ " គឺ សំវដ្តកប្ប ១ សំវដ្តឋាយីកប្ប ១ វិវដ្តកប្ប ១ វិវដ្តឋាយីកប្ប ១[១] ។ ទាំងអស់ រមែងជាការដែលលោកកាន់យកហើយ ។

បណ្តាកប្បទាំងនោះ សំវដ្តកប្បមាន ៣ គឺ តេជោសំវដ្តកប្ប (គឺ កប្បដែលវិនាសទៅព្រោះភ្លើង) ១ អាបោសំវដ្តកប្ប (គឺ កប្បដែលវិនាសទៅព្រោះទឹក) ១ វាយោសំវដ្តកប្ប (គឺ កប្បដែលវិនាសទៅព្រោះខ្យល់) ។

ព្រំប្រទល់នៃសំវដ្តកប្បមាន ៣ គឺ ជាន់អាភស្សរៈ ១ ជាន់សុភកិណ្ហៈ ១ ជាន់វេហប្ផលៈ ១ ។ ក្នុងកាលណា កប្ប រមែងវិនាសទៅព្រោះភ្លើង, ក្នុងកាលនោះ លោករមែងត្រូវភ្លើងឆេះ ខាងក្រោមតាំងពីជាន់អាភស្សរៈចុះមក ។ ក្នុងកាលណា កប្បរមែងវិនាសទៅព្រោះទឹកក្នុងកាលនោះ លោករមែងត្រូវទឹកទម្លាយឱ្យខ្ទេចខ្ទីទៅ ខាងក្រោមតាំងពីជាន់សុភកិណ្ហៈចុះមក ។ ក្នុងកាលណា កប្បរមែងវិនាសទៅព្រោះ

---

១. អង្គុ. ចតុ. ឥន្ទ្រិយវគ្គ. ៤៣. ៦/២ ។

ខ្យល់, ក្នុងកាលនោះ លោករមែងត្រូវខ្យល់បក់ឱ្យខ្ចាត់ខ្ចាយទៅ ខាងក្រោមតាំងពីជាន់វេហប្ផលៈចុះមក ។ ក៏ដោយចំណែកច្រើន[១] ពុទ្ធខេត្តមួយយ៉ាង (គឺខេត្តរបស់ព្រះពុទ្ធ) រមែងវិនាសទៅ សូម្បីគ្រប់កាល ។

## ពុទ្ធខេត្ត ៣ ព្រមទាំងអត្ថាធិប្បាយ

ដែលឈ្មោះថា ពុទ្ធខេត្ត (គឺ ខេត្តរបស់ព្រះពុទ្ធ) មាន ៣ គឺ ជាតិខេត្ត (គឺខេត្តដែលប្រសូតិ)១ អាណាខេត្ត (គឺខេត្រដែនខែអំណាច) ១ វិស័យខេត្ត (គឺខេត្រដែនខែអារម្មណ៍ ឬសេចក្តីប្រាថ្នា)១ ។

ក្នុងពុទ្ធខេត្ត ៣ យ៉ាងនោះ ស្ថានជាទីញាប់ញ័រហើយ ព្រោះហេតុទាំងឡាយ មានការចាប់បដិសន្ធិជាដើម របស់ព្រះតថាគត ឈ្មោះថា ជាតិខេត្ត ដែលមានម៉ឺនចក្រវាឡជាទីបំផុត ។

ស្ថានទីអានុភាពនៃព្រះបរិត្តទាំងនេះ គឺ រតនបរិត្ត មេត្តាបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត មោរបរិត្ត ប្រព្រឹត្តទៅ ឈ្មោះថា អាណាខេត្តដែលមានសែនកោដិចក្រវាឡជាទីបំផុត ។

ខេត្តជាទីពឹងដែលព្រះអង្គទ្រង់រលឹកចំណង់ប្រាថ្នា ដែលព្រះអង្គទ្រង់សំដៅដល់ការត្រាស់ទុកថា ក៏ឬថា តថាគតគប្បីប្រាថ្នាលោកធាតុ

១. យោជនា ១/១៦១ : វិត្ថារតោតិ បុថុកតោ. ។

មានប្រមាណត្រឹមណា ដូច្នេះជាដើម ឈ្មោះថា វិស័យខេត្ត ដែលមានប្រមាណមិនមានទីបំផុត ។

បណ្តាពុទ្ធខេត្តទាំង ៣ ទាំងនោះ អាណាខេត្តមួយយ៉ាង រមែងវិនាសទៅដូចពណ៌នាមកដូច្នេះ ។ ក៏កាលអាណាខេត្តនោះវិនាសហើយ ជាតិខេត្តក៏រមែងវិនាសទៅផងដែរ ។ និងជាតិខេត្តកាលវិនាសទៅ ក៏រមែងវិនាសដោយរួមគ្នាទៅទ៉ុះឯង ។ សូម្បីកាលតាំងនៅ ក៏រមែងតាំងនៅដោយរួមគ្នា ។ ការវិនាសទៅ និងការតាំងនៅនៃខេត្តនោះ ខ្ញុំព្រះករុណាពោលទុកហើយក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ[១] ។ អ្នកសិក្សាទាំងឡាយ ដែលមានសេចក្តីត្រូវការ គប្បីកាន់យកអំពីបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គនោះ ។

ក៏បណ្តាសំវដ្តកប្បនិងវិវដ្តកប្ប ដែលព្រះមានព្រះភាគ ត្រាស់ទុកហើយយ៉ាងនោះ ព្រះមានព្រះភាគប្រថាប់អង្គុយនៅក្នុងពោធិមណ្ឌល ដើម្បីត្រូវការត្រាស់ដឹងក្រៃលែងនូវព្រះសម្មាសម្ពោធិញ្ញាណ ទ្រង់រលឹក (បុព្វេនិវាសបាន) រហូតដល់អស់សំវដ្តកប្បជាច្រើនខ្លះ រហូតដល់អស់វិវដ្តកប្បជាច្រើនខ្លះ រហូតដល់អស់សំវដ្តកប្បនិងវិវដ្តកប្បជាច្រើនខ្លះ ។

ទ្រង់រលឹកបាន ដោយន័យយ៉ាងណា ?

---

១. វិសុទ្ធិមគ្គ ២. ២២៥/២៦៥ ។

ទ្រង់រលឹកបានដោយន័យថា អមុត្រាសឹ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អមុត្រាសឹ : កើតក្នុងភពឯណោះ សេចក្តីថា ក្នុងសំវដ្តកប្បឈ្មោះឯណោះ យើងបានកើតហើយ គឺ ក្នុងភពក្តី ក្នុងកំណើតក្តី ក្នុងគតិក្តី ក្នុងវិញ្ញាណឋិតិក្តី ក្នុងសត្តាវាសក្តី ក្នុងសត្តនិកាយក្តី ឈ្មោះឯណោះ យើងបានមានហើយ ។

បទថា ឯវំនាមោ : មានឈ្មោះយ៉ាងនេះ សេចក្តីថា (ក្នុងភពជាដើមឈ្មោះឯណោះ) តថាគតមានឈ្មោះថា វេស្សន្តរ ឬមានឈ្មោះថា ជោតិបាល ។

បទថា ឯវំគោត្តោ : មានគោត្រយ៉ាងនេះ សេចក្តីថា តថាគតជាភគវគោត្រ ឬគោតមគោត្រ ។

បទថា ឯវំវណ្ណោ : មានសម្បុរយ៉ាងនេះ សេចក្តីថា តថាគតជាអ្នកមានសម្បុរស ឬខ្មៅស្រគំ ។

បទថា ឯវមាហារោ : មានអាហារយ៉ាងនេះ សេចក្តីថា តថាគតមានអាហារគឺ បាយនៃស្រូវសាលីដែលផ្សំដោយសាច់ ឬមានផ្លែឈើដែលជ្រុះចុះមកឯង ជារបស់បរិភោគ ។

បទថា ឯវំសុខទុក្ខប្បដិសំវេទី : ទទួលសុខទុក្ខយ៉ាងនេះ

សេចក្តីថា តថាគតបានសោយសុខ និងទុក្ខផ្សេងដោយប្រភេទមាន សាមិសសុខ និងនិរាមិសសុខជាដើម ដែលប្រព្រឹត្តទៅមកកាយ និងមកចិត្តដោយអនេកប្រការខ្លះ ។

បទថា **ឯវមាយុបរិយន្តោ** មានកំណត់អាយុប៉ុណ្ណេះ សេចក្តីថា (ក្នុងភពជាដើមឈ្មោះឯណោះ) តថាគតមានទីបំផុតនៃអាយុកំណត់បាន ១០០ ឆ្នាំ ឬមានទីបំផុតនៃអាយុកំណត់បាន ៨៤,០០០ កប្ប យ៉ាងនោះ ។

ច្រើនបទថា សោ តតោ ចុតោ អមុត្រ ឧទបាទឹ **: តថាគតច្យុតចាកអត្តភាពនោះហើយបានទៅកើតក្នុងភពឯណោះ** សេចក្តីថា តថាគតនោះចុតិចាកភព កំណើត គតិ វិញ្ញាណឋិតិ សត្តាវាស ឬសត្តនិកាយនោះហើយ ទើបបានកើតឡើងក្នុងភព កំណើត គតិ វិញ្ញាណឋិតិ សត្តាវាស ឬក្នុងសត្តនិកាយឈ្មោះឯណោះទៀត ។

បទថា **តត្រាបាសឹ** សេចក្តីថា ខាងក្រោយយើងបានមានហើយក្នុងភព កំណើតគតិ វិញ្ញាណឋិតិ សត្តាវាស ឬក្នុងសត្តនិកាយសូម្បីនោះ ដដែលទៀត ។ ពាក្យថា **ឯវំ នាមោ** ជាដើម មានន័យដូចពោលហើយនុ៎ះឯង ។

ម្យ៉ាងទៀត ព្រោះការរលឹកនេះថា **អមុត្រាសឹ** ជាការទ្រង់រលឹកតាមដែលត្រូវការរបស់ព្រះមានព្រះភាគ អ្នកទ្រង់រលឹកឡើងទៅតាមលំដាប់, ការរលឹកនេះថា **សោ តតោ ចុតោ** ជាការពិចារណារបស់ព្រះមានព្រះភាគ អ្នកទ្រង់រលឹកថយក្រោយត្រឡប់, ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីថា ព្រះមានព្រះភាគ ទ្រង់សំដៅយកភពតុសិត ទើបត្រាស់ពាក្យនេះថា អមុត្រ ឧទបាទឹ ក្នុងលំដាប់នៃការទ្រង់ឧប្បត្តិឡើងក្នុងភពនេះ ៗ ថា ឥធូបបន្នោ ។

ត្រើនបទថា តត្រាបាសឹ ឯវំនាមោ សេចក្តីថា យើងបានជាទេវបុត្រមាននាមថា សេតុកេតុ ក្នុងតុសិតពិភពសូម្បីនោះ ។

បទថា ឯវំគោត្តោ សេចក្តីថា យើងមានគោត្រដូចគ្នានឹងទេវតាទាំងនោះ ។

បទថា ឯវំវណ្ណោ សេចក្តីថា យើងមានពណ៌សម្បុរដូចមាស ។

បទថា ឯវមាហារោ សេចក្តីថា យើងមានអាហារសស្អាតជាទិព្វ ។

បទថា ឯវំសុខទុក្ខប្បដិសំវេទី សេចក្តីថា យើងបានសោយសុខដែលជាទិព្វយ៉ាងនេះ ។ ចំណែកទុក្ខ ត្រឹមតែជាទុក្ខប្រចាំសង្ខារប៉ុណ្ណោះ ។

បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា យើងមានទីបំផុតនៃអាយុ ៥៧ កោដិ និង ៦ លានឆ្នាំ យ៉ាងនេះ ។

ច្រើនបទថា សោ តតោ ចុតោ សេចក្តីថា យើងនោះ ចុតិចាកតុសិតពិភពនោះហើយ ។

ប្រជុំបទថា ឥធូបបន្នោ **:** **មកកើតក្នុងនេះ** សេចក្តីថា យើងកើតហើយក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវីក្នុងភពនេះ ។

បទថា ឥតិ **:** **យ៉ាងនេះ** គឺ ដោយប្រការដូច្នេះ ។

ពីរបទថា សាការំ សឧទ្ទេសំ **:** **ព្រមទាំងអាការ ព្រមទាំងឧទ្ទេស** គឺ ព្រមដោយឧទ្ទេស ដោយអំណាចឈ្មោះ និងគោត្រ, ព្រមដោយអាការ ដោយអំណាចពណ៌សម្បុរជាដើម ។

ពិតមែន សត្វ មនុស្សដែលគេសម្តែងឡើង ដោយឈ្មោះនិងគោត្រថា តិស្សៈ គោតមៈ ដូច្នេះ ។ សត្វ រមែងប្រាកដដោយភាពជាផ្សេង ៗ គ្នា ដោយពណ៌សម្បុរជាដើមថា ស លឿង ដូច្នេះជាដើម ។ ព្រោះហេតុនោះ ឈ្មោះនិង គោត្រ ឈ្មោះថា ឧទ្ទេស, ពណ៌សម្បុរជាដើមក្រៅនេះ ឈ្មោះថា អាការ ។

## ពួកតិរ្ថិយរលឹកជាតិបាន ៤០ កប្ប

សួរថា ក៏បុព្វេនិវាស រលឹកបានតែព្រះពុទ្ធទាំងឡាយមួយពួកប៉ុណ្ណោះឬ ? ខ្ញុំព្រះករុណានិងឆ្លើយតទៅ ៖ មិនមែនរលឹកបានតែព្រះពុទ្ធទាំងឡាយមួយពួកប៉ុណ្ណោះទេ, សូម្បីព្រះបច្ចេកពុទ្ធ ព្រះសាវក និងតិរ្ថិយក៏រលឹកបាន, ប៉ុន្តែថា រលឹកបានដោយមិនវិសេសឡើយ ។ ពិតមែន ពួកតិរ្ថិយ រមែងរលឹកបានត្រឹមតែ ៤០ កប្បប៉ុណ្ណោះ ហួសពីនោះទៅ រលឹកមិនបាន ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមានបញ្ញាទន់ខ្សោយ ។

ពិតមែន បញ្ញារបស់តិរ្ថិយទាំងនោះ ចាត់ថា មានកម្លាំងទន់ខ្សោយ ព្រោះវៀរចាកការកំណត់នាមនិងរូប ។

## ព្រះអសីតិមហាសាវករលឹកជាតិបាន១សែនកប្ប

ក៏បណ្ដាព្រះសាវកទាំងឡាយ ព្រះមហាសាវក ៨០ រូប រលឹកបានសែនកប្ប ។

ព្រះអគ្គសាវកទាំង ២ អង្គ រលឹកបានមួយអសង្ខេយ្យនិងមួយសែនកប្ប ។ ព្រះបច្ចេកពុទ្ធទាំងឡាយ រលឹកបានពីរអសង្ខេយ្យនិងមួយ

សែនកប្ប ។ ពិតមែន អភិនិហាររបស់ព្រះមហាសាវក ព្រះអគ្គសាវក និងព្រះបច្ចេកពុទ្ធទាំងនោះ មានប្រមាណប៉ុណ្ណេះ ។ ចំណែករបស់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់, ព្រះពុទ្ធទាំងឡាយ រមែងរលឹកបានដរាបប៉ុនដែលទ្រង់ប្រាថ្នា ។ តែពួកតិរ្ថិយ រមែងរលឹកបានតាមលំដាប់ខន្ធប៉ុណ្ណោះ ផុតលំដាប់ (ខន្ធ) ទៅ រមែងមិនអាចនឹងរលឹកបាន ដោយអំណាចចុតិនិងបដិសន្ធិ ។ ព្រោះថា ការឈានចុះកាន់ប្រទេស (នៃញាណ) ដែលខ្លួនប្រាថ្នា រមែងមិនមានដល់តិរ្ថិយទាំងនោះ អ្នកដូចជាមនុស្សខ្វាក់ ។ ព្រះសាវកទាំងឡាយ រមែងរលឹកបានសូម្បីដោយប្រការទាំង ២ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ដូចយ៉ាងនោះ ។ ចំណែកព្រះពុទ្ធទាំងឡាយ រមែងទ្រង់រលឹកបានរហូតដល់អស់ស្ថានទី ៗ ទ្រង់ប្រាថ្នានោះ ៗ ទាំងអស់តែម្តងក្នុងខាងក្រោមឬខាងលើ ក្នុងកោដិកប្បជាច្រើនដោយលំដាប់ខន្ធខ្លះ ដោយអំណាចចុតិនិងបដិសន្ធិខ្លះ ដោយអំណាចការឈានទៅដូចរាជសីហ៍ខ្លះ ។

ក្នុងពាក្យថា អយំ ខោ មេ ព្រាហ្មណ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា : ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមដំបូងនៃរាត្រី មានវិនិច្ឆ័យដូច្នេះ ៖

បទថា មេ : ដែលតថាគត បានដល់ គឺតថាគត ។

សេចក្ដីដឹងច្បាស់ លោកហៅថា វិជ្ជា ព្រោះអត្ថថា ធ្វើឱ្យដឹងច្បាស់ ។

សួរថា រមែងធ្វើឱ្យដឹងច្បាស់អ្វី ?

ឆ្លើយថា រមែងធ្វើឱ្យដឹងច្បាស់នូវបុព្វេនិវាស ។

មោហៈដែលបិទបាំងវិជ្ជានោះ លោកហៅថា អវិជ្ជា ព្រោះអត្ថថា ជាហេតុធ្វើមិនឱ្យដឹងច្បាស់នូវបុព្វេនិវាសនោះឯង ។ មោហៈនោះឯង លោកហៅថា តមៈ (សេចក្ដីងងឹត) ក្នុងបទថា តមោ ព្រោះអត្ថថា បិទបាំង ។ វិជ្ជានោះឯង លោកហៅថា អាលោកៈ ក្នុងបទថា អាលោកោ ព្រោះអត្ថថា ធ្វើពន្លឺ ។ ក៏បណ្ដាបទទាំងនេះ ក្នុងបទថា វិជ្ជា អធិគតា នេះ មានអធិប្បាយប៉ុណ្ណេះ ។ ពាក្យដែលនៅសល់ជាពាក្យពោលសរសើរ ។

ចំណែកក្នុងបទទាំង ២ ថា **វិជ្ជា អធិគតា អវិជ្ជា វិហតា** : សេចក្ដីល្អង់ខ្លាត់បាត់ទៅ សេចក្ដីចេះដឹងប្រាកដ នេះមានយោជនាថា វិជ្ជានេះឯង តថាគតបានសម្រេចហើយ អវិជ្ជា ដែលតថាគតអ្នកបានសម្រេចវិជ្ជានោះ កម្ចាត់បានហើយ, អធិប្បាយថា ឱ្យវិនាសហើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះហេតុដែលវិជ្ជាកើតឡើងហើយ ។

ក្នុងបទទាំង ២ (គឺ តមោ វិហតោ អាលោកោ ឧប្បន្នោ : ងងឹតខ្ទាត់

បាត់ទៅ ពន្លឺក៏កើតឡើង) សូម្បីក្រៅនេះ ក៏មានន័យនេះ ។

សព្ទថា យថា ក្នុងពាក្យថា យថាតំ នេះ ជានិបាត ចុះក្នុង សេចក្តីឧបមា ។

សព្ទថា តំ ជានិបាត ។

(វិជ្ជាជាដើមកើតឡើងហើយ) ដល់បុគ្គលអ្នកឈ្មោះថា មិនប្រមាទ ព្រោះការមិនទៅប្រាសចាកសតិ, អ្នកឈ្មោះថា មានសេចក្តីព្យាយាមដុតកិលេស ព្រោះញុំាងកិលេសឱ្យក្តៅដោយសេចក្តីព្យាយាម, អ្នកឈ្មោះថា មានខ្លួនបញ្ជូនទៅហើយ អធិប្បាយថា អ្នកបញ្ជូនចិត្តទៅហើយ ព្រោះជាអ្នកមិនមានសេចក្តីហួងហែងក្នុងកាយនិងជីវិត ។

ព្រះមានព្រះភាគ ត្រាស់ពាក្យអធិប្បាយនេះទុកថា អវិជ្ជា យើងកម្ចាត់បានហើយ, វិជ្ជាកើតឡើងហើយ (ដល់យើង), សេចក្តីងងឹតយើងកម្ចាត់បានហើយ, ពន្លឺកើតឡើងហើយ (ដល់យើង), ផលដែលសមគួរដល់ការប្រកបសេចក្តីព្យាយាមរឿយ ៗ នោះ យើងបានហើយ ដូចយ៉ាងអវិជ្ជា ដែលព្រះយោគាវចរគប្បីកម្ចាត់, វិជ្ជាគប្បីកើតឡើង,

សេចក្ដីផងនឹត គប្បីត្រូវកម្ចាត់, ពន្លឺគប្បីកើតឡើង ដល់ព្រះយោគាវចរ អ្នកមិនប្រមាទ អ្នកមានសេចក្ដីព្យាយាមដុតកិលេស អ្នកមានខ្លួនបញ្ជូនទៅហើយ ដូច្នោះដូចគ្នា ។

ប្រើនបទថា អយំ ខោ មេ ព្រាហ្មណ បឋមា អភិនិព្ភិទា អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា : ម្នាលព្រាហ្មណ៍ នេះឯងបឋមវិជ្ជា ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសម្បកពង សេចក្ដីថា ព្រាហ្មណ៍ ការញាស់ជាដំបូង គឺការចេញ(ពីសម្បក)ទៅមុនគេ បានដល់ ការកើតជាអរិយៈជាដំបូងនេះហើយ បានមានហើយដល់តថាគត ព្រោះទម្លាយសំបកពង គឺ អវិជ្ជាដែលបិទបាំងខ្លួន ដែលតថាគតនៅអាស្រ័យក្នុងភពមុន ដោយចុងចំពុះ គឺ បុព្វេនិវាសានុស្សតិញ្ញាណដូចការញាស់ចេញ គឺ ការចេញទៅ បាន ដល់ ការកើតនៃពួកកូនមាន់អំពីសំបកពងនោះ ក្នុងកាលខាងក្រោយ ព្រោះទម្លាយសំបកពង ដោយចុងចំពុះ ឬដោយចុងក្រចកជើងដូច្នោះ ដោយប្រការដូច្នេះ ។

បុព្វេនិវាសកថា ចប់

# ទិព្វចក្ខុកថា

ត្រើនបទថា សោ ឯវំ ។បេ ។ ចុតូបបាតញ្ញាណាយ : យ៉ាង នេះហើយ តថាគត ។ល ។ ចុតូបបាតញ្ញាណ សេចក្តីថា ព្រោះចិត្ត ខ្ជាប់ខ្ជួនជាដើមយ៉ាងនេះហើយ ទើបតថាគតបង្អោនចិត្តចូលទៅដើម្បី ញាណក្នុងចុតិនិងឧបបត្តិ ។ មានពាក្យអធិប្បាយថា (តថាគតបាន បង្អោនចិត្តទៅហើយ) ដើម្បីញាណដែលជាគ្រឿងដឹងចុតិនិងបដិសន្ធិ របស់សត្វទាំងឡាយ ។

ពីរបទថា ចិត្តំ អភិនិន្នាមេសឹ : ទើបតថាគតបង្អោនចិត្តចូល ទៅ សេចក្តីថា តថាគតបានបង្អោនបរិកម្មចិត្តទៅ ។

ចំណែកក្នុងពាក្យថា សោ ទិព្វេន ។បេ ។ បស្សាមិ : តថាគតពិចារណាមើល... ... ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ។ល ។ ក៏ ឃើញច្បាស់ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ព្រះមហាសត្វទាំងឡាយ អ្នកមានបារមីពេញប្រៀបហើយ រមែង មិនមានការធ្វើបរិកម្ម, ពិតមែន ព្រះមហាសត្វទាំងនោះ លុះមកាល បង្អោនចិត្តទៅប៉ុណ្ណោះ រមែងឃើញសត្វទាំងឡាយ ដែលចុតិ និងចាប់ បដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់ សុគតិនិងទុគ្គតិ ដោយទិព្វចក្ខុដ៏បរិសុទ្ធិកន្លងចក្ខុរបស់មនុស្ស ។ កុលបុត្រ

អ្នកជាអាទិកម្មិកទាំងឡាយ ត្រូវធ្វើបរិកម្មទើបឃើញបាន ។ ព្រោះហេតុនោះ ការបរិកម្ម ដោយអំណាចនៃកុលបុត្រទាំងនោះ ទើបគួរពោលទុកផង ។ តែកាលបើខ្ញុំព្រះករុណា នឹងពោលការបរិកម្មនោះផង នឹងធ្វើនិទាននៃព្រះវិន័យ ឱ្យជាភារៈធ្ងន់ក្រៃលែង, ព្រោះដូច្នោះ ខ្ញុំព្រះករុណាមិនពោលការបរិកម្មនោះទុក ។ ចំណែកអ្នកសិក្សាទាំងឡាយ អ្នកមានសេចក្ដីត្រូវការ គួរកាន់យកការបរិកម្មនោះ តាមន័យដែលខ្ញុំព្រះករុណាពោលទុកហើយ ក្នុងបករណ៍វិសេសឈ្មោះ វិសុទ្ធិមគ្គ[១] ។ តែក្នុងនិទាននៃព្រះវិន័យនេះ ខ្ញុំព្រះករុណានឹងពណ៌នាទុកចំពោះបាលីប៉ុណ្ណោះ ។

## អត្ថាធិប្បាយពាក្យថា ទិព្វចក្ខុជាដើម

បទថា សោ : នោះ គឺ សោ អហំ : តថាគតនោះ ។ ក្នុងពាក្យថា ទិព្វេន ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ចក្ខុប្បសាទ ឈ្មោះថា ទិព្វ ព្រោះដូចជានឹងដោយចក្ខុទិព្វ ។ ពិតមែន ចក្ខុប្បសាទរបស់ទេវតាទាំងឡាយ ដែលកើតព្រោះសុចរិតកម្មដែលទឹកប្រម៉ាត់ ស្លេស្ម និងឈាម ជាដើមមិនបានរុំព័ទ្ធ ដែលអាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយបាន ព្រោះជាធម្មជាតិដែលរួចផុតពីឧបក្កិលេស

១. វិសុទ្ធិមគ្គ ២. ២៥១/២៥៣ ។

គ្រឿងសៅហ្មង ឈ្មោះថា ជាទិព្វ ។ ក៏ម្យ៉ាងទៀត ញាណចក្ខុនេះ ដែលកើតព្រោះកម្លាំងនៃវីរិយភាវនា ក៏ដូចជាចក្ខុប្រសាទនោះដូចគ្នា, ព្រោះហេតុនោះ ញាណចក្ខុនោះ ទើបឈ្មោះថា ជាទិព្វ ព្រោះដូចជាទិព្វ, ញាណចក្ខុនោះ ឈ្មោះថា ជាទិព្វ ព្រោះជាចក្ខុដែលព្រះអង្គបានហើយដោយអំណាចទិព្វវិហារ និងព្រោះសូម្បីខ្លួនក៏អាស្រ័យទិព្វវិហារ ។ ឈ្មោះថា ជាទិព្វ សូម្បីព្រោះមានសេចក្តីរុងរឿងច្រើន ដោយកំណត់ពន្លឺ ។ ឈ្មោះថា ជាទិព្វ សូម្បីព្រោះមានគតិច្រើន ដោយការឃើញរូបដែលនៅខាងក្រៅជញ្ជាំងផ្ទះជាដើម ។ ពួក ៥ នៃអត្ថទាំងអស់នោះ បណ្ឌិតគប្បីជ្រាប តាមផ្លូវនៃគម្ពីរសព្ទសាស្ត្រ ។

ឈ្មោះថា ចក្ខុ ព្រោះអត្ថថា ឃើញ ដូចជាចក្ខុ ព្រោះធ្វើកិច្ចនៃចក្ខុ ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខុ ។ ឈ្មោះថា បរិសុទ្ធិ ព្រោះភាពជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយការឃើញការចុតិនិងបដិសន្ធិ (នៃសត្វទាំងឡាយ) ។ ពិតមែន អ្នកណា រមែងឃើញត្រឹមតែសេចក្តីចុតិប៉ុណ្ណោះ មិនឃើញបដិសន្ធិ(នៃសត្វទាំងឡាយ) អ្នកនោះ រមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិ (ឃើញថា ដាច់សូន្យ) ។ អ្នកណា រមែងឃើញត្រឹមតែបដិសន្ធិប៉ុណ្ណោះ មិនឃើញចុតិ (នៃសត្វទាំងឡាយ) អ្នកនោះ រមែងប្រកាន់ដោយទិដ្ឋិគឺ ការប្រាកដឡើងនៃសត្វថ្មី ៗ ។ ចំណែក

អ្នកណា រមែងឃើញទាំងពីរយ៉ាងនោះ អ្នកនោះ រមែងកន្លងហួសទិដ្ឋិទាំងពីរយ៉ាងនោះទៅ ព្រោះហេតុនោះ ទស្សនៈនោះរបស់អ្នកនោះ ទើបឈ្មោះថា ជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ចំណែកព្រះមានព្រះភាគ បានទតឃើញទាំងពីរយ៉ាងនោះហើយ ។ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាបានពោលពាក្យនេះថា ឈ្មោះថា បរិសុទ្ធិ ព្រោះភាពជាហេតុនៃទិដ្ឋិវិសុទ្ធិដោយការឃើញចុតិនិងបដិសន្ធិ (នៃសត្វទាំងឡាយ) ដូច្នេះ ។

## ទិព្វចក្ខុរបស់ព្រះពុទ្ធប្រាសចាកឧបក្កិលេស ១១ យ៉ាង

ម្យ៉ាងទៀត ឈ្មោះថា បរិសុទ្ធិ ព្រោះវៀរចាកឧបក្កិលេស (គ្រឿងសៅហ្មងចិត្ត)១១ យ៉ាង ។ ពិតមែន ទិព្វចក្ខុរបស់ព្រះមានព្រះភាគ វៀរស្រឡះចាកឧបក្កិលេស១១ យ៉ាងហើយ ។ ដូចដែលព្រះអង្គត្រាស់ទុកយ៉ាងនេះថា "ម្នាលអនុរុទ្ធទាំងឡាយ* កាលបើតថាគតដឹងច្បាស់ថា វិចិកិច្ឆាជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការៈ ជាឧបក្កិលេសរបស់ចិត្តហើយ

---

* ក្នុងឧបក្កិលេសសូត្រ មានព្រះអនុរុទ្ធៈ ព្រះនន្ទិយៈ និងព្រះកិម្ពិលៈ ទាំង៣ រូបចូលទៅគាល់, តែព្រះមានព្រះភាគត្រាស់ចេញឈ្មោះព្រះអនុរុទ្ធៈ តែមួយរូប ដែលជាប្រធាន ប្រើពហុវចនៈ ដូច សារីបុត្តទាំងឡាយ ជាដើម ។

ក៏បានលះបង់អមនសិការៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្ត ហើយ ក៏បានលះបង់ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីឆ្អើងឆ្អៃ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីឆ្អើងឆ្អៃ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីក្រវល់ក្រវាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសម្លឹងមើលរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ការ

សម្លឹងមើលរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។"[១] "ម្នាល អនុរុទ្ធទាំងឡាយ តថាគតមិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់ពន្លឺ តែមិនបានឃើញរូបទាំងឡាយទេ ឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺទេ"[២] ដូច្នេះជាដើម ។ ញាណចក្ខុនោះ (របស់ព្រះមានព្រះភាគអង្គនោះ) ឈ្មោះថា បរិសុទ្ធិព្រោះវៀរចាក ឧបក្កិលេស (គ្រឿងសៅហ្មងចិត្ត) ១១ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។ ឈ្មោះថា កន្លងចក្ខុរបស់មនុស្ស ព្រោះឃើញរូបកន្លងហួស ឧបចារៈនៃមនុស្សទៅ ។ម្យ៉ាងទៀត គប្បីជ្រាបថា ឈ្មោះថា អតិក្កន្តមានុសកៈ ព្រោះកន្លងហួសមំសចក្ខុរបស់មនុស្សទៅ ។ ដោយទិព្វចក្ខុនោះដែលបរិសុទ្ធិកន្លងហួសនូវចក្ខុរបស់មនុស្ស ។

ពីរបទថា សត្តេ បស្សាមិ : ក៏ឃើញច្បាស់នូវសត្វទាំងឡាយ សេចក្តីថា តថាគតរមែងមើល គឺរមែងឃើញ បានដល់ ត្រួតមើលសត្វទាំងឡាយ (ដោយទិព្វចក្ខុ) ដូចមនុស្ស មើលដោយមំសចក្ខុដូច្នោះ ។

---

១. មជ្ឈិ. ឧប. ឧបក្កិលេសសូត្រ. ២៧. ១៣៣/១៥៧ ។ ២. មជ្ឈិ. ឧប. ឧបក្កិលេសសូត្រ. ២៧. ១៣២/១៥៥ ។

ក្នុងពាក្យថា **ចវមានេ ឧបបជ្ជមានេ : ដែលចុតិនិងបដិសន្ធិ** ជាដើមនេះ មានវិនិច្ឆ័យដូច្នេះ ៖

អ្នកណា ៗ មិនអាចដើម្បីនឹងឃើញសត្វទាំងឡាយបាន ដោយទិព្វចក្ខុក្នុងខណៈចុតិ ឬក្នុងខណៈបដិសន្ធិ តែសត្វពួកណា អ្នកជិតចុតិថា នឹងចុតិឥឡូវនេះ សត្វទាំងនោះ លោកប្រាថ្នាថា កំពុងនឹងចុតិ និងសត្វពួកណា អ្នកកាន់បដិសន្ធិហើយ ឬអ្នកកើតហើយអម្បាញ់មិញនេះ សត្វទាំងនោះលោកក៏ប្រាថ្នាថា កំពុងនឹងបដិសន្ធិ ព្រះអ្នកមានព្រះភាគទ្រង់សម្តែងថា "តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែលច្យុតិនិងចាប់បដិសន្ធិ" ដូច្នេះ ។

បទថា **ហីនេ : ទាបថោក** សេចក្តីថា អ្នកត្រូវគេតិះដៀល គឺមើលងាយ មើលថោកដោយអំណាចជាតិត្រកូល និងភោគៈជាដើម ដែលឈ្មោះថា ថោកទាប ព្រោះភាពជាអ្នកប្រកបដោយផលវិបាកនៃមោហៈ ។

បទថា **បណីតេ : ឧត្តម** សេចក្តីថា អ្នកផ្ទុយគ្នាអំពីបុគ្គលថោកទាបនោះ ព្រោះភាពជាអ្នកប្រកបដោយផលវិបាកនៃអមោហៈ ។

បទថា **សុវណ្ណេ : មានសណ្ឋានល្អ** សេចក្តីថា អ្នកប្រកបដោយពណ៌សម្បុរ ដែលគួរប្រាថ្នា គួរស្រឡាញ់ និងគួរពេញចិត្ត ព្រោះភាពជា

អ្នកប្រកបដោយផលវិបាកនៃអទោសៈ ។

បទថា **ទុព្វណ្ណោ : មានសណ្ឋានអាក្រក់** សេចក្ដីថា អ្នកប្រកបដោយពណ៌សម្បុរដែលមិនគួរប្រាថ្នា មិនគួរស្រឡាញ់ និងមិនគួរពេញចិត្ត ព្រោះភាពជាអ្នកប្រកបដោយផលវិបាកនៃទោសៈ ។ អធិប្បាយថា អ្នកមានរូបប្លែកខុសពីអ្នកដែលមានរូបស្អាត ដូច្នេះខ្លះ ។

បទថា សុគតេ : **ទៅកាន់សុគតិ** បានដល់ អ្នកទៅកាន់សុគតិ ។ម៉្យាងទៀត បានដល់ អ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន ព្រោះភាពជាអ្នកប្រកបដោយផលវិបាកនៃអលោភៈ ។

បទថា ទុគ្គតេ : **ទៅកាន់ទុគ្គតិ** បានដល់ ទៅកាន់ទុគ្គតិ ។ ម៉្យាងទៀត បានដល់ អ្នកក្រលំបាកគឺ មានបាយនិងទឹកតិច ព្រោះភាពជាអ្នកប្រកបដោយផលវិបាកនៃលោភៈ ។

បទថា យថាកម្មូបគេ : **ដែលអន្ទោលទៅតាមកម្ម** បានដល់ អ្នកចូលដល់តាមកម្មដែលខ្លួនចូលទៅសន្សំទុកហើយ ។

បណ្ដាបទទាំងនោះ ព្រះមានព្រះភាគត្រាស់កិច្ចនៃទិព្វចក្ខុដោយបទដើម ៗថា ចវមានេ ជាដើម ។ មួយទៀត កិច្ចនៃយថាកម្មូបគញ្ញាណ (ញាណជាគ្រឿងដឹងសត្វអ្នកចូលដល់តាមកម្ម) ក៏ជាការដែលត្រាស់ហើយដោយបទនេះ ។

# លំដាប់ការកើតឡើងនៃយថាកម្មូបគញ្ញាណ

ក៏លំដាប់ការកើតឡើងនៃញាណនោះ មានដូចតទៅនេះ ៖

(ភិក្ខុក្នុងព្រះសាសនា[១] នេះ) ចម្រើនអាលោកកសិណ មានមុខឆ្ពោះទៅរកនរកខាងក្រោមហើយ រមែងឃើញសត្វនរកទាំងឡាយ ដែលកំពុងសោយទុក្ខដ៏ធំ ។ ការឃើញនោះចាត់ជាកិច្ចនៃទិព្វចក្ខុដោយពិត ។ លោកនោះដាក់ចិត្តយ៉ាងនេះថា សត្វទាំងនេះ ធ្វើកម្មអ្វីហ្ន៎ ទើបបានរងទុក្ខយ៉ាងនេះ ? លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើងដល់លោកនោះថា ព្រោះធ្វើកម្មឈ្មោះនេះ ។ មួយទៀត លោកនោះចម្រើនអាលោកកសិណ មានមុខឆ្ពោះទៅរកទេវលោកខាងលើហើយ រមែងឃើញសត្វទាំងឡាយក្នុងសួននន្ទវន មិស្សកវន និងបារុសកវនជាដើម អ្នកសោយសម្បត្តិដ៏ធំ សូម្បីការឃើញនោះចាត់ជាកិច្ចនៃទិព្វចក្ខុដោយពិត ។ លោកនោះដាក់ចិត្តយ៉ាងនេះថា "សត្វទាំងនេះធ្វើកម្មអ្វីហ្ន៎ ទើបបានសោយសម្បត្តិយ៉ាងនេះ ?" លំដាប់នោះញាណដែលមានកម្មនោះ ជាអារម្មណ៍ក៏កើតឡើងដល់លោកនោះថា "ព្រោះធ្វើកម្មឈ្មោះ

---

១. ដីកាបរមត្ថមញ្ជូសា ឥមានិ សព្ទនេះជា ឥមិនា ក្នុងវិសុទ្ធិមគ្គក៏ជា ឥមិនា ។

នេះ” ។ នេះឈ្មោះថា **យថាកម្មូបគញ្ញាណ** (ញាណជាគ្រឿងដឹងសត្វអ្នកចូលដល់តាមកម្ម) ។ ឈ្មោះថា ការបរិកម្មផ្សេងមួយសម្រាប់នៃយថាកម្មូបគញ្ញាណនេះក៏មិនមាន ។ យថាកម្មូបគញ្ញាណនេះ មិនមានការបរិកម្មទុកផ្សេងមួយសម្រាប់យ៉ាងណា សម្រាប់ **អនាគតំសញ្ញាណ** ក៏មិនមានយ៉ាងនោះដែរ ។ ពិតមែនញាណទាំងនេះ[២] ដែលជាបាទនៃទិព្វចក្ខុនុ៎ះឯង រមែងសម្រេចព្រមនិងទិព្វចក្ខុនុ៎ះឯង ។

ក្នុងពាក្យថា កាយទុច្ចរិតេន ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ការប្រព្រឹត្តអាក្រក់ ឬការប្រព្រឹត្តវិនាសអស់ ព្រោះមានកិលេសជាសេចក្តីវិនាសអស់ ព្រោះហេតុនោះ ទើបឈ្មោះថា ទុច្ចរិត ។ ការប្រព្រឹត្តអាក្រក់មកកាយ ឬការប្រព្រឹត្តអាក្រក់ដែលកើតអំពីកាយ ព្រោះហេតុនោះ ទើបឈ្មោះថា កាយទុច្ចរិត ។ សម្រាប់វចីទុច្ចរិត និងមនោទុច្ចរិត ក៏គួរជ្រាបដូចអធិប្បាយមកនេះ ។

បទថា សមន្នាគតា **:** ប្រកបដោយ គឺ ជាអ្នកមានព្រម ។

---

២. វិសុទ្ធិមគ្គ មានសព្ទថា ឥធ ភិក្ខុ ទើបបានប្រែទុកតាមនោះ ព្រោះសេចក្តីច្បាស់ល្អ ។

# ការជេរព្រះអរិយៈហាមសួគ៌និងហាមមគ្គ

ពីរបទថា អរិយានំ ឧបវាទកា : និយាយតិះដៀលអរិយបុគ្គលទាំងឡាយ សេចក្ដីថា សត្វទាំងឡាយ អ្នកមានសេចក្ដីឃើញខុស ជាអ្នកប្រាថ្នានូវសេចក្ដីវិនាសមិនមែនប្រយោជន៍ តិះដៀល មានពាក្យអធិប្បាយថា ជេរប្រទេច តិះដៀលព្រះអរិយៈទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធ ដោយហោចទៅ សូម្បីគ្រហស្ថអ្នកជាព្រះសោតាបន្ន ដោយអន្ដិមវត្ថុ ឬដោយការកម្ចាត់នូវគុណចេញ ។

ក្នុងការតិះដៀល ២ យ៉ាងនោះ បុគ្គលអ្នកពោលថា សមណធម៌របស់លោកទាំងនោះ មិនមាន, លោកទាំងនោះ មិនមែនសមណៈ ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា តិះដៀលដោយអន្ដិមវត្ថុ ។ បុគ្គលអ្នកពោលថា ឈានក្ដី វិមោក្ខក្ដី មគ្គក្ដី ផលក្ដី របស់លោកទាំងនោះ មិនមាន ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា តិះដៀលដោយការកម្ចាត់នូវគុណចេញ ។ ក៏អ្នកនោះគប្បីតិះដៀលទាំងដែលកំពុងដឹងខ្លួនក៏ដោយ មិនដឹងក៏ដោយ រមែងឈ្មោះថា ជាអ្នកតិះដៀលព្រះអរិយៈពិត សូម្បីដោយប្រការទាំងពីរ ។ កម្ម ( គឺ ការតិះដៀលព្រះអរិយៈ ) ជាកម្មធ្ងន់ ជាសគ្គាវរណៈ ( ហាមសួគ៌ ) ផង ជាមគ្គាវរណៈ ( ហាមមគ្គ ) ផង

## រឿងភិក្ខុកម្លោះតិះដៀលព្រះអរិយៈជាន់ខ្ពស់

ក៏ដើម្បីប្រកាសអំពីការជេរជាកម្មធ្ងន់នោះ ទើបព្រះបូរាណាចារ្យទាំងឡាយ នាំរឿងនេះមកជាឧទាហរណ៍ ដូចតទៅនេះ ៖

បានឮថា ព្រះថេរៈមួយរូប និងភិក្ខុកម្លោះមួយរូប ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកកន្លែងណាមួយ ។ លោកទាំង ២ នោះ បានយាគូក្តៅប្រមាណមួយបោយក្នុងផ្ទះដំបូងនុ៎ះឯង ។ តែព្រះថេរៈកើតខ្យល់សៀតពោះឡើង ។ លោកគិតថា "យាគូនេះ ជារបស់សប្បាយដល់យើង យើងនឹងឆាន់យាគូនោះមុនវាត្រជាក់" ទើបលោកអង្គុយឆាន់យាគូនោះលើកំណាត់ឈើដែលពួកមនុស្សអូសមកទុក ដើម្បីត្រូវការធ្វើធរណីទ្វារ ។ ភិក្ខុកម្លោះក្រៅនេះ បានរង្កៀសព្រះថេរៈនោះ ដោយគិតថា "ព្រះថេរៈចាស់នេះ ឃ្លានខ្លាំងណាស់ហ្ន៎ ធ្វើឱ្យយើងបានទទួលសេចក្តីអៀនខ្មាស" ។ ព្រះថេរៈត្រាច់ទៅក្នុងស្រុកហើយត្រឡប់ទៅកាន់វិហារ បាននិយាយចំពោះភិក្ខុកម្លោះថា "អាវុសោ ទីពឹងក្នុងព្រះសាសនានេះរបស់អាវុសោ មានឬទេ ?"

ភិក្ខុកម្លោះ ឆ្លើយប្រាប់ថា "មាន លោកម្ចាស់ ខ្ញុំព្រះករុណាជាព្រះសោតាបន្ន" ។ ព្រះថេរៈ និយាយជាស់តឿនថា "អាវុសោ បើដូច្នោះ

អ្នកមិនបានធ្វើសេចក្ដីព្យាយាម ដើម្បីត្រូវការមគ្គជាន់ខ្ពស់ឡើងទៅឬ ?* ព្រោះព្រះវីណាស្រេព លោកបានតិះដៀលហើយ" ។ ភិក្ខុកម្លោះរូបនោះ បានឱ្យព្រះថេរៈនោះអត់ទោសហើយ ព្រោះហេតុនោះកម្មនោះ របស់ភិក្ខុកម្លោះរូបនោះ ក៏បានត្រឡប់ជាប្រក្រតីដូចដើមហើយ ។

## វិធីសូមខមាដើម្បីឱ្យអត់ទោសឱ្យក្នុងការតិះដៀល

ព្រោះដូច្នោះ អ្នកណាសូម្បីដទៃ តិះដៀលព្រះអរិយៈ អ្នកនោះទៅហើយបើលោកចាស់ជាងខ្លួនសោត[១] ក៏គប្បីឱ្យលោកអត់ទោសឱ្យដោយទូលលោកថា "ខ្ញុំព្រះករុណាបានពោលពាក្យនេះ និងពាក្យនេះចំពោះលោកម្ចាស់ហើយ សូមលោកម្ចាស់បានអត់ទោសនោះឱ្យខ្ញុំព្រះករុណាផងចុះ" បើលោកខ្ចីជាងខ្លួនសោត[២] សំពះលោកហើយអង្គុយ

---

១. ក្នុងវិសុទ្ធិមគ្គ មានដូច្នេះគឺ តេនហាវុសោ ឧបរិមគ្គត្ថាយ វាយាមំ មា អកាសីតិ. កស្មា ភន្តេតិ. ឧណាសរេ តយា វ ឧបវទិតោតិ. : ព្រះថេរៈ និយាយដាស់តឿនថា អាវុសោ បើដូច្នោះគុណមិនបានធ្វើសេចក្ដីព្យាយាម ដើម្បីត្រូវការមគ្គខាងខ្ពស់ឡើងទៅឬ ? ភិក្ខុកម្លោះ ឆ្លើយប្រាប់ថា ព្រោះហេតុអ្វី លោកម្ចាស់ ? ព្រះថេរៈនិយាយថា ព្រោះព្រះវីណាស្រេព គុណបាន តិះដៀលហើយ កស្មា ភន្តេតិ ក្នុងសាមន្តនេះ គួរនឹងធ្លាក់ទៅ ។ ១. ភិក្ខុចាស់ដែលខុស សូមទោសភិក្ខុខ្ចី ។ ២. ភិក្ខុខ្ចីដែលខុស សូមខមាទោសភិក្ខុចាស់ ។

ប្រហោងផ្គងអញ្ជលី គប្បីសូមឱ្យលោកអត់ទោសឱ្យ ដោយទូលលោកថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានពោលពាក្យនេះនិងពាក្យនេះ ទឹងលោកហើយ សូមលោកអត់ទោសនោះឱ្យដល់ខ្ញុំព្រះករុណាផងចុះ" បើលោកមិនព្រមអត់ទោសឱ្យ ឬលោកជៀសទៅកាន់ទិស (ដទៃ) គប្បីទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ដែលនៅក្នុងវិហារនោះ, បើលោកចាស់ជាងខ្លួនសោត គប្បីឈរសូមខមាទោស បើលោកខ្ចីជាងខ្លួនសោត ក៏គប្បីអង្គុយប្រហោងផ្គងអញ្ជលី ឱ្យលោកជួយអត់ទោសឱ្យ គប្បីក្រាបទូលឱ្យលោកអត់ទោសយ៉ាងនេះថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានពោលពាក្យនេះ និងពាក្យនេះនឹងលោកអ្នកមានអាយុឈ្មោះឯណោះហើយ សូមលោកអ្នកមានអាយុរូបនោះ អត់ទោសឱ្យដល់ខ្ញុំព្រះករុណាផងចុះ" បើព្រះអរិយៈរូបនោះ បរិនិព្វានហើយសោត, គួរទៅកាន់ស្ថានទីតាំងគ្រែដែលលោកបរិនិព្វាន សូម្បីទៅដរាបដល់ព្រៃជាទីចោលសាកសពហើយ គប្បីឱ្យអត់ទោសឱ្យកាលខ្លួនបានធ្វើហើយយ៉ាងនេះ កម្មគឺ ការតិះដៀលនោះ ក៏មិនជាសគ្គាវរណៈនិងមិនជាមគ្គាវរណៈ (មិនហាមទាំងសួគ៌ទាំងមគ្គ) រមែងត្រឡប់ជាប្រក្រតីដូចដើមមែនពិត ។

## ការតិះដៀលព្រះអរិយៈ មានទោសដូចនឹងអនន្តរិយកម្ម

បទថា មិច្ឆាទិដ្ឋិកា : ជាមិច្ឆាទិដ្ឋិ គឺ មានសេចក្ដីឃើញវិបរិត ។

បទថា មិច្ឆាទិដ្ឋិកម្មសមាទានា : ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សេចក្ដីថា ក៏ជនពួកណា ឱ្យជនសូម្បីពួកដទៃសមាទាន បណ្ដាកម្មមានកាយកម្មជាដើម ដែលមានមិច្ឆាទិដ្ឋិជាមូល ។ អ្នកទាំងនោះ ឈ្មោះថាមានកម្មមានប្រភេទផ្សេង ៗ ដែលខ្លួនសមាទានកាន់យកហើយ ដោយអំណាចមិច្ឆាទិដ្ឋិ ។ ក៏បណ្ដាអរិយូបវាទនិងមិច្ឆាទិដ្ឋិទាំងនោះ សូម្បីកាលលោកសង្គ្រោះអរិយូបវាទចូលដោយវចីទុច្ចរិតស័ព្ទនុ៎ះឯង និងមិច្ឆាទិដ្ឋិចូលដោយមនោទុច្ចរិតស័ព្ទដូចគ្នាហើយ ការពោលដល់កម្មទាំង ២ នេះដដែលទៀត គប្បីជ្រាបថា មានការសម្ដែងដល់កម្មទាំង ២ នោះ ដែលមានទោសច្រើនជាប្រយោជន៍ ។ ពិតមែន អរិយូបវាទ មានទោសច្រើនដូចនឹងអនន្តរិយកម្ម ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលសារីបុត្រ ភិក្ខុដែលបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផល ក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ, ម្នាលសារីបុត្រ តថាគតពោលនូវហេតុ (នៃការមិនលះបង់នូវវាចាជាដើមរបស់បុគ្គលនោះ) ថា មានឧបមេយ្យ

ប្រហែលគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅវេទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះឯង"[១] ។ ក៏កម្មយ៉ាងដទៃឈ្មោះថា មានទោសច្រើនជាងមិច្ឆាទិដ្ឋិ រមែងមិនមាន ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលមានទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង"[២] ដូច្នេះ ។

ពីរបទថា កាយស្ស ភេទា : លុះដល់រំលាងខន្ធ សេចក្តីថា ព្រោះលះបង់ឧបាទិន្នក្ខន្ធចេញ ( ខន្ធដែលមានកិលេសចូលទៅអាស្រ័យ ) ។

បទថា បរម្មរណា : បន្ទាប់ពីមរណៈ សេចក្តីថា តាំងពីការកាន់យកខន្ធដែលកើតឡើងក្នុងលំដាប់នៃការលះបង់នោះ ។

ម្យ៉ាងទៀត ពីរបទថា កាយស្ស ភេទា គឺ ព្រោះសេចក្តីដាច់សូន្យនៃជីវិតិន្ទ្រិយ ។ បទថា បរម្មរណា គឺ ក្រោយពីចុតិចិត្ត ។

---

១. មជ្ឈិ. មូល. មហាសីហនាទសូត្រ. ២០. ១៦៦/២៧១ ។ ២. អង្គុ. ឯក. យោធាជីវវគ្គ. ៤០. ១៩៤/៧៦ ។

# អត្ថាធិប្បាយ នរក ឈ្មោះថា អបាយជាដើម

ពាក្យទាំងអស់ជាដើមយ៉ាងនេះថា **អបាយំ** ជាវេវចនៈនៃពាក្យថា និរយៈ ។ ពិតមែន និរយៈ ឈ្មោះថា អបាយ ព្រោះទៅប្រាសចាកសេចក្តីចម្រើន ដែលសន្មតថា ជាបុណ្យដែលជាហេតុនៃសួគ៌និងនិព្វាន ឬព្រោះមិនមានសេចក្តីចម្រើនឡើងនៃសេចក្តីសុខ ។

ដែលឈ្មោះថា ទុគ្គតិ ព្រោះអត្ថថា មានគតិនៃទុក្ខជាទីពឹង ។ ម្យ៉ាងទៀតឈ្មោះថា **ទុគ្គតិ** ព្រោះអត្ថថា មានគតិដែលកើតព្រោះកម្មដ៏អាក្រក់សាហាវ ព្រោះមានទោសច្រើន ។

ដែលឈ្មោះថា **វិនិបាត** ព្រោះអត្ថថា ជាស្ថានទីរបស់ពួកសត្វដែលពេញចិត្តធ្វើអាក្រក់ធ្លាក់ទៅឥតមានអំណាច ។ ម្យ៉ាងទៀត ឈ្មោះថា វិនិបាត ព្រោះអត្ថថា ជាស្ថានទីដែលពួកសត្វអ្នកកំពុងវិនាស មានអវយវៈតូចធំបែកខ្ចាយធ្លាក់ទៅ ។

ដែលឈ្មោះថា និរយៈ ព្រោះអត្ថថា ជាស្ថានទីមិនមានសេចក្តីចម្រើនដែលដឹងគ្នាថា សេចក្តីត្រេកអរ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់សម្តែងកំណើតសត្វតិរច្ឆានដោយអបាយសព្ទ ។ ពិតមែន កំណើតសត្វតិរច្ឆានចាត់ជាអបាយ ព្រោះប្រាសចាកសុគតិ តែមិនចាត់ជាទុគ្គតិ

ព្រោះជាស្ថានទីកើតនៃសត្វទាំងឡាយមានស្តេចនាគជាដើម ដែលមានស័ក្តាច្រើន ។ ព្រះមានព្រះភាគទ្រង់សម្តែងបេត្តវិស័យ ដោយទុគតិស័ព្ទ ។ ពិតមែន បេត្តវិស័យនោះចាត់ជាអបាយផង ជាទុគ្គតិផង ព្រោះប្រាសចាកអំពីសុគតិទៅ និងព្រោះជាគតិនៃទុក្ខ, តែមិនជាវិនិបាត ព្រោះមិនមានសេចក្តីធ្លាក់ទៅ ដូចនឹងពួកអសុរ ។ ពិតមែន សូម្បីវិមានទាំងឡាយ រមែងកើតឡើងដល់ពួកប្រេតអ្នកមានឫទ្ធិច្រើន ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអសុរកាយ ដោយវិនិបាតស័ព្ទ ។ សេចក្តីពិតអសុរកាយនោះ លោកហៅថា ជាអបាយផង ជាទុគ្គតិផង ព្រោះអត្ថតាមដែលពោលមកហើយនិងថា ជាវិនិបាត ព្រោះជាអ្នកមានសេចក្តីធ្លាក់ទៅចាកពីការកើតឡើងនៃសម្បត្តិទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់សម្តែងនរកទុំះឯង ដែលមានអនេកប្រការមានអវិចីជាដើម ដោយនិរយស័ព្ទ ។

បទថា ឧបប្បន្នា **: កើតឡើង** គឺ ចូលដល់ហើយ អធិប្បាយថា កើតឡើងហើយក្នុងនរកនោះ ។ សុក្កបក្ខ (ចំណែកស) គប្បីជ្រាបដោយបរិយាយដែលប្លែកគ្នាអំពីដែលពោលហើយ ។ ចំណែកសេចក្តីប្លែកគ្នាមានដូចតទៅនេះ : សូម្បីគតិនៃមនុស្ស លោកក៏សង្គ្រោះយក

ដោយសុគតិសព្ទ ក្នុងសុក្កបក្ខនេះ ។ ទេវគតិប៉ុណ្ណោះលោកសង្គ្រោះចូលដោយសគ្គសព្ទ ។

ក្នុង៣ បទថា សុគតី សគ្គំ លោកំ : ក្នុងលោក គឺ សុគតិ និងស្ថានសួគ, នោះ មានសេចក្តីចំពោះពាក្យដូច្នេះគឺ ៖

ឈ្មោះថា សុគតិ ព្រោះអត្ថថា ជាគតិល្អ ។ ឈ្មោះថា សគ្គៈ ព្រោះអត្ថថា ប្រសើរលើសដោយល្អ ដោយអារម្មណ៍ទាំងឡាយមានរូបជាដើម ។ សុគតិ និងសួគ៌ទាំងអស់នោះ ឈ្មោះថា លោក ព្រោះអត្ថថា វិនាសនិងបែកធ្លាយទៅ ។

វិជ្ជាគឺ ទិព្វចក្ខុញាណ ឈ្មោះថា វិជ្ជា ។ អវិជ្ជា ដែលជាគ្រឿងបិទបាំងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា អវិជ្ជា ។ ពាក្យដែលសល់មានន័យដូចពោលហើយនុ៎ះឯង ដោយប្រការដូច្នេះ ។

ទិព្វចក្ខុកថា ចប់

## អាសវក្ខយញ្ញាណកថា

ពិតមែន ក្នុងកថា ពោលអំពីទិព្វចក្ខុញ្ញាណនេះ មានសេចក្ដីប្លែកគ្នាដូចតទៅនេះ ។ ក្នុងកថា ពោលអំពីបុព្វេនិវាស ខ្ញុំព្រះករុណាពោលទុកហើយថា ព្រោះទម្លាយសំបកពង គឺ អវិជ្ជា ដែលបិទបាំងខន្ធដែលខ្ញុំនធ្លាប់នៅហើយក្នុងកាលមុន ដោយចុងចំពុះ គឺបុព្វេនិវាសានុស្សតិញ្ញាណ ដូច្នេះ យ៉ាងណា ក្នុងកថា ពោលអំពីទិព្វចក្ខុញ្ញាណនេះ ក៏គួរពោលថា ព្រោះទម្លាយសំបកពង គឺ អវិជ្ជាដែលបិទបាំងនូវចុតិ និងបដិសន្ធិ ( របស់សត្វទាំងឡាយ ) ដោយចុងចំពុះ គឺ ចុតូបបាតញ្ញាណនេះ ដូច្នោះ ។

ក្នុងពាក្យថា **សោ ឯវំ សមាហិតេ ចិត្តេ : កាលដែលចិត្តខាប់ខួន... យ៉ាងនេះហើយ** តថាគត នេះ គួរជ្រាបចិត្តក្នុងចតុត្ថជ្ឈានដែលជាបាទនៃវិបស្សនា ( តទៅ ) ។

ពីរបទថា **អាសវានំ ខយញ្ញាណាយ : ញាណជាហេតុឱ្យបានអស់ទៅនៃអាសវៈទាំងឡាយ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ។ ពិតមែន អរហត្តមគ្គ លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះធ្វើអាសវៈឱ្យវិនាសទៅ ។ ក៏ញាណនេះ ក្នុង

អរហត្តមគ្គនោះ លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះសេចក្ដីដែលញាណនោះជាធម៌រាប់បញ្ចូលហើយ ក្នុងមគ្គនោះ ដោយប្រការដូច្នេះ ។

ពីរបទថា ចិត្តំ អភិនិន្នាមេសឹ : តថាគតបានបង្អោនចិត្តចំពោះទៅ សេចក្ដីថា តថាគតបានបង្អោនវិបស្សនាចិត្តទៅចំពោះហើយ ។

ក្នុងពាក្យជាដើមយ៉ាងនេះថា សោ ឥទំ ទុក្ខំ យថាភូតំ អព្ភញ្ញាសឹ : តថាគតក៏ដឹងប្រាកដតាមពិតថា នេះជាទុក្ខ គប្បីជ្រាប សេចក្ដីយ៉ាងនេះថា យើងបានដឹង គឺ ជ្រាប បានដល់ ចាក់ធ្លុះហើយនូវទុក្ខសច្ចទាំងអស់ តាមសភាវៈពិត ដោយការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតថា ទុក្ខមានប្រមាណប៉ុណ្ណេះមិនមានទុក្ខ ក្រៅលែងឡើងទៅជាងនេះ និងយើងបានដឹង គឺ ជ្រាប បានដល់ ចាក់ធ្លុះហើយ នូវតណ្ហាដែលញុាំងទុក្ខនោះឱ្យកើតតាមសភាវៈពិត ដោយការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតថា នេះ ទុក្ខសមុទ័យ សូម្បីទុក្ខនិងតណ្ហាទាំង ២ នោះ ទៅដល់ស្ថានទីណា រមែងរលត់ទៅ យើងក៏បានដឹង គឺ បានជ្រាប បានដល់ ចាក់ធ្លុះហើយ នូវស្ថានទីនោះ គឺព្រះនិព្វាន ដែលប្រព្រឹត្តទៅមិនបាននៃទុក្ខ និង តណ្ហានោះ តាមសភាវៈពិត ដោយការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតថា នេះទុក្ខនិរោធ និងយើងក៏បានដឹង គឺបានជ្រាប បានដល់

ចាក់ធ្លុះហើយ នូវអរិយមគ្គ ដែលជាហេតុឱ្យសម្រេចទុក្ខនិរោធនោះ តាមសភាវៈពិត ដោយការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។

លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសច្ចៈទាំងឡាយ ដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលទឹងទ្រង់សម្ដែងដោយអំណាចកិលេសដោយបរិយាយ ទើបត្រាស់ពាក្យជាដើមថា ឥមេ អាសវា ដូច្នេះ ។

ប្រើនបទថា តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ : ដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ សេចក្ដីថា កាលយើងនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ។ ព្រះមានព្រះភាគ បានត្រាស់មគ្គដែលដល់ទីបំផុត ព្រមទាំងវិបស្សនាទុក (ក្នុងបទទាំងនោះ) ។

បទថា កាមាសវា : កាមាសវៈ គឺ ចាកកាមាសវៈ ។ ព្រះអង្គទ្រង់សម្ដែងខណៈនៃផលទុកដោយពាក្យថា រួចផុតហើយនេះ ពិតមែនចិត្ត រមែងរួចផុត ក្នុងខណៈនៃមគ្គ ក្នុងខណៈនៃផលចាត់ថា រួចផុតហើយ ទ្រង់សម្ដែងបច្ចវេក្ខណញ្ញាណទុកដោយពាក្យនេះថា កាលចិត្តរួចផុតហើយ ក៏បានមានញាណដឹងថា រួចផុតហើយ ដូច្នេះ ទ្រង់សម្ដែងភូមិនៃបច្ចវេក្ខណញ្ញាណនោះ ទុកដោយពាក្យជាដើមថា ជាតិអស់ហើយ

ពិតមែន ព្រះមានព្រះភាគ កាលទ្រង់ពិចារណាដោយព្រះញាណនោះ ក៏ទ្រង់បានដឹងហើយនូវទុក្ខសច្ចជាដើមថា ជាតិអស់ហើយ ។

សួរថា ក៏ជាតិណារបស់ព្រះមានព្រះភាគ ឈ្មោះថា អស់ហើយ និងព្រះអង្គទ្រង់ដឹងជាតិនោះបានយ៉ាងណា ?

ខ្ញុំព្រះករុណានឹងឆ្លើយតទៅ ៖

ជាតិដែលជាអតីតរបស់ព្រះអង្គ ឈ្មោះថា នៅមិនអស់ទៅ (ដោយមគ្គភាវនា) ព្រោះជាតិនោះអស់ទៅហើយ ក្នុងកាលមុន, ជាតិដែលជាអនាគតរបស់ព្រះអង្គ ឈ្មោះថា មិនទាន់អស់ទៅ ព្រោះមិនមានសេចក្តីព្យាយាមក្នុងអនាគត, ជាតិដែលជាបច្ចុប្បន្នរបស់ព្រះអង្គ ក៏ឈ្មោះថា មិនទាន់អស់ទៅ ព្រោះជាតិនៅមាន ។ ចំណែកជាតិណាដែលផ្សេងដោយប្រភេទគឺ ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ដែលនឹងគប្បីកើតឡើងក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព ព្រោះមិនទាន់បានអប់រំមគ្គ ជាតិនោះចាត់ថា អស់ទៅហើយ ព្រោះដល់ការមិនកើតឡើងជាធម្មតាហេតុមានមគ្គដែលបានអប់រំហើយ, លុះព្រះមានព្រះភាគអង្គនោះ ទ្រង់ពិចារណាដល់កិលេស ដែលព្រះអង្គទ្រង់លះដោយ

មគ្គភាវនាហើយ ទ្រង់ជ្រាបថា កាលមិនមានកិលេស កម្មសម្ពន្ធ័នៅមាន ក៏មិនមានបដិសន្ធិតទៅ ទើបឈ្មោះថា ទ្រង់បានដឹងជាតិនោះហើយ ។

បទថា វុសិតំ សេចក្តីថា (ព្រហ្មចរិយ) ដែលតថាគតនៅហើយ គឺ នៅចប់ហើយ ។ អធិប្បាយថា ដែលតថាគតធ្វើ ប្រព្រឹត្តឱ្យសម្រេចអស់ហើយ ។

បទថា ព្រហ្មចរិយំ បានដល់ មគ្គព្រហ្មចរិយ ។ ពិតមែន ព្រះសេក្ខបុគ្គល ៧ ពួក រួមជាមួយកល្យាណបុថុជ្ជន ដែលឈ្មោះថា រមែងនៅអប់រំព្រហ្មចរិយ ។ ព្រះខីណាស្រពមានការនៅព្រហ្មចរិយចប់ហើយ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ពិចារណាដល់ព្រហ្មចរិយវាសរបស់ព្រះអង្គ ក៏ទ្រង់បានដឹងហើយថា ព្រហ្មចរិយដែលតថាគតនៅចប់ហើយ ។

ពីរបទថា កតំ ករណីយំ : សោឡសកិច្ចអញ្ញក៏បានធ្វើរួចហើយ សេចក្តីថា កិច្ចសម្ពន្ធ័ ១៦ យ៉ាង តថាគតធ្វើឱ្យចប់ស្រេចហើយ ដោយអំណាចនៃការកំណត់ដឹង ការលះ ការធ្វើឱ្យច្បាស់ និងការអប់រំឱ្យចម្រើន ដោយមគ្គ ៤ ក្នុងសច្ចៈទាំង ៤ ។ ពិតមែន ព្រះសេក្ខបុគ្គល ៧ ពួកមានកល្យាណបុថុជ្ជនជាដើម នៅធ្វើកិច្ចនោះនៅឡើយ ។ ព្រះ

ទីណាស្រេចមានកិច្ចដែលគួរធ្វើ ដែលខ្លួនធ្វើរួចហើយ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ពិចារណាដល់កិច្ចដែលគួរធ្វើរបស់ព្រះអង្គ ក៏ទ្រង់បានដឹងថា កិច្ចដែលគួរធ្វើយើងធ្វើសម្រេចហើយ ។

ប្រើនបទថា ឆាបរំ ឥត្ថត្តាយ : កិច្ចដទៃដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់បានដឹងហើយថា ឥឡូវនេះ កិច្ចគឺ ការអប់រំដោយមគ្គ ដើម្បីភាពជាយ៉ាងនេះទៀត គឺដើម្បីសេចក្ដីចម្រើននៃសោឡសកិច្ច ឬដើម្បីសេចក្ដីអស់ទៅនៃកិលេសយ៉ាងនេះរបស់តថាគត រមែងមិនមាន ។

ឥឡូវនេះ ព្រះអង្គកាលនឹងទ្រង់សម្ដែងការសម្រេចញាណ ដែលជាហេតុអស់ទៅនៃអាសវៈទាំងឡាយនោះ ដែលបច្ចវេក្ខណញ្ញាណផ្គងហើយយ៉ាងនោះដល់ព្រាហ្មណ៍ ទើបត្រាស់ព្រះតម្រាស់ថា អយំ ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិធា អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា : ម្នាលព្រាហ្មណ៍ ការត្រាស់ដឹងរបស់តថាគត ជាគម្រប់ ៣ នេះ ដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកពងដូច្នេះ ។

ក្នុងបទទាំងនោះ សេចក្តីដឹងដែលសម្បយុត្តដោយអរហត្តមគ្គញ្ញាណ ឈ្មោះថា វិជ្ជា ការមិនដឹងដែលបិទបាំងសច្ចៈ ៤ ឈ្មោះថា អវិជ្ជា ។ ពាក្យដែលសល់មានន័យដូចពោលហើយនោះឯង ។

## ព្រះអង្គទ្រង់កើតមុនអ្នកណាទាំងអស់ដោយគុណធម៌

ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

ក្នុងពាក្យថា អយំ ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិទា អហោសិ នេះ មានអធិប្បាយថា ម្នាលព្រាហ្មណ៍ ការញាស់លើកទី ៣ គឺ ការចេញ (ពីសម្បក)លើកទី ៣ បានដល់ ការកើតជាអរិយៈលើកទី ៣ នេះឯង បានមានហើយដល់តថាគត ព្រោះបានទម្លាយសំបកពងគឺ អវិជ្ជា ដែលបិទបាំងសច្ចៈ ៤ ដោយចុងចំពុះគឺ អាសវក្ខយញ្ញាណដូចការញាស់ចេញ គឺ ការចេញទៅ បានដល់ ការកើតនៃពួកកូនមាន់អំពីសំបកពងនោះ ក្នុងកាលខាងក្រោយ ព្រោះបានទម្លាយសំបកពង ដោយចុងចំពុះ ឬដោយចុងក្រចកជើងដូច្នោះ ។

សួរថា ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះបំណងអ្វី ទុកដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ?

ឆ្លើយថា ទ្រង់សម្តែងព្រះបំណាងនេះទុកយ៉ាងថា ម្នាលព្រាហ្មណ៍ ក៏កូនមាន់នោះ បានទម្លាយសំបកពងហើយ ចេញទៅចាកពីសំបកពងនោះ រមែងឈ្មោះថា កើតគ្រាតែមួយប៉ុណ្ណោះ ចំណែកតថាគតបានទម្លាយសំបកពងគឺ អវិជ្ជា ដែលបិទបាំងខន្ធ ដែលយើងធ្លាប់អាស្រ័យនៅក្នុងកាលមុនហើយ ឈ្មោះថា កើតហើយគ្រាដំបូងតែម្តងព្រោះវិជ្ជាគឺ បុព្វេនិវាសានុស្សតិញ្ញាណ តពីនោះបានទម្លាយសំបកពង គឺអវិជ្ជាដែលបិទបាំងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា កើតហើយលើកទី ២ ព្រោះវិជ្ជា គឺ ទិព្វចក្ខុញ្ញាណ តមកទៀត បានទម្លាយសំបកពងគឺអវិជ្ជាដែលបិទបាំងសច្ចៈ ៤ ឈ្មោះថា កើតហើយលើកទី ៣ ព្រោះវិជ្ជា គឺ អាសវក្ខយញ្ញាណយើងជាអ្នកឈ្មោះថា កើតហើយ ៣ គ្រា ព្រោះវិជ្ជាទាំង ៣ ដូចពណ៌នាមកដូច្នេះ និងជាតិរបស់យើងនោះ ទើបជាអរិយៈ គឺ ល្អស្អាតបរិសុទ្ធិ ។

មួយទៀត ព្រះមានព្រះភាគ កាលទ្រង់សម្តែងយ៉ាងនេះ ទ្រង់ប្រកាសអតីតង្សញ្ញាណ ដោយបុព្វេនិវាសញ្ញាណ បច្ចុប្បន្នំសញ្ញាណ និងអនាគតង្សញ្ញាណ ដោយទិព្វចក្ខុ ព្រះគុណដែលជាលោកិយៈ និងលោកុត្តរៈទាំងអស់ ដោយអាសវក្ខយញ្ញាណគ្រាទ្រង់ប្រកាសគុណ គឺ ព្រះសព្វញ្ញុទាំងអស់ដោយវិជ្ជា ៣ ដូចដែលពោលមកហើយ ទើបទ្រង់

បានសម្តែងប្រការដែលព្រះអង្គជាអ្នកចម្រើន និងប្រសើរបំផុតដោយអរិយជាតិដល់ព្រាហ្មណ៍ ដោយប្រការដូច្នេះ ។[១]

អាសវក្ខយញាណកថា ចប់

---

១. បានប្រែបន្ថែមគ្រប់យ៉ាងក្នុងដីកាសារត្ថទីបនី ។

## វេរញ្ជព្រាហ្មណ៍បានលើកដឹងខ្លួន

[៤] ក្នុងពាក្យថា ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច : កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគវិញ នេះ មានអធិប្បាយថា កាលព្រះមានព្រះភាគ អ្នកទ្រង់អនុគ្រោះដល់លោក នឹងទ្រង់អនុគ្រោះព្រាហ្មណ៍បានត្រាស់សេចក្តីដែលព្រះអង្គជាច្បង និងប្រសើរបំផុត ដោយអរិយជាតិ សូម្បីដែលគួរបិទបាំង ដោយធម្មទេសនាដែលប្រកាសវិជ្ជា ៣ ដោយន័យដូចពោលមកយ៉ាងនេះ វេរញ្ជព្រាហ្មណ៍ មានកាយនិងចិត្តពោរពេញទៅដោយបីតិផ្សាយជ្រួតជ្រាបទៅ (ក្នុងសរីរៈ) ដឹងសេចក្តីដែលព្រះមានព្រះភាគ ជាច្បងនិងប្រសើរបំផុត ដោយអរិយជាតិនោះ ទើបតិះដៀលខ្លួនឯងថា "យើងបានពោលជាមួយនឹងព្រះសព្វញ្ញូ ដែលទ្រង់ជាបុគ្គលច្បង ជាបុគ្គលប្រសើរជាងសត្វលោកទាំងអស់ ទ្រង់ប្រកបដោយព្រះគុណទាំងពួង ប្រាកដដូច្នេះថា ទ្រង់មិនធ្វើកម្មមានការក្រាបថ្វាយបង្គំជាដើមដល់ជនពួកដទៃ នែអ្នកចង្រៃ គួរតិះដៀលសេចក្តីល្ងង់ដោយពិត" ដូច្នេះ ទើបបន្ទន់ចិត្តចុះថា "ឥឡូវនេះ ព្រះមានព្រះភាគព្រះអង្គនេះឈ្មោះថា ជាចម្បងបំផុតក្នុងលោក ព្រោះអត្ថថា ជាអ្នកកើតមុន ដោយអរិយជាតិ ឈ្មោះថា ជាអ្នកប្រសើរបំផុតព្រោះអត្ថថា មិនមានអ្នកស្មើ

ដោយព្រះគុណទាំងពួង ហើយបានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា "ព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរជាងមនុស្ស" ក៏ឯគ្រាក្រាបទូលយ៉ាងនោះហើយ កាលនឹងសរសើរព្រះធម្មទេសនារបស់ព្រះមានព្រះភាគនោះទៀត ទើបបានក្រាបទូលថា "បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់"ដូច្នេះជាដើម ។

## អធិប្បាយអភិក្កន្តសព្ទ ចុះក្នុងអត្ថ ៤ និង ៩ យ៉ាង

ក្នុងពាក្យថា អភិក្កន្តំ : ក្រៃលែងណាស់ ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖ អភិក្កន្តសព្ទនេះ រមែងប្រាកដក្នុងអត្ថ គឺ ខយៈ (សេចក្ដីអស់ទៅ) សុន្ទរៈ (សេចក្ដីល្អ) អភិរូបៈ (រូបល្អ) និងអព្ភនុមោទនៈ (សេចក្ដីសរសើរ) ។

ពិតមែន អភិក្កន្តសព្ទ ប្រាកដក្នុងសេចក្ដីអស់ទៅ ក្នុងប្រយោគទាំងឡាយជាដើមថា "**អភិក្កន្តា ភន្តេ, រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** : បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ"[១] ។

១. អង្គុ. អដ្ឋ. មហាវគ្គ. ៤៨. ២០/១០០ ។

អភិក្កន្តសព្ទ ប្រាកដក្នុងសេចក្ដីល្អ ក្នុងប្រយោគទាំងឡាយជាដើមថា "អយំ មេ បុគ្គលោ ខមតិ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច : បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ល្អជាងផង ប្រណីតជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ"[១] ។

អភិក្កន្តសព្ទ ប្រាកដក្នុងរូបល្អ ក្នុងប្រយោគទាំងឡាយជាដើមថា

"កោ មេ វន្ទតិ ឥទ្ធិយា យសសា ជលំ
អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា
អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មាន
សម្បុរដ៏ល្អ ញ៉ាំងទិសទាំងពួងឱ្យភ្លឺ មកថ្វាយបង្គំ
បាទានៃតថាគត"[២]

អភិក្កន្តសព្ទ ប្រាកដក្នុងសេចក្ដីសរសើរ ក្នុងប្រយោគទាំងឡាយជាដើមថា "អភិក្កន្តំ ភន្តេ : បពិត្រព្រះអង្គដ៏ចម្រើន (ភាសិតព្រះអង្គ) ពីរោះពេកណាស់"[៣] ។

សូម្បីក្នុងអធិការនេះ អភិក្កន្តសព្ទ ក៏ប្រាកដក្នុងសេចក្ដីសរសើរ

---

១. អង្គុ. ចតុ. អសុរវគ្គ. ៤២. ១០១/២៤៩ ។ ២. ខុទ្ទ. វិមា. មណ្ឌូកទេវបុត្តវិមាន. ៥៥. ៥១/១១០ ។ ៣. ទីឃ. សីល. សាមញ្ញផលសូត្រ. ១៤. ១៣៩-២១១ ។

ដោយពិត ។ គប្បីជ្រាបសន្និដ្ឋានថា ក៏ព្រោះអភិក្កន្តសព្ទ ប្រាកដក្នុងសេចក្តីសរសើរ ដូច្នោះ វេរញ្ជព្រាហ្មណ៍ ទើបពោលអធិប្បាយទុកថា ល្អណាស់ ៗ ព្រះគោតមដ៏ចម្រើន ។

ក៏ក្នុងអធិការនេះ អភិក្កន្តសព្ទនេះ គប្បីជ្រាបថា លោកពោលទុក ២ លើក ដោយអំណាចនៃសេចក្តីជ្រះថ្លា និងដោយអំណាចនៃសេចក្តីសរសើរ ដោយលក្ខណៈនេះ គឺ ៖

បណ្ឌិតអ្នកដឹង គប្បីធ្វើការពោលដដែល ៗ ទុក(ក្នុងអត្ថ ៩ យ៉ាងទាំងនេះ) គឺ ក្នុងភយៈ(សេចក្តីខ្លាច) ក្នុងកោធៈ (សេចក្តីក្រោធ) ក្នុងបសំសា (សេចក្តីសរសើរ) ក្នុងតុរិតៈ (សេចក្តីប្រញាប់ប្រញាល់) ក្នុងកោតុហលៈ (សេចក្តីភ្ញាក់ផ្អើល) ក្នុងអច្ឆរៈ (សេចក្តីអស្ចារ្យ) ក្នុងហាសៈ (សេចក្តីរីករាយ) ក្នុងសោកៈ (សេចក្តីសោក) និងក្នុងបសាទៈ(សេចក្តីជ្រះថ្លា) ។

ម្យ៉ាងទៀត បទថា អភិក្កន្តំ : ក្រៃលែងណាស់ គឺ គួរស្រឡាញ់ក្រៃលែង គួរប្រាថ្នាក្រៃលែង គួរពេញចិត្តក្រៃលែង មានពាក្យអធិប្បាយទុកថា ល្អក្រៃលែង ។

បណ្តាអភិក្កន្តសព្ទ ២ យ៉ាងនោះ វេរញ្ជព្រាហ្មណ៍ រមែងសរសើរទេសនា ដោយអភិក្កន្តសព្ទ មួយយ៉ាង, រមែងសរសើរសេចក្តីជ្រះថ្លា

របស់ខ្លួន ដោយអភិក្កន្តសព្ទ មួយយ៉ាង ៗ ពិតមែន ក្នុងសេចក្តីសរសើរនេះ មានអធិប្បាយដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះធម្មទេសនារបស់ព្រះគោតមដ៏ចម្រើននេះ គួរសរសើរក្រៃលែង សេចក្តីជ្រះថ្លារបស់ខ្ញុំព្រះអង្គអាស្រ័យព្រះធម្មទេសនារបស់ព្រះគោតមដ៏ចម្រើន ល្អក្រៃលែង ៗ វេរញ្ជព្រាហ្មណ៍ សរសើរបាវចនៈរបស់ព្រះមានព្រះភាគទ្រង់ឯង ប្រាថ្នាភាពជាពីរយ៉ាង ៗ ។

## បាវចនៈមានសេចក្តីល្អ ១៨ យ៉ាង

បណ្ឌិត គប្បីប្រកបបាវចនៈ ដោយហេតុទាំងឡាយជាដើមយ៉ាងនេះ គឺ ៖

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន ឈ្មោះថា ល្អក្រៃលែងណាស់ ព្រោះញ៉ាំងទោសៈឱ្យវិនាស ១ ឈ្មោះថា ល្អក្រៃលែងណាស់ ព្រោះឱ្យសម្រេចគុណ ១ មួយទៀត ព្រោះឱ្យកើតសទ្ធា ១ ព្រោះឱ្យកើតបញ្ញា ១ ព្រោះប្រព្រឹត្តទៅព្រមដោយអត្ថ ១ ព្រោះប្រព្រឹត្តទៅព្រមដោយព្យញ្ជនៈ ១ ព្រោះមានបទដែលងាយយល់ ១ ព្រោះមានសេចក្តីជ្រាលជ្រៅ ១ ព្រោះពីរោះត្រចៀក ១ ព្រោះចូលដល់ហទយៈ ១ ព្រោះមិនលើកខ្លួនឡើងអួតអាង ១ ព្រោះមិនសង្កត់សង្កិនអ្នកដទៃ ១

ព្រោះត្រូវជាក់ដោយព្រះករុណា ១ ព្រោះទ្រង់ត្រាស់ដោយព្រះបញ្ញា ១ ព្រោះជាទីរីករាយនៃគន្លង ១ ព្រោះអត់ធន់ចំពោះសេចក្ដីញាំញីបានយ៉ាងវិសេស ១ ព្រោះស្ដាប់នៅក៏ជាសុខ ១ ព្រោះពិចារណានៅក៏មានប្រយោជន៍ ១ ដូច្នេះ ។

## ព្រាហ្មណ៍សរសើរធម៌ទេសនាដោយឧបមា ៤ យ៉ាង

សូម្បីខាងមុខអំពីនោះទៅ វេរញ្ជព្រាហ្មណ៍ រមែងសរសើរទេសនានុ៎ះឯង ដោយឧបមា ៤ ប្រការ ។

បណ្ដាបទទាំងនោះ បទថា និក្កុជ្ជិតំ : របស់ដែលគេផ្កាប់ គឺភាជនៈដែលគេដាក់ផ្កាប់មាត់ទុក ឬមានមាត់នៅខាងក្រោម ។

បទថា ឧក្កុជ្ជេយ្យ : ឱ្យផ្ងារឡើង គឺ គប្បីផ្ងារមាត់ឡើង ។

បទថា បដិច្ឆន្នំ : ដែលគេលាក់បិទបាំង គឺ ដែលគេបិទទុកដោយវត្ថុ មានស្មៅ និងស្លឹកឈើជាដើម ។

បទថា វិវរេយ្យ : បើកបង្ហាញ គឺ គប្បីបើកឡើង ។

បទថា មូឡ្ហស្ស : អ្នកវង្វេង គឺ អ្នកវង្វេងទិស ។

ពីរបទថា មគ្គំ អាចិក្ខេយ្យ : ប្រាប់មក សេចក្ដីថា គប្បីចាប់ត្រង់ដៃហើយប្រាប់ថា នេះមក ។

បទថា អន្ធការេ : ក្នុងទីងងឹត សេចក្ដីថា ក្នុងសេចក្ដីងងឹតមានអង្គ ៤ (គឺ) ព្រោះថ្ងៃ ១៤ រោច ក្នុងកាឡបក្ខ ១ ពេលយប់ ១ ព្រៃស្រោងដែលក្រាស់ ១ ស្រទាប់ពពក ១ ។ អត្ថន័យនៃបទដែលនៅមិនភ្លឺច្បាស់មានប៉ុណ្ណេះសិន ។

ចំណែកការប្រកបសេចក្ដីអធិប្បាយ មានដូចតទៅនេះ ៖

(វេរញ្ជព្រាហ្មណ៍ សរសើរព្រះមានព្រះភាគថា) ព្រះគោតមដ៏ចម្រើន ទ្រង់ញ៉ាំងយើងអ្នកបែរមុខជៀសចេញចាកព្រះសទ្ធម្ម ធ្លាក់ទៅក្នុងអសទ្ធម្មហើយឱ្យចេញចាកអសទ្ធម្ម ដូចអ្នកណា ៗ គប្បីផ្ងារភាជនៈដែលផ្កាប់ឡើងទុកដូច្នោះ ទ្រង់បើកបង្ហាញនូវព្រះសាសនាដែលត្រូវព្រៃក្រាស គឺ មិច្ឆាទិដ្ឋិបិទបាំងទុក ចាប់តាំងពីព្រះសាសនារបស់ព្រះកស្សបមានព្រះភាគអន្តរធានទៅ ដូចអ្នកណា ៗ គប្បីបើករបស់ដែលបិទទុកចេញដូច្នោះ ទ្រង់ត្រាស់ប្រាប់មកសួគ, និងនិព្វានឱ្យដល់យើង អ្នកដើរទៅកាន់មកអាក្រក់និងមកខុស ដូចអ្នកណា ៗ គប្បីប្រាប់មកឱ្យដល់អ្នកវង្វេងមកដូច្នោះ ទ្រង់បញ្ចាំងពន្លឺ គឺ ទេសនា ដែលជាគ្រឿងកម្ចាត់នូវងងឹត គឺ មោហៈដែលបិទបាំងរូប គឺ ព្រះរតនត្រ័យមានព្រះពុទ្ធជាដើមនោះ ដល់យើង អ្នកលិចនៅក្នុងសេចក្ដីងងឹត គឺមោហៈ ដែលមិនឃើញរូប គឺ ព្រះរតនត្រ័យមានព្រះពុទ្ធជាដើម ដូចអ្នកណា ៗ គប្បីបំភ្លឺ

ប្រទីបប្រេងឱ្យក្នុងទីងងឹតដូច្នោះ ទ្រង់បានប្រកាសព្រះធម៌ដល់យើង ដោយអនេកបរិយាយ ព្រោះទ្រង់ប្រកាស ដោយបរិយាយទាំងឡាយនេះ ។

## វេរញ្ជព្រាហ្មណ៍សម្តែងខ្លួនដល់ព្រះរតនត្រ័យជាទីពឹង

លុះវេរញ្ជព្រាហ្មណ៍ សរសើរព្រះធម្មទេសនាយ៉ាងនោះហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យ ព្រោះព្រះធម្មទេសនានេះ កាលនឹងធ្វើអាការដែលអ្នកមានសេចក្តីជ្រះថ្លាគប្បីធ្វើ ទើបបានក្រាបទូលថា ឯសាហំ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា ឯសាហំ កាត់ជា ឯសោ អហំ ប្រែថា ខ្ញុំព្រះអង្គនោះ ។

ច្រើនបទថា ភវន្តំ គោតមំ សរណំ គច្ឆាមិ : សូមដល់នូវព្រះគោតមដ៏ចម្រើនផង ជាទីពឹងទីរលឹក សេចក្តីថា ខ្ញុំព្រះអង្គសូមដល់ព្រះគោតមដ៏ចម្រើនថា ជាទីពឹង គឺ ខ្ញុំព្រះអង្គសូមដល់ សូមសេពគប់ សូមសេពសោយ បានដល់ សូមចូលទៅអង្គុយជិតព្រះគោតមដ៏ចម្រើន ដោយសេចក្តីប្រាថ្នានេះថា ព្រះគោតមដ៏ចម្រើនទ្រង់ជាទីពឹងដល់ខ្ញុំព្រះអង្គ គឺ ទ្រង់ជាទីទៅក្នុងខាងមុខ ទ្រង់ជាអ្នកការពារសេចក្តីទុក្ខ និងទ្រង់ធ្វើប្រយោជន៍ (ដល់ខ្ញុំព្រះអង្គ) ខ្ញុំព្រះអង្គរមែងជ្រាបគឺ រមែងរលឹកដឹង

ដូចក្រាបទូលមកហើយនុ៎ះឯង ។

ពិតមែន គតិ (សេចក្ដីដល់) ជាអត្ថន័យនៃធាតុពួកណា សម្បត្តិ (សេចក្ដីដឹង) ក៏ជាអត្ថន័យនៃធាតុទាំងនោះ ព្រោះដូច្នោះ បទថា គច្ឆាមិ នេះ លោកក៏ពោលអត្ថន័យសម្បត្តិនេះទុកដូច្នេះថា ជានាមិ ពុជ្ឈាមិ (ប្រែថា រមែងជ្រាប គឺរមែងរលឹកដឹង) ។

## អត្ថាធិប្បាយពាក្យថា ព្រះធម៌

ក៏ក្នុងពាក្យថា ធម្មញ្ច នេះ មានវិនិច្ឆ័យដូច្នេះ ៖

សភាពដែលឈ្មោះថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវបុគ្គល អ្នកបានសម្រេចមគ្គ អ្នកធ្វើឱ្យច្បាស់និរោធហើយ និងអ្នកបដិបត្តិទៅតាមពាក្យទូន្មាន មិនបានធ្លាក់ទៅក្នុងអបាយ ។ ធម៌នោះ ដោយអត្ថ បានដល់អរិយមគ្គនិងនិព្វាន ។ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "យាវតា ភិក្ខវេ ធម្មា សង្ខតា អរិយោ អដ្ឋង្គិកោ មគ្គោ តេសំ អគ្គមក្ខាយតិ : ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ"[១] ។ គួរពោលឱ្យពិស្ដារ ។

---

១. អង្គុ. ចតុ. ចក្កវគ្គ. ៤២. ៣៥/៨៤ ។

ធម៌នោះ មិនមែនបានដល់អរិយមគ្គនិងនិព្វានតែម៉្យាងទេ សូម្បីបរិយត្តិធម៌រួមទាំងអរិយផល ក៏ឈ្មោះថា ធម៌ ។ សមពិតតាមដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឆត្តមាណវកវិមានថា ៖

"អ្នកចូរដល់នូវធម៌ ដែលប្រាសចាករាគៈ( អរិយមគ្គ ) មិនរំភើប មិនមានសោក ( អរិយផល ) ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោក( គឺតថាគត )ចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ"[១] ដូច្នេះ ។

ពិតមែន ក្នុងព្រះគាថានេះ ព្រះមានព្រះភាគត្រាស់មគ្គថា ជាធម៌ប្រាសចាករាគៈ ត្រាស់ផលថា ជាធម៌មិនរំភើប មិនមានសោក ត្រាស់ព្រះនិព្វានថា ជាសភាវធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ត្រាស់ធម្មក្ខន្ធទាំងអស់ដែលទ្រង់ចែកដោយបិដក ៣ ថា ជាធម៌មិនគួរខ្ពើម ជាធម៌ពីរោះ ដ៏ល្អិត ដែលតថាគតចែកត្រឹមត្រូវហើយ ។

---

១. ខុទ្. វិមា. ឆត្តមាណវកវិមាន. ៥៥. ៥៣/១១៦ ។

## អត្ថាធិប្បាយពាក្យថា ព្រះសង្ឃ

ក៏ក្នុងពាក្យថា ភិក្ខុសង្ឃញ្ច នេះ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ព្រះសង្ឃ ព្រោះអត្ថថា រួមគ្នាដោយធម៌ដែលស្មើគ្នាគឺ ទិដ្ឋិនិងសីល ។ ព្រះសង្ឃនោះដោយអត្ថ បានដល់ ប្រជុំព្រះអរិយបុគ្គល ៨ ។ សមពិត ដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងវិមានវត្ថុនោះដូចគ្នាថា ៖

"អ្នកប្រាជឥទាំងឡាយ បានពោលនូវទាន ដែលបុគ្គលឱ្យហើយចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូនៃបុរសនោះ ចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌ អ្នកចូរដល់ព្រះសង្ឃនេះជាសរណៈចុះ"[១] ដូច្នេះ ។ ពួកភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ។ ក៏ព្រាហ្មណ៍ប្រកាសសរណគមន៍ ៣ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីភាពជាអ្នកឆ្លាត ក្នុងត្រៃសរណគមន៍ទាំងនោះឯងគួរជ្រាបវិធីនេះ ដូច្នេះគឺ ៖ សរណៈ សរណគមន៍ អ្នកដល់សរណៈ ប្រភេទនៃសរណគមន៍ ផលនៃសរណគមន៍ សង្កិលេស (សេចក្តីសៅហ្មង) ភេទៈ (សេចក្តីបែកធ្លាយនៃសរណគមន៍) ក៏វិធីនោះ កាល

---

១. ខុទ្ទ. វិមា. ឆត្តមាណវកវិមាន. ៥៥. ៥៣/១១៦ ។

ខ្ញុំព្រះករុណានឹងពោលទុកក្នុងអធិការនេះ ក៏រមែងធ្វើនិទាននៃព្រះវិន័យឱ្យជាភារៈធ្ងន់ពេក ព្រោះដូច្នោះ ទើបខ្ញុំព្រះករុណាមិនពោល ។ ចំណែកអ្នកសិក្សាទាំងឡាយ អ្នកមានសេចក្តីត្រូវការ គប្បីកាន់យកវិធីនោះអំពីវណ្ណនានៃភយភេរវសូត្រ ក្នុងអដ្ឋកថានៃមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ឬអំពីវណ្ណនាសរណៈ ក្នុងអដ្ឋកថា ខុទ្ទកនិកាយ ឈ្មោះបតមត្ថជោតិកា ឬក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ដូច្នេះឯង ។

ពាក្យថា ឧបាសកំ មំ ភវំ គោតមោ ធារេតុ **: សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក** អធិប្បាយថា ព្រះគោតមដ៏ចម្រើន ចូរទ្រង់ចាំខ្ញុំព្រះអង្គទុកយ៉ាងនេះថា ខ្ញុំព្រះអង្គនេះជាឧបាសក ដូច្នេះចុះ ។ ក៏ក្នុងអធិការនេះ ដើម្បីភាពជាអ្នកឆ្លាតក្នុងវិធីសម្តែងខ្លួនជាឧបាសក គួរជ្រាបបកិណ្ណកៈនេះដូច្នេះថា អ្នកណា លោកហៅថា ឧបាសក ព្រោះហេតុអ្វី ទើបហៅថា ឧបាសក ឧបាសកនោះ មានសីលយ៉ាងណា មានអាជីវៈយ៉ាងណា មានអ្វីជាវិបត្តិ មានអ្វីជាសម្បត្តិ ខ្ញុំព្រះករុណាមិនបានចែកបកិណ្ណកៈនោះ ទុកក្នុងអធិការពោលអំពីនិទាននេះ ព្រោះនឹងធ្វើឱ្យជាភារៈធ្ងន់ពេក តែអ្នកសិក្សាទាំងឡាយ អ្នកមានសេចក្តីត្រូវការ គប្បីជ្រាបដោយន័យដែលខ្ញុំព្រះករុណាពោលទុកហើយក្នុងអដ្ឋកថា មជ្ឈិមនិកាយឈ្មោះបបញ្ចសូទនីនោះឯង ។

## អធិប្បាយអគ្គៈសព្ទដែលចុះក្នុងអត្ថ ៤ យ៉ាង

អគ្គៈសព្ទនេះ ក្នុងបទថា អជ្ជតគ្គេ ៈ ចាប់តាំងពីថ្ងៃនេះតទៅនេះ រមែងប្រាកដក្នុងអត្ថគឺអាទិ ( ខាងដើម ) កោដិ ( ខាងចុង ) កោដ្ឋាសៈ ( ចំណែក ) និង សេដ្ឋៈ( ប្រសើរ ) ។ ពិតមែន អគ្គៈសព្ទ រមែងប្រាកដក្នុងអត្ថគឺ ខាងដើម ក្នុងប្រយោគទាំងឡាយជាដើមថា "អជ្ជតគ្គេ សម្ម ទោវារិក្ក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ ៈ ម្នាលអ្នករក្សាទ្វារជាសម្លាញ់ តាំងពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រី"[១] ។

អគ្គៈសព្ទ រមែងប្រាកដក្នុងអត្ថគឺ ខាងចុង ក្នុងប្រយោគទាំងឡាយជាដើមថា "តេន អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសតិ ៈ ស្ទាបអង្អែលនូវចុងម្រាមនោះ ដោយចុងម្រាមនោះ"[២] ឧច្ឆគ្គំ ចុងអំពៅ វេឡគ្គំ ចុងឫស្សី ។

រមែងប្រាកដក្នុងអត្ថគឺ ចំណែក ក្នុងប្រយោគទាំងឡាយ ជាដើមថា "អម្ពិលគ្គំ វា មធុរគ្គំ វា តិត្តកគ្គំ វា ៈ មានរសជូរខ្លះ មាន

---

១. មជ្ឈិ. មជ្ឈិ. ឧបាលិវាទសូត្រ. ២៣. ៧៥/១១៥ ។ ២. អភិ. កថា. បច្ចុប្បន្នញ្ញាណកថា. ៨៥. ៦២៨/២៤៣; សមន្តបាលីថា ៈ តេនេវ ... បរាមសេយ្យ ។

រសផ្អែមខ្លះ ឬមានរសល្វីងខ្លះ”[១] ។ អនុជានាមិ ភិក្ខវេ វិហារគ្គេន វា បរិវេណគ្គេន វា ភាជេតុំ ; ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យប្រគល់តាមកំណត់នៃវិហារ ឬ ចំណែកនៃបរិវេណ”[២] ។

រមែងប្រាកដក្នុងអត្ថគឺ **ប្រសើរ** ក្នុងប្រយោគទាំងឡាយ ជាដើម ថា “យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញីនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ : ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ជាសត្វឥតជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើន មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី មានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែនក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ”[៣] ។ តែ អគ្គៈសព្ទនេះ ក្នុងអធិការនេះ គប្បីឃើញថា ចុះក្នុងអត្ថគឺ ខាងដើម ។ ព្រោះដូច្នោះ ក្នុងបទថា **អជ្ជតគ្គេ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ចាប់ផ្តើមតាំងពីថ្ងៃនេះជាដើមទៅ ។ លោកពោលពាក្យអធិប្បាយទុកថា

---

១. សំយុ. មហា. អម្ពលិវគ្គ. ៣៨. ២៧/២៣ ។ ២. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៣៨៩/៣២៩ ។ ៣. សំយុ. មហា. អប្បមាទវគ្គ. ៣៧. ២៤៥/១១១ ។

បទថា អជ្ជគ្គេ : ផ្ដើមថ្ងៃនេះ ក៏គឺ មានក្នុងថ្ងៃនេះ, ម្យ៉ាងទៀត បាលីថា អជ្ជទគ្គេ ដូច្នេះក៏មាន ។ ទ អក្សរ ធ្វើការតបទ ។ មានពាក្យអធិប្បាយថា ចាប់ផ្ដើមតាំងពីថ្ងៃនេះ ។

## វេរញ្ជព្រាហ្មណ៍សូមដល់ព្រះត្រៃរតនអស់មួយជីវិត

បទថា បាណុបេតំ : ដល់ សេចក្ដីថា អ្នកចូលដល់ (ព្រះរតនត្រ័យ) ដោយប្រាណ (គឺ ជីវិត) ។ វេរញ្ជព្រាហ្មណ៍ ក្រាបទូលថា ជីវិតរបស់ខ្ញុំព្រះអង្គនៅប្រព្រឹត្តទៅនៅត្រឹមណា, ព្រះគោតមដ៏ចម្រើន ចូរទ្រង់ចាំគឺ ទ្រង់ជ្រាបខ្ញុំព្រះអង្គថា (ជាឧបាសក) អ្នកចូលដល់ អ្នកដល់សរណៈដែលមិនមានសាស្ដាដទៃ ដោយត្រៃសរណគមន៍ត្រឹមនោះ ខ្ញុំព្រះអង្គឯងសូម្បីបើថា អ្នកណា ៗ នឹងគប្បីយកកាំបិតដ៏មុតកាត់សីសៈរបស់ខ្ញុំព្រះអង្គសោត, ក៏មិនគប្បីពោលដល់ព្រះពុទ្ធថា មិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ឬព្រះសង្ឃថា មិនមែនព្រះសង្ឃ ដូច្នេះឡើយ ។

ចំណែកក្នុងអធិការនេះ គប្បីជ្រាបអធិប្បាយថា ព្រាហ្មណ៍ កាលពោលដល់សរណគមន៍ដដែលទៀតថា "ជាឧបាសកដល់សរណគមន៍ស្មើដោយជីវិត" ឈ្មោះថា ប្រកាសប្រគល់ថ្វាយខ្លួន (ដល់ព្រះរតនត្រ័យ) ។

## ព្រាហ្មណ៍ទូលសូមឱ្យព្រះពុទ្ធចាំវស្សាក្នុងស្រុកវេរញ្ជា

លុះវេរញ្ជព្រាហ្មណ៍ ប្រគល់ថ្វាយខ្លួនយ៉ាងនោះហើយ មានសេចក្តីប្រាថ្នាទីឧបដ្ឋាកព្រះមានព្រះភាគ ព្រមទាំងបរិស័ទ ទើបក្រាបទូលថា “មិនតែប៉ុណ្ណោះទេ សូមព្រះគោតមដ៏ចម្រើន ទទួលនិមន្តគង់ចាំវស្សាជិតស្រុកវេរញ្ជា មួយអន្លើដោយភិក្ខុសង្ឃ” ។

ព្រាហ្មណ៍ ក្រាបទូលសេចក្តីប្រាថ្នាទុកយ៉ាងណា ។ ក្រាបទូលទុកយ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើន ចូរទ្រង់ចាំខ្ញុំព្រះអង្គថា ជាឧបាសក និងសូមទ្រង់ទទួលការនៅចាំវស្សាក្នុងស្រុកវេរញ្ជារបស់ខ្ញុំព្រះអង្គចុះ គឺ សូមឱ្យទ្រង់ទទួលការអាស្រ័យស្រុកវេរញ្ជា នៅចាំវស្សារហូតដល់អស់ត្រៃមាស ដើម្បីអនុគ្រោះខ្ញុំព្រះអង្គចុះ ។

## ព្រះពុទ្ធទ្រង់ទទួលនិមន្តនៅចាំវស្សាស្រុកវេរញ្ជា

ច្រើនបទថា អធិវាសេសិ ភគវា តុណ្ហីភាវេន : ព្រះមានព្រះភាគក៏ព្រមទទួលនិមន្តដោយតុណ្ហីភាព សេចក្តីថា គ្រានោះព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍នោះហើយ ក៏ទ្រង់មិនញ៉ាំងអង្គ គឺកាយ ឬអង្គគឺ វាចាឱ្យកម្រើកឡើយ ទ្រង់ទុកនូវព្រះខន្តិក្នុងខាងក្នុងទុ៎ះ

ឯង ទ្រង់ទទួល(ពាក្យអារាធនា) ដោយព្រះតុណ្ហីភាព ។ លោកអធិប្បាយទុកថា ព្រះមានព្រះភាគទ្រង់ទទួលដោយព្រះហឫទ័យតែម្តង ដើម្បីទ្រង់អនុគ្រោះព្រាហ្មណ៍ ។

ច្រើនបទថា អថខោ វេរញ្ជោ ព្រាហ្មណោ ភគវតោ អធិវាសនំ វិទិត្វា : លំដាប់វេរញ្ជព្រាហ្មណ៍ដឹងច្បាស់ថា ព្រះអង្គទទួលនិមន្តហើយ សេចក្តីថា គ្រានោះឯង វេរញ្ជព្រាហ្មណ៍ គិតថា បើព្រះសមណគោតមមិនគប្បីទ្រង់ទទួល (ពាក្យអារាធនា) របស់យើងនឹងគប្បីទ្រង់ជំទាស់ដោយកាយ ឬដោយវាចាតែព្រោះព្រះអង្គទ្រង់មិនជំទាស់ ទ្រង់ព្រះខន្តិទុកក្នុងខាងក្នុង, ដូច្នោះ ព្រះអង្គក៏ទ្រង់ទទួល (ពាក្យអារាធនា) របស់យើង ដោយព្រះហឫទ័យនុ៎ះឯង ដូច្នេះ គ្រាជ្រាបការទ្រង់ទទួលពាក្យអារាធនារបស់ព្រះមានព្រះភាគ ព្រោះសេចក្តីដែលខ្លួនជាអ្នកឆ្លាតក្នុងការកំណត់ដឹងអាការ ដូចពណ៌នាមកហើយនោះ ទើបក្រោកចាកអាសនៈដែលខ្លួនអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគក្នុងទិសទាំង ៤ ដោយសេចក្តីគោរព ហើយធ្វើប្រទក្សិណ ៣ ជុំ សូម្បីបានតិះដៀលចាប់ផ្តើមតាំងពីវេលាដែលខ្លួនមកថា ព្រះសមណគោតមទ្រង់មិនធ្វើសាមីចិកម្មមានការក្រាបថ្វាយបង្គំជាដើម ដល់ពួកព្រាហ្មណ៍ដែលចាស់ជាងដោយជាតិជាដើម ឥឡូវនេះ បានដឹងព្រះពុទ្ធគុណយ៉ាងជ្រាលជ្រៅហើយ

សូម្បីសំពះដោយកាយវាចានិងចិត្តច្រើនគ្រាច្រើនដង ក៏នៅជាអ្នកមិនផ្អែតនុំះឯង ទើបបានផ្គងប្រណម្យដៃ ដែលរុងរឿងដោយសេចក្ដីប្រជុំព្រមនៃម្រាមទាំង ១០ ហើយលើកឡើងទុកលើសិរសា ដើរថយក្រោយបែរមុខទៅមក (ព្រះមានព្រះភាគ) ដរាបផុតទស្សនវិស័យ បានថ្វាយបង្គំក្នុងទីផុតទស្សនវិស័យហើយជៀសទៅ ។

## ស្រុកវេរញ្ជាកើតទុព្ភិក្ខភ័យ

[៥] ច្រើនបទថា តេន ខោ បន សមយេន វេរញ្ជា ទុព្ភិក្ខា ហោតិ : សម័យនោះឯង ស្រុកវេរញ្ជាកើតអំអត់បាយ សេចក្ដីថា សម័យដែលវេរញ្ជព្រាហ្មណ៍ ទូលសូមឱ្យព្រះមានព្រះភាគទ្រង់អាស្រ័យស្រុកវេរញ្ជាចាំវស្សានោះ ស្រុកវេរញ្ជា ជាស្រុកកើតអំណត់អត់បាយ ។

បទថា ទុព្ភិក្ខា : ភិក្ខាលំបាក គឺ មានភិក្ខារកបានដោយលំបាក ។ ក៏សេចក្ដីមានភិក្ខារកបានលំបាកនោះ រមែងមានក្នុងតំបន់ដែលពួកមនុស្សមិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា ក្នុងវេលាដែលសន្ទូងបរិបូណ៌ក៏ដោយ ក្នុងវេលាបុព្វណ្ណៈនិងអបរណ្ណៈមានតម្លៃថោកក៏ដោយ ។ តែក្នុងស្រុកវេរញ្ជា មិនមែនយ៉ាងនោះទេ តាមការពិត បានមានព្រោះទោសគឺសេចក្ដីអត់ឃ្លាន ហេតុដែលមានសន្ទូងវិនាសអស់ ព្រោះដូច្នោះ ព្រះ

ឧបាលីថេរៈ កាលនឹងសម្តែងសេចក្តីនោះ ទើបពោលថា ទ្វីហិតិកា ដូច្នេះជាដើម ។

ក្នុងពាក្យថា ទ្វីហិតិកា ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា ទ្វីហិតិកា បានដល់ សេចក្តីព្យាយាមដែលប្រព្រឹត្តទៅហើយ ២យ៉ាង ។ ការកម្រើក ឈ្មោះថា ឦហិតៈ (សេចក្តីព្យាយាម) ។ សេចក្តីព្យាយាមនេះប្រព្រឹត្តទៅហើយ២ យ៉ាង គឺ ចិត្តឥរិយា (ការកម្រើកនៃចិត្ត) ១ ចិត្តឦហា (សេចក្តីប្រារព្ធព្យាយាមនៃចិត្ត) ១ ។

ក្នុងបទថា ទ្វីហិតិកា : មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក នេះ មានអធិប្បាយដូច្នេះថា ការកម្រើកនៃចិត្តដែលប្រព្រឹត្តទៅហើយ ២យ៉ាងនេះ គឺតើពួកយើងសូមវត្ថុអ្វី ៗ នៅក្នុងទីនេះនឹងបាន ឬមិនបានហ្ន៎ ម្យ៉ាងទៀត តើពួកយើងនឹងអាចដើម្បីរស់នៅឬមិនអាចហ្ន៎ ។

ម្យ៉ាងទៀត បទថា ទ្វីហិតិកា គឺ ជាអ្នកនៅយ៉ាងក្រៃក្រ ។ ពិតមែន បទទាំងឡាយជាដើមគឺ ឦហិតំ (សេចក្តីព្យាយាម) ឦហា (សេចក្តីប្រារព្ធព្យាយាម) អរិយនំ (ការកម្រើក) បវត្តនំ (ការប្រព្រឹត្តទៅ) ជីវិតំ (សេចក្តីរស់នៅ) មានសេចក្តីដូចគ្នា ព្រោះដូច្នោះ ក្នុងបទថា ទ្វីហិតិកា នេះ ទើបមានសេចក្តីចំពោះបទដូច្នេះ គឺ សេចក្តី

ព្យាយាមដោយភាពជាទុក្ខ រមែងប្រព្រឹត្តទៅក្នុងស្រុកវេរញ្ជានេះ ព្រោះហេតុនោះ ស្រុកវេរញ្ជានេះ ទើបឈ្មោះថា ទុ្វីហិតិកា ។

បទថា សេតដ្ឋិកា : មនុស្សណាដែលក្រលំបាកស្រាប់ក៏ស្លាប់ មានឆ្អឹងស សេចក្ដីថា ស្រុកវេរញ្ជា ឈ្មោះថា មានឆ្អឹងមនុស្សស្លាប់សដេរដាស់ ព្រោះអត្ថវិគ្រោះថា ដែលស្រុកវេរញ្ជានេះមានឆ្អឹងសដេរដាស់ ។ មានអធិប្បាយថា សាកសពរបស់ពួកមនុស្សកំព្រា សូម្បីអ្នកសូមរហូតដល់អស់មួយថ្ងៃក៏មិនបានអ្វី ៗ ស្លាប់ហើយ មានឆ្អឹងពណ៌ដូចផ្សិតក្បាលពស់ពាសពេញនៅក្នុងទីនោះ ៗ ។ បាលីថា សេតដ្ឋិកា ដូច្នេះខ្លះ ។ អត្ថន័យនៃបាលីនោះថា រោគក្រា-ស មាននៅក្នុងស្រុកវេរញ្ជានេះ ហេតុនោះ ស្រុកវេរញ្ជានេះ ទើបឈ្មោះថា មានរោគក្រា-ស ។ សេចក្ដីទុក្ខ គឺសេចក្ដីចាក់សៀត ព្រោះសេចក្ដីឈឺចុកចាប់ឈ្មោះថា អដ្ឋិ ។ ក៏ក្នុងស្រុកវេរញ្ជានោះ ក្នុងវេលាដែលស្រូវផើម គួរស្រូវសាលីក្ដី គួរស្រូវខ្សាយក្ដី គួរស្រូវដំណើបក្ដី មានពណ៌ស ៗ ត្រូវរោគក្រាន់ុះឯងធ្វើឱ្យខូច ក៏ដាច់ទឹកដោះ មិនមានគ្រាប់ស្រូវដុះចេញមក ( គឺ ធ្លាក់ជាគួរចេញមក ) ព្រោះដូច្នោះ ស្រុកវេរញ្ជានេះ ទើបលោកហៅថា សេតដ្ឋិកា ( ក្រុងមានរោគស្រូវក្រា-ស ) ។

## ស្រុកវេរញ្ជាមានស្លាកចែកទិញអាហារចិញ្ចឹមជីវិត

ក្នុងវេលាសាបព្រោះ សន្ទូងដែលប្រជាជនសូម្បីផ្សំពូជសាបព្រោះទុកល្អហើយ រមែងសម្រេចជាស្លាកប៉ុណ្ណោះ ក្នុងស្រុកវេរញ្ជានោះ ព្រោះហេតុនោះ ស្រុកវេរញ្ជានោះ ទើបឈ្មោះថា មានសន្ទូងដែលសាបព្រោះហើយសម្រេចជាស្លាក ។ ម្យ៉ាងទៀត ប្រជាជនទាំងឡាយ រមែងឱ្យជីវិតប្រព្រឹត្តទៅក្នុងស្រុកវេរញ្ជានោះដោយស្លាក (គឺ ការចែកប័ត្រ) ព្រោះដូច្នោះ ស្រុកវេរញ្ជានោះ ទើបឈ្មោះថា មានជីវិតប្រព្រឹត្តទៅបានដោយស្លាក ។

មានពាក្យពោលអធិប្បាយទុកយ៉ាងណា ? មានពាក្យពោលអធិប្បាយទុកយ៉ាងនេះ គឺ ដូចបានស្តាប់មក ក្នុងស្រុកវេរញ្ជានោះ កាលប្រជាជនទាំងឡាយ ដែលជាអ្នកទិញ ទៅកាន់សំណាក់របស់ពួកឈ្មួញអ្នកលក់ស្រូវ ពួកមនុស្សមានកម្លាំង (ទ្រព្យ) ជិះជាន់ពួកមនុស្សអ្នកមិនមានកម្លាំង (ទ្រព្យ) ហើយទិញយកស្រូវទៅ (អស់) ។ ពួកមនុស្សអ្នកមិនមានកម្លាំង (ទ្រព្យ) កាលមិនបាន (ស្រូវ) រមែងបញ្ចេញនូវសំឡេងខ្លាំង ។ ពួកឈ្មួញអ្នកលក់ស្រូវប្រឹក្សាគ្នាថា "ពួកយើងនឹងធ្វើការសង្គ្រោះប្រជាជនទាំងអស់" ទើបបង្គាប់ឱ្យអ្នកវាល់ស្រូវ អង្គុយក្នុងទីធ្វើការវាល់ស្រូវ ហើយឱ្យអ្នកជំនាញការមើលកហាបណៈអង្គុយនៅមួយកន្លែង ។ ពួកមនុស្សអ្នកមានសេចក្តីត្រូវការស្រូវ ក៏ទៅកាន់សំណាក់

របស់អ្នកជំនាញការមើលកហាបណៈ ។ អ្នកជំនាញការមើលកហាបណៈនោះ កាន់យកមូលតម្លៃដោយលំដាប់នៃជនអ្នកមកហើយ ទើបសរសេរស្លាក (គឺ ប័ណ្ណ) ឱ្យទៅថា “គួរឱ្យដល់ជនឈ្មោះនេះ មានប្រមាណប៉ុណ្ណេះ” ។ ពួកមនុស្សអ្នកមានសេចក្ដីត្រូវការស្រូវទាំងនោះ ទទួលយកស្លាកនោះហើយ ទៅកាន់សំណាក់របស់ជាងអ្នកវាល់ស្រូវ ហើយទទួលយកស្រូវដោយលំដាប់ដែលគេវាល់ឱ្យ ។ ប្រជាជនទាំងឡាយ រមែងញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅ ក្នុងស្រុកវេរញ្ជានោះដោយស្លាក ព្រោះហេតុនោះ ស្រុកវេរញ្ជានោះ ទើបឈ្មោះថា មានជីវិតប្រព្រឹត្តទៅបានដោយស្លាក ដូចពណ៌នាមកដូច្នេះ ។

ប្រើនបទថា ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ : ជនទាំងអស់ក្នុងស្រុកនោះព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក សេចក្ដីថា ភិក្ខុសង្ឃទឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយការកាន់បាត្រស្វែងរក ក៏ធ្វើមិនបានងាយ ។ មានពាក្យអធិប្បាយថា អ្នកណា ៗ កាន់បាត្រហើយ ទឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយការស្វែងរក ដូចដែលពួកព្រះអរិយៈធ្វើការស្វែងរក គឺ ត្រាច់ភិក្ខាចារនោះ ក៏ធ្វើមិនបានងាយ ៗ ឡើយ ។ បានឮថា គ្រានោះ ក្នុងស្រុកវេរញ្ជានោះ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតរហូតដល់អស់ ៧-៨ ស្រុក ក៏មិនបានអាហារល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ សូម្បីត្រឹមតែមួយថ្ងៃ ។

## ឈ្មួញសេះថ្វាយបាយមួយនាឡិដល់ភិក្ខុមួយរូប

ពាក្យថា តេន ខោ បន សមយេន ឧត្តរាបថកា អស្សវាណិជា ។បេ។ អស្សោសិ ខោ ភគវា ឧទុក្ខលសទ្ទំ : សម័យនោះមានពួកឈ្មួញសេះ នៅក្នុងឧត្តរាបថប្រទេស ។ល។ វេលានោះ ព្រះសម្ពុទ្ធទ្រង់បានព្វសូរត្បាល់ និងអង្រែនោះដែរ ។ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា តេន សេចក្តីថា ដោយសម័យដែលព្រះមានព្រះភាគទ្រង់អាស្រ័យស្រុកវេរញ្ជាចាំវស្សានោះ ពួកឈ្មួញសេះ អ្នកនៅក្នុងឧត្តរាបថជនបទ ឬអ្នកបានឈ្មោះយ៉ាងនោះ ព្រោះមកអំពីឧត្តរាបថជនបទ ទទួល (ទិញ) យកសេះ ៥០០ ក្នុងស្ថានទីជាកន្លែងកើតរបស់សេះទាំងឡាយ ក្នុងឧត្តរាបថជនបទហើយ កាលប្រាថ្នាចំណូល (ផលកំរៃ) ២-៣ ចំណែក ក៏ទៅកាន់ប្រទេសផ្សេង ៗ ហើយចូលសម្រាកវដូវភ្លៀងនៅក្នុងស្រុកវេរញ្ជា ព្រមដោយហ្វូងសេះមានប្រមាណ ៥០០ ដែលជាទំនិញដែលខ្លួនទឹងត្រូវលក់ទាំងនោះ ។

សួរថា ព្រោះហេតុអ្វី ទើបត្រូវសម្រាកដូច្នោះ ?

ឆ្លើយថា ព្រោះថា ក្នុងប្រទេសនោះ អ្នកណា ៗ មិនអាចដើរមក

ឆ្នាំ ហេតុដល់អស់ ៤ ខែក្នុងរដូវភ្លៀងបាន ... ក៏ពួកឈ្នួញសេះទាំងនោះ កាលទឹងចូលសម្រាករដូវភ្លៀង ទើបបានបង្គាប់ឱ្យជាងសាងផ្ទះសម្រាកសម្រាប់ខ្លួន និងរោងសេះសម្រាប់ពួកសេះទុកក្នុងទីដែលមិនលិចទឹក ក្នុងខាងក្រៅព្រះនគរហើយ ធ្វើរបងព័ទ្ធ ។ ស្ថានទីសម្រាករបស់ពួកឈ្នួញទាំងនោះ ៗ ប្រាកដថា អស្សមណ្ឌលិកា (ក្រោលសេះ) ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបពោលទុកថា "ពួកឈ្នួញដែលនៅក្នុងរោងសេះទាំងនោះ ក៏បានបញ្ញត្តគ្នាឱ្យប្រគេនបាយក្រៀមចំនួន ១ នាឡិ ៗ ម្នាក់ដល់ភិក្ខុទាំងឡាយ" ដូច្នេះ ។

បទថា បត្ថបត្ថបុលកំ : បាយក្រៀមចំនួន ១ នាឡិ ៗម្នាក់ បានដល់ បាយក្រៀមមានប្រមាណមួយនាឡិ ៗ សម្រាប់ភិក្ខុមួយរូប ៗ ។ ឈ្មោះថា មួយនាឡិ មានប្រមាណប៉ុនមួយនាឡិ ត្រឹមតែល្មមដើម្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ សម្រាប់មនុស្សម្នាក់ ។ សមពិតតាមដែលព្រះមានព្រះភាគត្រាស់ទុកក្នុងជាតក ទ្វាទសក កោសិយទី៧ ថា "បាយចំនួនអឌ្ឍមួយនាឡិនេះ មិនល្មមដល់ជន ២ នាក់ទេ"[១] ។

បាយក្រៀម ដែលបុគ្គលធ្វើឱ្យអស់អង្កាមហើយចំហុយឱ្យឆ្អិនទើបកាន់យក គេហៅឈ្មោះថា បាយក្រៀម ។ ពិតមែន បើបាយក្រៀម

---

១. ខុទ្ទ. ជាត. សុធាភោជនជាតក. ៦១. ២៤៩-១៣១ ។

នោះ នៅមានអង្កាម ពួកសត្វល្អិត រមែងចោះវេទ្ធបាន រមែងមិនគួររក្សាទុកយូរ ព្រោះដូច្នោះ ពួកឈ្មួញ ទាំងនោះ បានធ្វើឱ្យជារបស់គួររក្សាទុកបានយូរ ហើយកាន់យកបាយក្រៀម ទើបដើរមកឆ្ងាយ ដោយគិតថា "ក្នុងស្ថានទីណា ស្មៅជាអាហារពួកសេះស៊ី ដែលរកបានលំបាក ក្នុងស្ថានទីនោះឯង បាយក្រៀមនោះ នឹងជាអាហាររបស់សេះ" ។

សួរថា ក៏ព្រោះហេតុអ្វី ពួកឈ្មួញទាំងនោះ ទើបបានតាក់តែងបាយក្រៀមនោះទុកសម្រាប់ភិក្ខុទាំងឡាយ ?

ខ្ញុំព្រះករុណានឹងឆ្លើយតទៅ ៖

ពិតមែន ពួកមនុស្សក្នុងឧត្តរាបថជនបទទាំងនោះ នឹងជាអ្នកមិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា ដូចយ៉ាងពួកមនុស្សអ្នកទក្ខិណាបថជនបទ ក៏ទេ ។ សេចក្ដីពិត ពួកមនុស្សអ្នកឧត្តរាបថជនបទទាំងនោះ ជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ។ ពួកឈ្មួញទាំងនោះ ក្នុងវេលាព្រឹក កាលចូលទៅកាន់ក្រុងដោយករណីយកិច្ចយ៉ាងណាមួយនុ៎ះឯង បានជួបភិក្ខុ ៧-៨ រូប អ្នកស្លៀកដណ្ដប់រៀបរយ សម្បូណ៌ដោយឥរិយាបថត្រាច់ទៅបិណ្ឌបាតសូម្បីទូទាំងក្រុងក៏មិនបានវត្ថុអ្វី ៗ តាំង ២-៣ ថ្ងៃ លុះឃើញហើយពួកឈ្មួញទាំងនោះ បានមានសេចក្ដីគិតដូច្នេះថា "លោកម្ចាស់ទាំងឡាយ អាស្រ័យ

ស្រុកនេះនៅចាំវស្សា ឆាតកភ័យក៏កំពុងប្រព្រឹត្តទៅ និងលោកទាំងនេះក៏មិនបានវត្ថុអ្វី ៗ រមែងលំបាកជាយ៉ាងក្រៃលែង ទាំងពួកយើងក៏ជាអាគន្តុកៈ រមែងមិនអាចត្រៀមបបរ និងបាយប្រគេនលោកម្ចាស់ទាំងនោះរាល់ថ្ងៃ ៗ បាន តែសេះទាំងឡាយរបស់ពួកយើងបានអាហារពីរពេល គឺ ក្នុងពេលល្ងាចនិងពេលព្រឹក ដូចម្តេចហ្ន៎ ? ពួកយើងគប្បីបែងចែកថ្វាយបាយក្រៀមមួយនាឡិ ៗ ដល់ភិក្ខុមួយរូប ៗ អំពីអាហារពេលព្រឹករបស់សេះមួយ ៗ កាលបើដូច្នេះ លោកម្ចាស់ទាំងឡាយ នឹងមិនលំបាកទាំងសេះក៏នឹងល្មមញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅបាន” ។

ទើបពួកឈ្មួញទាំងនោះ ទៅកាន់សំណាក់របស់ភិក្ខុទាំងឡាយ ទូលប្រាប់សេចក្តីនោះឱ្យជ្រាប ហើយទូលសូមថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ទទួលបាយក្រៀមមួយនាឡិ ៗហើយធ្វើឱ្យជាអាហារយ៉ាងណាមួយឆាន់ចុះ” ដូច្នេះហើយ ទើបបានតាក់តែងបាយក្រៀមមួយនាឡិ ៗ ទុករាល់ថ្ងៃ ៗ ព្រោះហេតុនោះព្រះឧបាលីថេរៈទើបពោលទុកថា “ពួកឈ្មួញដែលនៅក្នុងរោងសេះទាំងនោះ ក៏បានបញ្ញត្តគ្នាឱ្យប្រគេនបាយក្រៀមចំនួន ១ នាឡិ ៗ ម្នាក់ដល់ភិក្ខុទាំងឡាយ” ។

បទថា **បញ្ញត្តំ : បញ្ញត្តិគ្នា** គឺ បានតាំងទុកហើយ ដោយសង្ខេបដូចជានិច្ចភត្ត ។

## អត្ថាធិប្បាយ បុព្វណ្ហសមយសព្ទ

ឥឡូវនេះ គួរជ្រាបវិនិច្ឆ័យក្នុងពាក្យថា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ : លុះដល់ពេលបុព្វណ្ហសម័យ ភិក្ខុទាំងឡាយ ស្លៀកស្បង់ទ្រង់ចីវរនិងបាត្រ ជាដើមតទៅ ៖

បទថា បុព្វណ្ហសមយំ : ពេលបុព្វណ្ហសម័យ គឺ សម័យដែលជាចំណែកខាងដើមនៃថ្ងៃ អធិប្បាយថា ក្នុងបុព្វណ្ហសម័យ ។ ម្យ៉ាងទៀត សម័យនៃពេលព្រឹក ឈ្មោះថា បុព្វណ្ហសម័យ លោកពោលពាក្យអធិប្បាយទុកថា ខណៈមួយក្នុងវេលាព្រឹក ។ កាលអធិប្បាយយ៉ាងនេះ ទុតិយាវិភត្តិ រមែងបានក្នុងអត្ថនៃអច្ចន្តសំយោគ ។

បទថា និវាសេត្វា : នៅអាស្រ័យហើយ គឺ ស្លៀកដណ្តប់ហើយ ។ បទថា និវាសេត្វា នោះ គប្បីជ្រាបដោយអំណាចនៃការផ្លាស់ប្តូរការស្លៀកដណ្តប់ក្នុងវត្ត ។ ក្នុងកាលមុនត្រាច់បិណ្ឌបាតនោះ ភិក្ខុទាំងនោះ មិនមែនមិនបានស្លៀកដណ្តប់សោះទេ ។

បទថា បត្តចីវរមាទាយ : ទ្រង់ចីវរនិងបាត្រ សេចក្តីថា យកដៃទាំង ២ ឱបបាត្រ យកចីវរប្រដាប់កាយ អធិប្បាយថា ទ្រទុក គឺ ពាក់ទុក ។ ពិតមែន ពួកភិក្ខុកាលកាន់យក ( បាត្រនិងចីវរ ) ដោយ

ប្រការណា ៗ ក៏ដោយ លោកក៏ហៅថា កាន់យក ដូចគ្នា ។ ដូចក្នុង ប្រយោគថា លុមកាន់យកបានប៉ុណ្ណោះ ក៏ជៀសទៅ ដូច្នេះ ។

ពីរបទថា បិណ្ឌាំ អលភមានា : នាំគ្នាចូលទៅបិណ្ឌបាត្រ សេចក្តីថា ត្រាច់ទៅពេញទាំងស្រុកវេរញ្ជា មិនថា តែដុំបាយឡើយ ដោយហោចទៅ សូម្បីត្រឹមតែពាក្យថា "និមន្តប្រោសសត្វខាងមុខចុះ" ក៏មិនបានដែរ ។

## ពួកភិក្ខុបានបាយក្រៀមមួយនាឡិៗ នាំទៅកិនឆាន់

ច្រើនបទថា បត្តបត្តបុលកំ អារាមំ ហរិត្វា : ក៏បានបាយក្រៀម ១ នាឡិ ៗម្នាក់ ហើយវិលមកអារាម សេចក្តីថា កាន់យកបាយក្រៀមមួយនាឡិ ៗ ដែលខ្លួនបានក្នុងទីដែលទៅហើយ ៗ នាំទៅកាន់អារាម ។

ច្រើនបទថា ឧទុក្ខលេ កោដ្តេត្វា បរិភុញ្ជន្តិ : យកបាយក្រៀមនោះបុកក្នុងត្បាល់ រួចនាំគ្នាឆាន់ សេចក្តីថា អ្នកណា ៗ ដែលជាកប្បិយការកទទួលយកបាយក្រៀមមួយនាឡិ ៗ នោះ ទៅចម្អិនជាបបរឬបាយ ប្រគេនដល់ព្រះថេរៈទាំងនោះ ក៏មិនមាន ។ សូម្បីការចម្អិននោះឯង រមែងមិនជាសមណសារុប្ប ទាំងមិនសមគួរ ។ ភិក្ខុទាំងនោះរួមជាពួក ៗ មួយពួក ៗ ៨ រូបខ្លះ មួយពួក ៗ ១០ រូបខ្លះ ប្រឹក្សាគ្នាថា

ភាពជាអ្នកមានការប្រព្រឹត្តស្រាលនិងផុតចាកពីការបម្រើនឲ្យឆ្អិននោះឯង នឹងមានដល់ពួកយើង ដោយវិធីយ៉ាងនេះ ដូច្នេះ ទើបបុកឲ្យល្អិតក្នុងត្បាល់ ហើយយកទឹកចាក់លាយចំណែករបស់ខ្លួន ៗ ឲ្យជោគហើយក៏ឆាន់ គ្រាលោកទាំងនោះឆាន់ហើយ ក៏ជាអ្នកមានការខ្វល់ខ្វាយតិច នៅបំពេញសមណធម៌ ដោយប្រការដូច្នេះ ។

## ឈ្មួញសេះថ្វាយបាយក្រៀមចំពោះព្រះមានព្រះភាគ

ចំណែកពួកឈ្មួញសេះទាំងនោះ ក៏ថ្វាយបាយក្រៀមមួយនាឡិនិងទឹកដោះថ្លា ទឹកឃ្មុំនិងដុំស្ករត្នោតដែលគួរដល់បាយក្រៀមនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអានន្ទនាំយកបាយក្រៀមនោះមកកិនលើថ្ម ។ បាយក្រៀមនោះ ដែលបុរសបណ្ឌិតអ្នកមានបុណ្យធ្វើហើយ រមែងជាទីពេញចិត្តពិត ។ គ្រានោះ ព្រះអានន្ទ កាលកិនបាយក្រៀមនោះ ក៏ផ្សំដោយគ្រឿងផ្សំមានទឹកដោះថ្លាជាដើម បង្អោនចូលទៅថ្វាយចំពោះព្រះមានព្រះភាគ ។

ខណៈនោះ ពួកទេវតា បានដាក់ទិព្វឱជាចុះក្នុងបាយក្រៀមដែលផ្សំនេះ ។ ព្រះមានព្រះភាគ ក៏សោយព្រះក្រយាហារដែលកិនថ្វាយនោះ លុះសោយហើយក៏ទ្រង់ញុំាងកាលឲ្យកន្លងទៅដោយផលសមាបត្តិ ចំណេរកាលតាំងពីនោះមកក៏ស្ដេចមិនត្រាច់បាត្រ ។

## ព្រះពុទ្ធត្រាស់ដឹង ២០ ឆ្នាំ មិនមានឧបដ្ឋាកប្រចាំ

សួរថា ក៏គ្រានោះ ព្រះអានន្ទត្ថេរ មិនទាន់បានជាអ្នកឧបដ្ឋាករបស់ព្រះមានព្រះភាគឬ ?

ឆ្លើយថា មិនទាន់បាន ទាំងលោកក៏មិនបានទទួលតំណែងអ្នកឧបដ្ឋាកឡើយ ។ សេចក្តីពិត ក្នុងគ្រាបឋមពោធិកាល ឈ្មោះថា ភិក្ខុដែលឧបដ្ឋាកប្រចាំ របស់ព្រះមានព្រះភាគ ក្នុងខាងក្នុង២០ វស្សា រមែងមិនមាន ។ ពេលខ្លះ ព្រះនាគសមាលត្ថេរឧបដ្ឋាកព្រះមានព្រះភាគ, ពេលខ្លះ ព្រះនាគិតត្ថេរ, ពេលខ្លះ ព្រះមេឃិយត្ថេរ, ពេលខ្លះ ព្រះឧបវាណត្ថេរ, ពេលខ្លះ ព្រះសាគតត្ថេរ, ពេលខ្លះ ព្រះថេរៈអ្នកជាឱរសរបស់ស្តេចលិច្ឆវី ឈ្មោះសុនក្ខត្តៈ ឧបដ្ឋាកព្រះមានព្រះភាគ ។ ព្រះថេរៈទាំងនោះ ឧបដ្ឋាកតាមសេចក្តីពេញចិត្តរបស់ខ្លួនហើយ ក៏ជៀសទៅក្នុងវេលាដែលខ្លួនប្រាថ្នា (នឹងជៀសទៅ) ។ ព្រះអានន្ទត្ថេរ កាលលោកទាំងនោះនៅឧបដ្ឋាក ក៏ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច កាលលោកទាំងនោះជៀសទៅហើយ ក៏ធ្វើវត្តបដិបត្តិដោយខ្លួនឯង សូម្បីព្រះមានព្រះភាគក៏ទ្រង់យល់ក្នុងព្រះទ័យថា ព្រះញាតិដ៏ធំរបស់យើង មិនបានទទួលតំណែងជាអ្នកឧបដ្ឋាកពីមុន ក៏ពិតមែនហើយ តែថា ព្រះអានន្ទនេះឯងជាអ្នកសមគួរក្នុងឋានៈទាំងឡាយបែបនេះ ដូច្នេះ ទើបទ្រង់នៅស្ងៀម ។

ព្រោះហេតុនោះ ទើបព្រះឧបាលីថេរៈពោលទុកថា "ព្រះអានន្ទដ៏មានអាយុ យកបាយក្រៀម ១ នាឡិ កិនក្នុងត្បាល់ថ្មហើយយកទៅថ្វាយព្រះមានព្រះភាគ ។ ព្រះអង្គក៏ទ្រង់ទទួលសោយបាយក្រៀមនោះ" ។

## ព្រាហ្មណ៍និងអ្នកស្រុកមិនបានថ្វាយភត្តចំពោះព្រះពុទ្ធ

សួរថា ក៏ក្នុងវេលាបាយមានតម្លៃថ្លៃ មនុស្សទាំងឡាយកើតសេចក្តីឧស្សាហ៍ធ្វើបុណ្យគ្នាយ៉ាងលើសលប់ពន់ពេក សូម្បីខ្លួនឯងក៏មិនបរិភោគ រមែងសម្គាល់របស់ដែលខ្លួនគួរថ្វាយដល់ពួកភិក្ខុមិនមែនឬ ? ព្រោះហេតុអ្វី ក្នុងគ្រានោះ ទើបពួកមនុស្សទាំងនោះ មិនបានថ្វាយសូម្បីភិក្ខាត្រឹមតែមួយវែកហុំ, និងវេរញ្ជព្រាហ្មណ៍នេះ ក៏បានទូលសូមព្រះមានព្រះភាគ ឱ្យនៅចាំវស្សា ដោយសេចក្តីឧស្សាហ៍ជាច្រើន, ព្រោះហេតុអ្វី បានជាព្រាហ្មណ៍នោះ មិនដឹងសូម្បីសេចក្តីដែលមានព្រះមានព្រះភាគប្រថាប់នៅឬ ?

ឆ្លើយថា ព្រោះត្រូវមារបណ្តាលចិត្ត ។ ពិតមែន មារបណ្តាលចិត្ត គឺ ធ្វើវេរញ្ជព្រាហ្មណ៍ អ្នកល្មមត្រឹមតែជៀសពីសំណាក់ព្រះមានព្រះភាគទៅប៉ុណ្ណោះ និងអ្នកនគរទាំងអស់ឱ្យវង្វេងភ្លេចភ្លាំងទាំងអស់ រហូតអស់ស្ថានទីមានប្រមាណមួយយោជន៍ដោយជុំវិញ (ស្រុកវេរញ្ជា) ដែលជាស្ថានទីពួកភិក្ខុអាចត្រាច់ទៅបិណ្ឌបាត ក្នុងវេលាមុនឆាន់ហើយត្រឡប់មកបាន ធ្វើឱ្យពួកមនុស្សទាំងអស់ កំណត់មិនបាន ហើយក៏ជៀសទៅ

ព្រោះដូច្នោះ អ្នកណា ៗ ទើបមិនបានដាក់ចិត្តដល់កិច្ចដែលខ្លួនគួរធ្វើ ដោយហោចទៅសូម្បីសាមីចិកម្ម ។

សួរថា ក៏សូម្បីព្រះមានព្រះភាគ មិនជ្រាបមារនឹងបណ្ដាលចិត្ត ឬ ? ទើបទ្រង់ចូលចាំវស្សាក្នុងស្រុកវេរញ្ជានោះ ។

ឆ្លើយថា ទ្រង់មិនជ្រាប ក៏ទេ ។

សួរថា កាលទ្រង់ជ្រាបដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់មិនចូលចាំវស្សាក្នុងបណ្ដាព្រះនគរកន្លែងណាមួយ មាននគរចម្បា សាវត្ថី និងរាជគ្រឹះជាដើម ?

ឆ្លើយថា ព្រះនគរទាំងឡាយមាននគរចម្បា សាវត្ថី និងរាជគ្រឹះជាដើមចូរលើកទុក, សូម្បីបើថា ព្រះមានព្រះភាគ ដល់ស្ដេចយាងទៅកាន់ឧត្តរកុរុទ្វីប ឬ ត្រៃទសបុរីហើយចូលចាំវស្សាក្នុងឆ្នាំនោះសោត, មារក៏គប្បីបណ្ដាលចិត្តអ្នកឧត្តរកុរុទ្វីប ឬត្រៃទសបុរីសូម្បីនោះបាន ។ បានឮថា មារនោះ បានជាអ្នកមានចិត្ត ត្រូវសេចក្ដីអាឃាតចូលមករុំព័ទ្ធចិត្តឱ្យកើតទុក្ខយ៉ាងក្រៃលែង រហូតដល់ឆ្នាំនោះ, ចំណែកក្នុងស្រុកវេរញ្ជានេះ ព្រះមានព្រះភាគ ក៏បានទតឃើញហេតុការណ៍នេះ បានយ៉ាងល្អថា ពួកឈ្មួញសេះ នឹងធ្វើការសង្គ្រោះភិក្ខុទាំងឡាយ ព្រោះដូច្នោះ ទើបទ្រង់ចូលវស្សាក្នុងស្រុកវេរញ្ជានុ៎ះឯង ។

## មារមិនអាចធ្វើអន្តរាយដល់បច្ច័យ ៤ បាន

សួរថា ក៏មារ មិនអាចនឹងបណ្ដាលចិត្តពួកឈ្មួញបានឬ ?

ឆ្លើយថា មិនមែននឹងមិនអាចទេ តែព្រោះឈ្មួញទាំងនោះ បានមកក្នុងកាលប្រជាជនត្រូវមារបណ្ដាលចិត្តសម្រេចអស់ទៅហើយ ។

សួរថា ព្រោះហេតុអ្វី ទើបមារមិនត្រឡប់មកបណ្ដាលចិត្តទៀតហ្ន៎ ?

ឆ្លើយថា ព្រោះមិនជាវិស័យ ទើបមិនត្រឡប់មក ។

ពិតមែន មារនោះ រមែងមិនអាចដើម្បីធ្វើអន្តរាយ ដល់ភិក្ខាដែលបុគ្គលនាំទៅចំពោះព្រះតថាគត ដល់និពទ្ធទាន ដល់វត្ថុទានដែលបុគ្គលកំណត់ថ្វាយទុកហើយ ។ សេចក្ដីពិត អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់បច្ច័យ ៤ បាន ។ តើដល់បច្ច័យ ៤ ពួកណា ? អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់បច្ច័យ ៤ ទាំងនេះ គឺ ៖

អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់និពទ្ធទាន ដោយសន្មែបថា ភិក្ខាដែលបុគ្គលនាំទៅចំពោះព្រះតថាគត ឬដល់បច្ច័យ ៤ ដែលបុគ្គលបរិច្ចាគហើយចំពោះព្រះតថាគតដោយសន្មែបថា វត្ថុទានដែលបុគ្គលកំណត់ថ្វាយទុកហើយ ១,

អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់ព្រះជន្មាយុ របស់ព្រះពុទ្ធទាំងឡាយបាន ១,

អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់ព្រះអនុព្យញ្ជនៈ ៨០ ឬដល់ព្រះរស្មី ដែលផ្សាយចេញម្ខាងមួយព្យាមបាន ។ ពិតមែន រស្មី សូម្បីនៃព្រះចន្ទ ព្រះអាទិត្យ ទេវតា និងព្រហ្ម លុមទៅដល់ប្រទេសនៃព្រះអនុព្យញ្ជនៈនិងព្រះរស្មីដែលផ្សាយចេញម្ខាងមួយព្យាម របស់ព្រះតថាគតហើយ ក៏អស់អានុភាពទៅ ១,

អ្នកណា ៗ មិនអាចនឹងធ្វើអន្តរាយដល់ព្រះសព្វញ្ញុតញ្ញាណ របស់ព្រះពុទ្ធទាំងឡាយបាន ១ ( រួមជា ៤ យ៉ាង ដោយប្រការដូច្នេះ ) ។

ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគព្រមទាំងព្រះសង្ឃសាវកសោយនិងឆាន់ភិក្ខា ដែលមារធ្វើអន្តរាយមិនបានក្នុងគ្រានោះ ។

## ព្រះមានព្រះភាគត្រាស់សួរវត្ថុដែលជាប្រយោជន៍

ក៏ព្រះមានព្រះភាគ កាលទ្រង់សោយយ៉ាងនោះ ថ្ងៃមួយ ទ្រង់បានស្តាប់សំឡេងត្បាល់ ។

ប្រែបទថា អស្សោសិ ខោ ភគវា ឧទុក្ខលសទ្ទំ : វេលានោះ ព្រះសម្ពុទ្ធទ្រង់បានឮសូរត្បាល់ និងអង្រែនោះដែរ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់បានស្តាប់សំឡេងត្បាល់ ដែលកើតព្រោះអង្រែប៉ះខ្ទប់ ( ត្បាល់ ) របស់ពួកភិក្ខុដែលកំពុងបុកបាយក្រៀមមួយនាឡិ ៗ ។ ព្រះ

ធម្មសង្គាហកាចារ្យទាំងឡាយ ពោលពាក្យជាដើម ដែលមានតពីពាក្យនោះទៅយ៉ាងនេះថា ព្រះតថាគតទាំងឡាយ សូម្បីទ្រង់បានជ្រាប ដូច្នេះ ក៏ដើម្បីសម្តែងការឆ្លើយព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់សួរខាងមុខថា ម្នាលអានន្ទនោះសំឡេងត្បាល់ឬហ្ន៎ ?

ក្នុងពាក្យទាំងនោះ មានការពណ៌នាដោយសង្ខេបដូចតទៅនេះ ៖

ធម្មតាថា ព្រះតថាគតទាំងឡាយ សូម្បីកាលទ្រង់ជ្រាប បើហេតុនៃការសួរដូច្នោះ មានសោត ទើបត្រាស់សួរ, តែបើហេតុនៃការសួរដូច្នោះ មិនមានសោត, ដល់ទ្រង់ជ្រាប ក៏មិនត្រាស់សួរ ។ ក៏ព្រោះដែលឈ្មោះថា វត្ថុដែលព្រះពុទ្ធទាំងឡាយទ្រង់មិនជ្រាប មិនមាន, ព្រោះដូច្នោះ ទើបលោកមិនពោលពាក្យថា សូម្បីកាលមិនដឹង ។

ប្រើនបទថា កាលំ វិទិត្វា បុច្ឆន្តិ : (ជ្រាបច្បាស់)នូវកាលគួរហើយ សួរក៏មាន សេចក្តីថា បើវេលានៃការត្រាស់សួរនោះៗ មានសោត, ទ្រង់ជ្រាបកាលនោះយ៉ាងនោះហើយ ទើបត្រាស់សួរ បើវេលានៃការត្រាស់សួរនោះ មិនមានសោត, ទ្រង់ជ្រាបកាលសូម្បីយ៉ាងនោះហើយ ក៏មិនត្រាស់សួរ ។ មួយទៀត ព្រះតថាគតទាំងឡាយ សូម្បីកាលទឹងត្រាស់សួរយ៉ាងនោះ រមែងត្រាស់សួរតែពាក្យដែលប្រកបដោយប្រយោជន៍ គឺ រមែងត្រាស់សួរចំពោះតែពាក្យ ដែលអាស្រ័យប្រយោជន៍អាស្រ័យ

ហេតុប៉ុណ្ណោះ មិនត្រាស់សួរពាក្យដែលមិនប្រកបដោយប្រយោជន៍ទេ ។ ព្រោះហេតុអ្វី ? ព្រោះព្រះតថាគតទាំងឡាយ ទ្រង់កម្ចាត់ពាក្យដែលមិនប្រកបដោយប្រយោជន៍ចេញបាន ដោយមគ្គ ឈ្មោះថា សេតុ ។ មគ្គលោកហៅថា សេតុ, មានពាក្យអធិប្បាយទុកថា ការកម្ចាត់គឺ ការកាត់ផ្តាច់ដោយល្អ នូវពាក្យដូច្នោះដោយមគ្គនុ៎ះឯង ។

ឥឡូវនេះ ព្រះឧបាលីថេរៈ កាលនឹងសម្តែងដល់ព្រះតម្រាស់ ដែលអាស្រ័យប្រយោជន៍ដែលព្រះតថាគតទាំងឡាយ ត្រាស់សួរនោះ ក្នុងបទថា អត្ថសញ្ហិតំ : ដែលប្រកបដោយប្រយោជន៍ នេះទើបពោលពាក្យជាដើមថា ទ្វីហិ អាការេហិ : ដោយអាការពីរប្រការ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អាការេហិ : ដោយអាការ គឺដោយហេតុទាំងឡាយ ។

ពីរបទថា ធម្មំ វា ទេសេស្សាម : ដើម្បីនឹងសម្តែងនូវធម៌ក្តី សេចក្តីថា យើងនឹងសម្តែងព្រះសូត្រដែលប្រកបដោយអត្ថុប្បត្តិហេតុ (គឺ រឿងដែលកើតឡើងចំពោះមុខ) ឬជាតកដែលប្រកបដោយហេតុនៃបុព្វចរិត (គឺ ការប្រព្រឹត្តក្នុងជាតិមុន) ។

ច្រើនបទថា សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាម : ដើម្បីនឹងបញ្ញត្តិនូវសិក្ខាបទដល់សាវកទាំងឡាយ សេចក្តីថា ឬ យើងនឹងធ្វើ

ទោសដែលកន្លងលើសឱ្យប្រាកដ ដោយការសួរនោះ ហើយនឹងបញ្ញត្តិសិក្ខាបទគឺ តាំងច្បាប់វិន័យធ្ងន់ ឬស្រាលទុកដល់សាវកទាំងឡាយ ។

ក្នុងពាក្យថា អថខោ ភគវា ។បេ។ ឯតមត្ថំ អារោចេសិ : គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រួចហើយក៏គង់នៅក្នុងទីដ៏សមគួរ នេះ មិនមានពាក្យអ្វី ៗ ដែលគួរពោលទុកទេ ។ ព្រោះថា ព្រះអានន្ទកាលទូលប្រាប់ការបានបាយក្រៀមមួយនាឡិ ៗ ភាពជាអ្នកមានការប្រព្រឹត្តស្រាល និងផុតចាកការចម្អិនឱ្យឆ្អិនខ្លួនឯង របស់ពួកភិក្ខុ ដែលខ្ញុំព្រះករុណាពោលហើយក្នុងផ្នែកដើមនុ៎ះឯងហៅថា បានទូលប្រាប់សេចក្តីនោះហើយ ។

## ពួកភិក្ខុចាំវស្សាស្រុកវេរញ្ជាឈ្នះសេចក្តីអត់ឃ្លានបាន

ចំណែកព្រះមានព្រះភាគ កាលទ្រង់ធ្វើឱ្យព្រះអានន្ទរីករាយ ទើបបានត្រាស់ព្រះតម្រាស់នេះថា "ត្រូវហើយ អានន្ទ ប្រពៃហើយ" ក៏ឯគ្រាទ្រង់ប្រទានសាធុការហើយ កាលទ្រង់សម្តែងធម៌ព្រមទទួលយកអាការមួយយ៉ាង ក្នុងបណ្តាអាការទាំង ២ ទើបបានត្រាស់ថា "អានន្ទអ្នកឯងរាល់គ្នាជាសប្បុរស ឈ្នះវិសេសហើយ, បណ្តាជនខាងក្រោយគេនឹង

ទឹកចង់ឱ្យនូវចង្ហាន់ដែលគេចម្អិន ដោយអង្ករស្រូវខ្សាយ ព្រមទាំងម្ហូបលាយដោយសាច់ ដ៏ឆ្ងាញ់ពិសារ (ដល់អ្នកពល់គ្នា)" ។

ក្នុងពាក្យថា តុម្ហេហិ ជាដើមនោះ មានអធិប្បាយដូចតទៅនេះ ៖ (ព្រះមានព្រះភាគត្រាស់ថា) ម្នាលអានន្ទ ក្នុងគ្រាទុព្ភិក្ខភ័យ គឺ ក្នុងគ្រាដែលមានដុំបាយដែលរកបានលំបាកយ៉ាងនេះ ពួកលោកជាសប្បុរសឈ្នះវិសេសហើយ ដោយភាពជាអ្នកប្រព្រឹត្តស្រោលនេះ និងដោយធម៌ដែលជាគ្រឿងជុសខាត់នេះ ។

សួរថា តើពួកលោកឈ្នះអ្វី ?

ឆ្លើយថា ឈ្នះទុព្ភិក្ខភ័យបាន ឈ្នះសេចក្ដីលោភបាន ឈ្នះការប្រព្រឹត្តដោយអំណាចនៃសេចក្ដីចង់បាន ។

សួរថា តើឈ្នះយ៉ាងណា ?

ឆ្លើយថា សូម្បីភិក្ខុមួយរូប រមែងមិនមានសេចក្ដីគិត ឬសេចក្ដីចង្អៀតចង្អល់ចិត្តថា "ស្រុកវេរញ្ជានេះ កើតអំណត់អត់បាយ តែស្រុកនិងនិគមក្នុងចន្លោះដោយជុំវិញ (នៃស្រុកវេរញ្ជានេះ) មានសន្ទុងឱនចុះដោយទម្ងន់គឺ ផ្លែ គឺថា មានភិក្ខាល្អ មានដុំបាយរកបានដោយងាយណ្ហើយចុះ ពួកយើងទៅក្នុងស្រុក និងនិគមនោះហើយ ទើបនឹងឆាន់", សូម្បីកាលជាដូច្នោះ ព្រះមានព្រះភាគ ក៏នឹងទ្រង់ទទួលយកពួកយើងនៅ

ក្នុងស្រុកនេះតែម្តង ដូច្នេះ ។ ទុព្ភិក្ខភ័យដែលភិក្ខុទាំងនោះឈ្មោះបានហើយ គឺ គ្របសង្កត់បានហើយ បានដល់ ឱ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ដោយអាការយ៉ាងនេះមុន ។

សួរថា តើឈ្មោះសេចក្តីលោភបានយ៉ាងណា ?

ឆ្លើយថា សូម្បីភិក្ខុមួយរូប មិនបានធ្វើឱ្យរាត្រីដាច់ដោយអំណាចនៃសេចក្តីលោភថា ស្រុកវេរញ្ជានេះ កើតអំណត់អត់បាយ, ចំណែកស្រុក និងនិគមក្នុងចន្លោះដោយជុំវិញ (នៃស្រុកវេរញ្ជានេះ) មានសទ្ធនឹងចុះដោយទម្ងន់ គឺ ផ្លែ បានដល់ មានភិក្ខាល្អ មានដុំបាយរកបានដោយងាយ ណ្ហើយចុះ ពួកយើងនឹងនាំគ្នាទៅឆាន់ក្នុងស្រុកនិងនិគមនោះ ឬមិនបានធ្វើឱ្យវស្សាដាច់ ដោយគិតថា "ពួកយើងនឹងចូលចាំវស្សាក្នុងស្រុក និងនិគមនោះ ក្នុងវស្សាក្រោយ" ដូច្នេះ, សេចក្តីលោភដែលភិក្ខុទាំងនោះឈ្មោះបានហើយដោយអាការយ៉ាងនេះ ។

សួរថា តើឈ្មោះការប្រព្រឹត្តដោយអំណាចនៃសេចក្តីប្រាថ្នាបានយ៉ាងណា ?

ឆ្លើយថា សូម្បីភិក្ខុមួយរូប មិនបានឱ្យសេចក្តីប្រាថ្នាបែបនេះកើតឡើងថា "ស្រុកវេរញ្ជានេះ កើតអំណត់អត់បាយ និងមនុស្សទាំងឡាយនេះ រមែងមិនសម្គាល់ពួកយើង សូម្បីអ្នកស្នាក់នៅ ២-៣ ខែ

ក្នុងគុណអ្វីឡើយ ដូចម្ដេចហ្ន៎ ? ពួកយើងធ្វើការជំនួញគុណធម៌ (អុត្តរិមនុស្សធម្ម) គឺ ប្រកាសនូវគ្នានិងគ្នា ដល់មនុស្សទាំងឡាយយ៉ាងនេះថា 'ភិក្ខុរូបឯណោះ បានបឋមជ្ឈាន ។ល។ រូបឯណោះបានអភិញ្ញា ៦, ដូច្នេះ ហើយបំប៉នផ្ទៃ ខាងក្រោយ ទើបអធិដ្ឋានសីលជាបណ្ដើរ ៗ" ដូច្នេះ, ការប្រព្រឹត្តដោយអំណាចនៃសេចក្ដីប្រាថ្នា ដែលភិក្ខុទាំងនោះឈ្មោះបានហើយ គឺ គ្រប់សង្កត់បានហើយ ប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ដោយអាការយ៉ាងនេះ ។

ចំណែកក្នុងអនាគត ដើម្បីព្រហ្មចារីជាន់ក្រោយ អង្គុយនៅក្នុងវិហារហើយ សូម្បីបាន(ភត្តាហារ) ដោយសេចក្ដីលំបាកត្រឹមតែបន្តិចបន្តួច ក៏នឹងមើលងាយនូវស្រូវសាលីនិងបាយដែលលាយដោយសាច់ គឺនឹងធ្វើឱ្យជារបស់មើលងាយ គួរតិះដៀល ដោយន័យជាដើមថា នេះជាបាយអ្វីហ្នឹង ? ជាបាយពងបង្កួយ ជ្រាយពេក មិនប្រៃ(សាបឈឹង) ប្រៃពេក មិនជូរ ជូរពេក នឹងប្រយោជន៍អ្វីដោយបាយនេះ ? ដូច្នេះ ។

ម្យ៉ាងទៀត (ព្រះមានព្រះភាគ ត្រាស់អធិប្បាយទុកថា) ដែលឈ្មោះថា ជនបទនឹងកើតអំណត់អត់បាយរហូតសព្វកាល ក៏ទេ គឺ ពេលខ្លះ ក៏រកភិក្ខាហារបានដោយលំបាក ពេលខ្លះ ក៏រកភិក្ខាហារបានដោយងាយ ក្នុងកាលណា ជនបទនោះ នឹងរកភិក្ខាហារបានដោយងាយ ក្នុង

កាលនោះ មនុស្សទាំងឡាយជ្រះថ្លាចំពោះវត្តបដិបត្តិនេះ របស់ពួកលោក អ្នកជាសប្បុរសហើយ នឹងសម្គាល់ស្រូវសាលីវិកតិ និងបាយដែលលាយដោយសាច់ ដែលមានប្រការច្រើនយ៉ាង ដោយប្រភេទមានបបរនិងរបស់ទំពាឆាន់ជាដើម ដែលខ្លួនគប្បីថ្វាយដល់ភិក្ខុទាំងឡាយ, បច្ឆិមជនតាជនពោលគឺ សព្រហ្មចារីរបស់ពួកលោក អង្គុយនៅក្នុងចន្លោះពួកលោកហើយ កាលសោយនូវសក្ការៈដែលកើតឡើងហើយអាស្រ័យពួកលោកនោះឯង នឹងមើលងាយ និងធ្វើសេចក្ដីមើលថោក ដែលមានការសោយសក្ការៈនោះជាបច្ច័យ ។

សួរថា នឹងធ្វើសេចក្ដីមើលថោកយ៉ាងណា ?

ឆ្លើយថា នឹងធ្វើសេចក្ដីមើលថោកយ៉ាងនេះថា "ព្រោះហេតុអ្វីទើបពួកលោកចម្អិនភត្តមានប្រមាណប៉ុណ្ណេះហ្ន៎ ? ភាជនៈ របស់ពួកលោកដែលជាទីដែលពួកលោកនឹងគប្បីដាក់របស់ ៗ ខ្លួនរក្សាទុក មិនមានឬ ?

# សីហនាទកថារបស់ព្រះមហាមោគ្គល្លាន

## ព្រះមហាមោគ្គល្លានទូលសូមអនុញ្ញាតត្រឡប់ផែនដី

[៦] ក្នុងបទទាំងឡាយជាដើមថា *អថខោ អាយស្មា មហាមោគ្គល្លានោ* មានវិនិច្ឆ័យដូច្នេះ ៖

បទថា អាយស្មា នេះ ជាពាក្យពោលអំពីសេចក្ដីស្រឡាញ់, បទនេះជាឈ្មោះនៃសេចក្ដីគោរព និងសេចក្ដីកោតក្រែងដោយឋានៈជាគ្រូ ។

បទថា មហាមោគ្គល្លានោ សេចក្ដីថា ព្រះថេរៈនោះឈ្មោះថា មហាដោយភាពជាអ្នកមានគុណធំ និងឈ្មោះថា មោគ្គល្លាន ដោយគោត្រ ព្រោះហេតុនោះព្រះថេរៈនោះ ទើបឈ្មោះថា មហាមោគ្គល្លាន ។

បទថា **ឯតទវោច** សេចក្ដីថា ព្រះមហាមោគ្គល្លាន បានក្រាបទូលពាក្យនេះ (ចំពោះព្រះមានព្រះភាគ) គឺ សម្ដែងពាក្យជាដើមដែលខ្ញុំគួរក្រាបទូលក្នុងឥឡូវនេះថា "សូមទ្រង់មេត្តាប្រោស ឥឡូវនេះស្រុកវេរញ្ជាកើតអំណត់អត់បាយ" ដូច្នេះ ។

សួរថា ព្រះមហាមោគ្គល្លាន បានក្រាបទូល (ពាក្យនេះ) ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះបានឮថា ព្រះថេរៈបួសហើយ ក្នុងថ្ងៃទី ៧ ទើបបានដល់ទីបំផុតនៃសាវកបារមីញាណ ទាំងព្រះសាស្តាក៏ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈ ព្រោះលោកមានឫទ្ធិច្រើន ។ ព្រះថេរៈនោះអាស្រ័យសេចក្តីដែលខ្លួនជាអ្នកមានឫទ្ធិច្រើននោះ ទើបត្រិះរិះថា "ស្រុកវេរញ្ជានេះ កើតអំណត់អត់បាយ និងភិក្ខុទាំងឡាយក៏រមែងលំបាក, ដូចម្តេចហ្ន៎ ? បើយើងនឹងត្រឡប់ផែនដី ហើយឱ្យភិក្ខុទាំងឡាយឆាន់ស្រទាប់នៃផែនដី" ។ គ្រានោះលោកបានមានសេចក្តីរំពឹងដូច្នេះថា "ក៏បើថាកាលយើងនៅក្នុងសំណាក់របស់ព្រះមានព្រះភាគ នឹងមិនទូលសូមចំពោះព្រះមានព្រះភាគ ហើយគប្បីធ្វើយ៉ាងនោះសោត អំពើនោះនឹងមិនជាការសមគួរដល់យើង នឹងគប្បីដូចជាការប្រណាំងប្រជែង ដែលយើងធ្វើចំពោះព្រះមានព្រះភាគ ; ព្រោះដូច្នោះ ព្រះថេរៈមានសេចក្តីប្រាថ្នានឹងទូលសូម ទើបមកក្រាបទូលពោលពាក្យនោះចំពោះព្រះមានព្រះភាគ ។

## ខាងក្រោមមានស្រទាប់នៃផែនដីដែលមានរសឱជា

ពីរបទថា ហេដ្ឋិមតលំ សម្បន្នំ : ផ្ទៃខាងក្រោមនៃផែនដីនេះ សេចក្តីថា បានឮថា ព្រះថេរៈពោលសំដៅយកពង(ឬក្រមរ)ដី ឱជាដីស្រទាប់នៃផែនដី ដែលមាននៅក្នុងផែនដីខាងក្រោមនៃផែនដី ។

បណ្ដាបទទាំងនោះ បទថា សម្បន្នំ : រសបរិបូរណ៍, គឺ មានរសផ្អែម អធិប្បាយថា មានរសល្អ ។ ដូចយ៉ាងក្នុងប្រយោគនេះថា "វនសណ្ឌោ តត្រស្ស រុក្ខោ សម្បន្នផលោ ច ឧប្បន្នផលោ ច មានដើមឈើក្នុងព្រៃនោះ ជាឈើមានផ្លែផ្អែមផង មានផ្លែច្រើនផង"[១] ដូច្នេះ គប្បីជ្រាបអត្ថន័យថា មានផ្លែឆ្ងាញ់យ៉ាងណា សូម្បីក្នុងអធិការនេះក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបអត្ថន័យនៃបទថា សម្បន្នំ : រសបរិបូរណ៍, នេះថា មានរសផ្អែម គឺ រសល្អ ។

ចំណែកពាក្យថា សេយ្យថាបិ ខុទ្ទកាមធុ អនីលកំ : មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយប្រឡំដោយមេឃ្មុំនេះ ព្រះថេរៈពោលហើយក៏ដើម្បីសម្ដែងសេចក្ដីឧបមា ព្រោះផែនដីខាងក្រោមនៃផែនដីនោះ ជាធម្មជាតិមានរសផ្អែម ។

ទឹកផ្អែម ដែលមេឃ្មុំតូច ៗ ធ្វើទុកហើយ ឈ្មោះថា ខុទ្ទកមធុ (ទឹកឃ្មុំផ្អិត) ។

បទថា អនីលកំ : ឥតលាយប្រឡំដោយមេឃ្មុំ សេចក្ដីថា មិនមានកូន គឺ មិនមានកូនឃ្មុំតូច ៗ បានដល់ ទឹកឃ្មុំដែលបរិសុទ្ធ ។ បាន

---

១. មជ្ឈិ. មជ្ឈិ. បោតលិយសូត្រ. ២៣. ៥៣/៧៧ ។

ពូថា ទឹកឃ្មុំនោះជារបស់កំពូលលើសប្រសើរ មានរសល្អ និងមានឱជាជាងទឹកផ្អែមទាំងអស់ ព្រោះហេតុនោះ ទើបព្រះថេរៈបានពោលថា សេយ្យថាបិ ខុទ្ទកមធុំ អនីលកំ ឯវមស្សាទំ : ផ្ទៃខាងក្រោមនៃផែនដីនេះ មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធ ឥតលាយប្រឡំដោយមេឃ្មុំ ដូច្នេះជាដើម ។

ច្រើនបទថា សាធាហំ ភន្តេ កាត់បទថា សាធុ អហំ ភន្តេ : សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ( ចង់ប្រែត្រឡប់ផែនដីនេះឱ្យផ្ការឡើង ) ។

ក៏បទថា សាធុ នោះ ដែលមាននៅក្នុងបទថា សាធាហំ នេះ ជាពាក្យក្រាបទូលសូម ។ ពិតមែន ព្រះថេរៈ កាលនឹងក្រាបទូលសូមអនុញ្ញាតការប្រែត្រឡប់ផែនដី ទើបបានក្រាបទូលចំពោះព្រះមានព្រះភាគយ៉ាងនោះ ។

បទថា បរិវត្តេយ្យំ : ប្រែត្រឡប់ សេចក្តីថា គប្បីផ្ការឡើង គឺគប្បីធ្វើផែនដីខាងក្រោមឱ្យត្រឡប់ឡើងខាងលើ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈត្រូវធ្វើយ៉ាងនោះ ?

ឆ្លើយថា ព្រោះថា កាលព្រះថេរៈធ្វើយ៉ាងនោះហើយ ភិក្ខុទាំងឡាយនឹងបានឆាន់ស្រទាប់នៃផែនដី គឺ ពងដី ដោយសប្បាយ ។

គ្រានោះ ព្រះមានព្រះភាគ សូម្បីទ្រង់មិនមានព្រះបំណងនឹងអនុញ្ញាតក៏ដោយ តែដើម្បីឱ្យព្រះថេរៈបន្លឺសីហនាទ ទើបត្រាស់សួរថា "ម្នាលមោគ្គល្លាន ចុះអ្នកនឹងយកមនុស្សសត្វទាំងឡាយ ដែលនៅអាស្រ័យលើផែនដីនេះ ឱ្យទៅនៅឯណា" ត្រាស់អធិប្បាយទុកថា សត្វទាំងឡាយក្នុងស្រុកនិងនិគមជាដើមពួកណាអ្នកនៅអាស្រ័យផែនដី កាលលោកប្រែត្រឡប់ផែនដី លោកនឹងធ្វើសត្វទាំងនោះ អ្នកមិនអាចនឹងតាំងនៅក្នុងអាកាសបានយ៉ាងណា ? គឺ នឹងដាក់នៅក្នុងស្ថានទីណា ។ គ្រានោះ ព្រះថេរៈ កាលនឹងប្រកាសឥទ្ធានុភាពរបស់ខ្លួនដ៏សមគួរដល់ភារៈនៃខ្លួន ដែលព្រះមានព្រះភាគទ្រង់តាំងទុកក្នុងតំណែងឯតទគ្គៈ ទើបបានក្រាបទូលថា **ឯកាហំ** ភន្តេ ជាដើម ប្រែថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងនិមិត្តបាតដៃម្ខាង ឱ្យបានដូចជាផែនដីធំ នឹងឱ្យសត្វទាំងឡាយដែលនៅអាស្រ័យលើផែនដី មកនៅលើបាតដៃម្ខាងនោះ ហើយខ្ញុំព្រះអង្គនឹងប្រែនូវផែនដីដោយដៃម្ខាង ។

សេចក្ដីនៃពាក្យថា ឯកាហំ ភន្តេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ (នឹងនិមិត្តបាត)ដៃម្ខាង ជាដើមនោះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនិមិត្តដៃម្ខាង ឱ្យដូចជាផែនដីធំនេះ គឺនឹងធ្វើឱ្យដូចជាផែនដីគ្រាក្រាបបង្គំទូលយ៉ាងនោះហើយ នឹងធ្វើពួកសត្វអ្នកអាស្រ័យផែនដី ឱ្យឈានឡើងទៅលើបាតដៃនោះ ដូចធ្វើឱ្យសត្វអ្នកតាំងនៅហើយលើផែនដីលើបាតដៃម្ខាងនោះ ឈានទៅលើផែនដី លើបាតដៃម្ខាងទៀតដូច្នោះ ។

## ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាតឱ្យត្រឡប់ផែនដី

លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ហាមនូវការទូលសូមរបស់ព្រះថេរៈនោះ ទើបទ្រង់ត្រាស់ពាក្យជាដើមថា "មោគ្គល្លាន អ្នកកុំពេញចិត្តឡើយ" ។

បណ្ដាបទទាំងនោះ បទថា អលំ : កុំឡើយ ជាព្រះតម្រាស់ដែលត្រាស់ហាម ។

ច្រើនបទថា វិបល្លាសម្បិ សត្តា បដិលភេយ្យុំ : សត្វទាំងឡាយនឹងដល់សេចក្ដីជ្រួលជ្រើមរចល់ មានសេចក្ដីថា សត្វទាំងឡាយគប្បីចូលដល់ការប្រកាន់ឃ្លៀងឃ្លាតទៅ ។

សួរថា គប្បីដល់ការកាន់ឃ្លៀងឃ្លាតយ៉ាងណា ?

ឆ្លើយថា យ៉ាងនេះ គឺ នេះជាផែនដី ឬ មិនមែនជាផែនដីហ្ន៎ ។ ម្យ៉ាងទៀត គឺគប្បីដល់ការប្រកាន់យៀងឃ្លាត ដែលផ្ទុយគ្នាយ៉ាងនេះគឺ នេះជាស្រុករបស់ពួកយើង ឬជាស្រុករបស់អ្នកដទៃហ្ន៎ ។ ក្នុងនិគម ជនបទ ស្រែ និងសួនជាដើម ក៏មានន័យដូចពោលមកហើយនោះ ។

ម្យ៉ាងទៀត នោះ មិនមែនវិបល្លាស ។ ព្រោះថា ឥទ្ធិវិស័យ របស់លោកអ្នកមានឫទ្ធិ ជាអចិន្តេយ្យៈ ។ ចំណែកមនុស្សទាំងឡាយ គប្បីបានទទួលនូវការយល់ខុស យ៉ាងនេះថា ដែលឈ្មោះថា ទុព្ភិក្ខភ័យ នេះ មិនមែនមានតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ, សូម្បីក្នុងអនាគត ក៏ នឹងមាន, ក្នុងគ្រានោះ ភិក្ខុទាំងឡាយ នឹងបានសព្រហ្មចារី អ្នកមានឫទ្ធិ ដូច្នោះ អំពីទីណាហ្ន៎ ? លោកទាំងនោះ ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះសុក្ខវិបស្សកៈ លោកអ្នកបានឈាន និងអ្នកសម្រេច បដិសម្ភិទា សូម្បីជាព្រះខីណាស្រពក៏មាន នឹងចូលទៅបិណ្ឌបាតក្នុង ត្រកូលដទៃ ព្រោះមិនមានកម្លាំងឫទ្ធិ សេចក្តីវិតក្កៈយ៉ាងនេះ របស់ មនុស្សទាំងឡាយ នឹងមានឡើងក្នុងភិក្ខុទាំងនោះថា ក្នុងសម័យពុទ្ធកាល ភិក្ខុទាំងឡាយ បានជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាទាំងឡាយហើយ, លោក ទាំងនោះ បានញ៉ាំងគុណទាំងឡាយ ឱ្យកើតឡើងហើយ ទាំងក្នុងគ្រាមាន

ទុព្ភិក្ខភ័យ ក៏បានត្រឡប់ផែនដី ហើយឆាន់ស្រូវទាប់ខាងក្រោមនៃផែនដី, តែឥឡូវនេះ លោកបានធ្វើឱ្យបរិបូណ៌ក្នុងសិក្ខា រមែងមិនមាន, បើនឹងគប្បីមានសោត ក៏នឹងគប្បីធ្វើដូចយ៉ាងនោះទៀត ដោយគិតថា មនុស្សទាំងឡាយ មិនគប្បីថ្វាយបិណ្ឌបាតដែលឆ្អិន ឬឆៅយ៉ាងណាមួយដល់ពួកយើង ដើម្បីឆាន់ ដូច្នេះ, ព្រោះសេចក្តីរិតក្កៈយ៉ាងនេះថា មនុស្សទាំងនោះ គប្បីបាននូវវិបល្លាស (សេចក្តីយល់ខុស) នេះ ក្នុងព្រះអរិយបុគ្គលទាំងឡាយ ដែលមានខ្លួននៅនុ៎ះឯងថា ព្រះអរិយបុគ្គលទាំងឡាយមិនមាន ; ក៏ឯមនុស្សទាំងឡាយ ដែលតិះដៀលថា រិះគន់នូវព្រះអរិយបុគ្គល ដោយអំណាចវិបល្លាស (សេចក្តីយល់ខុស) នឹងគប្បីជាអ្នកចូលទៅកាន់អបាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អ្នកកុំពេញចិត្ត និងការត្រឡប់ផែនដីនោះឡើយ** ដូច្នេះ ។ គ្រានោះ ព្រះថេរៈ កាលទូលសូមរឿងនេះមិនបាន នឹងទូលសូមរឿងដទៃ (តទៅទៀត) ទើបបានក្រាបទូលពាក្យមានអាទិថា **សូមទ្រង់ព្រះមេត្តាប្រោសព្រះពុទ្ធដីកាដែលទ្រង់ត្រាស់មកនោះប្រពៃហើយ** ព្រះមានព្រះភាគ កាលនឹងទ្រង់ហាមនូវពាក្យទូល សូមសូម្បីនោះ របស់ព្រះថេរៈនោះទៀត ទើបបានត្រាស់ព្រះតម្រាស់ជាដើមថា មោគ្គល្លាន កុំឡើយ ។ ពាក្យថា

សត្វទាំងឡាយ គប្បីបានទទួលសួម្បីវិបល្លាស ដូច្នេះ ទើបព្រះមានព្រះភាគមិនបានត្រាស់ទុកក្នុងពាក្យជាដើមថា **មោគ្គល្លាន កុំឡើយ** ដូច្នេះ ក៏ពិតមែនហើយ, តែថា បណ្ឌិតក៏គួរកាន់យកដោយន័យ ដូចដែលពោលមកហើយពីខាងដើមនុ៎ះឯង ។ មួយទៀត សួម្បីសេចក្ដីនៃពាក្យនោះ ក៏គួរជ្រាប ដូចគ្នាដែលពោលមកហើយនុ៎ះឯង ។ សួរថា ក៏បើព្រះមានព្រះភាគ គប្បីទ្រង់អនុញ្ញាតសោត, តើព្រះថេរៈនឹងធ្វើយ៉ាងណា ? ឆ្លើយថា ព្រះថេរៈគប្បីអធិដ្ឋានមហាសមុទ្រ ឱ្យមានទំហំប៉ុនអណ្ដូង ដែលនឹងគប្បីឆ្លងទៅដោយឈានតែមួយជំហាន ហើយនាំមកអំពីដើមស្មៅ ដែលនទ្បេរុយក្សអាស្រ័យនៅ ប្រាថ្នាឱ្យមានមុខឆ្ពោះទៅកាន់ឧត្តរកុរុទ្វីប ហើយសម្ដែងឧត្តរកុរុទ្វីប ទុកក្នុងទីដែលដល់ព្រមដោយការទៅ និងការមក ឱ្យភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាត ហើយចេញទៅបានតាមសប្បាយ ដូចចូលទៅកាន់គោចរគ្រាម ដូច្នោះ ។

សីហនាទកថារបស់ព្រះមហាមោគ្គល្លាន ចប់ ។

# រឿងបញ្ហាព្រះសារីបុត្រ

[៧] ឥឡូវនេះ ព្រះឧបាលី កាលនឹងសម្ដែងសេចក្ដីដែលព្រះសារីបុត្តត្ថេរ កើតមានសេចក្ដីត្រិះរិះ ដែលបដិសំយុត្តដោយសិក្ខាបទ ដើម្បីសម្ដែងនិទានផ្ដើមខាងដើមនៃការទ្រង់បញ្ញត្តិព្រះវិន័យ ទើបបានពោលពាក្យជាដើមថា អថខោ អាយស្មតោ សារិបុត្តស្ស : គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា រហោគតស្ស : ទៅនៅក្នុងទីរហោឋាន គឺ ទៅហើយក្នុងទីស្ងាត់ ។

បទថា បដិសល្លីនស្ស : ជាទីចេញចាកពួក បានដល់ នៅពួនសម្ងំ គឺ ដល់ភាពជាអ្នកនៅម្នាក់ឯង ។

បទថា កតមេសានំ : អង្គណាខ្លះហ្ន៎ សេចក្ដីថា បណ្ដាព្រះពុទ្ធទាំងឡាយ មានព្រះពុទ្ធវិបស្សីជាដើម ដែលកន្លងទៅហើយ របស់ព្រះពុទ្ធអង្គណា ? ។ ព្រហ្មចរិយៈ ឈ្មោះថាតាំងនៅយូរ ព្រោះអត្ថថាព្រហ្មចរិយៈនោះ តាំងនៅរហូតអស់កាលយូរ ឬមានការតាំងនៅយូរ ។ ពាក្យដែលសល់ក្នុងបទថា អថខោ អាយស្មតោ ជាដើមនេះ មានសេចក្ដីចំពោះបទ ងាយយល់ទាំងអស់ ។

សួរថា ក៏ព្រះថេរៈ មិនអាចនឹងវិនិច្ឆ័យសេចក្ដីបរិវិតក្កៈ របស់ខ្លួននេះ ដោយខ្លួនឯងឬ ?

ខ្ញុំព្រះករុណានឹងពោលឆ្លើយតទៅ ៖

ព្រះថេរៈ ទាំងអាច ទាំងមិនអាច, ពិតមែន ព្រះសារីបុត្តត្រេរនេះរមែងអាចវិនិច្ឆ័យហេតុមានប្រមាណប៉ុណ្ណេះបាន គឺធម្មតា សាសនារបស់ព្រះពុទ្ធទាំងនេះ តាំងនៅមិនបានយូរ, របស់ព្រះពុទ្ធទាំងនេះ តាំងនៅបានយូរ តែលោកមិនអាចដើម្បីវិនិច្ឆ័យហេតុនេះថា សាសនាតាំងនៅមិនបានយូរ ព្រោះហេតុនេះ តាំងនៅបានយូរ ព្រោះហេតុនេះ ដូច្នេះ ។

ចំណែកព្រះមហាបទុមត្ថេរពោលទុកថា ហេតុការណ៍សូម្បីនោះ ក៏ជារបស់មិនធ្ងន់ដល់ព្រះអគ្គសាវក អ្នកបានសម្រេចដល់ទីបំផុតនៃបញ្ញា ១៦ យ៉ាងឡើយ, ចំណែកការដែលព្រះអគ្គសាវក អ្នកនៅក្នុងស្ថានទីជាមួយ នឹងព្រះសម្មាសម្ពុទ្ធ ធ្វើការវិនិច្ឆ័យដោយខ្លួនឯង ក៏ដូចជាការលះបោលជញ្ជីង ហើយត្រឡប់ថ្លឹងដោយដៃ ; ព្រោះហេតុនោះ ទើបព្រះថេរៈចូលទៅគាល់ទូលសួរព្រះមានព្រះភាគ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់វិសជ្ជនាពាក្យទូលសួររបស់ព្រះថេរៈនោះ ទើបត្រាស់ព្រះតម្រាស់ជាដើមថា "ភគវតោ ច សារីបុត្ត វិបស្សិស្ស : ម្នាលសារីបុត្រ (ព្រហ្មចរិយៈ)របស់ព្រះមានព្រះភាគ ព្រះនាមវិបស្សី

១” ដូច្នេះ ។ ពាក្យនោះមានសេចក្ដីងាយយល់ទាំងអស់ ។

ព្រះថេរៈ កាលនឹងទូលសួរដល់ហេតុការណ៍តទៅទៀត ទើបបានក្រាបទូលពាក្យជាដើមថា កោ នុ ខោ ភន្តេ ហេតុ : សូមទ្រង់ព្រះមេត្តាប្រោស តើព្រោះហេតុដូចម្ដេច ។

បណ្ដាបទទាំងនោះ បទថា កោ នុ ខោ ភន្តេ ជាពាក្យទូលសួរដល់ហេតុការណ៍ ។ សេចក្ដីនៃបទនោះថា ហេតុដូចម្ដេចហ្ន៎ ? ព្រះអង្គ ។

ពាក្យទាំងពីរនេះគឺ ហេតុ បច្ចយោ ជាឈ្មោះនៃការណ៍ ពិតមែន ការណ៍លោកហៅថា ហេតុ ព្រោះជាគ្រឿងហូរចេញ គឺ ប្រព្រឹត្តទៅនៃផលរបស់ការណ៍នោះ ។ ព្រោះផលអាស្រ័យការណ៍នោះហើយទើបដំណើរ គឺ ទើបប្រព្រឹត្តទៅបាន ដូច្នោះ ទើបលោកហៅថា បច្ច័យ ។ បទសូម្បីទាំងពីរនេះក្នុងទីនោះ ៗ សូម្បីតែមួយដូចគ្នាដោយសេចក្ដី ព្រះថេរៈក៏ពោលទុក ដោយអំណាចនៃវោហារ និងដោយសេចក្ដីពីរោះរណ្ដំនៃពាក្យ ដូចដែលពោលមកហើយនោះ ។ ពាក្យដែលសល់ក្នុងពាក្យថា កោ នុ ខោ ជាដើមនេះ ក៏មានសេចក្ដីងាយយល់ទាំងអស់ ។

## ព្រះពុទ្ធទ្រង់សម្ដែងធម៌ដល់បរិស័ទច្រើនឬតិចក៏ដោយ

ក៏ដើម្បីនឹងសម្ដែងហេតុនិងបច្ច័យនោះ ក្នុងឥឡូវនេះ ព្រះមានព្រះភាគ ទើបត្រាស់ព្រះតម្រាស់ជាដើមថា សារីបុត្ត វិបស្សី ។

បណ្ដាបទទាំងនោះ បទថា គិលាសុនោ អហេសុម : ព្រះអង្គមិនស្ងួវប្រឹងប្រែង សេចក្ដីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម មិនមែនទ្រង់រាថយព្រះទ័យព្រោះសេចក្ដីខ្ជិលច្រអូសទេ ។ ពិតមែន ការខ្ជិលច្រអូសក្ដី ការមានព្រះវិរិយភាពធូរថយក្ដី របស់ព្រះពុទ្ធទាំងឡាយមិនមានទេ ។ ព្រោះថា ព្រះពុទ្ធទាំងឡាយ កាលនឹងទ្រង់សម្ដែងធម៌ដល់មួយចក្រវាឡក្ដី ពីរចក្រវាឡក្ដី ចក្រវាឡទាំងអស់ក្ដី រមែងទ្រង់សម្ដែងដោយព្រះឧស្សាហ៍ស្មើគ្នាតែម្ដង គ្រាទតឃើញបរិស័ទមានចំនួនតិចហើយទ្រង់ថយព្រះវិរិយភាពចុះក៏ទេ ទាំងទតឃើញបរិស័ទមានចំនួនច្រើនហើយទ្រង់មានព្រះវិរិយភាពច្រើនឡើងក៏ទេ ។ ដូចជា រាជសីហ៍ ជាស្ដេចនៃម្រឹគ កន្លងទៅ ៧ ថ្ងៃ ទើបចេញទៅដើម្បីរកស៊ី កាលប្រទះឃើញសត្វតូច ឬធំក៏ដោយ រមែងរត់ទៅដោយល្បឿនដ៏លឿនរហ័ស ដូចគ្នាជានិច្ច, សេចក្ដីនោះ ព្រោះហេតុនៃអ្វី ? ព្រោះហេតុនៃសេចក្ដីដាក់ចិត្តថា ការលឿនរហ័សរបស់យើងកុំសាបសូន្យទៅ ដូច្នេះ យ៉ាងណា ព្រះពុទ្ធទាំង

ឡាយ ក៏យ៉ាងនោះ រមែងទ្រង់សម្តែងធម៌ដល់បរិស័ទ ទោះជាមានចំនួនតិចក្តី ច្រើនក្តី ក៏ទ្រង់សម្តែងដោយព្រះឧស្សាហ៍ស្មើគ្នាទាំងអស់, សេចក្តីនោះ ព្រោះហេតុអ្វី ? ព្រោះហេតុនៃសេចក្តីយល់ក្នុងព្រះទ័យថា ពួកជនអ្នកជូន់ក្នុងធម៌របស់យើង កុំបានសាបសូន្យទៅ ដូច្នេះ ។ ពិតមែន ព្រះពុទ្ធទាំងឡាយ ទ្រង់ជូន់ក្នុងធម៌ ទ្រង់គោរពព្រះធម៌ ។ ដូចយ៉ាងថា ព្រះមានព្រះភាគរបស់យើងទាំងឡាយ ទ្រង់បានសម្តែងធម៌ដោយពិស្តារ ដូច (វលាហកទេវតា) ញុំាងមហាសមុទ្រសាគរឱ្យពេញប្រៀបយ៉ាងណា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើមទាំងនោះ មិនបានសម្តែងធម៌ដូច្នោះទេ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្តីដែលសត្វទាំងឡាយ មានធូលី គឺកិលេសក្នុងបញ្ញាចក្ខុតិចឬស្រាលស្តើង ។

ដូចបានស្តាប់មកថា ក្នុងកាលនៃព្រះពុទ្ធទាំងនោះ សត្វទាំងឡាយមានអាយុវែង បានជាអ្នកមានធូលី គឺ កិលេសក្នុងបញ្ញាចក្ខុតិចស្រាលខ្វះ ។ សត្វទាំងនោះល្មមបានស្តាប់សូម្បីព្រះគាថាតែមួយ ដែលប្រកបដោយសច្ចៈ ៤ រមែងសម្រេចធម៌បាន; ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងនោះ ទ្រង់មិនសម្តែងធម៌ដោយពិស្តារ ។ ក៏ព្រោះហេតុនោះឯង

នវង្គសត្ថុសាសនៈរបស់ព្រះពុទ្ធទាំងនោះ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម៌ វេទល្លៈ ទើបបានមានតិច ។ ការដែលនវង្គសត្ថុសាសន៍ មានសុត្តៈជាដើម ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងពាក្យថា អប្បកញ្ច : តិចតួចណាស់ ជាដើមនោះ ជាផ្សេង ៗ គ្នា ខ្ញុំព្រះករុណាបានពោលទុកហើយក្នុងវណ្ណនាបឋមសង្គីតិនោះឯង ។

## ព្រះវិបស្សីជាដើមទ្រង់មិនបានបញ្ញត្តិសិក្ខាបទជាដើមទេ

ប្រើនបទថា អប្បញ្ញត្តំ សាវកានំ សិក្ខាបទំ : សិក្ខាបទក៏ទ្រង់មិនបានបញ្ញត្តិដល់សាវកទាំងឡាយទេ សេចក្តីថា សិក្ខាបទ គឺច្បាប់ព្រះវិន័យដោយអំណាចអាបត្តិ ៧ កង ដែលគួរទ្រង់បញ្ញត្តិ ដោយសមគួរដល់ទោសដែលព្រះពុទ្ធមានព្រះវិបស្សីជាដើមទាំងនោះ ទ្រង់មិនបានបញ្ញត្តិទុក ដល់ព្រះសាវកទាំងឡាយ ព្រោះជាអ្នកមិនមានទោស ។

ពីរបទថា អនុទ្දិដ្ឋំ បាតិមោក្ខំ : អាណាបាតិមោក្ខ ក៏ព្រះពុទ្ធទាំងនោះមិនបានសម្តែងឡើយ សេចក្តីថា ព្រះបាតិមោក្ខ គឺច្បាប់ព្រះវិន័យ ក៏ទ្រង់មិនបានសម្តែងរាល់កន្លះខែ ។ ព្រះពុទ្ធទាំងនោះ ទ្រង់បានសម្តែងតែឱវាទបាតិមោក្ខ ប៉ុណ្ណោះ និងសូម្បីឱវាទបាតិមោក្ខនោះ ក៏

មិនបានសម្តែងរាល់កន្លះខែ ។ ពិតមែន ព្រះមានព្រះភាគវិបស្សី ទ្រង់សម្តែងឱវាទបាតិមោក្ខ ៦ ឆ្នាំម្តង ៗ ក៏ឯឱវាទបាតិមោក្ខនោះ ទ្រង់សម្តែងដោយព្រះអង្គឯងទាំងនោះ ។

ចំណែកពួកសាវករបស់ព្រះអង្គមិនបានសម្តែងក្នុងទីនៅរបស់ខ្លួន ៗ ភិក្ខុសង្ឃទាំងអស់ក្នុងសកលជម្ពូទ្វីប ធ្វើឧបោសថ ក្នុងទីកន្លែងតែមួយប៉ុណ្ណោះ គឺ ក្នុងឧទ្យានខេមមិគទាយវែនជិតរាជធានី ឈ្មោះពន្ធុមតី ដែលជាទីស្តេចប្រថាប់របស់ព្រះមានព្រះភាគវិបស្សី ។ ក៏ឯឧបោសថនោះបានធ្វើជាសង្ឃឧបោសថតែម្យ៉ាង មិនបានធ្វើជាគណៈឧបោសថ បុគ្គលឧបោសថ បារិសុទ្ធិឧបោសថ អធិដ្ឋានឧបោសថទេ បានជ្រាបថា ក្នុងវេលានោះ ក្នុងជម្ពូទ្វីប មានវិហារប្រាំបីម៉ឺនបួនពាន់ ក្នុងវិហារនីមួយ ៗ មានភិក្ខុនៅពាសពេញ វិហារមួយ ៗមួយម៉ឺនរូបខ្លះ ពីរម៉ឺនរូបខ្លះ បីម៉ឺនរូបខ្លះ ច្រើនជាងនោះខ្លះ ។

## ពួកទេវតាប្រាប់ថ្ងៃធ្វើឧបោសថដល់ពួកភិក្ខុ

ពួកទេវតាអ្នកប្រាប់ថ្ងៃឧបោសថ ត្រាច់ទៅប្រាប់ក្នុងទីនោះ ៗ ថា "លោកនិរទុក្ខទាំងឡាយ កន្លងទៅមួយឆ្នាំហើយ កន្លងទៅ ២ ឆ្នាំ ៣ ឆ្នាំ ៤ ឆ្នាំ ៥ ឆ្នាំហើយ, នេះឆ្នាំទី ៦ កាលតិថីខែពេញបូរមីមកដល់ ពួកលោកគួរទៅដើម្បីគាល់ព្រះពុទ្ធនិងដើម្បីធ្វើឧបោសថ កាលប្រជុំរបស់ពួក

លោកមកដល់ហើយ ក្នុងវេលានោះ ពួកភិក្ខុដែលមានអានុភាព ក៏ទៅដោយអានុភាពរបស់ខ្លួន ពួកក្រៅនេះទៅដោយអានុភាពរបស់ទេវតា ។

សួរថា ពួកក្រៅនេះទៅដោយអានុភាពរបស់ទេវតាបានយ៉ាងណា ?

ឆ្លើយថា បានជ្រាបថា ភិក្ខុទាំងនោះអ្នកនៅជិតសមុទ្រខាងទិសបូព៌ាឬជិតសមុទ្រខាងទិសបច្ចិម ឧត្តរ និងទក្សិណ បំពេញគមិយវត្តហើយកាន់យកបាត្រនិងចីវរ ញុំាងសេចក្តីគិតឱ្យកើតឡើងថា នឹងទៅ ។ ព្រមដោយចិត្តុប្បាទ ពួកលោកក៏ជាអ្នកទៅកាន់រោងឧបោសថ ។ ពួកភិក្ខុថ្វាយអភិវាទព្រះវិបស្សីសម្មាសម្ពុទ្ធហើយអង្គុយ ។

## ឱវាទបាតិមោក្ខគាថា

សូម្បីព្រះមានព្រះភាគ ក៏ទ្រង់សម្តែងឱវាទបាតិមោក្ខនេះ ក្នុងបរិស័ទអ្នកអង្គុយប្រជុំគ្នាហើយថា ៖

"សព្វបាបស្ស អករណំ    កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ    ឯតំ ពុទ្ធាន សាសនំ ។

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឱ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តី បរមំ តបោ តិតិក្ខា និព្ពានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី ន សមណោ ហោតិ
បរំ វិហេឋយន្តោ ។

(អធិប្បាយ) ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងពោលថា ព្រះនិព្វាន ជាធម្មជាតិដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថាបព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថាសមណៈឡើយ ។

អនុបវាទោ អនុបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ

ការមិនតិះដៀល១ ការមិនបៀតបៀន១ ការសង្រួមក្នុងបាតិមោក្ខ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត១ ការដេកនិងអង្គុយក្នុងទីស្ងាត់១ ការព្យាយាមក្នុងអធិចិត្ត១ នុះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។"(១)

(១). ទីឃ. មហា. ១៦. ៤៥-១០៣; ខុទ្ទ. ធម្ម. ៥២. ២៤-៥៩ ។

គប្បីជ្រាបបាតិមោក្ខុទ្ទេសរបស់ព្រះពុទ្ធទាំងឡាយ សូម្បីក្រៅនេះ ដោយឧបាយនេះឯង ។ ពិតមែន ព្រះពុទ្ធគ្រប់ព្រះអង្គ មានព្រះឱវាទបា្បតិមោក្ខគាថា ត្រឹមតែ ៣គាថា នេះប៉ុណ្ណោះ ។ គាថាទាំងនោះ រមែងមកកាន់ឧទ្ទេស ដរាបដល់ទីបំផុតនៃព្រះសាសនារបស់ព្រះពុទ្ធ ដែលមានព្រះជន្មាយុវែង ៗទាំងឡាយ ។ តែសម្រាប់ព្រះពុទ្ធមានព្រះជន្មាយុតិចទាំងឡាយ គាថាទាំងនោះ មកកាន់ឧទ្ទេសតែក្នុងបឋមពោធិកាលប៉ុណ្ណោះ ។ ដោយថា ចាប់ផ្តើមតាំងពីវេលាទ្រង់បញ្ញត្តិសិក្ខាបទមក ក៏សម្តែងចំពោះអាណាបាតិមោក្ខប៉ុណ្ណោះ ។ ក៏ឯអាណាបាតិមោក្ខនោះ ពួកភិក្ខុប៉ុណ្ណោះសម្តែង ។ ព្រះពុទ្ធទាំងឡាយទ្រង់មិនសម្តែងទេ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ សូម្បីរបស់ពួកយើង ក៏ទ្រង់សម្តែងឱវាទបា្បតិមោក្ខនេះ រហូតដល់អស់វេលាត្រឹមតែ ២០ វស្សា ក្នុងបឋមពោធិកាលប៉ុណ្ណោះ ។

## ហេតុដែលព្រះពុទ្ធទ្រង់មិនធ្វើឧបោសថនិងបាតិមោក្ខ

តមកថ្ងៃមួយ ព្រះមានព្រះភាគ ប្រថាប់អង្គុយនៅត្រង់ប្រាសាទរបស់មិគារមាតាក្នុងបុព្វារាម បានត្រាស់ហៅភិក្ខុទាំងឡាយមកថា "ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តាំងពីថ្ងៃនេះតទៅមុខ តថាគតនឹងមិនធ្វើឧបោសថ មិនសម្តែងបាតិមោក្ខទេ, ម្នាលភិក្ខុទាំងឡាយ ក្នុងកាល

ឥឡូវនេះ ចាប់ដើមអំពីថ្ងៃនេះតទៅមុខ ចូរអ្នកទាំងឡាយ នាំគ្នាធ្វើឧបោសថ សម្តែងបាតិមោក្ខចុះ, ម្នាលភិក្ខុទាំងឡាយ តថាគតនឹងមិនធ្វើឧបោសថ សម្តែងបាតិមោក្ខ ជាមួយនឹងបរិស័ទ មិនបរិសុទ្ធិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង មិនមែនជាឱកាស (លុះមិនធ្វើបានទេ)"[១] ។

តាំងពីនោះមក ពួកភិក្ខុក៏សម្តែងអាណាបាតិមោក្ខ ។ អាណាបាតិមោក្ខនេះជារបស់ដែលព្រះពុទ្ធ ៣ ព្រះអង្គ មានព្រះវិបស្សីជាដើម ទ្រង់មិនលើកឡើងសម្តែងដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា អនុទ្ទិដ្ឋំ បាតិមោក្ខំ ។

## ហេតុឱ្យព្រះសាសនាតាំងនៅមិនយូរនិងយូរ

ពាក្យថា តេសំ ពុទ្ធានំ : ព្រះពុទ្ធដ៏មានជោគទាំងឡាយនោះ សេចក្តីថា នៃព្រះពុទ្ធទាំង ៣ ព្រះអង្គមានព្រះវិបស្សីជាដើមទាំងនោះ ។ បទថា អន្តរធានេន អំណើះឥតអំពី...ទៅ គឺ ព្រោះខន្ធអន្តរធានទៅ, មានអធិប្បាយថា ព្រោះបរិនិព្វាន ។

---

១. វិន. ចុល្ល. បាតិមោក្ខដ្ឋបនក្ខន្ធកៈ. ១១. ១៣០/២១៦ ។

បទថា ពុទ្ធានុពុទ្ធានំ : សាវកទាំងឡាយ ជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ សេចក្ដីថា និងព្រោះសេចក្ដីអន្តរធានទៅនៃខន្ធរបស់ពួកព្រះសាវក ដែលបានត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ គឺ ព្រះសាវកដែលបានឃើញព្រះសាស្ដា ។

ពាក្យថា យេ តេបច្ឆិមា សាវកា : សាវកទាំងឡាយ ជាខាងក្រោយមកនោះ សេចក្ដីថា ពួកបច្ឆិមសាវកដែលបួសក្នុងសំណាក់របស់ពួកសាវកអ្នកបានឃើញព្រះសាស្ដា ។

បទថា នានានាមា : នាមផ្សេង ៗ សេចក្ដីថា មានឈ្មោះផ្សេង ៗ គ្នា ដោយអំណាចឈ្មោះជាដើមថា ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ។ បទថា នានាគោត្តា : គោត្តផ្សេង ៗ សេចក្ដីថា មានគោត្រផ្សេងគ្នា ដោយអំណាចគោត្រជាដើមថា គោតមៈ មោគ្គល្លាន ។

បទថា នានាជច្ចា : មានជាតិផ្សេង ៗ គឺ មានជាតិផ្សេងគ្នា ដោយអំណាចជាតិជាដើមថា ក្សត្រិយ៍ ព្រាហ្មណ៍ ។

ពីរបទថា នានាកុលា បព្វជិតា : បេញពីត្រកូលផ្សេង ៗ គ្នា ហើយបួស សេចក្ដីថា បេញបួសអំពីត្រកូលផ្សេងគ្នា ដោយអំណាចត្រកូលក្សត្រិយ៍ជាដើម ឬដោយអំណាចត្រកូល មានត្រកូលខ្ពស់

ត្រកូលទាប ត្រកូលមានភោគៈច្រើន និងតិចជាដើម ។

ពាក្យថា តេ តំ ព្រហ្មចរិយំ : សាវកក្រោយនោះ ក៏ញ៉ាំងព្រហ្មចរិយធម៌នោះ សេចក្តីថា ព្រោះបច្ឆិមសាវកទាំងនោះ ធ្វើក្នុងចិត្តថា ពួកយើងមានឈ្មោះតែមួយដូចគ្នា មានគោត្រតែមួយដូចគ្នា មានជាតិតែមួយដូចគ្នា បួសអំពីត្រកូលតែមួយដូចគ្នា សាសនាជាបែបផែនប្រពៃណីរបស់ពួកយើង ទើបជួយគ្នារក្សាព្រហ្មចរិយធ្វើឱ្យជាភារៈរបស់ខ្លួន បរិហារព្រះបរិយត្តិធម៌ទុកឱ្យយូរ តែបច្ឆិមសាវកទាំងនេះ មិនជាយ៉ាងនោះ ព្រោះដូច្នោះ ទើបពួកលោកបៀតបៀនគ្នា ប្រកាន់ការយល់ឃើញទំនាស់គ្នាធ្វើធុរថយដោយប្រកាន់មាំថា ព្រះថេរៈឯណោះទឹងជឹង ព្រះថេរៈឯណោះទឹងជ្រាប គប្បីញ៉ាំងព្រហ្មចរិយនោះឱ្យអន្តរធានទៅឆាប់រហ័សតែម្តង គឺ មិនលើកឡើងកាន់ការសង្គាយនារក្សាទុក ។

ពាក្យថា សេយ្យថាបិ : ការឧបមាដូចជា ជាការសម្តែងខ្លឹមសេចក្តីនោះដោយការឧបមា ។

បទថា វិកិរតិ : រមែងតែបក់បោក គឺ រមែងបក់រាត់រាយ ។

បទថា វិធមតិ : កំចាត់កំចាយ គឺ រមែងបក់ខ្ចាយទៅកាន់ទីដទៃ ។

បទថា វិធំសេតិ : ឱ្យវិនាសអស់ទៅ គឺ រមែងបក់ចេញទៅចាកទីដែលតាំងនៅ ។

ពាក្យថា យថាតំ សុត្តេន អសង្គហិតត្តា : ពីព្រោះផ្កាទាំងនោះ គេមិនបានដោតក្រងចងដោយខ្សែ សេចក្ដីថា ខ្យល់ រមែងបក់ខ្ចាយទៅដូចបក់ផ្កាឈើឱ្យរាត់រាយ ព្រោះមិនបានក្រង ព្រោះមិនបានចងដោយអំបោះ ដូច្នោះ ។ មានពាក្យអធិប្បាយថា (ផ្កាឈើទាំងឡាយ) ដែលមិនបានឃុំគ្រងដោយអំបោះ រមែងត្រូវខ្យល់បក់ឱ្យខ្ចាត់ខ្ចាយទៅយ៉ាងណា រមែងរាត់រាយទៅ យ៉ាងនោះ ។

ពាក្យថា ឯវមេវ ខោ : យ៉ាងណាមិញ ជាការញ៉ាំងសេចក្ដីឧបមេយ្យឱ្យដល់ព្រម ។

បទថា អន្តរធាបេសុំ : ញ៉ាំងឱ្យវិនាសទៅ សេចក្ដីថា (ពួកសាវកខាងក្រោយ) កាលមិនសង្គ្រោះ (គឺ សង្គាយនាជាពួក) ដោយវគ្គសង្គហ: និងបណ្ណាសសង្គហ:ជាដើម កាន់យកតែព្រហ្មចរិយ ពោល គឺ បរិយត្តិធម៌ដែលខ្ជិនពេញចិត្តប៉ុណ្ណោះ ចំណែកដែលសល់ក៏បញ្ចេញឱ្យវិនាសទៅ គឺ នាំទៅកាន់ការមិនប្រាកដ ។

ពាក្យថា អកិលាសុនោ ច តេ ភគវន្តោ អហេសុំ

សាវកានំ ចេតសាចេតោ បរិច្ច ឱវទិតុំ : ព្រះពុទ្ធដ៏មានជោគទាំងនោះ លោកមិនសូវប្រឹងប្រែងស្ទង់ចិត្ត(របស់សាវក) ដោយព្រះទ័យ(របស់ព្រះអង្គ) ហើយទូន្មាននូវសាវកទាំងឡាយប៉ុន្មានឡើយ មានសេចក្តីថា ម្នាលសារីបុត្រ ម្យ៉ាងទៀត ព្រះពុទ្ធទាំងនោះ ទ្រង់មិនមានព្រះហឫទ័យប្រឹងប្រែង ដើម្បីនឹងទ្រង់ប៉ាន់ស្មាន គឺ កំណត់ចិត្តរបស់ពួកសាវកដោយព្រះហឫទ័យរបស់ព្រះអង្គ ហើយទ្រង់ប្រៀនប្រដៅ គឺ ទ្រង់ជ្រាបចិត្តរបស់អ្នកដទៃហើយ ទ្រង់សម្តែងការណែនាំទូន្មាន ដោយមិនជាការៈធ្ងន់ ដោយមិនយឺតយូរ ។ ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់ជាដើមថា ភូតបុព្វំ សារិបុត្ត : ម្នាលសារីបុត្រ ពីដើមមកមានរឿងតំណាលថា ដូច្នេះ ដើម្បីប្រកាសសេចក្តីដែលព្រះពុទ្ធទាំងនោះ ទ្រង់មិនមានព្រះហឫទ័យប្រឹងប្រែង ។

បទថា ភឹសនកេ : ជាដងព្រៃគួរស្បើម គឺ គួរគប្បីខ្លាច បានដល់ ឱ្យកើតសេចក្តីគួរស្ញែតរន្ធត់ ។

ពាក្យថា ឯវំ វិតក្កេថ : អ្នកទាំងឡាយចូររិះគិតយ៉ាងនេះ សេចក្តីថា ពួកលោកចូរត្រិះរិះកុសលវិតក្កៈ ៣ មាននេក្ខម្មវិតក្កៈជាដើម ។

ពាក្យថា មា ឯវំ វិតក្កយិត្ថ : កុំគិតយ៉ាងនេះឡើយ សេចក្ដីថា ពួកលោកកុំបានត្រិះរិះអកុសលវិតក្កៈ ៣ មានកាមវិតក្កៈជាដើម ។

ពាក្យថា ឯវំ មនសិ ករោថ : ចូរយកចិត្តទុកដាក់យ៉ាងនេះ សេចក្ដីថា ពួកលោកចូរធ្វើទុកក្នុងចិត្តថា មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត មិនល្អ ។

ថា មា ឯវំ មនសាកត្ថ : កុំយកចិត្តទុកដាក់យ៉ាងនេះឡើយ សេចក្ដីថា ពួកលោកកុំធ្វើក្នុងចិត្តថា ទៀង ជាសុខ ជាអត្តា ស្អាត ល្អ ។

ពាក្យថា ឥទំ បជហថ : ចូរលះបង់អំពើយ៉ាងនេះចេញ គឺចូរលះអកុសល ។

ពាក្យថា ឥទំ ឧបសម្បជ្ជ វិហរថ : ហើយចូរផ្ដេកផ្ដួលឱ្យប្រជិតប្រជីទៅរកអំពើនេះវិញ សេចក្ដីថា ពួកលោកចូរចូលដល់ ត្រឡប់បាន គឺ ឱ្យកុសលសម្រេចចុះ ។

ថា អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចិំសុ : ចិត្តរបស់ភិក្ខុទាំង ១ ពាន់រូបនោះ ក៏បានរួចចាកអាសវក្កិលេស គឺរួចផុតហើយព្រោះមិនប្រកាន់មាំ ។ ពិតមែន ចិត្តរបស់ព្រះសាវកទាំងនោះ រួច

ផុតចាកពីអាសវៈពួកណា ចិត្តទាំងនោះរួចផុតហើយ ព្រោះមិនប្រកាន់មាំអាសវៈទាំងនោះ[១] ។ ក៏អាសវៈទាំងឡាយ រលត់ទៅ ដោយសេចក្តីរលត់ គឺ ការមិនកើតឡើង ឈ្មោះថា រួចផុតហើយ ព្រោះមិនប្រកាន់មាំ[២] ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ ។

ភិក្ខុទាំងអស់នោះ បានសម្រេចព្រះអរហត្តហើយ ជាអ្នកមានចិត្តរីករាយដូចផ្កាឈូកដែលត្រូវពន្លឺព្រះអាទិត្យដូច្នោះ ។

ក្នុងខថា តត្រ សុទំ សារិបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកតស្មឹ ហោតិ : ម្នាលសារីបុត្រ ដងព្រៃដែលមាននៅទីនោះ មុខគួរឱ្យស្ញែងពេកណាស់ នេះ ពាក្យថា តត្រ ជាពាក្យពោលសម្លឹង

---

១. សារត្ថទីបនី. ឱ្យប្រែថា ពិតមែន ចិត្តទាំងឡាយរបស់ព្រះសាវកទាំងនោះ ដែលអាសវៈពួកណារួចផុតទៅហើយ អាសវៈទាំងនោះ ឈ្មោះថា រួចផុតទៅហើយ ព្រោះមិនប្រកាន់ចិត្តទាំងនោះ ដោយអំណាចនៃអារម្មណ៍ ។ ២. យោជនាបាលី ជា អនុប្បាទនិរោធេន បទ អនុប្បាទសង្ខាតនិរោធវសេន និរុជ្ឈមានេ អាសវេ អគ្គហេត្វា ចិត្តានិ វិមុច្ចឹសុ ប្រែថា ក៏ចិត្តទាំងឡាយរបួតផុតហើយ ព្រោះមិនប្រកាន់អាសវៈទាំងឡាយដែលរលត់ទៅ នៅដោយសេចក្តីរលត់ ពោលគឺ ការមិនកើតឡើងទៀត ។

ដល់ពាក្យដើម ។ ពាក្យថា សុទំ ជានិបាតចុះក្នុងអត្ថត្រឹមតែធ្វើបទឱ្យពេញ ។ បទថា សារីបុត្ត ជាអាលបនៈ ។

ក៏ក្នុងពាក្យថា តត្រ សុទំ ជាដើមនេះ មានអត្ថយោជនាដូចតទៅនេះ ៖

បទថា តត្រ : **នៅទីនោះ** សេចក្តីថា នៃព្រៃស្រោងដែលគួរគប្បីខ្លាច ដែលព្រះមានព្រះភាគ ត្រាស់ទុកថា ភឹសនកៈ ក្នុងព្រះតម្រាស់ដែលព្រះអង្គត្រាស់ទុកថា អញ្ញតរស្មឹ ភឹសនកេ វនសណ្ឌេ, អធិប្បាយថា ភាវៈដែលគួរគប្បីខ្លាច ឈ្មោះថា សេចក្តីគួរស្លុតរន្ធត់មានក្នុងភាវៈគួរស្លុតរន្ធត់គឺ ក្នុងការធ្វើ ឱ្យស្លុតខ្លាច ។ សួរថា ជាយ៉ាងណា ? ឆ្លើយថា ជាយ៉ាងនេះគឺអ្នកណាម្នាក់ដែលមិនទាន់ប្រាសចាករាគៈចូលទៅកាន់ព្រៃស្រោងនោះដោយច្រើន លោមជាតិ រមែងព្រឺរោម ។ម្យ៉ាងទៀត ពាក្យថា តត្រ ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

ស័ព្ទថា សុ ជានិបាត ដូចក្នុងប្រយោគទាំងឡាយជាដើមថា “កឹសុ នាម តេ ភោន្តោ សមណព្រាហ្មណា : ចុះហេតុអ្វីបានជាសមណព្រាហ្មណ៍ដ៏ចម្រើន អម្បាលនោះ”[១] ។ បទថា ឥទំ បណ្ឌិតគប្បីឃើញ

---

១. មជ្ឈិ. មូល. ចូឡធម្មសមាទានសូត្រ. ២២. ១៥៦/៣០៥ ។

ថា ជាពាក្យសម្តែងអត្ថន័យតាមដែលប្រាថ្នាដូចធ្វើឱ្យឃើញបានច្បាស់ ។ ពាក្យថា សុ ឥធំ សន្ធិចូលជា សុធំ ។ គប្បីជ្រាបថា លុប ឥ អក្សរ ដោយអំណាចនៃសន្ធិ ដូចក្នុងប្រយោគទាំងឡាយជាដើមថា "ចក្ខុន្ទ្រិយំ ឥត្ថិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ : ឥន្ទ្រិយ គឺភ្នែក ឥន្ទ្រិយ គឺភេទស្រី ឥន្ទ្រិយ គឺការតាំងចិត្តថា នឹងដឹងច្បាស់នូវអមតនិព្វាន ឬចតុសច្ចធម៌ដែលមិនទាន់ដឹងហើយ"[១] ។ "កឹសូធ វិត្តំ : ក្នុងលោកនេះ អ្វីជាទ្រព្យ (គ្រឿងរីករាយចិត្ត)"[២] ។ ក៏ក្នុងពាក្យនេះមានអត្ថយោជនាដូចតទៅនេះ ៖ "ម្នាលសារីបុត្រ ដងព្រៃដែលមាននៅទីមុខនោះគួរស្ញើមពេកណាស់" ទើបមានពាក្យនិយាយគ្នាដូច្នេះឯង ។ បទថា ភឹសនកតស្មឹ : គួរស្ញើមពេកណាស់ សេចក្តីថា ក្នុងព្រោះព្រៃស្រោងជាទីដែលគួរខ្លាច ។ គប្បីឃើញថា លុប ត អក្សរមួយទៅ ។ មួយទៀត ព្រះបាលីថា ភឹសនកត្តស្មឹ ដូច្នេះក៏មាន ។ មួយទៀត ក្នុងកាលគួរនឹងពោលជាឥត្ថីលិង្គថា ភឹសនកតាយ លោកក៏ធ្វើឱ្យជាលិង្គវិបល្លាស ។ ក៏ក្នុងពាក្យថា ភឹសនកតស្មឹ នេះជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្ត ។

១. អភិ. វិភ. ឥន្ទ្រិយវិភង្គ ៨០. ២៣៦/២៤៧ ។ ២. ខុទ្ទ. សុត្ត. អាឡវកសូត្រ. ៥៤. ១៨/៦២ ។

ព្រោះដូច្នោះ គប្បីឃើញសម្ពន្ធយ៉ាងនេះថា ពាក្យនេះឯង រមែងមានក្នុងព្រោះសេចក្តីដែលព្រៃស្រោងគួរខ្លាច ជាអាវាសដែលមានសេចក្តីស្ដុតរន្ធត់ជានិមិត្ត គឺ មានពាក្យនិយាយនេះឯង ព្រោះមានសេចក្តីស្ដុតរន្ធត់ជាហេតុ ព្រោះមានសេចក្តីស្ដុតរន្ធត់ជាបច្ច័យ ពាក្យថា អ្នកណាម្នាក់ដែលមិនទាន់ប្រាសចាករាគៈ ចូលទៅកាន់ព្រៃស្រោងនោះ ដោយច្រើន លោមជាតិ រមែងព្រឺរោម សេចក្តីថា រោមជាច្រើនណាស់ រមែងព្រឺគឺ តាំងបះចុងឡើងដូចជាទឹងម្ជុលនិងដូចជាទឹងបន្លា ចំនួនតិចមិនព្រឺរោម មួយទៀត លោមជាតិរបស់សត្វចំនួនជាច្រើន រមែងព្រឺ តែរបស់អ្នកក្លាហានក្រៃលែងតិចណាស់ រមែងមិនព្រឺ ។

ឥឡូវនេះ មានពាក្យថា អយំ ខោ សារីបុត្ត ហេតុ អយំ បច្ចយោ : ម្នាលសារីបុត្រ ព្រោះហេតុនិងបច្ច័យប៉ុណ្ណេះឯង ជាដើម ជាពាក្យពោលដដែល ៗ ចំណែកពាក្យដែលខ្ញុំព្រះករុណាមិនបានពោលទុកក្នុងចន្លោះ ៗ ក្នុងព្រះបាលីនេះ មានអត្ថងាយយល់ទាំងអស់ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបតាមលំដាប់នៃព្រះបាលីនោះឯង ។ តែព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា មិនតាំងនៅយូរ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់ដោយអំណាចនៃយុគ (សម័យកាល)របស់មនុស្ស ។

## ព្រះពុទ្ធវិបស្សីជាដើមមានអាយុកាលផ្សេងគ្នា

ពិតមែន ព្រះមានព្រះភាគវិបស្សីដោយការរាប់ឆ្នាំ មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ សូម្បីពួកសាវករបស់ព្រះអង្គ ក៏អាយុប្រមាណប៉ុណ្ណោះឆ្នាំដូចគ្នា ។ ព្រហ្មចរិយ (សាសនា) បន្តដោយសាវករបស់ព្រះមានព្រះភាគនោះ ដែលជាអង្គចុងគេបង្អស់ តាំងនៅបានរហូតដល់អស់ ១សែន ៦ម៉ឺនឆ្នាំ ដោយប្រការយ៉ាងនេះ ។ តែដោយអំណាចនៃយុគមនុស្ស ព្រហ្មចរិយបានតាំងនៅតមក ដោយការបន្តគ្នានៃយុគជរាបដល់តំណមនុស្ស ២ យុគប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា មិនតាំងនៅយូរ ។ ក៏ព្រះមានព្រះភាគព្រះនាមថា សិខី មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ សូម្បីពួកសាវកនៅចំពោះព្រះភក្ត្រ (គឺបានទាន់) ព្រះអង្គ ក៏មានអាយុប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រះមានព្រះភាគព្រះនាមថា វេស្សភូ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ សូម្បីពួកសាវកដែលនៅចំពោះព្រះភក្ត្ររបស់ព្រះអង្គ ក៏មានអាយុប្រមាណប៉ុណ្ណោះឆ្នាំដូចគ្នា ។ ព្រហ្មចរិយ (សាសនា) បន្តដោយសាវកអង្គចុងក្រោយគេបង្អស់ នៃព្រះមានព្រះភាគព្រះនាមថា សិខីនិងវេស្សភូសូម្បីនោះតាំងនៅតមកបានប្រមាណ ១ សែន ៤ ម៉ឺនឆ្នាំ និងប្រមាណ ១ សែន ២ ម៉ឺនឆ្នាំ ។ តែពោលដោយអំណាចនៃយុគមនុស្ស ព្រហ្មចរិយតាំងនៅតមកបានដោយការបន្តនៃយុគ

រហូតដល់អស់យុគមនុស្ស ២ យុគស្មើ ៗគ្នា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា តាំងនៅមិនយូរ ។ ព្រះសារីបុត្រ ស្តាប់ហេតុនៃការតាំងនៅមិនយូរនៃព្រហ្មចរិយរបស់ព្រះពុទ្ធ ៣ ព្រះអង្គយ៉ាងនេះហើយ មានសេចក្តីប្រាថ្នានឹងស្តាប់ហេតុនៃការតាំងនៅបានយូរ នៃព្រហ្មចរិយរបស់ព្រះពុទ្ធ ៣ ព្រះអង្គក្រៅនេះ ទើបបានទូលសួរព្រះមានព្រះភាគទៀតដោយន័យ ជាដើមថា ក៏ អ្វីជាហេតុ ព្រះអង្គ ។ សូម្បីព្រះមានព្រះភាគក៏ទ្រង់បានព្យាករណ៍ដល់លោក ។ ពាក្យព្យាករណ៍ទាំងអស់នោះ គប្បីជ្រាបដោយអំណាចន័យដែលផ្ទុយគ្នាពីដែលពោលហើយ ។ និងសូម្បីក្នុងសេចក្តីតាំងនៅយូរ ក្នុងពាក្យព្យាករណ៍នោះ បណ្ឌិតគប្បីជ្រាបសេចក្តីតាំងនៅយូរ ដោយហេតុទាំងពីរគឺ ដោយប្រមាណនៃព្រះជន្មាយុរបស់ព្រះពុទ្ធទាំងនោះខ្លះ ដោយយុគនៃមនុស្សខ្លះ ។ សេចក្តីពិស្តារថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា កកុសន្ធៈ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ព្រះមានព្រះភាគទ្រង់ព្រះនាមថា កោនាគមនៈ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សប មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ សូម្បីព្រះសាវកនៅចំពោះព្រះភក្ត្រទាំងឡាយរបស់ព្រះពុទ្ធទាំងនោះ ក៏មានអាយុប៉ុណ្ណោះឆ្នាំដូចគ្នា ។ និងយុគនៃសាវកជាច្រើនរបស់ព្រះពុទ្ធទាំងនោះ ញុំាងព្រហ្មចរិយៈឱ្យប្រព្រឹត្តទៅដោយការបន្តគ្នាមក ។ ព្រហ្មចរិយ

តាំងនៅយូរដោយហេតុទាំងពីរគឺ ដោយប្រមាណនៃព្រះជន្មាយុ របស់ព្រះពុទ្ធទាំងនោះខ្លះ ដោយយុគនៃសាវកខ្លះ ដោយប្រការដូច្នេះ ។

## ហេតុដែលព្រះពុទ្ធរបស់យើង កើតក្នុងកាលមនុស្សមានអាយុតិច

ក៏ព្រះមានព្រះភាគរបស់ពួកយើង គួរនឹងស្ដេចឧប្បត្តិឡើងក្នុងកាលនៃមនុស្សមានអាយុ ១ ម៉ឺនឆ្នាំ ដែលប៉ុននឹងអាយុពាក់កណ្ដាល នៃព្រះជន្មាយុរបស់ព្រះមានព្រះភាគទ្រង់ព្រះនាមថា កស្សប មិនដល់កាលនៃមនុស្សមានអាយុ ១ ម៉ឺនឆ្នាំនោះ ក៏គួរនឹងស្ដេចឧប្បត្តិឡើងក្នុងកាលនៃមនុស្សមានអាយុ ៥,០០០ ឆ្នាំ ឬក្នុងកាលនៃមនុស្សមានអាយុមួយពាន់ឆ្នាំ ឬសូម្បីក្នុងកាលនៃមនុស្សមានអាយុ ៥០០ ឆ្នាំ តែព្រោះកាលព្រះអង្គទ្រង់ស្វែងរក គឺ ស្វែងរកធម៌ដែលធ្វើភាពជាព្រះពុទ្ធ ទ្រង់ញ៉ាំងញាណឱ្យចាស់ក្លា ឱ្យតាំងគភ៌ (ដើម្បីប្រសូតគុណពិសេស) ញាណបានដល់ សេចក្ដីចាស់ក្លា ក្នុងកាលនៃអ្នកមានអាយុ ១០០ ឆ្នាំ ព្រោះដូច្នោះ ទើបព្រះអង្គស្ដេចឧប្បត្តិឡើង ក្នុងកាលនៃមនុស្សមានអាយុតិចពេក ព្រោះដូច្នោះ គួរពោលបានថា ព្រហ្មចរិយសូម្បីតាំងនៅបានយូរដោយអំណាចសេចក្ដីបន្តគ្នានៃព្រះសាវករបស់ព្រះអង្គ តែក៏តាំងនៅបានមិនយូរដោយការរាប់ឆ្នាំ ដោយអំណាចបរិមាណនៃអាយុដូចគ្នា ។

## ព្រះសារីបុត្រទូលសូមឱ្យទ្រង់បញ្ញត្តិសិក្ខាបទ

[៨] សួរថា ក្នុងពាក្យថា អថខោ អាយស្មា សារីបុត្តោ : លំដាប់នោះព្រះសារីបុត្រ មានអ្វីជាអនុសន្ធិ ។ ឆ្លើយថា គឺ ព្រះសារីបុត្រ កាលបានស្តាប់ហេតុការណ៍តាំងនៅយូរនៃព្រហ្មចរិយរបស់ព្រះពុទ្ធ ៣ ព្រះអង្គយ៉ាងនេះហើយ ដល់ការសម្រេចចិត្តថា ការបញ្ញត្តិសិក្ខាបទប៉ុណ្ណោះ ជាហេតុនៃសេចក្តីតាំងនៅបានយូរ កាលប្រាថ្នាសេចក្តីតាំងនៅយូរនៃព្រហ្មចរិយ សូម្បីរបស់ព្រះមានព្រះភាគ ទើបទូលអង្វរសូមការបញ្ញត្តិសិក្ខាបទចំពោះព្រះមានព្រះភាគ ។ ព្រះឧបាលីថេរៈពោលពាក្យថា អថខោ អាយស្មា សារីបុត្តោ ឧដ្ឋាយាសនា ។បេ ។ ចិរដ្ឋិតិកំ នេះដើម្បីសម្តែងវិធីទូលអង្វរសូមការបញ្ញត្តិសិក្ខាបទនោះ ។ បណ្តាបទទាំងនោះ បទថា អទ្ធនិយំ គឺ គួរដល់កាលយូរ មានពាក្យអធិប្បាយថា មានកាលយូរអង្វែង ។ ពាក្យដែលសល់មានអត្ថងាយយល់ទាំងអស់ ។

## ព្រះមានព្រះភាគត្រាស់ហាមព្រះសារីបុត្រ

លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសដល់ព្រះសារីបុត្រនោះថា វេលានេះ មិនទាន់ជាកាលនៃការបញ្ញត្តិសិក្ខាបទទេ ទើបត្រាស់ថា អាគមេហិ ត្វំ សារីបុត្ត : ម្នាលសារីបុត្រ អ្នកចូរ

**បន្អន់**សិន ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ ពាក្យថា **អាគមេហិ ត្វំ** សេចក្តីថា លោកចូររង់ចាំ មានពាក្យអធិប្បាយថា លោកចូរផ្អាកសិន ។ ក៏ពាក្យនេះ ព្រះមានព្រះភាគត្រាស់ដដែលពីរដង ដោយអំណាចសេចក្តីអើពើ ។ ដោយពាក្យថា **អាគមេហិ** ជាដើមនេះ ព្រះមានព្រះភាគទ្រង់ហាមនូវការបញ្ញត្តិសិក្ខាបទ ដែលជាវិស័យរបស់ព្រះសាវក កាលនឹងទ្រង់ធ្វើឱ្យច្បាស់ថា ការបញ្ញត្តិសិក្ខាបទជាពុទ្ធវិស័យ ទើបត្រាស់ពាក្យថា **តថាគតោវ : តថាគតឯង** ជាដើម ។ ក៏ក្នុងពាក្យថា **តថាគតោវ** នេះ ពាក្យថា **តត្ថ** ជាសត្តមីវិភត្តិ សម្ព័ន្ធដល់ការអង្វរសូមឱ្យទ្រង់បញ្ញត្តិសិក្ខាបទ ។

ក្នុងពាក្យថា **តថាគតោវ** នោះ មានយោជនាដូចតទៅនេះ ៖

ក្នុងពាក្យដែលលោកពោលថា ព្រះមានព្រះភាគគប្បីបញ្ញត្តិសិក្ខាបទនោះ ព្រះតថាគតប៉ុណ្ណោះ នឹងដឹងកាលនៃការបញ្ញត្តិសិក្ខាបទនោះ ។ ព្រះមានព្រះភាគគ្រាត្រាស់យ៉ាងនេះហើយ ដើម្បីនឹងសម្តែងសម័យមិនមែនកាលមុន ទើបត្រាស់ពាក្យជាដើមថា **ន តាវ សារិបុត្ត : ម្នាលសារីបុត្រ ធម៌**ទាំងឡាយដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដ ដូច្នេះ ។ ក្នុងពាក្យថា **ន តាវ សារិបុត្ត** ជាដើមនោះ មាន

វិនិច្ឆ័យថា អាសវៈទាំងឡាយ រមែងតាំងនៅក្នុងធម៌ទាំងនេះ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា ជាទីតាំងនៃអាសវៈ, ម្យ៉ាងទៀត ធម៌ទាំងឡាយដែលអាសវៈគប្បីតាំងនៅ គឺ មិនគប្បីកន្លងហួសទៅ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា ជាទីតាំងនៃអាសវៈ ។ អធិប្បាយថា អាសវៈ គឺ ទុក្ខ និងអាសវៈ គឺ កិលេស ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌និងក្នុងសម្បរាយភព អាសវៈមានការជៀលត្មះរបស់អ្នកដទៃ សេចក្តីវិប្បដិសារ ការសម្លាប់និងការឃុំឃាំងជាដើម និងអាសវៈដែលជាទុក្ខពិសេសក្នុងអបាយ រមែងតាំងនៅនោះពិត ក្នុងវិតិក្កមធម៌ពួកណា ព្រោះវិតិក្កមធម៌ទាំងនោះ ជាហេតុនៃអាសវៈមានអាសវៈ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ជាដើមទាំងនោះ ។

វាចាសម្រាប់ប្រកបក្នុងពាក្យថា **ន តាវ** ជាដើមនេះ ដូច្នេះថា វិតិក្កមធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះ មិនទាន់មានប្រាកដក្នុងសង្ឃត្រឹមណា ព្រះសាស្តានឹងទ្រង់មិនបញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយត្រឹមនោះ ។ កំបើគប្បីបញ្ញត្តិសោត មិនផុតពីសេចក្តីជៀលត្មះរបស់អ្នកដទៃ មិនផុតពីសេចក្តីជំទាស់របស់អ្នកដទៃ មិនផុតពីទោស គឺការរិះគន់ ។

## ការតិះដៀលក្នុងការបញ្ញត្តិសិក្ខាបទ

សួរថា មិនគប្បីផ្តុតយ៉ាងណា ? ឆ្លើយថា ពិតមែន សិក្ខាបទទាំងពួងជាដើមថា **យោ បន ភិក្ខុ មេថុនំ ធម្មំ បដិសេវេយ្យ** ដូច្នេះ គប្បីជាសិក្ខាបទដែលព្រះសាស្តាអ្នកនឹងបញ្ញត្តិ គួរបញ្ញត្តិ ៗ ចំណែកជនពួកដទៃមិនឃើញវិតិក្កមទោស តែដឹងព្រះបញ្ញត្តិនេះ នឹងគប្បីញ៉ាំងសេចក្តីដៀលត្មះ សេចក្តីជំទាស់និងសេចក្តីតិះដៀលឱ្យប្រព្រឹត្តទៅយ៉ាងនេះថា "តើយ៉ាងម៉េចហ្ន៎ បានជាព្រះសមណគោតមចងក្រង ដោយសិក្ខាបទទាំងឡាយ នឹងបញ្ញត្តិបារាជិក ដោយហេតុត្រឹមប៉ុណ្ណេះថា ភិក្ខុសង្ឃព្រមប្រព្រឹត្តតាមតថាគត ធ្វើតាមពាក្យរបស់តថាគត កុលបុត្រទាំងនេះ លះបង់គំនរភោគៈធំ លះបង់ពពួកញាតិធំ និងលះបង់សូម្បីនូវរាជសម្បត្តិដែលនៅក្នុងការគ្រប់គ្រង ហើយបួស ជាអ្នកសន្តោសដោយភាពជាអ្នកមានអាហារ និងគ្រឿងស្លៀកដណ្តប់ជាយ៉ាងក្រៃលែង មានសេចក្តីគោរពក្នុងសិក្ខា មិនហួងហែងក្នុងរាងកាយនិងជីវិតនៅមិនមែនឬ ក្នុងកុលបុត្រទាំងនោះ អ្នកណាហ្ន៎ នឹង សេពមេថុនដែលជាលោកាមិស ឬនឹងលួចទ្រព្យអ្នកដទៃ ឬនឹងចូលទៅកាត់ជីវិតរបស់អ្នកដទៃ ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ផ្អែមក្រៃលែងណាស់ ឬនឹងសម្រេចការចិញ្ចឹមជីវិតដោយអួតគុណដែលមិនមាន, កាលបារាជិក សូម្បីទ្រង់មិនបញ្ញត្តិ

ទុក សិក្ខាបទនោះ ជាការដែលព្រះអង្គទ្រង់ធ្វើឱ្យប្រាកដហើយ ដោយសង្ខេបក្នុងបពួជ្ជានុ៎ះឯង មិនមែនឬ ?" ជនទាំងឡាយមិនជ្រាបកម្លាំងអានុភាព និងកម្លាំង សូម្បីនៃព្រះតថាគត, សិក្ខាបទសូម្បីដែលទ្រង់បញ្ញត្តិទុក នឹងគប្បីកម្រើក គឺ មិនគង់នៅក្នុងស្ថានពីដើម ។

## ប្រៀបដូចជាពេទ្យអ្នកមិនឆ្លាតធ្វើការវះកាត់

ពេទ្យអ្នកមិនឆ្លាត ហៅបុរសណាម្នាក់ ដែលមិនទាន់មានបូសកើតឡើង មកហើយប្រាប់ថា "នែលោកដ៏ចម្រើន បូសធំនឹងកើតឡើងក្នុងសរីរៈត្រង់ទីនេះរបស់លោក, នឹងញ៉ាំងសេចក្តីវិនាសឱ្យមកដល់លោក, លោកចូរប្រញាប់ឱ្យពេទ្យព្យាបាលវាចេញចុះ" ដូច្នេះ អ្នកដែលបុរសនោះពោលថា "ល្អណាស់ លោកអាចារ្យ លោកនុ៎ះឯងចូរផ្សំថ្នាំព្យាបាលវាចុះ" ទើបវះសរីរប្រទេសដែលមិនមានរោគរបស់បុរសនោះ ទប់ឃាត់ឈាមចេញហើយធ្វើសរីរត្រង់ទីនោះឱ្យមានសម្បុរល្អឡើងវិញ ដោយថ្នាំលាបនិងថ្នាំបំពោក និងការលាងជម្រះជាដើមហើយ ទើបពោលនឹងបុរសនោះថា "រោគបូសធំរបស់លោក យើងបានផ្សំថ្នាំព្យាបាលហើយ លោកចូរឱ្យតម្លៃឈ្នួលដល់យើង" ។ បុរសនោះ គប្បីជៀលត្មះ គប្បីជំទាស់ និងគប្បីតិះដៀលនាយពេទ្យយ៉ាងនេះថា "ពេទ្យល្ងង់នេះនិយាយអ្វី បានព្

ថា ភោគប្រភេទណារបស់យើង ដែលពេទ្យល្ងង់នេះបានផ្សំថ្នាំព្យាបាលហើយ, ពេទ្យល្ងង់នេះ ធ្វើទុក្ខឱ្យកើតដល់យើង និងធ្វើឱ្យយើងត្រូវចេញឈាមទៅមិនមែនឬ” ដូច្នេះ និងមិនគប្បីដឹងគុណរបស់ពេទ្យនោះ សេចក្តីនេះ យ៉ាងណា, បើកាលវិតិក្កមទោសមិនទាន់កើតឡើង ព្រះសាស្តា គប្បីបញ្ញត្តិសិក្ខាបទដល់ព្រះសាវកសោត ព្រះអង្គមិនគប្បីផុតពីអនិដ្ឋផល មានសេចក្តីដៀលត្មះរបស់អ្នកដទៃជាដើម និងជនទាំងឡាយនឹងមិនដឹងកម្លាំងព្រះប្រាជ្ញាអាចរបស់ព្រះអង្គ ដូច្នោះទុ៎ះឯង និងសិក្ខាបទដែលទ្រង់បញ្ញត្តិហើយ នឹងគប្បីកម្រើក គឺ មិនតាំងនៅក្នុងស្ថានពីដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន តាវ សារីបុត្ត សត្ថា សាវកានំ ។បេ។ បាតុភវន្តិ :** ម្នាលសារីបុត្រ ធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដ ។ល។ ទាំងនោះប៉ុណ្ណោះ ។ ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងកាលដែលមិនគួរយ៉ាងនេះហើយ ទើបត្រាស់ពាក្យថា **យតោ ច ខោ សារីបុត្ត :** ម្នាលសារីបុត្រ ក្នុងកាលណា ជាដើម ដើម្បីសម្តែងកាលទៀត ។ បណ្តាបទទាំងនោះ បទថា **យតោ** គឺ កាលណា មានពាក្យអធិប្បាយថា ក្នុងកាលណា ។ ពាក្យដែលសល់ គប្បីជ្រាបដោយទំនងដែលពោលហើយទុ៎ះឯង ។

ន័យមួយទៀត ក្នុងពាក្យថា យតោ ជាដើមនេះ មានសេចក្តីសង្ខេបដូចតទៅនេះ ៖

វីតិក្កមទោសដែលដល់នូវការរាប់ថា ធម៌ជាទីតាំងនៃអាសវៈ រមែងមានប្រាកដក្នុងសង្ឃក្នុងកាលណា, ក្នុងកាលនោះ ព្រះសាស្តារមែងទ្រង់បញ្ញត្តិសិក្ខាបទដល់ពួកសាវក រមែងទ្រង់សម្តែងបាតិមោក្ខ, ព្រោះហេតុអ្វី ? ព្រោះដើម្បីកម្ចាត់វីតិក្កមទោសទាំងនោះឯង ដែលដល់នូវការរាប់ថា ធម៌ជាទីតាំងនៃអាសវៈ ។ ព្រះមានព្រះភាគកាលទ្រង់បញ្ញត្តិយ៉ាងនោះ រមែងជាអ្នកមិនគួរជៀលត្មះជាដើម និងជាអ្នកមានអានុភាពប្រាកដ ក្នុងសព្វញ្ញុវិស័យរបស់ព្រះអង្គ រមែងដល់សក្ការៈ និងសិក្ខាបទរបស់ព្រះអង្គនោះ រមែងមិនកម្រើក គឺ តាំងនៅក្នុងស្ថានដើម, ប្រៀបដូចពេទ្យឆ្លាត ផ្សំថ្នាំព្យាបាលបូសដែលកើតឡើងហើយដោយការវះកាត់បំពោកថ្នាំរុំដំរ និងលាងជម្រះជាដើមធ្វើឱ្យសប្បាយមានសម្បុរល្អ ជាអ្នកមិនគួរជៀលត្មះជាដើមឡើយ និងជាអ្នកមានអានុភាពប្រាកដក្នុងកម្មនៃអាចារ្យរបស់ខ្លួន រមែងជួបប្រសព្វសក្ការៈដូច្នោះ ។

លុះព្រះមានព្រះភាគត្រាស់ការមិនកើតឡើង និងការកើតឡើងនៃធម៌ជាទីតាំងរបស់អាសវៈ អកាលនិងកាលនៃការបញ្ញត្តិសិក្ខាបទយ៉ាងនេះដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្តែងកាលមិនទាន់កើតឡើង

នៃធម៌ទាំងនោះឯង ទើបត្រាស់ពាក្យថា ន តាវ សារិបុត្ត អាគមេហិ : ក្នុងកាលនោះឯង ម្នាលសារីបុត្រ ជាដើម ។ ក្នុងពាក្យថា តាវ ជាដើមនោះ បទទាំងឡាយដែលមានអត្ថងាយយល់ គប្បីជ្រាបដោយអំណាចព្រះបាលីនុ៎ះឯង ។

## អធិប្បាយហេតុដែលឱ្យទ្រង់បញ្ញត្តិសិក្ខាបទ

ចំណែកការពណ៌នាបទដែលមិនងាយយល់ដូចតទៅនេះ ៖

ភិក្ខុទាំងឡាយ ឈ្មោះថា រត្តញ្ញូ ព្រោះអត្ថថា ដឹងរាត្រីយូរ គឺដឹងរាត្រីជាច្រើនតាំងពីថ្ងៃដែលខ្លួនបួសមក, មានអធិប្បាយថា បួសមកយូរ ។ ភាពជាពួកដោយពួកភិក្ខុដែលដឹងរាត្រីយូរ ឈ្មោះថា រត្តញ្ញុមហត្ត : ដល់នូវសេចក្ដីចម្រើន មានភិក្ខុបួសចាស់វស្សាច្រើនគ្នា ។ អធិប្បាយថា ភាពជាពួកធំដោយពួកភិក្ខុដែលបួសមកយូរ ។

បណ្ឌិតគប្បីជ្រាបថា សិក្ខាបទដែលព្រះមានព្រះភាគ ទ្រង់ប្រារព្ធព្រះឧបសេនវង្គន្តបុត្របញ្ញត្តិ ព្រោះសង្ឃដល់ភាពជាពួកធំដោយភិក្ខុដែលដឹងរាត្រីយូរ ក្នុងបណ្ដាភាពជាពួកធំទាំងនោះ ។ ពិតមែន លោកដ៏មានអាយុនោះបានឃើញភិក្ខុទាំងឡាយ អ្នកមានវស្សាខ្វះ ១០ ឱ្យឧបសម្បទាខ្លួនមានវស្សាតែមួយ ទើបឱ្យសទ្ធិវិហារិកឧបសម្បទាខ្លះ ។ គ្រានោះឯង

ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានវស្សាថយអំពី ១០ ចុះមក មិនត្រូវឱ្យឧបសម្បទា, ដល់កុលបុត្រឡើយ ភិក្ខុណាឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ"[១] កាលសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយយ៉ាងនោះ ភិក្ខុទាំងឡាយ ដែលល្ងង់ខ្លៅ មិនឆ្លាស គិតថា យើងបាន ១០ វស្សា យើងមានវស្សាគ្រប់ ១០ ទើបឱ្យឧបសម្បទាទៀត ។ លំដាប់នោះ ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិសិក្ខាបទសូម្បីដដែលម្តងទៀតថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុពាលមិនឆ្លាស មិនត្រូវឱ្យឧបសម្បទា (ដល់កុលបុត្រ)ឡើយ ភិក្ខុពាលណា ឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលឆ្លាសប្រតិពលមានវស្សា ១០ ឬច្រើនជាង ១០ ឡើងទៅ គួរឱ្យឧបសម្បទា(ដល់កុលបុត្រ)បាន"[២] ។ ក្នុងកាលដែលសង្ឃដល់ភាពជាពួកធំ ដោយភិក្ខុដែលដឹងរាត្រីយូរ ទ្រង់បានបញ្ញត្តិពីរសិក្ខាបទ ។

បទថា វេបុល្លមហត្តំ : ដល់នូវសេចក្តីចម្រើន មានគ្នាច្រើន មានសេចក្តីថា ភាពជាពួកធំដោយភាពជាពួកគណៈច្រើន ។ ពិតមែនសង្ឃមិនទាន់ដល់ភាពជាពួកធំ ដោយភាពជាពួកគណៈច្រើន ដោយ

១. វិន. មហា. មហាខន្ធក. ៦. ៩០/១៧៩ ។

២. វិន. មហា. មហាខន្ធកៈ. ៦. ៩១/១៨២ ។

អំណាចភិក្ខុទាំងឡាយ ដែលជាព្រះថេរៈ អ្នកធំនិងអ្នកបែបកណ្ដាលត្រឹមណា សេនាសនៈ រមែងគ្រប់គ្រាន់, អាសវដ្ឋានិយធម៌ពួកខ្លះ ក៏មិនទាន់កើតឡើងក្នុងសាសនាត្រឹមនោះ, តែកាលសង្ឃដល់ភាពជាអ្នកធំ ដោយភាពជាពួកគណៈច្រើនហើយ អាសវដ្ឋានិយធម៌ទាំងនោះ រមែងកើតឡើង ។ ពេលនោះព្រះសាស្ដា រមែងទ្រង់បញ្ញត្តិសិក្ខាបទ ។ សិក្ខាបទដែលទ្រង់បញ្ញត្តិព្រោះសង្ឃដល់ភាពជាពួកធំ ដោយភាពជាពួកគណៈច្រើនក្នុងបណ្ដាភាពជាពួកធំទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យនេះថា "ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាងពីរយប់ឬបីយប់ឡើងទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ"[១] ។ "ភិក្ខុនីណាមួយឱ្យឧបសម្បទារាល់ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ"[២] ។ "ភិក្ខុនីណាមួយ ឱ្យឧបសម្បទាដល់ស្រីពីររូបក្នុង១ ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ"[៣] ។

បទថា លាភគ្គមហត្តំ : ដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈ មានសេចក្ដីថា ភាពជាធំជាកំពូលនៃលាភ អធិប្បាយថា ភាពជាធំណា ជាកំពូល គឺ ខ្ពស់បំផុតនៃលាភ សង្ឃជាអ្នកដល់ភាពជាធំ

១. វិន. បាចិ. មុសាវាទវគ្គ. ៣. ២៩០/២៩២ ។ ២. វិន. ភិក្ខុនី. កុមារីភូតវគ្គ. ៥. ៤៣៨/៣៨១ ។ ៣. វិន. ភិក្ខុនី. កុមារីភូតវគ្គ. ៥. ៤៤១/៣៨២ ។

នោះ ។ ម្យ៉ាងទៀត ដល់ភាពជា ពួកធំ កំពូលលើសដោយលាភក៏បាន, អធិប្បាយថា ដល់ភាពជាពួកប្រសើរ និងភាពជាពួកធំដោយលាភ ។ ពិតមែន សង្ឃមិនទាន់ដល់ភាពជាពួកធំកំពូលលើសដោយលាភ ត្រឹមណា អាសវដ្ឋានិយធម៌អាស្រ័យលាភ ក៏មិនទាន់កើតឡើង ត្រឹមនោះ តែកាលដល់ហើយ រមែងកើតឡើង ។ ពេលនោះ ព្រះសាស្តា រមែងទ្រង់បញ្ញត្តិសិក្ខាបទថា "ភិក្ខុណាមួយ ឱ្យវត្ថុដែលបុគ្គលគួរទំពា ឬវត្ថុដែលបុគ្គលគួរបរិភោគ ដល់អចេលក្តី បរិព្វាជកក្តី បរិព្វាជិកាក្តី ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ"[១] ។ ពិតមែន សិក្ខាបទនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិព្រោះសង្ឃដល់ភាពជាពួកធំកំពូលលើសដោយលាភ ។

បទថា ពាហុសច្ចមហត្តំ : ដល់នូវសេចក្តីចម្រើនដោយអ្នកសេចះដឹងច្រើន មានសេចក្តីថា សេចក្តីដែលពាហុសច្ចៈជាគុណធំ ។ ពិតមែន សង្ឃមិនទាន់ដល់សេចក្តីដែលពាហុសច្ចៈជាគុណធំត្រឹមណា អាសវដ្ឋានិយធម៌ ក៏មិនទាន់កើតឡើងត្រឹមនោះ ។ តែកាលដល់សេចក្តីដែលពាហុសច្ចៈជាគុណធំហើយ រមែងកើតឡើង ព្រោះហេតុថា បុគ្គលទាំងឡាយរៀនពុទ្ធវចនៈ មួយនិកាយខ្លះ ពីរនិកាយខ្លះ ។ល ។ ប្រាំ

១. វិន. បាចិ. អចេលកវគ្គ. ៤. ១៤៥/១៥៣ ។

និកាយខ្លះហើយ កាលពិចារណាដោយឧបាយមិនជាប្រាជ្ញា ប្រៀបធៀបរសដោយរសហើយ រមែងសម្តែងសត្ថុសាសនាក្រៅធម៌ក្រៅវិន័យ ។ ពេលនោះ ព្រះសាស្តា រមែងទ្រង់បញ្ញត្តិសិក្ខាបទ ដោយន័យជាដើមថា "ភិក្ខុណាមួយ ពោលយ៉ាងនេះថា ធម៌ទាំងឡាយណា តែងធ្វើនូវសេចក្តីអន្តរាយ ដែលព្រះមានព្រះភាគសម្តែងហើយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយដោយប្រការយ៉ាងនោះ ។ល ។"[១] "បើសមណុទ្ទេសពោលយ៉ាងនេះ ។ល ។"[២] ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងកាលមិនកើតនិងកាលកើតឡើងនៃធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងការមិនមាននៃអាសវដ្ឋានិយធម៌ទាំងនោះ សូម្បីដោយប្រការទាំងពួង ក្នុងសម័យនោះ ទើបត្រាស់ពាក្យមានថា និរព្វុទោ ហិ សារិបុត្ត : ម្នាលសារីបុត្រ ពីព្រោះ (ឥឡូវនេះ) នៅមិនទាន់មានពុតនៅឡើយ ជាដើម ។

---

១-២. វិន. បាចិ. សប្បាណវគ្គ. ៤. ២៨០/២៨១; ២៩២/៣០០ ។

## អត្ថាធិប្បាយ ពាក្យថា និរព្វុទោ ជាដើម

បណ្ដាបទទាំងនោះ បទថា និរព្វុទោ : **នៅមិនទាន់មានពុតនៅឡើយ** គឺ វៀរចាកស្មៀត ៗ ពួកចោរ លោកហៅថា ស្មៀត ៗ អធិប្បាយថា អស់ចោរ ។ ក៏ក្នុងអត្ថនេះ ពួកភិក្ខុទ្រុស្តសីលលោកចាត់ថា ជាចោរ ។ ពិតមែន ភិក្ខុដែលទ្រុស្តសីលទាំងនោះ រមែងលួចបច្ច័យរបស់ពួកមនុស្សដទៃ ព្រោះជាអ្នកមិនមែនសមណៈ តែមានសេចក្ដីសម្គាល់ថា ជាសមណៈ ព្រោះហេតុនោះ ភិក្ខុសង្ឃមិនមានស្មៀត មិនមានចោរ មានអធិប្បាយថា មិនមានអ្នកទ្រុស្តសីល ។

បទថា និរាទីនវោ : **មិនទាន់មានទោសមោះមៃនៅឡើយ** បានដល់ មិនមានឧបទ្រវៈ គឺ មិនមានឧបសគ្គ ៗ មានពាក្យអធិប្បាយថា វៀរចាកទោសរបស់អ្នកទ្រុស្តសីលនោះ ។ អ្នកទ្រុស្តសីលនោះ លោកហៅថា មនុស្សខ្មៅ ក្នុងពាក្យថា អបគតកាឡកោ : **ឥតទាន់មានពណ៌ខ្មៅសៅហ្មង** នេះ ។ ពិតមែន អ្នកទ្រុស្តសីលទាំងនោះ សូម្បីជាមនុស្សមានវណ្ណៈដូចមាស គប្បីជ្រាបថា ជាមនុស្សខ្មៅ ព្រោះប្រកបដោយធម៌ខ្មៅ ។ ព្រោះមិនមានមនុស្សមានធម៌ខ្មៅទាំងនោះ ទើបឈ្មោះថា អបគតកាឡក ៗ បាលីថា អបហាតកាឡក ក៏មាន ។ បទថា

សុទ្ធោ : កំពុងនៅមានធម៌បរិសុទ្ធ គឺឈ្មោះថា បរិសុទ្ធិ ព្រោះមានធម៌ខ្មៅប្រាសចាកទៅហើយនុ៎ះឯង ។ បទថា បរិយោទាតោ : សុទ្ធស្អាតតែផូរផង់ចិត្ត គឺផូរផង់ ។ គុណគឺ សីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ លោកហៅថា សារៈ ក្នុងពាក្យថា សារេ បតិដ្ឋិតោ : ស្ថិតនៅក្នុងធម៌មានខ្លឹមនៅឡើយ នេះ ។ ព្រោះតាំងនៅហើយក្នុងសារៈនោះ ទើបឈ្មោះថា តាំងនៅក្នុងសារគុណ ។ ព្រះមានព្រះភាគ ត្រាស់សេចក្តីដែលភិក្ខុសង្ឃតាំងនៅក្នុងសារគុណយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងទៀតថា ក៏សេចក្តីដែលភិក្ខុសង្ឃនោះ តាំងនៅក្នុងសារគុណនោះ គប្បីជ្រាបយ៉ាងនេះ ទើបត្រាស់ពាក្យជាដើមថា ឥមេសំ ហិ សារីបុត្ត បញ្ចន្នំ ភិក្ខុសតានំ : ម្នាលសារីបុត្រ ក៏បណ្តាភិក្ខុទាំង ៥០០ រូប នេះ ។

ក្នុងពាក្យនោះ មានការពណ៌នាដោយសង្ខេបដូចតទៅនេះ ៖

បណ្តាភិក្ខុ ៥០០ រូបនេះ អ្នកចូលវស្សាក្នុងស្រុកវេរញ្ជា ភិក្ខុដែលទាបដោយអំណាចគុណ គឺ មានគុណទាបជាងភិក្ខុគ្រប់រូប ក៏ជាព្រះសោតាបន្ន ពាក្យថា សោតាបន្នោ គឺ អ្នកធ្លាក់ដល់ត្រែស ។ ក៏ពាក្យថា សោតោ នេះ ជាឈ្មោះរបស់មគ្គ ។

ពាក្យថា សោតាបន្នោ ជាឈ្មោះរបស់បុគ្គលអ្នកប្រកបដោយមគ្គនោះ ។ ដូចដែលត្រាស់ទុកថា “ម្នាលសារីបុត្រ គេតែងពោលថា សោតៈ ៗ ដូច្នេះ ម្នាលសារីបុត្រ ចុះសោតៈ តើដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន មគដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ មគដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីឃើញត្រូវ ១ ការត្រិះរិះត្រូវ១ ការនិយាយត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ ការព្យាយាមត្រូវ១ ការរលឹកត្រូវ១ ការតម្កល់ចិត្តទីងត្រូវ១ ។

ម្នាលសារីបុត្រ ប្រពៃពេកណាស់ ម្នាលសារីបុត្រ មែនហើយ មគដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ មគដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្ដេចខ្លះ ។ គឺសេចក្ដីឃើញត្រូវ១ ។ បេ ។ ការតម្កល់ចិត្តទីងត្រូវ១ ។

“ម្នាលសារីបុត្រ គេតែងពោលថា បុគ្គលដល់នូវសោតៈ ៗ ដូច្នេះ ម្នាលសារីបុត្រ ចុះបុគ្គលដល់នូវសោតៈ តើដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាប្រកបដោយមគដ៏ប្រសើរប្រកបដោយអង្គ ៨ នេះហៅថា បុគ្គលដល់នូវសោតៈ លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ”[១] ។

---

១. សំយុ. មហា. វេឡុទ្វារវគ្គ. ៣៩. ១៣១_៣/៧៣_៤ ។

ក៏ក្នុងបទនេះ គប្បីជ្រាបថា មគ្គឱ្យឈ្មោះដល់ផល ព្រោះដូច្នោះ បុគ្គលអ្នកតាំងនៅក្នុងផលឈ្មោះថា សោតាបន្ន ។

បទថា **អវិនិបាតធម្មោ : លែងធ្លាក់ទៅក្នុងអបាយភូមិហើយ** មានវិគ្រោះថា ធម៌ដែលឈ្មោះថា វិនិបាត ព្រោះអត្ថថា ឱ្យធ្លាក់ទៅ ។ ព្រះសោតាបន្នឈ្មោះថា អវិនិបាតធម៌ព្រោះអត្ថថា លោកមិនមានវិនិបាតធម៌ ។ មានពាក្យអធិប្បាយថា លោកមិនមានការញ៉ាំងខ្លួនឱ្យធ្លាក់ទៅក្នុងអបាយជាសភាព ។ ព្រោះហេតុអ្វី ? ព្រោះសេចក្ដីអស់ទៅនៃធម៌ជាហេតុនាំទៅកាន់អបាយ ។ ម្យ៉ាងទៀត ការធ្លាក់ទៅ ឈ្មោះថា វិនិបាត ។ ព្រះសោតាបន្ន ឈ្មោះថា អវិនិបាតធម៌ ព្រោះអត្ថថា លោកមិនមានធម៌ដែលធ្លាក់ទៅ ។ មានពាក្យអធិប្បាយថា សេចក្ដីធ្លាក់ទៅក្នុងអបាយជាសភាព មិនមានដល់លោក ។

ឈ្មោះថា ជាអ្នកទៀង ព្រោះជាអ្នកពិតប្រាកដដោយមគ្គ ដែលកំណត់ដោយភាពជាធម៌ត្រូវ ។ ឈ្មោះថា ជាអ្នកដែលនឹងត្រាស់ដឹងក្នុងខាងមុខ ព្រោះអត្ថថា ព្រះសោតាបន្ននោះមានសេចក្ដីត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ គឺ ជាគតិខាងមុខ ។ អធិប្បាយថា ព្រះសោតាបន្ននោះ នឹងធ្វើខ្លួនឱ្យបានសម្រេចដល់មគ្គ ៣ ខាងលើពិតប្រាកដ ។ ព្រោះហេតុអ្វី ? ព្រោះលោកបានបឋមមគ្គហើយឯង ។

# ព្រះមានព្រះភាគទ្រង់យាងចេញពីស្រុកវេរញ្ជា

## អាចិណ្ណៈ ទំនៀម មាន ២ យ៉ាង

គ្រានោះឯង ព្រះមានព្រះភាគ គ្រាទ្រង់ញុាំងព្រះធម្មសេនាបតី ឱ្យយល់ព្រមយ៉ាងនោះហើយ ទ្រង់សម្រាកនៅរហូតអស់វស្សានោះក្នុងស្រុកវេរញ្ជា ស្ដេចចេញវស្សាបវារណាក្នុងថ្ងៃមហាបវារណាហើយ ទើបត្រាស់ហៅព្រះអានន្ទមក ។

បទថា អាមន្តេសិ **:** ទ្រង់ត្រាស់ហៅ សេចក្ដីថា ទ្រង់បានហៅ គឺ ទ្រង់បានត្រាស់ហៅ បានដល់ ទ្រង់ជាស់តឿនឱ្យដឹង ។

សួរថា ទ្រង់ជាស់តឿនឱ្យដឹងថា យ៉ាងណា ?

ឆ្លើយថា ទ្រង់ជាស់តឿនឱ្យដឹងរឿងជាដើមយ៉ាងនេះថា **អាចិណ្ណំ ខោ បនេតំ** ។

បទថា អាចិណ្ណំ **:** ទំនៀម គឺ ជាការប្រព្រឹត្ត ជាទំនៀម បានដល់ ជាធម្មតា ។

ក៏ទំនៀមនោះឯង មាន ២ យ៉ាង គឺ ពុទ្ធាចិណ្ណៈ( ទំនៀមរបស់ព្រះពុទ្ធ ) ១ សាវកាចិណ្ណៈ ( ទំនៀមរបស់ព្រះសាវក ) ១ ។

ពុទ្ធាចិណ្ណៈ ( ទំនៀមរបស់ព្រះពុទ្ធ ) ដូចម្ដេច ?

ពាក្យថា ព្រះតថាគតទាំងឡាយមិនទាន់បានលា គឺ មិនទាន់បានលាអ្នកដែលនិមន្តឱ្យនៅចាំវស្សាហើយ ទ្រង់មិនជៀសទៅកាន់ទីចារិកក្នុងជនបទ ដូច្នេះ នេះជាពុទ្ធាចិណ្ណៈ ប្រការមួយ ។ ចំណែកព្រះសាវកទាំងឡាយ នឹងលាឬមិនលាក៏ដោយ រមែងជៀសទៅបានតាមសប្បាយ ។

នៅមានពុទ្ធាចិណ្ណៈសូម្បីដទៃទៀត គឺ ព្រះពុទ្ធទាំងឡាយ ស្តេចនៅចាំវស្សាបវារណាហើយ រមែងស្តេចយាងទៅកាន់ទីចារិកក្នុងជនបទតែម្តង ដើម្បីទ្រង់សង្គ្រោះប្រជាជន ។

## ព្រះពុទ្ធស្តេចត្រាច់ចារិកទៅក្នុងមណ្ឌល ៣

ក៏ព្រះពុទ្ធទាំងឡាយ កាលនឹងស្តេចយាងទៅក្នុងជនបទ រមែងស្តេចយាងទៅក្នុងមណ្ឌលណាមួយបណ្តាមណ្ឌលទាំង ៣ នេះ គឺ មហាមណ្ឌល ១ មជ្ឈិមមណ្ឌល ១ អន្តិមមណ្ឌល ១ ។

បណ្តាមណ្ឌលទាំង ៣ នោះ មហាមណ្ឌលប្រមាណ ៩០០ យោជន៍ មជ្ឈិមមណ្ឌលប្រមាណ ៦០០ យោជន៍ អន្តិមមណ្ឌលប្រមាណ ៣០០ យោជន៍ ។

ក្នុងកាលណា ព្រះពុទ្ធទាំងឡាយ មានព្រះបំណងនឹងស្តេចត្រាច់ចារិកទៅក្នុងមហាមណ្ឌល ក្នុងកាលនោះ ទ្រង់បវារណាក្នុងថ្ងៃមហា

បវារណាហើយ មានភិក្ខុសង្ឃពួកធំជាបរិវារ ស្ដេចចេញក្នុងថ្ងៃបាដិបទកាលទឹងទ្រង់អនុគ្រោះមហាជនក្នុងស្រុក និងនិគមជាដើម ដោយការទ្រង់ទទួលអាមិស និងកាលទ្រង់បន្ថែមកពូនកុសល ដែលអាស្រ័យវិវដ្ដគាមិនីដល់មហាជននោះដោយធម្មទាន ទ្រង់ញុំាងការយាងចារិកទៅក្នុងជនបទឱ្យសម្រេចអស់ ដោយវេលា ៩ ខែ ។

ក៏បើខាងក្នុងវស្សា សមថ: និងវិបស្សនារបស់ភិក្ខុទាំងឡាយនៅទន់ខ្សោយ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនបវារណាក្នុងថ្ងៃមហាបវារណា ទ្រង់ប្រទានបវារណាសង្គ្រោះ ទៅបវារណាក្នុងថ្ងៃពេញបូណ៌មីខែកត្ដិក (កណ្ដាលខែ ១២) សម្រេចហើយមានភិក្ខុសង្ឃពួកធំជាបរិវារ ស្ដេចចេញទៅក្នុងថ្ងៃដើមនៃខែមិគសិរ[១] ហើយញុំាងការយាងចារិកទៅក្នុងមជ្ឈិមមណ្ឌល ឱ្យសម្រេចអស់វេលា ៨ ខែ តាមន័យដូចពោលមកហើយនុ៎ះឯង ។

ក៏បើស្ដេចចេញវស្សាហើយ វេនេយ្យសត្វទាំងឡាយណារបស់ព្រះពុទ្ធ នៅមានឥន្ទ្រិយមិនទាន់ចាស់ក្លា ។ ព្រះពុទ្ធទាំងឡាយ ក៏ទ្រង់រង់ចាំឱ្យវេនេយ្យសត្វទាំងនោះ មានឥន្ទ្រិយចាស់ក្លាសិន ស្ដេចសម្រាកក្នុងស្ថានទីនោះឯង សូម្បីរហូតដល់អស់ខែមិគសិរហើយ មានភិក្ខុសង្ឃពួក

---

១. គឺ ថ្ងៃ១រោចខែកត្ដិក ទើបគ្រប់ ៨ ខែ ។

ធំជាបរិវារស្តេចចេញទៅក្នុងថ្ងៃដើមនៃខែបុស្ស[១] ហើយទ្រង់ញ៉ាំងការយាងចារិកទៅក្នុងអន្តិមមណ្ឌល ឱ្យសម្រេចអស់វេលា ៧ ខែ តាមន័យដូចពោលមកហើយនុ៎ះឯង ។

មួយទៀត ព្រះពុទ្ធទាំងឡាយ សូម្បីកាលស្តេចត្រាច់ទៅក្នុងបណ្តាមណ្ឌលទាំងនោះកន្លែងណាមួយ ទ្រង់ដោះលែងសត្វទាំងនោះ ៗ ឱ្យផុតពីកិលេសទាំងឡាយ ទ្រង់ប្រកបសត្វទាំងនោះ ៗ ទុកដោយអរិយផលមានសោតាបត្តិផលជាដើម ស្តេចយាងទៅនៅដោយអំណាចនៃវេនេយ្យសត្វប៉ុណ្ណោះ ដូចទ្រង់រក្សាផ្កាឈើបញ្ចពណ៌មានប្រភេទផ្សេង ៗនៅដូច្នោះ ។

នៅមានពុទ្ធាចិណ្ណៈ សូម្បីដទៃទៀត គឺ ៖

ក្នុងវេលាជិតភ្លឺរាល់ថ្ងៃ ការធ្វើព្រះនិព្វានដែលជាសុខស្ងប់ឱ្យជាអារម្មណ៍ ស្តេចចូលផលសមាបត្តិ ចេញចាកផលសមាបត្តិហើយ ទ្រង់ចូលសមាបត្តិដែលប្រកបដោយព្រះមហាករុណា ខាងក្រោយពីនោះ ក៏ទ្រង់ត្រួតមើលវេនេយ្យសត្វ ដែលល្មមទឹងណែនាំឱ្យត្រាស់ដឹងបានក្នុងម៉ឺនចក្រវាឡ ។

---

១. គឺថ្ងៃ១រោចខែមិគសិរ ទើបគ្រប់ ៧ ខែ ។

នៅមានពុទ្ធាចិណ្ណៈសូម្បីដទៃទៀត គឺ ៖

ទ្រង់ធ្វើការបដិសណ្ឋារៈពួកអាគន្តុកៈជាមុន, ទ្រង់សម្តែងធម៌ដោយអំណាចរឿងដែលកើតឡើង, កាលទោសកើតឡើង ទ្រង់បញ្ញត្តិសិក្ខាបទ, នេះជាពុទ្ធាចិណ្ណៈ (សេចក្តីធ្លាប់ប្រព្រឹត្តមករបស់ព្រះពុទ្ធ) ដូចពណ៌នាមកដូច្នេះឯង ។

## សាវកាចិណ្ណៈ ការធ្លាប់ប្រព្រឹត្តមករបស់ព្រះសាវក

សាវកាចិណ្ណៈ (ការធ្លាប់ប្រព្រឹត្តមករបស់ព្រះសាវក) ដូចម្តេច ? គឺក្នុងកាលនៃព្រះមានព្រះភាគ (នៅមានព្រះជន្ម) មានការប្រជុំ (ព្រះសាវក) ២ លើក គឺ វេលាមុនចូលវស្សានិងថ្ងៃចូលវស្សា ដើម្បីរៀនយកកម្មដ្ឋាន ១ ដើម្បីប្រាប់គុណដែលខ្លួនបានសម្រេចដល់ភិក្ខុដែលចេញវស្សាមកហើយ ១ ដើម្បីរៀនយកកម្មដ្ឋានដែលខ្ពស់ ៗ ឡើងទៅ ១ នេះជាសាវកាចិណ្ណៈ (ការធ្លាប់ប្រព្រឹត្តមករបស់ព្រះសាវក) ។

ចំណែកក្នុងអធិការនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងដល់ពុទ្ធាចិណ្ណៈ (ការធ្លាប់ប្រព្រឹត្តមករបស់ព្រះពុទ្ធ) ទើបត្រាស់ព្រះតម្រាស់ជាដើមថា **អាចិណ្ណំ ខោ បនេតំ អានន្ទ តថាគតានំ : អសនន្ទ** ទំនៀមព្រះតថាគតទាំងឡាយ ដូច្នេះ ។

បទថា អាយាម : មក គឺ មកយើងនឹងទៅជាមួយគ្នា ។

បទថា អបលោកស្សាម : យើងនឹងទៅលា គឺ យើងនឹងលា (វេរញ្ជព្រាហ្មណ៍) ដើម្បីត្រូវការត្រាច់ទៅកាន់ទីចារិក ។

សព្ទថា ឯវំ ជានិបាត ចុះក្នុងអត្ថថា ព្រមទទួល ។

ពាក្យថា ភន្តេ នោះ ជាឈ្មោះហៅដោយសេចក្តីគោរព ។ នឹងនិយាយថា ថ្វាយពាក្យទូលតបចំពោះព្រះសាស្តា ដូច្នេះខ្លះ ក៏ប្រើបាន ។

ពីរបទថា ភគវតោ បច្ចស្សោសិ : ទទួលព្រះពុទ្ធដីកា សេចក្តីថា ព្រះអានន្ទទទួលស្តាប់ គឺ តម្រង់មុខស្តាប់ បានទូលទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគដោយល្អ ។ មានពាក្យអធិប្បាយថា ទទួលដោយពាក្យថា ឯវំ នេះ ។

ក្នុងពាក្យថា អថខោ ភគវា និវាសេត្វា បត្តចីវរមាទាយ : លំលាប់នោះ ព្រះភគវាព្រះអង្គ ទ្រង់ស្បង់ចីពរព្រមទាំងបាត្រស្រេចហើយ នេះ ព្រះឧបាលីមិនបានពោលទុកថា ជាវេលាព្រឹក ឬ ជាវេលាល្ងាច ។ សូម្បីកាលជាដូច្នោះ ព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ចសម្រេចហើយ ទ្រង់សម្រាកនៅរហូតដល់អស់វេលាថ្ងៃត្រង់ ឱ្យព្រះអានន្ទជាបច្ឆាសមណៈ ទ្រង់ញាំងថ្នល់ក្នុងព្រះនគរ ចាប់ផ្តើមតាំងពីទ្វារព្រះនគរទៅ

ឱ្យរុងរឿងទៅដោយព្រះពុទ្ធរស្មី ដែលមានបណ្ដាញដូចខ្សែមាស ស្ដេចចូលទៅតាមមកនៃលំនៅរបស់វេរញ្ជព្រាហ្មណ៍នោះតាំងនៅ ។ ចំណែកបរិជនឃើញព្រះមានព្រះភាគ ល្មមប្រថាប់ឈរនៅត្រង់ទ្វារផ្ទះរបស់វេរញ្ជព្រាហ្មណ៍ប៉ុណ្ណោះ ក៏បានប្រាប់នូវដំណឹងដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ត្រឡប់រលឹកបាន ហើយក៏កើតសេចក្ដីសង្វេគ ទើបប្រញាប់ក្រោកឡើងបង្គាប់ឱ្យចាត់ក្រាលអាសនៈដ៏គួរដល់តម្លៃច្រើន ចេញទៅទទួលព្រះមានព្រះភាគ ក្រាបទូលថា "សូមព្រះមានព្រះភាគ ស្ដេចយាងចូលមកតាមមកនេះចុះ" ។ ព្រះមានព្រះភាគ បានស្ដេចយាងចូលទៅគង់លើអាសនៈដែលគេចាត់ក្រាលទុកហើយ ។ លំដាប់នោះឯង វេរញ្ជព្រាហ្មណ៍មានសេចក្ដីប្រាថ្នានឹងចូលទៅអង្គុយជិតព្រះមានព្រះភាគ ទើបបានចូលទៅគាល់តាមមកដែលព្រះមានព្រះភាគប្រថាប់នៅ ចាកទីដែលខ្លួនឈរ ។ ពាក្យខាងមុខអំពីនេះទៅ មានសេចក្ដីភ្លឺច្បាស់ហើយទាំងអស់នោះឯង ។

## វេរញ្ជព្រាហ្មណ៍ទូលរឿងមិនបានថ្វាយទាន ៣ ខែ

ក៏ក្នុងពាក្យដែលព្រាហ្មណ៍ក្រាបទូលថា "តែថាទេយ្យធម៌ដែលខ្ញុំព្រះអង្គបម្រុងនឹងថ្វាយនោះ ខ្ញុំព្រះអង្គមិនទាន់បានថ្វាយនៅឡើយ" មានពាក្យអធិប្បាយដូចតទៅនេះ ៖

ខ្ញុំព្រះអង្គមិនទាន់បានថ្វាយទេយ្យធម៌ ដែលគួរនឹងថ្វាយជាដើម យ៉ាងនេះ គឺ រាល់ ៗ ថ្ងៃ រហូតដល់អស់ត្រៃមាស វេលាព្រឹកគួរថ្វាយយាគូ និងរបស់គួរទំពា វេលាថ្ងៃត្រង់ គួរថ្វាយខាទនិយៈភោជនិយៈ វេលាល្ងាចគួរថ្វាយបូជាសក្ការៈ ដោយវត្ថុមានទឹកបានៈដែលផ្សំដោយប្រភេទផ្សេង ៗ ជាច្រើន របស់ក្រអូបនិងផ្កាឈើជាដើម ដល់ព្រះអង្គដែលខ្ញុំព្រះអង្គនិមន្តឱ្យនៅចាំវស្សាហើយ ។ ក៏ក្នុងពាក្យថា តញ្ច ខោ នោ អសន្តំ **: ឯទេយ្យធម៌នោះ មិនមែនជាគ្មានទេ** នេះ គប្បីជ្រាបថាជាលិង្គវិបល្លាស ។ ក៏ក្នុងពាក្យនេះ មានសេចក្តីដូច្នេះថា ក៏ឯទេយ្យធម៌នោះ មិនមានដល់ខ្ញុំព្រះអង្គក៏មិនមែន ។ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា ខ្ញុំព្រះអង្គគប្បីថ្វាយរបស់ណា ៗ ដល់ព្រះអង្គ ក៏ឯរបស់នោះ មិនមែននឹងមិនមាន ។ ពាក្យថា នោ បិ អធាតុកម្យតា **: ខ្ញុំព្រះអង្គនឹងបម្រុងថា នឹងមិនថ្វាយនោះក៏ទេ** សេចក្តីថា សូម្បីការមិនចង់ថ្វាយរបស់ខ្ញុំព្រះអង្គ ដូចរបស់ពួកជនអ្នកមានសេចក្តីកំណាញ់ ដែលមានឧបករណ៍ដល់ទ្រព្យ ជាគ្រឿងសប្បាយចិត្តជាច្រើន មិនចង់ថ្វាយដូច្នោះ ក៏មិនមាន ។ ខាងក្នុងត្រៃមាសនេះ ព្រះអង្គបានទេយ្យធម៌នោះអំពីណា ព្រោះឃរាវាសមានកិច្ចច្រើន មានករណីយ៍ច្រើន ។

ក្នុងពាក្យថា តំ កុតេត្ថ លព្ភា ពហុកិច្ចា ឃរាវាសា : ព្រោះជាតិជាគ្រហស្ថអ្នកគ្រប់គ្រងផ្ទះសម្បែង រមែងមានកិច្ចរវល់ច្រើន មានការងារច្រើន ចំណែកព្រះអង្គសោត ទ្រង់បានទេយ្យធម៌នោះមកអំពីណា នោះ មានការប្រកបសេចក្ដីដូចតទៅនេះ ៖

ព្រាហ្មណ៍ កាលនឹងតិះដៀលការនៅគ្រប់គ្រងផ្ទះ ទើបបានក្រាបទូលថា ព្រោះការនៅគ្រប់គ្រងផ្ទះមានកិច្ចច្រើន ដូច្នោះ ខាងក្នុងត្រៃមាសនេះ កាលទេយ្យធម៌ និងបំណងនឹងថ្វាយសូម្បីមាន ព្រះអង្គគប្បីបានទេយ្យធម៌ ដែលខ្ញុំព្រះអង្គនឹងគប្បីថ្វាយដល់ព្រះអង្គអំពីទីណា គឺ ព្រះអង្គអាចបានទេយ្យធម៌នោះ អំពីទីណា ។ បានឮថា វេរញ្ជព្រាហ្មណ៍នោះរមែងមិនដឹងសេចក្ដីដែលខ្លួនត្រូវមារបណ្ដាលចិត្ត ទើបបានសម្គាល់ថា យើងកើតជាអ្នកមានសតិវង្វេងភ្លេច ព្រោះកង្វល់ដោយការគ្រប់គ្រងផ្ទះ ។ ព្រោះដូច្នោះ ទើបព្រាហ្មណ៍បានក្រាបទូលយ៉ាងនោះ ។

ម្យ៉ាងទៀត ក្នុងពាក្យថា តំ កុតេត្ថ លព្ភា : ចំណែកព្រះអង្គសោត ទ្រង់បានទេយ្យធម៌នោះមកអំពីណា នេះ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ខាងក្នុងត្រៃមាសនេះ ខ្ញុំព្រះករុណានឹងគប្បីថ្វាយទេយ្យធម៌យ៉ាងណាចំពោះព្រះអង្គ ទេយ្យធម៌យ៉ាងនោះ ខ្ញុំព្រះអង្គនឹងគប្បីបានអំពីណា ? ព្រោះថា ការនៅគ្រប់គ្រងផ្ទះមានកិច្ចច្រើន ។

## វេរញ្ជព្រាហ្មណ៍អារាធនាព្រះពុទ្ធដើម្បីសោយភត្តាហារ

គ្រានោះ ព្រាហ្មណ៍ត្រិះរិះថា ដូចម្តេចហ្ន៎ ? ទេយ្យធម៌យ៉ាងណា ជារបស់ដែលយើងនឹងគប្បីថ្វាយ ដោយ ៣ ខែ យើងគួរថ្វាយទេយ្យធម៌យ៉ាងនោះទាំងអស់ ដោយមួយថ្ងៃប៉ុណ្ណោះហើយ ទើបបានក្រាបទូលពាក្យជាដើមថា "សូមព្រះគោតមដ៏ចម្រើន ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ" ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ស្វាតនាយ : ក្នុងថ្ងៃស្អែកសិន សេចក្តីថា ដើម្បីប្រយោជន៍ដល់បុណ្យកុសល និងបីតិបាមោជ្ជៈដែលនឹងមានក្នុងថ្ងៃស្អែកនេះ ក្នុងកាលខ្ញុំព្រះអង្គបានធ្វើសក្ការៈក្នុងព្រះអង្គ ។

## ព្រះមានព្រះភាគទ្រង់ទទួលអារាធនារបស់ព្រាហ្មណ៍

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ព្រះរំពឹងថា បើតថាគតនឹងមិនទទួលពាក្យអារាធនាសោត ព្រាហ្មណ៍និងអ្នកស្រុកវេរញ្ជា នឹងគប្បីតិះដៀល យ៉ាងនេះថា ព្រះសមណៈអង្គនេះ មិនបានអ្វី ៗ រហូតដល់អស់ត្រៃមាស មុខជានឹងគប្បីក្រោធទេដឹង ? ព្រោះហេតុនោះ កាលយើងអង្វរ ក៏ទ្រង់មិនទទួលសូម្បីចង្ហាន់ម្តង, ក្នុងព្រះសមណៈអង្គនេះ មិនមានអធិវាសនខន្តិ ព្រះសមណៈអង្គនេះ មិនមែនសព្វញ្ញូ ក៏នឹងគប្បីប្រសព្វ

វត្ថុដែលមិនមែនបុណ្យជាច្រើន, ការប្រសព្វវត្ថុដែលមិនមែនបុណ្យនោះ កុំមានដល់ជនទាំងនោះឡើយ” ដូច្នេះហើយ ទើបទ្រង់ទទួលពាក្យអារាធនា ដើម្បីអនុគ្រោះដល់ជនទាំងនោះដោយតុណ្ហីភាព ។

ក៏គ្រានោះឯង ព្រះមានព្រះភាគ កាលទ្រង់ទទួលអារាធនាហើយ ទ្រង់បានជាស់តឿនវេរញ្ជព្រាហ្មណ៍ ឱ្យយល់ព្រមថា មិនគួរគិតដល់ការកង្វល់ ដោយការនៅគ្រប់គ្រប់គ្រងផ្ទះឡើយ ហើយទ្រង់ណែនាំពន្យល់ឱ្យវេរញ្ជព្រាហ្មណ៍ ឃើញប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ, ឱ្យជឿជាក់ក្នុងកុសលធម៌ គឺ ឱ្យទទួលយកកុសលធម៌, និងឱ្យវេរញ្ជព្រាហ្មណ៍នោះ ខ្មីខ្មាតសង្វាតធ្វើការកុសល គឺ ធ្វើឱ្យមានសេចក្តីឧស្សាហ៍ក្នុងកុសលធម៌ តាមដែលខ្លួនជឿជាក់ហើយនោះ, និងទ្រង់លួងលោមឱ្យរីករាយ ដោយភាពជាអ្នកមានឧស្សាហ៍នោះ, និងដោយគុណធម៌ដែលមាននៅយ៉ាងដទៃ ដោយធម្មីកថា ដ៏សមគួរដល់ខណៈនោះ ទ្រង់បានញ៉ាំងភ្លៀង គឺ ព្រះធម្មរតនៈឱ្យធ្លាក់ចុះហើយ ក៏ស្តេចក្រោកចាកពីអាសនៈត្រឡប់ទៅ ។

## វេរញ្ជព្រាហ្មណ៍ត្រៀមភត្តាហារថ្វាយស្អែក

កាលព្រះមានព្រះភាគត្រឡប់ទៅហើយ វេរញ្ជព្រាហ្មណ៍បានហៅបុត្រ និងភរិយាមកបង្គាប់ថា "នែអ្នកដ៏ចម្រើន ខ្ញុំបាននិមន្តព្រះមានព្រះភាគ(ឱ្យនៅចាំវស្សា) រហូតអស់ត្រៃមាសហើយ សូម្បីក្នុងមួយថ្ងៃ ក៏មិនបានថ្វាយចង្ហាន់ ត្រឹមតែមួយដុំឡើយ ណ្ហើយចុះ ឥឡូវនេះ ពួកលោកចូរត្រៀមទាន ឱ្យដូចជាទេយ្យធម៌សូម្បីដែលគួរថ្វាយរហូតដល់អស់ត្រៃមាស ជារបស់អាចថ្វាយក្នុងថ្ងៃស្អែកនេះបាន ដោយ(ថ្វាយ)តែមួយថ្ងៃប៉ុណ្ណោះ" ។

តពីនោះ វេរញ្ជព្រាហ្មណ៍ បង្គាប់ឱ្យត្រៀមទានដ៏ប្រណីតរហូតដល់អស់មួយថ្ងៃ ដែលខ្លួននិមន្តព្រះមានព្រះភាគទុក ដោយកន្លងទៅនៃរាត្រីនោះ ក៏បានបង្គាប់ឱ្យប្រដាប់ទីតាំងអាសនៈ ឱ្យក្រាលអាសនៈទាំងឡាយ ដែលគួរដល់តម្លៃច្រើនទុក ចាត់ចែងការបូជាយ៉ាងធំដ៏វិចិត្រដោយរបស់ក្រអូប ធូប គ្រឿងអប់ និងផ្កាកុសុមៈរួចស្រេចហើយ ទើបបង្គាប់ឱ្យអ្នកបម្រើទៅក្រាបទូលនូវកាលចំពោះព្រះមានព្រះភាគ ។ ព្រោះហេតុនោះ ទើបព្រះឧបាលីថេរៈបានពោលថា "អថខោ វេរញ្ជោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន ។បេ ។ និដ្ឋិតំ ភត្តំ : ដល់វេលាព្រឹកឡើង វេរញ្ជព្រាហ្មណ៍ បង្គាប់ជនទាំងឡាយ ឱ្យចាត់ចែងធ្វើខាទនីយភោជនីយាហារ(បង្អែមនិងចំអាប)ដ៏ឆ្ងាញ់ពិសារ ក្នុងលំនៅរបស់ខ្លួនស្រេចហើយ" ។

## ទ្រង់យាងទៅកាន់លំនៅរបស់វេរញ្ជព្រាហ្មណ៍

ព្រះមានព្រះភាគ មានភិក្ខុសង្ឃហែហមហើយ បានស្ដេចយាងទៅកាន់លំនៅរបស់ព្រាហ្មណ៍នោះ, ព្រោះហេតុនោះ ទើបព្រះឧបាលីថេរៈពោលថា “អថខោ ភគវា ។បេ។ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន : លំដាប់នោះ ព្រះមានព្រះភាគព្រះអង្គទ្រង់ស្បង់ និងចីវរព្រមទាំងបាត្រ ហើយយាងចូលទៅកាន់លំនៅរបស់វេរញ្ជព្រាហ្មណ៍ ជាមួយនឹងព្រះភិក្ខុសង្ឃក្នុងវេលាព្រឹកនោះ លុះដល់ហើយទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ” ។

បទថា ពុទ្ធប្បមុខំ : មានព្រះពុទ្ធជាប្រធាន ក្នុងពាក្យថា អថខោ វេរញ្ជោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ : វេលានោះ វេរញ្ជព្រាហ្មណ៍ ... ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន, នេះមានពាក្យអធិប្បាយថា អ្នកអង្គុយឱ្យព្រះពុទ្ធជាព្រះសង្ឃត្ថេរ ។

បទថា បណីតេន ដ៏ឆ្ងាញ់ពិសារ គឺ ឧត្តម : ដ៏ល្អប្រសើរ ។

បទថា សហត្ថា : ដៃខ្លួន គឺ ដោយដៃខ្លួនឯង ។

បទថា សន្តប្បេត្វា : ឱ្យឆ្អែតស្កប់ស្កល់ សេចក្ដីថា ឱ្យឆ្អែតគ្រប់គ្រាន់ដោយល្អ គឺ ឱ្យបរិបូណ៌, បានដល់ ទំនុកបម្រុងដោយល្អ

ដរាបទាល់តែល្មមដល់សេចក្តីត្រូវការ ។

បទថា សម្បវារេត្វា : គ្រាតែលោកប្រកែកលែងទទួលទៀត សេចក្តីថា ឱ្យទ្រង់ហាមហើយដោយល្អ គឺ ឱ្យទ្រង់ឃាត់ដោយហត្ថសញ្ញា មុខសញ្ញា និងវចីភេទថា "ល្មមហើយ ៗ" ។

បទថា ភុត្តាវី : ទ្រង់សោយស្រេច គឺ អ្នកសោយរួចស្រេចហើយ ។

បទថា ឱនីតបត្តបាណឹ : លែងលូកព្រះហស្តទៅក្នុងបាត្រហើយ មានសេចក្តីថា ទ្រង់នាំព្រះហស្តចេញពីបាត្រ, មានពាក្យអធិប្បាយថា ទ្រង់នាំព្រះហស្តចេញហើយ (ទ្រង់លាងព្រះហស្តហើយ) ។

## ព្រាហ្មណ៍ថ្វាយត្រៃចីវរ

ពីរបទថា តិចីវរេន អច្ឆាទេសិ : ក៏ថ្វាយចីវរ ១ ត្រៃ សេចក្តីថា (ព្រាហ្មណ៍) បានថ្វាយត្រៃចីវរចំពោះព្រះមានព្រះភាគ ។ ក៏ពាក្យថា តិចីវរេន អច្ឆាទេសិ នេះ ត្រឹមតែជាវោហារវចនៈ ក៏ក្នុងត្រៃចីវរនោះ សំពត់សាដកមួយផ្ទាំង ៗ មានតម្លៃមួយពាន់ ។ ព្រាហ្មណ៍បានថ្វាយត្រៃចីវរដ៏ល្អក្រៃលែង ដូចគ្នានឹងសំពត់ដែនកាសី មានតម្លៃដល់បីពាន់

ចំពោះព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ច្រើនបទថា ឯកមេកញ្ច ភិក្ខុំ ឯកមេកេន ទុស្សយុគេន : ហើយប្រគេនសំពត់ព្រះភិក្ខុសង្ឃ ១ គូ ៗ រាល់អង្គ សេចក្ដីថា ព្រាហ្មណ៍បានឱ្យភិក្ខុមួយរូប ៗ គ្រងដោយសំពត់មួយគូ ៗ ។ បណ្ដាសំពត់ទាំងនោះសំពត់សាដកមួយផ្ទាំង ៗ មានតម្លៃប្រាំរយ ។ ព្រាហ្មណ៍បានថ្វាយសំពត់មានតម្លៃប្រាំសែន ដល់ភិក្ខុ ៥០០ រូប ដោយប្រការដូច្នេះ ។ ព្រាហ្មណ៍ថ្វាយហើយដល់ប៉ុណ្ណេះ មិនទាន់ល្មមដល់ចិត្ត បានបែងចែកសំពត់កម្ពលក្រហម និងសំពត់បត្តុណ្ណៈ និងសំពត់ដណ្ដប់ជាច្រើនមានតម្លៃ ៧-៨ ពាន់ ថ្វាយដើម្បីប្រយោជន៍ដល់បរិក្ខារ មានសំពត់រឹតជង្គង់ សំពត់ឆៀង វត្ថពន្ធចង្កេះ និងសំពត់ត្រងទឹកជាដើមទៀត និងបានវាល់ប្រេង ថ្នាំដែលស្លរាប់រយពាន់ដង ឱ្យពេញនាឡិថ្វាយប្រេងមានតម្លៃមួយពាន់ ដើម្បីប្រយោជន៍ដល់ការលាប ដល់ភិក្ខុមួយរូប ៗ ។ នឹងមានប្រយោជន៍អ្វី ដោយការពោលច្រើនក្នុងបច្ច័យបួន ។ បរិក្ខារអ្វី ៗ ដែលជាគ្រឿងប្រើរបស់សមណៈ ឈ្មោះថា ព្រាហ្មណ៍មិនបានថ្វាយហើយមិនមាន តែក្នុងព្រះបាលីពោលតែត្រឹមតែចីវរប៉ុណ្ណោះ ។

គ្រានោះឯង ព្រះមានព្រះភាគ នឹងទ្រង់ញុំាងភ្លៀងគឺ អមតធម៌ឱ្យ

ធ្លាក់ធ្វើវេរញ្ជព្រាហ្មណ៍អ្នកសាបសូន្យពីការបរិភោគរសនៃអមតៈ គឺ ការស្តាប់ធម៌ដោយត្រូវមារបណ្តាលចិត្តឱ្យឡប់ឡិនភ្លេចភ្លាំងអស់បីខែ អ្នកធ្វើការបូជាធំយ៉ាងនោះហើយ ព្រមដោយបុត្រនិងភរិយាថ្វាយបង្គំហើយអង្គុយឱ្យជាអ្នកមានសេចក្តីត្រិះរិះពេញបរិបូរណ៍ ដោយរយៈកាលតែមួយថ្ងៃប៉ុណ្ណោះ លំដាប់នោះ ព្រះភគវាទ្រង់ត្រាស់សម្តែងណែនាំពន្យល់ ឱ្យវេរញ្ជព្រាហ្មណ៍យល់ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោកឱ្យជឿជាក់ក្នុងកុសល ឱ្យរីករាយខ្ជាប់ខ្ជួនសង្វាតធ្វើការកុសល រួចព្រះអង្គក្រោកចាកអាសនៈហើយយាងត្រឡប់មកវិញ ។

ចំណែកព្រាហ្មណ៍ ព្រមទាំងបុត្រនិងភរិយា ថ្វាយបង្គំព្រះមានព្រះភាគ និងភិក្ខុសង្ឃ ហើយតាមជូនដំណើរស្តេចទៅបណ្តើរ ពោលពាក្យជាដើមយ៉ាងនេះ បណ្តើរថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គធ្វើសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ ទាំងឡាយសូម្បី ( ក្រោយ ) ទៀត" ហើយ ( ក៏យំ ) បង្ហូរទឹកភ្នែក ត្រឡប់មកវិញ ។

## ព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងវេសាលី

ច្រើនបទថា អថខោ ភគវា វេរញ្ជាយំ យថាភិរន្តំ វិហរិត្វា : លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងធម៌ណែនាំពន្យល់ ឱ្យវេរញ្ជព្រាហ្មណ៍ យល់ប្រយោជន៍ មានសេចក្តីថា ព្រះមានព្រះភាគស្តេចនៅតាមព្រះអធ្យាស្រ័យ គឺ តាមសេចក្តីពេញព្រះទ័យហើយ ចេញចាកស្រុកវេរញ្ជា មានព្រះបំណងនឹងទ្រង់លះពុទ្ធវិថី ដែលនឹងគប្បីស្តេចយាងទៅ ក្នុងកាលជាទីស្តេចត្រាច់ចារិកក្នុងមណ្ឌលធំ នឹងទ្រង់នាំភិក្ខុសង្ឃដែលលំបាកដោយទុព្ភិក្ខទោស ស្តេចយាងទៅដោយមកត្រង់ ទើបទ្រង់មិនឆៀងចូលស្រុកទាំងឡាយ មានស្រុកសោរេយ្យៈជាដើម ស្តេចយាងទៅកាន់ស្រុកបយាគបតិដ្ឋាន ឆ្លងទន្លេគង្គានាស្រុកនោះហើយ ស្តេចយាងទៅដោយទិសាភាគខាងក្រុងពារាណសី ។ ព្រះមានព្រះភាគបានស្តេចយាងទៅដោយទិសាភាគនោះ ព្រោះដូច្នោះ ទើបឈ្មោះថា តនវសរិ : ហើយយាងទៅ ។ ព្រះអង្គប្រថាប់នៅតាមព្រះអធ្យាស្រ័យ សូម្បីក្នុងក្រុងពារាណសីនោះហើយ បានស្តេចយាងទៅកាន់ក្រុងវេសាលី ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា "ទ្រង់ក៏យាងចេញទៅកាន់នគរសោរេយ្យៈ រួចទៅនគរសង្កស្ស ហើយហួសទៅនគរក

ណ្ណកុជ្ជៈ (តពីនោះទៅ) ទ្រង់យាងសំដៅទៅស្រុកបយាគបតិដ្ឋាន លុះទៅដល់ហើយទ្រង់ឆ្លងគង្គានទីក្នុងស្រុកបយាគបតិដ្ឋាន ហើយយាងទៅដល់នគរពារាណសី ។ គ្រានោះ ព្រះអង្គគង់កំសាន្ត(សម្រាក) ក្នុងក្រុងពារាណសី ហើយទ្រង់ជៀសទៅកាន់ចារិកនៃក្រុងវេសាលី កាលទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះដ៏មានជោគព្រះអង្គទៅគង់សម្រាន្តឥរិយាបថ ក្នុងកូដាគារសាលានៅទាមហាវ័ន (ព្រៃធំ) ជិតក្រុងវេសាលីនោះ ។

**ចប់ វេរញ្ជកណ្ឌវណ្ណនា ៕**

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## ពាហិរនិទាន វេរញ្ជកណ្ឌ

## ភាគ ១

## ចប់ ដោយបរិបូណ៌

